# សេចក្តីផ្តើម
# នីតិរដ្ឋប្បវេណី

និពន្ធដោយ សាស្ត្រាចារ្យ ណូមូរ៉ា តូយ៉ូហ៊ីរ៉ូ

បោះពុម្ពលើកទី ៥ ភ្នំពេញ ២០១១

# សេចក្តីផ្តើម
# នីតិរដ្ឋប្បវេណី

និពន្ធដោយ
សាស្ត្រាចារ្យ ណូមូរ៉ា តូយ៉ូហ៊ីរ៉ូ

បោះពុម្ពលើកទី ៥
ភ្នំពេញ ២០១១

បោះពុម្ពនៅរាជធានីភ្នំពេញ
ដោយគម្រោងអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌
របស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)
ប្រចាំក្រសួងយុត្តិធម៌ ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១១

សិទ្ធិអ្នកនិពន្ធ © សាស្ត្រាចារ្យ **ណូម៉ូរ៉ា តូយ៉ូហ៊ីរ៉ូ** ឆ្នាំ ២០០១
ISBN: 9789996326035

**អ្នកបកប្រែ:**

លោក **សរ សិនិរ៉ា** អតីតជំនួយការជាន់ខ្ពស់ នៃគម្រោងអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌

លោក **ស៊ឹម ថេរៈ** អតីតជំនួយការ នៃគម្រោងអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌

**អ្នកត្រួតពិនិត្យ និង កែសម្រួល:**

លោក **កែវ ម៉ាន្នី** មន្ត្រីច្បាប់ នៃគម្រោងអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌

លោក Harada Masayoshi ទីប្រឹក្សាច្បាប់ នៃគម្រោងអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌

**<u>កំណត់សំគាល់:</u>**

ការពន្យល់នៅក្នុងសៀវភៅស្តីពី "សេចក្តីផ្តើមនីតិរដ្ឋប្បវេណី"នេះ គឺយោងទៅលើមាត្រាក្រមរដ្ឋប្បវេណីជប៉ុនប៉ុណ្ណោះ មិនមែនយោងទៅលើមាត្រាក្រមរដ្ឋប្បវេណីកម្ពុជាទេ។ អាស្រ័យហេតុនេះ សូមកុំភាន់ច្រឡំចំពោះមាត្រាយោងនៅក្នុងសៀវភៅនេះ។

# អារម្ភកថាចំពោះ "សេចក្តីផ្តើមនីតិរដ្ឋប្បវេណី" ជាភាសាខ្មែរ

សៀវភៅនេះគឺជាការពន្យល់ដែលធ្វើឲ្យងាយយល់អំពីនីតិរដ្ឋប្បវេណីក្នុងច្បាប់ជប៉ុន។ សៀវភៅនេះមានបំណងជួយឲ្យនិស្សិតដែលទើបចាប់ផ្តើមសិក្សាផ្នែកច្បាប់ក្នុងមហាវិទ្យាល័យច្បាប់ ស្វែងយល់ជាទូទៅអំពីនីតិរដ្ឋប្បវេណីទាំងមូល មុននឹងធ្វើការស្វែងយល់ស៊ីជម្រៅអំពីច្បាប់នានានៃនីតិរដ្ឋប្បវេណី ដូចជាច្បាប់រដ្ឋប្បវេណី ច្បាប់ពាណិជ្ជកម្ម ច្បាប់នីតិវិធីរដ្ឋប្បវេណី ជាដើម។ ការបោះពុម្ពផ្សាយលើកទី ១ ធ្វើឡើងនៅឆ្នាំ ១៩៩៨ ហើយក្រោយមក មានការកែសម្រួលជាច្រើនលើក ដើម្បីសម្របទៅតាមការប្រែប្រួលនៃសង្គម និងការវិវដ្តនៃទ្រឹស្តីសិក្សា និង យុត្តិសាស្ត្រ (ការបោះពុម្ពផ្សាយលើកទី ៥ ធ្វើឡើងនៅឆ្នាំ ២០០៩)។ សៀវភៅនេះបានទទួលការគាំទ្រពីស្រទាប់អ្នកអានយ៉ាងទូលំទូលាយ ហួសពីការប៉ាន់ស្មានដំបូងដែលសំដៅតែទៅលើអ្នកអានដែលជាអ្នកសិក្សាថ្មីថ្មោងនៅមហាវិទ្យាល័យច្បាប់ប៉ុណ្ណោះ។ ខ្ញុំបានឮថា មានការយកសៀវភៅនេះទៅប្រើប្រាស់ធ្វើជាសៀវភៅសិក្សាមូលដ្ឋានផ្នែកច្បាប់សម្រាប់និស្សិតក្រៅពីមហាវិទ្យាល័យច្បាប់ផងដែរ។ ហើយខ្ញុំក៏ឮថា និស្សិតនៅមហាវិទ្យាល័យច្បាប់ដែលបានសិក្សាច្បាប់ដល់កម្រិតមួយហើយក៏ដោយ ពួកគេក៏នៅប្រើសៀវភៅនេះ ដើម្បីរំលឹកឡើងវិញនូវអ្វីដែលគេបានសិក្សា ក៏ដូចជាដើម្បីយល់អំពីប្រព័ន្ធនៃនីតិរដ្ឋប្បវេណី ។

ពិតណាស់ថា សៀវភៅនេះគឺជាការពន្យល់អំពីនីតិរដ្ឋប្បវេណីជប៉ុន ហើយពុំមែនជាការពន្យល់អំពីនីតិរដ្ឋប្បវេណីរបស់កម្ពុជានោះទេ។ ប៉ុន្តែ ទោះបីជាសេចក្តីលំអិតមានភាពខុសគ្នាបន្តិចបន្តួចក្នុងប្រព័ន្ធច្បាប់យ៉ាងណាក្តី ចំពោះគោលគំនិតជាមូលដ្ឋានអំពីនីតិរដ្ឋប្បវេណី និង បែបបទនៃគិតពិចារណា និង ទ្រឹស្តីច្បាប់ នៅតែមានប្រយោជន៍សម្រាប់អ្នកសិក្សានីតិរដ្ឋប្បវេណីនៅប្រទេសកម្ពុជាដែរ។ ព្រោះថា ទោះបីជានីតិរដ្ឋប្បវេណីជប៉ុន និង នីតិរដ្ឋប្បវេណីកម្ពុជា មានភាពខុសគ្នាតាមបញ្ញត្តិនៃមាត្រានីមួយៗក្តី ខ្ញុំគិតថាការរៀបចំបញ្ញត្តិច្បាប់របស់ប្រទេសទាំងពីរគឺមានលក្ខណៈស្រដៀងគ្នាច្រើន។ បើនិយាយពីច្បាប់ជប៉ុន គឺកើតឡើងពីការវិវដ្តនៃក្រមមូលដ្ឋានដែលត្រូវបានបញ្ញត្តឡើងនៅពាក់កណ្តាលចុងក្រោយនៃសតវត្សទី ១៩ ដោយយកគំរូតាមច្បាប់របស់បារាំង និង អាល្លឺម៉ង់ ជាដើម ដែលជាប្រព័ន្ធច្បាប់ទ្វីបរបស់អឺរ៉ុប។ ហើយបើនិយាយពីច្បាប់របស់កម្ពុជាវិញ ច្បាប់រដ្ឋប្បវេណី និង ច្បាប់នីតិវិធីរដ្ឋប្បវេណី ត្រូវបានបញ្ញត្តឡើងដោយមានកិច្ចសហការពីអ្នកច្បាប់ ក៏ដូចជាអ្នកប្រកបវិជ្ជាជីវៈច្បាប់របស់ជប៉ុន ហើយតាមរយៈច្បាប់ជប៉ុន ច្បាប់កម្ពុជាគឺបានទទួលឥទ្ធិពលយ៉ាងខ្លាំងពីប្រព័ន្ធច្បាប់ទ្វីបរបស់អឺរ៉ុបដូចជា ច្បាប់បារាំង និង ច្បាប់អាល្លឺម៉ង់ ជាដើម។ ម្យ៉ាងទៀត ក្នុងដំណើរការរៀបចំសេចក្តីព្រាងច្បាប់រដ្ឋប្បវេណីកម្ពុជា ក៏មានការយកច្បាប់រដ្ឋប្បវេណីចាស់របស់កម្ពុជាមកយោងផងដែរ ហើយយើងមិនអាចមើលរំលងអំពីការដែលក្រមរដ្ឋប្បវេណីកម្ពុជាចាស់ទទួលឥទ្ធិពលពីច្បាប់រដ្ឋប្បវេណីបារាំងបានដែរ ។

ក្នុងសៀវភៅនេះ ខ្ញុំព្យាយាមពន្យល់យ៉ាងងាយៗអំពីគោលគំនិតច្បាប់ តាមរយៈការប្រើប្រាស់ប្រយោគសាមញ្ញៗ។ ខ្ញុំសង្ឃឹមថា ទោះបីជាត្រូវបានប្រែសម្រួលជាភាសាខ្មែរក្តី លក្ខណៈពិសេសត្រង់

ចំណុចនេះ នឹងនៅរក្សាបានដដែល ។

ក្នុងនាមជាអ្នកដែលបានចូលរួមពាក់ព័ន្ធជាយូរមកហើយក្នុងការជួយជ្រោមជ្រែងរបស់ជប៉ុន ដល់ការអភិវឌ្ឍប្រព័ន្ធច្បាប់របស់កម្ពុជា ដូចជា ច្បាប់រដ្ឋប្បវេណី និង ច្បាប់នីតិវិធីរដ្ឋប្បវេណី ខ្ញុំសង្ឃឹមថា ប្រព័ន្ធច្បាប់នេះនឹងចាក់ឫសក្នុងប្រទេសកម្ពុជា ហើយនឹងអាចជួយកសាងសង្គមដ៏ប្រសើរមួយ។ ក្នុងស្មារតីនេះ ដើម្បីទ្រទ្រង់ប្រព័ន្ធច្បាប់ថ្មីៗ ចាំបាច់ត្រូវបណ្តុះបណ្តាលអ្នកប្រកបវិជ្ជាជីវៈច្បាប់ឲ្យបានទាំងបរិមាណ និង គុណភាព។ ខ្ញុំសង្ឃឹមថា សៀវភៅនេះនឹងអាចចូលរួមចំណែកក្នុងការបណ្តុះបណ្តាលដល់អ្នកប្រកបវិជ្ជាជីវៈច្បាប់ប្រកបដោយសមត្ថភាពខ្ពស់ទាំងនោះ។

ខែកុម្ភៈ ឆ្នាំ ២០១១

ណូមូរ៉ា តូយ៉ូហ៊ីរ៉ូ

# មាតិកា

**ជំពូកទី ១ នីតិរដ្ឋប្បវេណី**.......................................................................................១

**១ អត្ថន័យនៃនីតិរដ្ឋប្បវេណី**.......................................................................................២

នីតិសាធារណៈ និង នីតិឯកជន (២) អត្ថន័យនៃនីតិរដ្ឋប្បវេណី (៣)

**២ រចនាសម្ព័ន្ធនៃនីតិរដ្ឋប្បវេណី**.......................................................................................៣

ច្បាប់សារធាតុ (៣) ច្បាប់នីតិវិធី (៤)

**៣ ប្រភពនៃនីតិ**.......................................................................................៤

នីតិសរសេរ (៥) នីតិឥតសរសេរ (៥) ទ្រឹស្តី និង លទ្ធិ (៦)

✎ ការសម្រេចឲ្យបាននូវការអនុវត្តច្បាប់ (សិទ្ធិ )--ការពិចារណាតាមរយៈករណីសិក្សា.........................៧

**ជំពូកទី ២ ច្បាប់រដ្ឋប្បវេណី និង ក្រមរដ្ឋប្បវេណី**.......................................................................................៨

**១ អត្ថន័យនៃច្បាប់រដ្ឋប្បវេណី**.......................................................................................៩

និយមន័យនៃច្បាប់រដ្ឋប្បវេណី (៩) ច្បាប់ទូទៅ និង ច្បាប់ពិសេស (៩) ច្បាប់រដ្ឋប្បវេណីក្នុងឋានៈជាច្បាប់ទូទៅ (១០) ភាពមិនដាច់ខាតនៃចំណាត់ថ្នាក់រវាងច្បាប់ទូទៅ និង ច្បាប់ពិសេស (១១)

**២ រចនាសម្ព័ន្ធនៃច្បាប់រដ្ឋប្បវេណី**.......................................................................................១២

អត្ថន័យជាទម្រង់ និង អត្ថន័យគ្រឹះនៃច្បាប់រដ្ឋប្បវេណី (១២) រចនាសម្ព័ន្ធនៃក្រមរដ្ឋប្បវេណី (១២)

**៣ ប្រវត្តិនៃច្បាប់រដ្ឋប្បវេណី**.......................................................................................១២

មូលហេតុនៃការចងក្រងជាក្រមនៃច្បាប់រដ្ឋប្បវេណី (១៣) ការចងក្រងជាក្រមនៃច្បាប់រដ្ឋប្បវេណីចាស់ (១៣) ភាពចម្រូងចម្រាស់ក្នុងក្រម (១៤) ការចងក្រងក្រមរដ្ឋប្បវេណីបច្ចុប្បន្ន (១៤) ការកែប្រែនៅក្រោយពេលចងក្រងជាក្រម (១៥)

**៤ គោលការណ៍ជាមូលដ្ឋាននៃច្បាប់រដ្ឋប្បវេណី**.......................................................................................១៧

គោលការណ៍ជាមូលដ្ឋាននៃច្បាប់ស្តីពីទ្រព្យសម្បត្តិ (១៧) គោលការណ៍ជាមូលដ្ឋាននៃច្បាប់ស្តីពីគ្រួសារ (១៩)

✎ ច្បាប់រដ្ឋប្បវេណីក្នុងឋានៈជាច្បាប់ទូទៅ និង ច្បាប់ពាណិជ្ជកម្មក្នុងឋានៈជាច្បាប់ពិសេស----------ការពិចារណាតាមរយៈករណីសិក្សា.......................................................................................២០

**ជំពូកទី ៣ សិទ្ធិ និង ភាតព្វកិច្ច**.......................................................................................**២១**

**១ សិទ្ធិ និង ភាតព្វកិច្ច**..............,,,.......................................................................**២២**

អត្ថន័យនៃសិទ្ធិ និង ភាតព្វកិច្ច (២២)

**២ សិទ្ធិប្រត្យក្ស និង សិទ្ធិលើបំណុល**.......................................................................**២៣**

សិទ្ធិឯកជន និង សិទ្ធិសាធារណៈ (២៣) សិទ្ធិប្រត្យក្ស និង សិទ្ធិលើបំណុល (២៣) ភាពដាច់ខាត និង ភាពមិនដាច់ខាត (២៤) ភាពផ្តាច់មុខ (២៤) គោលការណ៍នៃការកំណត់សិទ្ធិប្រត្យក្សដោយច្បាប់ (២៥)

**៣ ការប្រើប្រាស់សិទ្ធិដោយបំពាន**.......................................................................**២៥**

ភាពលក្ខណៈជាសង្គមនៃសិទ្ធិ (២៦) ការប្រើប្រាស់សិទ្ធិដោយបំពាន (២៦)

✎ ល័ក្ខខ័ណ្ឌនៃការប្រើប្រាស់សិទ្ធិដោយបំពាន-- ការពិចារណាតាមរយៈករណីសិក្សា.........................២៧

**ជំពូកទី ៤ សកម្មភាពគតិយុត្ត**.......................................................................................**២៨**

**១ កិច្ចសន្យា និង សកម្មភាពគតិយុត្ត**.......................................................................**២៩**

(១) ការបង្ហាញឆន្ទៈ កិច្ចសន្យា និង សកម្មភាពគតិយុត្ត.........................................................២៩

ការបង្ហាញឆន្ទៈ (២៩) កិច្ចសន្យា និង សកម្មភាពគតិយុត្ត (២៩)

(២) សណ្តាប់ធ្នាប់សាធារណៈ ទំនៀមទម្លាប់ល្អ និង សមភាព.................................................៣០

អត្ថន័យនៃសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ (៣០) ឧទាហរណ៍ជាក់ស្តែងអំពីភាពផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ (៣១) សមភាពនៃល័ក្ខខ័ណ្ឌដែលមានចែងនៅក្នុងកិច្ចសន្យា (៣១)

(៣) ការបង្ហាញឆន្ទៈដែលមានវិការៈ.......................................................................៣២

ឋបនីយផ្លូវចិត្ត (៣២) ការបង្ហាញឆន្ទៈមិនពិត (៣២) ការភាន់ច្រឡំ (៣៣) ការឆបោក ឬ ការគម្រាមកំហែង (៣៤) អំពើអូសទាញដោយមិនសមហេតុផលដើម្បីកេងយកចំណេញហួសហេតុ (៣៥)

(៤) មោឃភាព និង ការលុបចោល......................................................................................................៣៥

ភាពខុសគ្នារវាងមោឃភាព និង ការលុបចោល (៣៥)

**២ សមត្ថភាពទទួលសិទ្ធិ សមត្ថភាពខាងឆន្ទៈ និង សមត្ថភាពក្នុងការធ្វើសកម្មភាពគតិយុត្ត..............៣៦**

(១) សមត្ថភាពទទួលសិទ្ធិ......................................................................................................៣៦

អត្ថន័យនៃសមត្ថភាពទទួលសិទ្ធិ (៣៦) សមត្ថភាពទទួលសិទ្ធិរបស់នីតិបុគ្គល (៣៧)

(២) សមត្ថភាពខាងឆន្ទៈ និង សមត្ថភាពក្នុងការធ្វើសកម្មភាពគតិយុត្ត..........................................៣៧

សមត្ថភាពខាងឆន្ទៈ (៣៧) សមត្ថភាពក្នុងការធ្វើសកម្មភាពគតិយុត្ត និង ការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពគតិយុត្ត (៣៧) ជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព (៣៨) អនីតិជន (៣៩) នីតិជននៅក្រោមអាណាព្យាបាល (៤០) ជននៅក្រោមហិតូបត្ថម្ភ (៤០) ជននៅក្រោមជំនួយ (៤១) កិច្ចការជំនួញរបស់ជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព (៤១)

✐ សកម្មភាពគតិយុត្តរបស់អនីតិជន--ការពិចារណាតាមរយៈករណីសិក្សា......................................៤២

**ជំពូកទី ៥ ការតំណាង ......................................................................................................៤៥**

**១ អត្ថន័យនៃរបបតំណាង......................................................................................................៤៦**

ម្ចាស់សិទ្ធិ និង អ្នកតំណាង (៤៦) ការតំណាងដែលច្បាប់បានកំណត់ (៤៦) ការតំណាងដោយអាណត្តិ (៤៧) ចំណុចដែលជាបញ្ហានៃរបបតំណាង (៤៨)

**២ ការតំណាងដោយគ្មានសិទ្ធិ......................................................................................................៤៨**

ការតំណាងដោយគ្មានសិទ្ធិ (៤៨) ការផ្តល់សច្ចានុមតិ (៤៩) ការលុបចោល (៥០) ការទទួលខុសត្រូវរបស់អ្នកតំណាងដោយគ្មានសិទ្ធិ (៥០)

**៣ ការតំណាងដែលមានលក្ខណៈជារូបភាព......................................................................................៥០**

អត្ថន័យនៃការតំណាងដែលមានលក្ខណៈជារូបភាព(៥០) ប្រភេទទាំងបីនៃការតំណាងដែលមានលក្ខណៈជារូបភាព (៥១) ទំនាក់ទំនងរវាងការតំណាងដែលមានលក្ខណៈជារូបភាព និង ការតំណាងដោយគ្មានសិទ្ធិ (៥២)

✎ ការតំណាងដែលមានលក្ខណៈជារូបភាពដែលហួសពីទំហំនៃសិទ្ធិតំណាង----ការពិចារណាតាមរយៈករណីសិក្សា..........៥៣

**ជំពូកទី ៦ អាជ្ញាយុកាល**..........**៥៥**

**១ របបអាជ្ញាយុកាល**..........**៥៦**

(១) អត្ថន័យនៃរបបអាជ្ញាយុកាល (មូលហេតុនៃអត្ថិភាព)..........៥៦

ភាពបន្តឥតដាច់នៃស្ថានភាពអង្គហេតុ (៥៦) ភាពលំបាកក្នុងការបញ្ជាក់ (៥៧) ការធ្វេសប្រហែសរបស់អ្នកមានសិទ្ធិ (៥៨)

(២) ការលើកឡើងនូវអាជ្ញាយុកាល និង អានុភាពនៃអាជ្ញាយុកាល..........៥៨

អានុភាពនៃអាជ្ញាយុកាល (៥៨) ការពន្យល់តាមន័យច្បាប់សារធាតុ និង តាមន័យច្បាប់នីតិវិធី (៥៩) វិសាលភាពនៃអ្នកដែលមានសិទ្ធិលើកឡើងនូវអាជ្ញាយុកាល (៦០) ការបោះបង់ចោលនូវផលប្រយោជន៍នៃអាជ្ញាយុកាល (៦០)

(៣) ការផ្អាកអាជ្ញាយុកាល និង ការបង្អង់អាជ្ញាយុកាល..........៦១

ការផ្អាកអាជ្ញាយុកាល (៦១) មូលហេតុនៃការផ្អាក (៦១) មូលហេតុនៃការបង្អង់ (៦៣)

**២ អាជ្ញាយុកាលនៃលទ្ធកម្ម**..........**៦៣**

លក្ខខណ្ឌនៃអាជ្ញាយុកាលនៃលទ្ធកម្ម (៦៣) ការបញ្ជាក់ពីអាជ្ញាយុកាលនៃលទ្ធកម្ម (៦៤)

**៣ លក្ខខណ្ឌនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិ**..........**៦៤**

លក្ខខណ្ឌនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិ (៦៤) អាជ្ញាយុកាលនៃការរំលត់សិទ្ធិរយៈពេលខ្លី (៦៥)

✎ ការលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិ--ការពិចារណាតាមរយៈករណីសិក្សា..........៦៦

**ជំពូកទី ៧ កិច្ចសន្យា**..........**៦៩**

**១ ការបង្កើតកិច្ចសន្យា**..........**៦៩**

សំណើ និង ស្វីការ (៦៩) ពេលនៃការបង្កើតកិច្ចសន្យា (៧០) ប្រតិបត្តិការដោយការប្រើប្រាស់កុំព្យូទ័រ (៧១)

**២ អានុភាពនៃកិច្ចសន្យា** .................... **៧២**

ការកើតឡើងនូវសិទ្ធិ និង កាតព្វកិច្ច (៧២) កិច្ចសន្យាដែលចាំបាច់ត្រូវប្រគល់វត្ថុ (៧៣)

**៣ ទំនាក់ទំនងរវាងកាតព្វកិច្ចពីរនៅក្នុងកិច្ចសន្យាអញ្ញមញ្ញ** .................... **៧៣**

សិទ្ធិតវ៉ាឲ្យអនុវត្តព្រមគ្នា (៧៤) ការទទួលបន្ទុកហានិភ័យ (៧៥)

**៤ ការអនុវត្តកិច្ចសន្យា (ការអនុវត្តកាតព្វកិច្ច)** .................... **៧៦**

ការអនុវត្តដោយស្ម័គ្រចិត្ត (៧៦) ការអនុវត្តដោយផ្ទាល់ (៧៦) ការអនុវត្តជំនួស (៧៧) ការអនុវត្តដោយប្រយោល (៧៧) ករណីដែលមិនអាចសម្រេចបានតាមរយៈការអនុវត្តដោយបង្ខំ (៧៩)

**៥ ការមិនអនុវត្តកិច្ចសន្យា (ការមិនអនុវត្តកាតព្វកិច្ច)** .................... **៧៩**

អលទ្ធភាពក្នុងការអនុវត្ត (៧៩) ការយឺតយ៉ាវក្នុងការអនុវត្ត (៨០) ការអនុវត្តមិនពេញលេញ (៨០) មូលហេតុនៃការដាក់ការទទួលខុសត្រូវ និង ភាពផ្ទុយនឹងច្បាប់ (៨១) សំណងការខូចខាត (៨២) ការរំលាយកិច្ចសន្យា (៨៣) ការមិនអនុវត្តកាតព្វកិច្ចដោយគ្មានមូលហេតុនៃការទទួលខុសត្រូវ (៨៤)

✎ ការបង្កើតកិច្ចសន្យារវាងភាគីដែលនៅឆ្ងាយពីគ្នា-- ការពិចារណាតាមរយៈករណីសិក្សា.................... ៨៦

**ជំពូកទី ៨ កម្មសិទ្ធិ** .................... **៨៩**

**១ ប្រភេទនៃសិទ្ធិប្រត្យក្ស** .................... **៨៩**

កម្មសិទ្ធិ និង សិទ្ធិប្រត្យក្សផ្សេងទៀត (៨៩) ការកាន់កាប់ (៩០) សិទ្ធិប្រត្យក្សប្រើប្រាស់ និង អាស្រ័យផល និង សិទ្ធិប្រាតិភោគប្រត្យក្ស (៩១)

**២ កម្មសិទ្ធិ: ចលនវត្ថុ និង អចលនវត្ថុ** .................... **៩២**

វត្ថុ (៩២) ចលនវត្ថុ និង អចលនវត្ថុ (៩៣)

**៣ លទ្ធកម្មនៃកម្មសិទ្ធិ** .................... **៩៣**

លទ្ធកម្មដោយកិច្ចសន្យា និង លទ្ធកម្មដោយសន្តតិកម្ម (៩៣) លទ្ធកម្មដោយវិធីផ្សេងទៀត (៩៤) ល័ក្ខខ័ណ្ឌតតាំង (៩៤)

**៤ សិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្ស** .................... **៩៥**

អត្ថន័យនៃសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្ស (៩៥) សិទ្ធិទាមទារឲ្យប្រគល់វិញ សិទ្ធិទាមទារឲ្យបញ្ឈប់ និង បង្ការការរារាំង (៩៦)

✎ សិទ្ធិទាមទារឲ្យបង្ការការរារាំង និង ការទទួលបន្ទុកចំពោះសោហ៊ុយ--ការពិចារណាតាមរយៈករណីសិក្សា......................................................................................................................៩៧

**ជំពូកទី ៩ អំពើអនីត្យានុកូល ......................................................................................៩៩**

**១ អំពើអនីត្យានុកូល ...........................................................................................១០០**

(១ អត្ថន័យនៃអំពើអនីត្យានុកូល.................................................................................១០០

ទំនាក់ទំនងរវាងសិទ្ធិលើបំណុល និង កាតព្វកិច្ចដោយផ្អែកលើមូលហេតុក្រៅកិច្ចសន្យា ( ១០០) អត្ថន័យនៃអំពើអនីត្យានុកូល (១០០)

(២) មុខងាររបស់ច្បាប់ស្តីពីអំពើអនីត្យានុកូល...........................................................................១០១

ការធ្វើបដិទានចំពោះការខូចខាត (១០១) ទណ្ឌកម្មចំពោះចារីនៃអំពើអនីត្យានុកូល (១០១) ការទប់ស្កាត់ការខូចខាត (១០២)

(៣) អំពើអនីត្យានុកូល និង ការធានារ៉ាប់រង ...................................................................១០២

សំណងដោយផ្អែកលើរបបធានារ៉ាប់រង (១០២) បញ្ហាចំពោះរបបធានារ៉ាប់រង និង វិធានការ (១០៣)

(៤) ល័ក្ខខ័ណ្ឌនៃអំពើអនីត្យានុកូល...................................................................................១០៣

ចេតនា ឬ កំហុស (១០៤) ទំនាក់ទំនងនៃហេតុផល (១០៥) សមត្ថភាពទទួលខុសត្រូវ (១០៥) ភាពផ្ទុយច្បាប់ (១០៦)

(៥) ប្រភេទនៃអំពើអនីត្យានុកូល (អំពើអនីត្យានុកូលដែលមានលក្ខណៈទូទៅ និងអំពើអនីត្យានុកូលដែលមានលក្ខណៈពិសេស)......................................................................................១០៦

អំពើអនីត្យានុកូលដែលមានលក្ខណៈទូទៅ និង អំពើអនីត្យានុកូលដែលមានលក្ខណៈពិសេស (១០៧) ប្រភេទផ្សេងទៀតនៃអំពើអនីត្យានុកូលដែលមានលក្ខណៈពិសេស (១០៧)

**២ សំណងការខូចខាត......................................................................................១០៨**

ខ្លឹមសារនៃសំណងការខូចខាត (១០៩) វិសាលភាពនៃសំណងការខូចខាត (១០៩) អាជ្ញាយុកាល នៃ

សិទ្ធិទាមទារសំណងការខូចខាត (១១០)

✐ ការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលក្នុងករណីគ្រោះថ្នាក់រថយន្ត...............ការពិចារណាតាមរយៈករណីសិក្សា.......................................................................................................១១០

**ជំពូកទី ១០ ការគ្រប់គ្រងដោយឈឺឆ្នាល និង សេចក្ដីចម្រើនដោយឥតហេតុ.............................១១២**

**១ ការគ្រប់គ្រងដោយឈឺឆ្នាល.......................................................................................១១៣**

(១) អត្ថន័យនៃការគ្រប់គ្រងដោយឈឺឆ្នាល.......................................................................១១៣

អត្ថន័យនៃការគ្រប់គ្រងដោយឈឺឆ្នាល (១១៣) គោលបំណងនៃរបបការគ្រប់គ្រងដោយឈឺឆ្នាល (១១៤) ការគ្រប់គ្រងដោយឈឺឆ្នាលដោយផ្អែកលើច្បាប់ពិសេស (១១៤) លក្ខខណ្ឌនៃការគ្រប់គ្រងដោយឈឺឆ្នាល (១១៥)

(2) ការគ្រប់គ្រងដោយឈឺឆ្នាលដែលមិនពេញលេញ...........................................................១១៥

ករណីខ្វះលក្ខខណ្ឌបង្កើតការគ្រប់គ្រងដោយឈឺឆ្នាល (១១៥) ការគ្រប់គ្រងដោយឈឺឆ្នាលដែលមិនពេញលេញ (១១៦)

**២ សេចក្ដីចម្រើនដោយឥតហេតុ ...............................................................................១១៦**

(១) អត្ថន័យនៃសេចក្ដីចម្រើនដោយឥតហេតុ ...............................................................១១៦

អត្ថន័យនៃសេចក្ដីចម្រើនដោយឥតហេតុ (១១៦) លក្ខខណ្ឌនៃសេចក្ដីចម្រើនដោយឥតហេតុ (១១៧) អានុភាពនៃការបង្កើតសេចក្ដីចម្រើនដោយឥតហេតុ (១១៧)

(២) សេចក្ដីចម្រើនដោយឥតហេតុដែលមានបុគ្គលបីនាក់ចូលរួម.............................................១១៨

សេចក្ដីចម្រើនដោយឥតហេតុដែលមានតតិយជនចូលរួម (១១៨) សិទ្ធិប្ដឹងទាមទារទៅតាមវត្ថុដែលត្រូវបានផ្ទេរ (១១៩)

(៣) ការផ្ដល់គាវកាលិកដោយមូលហេតុខុសច្បាប់...........................................................១២១

ការផ្ដល់គាវកាលិកដោយមូលហេតុខុសច្បាប់ (១២១)

✐ ការបើកប្រាក់បញ្ញើលើស និង សេចក្ដីចម្រើនដោយឥតហេតុ--ការពិចារណាតាមរយៈករណីសិក្សា.....១២២

**ជំពូកទី ១១ ការសងបំណុល**............................................................................................១២៤

**១ ការធានាបំណុល ( ការធានាដោយវត្ថុ និង ការធានាដោយបុគ្គល )**........................................១២៥

ការធានាបំណុល (១២៥) ការធានាដោយវត្ថុ (សិទ្ធិប្រាតិភោគប្រត្យក្ស) (១២៦) ការធានាដោយបុគ្គល (ការធានា) (១២៧) ការធានាបំណុលអណ្តែត (១២៨)

**២ ការសងបំណុល ( ការអនុវត្តកាតព្វកិច្ច )**..............................................................................១២៨

របៀបសងបំណុល (១២៨)

**៣ រូបិយាណត្តិ និង មូលប្បទានប័ត្រ**.......................................................................................១២៩

(១) អត្ថន័យនៃរូបិយាណត្តិ និង មូលប្បទានប័ត្រ........................................................................១២៩

របបឧបករណ៍ដែលអាចជួញដូរបាន (១២៩) រូបិយាណត្តិ (១២៩) មូលប្បទានប័ត្រ (១៣០)

(២) ច្បាប់ស្តីពីរូបិយាណត្តិ និង មូលប្បទានប័ត្រ..........................................................................១៣០

ប្រព័ន្ធច្បាប់ដែលពាក់ព័ន្ធនឹងរូបិយាណត្តិ និង មូលប្បទានប័ត្រ (១៣១)

**៤ ការផ្ញើប្រាក់តាមធនាគារ**....................................................................................................១៣២

ការផ្ញើរប្រាក់ដោយការផ្ទេរប្រាក់តាមគណនីធនាគារ (១៣២) ទំនាក់ទំនងគតិយុត្តនៃការផ្ទេរប្រាក់ (១៣២)

**៥ ប័ណ្ណឥណទាន ជាដើម**......................................................................................................១៣៣

យន្តការប័ណ្ណឥណទាន (១៣៣) បញ្ហាប័ណ្ណឥតទាន (១៣៤) ប័ណ្ណឥណពន្ធ (១៣៤) រូបិយវត្ថុអេឡិកត្រូនិក (១៣៥)

✎ របៀបបង់ថ្លៃលក់ទិញ--ការពិចារណាតាមរយៈករណីសិក្សា.............................................................១៣៥

**ជំពូកទី ១២ គ្រួសារ**...........................................................................................................១៣៨

**១ ច្បាប់ស្តីពីគ្រួសារ**............................................................................................................១៣៩

អត្ថន័យនៃច្បាប់ស្តីពីគ្រួសារ (១៣៩) បុគ្គលនិយម (១៣៩) សមភាពរវាងបុរស និង នារី (១៤០)

**២ ញាតិ**............................................................................................................................១៤១

ញាតិ (១៤១) ញាតិលោហិត ញាតិខ្សែផ្ទាល់ សាខាញាតិ បុព្វញាតិ បច្ឆាញាតិ (១៤១) សហព័ទ្ធ និងញាតិពន្ធ (១៤៤)

**៣ សហព័ទ្ធ.......................................................................................................១៤៥**

(១) អាពាហ៍ពិពាហ៍.......................................................................................................១៤៥

អត្ថន័យនៃអាពាហ៍ពិពាហ៍ (១៤៥) ការបង្កើតអាពាហ៍ពិពាហ៍ (១៤៦) អានុភាពនៃអាពាហ៍ពិពាហ៍ (១៤៧) ប្រព័ន្ធទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ (១៤៧) ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ (១៤៨) អនីតិសង្វាស (១៤៩)

(២) ការលែងលះ.......................................................................................................១៤៩

អត្ថន័យនៃការលែងលះ (១៤៩) មូលហេតុនៃការលែងលះ (១៥០) ការលែងលះដោយការព្រមព្រៀង (១៥១) គោលការណ៍នៃការបែកបាក់ (១៥២) អានុភាពនៃការលែងលះ (១៥២)

✎ ការទាមទារលែងលះរបស់សហព័ទ្ធដែលមានករណីយកិច្ច--ការពិចារណាតាមរយៈករណីសិក្សា .....១៥៣

**ជំពូកទី ១៣ ឪពុកម្តាយ និង កូន និង អាហារកាតព្វកិច្ច ....................................................១៥៦**

**១ ទំនាក់ទំនងបុត្តភាព.......................................................................................................១៥៧**

(១) កូនបង្កើត.......................................................................................................១៥៧

កូនមានខាន់ស្លា (១៥៧) ទំនាក់ទំនងបុត្តភាពតាមរយៈការទទួលស្គាល់ (១៥៨)

(២) សុំកូន.......................................................................................................១៥៨

អត្ថន័យនៃរបបសុំកូន(១៥៨) សុំកូនពេញលេញ និង សុំកូនមិនពេញលេញ (១៥៩) សុំកូនធម្មតា (១៥៩) និងសុំកូនពិសេស (១៦០)

(៣) កូនដែលកើតតាមវិធីបង្កកំណើតសិប្បនិម្មិត.......................................................................................................១៦១

ទំនាក់ទំងរវាងឪពុកម្តាយ និង កូនដែលកើតតាមវិធីបង្កកំណើតសិប្បនិម្មិត (១៦១) បញ្ហាផ្លូវច្បាប់រវាងម្តាយជំនួស និង AID (១៦១) ភាពជាក់ស្តែងនៃបញ្ហា និង ការដោះស្រាយដោយផ្អែកលើនីតិកម្ម (១៦២)

**២ អនីតិជន និង អំណាចមេបារបស់ឪពុកម្តាយ.......................................................................................................១៦៣**

ខ្លឹមសារនៃអំណាចមេបា (១៦៣) គោលការណ៍នៃអំណាចមេបារួម (១៦៤) របបអាណាព្យាបាល (១៦៥)

៣ ញាតិ (អាហារកាតព្វកិច្ច)............................................................................................១៦៥

ខ្លឹមសារនៃករណីយកិច្ចផ្តត់ផ្គង់អាហារកាតព្វកិច្ច(១៦៦)

✎ ល័ក្ខខ័ណ្ឌនៃការបង្កើតសុំកូន --ការពិចារណាតាមរយៈករណីសិក្សា ........................................១៦៦

ជំពូកទី ១៤ សន្តតិកម្ម.......................................................................................................១៦៨

១ សន្តតិកម្ម...........................................................................................................១៦៩

(១) អត្ថន័យនៃសន្តតិកម្ម...........................................................................................១៦៩

ការស្នងបុគ្គលគតិយុត្ត(១៦៩) ប្រវត្តិនៃរបបសន្តតិកម្ម (១៧០)

(២) មូលដ្ឋាននៃសន្តតិកម្ម...........................................................................................១៧០

ការសម្រួលចំណែកដែលមានសក្តានុពល (១៧១) ការធានាជីវភាពគ្រួសារ (១៧១)

(៣) សន្តតិកម្មតាមច្បាប់ និង សន្តតិកម្មតាមមតកសាសន៍.....................................................១៧១

សន្តតិកម្មតាមច្បាប់ (១៧២) សន្តតិកម្មតាមមតកសាសន៍ (១៧២) គោលការណ៍នៃសន្តតិកម្ម (១៧៣)

២ សន្តតិជន និង ចំណែកមត៌ក.....................................................................................១៧៣

(១) សន្តតិជន...........................................................................................................១៧៣

កូន បុព្វញាតិផ្ទាល់ និង បងប្អូនប្រុសស្រី (១៧៣) សហព័ទ្ធ (១៧៤)

(២) ការយល់ព្រម និង ការបោះបង់ចោល.........................................................................១៧៤

ការយល់ព្រមទាំងស្រុង ការបោះបង់ចោល និង ការយល់ព្រមដោយមានកម្រិត (១៧៤)

(៣) ចំណែកមត៌ក.......................................................................................................១៧៥

ចំណែកមត៌កដែលកំណត់ដោយច្បាប់ (១៧៥) សមាមាត្រនៃចំណែកមត៌កដែលកំណត់ដោយច្បាប់ (១៧៥)

(៤) ភាគបម្រុង........................................................................................................១៧៦

សមាមាត្រនៃចំណែកមត៌កតាមមតកសាសន៍ (១៧៦) របបភាគបម្រុង (១៧៦)

**៣ មតកសាសន៍**........................................................................................................**១៧៦**

អត្ថន័យនៃមតកសាសន៍ (១៧៦) មតកសាសន៍ដោយលិខិតឯកជន (១៧៧) មតកសាសន៍ដោយលិខិតយថាភូត(១៧៧) មតកសាសន៍ដោយលិខិតសម្ងាត់ (១៧៨) មតកសាសន៍ពិសេស (១៧៨)

✎ សន្តតិកម្មតាមច្បាប់--ការពិចារណាតាមរយៈករណីសិក្សា.....................................................១៧៩

**ជំពូកទី ១៥ ស្ថាប័ន**........................................................................................................**១៨១**

**១ ប្រធាននៃសិទ្ធិ ៖ រូបវន្តបុគ្គល ឬ នីតិបុគ្គល**........................................................................**១៨២**

(១) របបនីតិបុគ្គល........................................................................................................១៨២

អត្ថន័យនៃនីតិបុគ្គល (១៨២) មុខងារនៃនីតិបុគ្គលសាជីវកម្ម (១៨២) មុខងារនៃនីតិបុគ្គលមូលនិធិ (១៨៣)

(២) ច្បាប់ដែលពាក់ព័ន្ធនឹងនីតិបុគ្គល........................................................................................១៨៤

**២ សកម្មភាពនីតិបុគ្គល**........................................................................................................**១៨៥**

ការបង្កើតនីតិបុគ្គល(១៨៥) នីតិវិធីបង្កើត និង អានុភាពនៃការបង្កើត (១៨៦) រចនាសម្ព័ន្ធរបស់នីតិបុគ្គល (១៨៦)

**៣ សាជីវកម្ម ឬ មូលនិធិដែលគ្មានសមត្ថភាពទទួលសិទ្ធិ**.......................................................**១៨៧**

អត្ថន័យនៃសាជីវកម្ម ឬ មូលនិធិដែលគ្មានសមត្ថភាពទទួលសិទ្ធិ (១៨៧)

**៤ ក្រុមហ៊ុន** ........................................................................................................**១៨៨**

អត្ថន័យ និង ប្រភេទនៃក្រុមហ៊ុន (១៨៨) ការបង្កើតក្រុមហ៊ុន (១៩០) រចនាសម្ព័ន្ធក្រុមហ៊ុន (១៩១)

✎កាតព្វកិច្ចរបស់នីតិបុគ្គលសាជីវកម្មដែលគ្មានសមត្ថភាពទទួលសិទ្ធិ-ការពិចារណាតាមរយៈករណីសិក្សា......១៩៣

**ជំពូកទី ១៦ ការសម្រេចសិទ្ធិ**........................................................................................................**១៩៥**

**១ ការសម្រេចសិទ្ធិ..........១៩៦**

(១) របៀបសម្រេចសិទ្ធិ..........១៩៦

ការអនុវត្តដោយស្ម័គ្រចិត្ត (១៩៦)

(២) ការសម្រេចសិទ្ធិតាមរយៈបណ្តឹង..........១៩៦

ការហាមឃាត់ការចាត់វិធានការសង្គ្រោះដោខ្លួនឯង (១៩៦) ការសម្រេចសិទ្ធិតាមរយៈបណ្តឹង (១៩៨) ការអនុវត្តដោយបង្ខំ (១៩៨)

**២ ការដោះស្រាយវិវាទ និង ប្រព័ន្ធតុលាការ..........១៩៩**

រឿងក្តីរដ្ឋប្បវេណីធម្មតា (១៩៩) រឿងក្តីគ្រួសារ (២០១) ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (២០២)

✎ ការសម្រេចសិទ្ធិតាមរយៈបណ្តឹង--ការពិចារណាតាមរយៈករណីសិក្សា..........២០២

Khmer Law's Association

# ជំពូកទី ១

## នីតិរដ្ឋប្បវេណី

**១ អត្ថន័យនៃនីតិរដ្ឋប្បវេណី**

**២ រចនាសម្ព័ន្ធនៃនីតិរដ្ឋប្បវេណី**

**៣ ប្រភពនៃនីតិ**

✎ ការសម្រេចឲ្យបាននូវការអនុវត្តច្បាប់ (សិទ្ធិ )--ការពិចារណាតាមរយៈករណីសិក្សា

Khmer Law's Association

**ករណីសិក្សា៖** A ដែលជាម្ចាស់ហាងផ្គត់ផ្គង់បរិក្ខារការិយាល័យមួយ បានព្រមព្រៀងលក់ក្រដាស សម្រាប់បោះពុម្ពអក្សរ និង បរិក្ខារមួយចំនួនផ្សេងទៀតទៅក្រុមហ៊ុន B ក្នុងតម្លៃ ១ លានយ៉េន ដោយបានប្រគល់បរិក្ខារទាំងនោះទៅ B រួចហើយ។ ក៏ប៉ុន្តែ ទោះបីជាកាលបរិច្ឆេទបង់ប្រាក់ថ្លៃទិញ បានកន្លងហួសទៅហើយក៏ដោយ ក៏ក្រុមហ៊ុន B មិនបានបង់ប្រាក់ដែរ។ ក្នុងករណីនេះ តើ A គួរធ្វើយ៉ាងណា ?

## ១ អត្ថន័យនៃនីតិរដ្ឋប្បវេណី

### ក) នីតិសាធារណៈ និង នីតិឯកជន

នីតិអាចត្រូវបានបែងចែកជាពីរប្រភេទគឺ នីតិសាធារណៈ និង នីតិឯកជន។ ឧទាហរណ៍ចំពោះច្បាប់ដែលស្ថិតនៅក្នុងប្រភេទនៃនីតិសាធារណៈមានដូចជា ច្បាប់រដ្ឋធម្មនុញ្ញជប៉ុន ច្បាប់សភា និង ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសមន្ត្រីសាធារណៈ ជាដើម ។ល។ ដោយឡែកចំពោះច្បាប់ដែលស្ថិតនៅក្នុងប្រភេទនៃនីតិឯកជនវិញមានដូចជា ច្បាប់រដ្ឋប្បវេណី ច្បាប់ពាណិជ្ជកម្ម ច្បាប់ក្រុមហ៊ុន និង ច្បាប់ស្តីពីរូបិយាណត្តិ ជាដើម ។ល។

ការកំណត់ឲ្យចំនូវអត្ថន័យនៃនីតិសាធារណៈ និង នីតិឯកជន គឺមានការពិបាក។ ក៏ប៉ុន្តែ នាពេលបច្ចុប្បន្ន គេអាចកំណត់បានថា បទប្បញ្ញត្តិទាំងឡាយដែលសម្រាប់កំណត់នូវទំនាក់ទំនងស្មើភាពរវាងបុគ្គលឯកជន និង បុគ្គលឯកជន គឺជានីតិឯកជន រីឯនីតិសាធារណៈវិញគឺសំដៅលើបទប្បញ្ញត្តិដែលសម្រាប់កំណត់នូវទំនាក់ទំនងរវាងរដ្ឋជាមួយបុគ្គលឯកជន ឬ ទំនាក់ទំនងរវាងរដ្ឋបាលមូលដ្ឋាន (សំដៅលើរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង ភូមិនានានៃប្រទេសជប៉ុន) ជាមួយបុគ្គលឯកជន ដោយទទួលស្គាល់ឧត្តមានុភាពរបស់ស្ថាប័នរដ្ឋក្នុងនាមជាប្រធាននៃអំណាចសាធារណៈនៅក្នុងទំនាក់ទំនងនោះ។ ម្យ៉ាងវិញទៀត នីតិសាធារណៈ ក៏ជាបទប្បញ្ញត្តិសម្រាប់គ្រប់គ្រងនូវទំនាក់ទំនងរវាងរដ្ឋ និង រដ្ឋបាលមូលដ្ឋាន និង រវាងរដ្ឋបាលមូលដ្ឋាន និង រដ្ឋបាលមូលដ្ឋានដែរ ។

ក៏ប៉ុន្តែ នាពេលបច្ចុប្បន្ន ព្រំដែននៃវិស័យនីតិឯកជន និង នីតិសាធារណៈកាន់តែមានភាពមិនច្បាស់លាស់ ហើយទន្ទឹមគ្នានេះ ក៏មានការលេចចេញនូវច្បាប់ដែលនៅចន្លោះព្រំដែននេះ (ឧទាហរណ៍ដូចជាច្បាប់ការងារ ច្បាប់សន្តិសុខសង្គម និង ច្បាប់ក្រុមហ៊ុន ជាដើម ដែលគេហៅថាវិស័យច្បាប់សង្គម)។

ច្បាប់ដែលតំណាងឲ្យនីតិឯកជនមានដូចជាច្បាប់រដ្ឋប្បវេណី និង ច្បាប់ពាណិជ្ជកម្ម ក៏ប៉ុន្តែ ក្រៅពីនោះ ក៏នៅមានច្បាប់ជាច្រើនទៀតដូចជា ច្បាប់ស្តីពីការចុះបញ្ជីអចលនវត្ថុ ច្បាប់ស្តីពីការចុះបញ្ជីគ្រួសារ ច្បាប់ស្តីពីការជួលដី និង អគារ ច្បាប់ស្តីពីអគារសហកម្មសិទ្ធិ ច្បាប់ស្តីពីការទទួលខុសត្រូវ

ចំពោះផលិតផល ច្បាប់ស្ដីពីក្រុមហ៊ុន ច្បាប់ស្ដីពីការចុះបញ្ជីពាណិជ្ជកម្ម ច្បាប់ស្ដីពីរូបិយាណត្តិ និង មូលប្បទានប័ត្រពាណិជ្ជកម្ម ជាដើម ដែលស្ថិតក្នុងវិស័យនីតិឯកជន ។

### ខ) អត្ថន័យនៃនីតិរដ្ឋប្បវេណី

ពាក្យដែលត្រូវបានប្រើប្រាស់ក្នុងទស្សនាទានស្រដៀងគ្នាទៅនឹងនីតិឯកជន គឺពាក្យថានីតិរដ្ឋប្បវេណី ដែលត្រូវបានប្រើប្រាស់ជាពាក្យផ្ទុយនឹងនីតិព្រហ្មទណ្ឌ។ ជាធម្មតា នីតិរដ្ឋប្បវេណីនេះសំដៅលើនីតិ ដែលរួមបញ្ចូលក្រមរដ្ឋប្បវេណី និង ច្បាប់ពាណិជ្ជកម្ម ជាអាទិ៍ ដែលជាច្បាប់សារធាតុក្នុងវិស័យ នីតិឯកជន និង ក្រមនីតិវិធីរដ្ឋប្បវេណី ច្បាប់ស្ដីពីនីតិវិធីនៃបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល និង ច្បាប់ស្ដី ពីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ជាអាទិ៍ ដែលជាច្បាប់នីតិវិធីក្នុងវិស័យនីតិឯកជន។ ច្បាប់ សារធាតុត្រង់កន្លែងនេះគឺមានន័យថាជាច្បាប់ទាំងឡាយណាដែលបញ្ញត្តពីការកើតឡើង ការរលត់ ការផ្ទេរ និង ការផ្លាស់ប្ដូរនៃសិទ្ធិ និង កាតព្វកិច្ច។ ដោយឡែកច្បាប់នីតិវិធីវិញ គឺសំដៅលើច្បាប់ដែល ចែងអំពីនីតិវិធីដើម្បីសម្រេចឲ្យបាននូវសិទ្ធិដែលមានកំណត់នៅក្នុងច្បាប់សារធាតុ ។

ផ្ទុយនឹងនីតិរដ្ឋប្បវេណី នីតិព្រហ្មទណ្ឌសំដៅលើច្បាប់ដែលបញ្ញត្តអំពីការអនុវត្តសិទ្ធិដាក់ទណ្ឌកម្ម របស់រដ្ឋ ឬ អាចនិយាយបាន ម្យ៉ាងទៀតថា នីតិព្រហ្មទណ្ឌគឺសំដៅទៅលើច្បាប់ដែលពាក់ព័ន្ធទៅនឹង ការដាក់ទណ្ឌកម្មចំពោះជនដែលបានប្រព្រឹត្តបទល្មើស។ ឧទាហរណ៍ជាក់ស្ដែង រួមមានក្រមព្រហ្មទណ្ឌ ជាអាទិ៍ ដែលជាច្បាប់សារធាតុ និង ក្រមនីតិវិធីព្រហ្មទណ្ឌ ជាអាទិ៍ ដែលជាច្បាប់នីតិវិធី និង ច្បាប់ ដែលពាក់ព័ន្ធទៅនឹងប្រព្រឹត្តកម្មចំពោះកន្លែងឃុំខ្លួន និង ជនដែលត្រូវឃុំខ្លួន ជាអាទិ៍ ដែលជាច្បាប់ រដ្ឋបាលព្រហ្មទណ្ឌ។

## ២ វចនាសម្ព័ន្ធនៃនីតិរដ្ឋប្បវេណី

### ក) ច្បាប់សារធាតុ

ដូចបានរៀបរាប់ខាងលើ នីតិរដ្ឋប្បវេណីគឺផ្សំឡើងពីក្រមរដ្ឋប្បវេណី និង ច្បាប់ពាណិជ្ជកម្ម ជាអាទិ៍ ដែលជាច្បាប់សារធាតុ និង ក្រមនីតិវិធីរដ្ឋប្បវេណី ជាដើម ដែលជាច្បាប់នីតិវិធី។ ក៏ប៉ុន្តែ ដើម្បីស្វែង យល់ពីទំនាក់ទំនងនៃច្បាប់ទាំងនេះ ចាំបាច់ត្រូវលើកករណីសិក្សាជាក់លាក់ ។

ឧទាហរណ៍ ក្នុងករណីសិក្សាខាងលើ ក្រុមហ៊ុន B បានទិញក្រដាសសម្រាប់បោះពុម្ពអក្សរ និង បរិក្ខារការិយាល័យមួយចំនួនទៀតពី A ក្នុងតម្លៃ ១ លានយ៉េន ដែលតាមរយៈនោះ B មានកាតព្វកិច្ច ត្រូវបង់ថ្លៃលក់ទិញ ១ លានយ៉េន ទៅ A។ ប្រសិនបើយើងមើលលើទស្សនៈរបស់ A គឺ A មានសិទ្ធិទាម ទារឲ្យក្រុមហ៊ុន B បង់ប្រាក់ ១ លានយ៉េន។ បញ្ញត្តិដែលកំណត់នូវទំនាក់ទំនងគតិយុត្តបែបនេះរវាង A

និង ក្រុមហ៊ុន B គឺក្រមរដ្ឋប្បវេណីដែលជាច្បាប់សារធាតុ។ បានសេចក្តីថា កិច្ចសន្យារវាង A និង B ហៅថា កិច្ចសន្យាលក់ទិញដែលក្នុងក្រមរដ្ឋប្បវេណី ចាប់ពីមាត្រា ៥៥៥ តទៅ មានចែងលម្អិតពីទំនាក់ទំនងនៃសិទ្ធិ និង កាតព្វកិច្ចរវាងអ្នកលក់ និង អ្នកទិញ (ជំពូកទី ៧ នឹងមានពន្យល់លម្អិតពាក់ព័ន្ធនឹងកិច្ចសន្យា) ។

### ខ) ច្បាប់នីតិវិធី

ប្រសិនបើក្រុមហ៊ុន B បង់ប្រាក់ ១ លានយ៉េន ទៅឲ្យ A តាមការសន្យា គឺមិនមានបញ្ហាអ្វីកើតឡើងទេ។ ក៏ប៉ុន្តែ ប្រសិនបើក្នុងករណីដែលក្រុមហ៊ុន B នៅតែមិនបង់ប្រាក់ទៅឲ្យ A បើទោះជាកំណត់ពេលសងដែលបានសន្យានោះបានមកដល់ហើយក្តី នោះវិវាទរវាង A និង ក្រុមហ៊ុន B នឹងកើតឡើង។ ក្នុងករណីបែបនេះ បទប្បញ្ញត្តិដែលចែងអំពីនីតិវិធីថាតើ A ត្រូវធ្វើដូចម្តេច ដើម្បីសម្រេចឲ្យបាននូវសិទ្ធិរបស់ខ្លួន (បានសេចក្តីថាតើ A ត្រូវធ្វើដូចម្តេចដើម្បីអាចប្រមូលប្រាក់ ១ លានយ៉េន ពីក្រុមហ៊ុន B) នោះគឺក្រមនីតិវិធីរដ្ឋប្បវេណី។ វិធីដែល A អាចសម្រេចនូវសិទ្ធិរបស់ខ្លួនគឺមានច្រើន ក៏ប៉ុន្តែ វិធីដែលប្រើជាសាមញ្ញបំផុត គឺការដាក់ពាក្យបណ្តឹងទៅតុលាការ។ មានន័យថា A អាចទាមទារសុំឲ្យតុលាការបង្គាប់ក្រុមហ៊ុន B ឲ្យបង់ប្រាក់មកខ្លួន ១ លានយ៉េន។ តាមរយៈការអះអាងរបស់ A និងក្រុមហ៊ុន B តុលាការនឹងធ្វើការពិនិត្យល្អិតល្អន់ទៅលើទំនាក់ទំនងនៃអង្គហេតុ ហើយក្រោយពេលដែលតុលាការវិនិច្ឆ័យឃើញថា ការទាមទាររបស់ A មានមូលដ្ឋានគ្រប់គ្រាន់ហើយ តុលាការនឹងបង្គាប់ឲ្យក្រុមហ៊ុន B បង់ប្រាក់ ១ លានយ៉េនទៅ A ។ សេចក្តីបង្គាប់របស់តុលាការបែបនេះ ហៅថា សាលក្រម ឬ សាលដីកា។ ក្នុងករណីដែលតុលាការបានវិនិច្ឆ័យឃើញថា ការទាមទាររបស់ A មិនមានមូលដ្ឋានគ្រប់គ្រាន់ តុលាការនឹងចេញសាលក្រម ឬ សាលដីកាដែលមានខ្លឹមសារច្រានចោលការទាមទាររបស់ A។ ច្បាប់ដែលបញ្ញត្តអំពីនីតិវិធីនៃការជំនុំជម្រះបែបនេះ គឺក្រមនីតិវិធីរដ្ឋប្បវេណី។

ក្នុងករណីមានសាលក្រម ឬ សាលដីកាដែលទទួលស្គាល់ការទាមទាររបស់ A ដោយបង្គាប់ឲ្យក្រុមហ៊ុន B បង់ប្រាក់ ១ លានយ៉េនទៅឲ្យ A ហើយក៏ដោយ តែក្រុមហ៊ុន B នៅតែមិនព្រមបង់ទៅតាមការបង្គាប់ទៀតនោះ A អាចទាមទារទៅតុលាការ (ឬក៏ទាមទារទៅអាជ្ញាសាលា) ដើម្បីអនុវត្តសាលក្រម ឬ សាលដីកាដោយបង្ខំបាន។ ជាក់ស្តែង អនុលោមទៅតាមការទាមទាររបស់ A តុលាការអាចធ្វើការរឹបអូសទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន B ហើយដាក់លក់ឡៃឡុង និង ដកយកប្រាក់ ១ លានយ៉េន ពីក្នុងចំណោមប្រាក់ដែលបានមកពីការលក់ប្រគល់ទៅឲ្យ A ។ ច្បាប់ដែលចែងអំពីការអនុវត្តដោយបង្ខំរបៀបនេះ គឺច្បាប់ស្តីពីការអនុវត្តនៅក្នុងរឿងក្តីរដ្ឋប្បវេណី (សេចក្តីលម្អិតស្តីពីការអនុវត្តដោយបង្ខំដើម្បីសម្រេចបាននូវសិទ្ធិ មាននៅក្នុងជំពូកទី ១៦)។

## ៣ ប្រភពនៃនីតិ

ពាក្យថាប្រភពនៃនីតិត្រូវបានប្រើប្រាស់ក្នុងន័យច្រើន ក៏ប៉ុន្តែ ជាធម្មតា វាមានន័យថាជាបទដ្ឋានដែលអាចស្រង់ចេញមក នៅពេលដែលគេបកស្រាយច្បាប់ ឬ ប្រើប្រាស់ច្បាប់។ នៅតុលាការ បទដ្ឋានគតិយុត្តដែលនឹងក្លាយទៅជាមូលដ្ឋានសម្រាប់ចៅក្រមធ្វើការដោះស្រាយរឿងក្តី គឺជាឧទាហរណ៍គំរូនៃប្រភពនៃនីតិនោះ ក៏ប៉ុន្តែ ជួលកាល វាក៏អាចមានន័យថាជាវិធានដែលត្រូវបានអនុវត្តជាក់ស្តែងនៅក្នុងសង្គមយ៉ាងទូលំទូលាយ ដែលមិនមែនជាតុលាការដែរ។ សូមធ្វើការពិនិត្យមើលចំពោះប្រភេទមួយចំនួននៃប្រភពនៃនីតិដូចខាងក្រោម ។

## ក) នីតិសរសេរ

ទី ១ គឺនីតិសរសេរ។ នីតិសរសេរ គឺមានន័យថា វិធានគតិយុត្តដែលត្រូវបានបញ្ញត្តឡើងក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ ហើយក៏អាចហៅម្យ៉ាងទៀតថាជាច្បាប់ដែលត្រូវបានអនុម័តពីស្ថាប័ននីតិបញ្ញត្តិដែលមានសមត្ថកិច្ចតាក់តែងច្បាប់ ដូចជា សភា ជាដើម។ ជាទូទៅ ច្បាប់សរសេរគឺសំដៅទៅលើច្បាប់ដែលអនុម័តដោយផ្អែកទៅលើសេចក្តីសម្រេចរបស់សភា ក៏ប៉ុន្តែនៅមានច្បាប់ដែលមានទម្រង់ផ្សេងៗទៀតដូចជា រដ្ឋធម្មនុញ្ញដែលកំណត់អំពីមូលដ្ឋាននៃរបបគ្រប់គ្រងរដ្ឋ លិខិតបទដ្ឋានដែលបញ្ញត្តដោយស្ថាប័នរដ្ឋបាល (ដូចជា ប្រកាសរបស់គណៈរដ្ឋមន្ត្រី អនុក្រឹត្យរបស់នាយករដ្ឋមន្ត្រី ប្រកាសរបស់ក្រសួងនានា ជាដើម) វិធានទូទៅដែលតុលាការកំពូល ឬ សភានីមួយៗកំណត់ និង បទប្បញ្ញត្តិនានាដែលចេញដោយរដ្ឋបាលមូលដ្ឋាន។ ប្រភពនៃនីតិដ៏សំខាន់នៃច្បាប់សរសេររបស់ប្រទេសយើង គឺជាច្បាប់សរសេរដែលត្រូវបានតាក់តែងឡើងតាមរបៀបជាឯកសារដែលមានការសរសេរជាក់លាក់ដែលវាដូចគ្នាជាមួយនឹងបណ្តាប្រទេសដែលប្រកាន់យកប្រព័ន្ធច្បាប់ស៊ីវិលមួយចំនួន ដូចជា ប្រទេសអាល្លឺម៉ង់ និង ប្រទេសបារាំង ជាដើម ក៏ប៉ុន្តែ បណ្តាប្រទេសមួយចំនួនដែលត្រូវបានហៅថាជាប្រទេសប្រកាន់យកប្រព័ន្ធច្បាប់ខំមិនឡ (common law) ដូចជាប្រទេសអង់គ្លេស និង សហរដ្ឋអាមេរិក ជាដើមវិញ យុត្តិសាស្ត្រដែលនឹងរៀបរាប់ខាងក្រោមនេះ គឺជាប្រភពដ៏សំខាន់នៃនីតិ (ហៅថា ប្រព័ន្ធច្បាប់ដែលបង្កើតដោយតុលាការ) ។

## ខ) នីតិឥតសរសេរ

ទី ២ គឺនីតិឥតសរសេរ។ នីតិឥតសរសេរមានន័យថាជាវិធានគតិយុត្តដែលមិនត្រូវបានតាក់តែងឡើងតាមរបៀបសរសេរជាលាយលក្ខណ៍អក្សរទេ ក៏ប៉ុន្តែ វាជាទស្សនៈគតិយុត្តដែលដូចគ្នាទៅនឹងច្បាប់សរសេរដែរ។ ច្បាប់ទំនៀមទម្លាប់ និង យុត្តិសាស្ត្រ គឺជាឧទាហរណ៍គំរូនៃនីតិឥតសរសេរនោះ។ ទំនៀមទម្លាប់អាចនិយាយបានថាជាការអនុវត្តច្រំដែលៗនូវវិធានរួមនៃសង្គមជាកំណត់មួយដែលកំណត់ផ្អែកទៅលើតែចំពោះប្រភេទអាជីវកម្ម (ឧទាហរណ៍ វិស័យប្រេងឥន្ធនៈ) ឬ ក៏ចំពោះតំបន់ជាក់លាក់

ណាមួយ (ឧទាហរណ៍ តំបន់តូក្យូ) ហើយក្នុងទំនៀមទម្លាប់ទាំងនោះ ទំនៀមទម្លាប់ដែលគេគិតថាមានអានុភាពគតិយុត្តនោះ ជាពិសេស ហៅថា ច្បាប់ទំនៀមទម្លាប់ ។

បើតាមមាត្រា ៩២ នៃក្រមរដ្ឋប្បវេណី នៅក្នុងករណីដែលទំនៀមទម្លាប់ផ្ទុយទៅនឹងបញ្ញត្តិណាមួយនៃច្បាប់ដែលមិនពាក់ព័ន្ធជាមួយនឹងសណ្តាប់ធ្នាប់សាធារណៈ ហើយភាគីមានឆន្ទៈអនុវត្តតាមទំនៀមទម្លាប់នោះ ទំនៀមទម្លាប់នោះត្រូវយកមកអនុវត្ត។ម្យ៉ាងវិញទៀត មាត្រា ១ នៃក្រមពាណិជ្ជកម្មចែងថា ក្នុងករណីដែលមិនមានបញ្ញត្តិដែលពាក់ព័ន្ធជាមួយពាណិជ្ជកិច្ចនៅក្នុងក្រមពាណិជ្ជកម្មទេ ត្រូវអនុវត្តតាមច្បាប់ទំនៀមទម្លាប់ពាណិជ្ជកម្ម ហើយក្នុងករណីដែលមិនមានច្បាប់ទំនៀមទម្លាប់ពាណិជ្ជកម្មទេ ក្រមរដ្ឋប្បវេណីត្រូវយកមកអនុវត្ត ពោលគឺបានបញ្ជាក់យ៉ាងច្បាស់ថា ច្បាប់ទំនៀមទម្លាប់ពាណិជ្ជកម្មមានអាទិភាពជាងក្រមរដ្ឋប្បវេណីដែលជានីតិសរសេរដែរ ។

យុត្តិសាស្ត្រត្រូវបានគេប្រើសំដៅទៅលើវិធានគតិយុត្តដែលមានខ្លឹមសារដូចគ្នានៅក្នុងសាលក្រម ឬ សាលដីកាមួយចំនួនដែលត្រូវបានសម្រេចចំពោះរឿងក្តីដែលមានប្រភេទដូចគ្នា (ហើយក៏អាចមានករណីដែលសាលក្រម ឬ សាលដីកាតែមួយអាចក្លាយទៅជាយុត្តិសាស្ត្របានដែរ) (នៅក្នុងករណីមួយចំនួនធំ យើងឃើញថា យុត្តិសាស្ត្រគឺធ្វើការបកស្រាយ និង អនុវត្តវិធានគតិយុត្តនៃនីតិសរសេរ និងច្បាប់ទំនៀមទម្លាប់ ជាអាទិ៍)។ វាពុំមានបញ្ញត្តិច្បាប់ណាដែលចែងថា តុលាការត្រូវតែធ្វើតាមយុត្តិសាស្ត្រ នៅពេលចេញសាលក្រម ឬ សាលដីកានោះទេ។ ដូច្នេះ យុត្តិសាស្ត្រពុំមែនជាប្រភពនៃនីតិដែលមានលក្ខណៈជាប្រព័ន្ធទេ។ ក៏ប៉ុន្តែ នៅក្នុងស្ថានភាពជាក់ស្តែង នៅពេលដែលតុលាការចេញសាលក្រម ឬ សាលដីកា គឺតុលាការគោរពយុត្តិសាស្ត្រដែលពាក់ព័ន្ធជាមួយរឿងក្តីប្រភេទដូចគ្នាដែលមានកាលពីមុន។ ដូច្នេះ យុត្តិសាស្ត្របានក្លាយទៅជាប្រភពនៃនីតិតាមភាពជាក់ស្តែង។ ប្រសិនបើនិយាយពីស្ថិរភាពគតិយុត្ត និង ភាពដែលអាចប្រមើលមើលទុកជាមុនបាននៃការវិនិច្ឆ័យវិញ ការគោរពតាមយុត្តិសាស្ត្របែបនេះ គឺជាប្រការមួយដែលគេចង់បាន។

### គ) ទ្រឹស្តី និង លទ្ធិ

ទី ៣ ទ្រឹស្តី និង លទ្ធិ ជាដើម ត្រូវបានគេជជែកដេញដោលយ៉ាងច្រើនថាតើពួកវាមានលក្ខណៈជាប្រភពនៃនីតិដែរ ឬ យ៉ាងណា។ យើងមិនអាចបដិសេធបានចំពោះឥទ្ធិពលជាក់ស្តែងនៃទ្រឹស្តីទៅលើការវិនិច្ឆ័យរបស់តុលាការនោះទេ (ជាឧទាហរណ៍ មានករណីដែលយុត្តិសាស្ត្រត្រូវបានផ្លាស់ប្តូរដោយសារការរិះគន់ពីទ្រឹស្តី) ក៏ប៉ុន្តែ គេមិនគិតថាទ្រឹស្តីជាប្រភពនៃនីតិទេ។ លទ្ធិត្រូវបានយល់ក្នុងន័យថាជាអ្វីដែលមានភាពសមហេតុផល។ មាត្រា ១ នៃក្រមរដ្ឋប្បវេណីប្រទេសស្វីសមានចែងអំពីការដែលលទ្ធិក្លាយជាប្រភពនៃនីតិ ក៏ប៉ុន្តែ បញ្ញត្តិបែបនេះមិនមាននៅក្នុងក្រមរដ្ឋប្បវេណីជប៉ុនទេ។ ក៏ប៉ុន្តែ ចំពោះប្រទេសជប៉ុនវិញ មានទ្រឹស្តីដែលទទួលស្គាល់នូវលក្ខណៈជាប្រភពនៃនីតិរបស់លទ្ធិ នេះបើយើងដក

ស្រង់យកខ្លឹមសារនៃប្រកាសរបស់គណៈរដ្ឋមន្ត្រីសម័យមេជិ លេខ ១០៣ ឆ្នាំ ១៨៧៥ ដែលចែងថា "ចំពោះការវិនិច្ឆ័យរដ្ឋប្បវេណី ក្នុងករណីដែលគ្មានច្បាប់ជាលាយលក្ខណ៍អក្សរ ត្រូវអាស្រ័យលើទំនៀមទម្លាប់ ហើយក្នុងករណីដែលគ្មានទំនៀមទម្លាប់ ត្រូវធ្វើការវិនិច្ឆ័យដោយគិតថ្លឹងថ្លែងពិចារណាលើលទ្ធិ" (នេះជាបញ្ញត្តិដែលមាននៅមុនពេលអនុម័តក្រមរដ្ឋប្បវេណី ដូច្នេះ ថាតើបញ្ញត្តិនេះនៅមានអានុភាពគតិយុត្ត ឬ យ៉ាងណា នៅពេលបច្ចុប្បន្ន គឺមិនមានភាពច្បាស់លាស់ទេ) ។

✎ ការសម្រេចឲ្យបាននូវការអនុវត្តច្បាប់(សិទ្ធិ)--ការពិចារណាតាមរយៈករណីសិក្សា

ពាក់ព័ន្ធនឹងករណីសិក្សា យើងបានឃើញរួចហើយពីរបៀបធ្វើយ៉ាងណាដើម្បីសម្រេចឲ្យបាននូវការអនុវត្តសិទ្ធិ។ ចំពោះ A និង ក្រុមហ៊ុន B នៅពេលដែលកិច្ចសន្យាត្រូវបានធ្វើរួចហើយ សិទ្ធិ និងកាតព្វកិច្ច នឹងកើតមានចំពោះ A និង ក្រុមហ៊ុន B ដូចតទៅនេះ។ A មានកាតព្វកិច្ចប្រគល់ក្រដាសបោះពុម្ពអក្សរ ជាដើម ដូចដែលបានសន្យាទៅក្រុមហ៊ុន B ក៏ប៉ុន្តែ A មានសិទ្ធិទាមទារប្រាក់ ១ លានយ៉េន ពីក្រុមហ៊ុន B។ ផ្ទុយទៅវិញ ក្រុមហ៊ុន B មានកាតព្វកិច្ចត្រូវបង់ប្រាក់ ១ លានយ៉េន ទៅ A ក៏ប៉ុន្តែខ្លួនមានសិទ្ធិទាមទារឲ្យប្រគល់ក្រដាសបោះពុម្ពអក្សរ ជាដើម ដែលជាកម្មវត្ថុនៃកិច្ចសន្យា។ នៅក្នុងករណីសិក្សា A បានអនុវត្តកាតព្វកិច្ចប្រគល់ក្រដាសបោះពុម្ពអក្សរទៅឲ្យក្រុមហ៊ុន B រួចហើយ ដូច្នេះនៅសល់តែកាតព្វកិច្ចបង់ប្រាក់របស់ក្រុមហ៊ុន B តែប៉ុណ្ណោះ ។

នៅក្នុងករណីដែលក្រុមហ៊ុន B មិនបានបង់ប្រាក់ទៅតាមកិច្ចសន្យាទេ A អាចដាក់ពាក្យបណ្តឹងទៅតុលាការដោយយកក្រុមហ៊ុន B ជាចុងចម្លើយ ។ ប្រសិនបើតុលាការវិនិច្ឆ័យថា ការអះអាងរបស់ A គឺជាការពិត តុលាការនឹងចេញសាលក្រមបង្គាប់ឲ្យក្រុមហ៊ុន B បង់ប្រាក់ ១ លានយ៉េន ទៅ A ។ ដើម្បីវិនិច្ឆ័យថាតើ A មានសិទ្ធិដូចដែលគាត់អះអាងដែរ ឬ យ៉ាងណានោះ តុលាការត្រូវផ្អែកទៅលើបញ្ញត្តិនៃក្រមរដ្ឋប្បវេណីជាមូលដ្ឋាន។ ប្រសិនបើក្រុមហ៊ុន B បង់ប្រាក់ ១ លានយ៉េន ទៅតាមការបង្គាប់របស់សាលក្រម គឺវិវាទត្រូវបញ្ចប់ ។

ក៏ប៉ុន្តែ ក្នុងករណីដែលក្រុមហ៊ុន B មិនអនុវត្តតាមការបង្គាប់របស់សាលក្រមទេ A អាចទាមទារទៅតុលាការឲ្យមានការអនុវត្តសាលក្រមដោយបង្ខំបាន។ តុលាការអាចធ្វើការរឹបអូសទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន B ប្តូរទ្រព្យនោះឲ្យទៅជាប្រាក់ រួចហើយដកយក ១ លានយ៉េន ប្រគល់ទៅឲ្យ A ។

ការអនុវត្តបែបនេះ A អាចសម្រេចបាននូវសិទ្ធិរបស់ខ្លួនតាមរយៈអំណាចរដ្ឋ (ក៏ប៉ុន្តែ ប្រសិនបើក្រុមហ៊ុន B មិនមាននូវទ្រព្យសម្បត្តិអ្វីទេ សិទ្ធិនោះក៏មិនអាចសម្រេចបានដែរ )។

# ជំពូកទី ២

## ច្បាប់រដ្ឋប្បវេណី និង ក្រមរដ្ឋប្បវេណី

**១ អត្ថន័យនៃច្បាប់រដ្ឋប្បវេណី**

**២ រចនាសម្ព័ន្ធនៃច្បាប់រដ្ឋប្បវេណី**

**៣ ប្រវត្តិនៃច្បាប់រដ្ឋប្បវេណី**

**៤ គោលការណ៍ជាមូលដ្ឋាននៃច្បាប់រដ្ឋប្បវេណី**

✏ ច្បាប់រដ្ឋប្បវេណីក្នុងឋានៈជាច្បាប់ទូទៅ និង ច្បាប់ពាណិជ្ជកម្មក្នុងឋានៈជាច្បាប់ពិសេស --ការពិចារណាតាមរយៈករណីសិក្សា

Khmer Law's Association

**ករណីសិក្សា៖** A ដែលជាអ្នកបើកហាងកាហ្វេជាលក្ខណៈឯកជនម្នាក់បានឲ្យខ្ចីប្រាក់ ១ លានយ៉េន ទៅ B ដែលមានមុខរបរដូចគ្នាតាមការស្នើសុំ។ មានការសន្យាថានឹងសងវិញក្នុងអំឡុងពេល ៣ ខែក្រោយ ក៏ប៉ុន្តែ B នៅតែមិនបានសងទៅ A ទោះបីជាកំណត់ពេលសងបានមកដល់ក៏ដោយ។ តើ A អាចធ្វើការទាមទារយ៉ាងដូចម្តេចបាន ?

## ១ អត្ថន័យនៃច្បាប់រដ្ឋប្បវេណី

### ក) និយមន័យនៃច្បាប់រដ្ឋប្បវេណី

ពាក្យថា "ច្បាប់រដ្ឋប្បវេណី" គឺត្រូវនឹងពាក្យរបស់បស្ចិមប្រទេសដែលហៅថា droit civil ឬ bürgerliches Recht ប៉ុន្តែ ក្នុងភាសាបារាំង ពាក្យថា civil ឬ ក្នុងភាសាអាល្លឺម៉ង់ ពាក្យថា bürgerliches មានន័យច្រើនណាស់។ ឧទាហរណ៍ នៅក្នុងភាសាបារាំង ពាក្យថា civil បើក្នុងន័យសាសនាគឺមានន័យសំដៅលើគ្រហស្ថ ហើយបើក្នុងន័យទាហានវិញ គឺសំដៅលើជនស៊ីវិល ជាដើម។ ដូច្នេះ នៅពេលដែលនិយាយថា ច្បាប់រដ្ឋប្បវេណីគឺមានន័យថា ច្បាប់សម្រាប់ពលរដ្ឋសាមញ្ញ។ ឧទាហរណ៍ដូចជានៅក្នុងសម័យចក្រភពរ៉ូមបុរាណ ពលរដ្ឋក្រុងរ៉ូមគឺមានន័យសំដៅតែទៅលើបុគ្គលទាំងឡាយដែលមានឋានៈកំណត់មួយប៉ុណ្ណោះ ដូច្នេះ ក្នុងសម័យកាលនោះ ច្បាប់ពលរដ្ឋគឺអនុវត្តតែចំពោះពលរដ្ឋមួយផ្នែកប៉ុណ្ណោះ។ ប៉ុន្តែ ក្នុងសម័យបច្ចុប្បន្ន មិនមានឋានៈខុសគ្នាអ្វីទេ ដូច្នេះ ពាក្យថាច្បាប់ពលរដ្ឋដែលគេប្រើសម្រាប់អនុវត្តចំពោះបុគ្គលកំណត់នោះ លែងមានន័យអ្វីទៀតហើយ។ បានសេចក្តីថា ច្បាប់រដ្ឋប្បវេណីគឺត្រូវយកទៅអនុវត្តចំពោះគ្រប់បុគ្គលទាំងអស់។ ដូច្នេះ យើងនឹងធ្វើការបញ្ជាក់ឲ្យបានច្បាស់ថាតើច្បាប់រដ្ឋប្បវេណីក្នុងលក្ខណៈជាច្បាប់ដែលត្រូវបានអនុវត្តជាសកលចំពោះជនគ្រប់រូបនោះ មានអត្ថន័យយ៉ាងដូចម្តេចខ្លះ។

### ខ) ច្បាប់ទូទៅ និង ច្បាប់ពិសេស

ច្បាប់រដ្ឋប្បវេណីត្រូវបានហៅថាជាច្បាប់ទូទៅនៃនីតិឯកជន។ បានសេចក្តីថា ប្រសិនបើយើងធ្វើការបែងចែកនីតិជានីតិសាធារណៈ និង នីតិឯកជន ច្បាប់រដ្ឋប្បវេណីស្ថិតនៅក្នុងប្រភេទនីតិឯកជន ហើយនៅក្នុងវិស័យនីតិឯកជននេះ ប្រសិនបើយើងបែងចែកជាច្បាប់ទូទៅ និង ជាច្បាប់ពិសេស ច្បាប់រដ្ឋប្បវេណីមានន័យថាជាច្បាប់ទូទៅនៃនីតិឯកជន។ ហេតុដូច្នេះ ដើម្បីកំណត់ឲ្យបានច្បាស់នូវខ្លឹមសារនៃច្បាប់រដ្ឋប្បវេណី ជាបឋម យើងត្រូវធ្វើការកំណត់ឲ្យច្បាស់នូវការបែងចែករវាងនីតិសាធារណៈ និង នីតិឯកជន ហើយនិងរវាងច្បាប់ទូទៅ និង ច្បាប់ពិសេស។ ក៏ប៉ុន្តែ យើងបានសិក្សាពីខាងលើរួចហើយ (ជំពូកទី ១) ពីភាពខុសគ្នានៃនីតិសាធារណៈ និង នីតិឯកជន។ ដូច្នេះ នៅពេលនេះ យើងនឹងលើកយកមកពិភាក្សាតែពីការបែងចែករវាងច្បាប់ទូទៅ និង ច្បាប់ពិសេសតែប៉ុណ្ណោះ ។

ក្នុងករណីដែលច្បាប់ទាំងឡាយណាមានកំណត់នូវវិសាលភាពច្បាស់លាស់ចំពោះមនុស្ស វត្ថុ ទីកន្លែង និង សកម្មភាពដែលជាកម្មវត្ថុនៃការអនុវត្តច្បាប់ ច្បាប់នោះហៅថា ច្បាប់ពិសេស។ ក៏ប៉ុន្តែ ប្រសិនបើមិនមានការកំណត់នូវវិសាលភាពនៃការអនុវត្តច្បាស់លាស់បែបដូច្នេះទេ ពោលគឺត្រូវយក ទៅអនុវត្ត ជាទូទៅ ច្បាប់ប្រភេទនោះហៅថា ច្បាប់ទូទៅ។ ផលប្រយោជន៍នៃការបែងចែកបែបនេះ គឺដូចដែលភាសាច្បាប់ពោលថា "ច្បាប់ពិសេសមានអាទិភាពលើច្បាប់ទូទៅ" គឺមានន័យថា ប្រសិន បើក្នុងករណីដែលមានបញ្ហាថាត្រូវអនុវត្តបទដ្ឋានច្បាប់មួយណានោះ បញ្ញត្តិច្បាប់ពិសេសត្រូវយកទៅ អនុវត្តដោយមានអានុភាពលើបញ្ញត្តិច្បាប់ទូទៅ។ អាចនិយាយបានម្យ៉ាងទៀតថា ប្រសិនបើមាន បញ្ញត្តិច្បាប់ពីរអាចយកទៅអនុវត្តចំពោះកម្មវត្ថុជាកំណត់មួយ ហើយបញ្ញត្តិច្បាប់ទាំងពីរនោះមាន ភាពផ្ទុយគ្នា គឺបញ្ញត្តិច្បាប់ពិសេសត្រូវយកទៅអនុវត្ត ។

### គ) ច្បាប់រដ្ឋប្បវេណីក្នុងឋានៈជាច្បាប់ទូទៅ

ដូច្នេះ ប្រសិនបើយើងពិនិត្យមើលពីទស្សនៈនៃការបែងចែករវាងច្បាប់ទូទៅ និង ច្បាប់ពិសេស ច្បាប់រដ្ឋប្បវេណីគឺជាច្បាប់ទូទៅនៅក្នុងវិស័យនីតិឯកជន។ មានន័យថា ច្បាប់រដ្ឋប្បវេណីត្រូវយកទៅ អនុវត្តចំពោះបុគ្គលគ្រប់រូប ដោយមិនមានការបែងចែកបុរស ឬ ស្ត្រី អាយុ ឬ ក៏មុខរបរអ្វីឡើយ។ ផ្ទុយ ទៅវិញ ច្បាប់ផ្សេងៗទៀតក្នុងវិស័យនីតិឯកជនត្រូវបានកម្រិតវិសាលភាពនៃការអនុវត្ត ទោះបីតិចក្តី ច្រើនក្តី។ ឧទាហរណ៍ នៅក្នុងទំនាក់ទំនងជាមួយច្បាប់រដ្ឋប្បវេណី ច្បាប់ពាណិជ្ជកម្ម និង ច្បាប់ផ្សេង ទៀតគឺជាច្បាប់ពិសេស។ ជាក់ស្តែង យើងសូមពន្យល់ចំពោះបញ្ហានេះ តាមករណីសិក្សាដែលក្នុង នោះ A ដែលជាអ្នកបើកហាងកាហ្វេជាលក្ខណៈឯកជនម្នាក់ បានឲ្យ B ខ្ចីប្រាក់ដែលមានមុខរបរ ដូចគ្នា។ ជាធម្មតា ក្នុងការខ្ចី និង ការឲ្យខ្ចីវត្ថុ អ្នកខ្ចីត្រូវសងវត្ថុដែលបានខ្ចីទៅអ្នកឲ្យខ្ចីវិញ ហើយចំពោះ ការខ្ចីវត្ថុដែលអាចជំនួសបាន ដូចជាប្រាក់ នៅក្រោយពេលបានប្រើប្រាស់វត្ថុដែលបានខ្ចីរួចហើយ ត្រូវ សងទៅឲ្យអ្នកឲ្យខ្ចីវិញនូវវត្ថុដែលមានប្រភេទ និង ចំនួនស្មើនឹងវត្ថុដែលបានទទួលពីអ្នកឲ្យខ្ចីនោះ ដែរ។ ការខ្ចីបែបនេះហៅថាការខ្ចីបរិភោគ។ ការខ្ចីប្រាក់គឺជាឧទាហរណ៍នៃការខ្ចីប្រាក់បរិភោគដែលត្រូវ បានគេប្រើជាញឹកញាប់ ។

ពាក់ព័ន្ធនឹងការខ្ចីបរិភោគជាប្រាក់ មាត្រា ៥៨៧ នៃក្រមរដ្ឋប្បវេណីចែងថា "ការខ្ចីបរិភោគកើតមាន អានុភាពនៅពេលដែលភាគីម្ខាងសន្យាថានឹងសងទៅឲ្យភាគីម្ខាងទៀតនូវវត្ថុដែលមានប្រភេទ គុណភាព និង ចំនួនស្មើគ្នានឹងវត្ថុដែលខ្លួនបានទទួលពីភាគីម្ខាងទៀតនោះ" ហើយជាទូទៅ ចំពោះការខ្ចីប្រាក់ ប្រសិនបើមិនមានការព្រមព្រៀងពិសេសទេ គឺត្រូវកំណត់ថាជាការខ្ចីដោយគ្មានភ្ជាប់ការប្រាក់។ ចំពោះ ការខ្ចីបរិភោគនេះ កថាខណ្ឌទី ១ មាត្រា ៥១៣ នៃក្រមពាណិជ្ជកម្មចែងថា "ចំពោះការខ្ចីប្រាក់បរិភោគ ដែលបានធ្វើឡើងរវាងពាណិជ្ជករ និង ពាណិជ្ជករ អ្នកឲ្យខ្ចីអាចទាមទារនូវការប្រាក់តាមអត្រាការប្រាក់ ដែលកំណត់ដោយច្បាប់បាន" ដូច្នេះ នៅពេលមានការខ្ចីរវាងពាណិជ្ជករ និង ពាណិជ្ជករ បើទោះបី

ជាមិនមានការព្រមព្រៀងអំពីការប្រាក់ក៏ដោយ ក៏អ្នកឲ្យខ្ចីអាចទាមទារការប្រាក់តាមអត្រាការប្រាក់ដែលកំណត់ដោយច្បាប់បានដែរ។ ការប្រាក់ដែលកំណត់ដោយច្បាប់ត្រង់នេះ មានន័យថាជាការប្រាក់ដែលអត្រារបស់វាត្រូវបានកំណត់នៅក្នុងច្បាប់ ។

បញ្ញត្តិទាំងពីរខាងលើនេះមើលទៅហាក់ដូចជាមានភាពផ្ទុយគ្នា ក៏ប៉ុន្តែ បើយើងអនុលោមទៅតាមគោលការណ៍ "ច្បាប់ពិសេសមានអាទិភាពលើច្បាប់ទូទៅ" ជាមូលដ្ឋាន គឺមាត្រា ៥១៣ ត្រូវយកទៅអនុវត្តចំពោះការខ្ចីបរិភោគរវាងពាណិជ្ជករ និង ពាណិជ្ជករ ដែលបើទោះបីជាមិនមានការព្រមព្រៀងគ្នាក៏ដោយ ក៏ A អាចទាមទារពី B នូវការប្រាក់ដែលត្រូវគណនាតាមអត្រាដែលកំណត់ដោយច្បាប់។ ម្យ៉ាងវិញទៀត ចំពោះអត្រាការប្រាក់ដែលកំណត់ដោយច្បាប់ ដោយសារតែមាត្រា ៤០៤ នៃច្បាប់រដ្ឋប្បវេណីកំណត់យក ៥% ក្នុងមួយឆ្នាំ ហើយមាត្រា ៥១៤ នៃច្បាប់ពាណិជ្ជកម្មកំណត់ ៦% ក្នុងមួយឆ្នាំ ហើយដោយសារតែច្បាប់រដ្ឋប្បវេណីជាច្បាប់ទូទៅ ហើយច្បាប់ពាណិជ្ជកម្មជាច្បាប់ពិសេស ដូច្នេះមាត្រា ៥១៤ នៃក្រមពាណិជ្ជកម្មត្រូវយកមកអនុវត្ត ។ ដូច្នេះមានន័យថា A អាចទាមទារប្រាក់ដើម ១ លានយ៉េន បូកជាមួយនឹងការប្រាក់សម្រាប់រយៈពេល ៣ ខែ ដែលត្រូវបានគណនាក្នុងអត្រា ៦ % ក្នុងមួយឆ្នាំ ដែលស្មើនឹង ១៥០០០ យ៉េនទៀត។ លើសពីនេះទៀត គាត់ក៏អាចទាមទារប្រាក់សំណងចំពោះការយឺតយ៉ាវជាសំណងការខូចខាតចំពោះការយឺតយ៉ាវដោយការមិនបានសងទៅតាមការកំណត់ពេលសងដែលបានសន្យា ដោយគណនាតាមអត្រា ៦ % ក្នុងមួយឆ្នាំ ដោយគិតចាប់ពីពេលដែលត្រូវសងរហូតដល់ពេលសងជាក់ស្តែង ។

### ឃ) ភាពមិនដាច់ខាតនៃចំណាត់ថ្នាក់រវាងច្បាប់ទូទៅ និង ច្បាប់ពិសេស

ទំនាក់ទំនងរវាងច្បាប់ទូទៅ និង ច្បាប់ពិសេសដូចខាងលើនេះ គឺមានភាពមិនច្បាស់លាស់។ ជាឧទាហរណ៍ នៅក្នុងទំនាក់ទំនងជាមួយច្បាប់រដ្ឋប្បវេណី ច្បាប់ពាណិជ្ជកម្ម គឺជាច្បាប់ពិសេស។ ក៏ប៉ុន្តែនៅក្នុងទំនាក់ទំនងជាមួយច្បាប់ស្តីពីការជួញដូរឧបករណ៍ហិរញ្ញវត្ថុវិញ ច្បាប់ពាណិជ្ជកម្មនឹងក្លាយជាច្បាប់ទូទៅ ហើយច្បាប់ស្តីពីការជួញដូរឧបករណ៍ហិរញ្ញវត្ថុគឺជាច្បាប់ពិសេស។ ម្យ៉ាងវិញទៀត ទោះបីជានៅក្នុងច្បាប់តែមួយក៏ដោយ ក៏វាមានលេចចេញនូវបញ្ញត្តិទូទៅ និង បញ្ញត្តិពិសេសដែរ។ ឧទាហរណ៍ក្នុងករណីនៃការបង្ហាញឆន្ទៈទៅអ្នកដែលនៅឆ្ងាយ តាមរយៈសំបុត្រប្រៃសណីយ៍ មាត្រា ៩៧ នៃក្រមរដ្ឋប្បវេណីចែងថា ត្រូវចាត់ទុកថាបានបង្ហាញឆន្ទៈចាប់ពីពេលដែលសំបុត្រនោះបានទៅដល់ភាគីម្ខាងទៀត។ ផ្ទុយទៅវិញ មាត្រា ៥២៦ ដែលជាបញ្ញត្តិក្នុងបញ្ញត្តិដោយឡែកស្តីពីសិទ្ធិលើបំណុល ក្រមរដ្ឋប្បវេណីចែងថា កិច្ចសន្យាត្រូវចាត់ទុកថាបានបង្កើតឡើងនៅពេលដែលភាគីដែលបានទទួលនូវសំណើសុំបង្កើតកិច្ចសន្យា បានបង្ហាញការយល់ព្រមចំពោះសំណើ ដោយការជូនដំណឹងអំពីស្វីការ។ ដូច្នេះ បញ្ញត្តិមាត្រា ៩៧ គឺជាបញ្ញត្តិទូទៅដែលត្រូវអនុវត្តជាទូទៅចំពោះអ្នកធ្វើសំណើដែលបង្ហាញ

ឆន្ទៈ រីឯបញ្ញត្តិមាត្រា ៥២៦ គឺជាបញ្ញត្តិពិសេសដែលត្រូវអនុវត្តជាពិសេសចំពោះតែស្ទីការដែលឆ្លើយតបនឹងសំណើសុំបង្កើតកិច្ចសន្យាតែប៉ុណ្ណោះ។

## ២ រចនាសម្ព័ន្ធនៃច្បាប់រដ្ឋប្បវេណី

### ក) អត្ថន័យជាទម្រង់ និង អត្ថន័យគ្រឹះនៃច្បាប់រដ្ឋប្បវេណី

ពាក្យថាច្បាប់រដ្ឋប្បវេណីមានអត្ថន័យពីរយ៉ាង ប្រសិនបើយើងពិចារណាមើលពីទស្សនៈថាតើច្បាប់រដ្ឋប្បវេណីកើតចេញពីបទដ្ឋានគតិយុត្តបែបណា។ អត្ថន័យទីមួយនៃច្បាប់រដ្ឋប្បវេណីគឺក្នុងន័យចង្អៀត គឺសំដៅលើច្បាប់ដែលមានឈ្មោះថា "ច្បាប់រដ្ឋប្បវេណី" (គឺក្រមរដ្ឋប្បវេណី)។ ច្បាប់រដ្ឋប្បវេណីក្នុងន័យបែបនេះ ហៅថាច្បាប់រដ្ឋប្បវេណីក្នុងន័យជាទម្រង់។ អត្ថន័យទីពីរនៃច្បាប់រដ្ឋប្បវេណីគឺក្នុងន័យទូលាយដែលច្បាប់រដ្ឋប្បវេណីមានន័យថាជាច្បាប់ទូទៅនៃនីតិឯកជន។ ច្បាប់រដ្ឋប្បវេណី ក្នុងន័យបែបនេះ ហៅថាច្បាប់រដ្ឋប្បវេណីក្នុងអត្ថន័យគ្រឹះ។ ជាក់ស្តែង មិនមែនមានតែច្បាប់រដ្ឋប្បវេណីប៉ុណ្ណោះទេ ប៉ុន្តែនៅមានច្បាប់ដទៃផ្សេងទៀត ដូចជាច្បាប់ស្តីពីការចុះបញ្ជីអចលនវត្ថុ ច្បាប់ស្តីពីការចាត់ចែងចំពោះវត្ថុបាត់ ច្បាប់ស្តីពីការទទួលខុសត្រូវចំពោះផលិតផល ច្បាប់ស្តីពីការចុះបញ្ជីគ្រួសារជាដើម ។

### ខ) រចនាសម្ព័ន្ធនៃក្រមរដ្ឋប្បវេណី

ក្រមរដ្ឋប្បវេណីមានបែងចែកជា ៥ គន្ថី ដែលរួមមានគន្ថីស្តីពីបទប្បញ្ញត្តិទូទៅ គន្ថីស្តីពីសិទ្ធិប្រត្យក្សគន្ថីស្តីពីសិទ្ធិលើបំណុល គន្ថីស្តីពីញាតិ និង គន្ថីស្តីពីសន្តតិកម្ម។ ការបែងចែកជាគន្ថីបែបនេះ គឺយកលំនាំតាមក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ (ដែលដើមដំបូងឡើយ យកលំនាំតាមការចងក្រងទ្រឹស្តីច្បាប់រ៉ូម៉ាំង (Pandectae ឬហៅថា Digesta) ដូច្នេះហើយទើបហៅថា ប្រព័ន្ធប៉ានដេកតេន)។ បទប្បញ្ញត្តិទូទៅគឺប្រមូលផ្តុំទៅដោយបញ្ញត្តិទូទៅដែលទាក់ទងទៅនឹងគន្ថី ក្រោយពីគន្ថីស្តីពីសិទ្ធិប្រត្យក្សតទៅ។ ហើយចំពោះសិទ្ធិ មានការបែងចែកជាសិទ្ធិប្រត្យក្ស និង សិទ្ធិលើបំណុល (ចំពោះការបែងចែកសិទ្ធិប្រត្យក្ស និង សិទ្ធិលើបំណុល នឹងមានពិភាក្សាក្នុងជំពូកទី៣) ដែលបញ្ញត្តិនីមួយៗមានចែងប្រមូលផ្តុំដោយឡែកៗក្នុងគន្ថីស្តីពីសិទ្ធិប្រត្យក្ស និង គន្ថីស្តីពីសិទ្ធិលើបំណុល។ គន្ថីស្តីពីញាតិគឺប្រមូលផ្តុំទៅដោយបញ្ញត្តិដែលពាក់ព័ន្ធជាមួយគ្រួសារ ដែលមានដូចជា សហព័ទ្ធ ឪពុកម្តាយ និង កូន ជាដើម។ គន្ថីចុងក្រោយស្តីពីសន្តតិកម្ម គឺប្រមូលផ្តុំទៅដោយបញ្ញត្តិស្តីការទទួលបន្តនូវទ្រព្យសម្បត្តិដោយសារការស្លាប់របស់មនុស្ស។ ជាទូទៅ គន្ថីបីដំបូងហៅថាច្បាប់ស្តីពីទ្រព្យសម្បត្តិ រីឯគន្ថីពីរចុងក្រោយហៅថាច្បាប់ស្តីពីគ្រួសារ (ឬច្បាប់ស្តីពីឋានៈបុគ្គល) (អត្ថន័យនៃច្បាប់ស្តីពីគ្រួសារនឹងពិភាក្សានៅក្នុងជំពូកទី ១២)។

## ៣ ប្រវត្តិនៃច្បាប់រដ្ឋប្បវេណី

## ក) មូលហេតុនៃការចងក្រងជាក្រមនៃច្បាប់រដ្ឋប្បវេណី

ដើម្បីរៀបចំប្រព័ន្ធច្បាប់ទំនើប រដ្ឋាភិបាលសម័យមេជិបានពិចារណាដល់ការបញ្ញត្តច្បាប់រដ្ឋប្បវេណី និង ច្បាប់ផ្សេងទៀត តាំងពីដើមដំបូង។ ក៏ប៉ុន្តែ ចុងបញ្ចប់ ក្រមរដ្ឋប្បវេណីបច្ចុប្បន្នត្រូវបានតាក់តែងឡើង និង ចូលជាធរមាននៅឆ្នាំ ១៨៩៨ ។

មានហេតុផលបីយ៉ាងចំពោះបញ្ហាថាតើហេតុអ្វីបានជាត្រូវការការរៀបចំប្រព័ន្ធច្បាប់ទំនើបបូករួមទាំងក្រមរដ្ឋប្បវេណី ដែលរៀនសូត្រពីបស្ចិមប្រទេស។ ហេតុផលទាំងបីនោះ គឺទី១ ភាពចាំបាច់ក្នុងការធ្វើឯកភាវូបនីយកម្មច្បាប់ក្នុងប្រទេស ទី២ គឺភាពចាំបាច់ក្នុងការលុបបំបាត់ចោលនូវរបបសក្តិភូមិដោយបង្កើតឲ្យមាននូវរបបមូលធននិយម និង ទី៣ គឺភាពចាំបាច់ក្នុងការធ្វើវិសោធនកម្មសន្ធិសញ្ញាទាំងឡាយដែលមានលក្ខណៈមិនស្មើភាព។ មូលហេតុទី៣ គឺជាហេតុផលសំខាន់បំផុតក្នុងការជម្រុញឲ្យមានការរៀបចំប្រព័ន្ធច្បាប់។ នាអំឡុងពេលចុងក្រោយនៃសម័យអេដូ សន្ធិសញ្ញាពាណិជ្ជកម្មត្រូវបានចុះហត្ថលេខាដោយរដ្ឋបាលរបស់មហាសេនាតុគូហ្គាវ៉ាជាមួយបរទេសដែលខ្លឹមសារគ្មានសមភាព ពោលគឺមានខសន្យាដែលទទួលស្គាល់យុត្តាធិការជម្រះក្តីក្រៅដែនសមត្ថកិច្ច ដោយបញ្ញត្តអំពីសិទ្ធិជំនុំជម្រះរបស់ស្ថានកុងស៊ុល ដែលធ្វើឲ្យប្រទេសជប៉ុនគ្មានសិទ្ធិជម្រះក្តី ការទទួលស្គាល់នូវរបបនៃការព្រមព្រៀងចំពោះការកំណត់ពន្ធគយដែលធ្វើឲ្យបាត់បង់អធិបតេយ្យភាពចំពោះពន្ធគយ និង បញ្ញត្តិស្តីពីឋានៈប្រទេសដែលទទួលការអនុគ្រោះបំផុតផ្នែកពាណិជ្ជកម្ម ជាដើម។ ដោយហេតុនេះហើយ នៅក្នុងរដ្ឋាភិបាលមេជិ វិសោធនកម្មសន្ធិសញ្ញាទាំងនេះគឺជាបញ្ហាប្រឈមដ៏ធំ ហើយដើម្បីសម្រេចឲ្យបាននូវគោលបំណងនេះ ចាំបាច់ត្រូវធ្វើកំណែទម្រង់ប្រព័ន្ធច្បាប់ឲ្យទៅជាប្រព័ន្ធច្បាប់មួយទំនើប ។

## ខ) ការចងក្រងជាក្រមនៃច្បាប់រដ្ឋប្បវេណីចាស់

នាដើមសម័យមេជិ ការព្យាយាមចងក្រងក្រមនៃច្បាប់រដ្ឋប្បវេណីមិនទទួលបានជោគជ័យទេ។ ដោយហេតុនេះហើយបានជានៅឆ្នាំ ១៨៨០ ចាប់ផ្តើមមានការរៀបចំសេចក្តីព្រាងក្រមរដ្ឋប្បវេណីដោយពេញលេញមួយដោយជនជាតិបារាំងម្នាក់ឈ្មោះ ប៊័រសុងណាដ (Boissonade de Fontarabie, Gustave Emile) ដែលជាទីប្រឹក្សាច្បាប់ប្រចាំនៅក្រសួងយុត្តិធម៌។ សេចក្តីព្រាងនោះបានធ្វើឡើងដោយការបកប្រែសេចក្តីព្រាងដែលលោកប៊័រសុងណាដបានរៀបចំជាភាសាបារាំង (ក៏ប៉ុន្តែ ផ្នែកស្តីពីសន្តតិកម្មនៅក្នុងគន្ថីស្តីពីលទ្ធកម្មទ្រព្យសម្បត្តិ និង គន្ថីស្តីពីឋានៈបុគ្គលត្រូវបានតាក់តែងឡើងដោយជនជាតិជប៉ុន) ហើយទីបំផុត នៅឆ្នាំ១៨៩០ គន្ថីទាំង ៥ ត្រូវបានប្រកាសឲ្យប្រើ ហើយនៅថ្ងៃទី ១ ខែមករា ឆ្នាំ ១៨៩៣ ក្រមនោះត្រូវបានចូលជាធរមាន។ ក្រមរដ្ឋប្បវេណីនេះត្រូវបានហៅថាក្រមរដ្ឋប្បវេណីចាស់ ឬ ក្រមរដ្ឋប្បវេណីប៊័រសុងណាដ។ ក្រមរដ្ឋប្បវេណីចាស់ គឺមានលក្ខណៈទំនើបនិយមដោយក្រមនេះផ្អែកលើគោលការណ៍សេរីនិយម និង បុគ្គលនិយម (individualism) ដែលក្លាយមកពី

ក្រមរដ្ឋប្បវេណីបារាំង។ម្យ៉ាងវិញទៀត ប៊ឺសុងណាដមិនមែនសិក្សាតែក្រមរដ្ឋប្បវេណីបារាំងប៉ុណ្ណោះទេ ក៏ប៉ុន្តែ គាត់ក៏បានយោងទៅលើក្រមរដ្ឋប្បវេណីអ៊ីតាលី ក្រមរដ្ឋប្បវេណីប៊ែលហ្ស៊ិក និង ក្រមផ្សេងៗទៀតដែលប្រើប្រព័ន្ធច្បាប់របស់បារាំងផងដែរ។ ចំពោះការរៀបចំជាគន្ថីមានការពិបាកក្នុងការរៀបចំជាប្រព័ន្ធជាងក្រមរបស់បារាំងដែលមានតែ ៣ គន្ថី (ការរៀបចំជាគន្ថីក្នុងក្រមរដ្ឋប្បវេណីបារាំងក៏មានឫសគល់ចេញពីច្បាប់របស់រ៉ូម៉ាំង (Institutiones) ដែរ តែវាខុសគ្នាពីក្រមរបស់អាល្លឺម៉ង់)។ ក៏ប៉ុន្តែចំណុចខ្សោយមួយចំនួនរបស់ក្រមនេះត្រូវបានគេលើកឡើងដែលចំណុចទាំងនោះរួមមានដូចជា ការខកខានមិនបានធ្វើការយោងទៅលើក្រមអង់គ្លេស និង ក្រមអាល្លឺម៉ង់ បញ្ញត្តិស្ដីពីនិយមន័យ និង គោលការណ៍មានច្រើនពេក បញ្ញត្តិដែលជាន់គ្នាមានច្រើន និង មានការពិបាកយល់ ការរៀបចំលំដាប់មិនទាន់បានគ្រប់គ្រាន់ បញ្ញត្តិដែលបានបកប្រែមកមិនច្បាស់លាស់ និង ភាពគ្មានសង្គតភាពរវាងក្រមរដ្ឋប្បវេណី និង ក្រមពាណិជ្ជកម្ម ជាដើម ។ល។

## គ) ភាពចម្រូងចម្រាស់ក្នុងក្រម

ក៏ប៉ុន្តែ ដោយសារតែក្រមរដ្ឋប្បវេណីចាស់នេះទទួលនូវឥទ្ធិពលខ្លាំងពេកពីក្រមរដ្ឋប្បវេណីបារាំង ទើបមានទស្សនៈជំទាស់ចំពោះការអនុវត្តក្រមនេះ ហើយវាក៏បានក្លាយទៅជាភាពចម្រូងចម្រាស់ដ៏ធំមួយ (នៅដើមសតវត្សទី ១៩ ដោយបានទទួលឥទ្ធិពលពីការចងក្រងក្រមរដ្ឋប្បវេណីបារាំង (ឆ្នាំ ១៨០៤) មានភាពមិនចុះសម្រុងគ្នាក្នុងសង្គមអាល្លឺម៉ង់ទាក់ទងនឹងចំណុចថាតើអាល្លឺម៉ង់គួរបញ្ញត្តក្រមរដ្ឋប្បវេណីដែរឬទេ ហើយអ្នកប្រាជ្ញច្បាប់អាល្លឺម៉ង់លោកទីបូ (Anton Friedrich Justus Thibaut) បានលើកឡើងនូវទស្សនៈថាអាល្លឺម៉ង់គួរតែចងក្រងក្រមរដ្ឋប្បវេណី ប៉ុន្តែលោកសាវីញី (Friedrich Carl von Savigny) បានជំទាស់ទៅនឹងទស្សនៈនោះ។ ភាពមិនចុះសម្រុងគ្នានេះ បើប្រៀបធៀបទៅគឺមានដូចគ្នាចំពោះក្រមរដ្ឋប្បវេណីចាស់របស់ប្រទេសជប៉ុន។ សកម្មភាពនៃក្រុមដែលទាមទារឲ្យរក្សាក្រមរដ្ឋប្បវេណីចាស់ និង ក្រុមដែលទាមទារឲ្យពន្យារការអនុវត្តក្រម បានក្លាយទៅជាភាពចម្រូងចម្រាស់យ៉ាងស្រួចស្រាវ ប៉ុន្តែ ភាពចម្រូងចម្រាស់នេះមិនមែនជាវិវាទចំពោះតែខ្លឹមសារនៃក្រមរដ្ឋប្បវេណីចាស់ប៉ុណ្ណោះទេ ប៉ុន្តែទន្ទឹមនឹងនេះវាក៏ជាវិវាទរវាងក្រុមអ្នកច្បាប់ដែលគាំទ្រទស្សនៈច្បាប់បារាំង (ក្រុមដែលទាមទារឲ្យអនុវត្ត) និង ក្រុមដែលគាំទ្រទស្សនៈច្បាប់អង់គ្លេស (ក្រុមដែលទាមទារឲ្យពន្យារការអនុវត្ត)។ ទីបំផុត នៅឆ្នាំ ១៨៩២ ការចូលជាធរមាននៃក្រមរដ្ឋប្បវេណីត្រូវបានពន្យារ ហើយក៏មានការធ្វើវិសោធនកម្ម ។

## ឃ) ការចងក្រងក្រមរដ្ឋប្បវេណីបច្ចុប្បន្ន

ដោយហេតុនេះ ទើបបានជាគណៈកម្មការស្រាវជ្រាវក្រមមួយត្រូវបានបង្កើតឡើងនៅគណៈរដ្ឋមន្ត្រី ហើយក៏មានការចាប់ផ្ដើមតាក់តែងសេចក្ដីព្រាងក្រមជាថ្មី។ សមាជិកគណៈកម្មការតាក់តែង

សេចក្តីព្រាងដែលត្រូវបានតែងតាំងនៅពេលនោះមានបីរូប គឺ ហូហ្ស៊ុមិ ណូប៊ូស៊ីហ្គេ (Hozumi Nobushige) អ៊ូមេ កេនជិរ៉ូ (Ume Kenjiro) តុមិ ម៉ាសាអាគិរ៉ា (Tomi Masa-akira) ដែលម្នាក់ៗស្ថិតនៅក្នុងវ័យជាងសាមសិបឆ្នាំ និងជាសាស្ត្រាចារ្យមហាវិទ្យាល័យច្បាប់ (បច្ចុប្បន្នជាមហាវិទ្យាល័យច្បាប់នៃសាកលវិទ្យាល័យតូក្យូ)។ ដូច្នេះហើយ ក្រមរដ្ឋប្បវេណីត្រូវបានតាក់តែងឡើងដោយមានគណៈកម្មការតាក់តែងសេចក្តីព្រាងជាអ្នកទទួលបន្ទុកធ្វើសេចក្តីព្រាងដំបូង រួចហើយបញ្ជូនទៅជជែកពិភាក្សានៅក្នុងគណៈកម្មការស្រាវជ្រាវក្រមរដ្ឋប្បវេណី។ បន្ទាប់មក បីគន្ថីដំបូងដែលបានតាក់តែងហើយនៅឆ្នាំ ១៨៩៦ (គន្ថីស្តីពីបទប្បញ្ញត្តិទូទៅ គន្ថីស្តីពីសិទ្ធិប្រត្យក្ស គន្ថីស្តីពីសិទ្ធិលើបំណុល) និងគន្ថី ២ ទៀត (គឺគន្ថីស្តីពីញាតិ និង គន្ថីស្តីពីសន្តតិកម្ម) ដែលបានបន្សល់ទុករហូតដល់ឆ្នាំ ១៨៩៨ ត្រូវបានប្រកាសឲ្យប្រើ ហើយត្រូវបានចូលជាធរមាននៅថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ១៨៩៨។ ក្រមនេះគឺជាក្រមដែលប្រើនាពេលបច្ចុប្បន្ន (ក្រមនេះត្រូវបានហៅថាក្រមសម័យមេជិ។ នាឆ្នាំ ២០០៤ វាក្យសព្ទដែលប្រើប្រាស់នៅក្នុងក្រមនេះត្រូវបានធ្វើទំនើបភាវូបនីយកម្ម ប៉ុន្តែ ដោយសារតែមិនមានការកែប្រែនូវខ្លឹមសារនៃមាត្រានីមួយៗ ទើបក្នុងសៀវភៅនេះ យើងប្រើពាក្យថាក្រមបច្ចុប្បន្ន) ។

ក្រមបច្ចុប្បន្ន គឺខុសពីក្រមចាស់ ដោយអនុម័តយកនូវរបៀបតាក់តែងតាមក្រមអាល្លឺម៉ង់ និងមានលក្ខណៈជាប្រព័ន្ធច្រើនជាង។ ម្យ៉ាងវិញទៀត វាក្យសព្ទនៅក្នុងមាត្រានីមួយត្រូវបានធ្វើឲ្យងាយស្រួលជាងមុន ហើយច្បាស់លាស់។ របបនៃការតាក់តែងក្រមគឺមិនមែនយកលំនាំតាមតែក្រមបារាំង និងអាល្លឺម៉ង់ប៉ុណ្ណោះទេ ក៏ប៉ុន្តែ ក៏បានយោងទៅក្រមរបស់ប្រទេសដទៃផ្សេងទៀតជាច្រើន (យោងទៅតាមឯកសារកំណត់ត្រាកិច្ចការប្រជុំរបស់គណៈកម្មការស្រាវជ្រាវក្រមរដ្ឋប្បវេណី យើងអាចដឹងពីមូលហេតុនៃការតាក់តែងមាត្រានីមួយៗ ហើយយើងនឹងឃើញថាមាត្រាទាំងនោះយោងទៅលើក្រមរបស់ប្រទេសជាច្រើន។)

## ង) ការកែប្រែនៅក្រោយពេលចងក្រងជាក្រម

ក្រមរដ្ឋប្បវេណីដែលបានដាក់ឲ្យអនុវត្តឆ្នាំ ១៨៩៨ នេះបានទទួលនូវការកែប្រែយ៉ាងច្រើនដើម្បីឆ្លើយតបទៅនឹងការវិវដ្តរបស់សង្គម ក៏ប៉ុន្តែមកដល់ពេលបច្ចុប្បន្ន វានៅតែរក្សាឋានៈជាក្រមរដ្ឋប្បវេណីដែលទំនើបនៅឡើយ។ ការធ្វើវិសោធនកម្មដែលសំខាន់បំផុតនាអំឡុងពេលនោះគឺការធ្វើវិសោធនកម្មទាំស្រុងនូវគន្ថីស្តីពីសន្តតិកម្ម និង គន្ថីស្តីពីគ្រួសារ ក្នុងឆ្នាំ ១៩៤៧ (ក្នុងគន្ថីទាំងនោះ ខ្លឹមសារនៃមាត្រាត្រូវបានកែប្រែទៅជាប្រយោគភាសានិយាយដែលសរសេរជាអក្សរហ៊ីរ៉ាហ្គាណា)។ ហើយនៅឆ្នាំ ២០០៤ ទំនើបកម្មវាក្យសព្ទក្រមរដ្ឋប្បវេណីមួយត្រូវបានធ្វើឡើង (ខ្លឹមសារសំខាន់គឺជាទំនើបកម្មនៃឃ្លាប្រយោគ)។ ខ្លឹមសារនៃការកែប្រែនោះរួមមានការកែប្រែខ្លឹមសារមាត្រាដែលត្រូវបានតាក់តែងជាភាសាសរសេរកាតាហ្កាណា ទៅជាប្រយោគភាសានិយាយដែលសរសេរជាអក្សរហ៊ីរ៉ាហ្កាណាវិញ ការដាក់បញ្ចូលនូវចំណងជើងនៃមាត្រានីមួយៗ និង ការផ្លាស់ប្តូរពាក្យដែលពិបាកៗទៅជាពាក្យដែលងាយ

ស្រួលយល់វិញដែលមិនមែនជាការកែប្រែនូវអត្ថន័យឡើយ លើកលែងតែការកែប្រែខ្លឹមសារលើមាត្រាមួយចំនួនដើម្បីឲ្យស្របទៅតាមការបកស្រាយនូវទ្រឹស្តី និង យុត្តិសាស្ត្រ ដែលបានចូលជាស្ថាពរ (ឧទាហរណ៍ដូចជា មាត្រា ១០៩) ។

ចំពោះការកែប្រែដាច់ដោយឡែកពីគ្នាវិញ មានដូចជាការបង្កើតថ្មីនូវរបបហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត (១៩៧១) របបដែលនៅក្រោយពេលលែងលះ សហព័ទ្ធអាចប្រើប្រាស់នូវនាមត្រកូលមុនរៀបអាពាហ៍ពិពាហ៍វិញបាន (១៩៧៦) ការកែប្រែដែលពាក់ព័ន្ធទៅនឹងវិសាលភាពនៃឧបជនដែលត្រូវបានកម្រិតសមត្ថភាព និង ការពង្រឹងការគ្រប់គ្រងនីតិបុគ្គលដែលបម្រើផលប្រយោជន៍សាធារណៈ (១៩៧៩) ការបន្ថែមនូវចំណែកមត៌ករបស់សហព័ទ្ធ (១៩៨០) ការបង្កើតថ្មីនូវរបបសុំកូនពិសេស (១៩៨៧) ការអនុម័តយកនូវរបបអាណាព្យាបាលថ្មី និង ការកែប្រែមត៌កសាសន៍ (១៩៩៩) ការកែប្រែដែលពាក់ព័ន្ធទៅនឹងសិទ្ធិប្រាតិភោគប្រត្យក្ស (២០០៣) ការកែប្រែដែលពាក់ព័ន្ធទៅនឹងការធានាបំណុលអណ្តែត (គឺធ្វើឡើងព្រមពេលជាមួយគ្នានឹងការធ្វើទំនើបកម្មឃ្លាប្រយោគ ដែលធ្វើនៅក្នុងឆ្នាំ ២០០៤) ការកែប្រែដែលពាក់ព័ន្ធទៅនឹងនីតិបុគ្គល (២០០៦) ជាដើម ដែលសុទ្ធសឹងតែជាការកែប្រែសំខាន់ៗ។

ម្យ៉ាងវិញទៀត ក្រៅពីច្បាប់រដ្ឋប្បវេណី ដូចជាច្បាប់ស្តីពីការចុះបញ្ជីអចលនវត្ថុ (ច្បាប់លេខ ២៤ ឆ្នាំ ១៨៩៩ ដែលត្រូវបានវិសោធនកម្មទាំងស្រុងទៅជាច្បាប់ លេខ ២២៣ នៅឆ្នាំ ២០០៤) ច្បាប់ស្តីពីវត្ថុបាត់ (ច្បាប់លេខ ៨៧ ឆ្នាំ ១៨៩៩) ច្បាប់ស្តីពីការតម្កល់ (ច្បាប់លេខ ១៥ ឆ្នាំ ១៨៩៩) ច្បាប់ស្តីពីការចុះបញ្ជីគ្រួសារ (ច្បាប់លេខ ១២ ឆ្នាំ ១៨៩៨។ ក៏ប៉ុន្តែ ក្នុងឆ្នាំ ១៩៤៧ ច្បាប់ស្តីពីការចុះបញ្ជីគ្រួសារថ្មីត្រូវបានបញ្ញត្តព្រមគ្នានឹងពេលធ្វើវិសោធនកម្មទាំងស្រុងលើគន្ថីស្តីពីសន្តតិកម្ម និង គន្ថីស្តីពីញាតិនៃក្រមរដ្ឋប្បវេណី) ដែលជាច្បាប់ពិសេសដែលក្រមរដ្ឋប្បវេណីបានប្រមើលមើលទុក ប៉ុន្តែទន្ទឹមនឹងនេះ ច្បាប់ពិសេសផ្សេងទៀតក៏បានបញ្ញត្តឡើងដែរ ដើម្បីដោះស្រាយបញ្ហាទាំងឡាយណាដែលមិនអាចចាត់ចែងឲ្យបានសមរម្យតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី។ ក្នុងច្បាប់ពិសេសទាំងនោះ គោលការណ៍ជាមូលដ្ឋានមួយចំនួនធំនៃក្រមរដ្ឋប្បវេណីត្រូវបានកែប្រែ។ ឧទាហរណ៍ ដូចជាច្បាប់ស្តីពីការទទួលខុសត្រូវចំពោះអគ្គិភ័យ (ច្បាប់លេខ ៤០ ឆ្នាំ ១៨៩៩) ច្បាប់ស្តីពីហ៊ីប៉ូតែកលើរោងចក្រ (ច្បាប់លេខ ៥៤ ឆ្នាំ ១៩០៥) ច្បាប់ដែលពាក់ព័ន្ធជាមួយដើមឈើ (ច្បាប់លេខ ២២ ឆ្នាំ ១៩០៩) ច្បាប់ស្តីពីការការពារអគារ (ច្បាប់លេខ ៤០ ឆ្នាំ ១៩០៩) ច្បាប់ស្តីពីការជួលដីធ្លី (ច្បាប់លេខ ៤៩ ឆ្នាំ ១៩២១) ច្បាប់ស្តីពីការជួលផ្ទះ (ច្បាប់លេខ ៥០ ឆ្នាំ ១៩២២) ច្បាប់ស្តីពីការធានាបុគ្គល (ច្បាប់លេខ ៤២ ឆ្នាំ ១៩៣៣) ច្បាប់ស្តីពីការកម្រិតអត្រាការប្រាក់ (ច្បាប់លេខ ១០០ ឆ្នាំ ១៩៥៤) ច្បាប់ស្តីពីការទិញលក់ដោយបង់រំលោះ (ច្បាប់លេខ ១៥៩ ឆ្នាំ ១៩៦១) ច្បាប់ស្តីពីសហកម្មសិទ្ធិលើអគារ (ច្បាប់លេខ ៦៩ ឆ្នាំ ១៩៦២) ច្បាប់ស្តីពីប្រតិបត្តិការពាណិជ្ជកម្មពិសេស (ច្បាប់លេខ៥៧ ឆ្នាំ ១៩៧៦។ ច្បាប់ចាស់មានឈ្មោះថា

"ច្បាប់ដែលពាក់ព័ន្ធជាមួយនឹងការលក់ទិញដោយផ្ទាល់តាមផ្ទះ" ហើយនៅឆ្នាំ ២០០០ ទើបប្តូរទៅជាឈ្មោះបច្ចុប្បន្ន) ច្បាប់ស្តីពីកិច្ចសន្យាប្រាតិភោគដោយការចុះបញ្ជីជាបណ្តោះអាសន្ន (ច្បាប់លេខ ៧៨ ឆ្នាំ ១៩៧៨) ច្បាប់ស្តីពីការជួលផ្ទះ ឬ ដី (ច្បាប់លេខ ៩០ ឆ្នាំ ១៩៩១ ជាច្បាប់ដែលជាលទ្ធផលនៃវិសោធនកម្ម និង ដាក់បញ្ចូលគ្នានូវច្បាប់ពាក់ព័ន្ធជាមួយការថែរក្សាគ្រប់គ្រងអគារ ច្បាប់ស្តីពីការជួលផ្ទះ និង ច្បាប់ស្តីពីការជួលដី) ច្បាប់ស្តីពីការទទួលខុសត្រូវលើផលិតផល (ច្បាប់លេខ ៨៥ ឆ្នាំ ១៩៩៤) ច្បាប់ដែលពាក់ព័ន្ធជាមួយការអនុវត្តជាពិសេសលើក្រមរដ្ឋប្បវេណីចំពោះល័ក្ខខ័ណ្ឌតតាំងនៃការផ្ទេរចលនវត្ថុ និង អនុប្បទានសិទ្ធិលើបំណុល (ច្បាប់លេខ ១០៤ ឆ្នាំ ១៩៩៨។ ច្បាប់ចាស់គឺ "ច្បាប់ស្តីពីបទប្បញ្ញត្តិពិសេសលើក្រមរដ្ឋប្បវេណីចំពោះល័ក្ខខ័ណ្ឌតតាំងនៃអនុប្បទានសិទ្ធិលើបំណុល"។ នៅក្នុងឆ្នាំ ២០០៤ ច្បាប់នោះ ត្រូវបានធ្វើវិសោធនកម្មព្រមគ្នាជាមួយនឹងច្បាប់ស្តីពីបទប្បញ្ញត្តិពិសេសលើក្រមរដ្ឋប្បវេណីចំពោះល័ក្ខខ័ណ្ឌតតាំងនៃការផ្ទេរចលនវត្ថុ ហើយប្តូរឈ្មោះទៅជាឈ្មោះបច្ចុប្បន្ន) ច្បាប់ស្តីពីកិច្ចសន្យាអាណាព្យាបាលដោយស្ម័គ្រចិត្ត (ច្បាប់លេខ ១៥០ ឆ្នាំ ១៩៩៩) ច្បាប់ស្តីពីកិច្ចសន្យាអ្នកប្រើប្រាស់ (ច្បាប់លេខ ៦១ ឆ្នាំ ២០០០) ច្បាប់ស្តីពីការជួញដូរឧបករណ៍ហិរញ្ញវត្ថុ (ច្បាប់លេខ ១០១ ឆ្នាំ ២០០០) ច្បាប់ស្តីពីការចុះហត្ថលេខាតាមមធ្យោបាយអេឡិកត្រូនិក និង ភារកិច្ចផ្តល់ការបញ្ជាក់ (ច្បាប់លេខ ១០២ ឆ្នាំ ២០០១) ច្បាប់ស្តីពីនីតិបុគ្គលអន្តរការី (ច្បាប់លេខ ៤៩ ឆ្នាំ ២០០១) ច្បាប់ស្តីពីបទប្បញ្ញត្តិពិសេសលើក្រមរដ្ឋប្បវេណីទាក់ទងនឹងកិច្ចសន្យាអ្នកប្រើប្រាស់តាមប្រព័ន្ធអេឡិកត្រូនិក និង ការជូនដំណឹងពីស្ទីការតាមអេឡិកត្រូនិក (ច្បាប់លេខ ៩៥ ឆ្នាំ ២០០១) និងច្បាប់ស្តីពីនិតិបុគ្គលសាជីវកម្មទូទៅ និង នីតិបុគ្គលមូលនិធិទូទៅ (ច្បាប់លេខ ៤៨ ឆ្នាំ ២០០៦។ ដោយសារច្បាប់នេះ ច្បាប់ស្តីពីនីតិបុគ្គលអន្តរការីត្រូវបានធ្វើឲ្យនិរាករណ៍) ជាដើម ។

## ៤ គោលការណ៍ជាមូលដ្ឋាននៃច្បាប់រដ្ឋប្បវេណី

ដូចបានរៀបរាប់ខាងដើម ក្រមរដ្ឋប្បវេណីជប៉ុនបានទទួលឥទ្ធិពលពីក្រមរដ្ឋប្បវេណីបារាំង និង ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ ហើយជប៉ុនក៏ទទួលបន្តនូវទស្សនៈវិជ្ជាក្នុងក្រមទាំងនោះដែរ។ ជាពិសេស គឺការរំលេចនូវគោលការណ៍សមភាព និង សេរីភាពដែលជាគោលការណ៍នៃបដិវត្តន៍បារាំង។ ចំពោះគោលការណ៍ជាមូលដ្ឋាននៃក្រមរដ្ឋប្បវេណីទាំងមូល យើងអាចលើកឡើងនូវគោលការណ៍ដូចតទៅ ។

### ក) គោលការណ៍ជាមូលដ្ឋាននៃច្បាប់ស្តីពីទ្រព្យសម្បត្តិ

ជាបឋម សូមលើកយកមកបង្ហាញជូននូវគោលការណ៍ជាមូលដ្ឋានបីនៃច្បាប់ស្តីពីទ្រព្យសម្បត្តិ ។

គោលការណ៍ទី ១ គឺគោលការណ៍ដាច់ខាតនៃកម្មសិទ្ធិ។ មានន័យថា កម្មសិទ្ធិដែលជាសិទ្ធិគ្រប់គ្រងវត្ថុ ត្រូវបានគិតថាជាសិទ្ធិដែលពេញលេញបំផុត ពោលគឺម្ចាស់កម្មសិទ្ធិអាចប្រើប្រាស់អាច

អាស្រ័យផល និង ចាត់ចែងវត្ថុដែលជាកម្មសិទ្ធិរបស់ខ្លួនបានដោយសេរី ហើយតតិយជន ទោះបីជារដ្ឋក្តី ក៏មិនអាចបំពាននូវសេរីភាពរបស់ម្ចាស់កម្មសិទ្ធិបានដែរ។ ក្នុងមាត្រា ២០៦ នៃក្រមរដ្ឋប្បវេណីដែលកំណត់អំពីខ្លឹមសារនៃកម្មសិទ្ធិមានចែងអំពីគោលការណ៍នេះ ។

គោលការណ៍ទី ២ គឺគោលការណ៍សេរីភាពក្នុងកិច្ចសន្យា។ មានន័យថា ភាគីក្នុងកិច្ចសន្យាមានសេរីភាពក្នុងការសម្រេចថាត្រូវចុះ ឬ មិនចុះកិច្ចសន្យា ត្រូវចុះជាមួយដៃគូមួយណា ហើយត្រូវចុះកិច្ចសន្យាក្នុងទម្រង់បែបណា (កិច្ចសន្យាជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់) និង ត្រូវកំណត់ខ្លឹមសារនៃកិច្ចសន្យាបែបណា។ ថ្វីត្បិតតែក្រមរដ្ឋប្បវេណីបច្ចុប្បន្នមិនមានចែងជាពិសេសអំពីគោលការណ៍នេះក៏ដោយ (ក្រមរដ្ឋប្បវេណីចាស់មានចែង) ក៏ប៉ុន្តែគោលការណ៍នេះត្រូវបានគេចាត់ទុកថាជាការពិតដែលត្រូវតែទទួលស្គាល់ជាទូទៅ ។

តាំងពីដើមដំបូង គោលការណ៍ស្វ័យភាពនៃបុគ្គលឯកជនត្រូវបានគេពិចារណាក្នុងលក្ខណៈជាគោលការណ៍មូលដ្ឋាននៃក្រមរដ្ឋប្បវេណី។ គោលការណ៍ស្វ័យភាពនៃបុគ្គលឯកជនមានន័យថា រដ្ឋមិនត្រូវធ្វើអន្តរាគមន៍យ៉ាងសកម្មចំពោះជីវិតឯកជនរបស់បុគ្គលម្នាក់ៗនោះទេ ពោលគឺត្រូវអាស្រ័យទៅលើសម្រេចតាមឆន្ទៈសេរីរបស់បុគ្គលម្នាក់ៗ (អាចហៅម្យ៉ាងទៀតបានថាគោលការណ៍ស្វ័យភាពខាងឆន្ទៈ ក៏ប៉ុន្តែមានទស្សនៈផ្សេងៗគ្នាចំពោះទំនាក់ទំនងនៃគោលការណ៍ទាំងពីរនេះ)។ គោលការណ៍សេរីភាពក្នុងកិច្ចសន្យា គឺជាទម្រង់មួយនៃគោលការណ៍ស្វ័យភាពរបស់បុគ្គលឯកជននៅក្នុងកិច្ចសន្យា។

គោលការណ៍ទី ៣ គឺគោលការណ៍ទទួលខុសត្រូវដោយកំហុស។ បានសេចក្តីថា មនុស្សគ្រប់រូបអាចធ្វើសកម្មភាពដោយសេរីបាន ហើយមានកាតព្វកិច្ចទទួលខុសត្រូវចំពោះសំណងការខូចខាតត្រឹមតែករណីដែលមានការខូចខាតចំពោះតតិយជន ដោយសារកំហុស ឬ ចេតនារបស់ខ្លួនប៉ុណ្ណោះ (ប្រសិនបើមិនមានកំហុស ឬ ចេតនាទេ ក៏មិនមានការទទួលខុសត្រូវដែរ)។ ជាពិសេស មាត្រា ៧០៩ នៃក្រមរដ្ឋប្បវេណីដែលពាក់ព័ន្ធជាមួយអំពើអនីត្យានុកូល មានចែងច្បាស់អំពីចំណុចនេះ (ចំពោះអំពើអនីត្យានុកូល នឹងមានលើកមកបង្ហាញជាលម្អិតក្នុងជំពូកទី ៩)។ មាត្រា ៤១៥ នៃក្រមរដ្ឋប្បវេណីដែលចែងពាក់ព័ន្ធជាមួយការមិនអនុវត្តកាតព្វកិច្ចទទួលស្គាល់កាតព្វកិច្ចទទួលខុសត្រូវរបស់កូនបំណុលចំពោះសំណងការខូចខាត ក្នុងករណីនៃការមិនអនុវត្តកាតព្វកិច្ចទៅតាមមូលហេតុនៃការទទួលខុសត្រូវរបស់កូនបំណុលនោះ ពោលគឺស្របទៅតាមគោលការណ៍ទទួលខុសត្រូវដោយកំហុស (ជំពូកទី ៧ នឹងមានលើកបង្ហាញជាលម្អិតអំពីការមិនអនុវត្តកាតព្វកិច្ច)។ យើងអាចនិយាយបានថា ការគោរពចំពោះស្វ័យភាពខាងឆន្ទៈរបស់បុគ្គល គឺបង្ហាញពីសង្គតភាពជាមួយនឹងគោលការណ៍សេរីភាពក្នុងកិច្ចសន្យា។

ក៏ប៉ុន្តែក្រោយមក គោលការណ៍ទាំងឡាយដែលបានរៀបរាប់ខាងលើត្រូវបានយល់ឃើញថាមិន

មានភាពដាច់ខាតទាំងស្រុងពេកនោះទេ ទើបបានជាមានការកែប្រែមួយចំនួនធំ។ ឧទាហរណ៍ដូចជាពាក់ព័ន្ធជាមួយនឹងគោលការណ៍ទី ១ ស្តីពីភាពដាច់ខាតនៃកម្មសិទ្ធិ យុត្តិសាស្ត្ររបស់តុលាការមានបន្ថែមនូវការរឹតបន្តឹងតាមគោលការណ៍គតិយុត្តស្តីពីការអនុវត្តសិទ្ធិដោយបំពាន។ យោងតាមវិសោធនកម្មក្រមរដ្ឋប្បវេណីនៅក្រោយសង្គ្រាម កថាខណ្ឌទី ៣ នៃមាត្រា ១ មានចែងកំណត់អំពីព្រំដែននៃសេរីភាពក្នុងការអនុវត្តសិទ្ធិកម្មសិទ្ធិ ហើយកថាខណ្ឌទី ១ នៃមាត្រាដដែលនេះ ក៏មានចែងផងដែរថា "ការអនុវត្តសិទ្ធិឯកជនត្រូវឲ្យស្របទៅតាមសុខុមាលភាពសាធារណៈ"។ ម្យ៉ាងវិញទៀត គោលការណ៍ទី ២ ដែលពាក់ព័ន្ធជាមួយនឹងសេរីភាពក្នុងកិច្ចសន្យាដែលមានដូចនៅក្នុងច្បាប់ជាច្រើន ដូចជាច្បាប់ស្តីពីការលក់ទិញដោយការបង់រំលោះ ច្បាប់ស្តីពីការជួលផ្ទះ និង ច្បាប់ស្តីពីការជួលដីធ្លី (បច្ចុប្បន្នគឺបានក្លាយទៅជាច្បាប់ស្តីពីការជួលដី និង ផ្ទះ) ជាដើម ដែលធ្លាប់មានគោលបំណងការពារនូវឆន្ទៈរបស់ភាគីតែម្ខាងនៃកិច្ចសន្យា ក៏ត្រូវបានកែប្រែដែរ។ មានន័យថា មានការកំណត់នូវបញ្ញត្តិដែលអនុវត្តដោយបង្ខំនៅក្នុងខ្លឹមសារជាក់លាក់នៃកិច្ចសន្យា (ក្នុងករណីដែលភាគីនៃកិច្ចសន្យាបានធ្វើការព្រមព្រៀងដែលខុសពីការកំណត់របស់បញ្ញត្តិច្បាប់ ហើយអានុភាពនៃការព្រមព្រៀងនោះត្រូវបានទទួលស្គាល់ បញ្ញត្តិនោះហៅថា បញ្ញត្តិស្ម័គ្រចិត្ត ក៏ប៉ុន្តែ ប្រសិនបើអានុភាពនៃការព្រមព្រៀងនោះមិនត្រូវបានទទួលស្គាល់ទេ បញ្ញត្តិនោះគឺជាបញ្ញត្តិដែលអនុវត្តដោយបង្ខំ) ដែលភាគីមិនអាចធ្វើការព្រមព្រៀងផ្ទុយពីនោះបាន (ឧទាហរណ៍ដូចជាមាត្រា ៩ និង មាត្រា ៣០ នៃច្បាប់ស្តីពីការជួលដី និង ផ្ទះ ជាដើម) ហើយមានការកំណត់អំពីករណីយកិច្ចពន្យល់អំពីចំណុចសំខាន់ៗនៃកិច្ចសន្យា និង ករណីយកិច្ចប្រគល់ឯកសារនៃកិច្ចសន្យា (ឧទាហរណ៍ដូចជាមាត្រា ៤ នៃច្បាប់ស្តីពីការលក់ទិញដោយការបង់រំលោះ)។ ដោយឡែកគោលការណ៍ទី ៣ ស្តីពីការទទួលខុសត្រូវដោយកំហុស អាស្រ័យដោយការប្រែប្រួលនៃសង្គម ទ្រឹស្តីនៃការទទួលខុសត្រូវដោយកំហុសមិនមានលក្ខណៈសមរម្យទេ ហើយក៏លេចចេញនូវទស្សនៈតម្រូវឲ្យមានការទទួលខុសត្រូវដាច់ខាតរបស់អ្នកប្រព្រឹត្តដោយបំពានក្នុងករណីគ្មានកំហុសក៏ដោយ។ តួយ៉ាងដូចជាករណីគ្រោះថ្នាក់ចរាចរណ៍បង្កដោយរថយន្ត និង ការបំពុលដែលបង្កឡើងដោយរោងចក្រធំៗ ជាដើម។ ហេតុដូច្នេះ ប្រសិនបើមានការខូចខាតកើតឡើងក្នុងករណីទាំងនេះ បើទោះជាគ្មានកំហុសក៏ដោយ ក៏មានច្បាប់ដែលដាក់បន្ទុកឲ្យទទួលខុសត្រូវចំពោះសំណងដែរ (មាត្រា ២៥ នៃច្បាប់ស្តីពីការទប់ស្កាត់ការបំពុលបរិយាកាស និង មាត្រា ៩ នៃច្បាប់ស្តីពីការទប់ស្កាត់ការបំពុលបរិស្ថានទឹក)។ ម្យ៉ាងវិញទៀត ដូចជាមាត្រា ៣ នៃច្បាប់ស្តីពីការធានាសំណងការខូចខាតដោយសាររថយន្ត ទទួលយកនូវទ្រឹស្តីនៃការទទួលខុសត្រូវដោយកំហុសដែរ ក៏ប៉ុន្តែ ទន្ទឹមនឹងនេះក៏មានបញ្ញត្តិដែលដាក់បន្ទុកឲ្យចារីមានករណីយកិច្ចបញ្ជាក់ពីភាពគ្មានកំហុស (បើតាមមាត្រា ៧០៩ នៃក្រមរដ្ឋប្បវេណី ជនរងគ្រោះត្រូវបញ្ជាក់បង្ហាញអំពីចេតនា ឬ កំហុសរបស់ចារី)។

### ខ) គោលការណ៍ជាមូលដ្ឋាននៃច្បាប់ស្តីពីគ្រួសារ

គន្ថីទី ៤ និង គន្ថីទី ៥ នៃក្រមរដ្ឋប្បវេណីដែលពាក់ព័ន្ធជាមួយច្បាប់ស្តីពីគ្រួសារ ត្រូវបានកែប្រែទាំងស្រុង ទៅតាមការធ្វើវិសោធនកម្មក្រមរដ្ឋប្បវេណីក្រោយសង្គ្រាម។ ច្បាប់ស្តីពីគ្រួសារមុន គឺបានឆ្លុះបញ្ចាំងពីរបបគ្រួសារជប៉ុន ដែលគោលការណ៍បុគ្គលនិយម និង សមភាពរវាងបុរស និង នារីមានភាពមិនគ្រប់គ្រាន់ (ក៏ប៉ុន្តែ បើមើលតែក្រមរដ្ឋប្បវេណីជប៉ុនតែមួយប៉ុណ្ណោះ គឺមិនអាចឃើញពីសមភាពនៃបុរស និង នារីទេ)។ ក៏ប៉ុន្តែ ក្នុងការធ្វើវិសោធនកម្មក្រមរដ្ឋប្បវេណីដែលជាផ្នែកមួយនៃប្រជាធិបតេយ្យូបនីយកម្មនៅក្រោយសង្គ្រាម ចំណុចទាំងនេះត្រូវបានធ្វើវិសោធនកម្ម (ជាពិសេសមាត្រា ២ នៃក្រមរដ្ឋប្បវេណីដែលត្រូវបានដាក់បញ្ចូលនាពេលធ្វើវិសោធនកម្មសម័យក្រោយសង្គ្រាមមានចែងអំពីគោលការណ៍នៃការធានាសេចក្តីថ្លៃថ្នូររបស់បុគ្គល និង សមភាពរបស់បុរសនារី)។ ហេតុដូច្នេះ នាពេលនេះ គោលការណ៍ជាមូលដ្ឋានពីរនៃច្បាប់ស្តីពីគ្រួសារ (ខ្លឹមសារជាក់ស្តែងនៃគោលការណ៍ទាំងពីរនេះ នឹងមានលើកមកបង្ហាញពិស្តារក្នុងជំពូកទី ១២) អាចលើកយកមកបង្ហាញដូចខាងក្រោម ។

គោលការណ៍ទី ១ គឺគោលការណ៍បុគ្គលនិយម។ បានសេចក្តីថា បុគ្គលមានអាទិភាពជាងគ្រួសារ និង សង្គម។ បើយើងយោងលើឧត្តមគតិស្តីពីការគោរពសេរីភាពបុគ្គល និង សមភាព ទស្សនៈបែបនេះគឺជារឿងធម្មតា ។

គោលការណ៍ទី ២ គឺគោលការណ៍សមភាពរវាងបុរស និង នារី។ គោលការណ៍នេះក៏ពប់បញ្ចូលទាំងសមភាព និង សេរីភាពបុគ្គលដែរ ក៏ប៉ុន្តែ តាមប្រវត្តិសាស្ត្រ មិនដែលមានសមភាពរវាងបុរស និង នារីទេ ហេតុនេះហើយបានជាត្រូវបានលើកឡើងជាពិសេសដោយឡែកពីគោលការណ៍បុគ្គលនិយម ។

✎ ច្បាប់រដ្ឋប្បវេណីក្នុងឋានៈជាច្បាប់ទូទៅ និង ច្បាប់ពាណិជ្ជកម្មក្នុងឋានៈជាច្បាប់ពិសេស--ការពិចារណាតាមរយៈករណីសិក្សា

នៅក្នុងករណីសិក្សា ដោយសារតែពេលកំណត់ដែល B បានសន្យាបានមកដល់ហើយក៏ដោយក៏គាត់នៅតែមិនទាន់សងប្រាក់ទៀត ទើប A អាចធ្វើការទាមទារឲ្យ B សងប្រាក់ដែលបានខ្ចី ១ លានយ៉េន មកវិញបាន។ ដូចបានពន្យល់ក្នុងសៀវភៅនេះស្រាប់ ក្នុងករណីនេះ បញ្ញត្តិនៃក្រមពាណិជ្ជកម្មត្រូវយកមកអនុវត្ត ដោយ A មិនត្រឹមតែអាចទាមទារឲ្យ B បង់ការប្រាក់ ៦% ក្នុងមួយឆ្នាំដែលកំណត់ដោយច្បាប់ក្នុងកិច្ចការពាណិជ្ជកម្មសម្រាប់រយៈពេល ៣ ខែ ដែលគិតមកត្រឹមពេលកំណត់ត្រូវសងប៉ុណ្ណោះទេ ក៏ប៉ុន្តែគាត់អាចទាមទារបានផងដែរនូវប្រាក់សំណងចំពោះការយឺតយ៉ាវ (សំណងការខូចខាត) ក្នុងអត្រាដូចគ្នាដោយគិតចាប់ពីក្រោយពេលកំណត់ត្រូវសង។

# ជំពូកទី ៣

## សិទ្ធិ និង កាតព្វកិច្ច

១ សិទ្ធិ និង កាតព្វកិច្ច

២ សិទ្ធិប្រត្យក្ស និង សិទ្ធិលើបំណុល

៣ ការប្រើប្រាស់សិទ្ធិដោយបំពាន

✎ ល័ក្ខខ័ណ្ឌនៃការប្រើប្រាស់សិទ្ធិដោយបំពាន --ការពិចារណាតាមរយៈករណីសិក្សា

Khmer Law's Association

ករណីសិក្សា៖ បំពង់សម្រាប់បង្ហូរទឹកក្ដៅសម្រាប់សណ្ឋាគារអុនសេន (ស្ប៉ាជប៉ុន) ដែលគ្រប់គ្រងដោយក្រុមហ៊ុន A ត្រូវបានដាក់ដំឡើងដោយឆ្លងកាត់ដីរបស់ B ដោយគ្មានការអនុញ្ញាត។ ដោយហេតុនោះទើប B បានប្ដឹងទាមទារឲ្យ A រុះរើយកបំពង់នោះចេញ។ តើការទាមទាររបស់ B ត្រូវបានទទួលស្គាល់ដែរឬទេ?

## ១ សិទ្ធិ និង កាតព្វកិច្ច

### ក) អត្ថន័យនៃសិទ្ធិ និង កាតព្វកិច្ច

មនុស្សខ្លះអាចទទួលផលប្រយោជន៍ជាក់លាក់ពីវត្ថុខ្លះ ឬ ផលប្រយោជន៍ដែលអាចទាមទារឲ្យអ្នកដទៃធ្វើ ឬ មិនធ្វើសកម្មភាពអ្វីមួយដោយផ្អែកលើបទដ្ឋានគតិយុត្តនោះ ហៅថាសិទ្ធិ រីឯចំណងដែលកើតមានចំពោះខ្លួនក្នុងការធ្វើ ឬ មិនត្រូវធ្វើសកម្មភាពអ្វីមួយ ទៅតាមការទាមទាររបស់អ្នកដទៃនោះហៅថា កាតព្វកិច្ច។ ហេតុដូច្នេះ សិទ្ធិ និង កាតព្វកិច្ច អាចហៅបានថាជាទំនាក់ទំនងដែលមានមុខពីរបាន។ បានសេចក្ដីថា សិទ្ធិគឺជាអ្វីដែលស្របនឹងបញ្ញត្តិច្បាប់ដែលត្រូវបានការពារដោយរដ្ឋ។

ឧទាហរណ៍ថា ប្រសិនបើ A កាន់កាប់ដី (ក) (បានសេចក្ដីថា ក្នុងករណីដែល A មានកម្មសិទ្ធិលើដី (ក) ) គឺ A អាចប្រើប្រាស់ដីនោះបានដោយសេរី និង អាចអាស្រ័យផលពីដីនោះបាន។ យើងអាចគិតឃើញនូវករណីជាច្រើនដូចជា គាត់អាចសាងសង់អគារ ឬ ផ្ទះនៅលើដីនោះសម្រាប់ប្រើប្រាស់ រស់នៅ ឬ ជួលដីនោះទៅឲ្យអ្នកដទៃដើម្បីគាត់ទទួលបានប្រាក់ឈ្នួល ជាដើម។ ហេតុដូច្នេះ ប្រសិនបើផលប្រយោជន៍ទាំងនោះត្រូវបានរារាំងដោយអ្នកដទៃ គាត់អាចពឹងពាក់អំណាចរបស់តុលាការ (រដ្ឋ) ដើម្បីបំបាត់នូវការរារាំងទាំងនោះ។ ដូច្នេះ ផលប្រយោជន៍ X ដែលត្រូវបានការពារដោយយោងតាមបទដ្ឋានច្បាប់ គឺជាខ្លឹមសារនៃកម្មសិទ្ធិ (ពាក់ព័ន្ធជាមួយនឹងកម្មសិទ្ធិ ជំពូកទី ៨ នឹងមានលើកយកមកបង្ហាញជាលម្អិត)។ ក្នុងករណី X លក់ដី (ក) របស់ខ្លួនទៅឲ្យ Y គឺ X ចាំបាច់ត្រូវតែប្រគល់ដីនោះទៅឲ្យ Y ហើយគាត់អាចទទួលបានថ្លៃលក់ទិញស្មើនឹងតម្លៃដីនោះពី Y ។ មានន័យថា X មានសិទ្ធិលើបំណុលដែលជាថ្លៃលក់ទិញ។ ក្នុងករណីដែល Y មិនព្រមបង់ថ្លៃលក់ទិញនោះមកឲ្យខ្លួនទេ X អាចប្ដឹងទៅតុលាការដើម្បីបង្ខំយកថ្លៃលក់ទិញនោះ។ ផលប្រយោជន៍របស់ X ដែលត្រូវបានការពារដោយបទដ្ឋានច្បាប់គឺជាខ្លឹមសារនៃសិទ្ធិលើបំណុល ។

ប្រសិនបើពិនិត្យមើលករណីសិក្សាពីទស្សនៈខាង X គឺ X ជាអ្នកមានសិទ្ធិ (គឺកម្មសិទ្ធិ និង សិទ្ធិលើបំណុល) ក៏ប៉ុន្តែ ប្រសិនបើពិនិត្យមើលពីខាង Y វិញ គឺ Y មានកាតព្វកិច្ចត្រូវបង់ថ្លៃលក់ទិញ មានន័យថា គាត់មានកាតព្វកិច្ច ។

## ២ សិទ្ធិប្រត្យក្ស និង សិទ្ធិលើបំណុល

### ក) សិទ្ធិឯកជន និង សិទ្ធិសាធារណៈ

សិទ្ធិ គឺមានសិទ្ធិតាមច្បាប់ឯកជន និង សិទ្ធិតាមច្បាប់សាធារណៈ។ សិទ្ធិតាមច្បាប់ឯកជនគឺមានន័យថាជាសិទ្ធិដែលបុគ្គលម្នាក់ៗមាននៅក្នុងទំនាក់ទំនងរវាងបុគ្គលឯកជន និង បុគ្គលឯកជន។ យោងតាមក្រមរដ្ឋប្បវេណី ជាពិសេសគឺសិទ្ធិតាមច្បាប់ឯកជន ត្រូវបានហៅថា សិទ្ធិឯកជន (ផ្ទុយទៅវិញ ចំពោះសិទ្ធិដែលកើតមានតាមច្បាប់សាធារណៈត្រូវបានហៅថា សិទ្ធិសាធារណៈ)។ កថាខណ្ឌទី ១ មាត្រា ៣ នៃក្រមរដ្ឋប្បវេណីបញ្ញត្តថា "សិទ្ធិឯកជនគឺទទួលបាននូវពេលចាប់កំណើត"។ បញ្ញត្តិនោះចែងថា នៅពេលដែលមនុស្សម្នាក់កើតមកភ្លាម គេមានសមត្ថភាពទទួលសិទ្ធិភ្លាម (ចំណុចនេះមានជដែកលម្អិតក្នុងជំពូកទី ៤) ក៏ប៉ុន្តែ សិទ្ធិដែលជាកម្មវត្ថុនៃការទទួលនេះគឺជាសិទ្ធិតាមច្បាប់ឯកជន ហើយសិទ្ធិតាមច្បាប់ សាធារណៈមិនត្រូវបានរាប់បញ្ចូលទេ ។

### ខ) សិទ្ធិប្រត្យក្ស និង សិទ្ធិលើបំណុល

សិទ្ធិតាមច្បាប់ឯកជនដែលរៀបរាប់ខាងលើ ត្រូវបានបែងចែកជាសិទ្ធិប្រត្យក្ស និង សិទ្ធិលើបំណុល។ ជាទូទៅ សិទ្ធិប្រត្យក្សគឺសំដៅលើសិទ្ធិគ្រប់គ្រងវត្ថុដោយចំពោះ។ ឧទាហរណ៍ថា មានកម្មសិទ្ធិលើវត្ថុរូបិយណាមួយ ដូច្នេះ កម្មសិទ្ធិករនៃវត្ថុនោះអាចគ្រប់គ្រងដោយសេរីលើវត្ថុដែលជារបស់ខ្លួននោះបាន ដោយមិនមានការជ្រៀតជ្រែកពីអ្នកដទៃ។ ជាក់ស្តែងគឺគាត់អាចប្រើប្រាស់ចាត់ចែង និង អាចលក់វត្ថុនោះបាន។ ដោយឡែកសិទ្ធិលើបំណុលវិញ មានន័យថាជាសិទ្ធិដែលអាចទាមទារឲ្យបុគ្គលណាម្នាក់ធ្វើសកម្មភាពអ្វីមួយ ។

ឧទាហរណ៍ អ្នកដែលបានជួលក្រុមហ៊ុនសំណង់ឲ្យសង់អគារឲ្យខ្លួន (កិច្ចសន្យាមួយដែលភាគីម្ខាងមានកាតព្វកិច្ចសម្រេចការងារដែលបានព្រមព្រៀង ហើយភាគីម្ខាងទៀតមានកាតព្វកិច្ចផ្តល់កម្រៃចំពោះលទ្ធផលការងារដែលបានធ្វើនោះ ហៅថា កិច្ចសន្យាម៉ៅការ) អាចទាមទារឲ្យក្រុមហ៊ុនសំណង់សង់អគារទៅតាមការសន្យា។ មានន័យថា សិទ្ធិលើបំណុលដែលមានចំពោះក្រុមហ៊ុនសាងសង់ គឺសិទ្ធិទាមទារឲ្យសង់អគារ។ ដូច្នេះ អ្នកដែលមានសិទ្ធិលើបំណុល គឺជាម្ចាស់បំណុល។ ប្រសិនបើយើងមើលពីខាងក្រុមហ៊ុនសំណង់វិញ គឺក្រុមហ៊ុនសំណង់មានកាតព្វកិច្ចសាងសង់អគារទៅតាមការបញ្ជា។ កាតព្វកិច្ចសាងសង់នេះគឺជាបំណុល រីឯអ្នកដែលមានកាតព្វកិច្ចគឺជាកូនបំណុល ។

ម្យ៉ាងវិញទៀត ចំពោះការឲ្យខ្ចី និង ខ្ចីប្រាក់ (ការខ្ចីបរិភោគ) អ្នកឲ្យខ្ចីអាចទាមទារឲ្យអ្នកខ្ចីសងមកខ្លួនវិញ។ មានន័យថា អ្នកឲ្យខ្ចីមានសិទ្ធិទាមទារអ្នកខ្ចីឲ្យសងប្រាក់កម្ចីមកខ្លួនវិញ។ ហេតុដូច្នេះ

ប្រសិនបើយើងមើលពីខាងអ្នកខ្ចីទៅ គឺអ្នកខ្ចីមានកាតព្វកិច្ចសងប្រាក់ទៅអ្នកឲ្យខ្ចីវិញ។ ករណីយកិច្ចបែបនេះ ហៅថា កាតព្វកិច្ច។ ជាសរុបមក អ្នកឲ្យខ្ចីគឺជាម្ចាស់បំណុល រីឯអ្នកខ្ចីគឺជាកូនបំណុល។

ថ្វីត្បិតតែមិនមានភាពខុសគ្នារវាងសិទ្ធិប្រត្យក្ស និង សិទ្ធិលើបំណុលទាក់ទងនឹងចំណុចដែលមានការការពារតាមផ្លូវច្បាប់នូវផលប្រយោជន៍របស់ម្ចាស់សិទ្ធិក៏ដោយ ក៏ប៉ុន្តែខ្លឹមសារនៃសិទ្ធិទាំងពីរនេះគឺមានចំណុចខុសគ្នាច្រើន។

## គ) ភាពដាច់ខាត និង ភាពមិនដាច់ខាត

ភាពខុសគ្នាជាសារវន្តនៃសិទ្ធិទាំងពីរ គឺសិទ្ធិប្រត្យក្សត្រូវបានទទួលស្គាល់នូវភាពដាច់ខាត រីឯសិទ្ធិលើបំណុលមិនមានភាពដាច់ខាតទេ គឺមានតែភាពមិនដាច់ខាតប៉ុណ្ណោះដែលត្រូវបានទទួលស្គាល់។ សិទ្ធិប្រត្យក្សដែលមានភាពដាច់ខាត មានន័យថា ម្ចាស់សិទ្ធិប្រត្យក្ស អាចអះអាងអំពីការដែលខ្លួនមានសិទ្ធិប្រត្យក្សចំពោះគ្រប់បុគ្គលដទៃបាន។ ឧទាហរណ៍ កម្មសិទ្ធិករអាចអះអាងអំពីកម្មសិទ្ធិរបស់ខ្លួនចំពោះគ្រប់បុគ្គលដទៃបាន។ ប្រសិនបើនិយាយផ្ទុយមកវិញ គឺថាបុគ្គលដែលមិនមែនជាកម្មសិទ្ធិករត្រូវតែគោរពសិទ្ធិលើកម្មសិទ្ធិរបស់កម្មសិទ្ធិករជាដាច់ខាត (ទាក់ទងនឹងកម្មសិទ្ធិនេះ ហៅថា គោលការណ៍ដាច់ខាតនៃកម្មសិទ្ធិដែលជាគោលការណ៍មូលដ្ឋានមួយនៃក្រមរដ្ឋប្បវេណី។ សូមមើលជំពូកទី ២។) ដោយហេតុនេះ ប្រសិនបើមានករណីរារាំងនូវការអនុវត្តសិទ្ធិលើកម្មសិទ្ធិកើតឡើង កម្មសិទ្ធិករអាចប្ដឹងទៅតុលាការដើម្បីទាមទារឲ្យបញ្ឈប់ការរារាំងនោះបាន។

ដោយឡែកចំពោះសិទ្ធិលើបំណុលដែលមានត្រឹមតែភាពមិនដាច់ខាតវិញ គឺមានន័យថាទំនាក់ទំនងមានត្រឹមតែរវាងម្ចាស់សិទ្ធិជាកំណត់ (ម្ចាស់បំណុល) និង អ្នកមានកាតព្វកិច្ចជាកំណត់ (កូនបំណុល) តែប៉ុណ្ណោះ ពោលគឺមិនមានទំនាក់ទំនងជាមួយបុគ្គលដទៃទេ។ អាចនិយាយបានម្យ៉ាងទៀតថា ម្ចាស់បំណុលអាចទាមទារបានត្រឹមតែឲ្យកូនបំណុលអនុវត្តកាតព្វកិច្ចតែប៉ុណ្ណោះ ក្រៅពីនោះគឺមិនអាចធ្វើការទាមទារបែបនេះទៅតតិយជនបានទេ។ ដូចជាក្នុងករណីសិក្សាស្ដីពីកិច្ចសន្យាម៉ៅការដែលបានលើកឡើងជាឧទាហរណ៍ពីខាងដើម ម្ចាស់ការមិនអាចទាមទារទៅក្រុមហ៊ុនសំណង់ផ្សេងឲ្យសាងសង់អគារឲ្យខ្លួនក្រៅពីកូនបំណុល (អ្នកម៉ៅការ) បានឡើយ។ ម្យ៉ាងវិញទៀត នៅក្នុងករណីការខ្ចីបរិភោគ អ្នកឲ្យខ្ចីមិនអាចទាមទារឲ្យអ្នកផ្សេង (ឧទាហរណ៍ដូចជាឪពុកម្ដាយរបស់អ្នកខ្ចី ជាដើម) ក្រៅពីអ្នកខ្ចីសងប្រាក់មកខ្លួនវិញបានទេ ។

## ឃ) ភាពផ្ដាច់មុខ

ចំណុចខុសគ្នាបន្ទាប់មកទៀត គឺសិទ្ធិប្រត្យក្សមានភាពផ្ដាច់មុខ រីឯសិទ្ធិលើបំណុលវិញមិនមានភាពផ្ដាច់មុខទេ។ ភាពផ្ដាច់មុខចំពោះសិទ្ធិមួយមានន័យថា ភាពរារាំងមិនឲ្យមានសិទ្ធិដូចគ្នាណាមួយ

ជាន់គ្នាជាមួយនឹងសិទ្ធិនោះ។ ដោយឡែកភាពផ្ដាច់មុខមានចំពោះសិទ្ធិប្រត្យក្សមានន័យថា មិនអាចទទួលស្គាល់ឲ្យបង្កើតសិទ្ធិមួយទៀតដែលមានខ្លឹមសារដូចគ្នាលើវត្ថុតែមួយបានទេ (មានន័យថា វត្ថុមួយមានសិទ្ធិមួយ)។ ភាពផ្ដាច់មុខបែបនេះមិនត្រូវបានទទួលស្គាល់ចំពោះសិទ្ធិលើបំណុលទេ ហើយបើទោះបីជាអាចមានករណីដែលមិនអាចសម្រេចសិទ្ធិណាមួយក្នុងចំណោមសិទ្ធិទាំងឡាយក៏ដោយ ក៏សិទ្ធិលើបំណុលដែលមានខ្លឹមសារតែមួយដូចគ្នាអាចត្រូវបង្កើតឡើងជាច្រើនបានដែរ។ ឧបមាថា មានអ្នកនិពន្ធប្រលោមលោកម្នាក់បានចុះកិច្ចសន្យាថាផ្ដល់បទឧទ្ទេសនាមមួយនៅសាប៉ូរ៉ូ ហើយគាត់បានចុះកិច្ចសន្យាជាមួយអ្នកផ្សេងទៀតថាទៅផ្ដល់បទឧទ្ទេសនាមនៅថ្ងៃជាមួយគ្នានៅហ្វុគូអូកា ក្នុងករណីបែបនេះភាពមុន ឬ ក្រោយនៃកិច្ចសន្យា មិនជាបញ្ហាទេ ដោយទំនាក់ទំនងរវាងសិទ្ធិលើបំណុល និងកាតព្វកិច្ចទាំងពីរត្រូវបានទទួលស្គាល់ថាមានសុពលភាពពេញលេញ។ មានន័យថា សិទ្ធិលើបំណុលទាំងពីរ (ភាគីម្ខាងទៀតនៃកិច្ចសន្យាអាចទាមទារឲ្យអ្នកនិពន្ធប្រលោមលោកនោះទៅធ្វើបទឧទ្ទេសនាមបាន) មានសុពលភាពពេញលេញ។ ប្រសិនបើអ្នកនិពន្ធប្រលោមលោកទៅធ្វើបទឧទ្ទេសនាមនៅសាប៉ូរ៉ូ គឺគាត់មិនអាចទៅធ្វើបទឧទ្ទេសនាមនៅហ្វុគូអូកាបានទេ ដូច្នេះគឺមានបញ្ហាសំណងការខូចខាតដោយសារការមិនបានអនុវត្តកាតព្វកិច្ច (សេចក្ដីលម្អិត សូមអានជំពូកទី ៧) ។

### ង) គោលការណ៍នៃការកំណត់សិទ្ធិប្រត្យក្សដោយច្បាប់

ដើម្បីឲ្យអាចទទួលស្គាល់បាននូវភាពដាច់ខាត និង ភាពផ្ដាច់មុខ ចំពោះសិទ្ធិប្រត្យក្សបែបនេះ សិទ្ធិប្រត្យក្សត្រូវមានឥទ្ធិពលខ្លាំងក្លាចំពោះតតិយជនផ្សេងក្រៅពីម្ចាស់សិទ្ធិប្រត្យក្ស។ ដោយហេតុនេះ សិទ្ធិប្រត្យក្សមិនអាចត្រូវបានបង្កើតឡើងដោយសេរីក្រៅពីតាមការកំណត់របស់ក្រមរដ្ឋប្បវេណី និងតាមការកំណត់របស់ច្បាប់ផ្សេងឡើយ (មាត្រា ១៧៥ នៃក្រមរដ្ឋប្បវេណី)។ គោលការណ៍នេះហៅថា គោលការណ៍កំណត់សិទ្ធិប្រត្យក្សដោយច្បាប់។ ផ្ទុយទៅវិញ ដោយសារតែសិទ្ធិលើបំណុលគឺជាភាពជាប់ពាក់ព័ន្ធគ្នារវាងកូនបំណុល និង ម្ចាស់បំណុល ទើបឥទ្ធិពលដែលមានចំពោះតតិយជនមិនធំធេងទេ។ ហេតុនេះហើយ ទើបគេអាចគិតបានថា ភាគីអាចបង្កើតសិទ្ធិលើបំណុលបានដោយសេរី។ ការទទួលស្គាល់នូវសេរីភាពបែបនេះ គឺជាគោលការណ៍សេរីភាពក្នុងកិច្ចសន្យា។ ថ្វីបើមិនមានបញ្ញត្តិច្បាស់លាស់នៅក្នុងក្រមរដ្ឋប្បវេណីក៏ដោយ ក៏គេអាចគិតឃើញដែរថា គោលការណ៍បែបនោះគឺជាការធម្មតា។

## ៣ ការប្រើប្រាស់សិទ្ធិដោយបំពាន

យោងតាមទស្សនៈគតិយុត្តបុគ្គលនិយម នាពេលបច្ចុប្បន្ន សិទ្ធិ ជាពិសេសគឺសិទ្ធិឯកជន គឺជាវត្ថុដាច់ខាតដែលមិនត្រូវមានការបំពានណាមួយពីជនដទៃឡើយ។ ជាឧទាហរណ៍ តាមរយៈបដិវត្តន៍បារាំង សេចក្ដីប្រកាសស្ដីពីសិទ្ធិមនុស្សត្រូវបានធ្វើឡើង ហើយក្រោយមក ក្រមរដ្ឋប្បវេណីបារាំង (មាត្រា ៥៥៤)

ក៏បានឆ្លុះបង្ហាញច្បាស់លាស់អំពីចំណុចនេះ។ ដោយឡែកមាត្រា ២០៦ ក្រមរដ្ឋប្បវេណីជប៉ុនក៏មានចែង នូវខ្លឹមសារដូចគ្នានេះដែរ ។

## ក) ភាពលក្ខណៈជាសង្គមនៃសិទ្ធិ

ក៏ប៉ុន្តែ ព្រមគ្នាជាមួយនឹងការវិវឌ្ឍសម័យកាល ភាពលក្ខណៈជាសង្គម និង ភាពជាសាធារណៈនៃសិទ្ធិឯកជនត្រូវបានគេលើកឡើងជាសំខាន់ ។ មានន័យថា គេមិនអាចគិតទៅដល់បុគ្គលឯកជនដោយបែងចែកបុគ្គលចេញពីសង្គម ឬ រដ្ឋទេ ពោលគឺគេចាំបាច់ត្រូវគិតថា តើត្រូវគោរពនូវផលប្រយោជន៍របស់បុគ្គលឯកជនដែលនៅក្នុងជីវភាពសង្គមបែបណា។ មាត្រា ១ នៃក្រមរដ្ឋប្បវេណីដែលត្រូវបានដាក់បញ្ចូលថ្មីនាពេលវិសោធនកម្មក្រោយសម័យសង្គ្រាមបានប្រកាសអំពីភាពលក្ខណៈជាសង្គមនៃសិទ្ធិឯកជននោះ។ កថាខណ្ឌទី ១ នៃមាត្រាដដែលមានចែងអំពីគោលការណ៍ថា សិទ្ធិឯកជនត្រូវស្របជាមួយនឹងសុខុមាលភាពសាធារណៈ។ មានន័យថា សិទ្ធិឯកជនមិនមែនគឺដើម្បីការពារតែផលចំណេញ និង ផលប្រយោជន៍ឯកជនតែប៉ុណ្ណោះទេ ក៏ប៉ុន្តែ វាត្រូវស្របជាមួយនឹងផលប្រយោជន៍របស់សង្គមទាំងមូលផងដែរ។ កថាខណ្ឌទី ២ បញ្ញត្តថាការប្រើសិទ្ធិ ឬ អនុវត្តកាតព្វកិច្ច ត្រូវស្របទៅតាមគោលការណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់ (ជាញឹកញាប់ គេប្រើកាត់មកត្រឹមគោលការណ៍នៃភាពសុចរិត)។ ដោយហេតុនេះហើយ កថាខណ្ឌទី ៣ បានហាមនូវការប្រើប្រាស់សិទ្ធិដោយបំពាន ។

## ខ) ការប្រើប្រាស់សិទ្ធិដោយបំពាន

ការប្រើសិទ្ធិដោយបំពានក្នុងន័យនេះគឺមើលពីខាងក្រៅទៅឃើញថាជាការប្រើប្រាស់សិទ្ធិ ក៏ប៉ុន្តែជាក់ស្តែងការអនុវត្តនូវសិទ្ធិនោះគឺហួសពីទំហំដែលដែលសមរម្យ។ បានសេចក្តីថា ល័ក្ខខ័ណ្ឌសត្យានុម័ត និង ល័ក្ខខ័ណ្ឌអត្តនោម័តមានភាពចាំបាច់ ។

ល័ក្ខខ័ណ្ឌសត្យានុម័ត គឺផលប្រយោជន៍ដែលម្ចាស់សិទ្ធិអាចទទួលបាន ដោយផ្អែកទៅលើការទទួលស្គាល់ការប្រើប្រាស់សិទ្ធិ (ឬក៏ការខូចខាតដែលទទួលរងដោយសារតែការប្រើប្រាស់សិទ្ធិរបស់ម្ចាស់សិទ្ធិត្រូវបានរារាំង) អាចពិចារណាដោយការប្រៀបធៀបជាមួយនឹងការខាតបង់ដែលទទួលរងដោយអ្នកដទៃ ដែលជាលទ្ធផលនៃការអនុវត្តសិទ្ធិ។ បើទោះជាផលប្រយោជន៍ដែលទទួលបាននោះតិចតួចក៏ដោយ ក៏ប៉ុន្តែប្រសិនបើការខាតបង់នោះមានទំហំធំធេងពេក ការអនុវត្តសិទ្ធិបែបនោះជាការប្រើសិទ្ធិដោយបំពានដែលមិនអាចទទួលយកបានឡើយ។ ចំពោះល័ក្ខខ័ណ្ឌអត្តនោម័តវិញ គឺអាចពិចារណាបានថាតើម្ចាស់សិទ្ធិអាចអនុវត្តសិទ្ធិរបស់ខ្លួនដោយចេតនារបៀបណា។ ក្នុងករណីបើមានចេតនាត្រឹមតែផ្តល់ឲ្យអ្នកដទៃនូវការខូចខាត ឬ ករណីដែលមានបំណងទទួលសេចក្តីចម្រើនដោយឥតហេតុ ជាដើម គឺត្រូវវិនិច្ឆ័យថាជាការប្រើប្រាស់សិទ្ធិដោយបំពាន ។

ទ្រឹស្តីគតិយុត្តដែលពាក់ព័ន្ធជាមួយការប្រើប្រាស់សិទ្ធិដោយបំពានត្រូវបានទទួលស្គាល់ដោយទ្រឹស្តី និង យុត្តិសាស្ត្រតាំងពីសម័យមុនសង្គ្រាម ក៏ប៉ុន្តែនៅក្នុងយុត្តិសាស្ត្ររបស់តុលាការ បើគិតពិចារណាទាំងល័ក្ខខ័ណ្ឌអត្តនោម័ត និង ល័ក្ខខ័ណ្ឌសត្យានុម័ត និន្នាការគឺមានការវិវដ្តឆ្ពោះទៅរកទិសដៅដែលផ្តល់តម្លៃទៅលើល័ក្ខខ័ណ្ឌសត្យានុម័តជាង ។

### ✎ ល័ក្ខខ័ណ្ឌនៃការប្រើប្រាស់សិទ្ធិដោយបំពាន...ការពិចារណាតាមរយៈករណីសិក្សា

ប្រសិនបើយើងពិចារណាដោយផ្អែកលើករណីសិក្សាថាតើអាចទទួលស្គាល់ថាមានការប្រើប្រាស់សិទ្ធិដោយបំពានដែរ ឬ យ៉ាងណានោះ គឺយើងនឹងឃើញដូចខាងក្រោម។ ជាបឋម ចំពោះល័ក្ខខ័ណ្ឌសត្យានុម័ត ការខូចខាតដែល B បានទទួលដោយសារដីរបស់ B ត្រូវបានប្រើប្រាស់ដោយគ្មានការអនុញ្ញាត ព្រមជាមួយនឹងការដកយកបំពង់បង្ហូរទឹកក្តៅចេញ និង ការខាតបង់របស់ A ចំពោះការយកបំពង់ទៅដំឡើងកន្លែងផ្សេង គឺនឹងក្លាយទៅជាការប្រៀបធៀប។ ដោយឡែកចំពោះល័ក្ខខ័ណ្ឌអត្តនោម័តវិញ ចេតនារបស់ B ដែលទាមទារឲ្យដកយកបំពង់ចេញនឹងត្រូវបានធ្វើការពិចារណា។ ឧទាហរណ៍ថា ប្រសិនបើមានស្ថានភាពដែលត្រូវបានទទួលស្គាល់យ៉ាងដូច្នេះថា ដីដែលមានបញ្ហានេះស្ទើរតែគ្មានតម្លៃសម្រាប់ប្រើប្រាស់អ្វីសោះ ហើយការដកបំពង់នោះចេញយកទៅដំឡើងនៅកន្លែងផ្សេងគឺត្រូវចំណាយសោហ៊ុយច្រើនពេក រីឯការដែល B ទាមទារឲ្យដកបំពង់ចេញនោះគឺដោយសារតែ A បដិសេធមិនព្រមទិញដីនោះក្នុងតម្លៃខ្ពស់ នោះការទាមទាររបស់ B ដោយសំអាងលើការប្រើប្រាស់សិទ្ធិដោយបំពានគឺមិនអាចអនុញ្ញាតបានឡើយ ។

Khmer Law's Association

# ជំពូកទី ៤

# សកម្មភាពគតិយុត្ត

## ១ កិច្ចសន្យា និង សកម្មភាពគតិយុត្ត

(១) ការបង្ហាញឆន្ទៈ កិច្ចសន្យា និង សកម្មភាពគតិយុត្ត

(២) សណ្តាប់ធ្នាប់សាធារណៈ ទំនៀមទម្លាប់ល្អ និង សមភាព

(៣) ការបង្ហាញឆន្ទៈដែលមានវិការៈ

(៤) មោឃភាព និង ការលុបចោល

## ២ សមត្ថភាពទទួលសិទ្ធិ សមត្ថភាពខាងឆន្ទៈ និង សមត្ថភាពក្នុងការធ្វើសកម្មភាពគតិយុត្ត

(១) សមត្ថភាពទទួលសិទ្ធិ

(២) សមត្ថភាពខាងឆន្ទៈ និង សមត្ថភាពក្នុងការធ្វើសកម្មភាព

✎ សកម្មភាពគតិយុត្តរបស់អនីតិជន-- ការពិចារណាតាមរយៈករណីសិក្សា

ករណីសិក្សា៖ A ជាអនីតិជន បានលក់ដីកម្មសិទ្ធិ (ក) របស់ខ្លួនទៅ B និង បានចុះបញ្ជីផ្ទេរ។ តើ C និង D ដែលជាអ្នកមានអំណាចមេបាលើ A អាចលុបចោលកិច្ចសន្យាលក់ទិញនោះបានដែរឬទេ ?

## ១ កិច្ចសន្យា និង សកម្មភាពគតិយុត្ត

### (១) ការបង្ហាញឆន្ទៈ កិច្ចសន្យា និង សកម្មភាពគតិយុត្ត

#### ក) ការបង្ហាញឆន្ទៈ

តាមក្រមរដ្ឋប្បវេណី ការបង្ហាញ (សកម្មភាពបង្ហាញ) ទៅខាងក្រៅនូវឆន្ទៈ (ឆន្ទៈខាងក្នុង) ដែលធ្វើឲ្យកើតឡើងនូវអានុភាពតាមផ្លូវច្បាប់ ហៅថា ការបង្ហាញឆន្ទៈ។ ដូច្នេះ អ្នកដែលបានបង្ហាញឆន្ទៈ ហៅថា អ្នកបង្ហាញឆន្ទៈ។ ឧទាហរណ៍ ឆន្ទៈដែលបានបង្ហាញទៅខាងក្រៅ (ឧទាហរណ៍ថាដោយការនិយាយផ្ទាល់មាត់ ឬ ដោយការសរសេរលើក្រដាស ជាដើម) ថាចង់លក់របស់មួយ ឬ ចង់ទិញរបស់មួយ គឺជាការបង្ហាញឆន្ទៈ។ មានន័យថា ឆន្ទៈមុនគឺជាឆន្ទៈរបស់អ្នកលក់ រីឯឆន្ទៈក្រោយគឺជាឆន្ទៈរបស់អ្នកទិញ។ កិច្ចសន្យាគឺជាភាពត្រូវគ្នានៃការបង្ហាញឆន្ទៈដែលមកពីទិសដៅផ្ទុយគ្នាបែបនេះ ។

ដោយឡែកអ្នកក្រៅពីអ្នកបង្ហាញឆន្ទៈ ការយល់ដឹងអំពីឆន្ទៈខាងក្នុងរបស់អ្នកបង្ហាញឆន្ទៈគឺមិនមែនជាការងាយស្រួលឡើយ។ គ្មានមធ្យោបាយផ្សេងដែលអាចស្មានយល់ពីឆន្ទៈខាងក្នុងបានឡើយ លើកលែងតែត្រូវបានបង្ហាញមកខាងក្រៅ។ ក៏ប៉ុន្តែ បន្ទុកនៃទំនាក់ទំនងរវាងការបង្ហាញឆន្ទៈមកខាងក្រៅ និង ឆន្ទៈខាងក្នុងនីមួយៗមានផ្សេងៗគ្នា។ ករណីនេះគឺជាបញ្ហានៃការបង្ហាញឆន្ទៈដែលមានវិការៈដែលនឹងលើកយកមកពិភាក្សាពេលក្រោយ ។

#### ខ) កិច្ចសន្យា និង សកម្មភាពគតិយុត្ត

បញ្ហានៅក្នុងករណីសិក្សាខាងលើគឺជាបញ្ហាកិច្ចសន្យា។ នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ពាក្យថា ការលក់ទិញ ឬ កិច្ចសន្យាលក់ទិញត្រូវបានប្រើប្រាស់ជាប់ជាប្រចាំ។ ក្រៅពីការលក់ទិញ ក៏មានកិច្ចសន្យាប្រភេទច្រើនផ្សេងទៀតដូចជា ភតិសន្យា (ការជួល ឬ ការឲ្យជួលវត្ថុ ដោយអ្នកជួលត្រូវបង់ប្រាក់ឈ្នួល) កិច្ចសន្យាខ្ចីបរិភោគ (ការខ្ចី និង ការឲ្យខ្ចីប្រាក់ ជាដើម )។

សកម្មភាពដែលបង្កើតឲ្យមានអានុភាពតាមផ្លូវច្បាប់មិនកម្រិតត្រឹមតែកិច្ចសន្យាប៉ុណ្ណោះទេ។ ជាឧទាហរណ៍ ដូចជាក្នុងករណីដែលអ្នកឲ្យខ្ចីប្រាក់មិនតម្រូវឲ្យអ្នកខ្ចីបង់ប្រាក់មកខ្លួនវិញជាដើម បើទោះបីជាមិនមានការព្រមព្រៀងពីអ្នកខ្ចីក៏ដោយ ក៏អានុភាពលើកលែងបំណុលកើតមានឡើងដែរ។ មានន័យថា មានការបង្ហាញឆន្ទៈរបស់បុគ្គលតែម្នាក់ ក៏អានុភាពតាមផ្លូវច្បាប់កើតមានឡើងដែរ។ សកម្មភាព

បែបនេះ ហៅថា សកម្មភាពឯកតោភាគី។ ការលើកលែងបំណុល ឬ ការលុបចោលនូវកិច្ចសន្យាជាដើម គឺជាឧទាហរណ៍នៃសកម្មភាពឯកតោភាគីនោះ ។

លើសពីនេះទៅទៀត ទ្រឹស្តីទទួលស្គាល់ទស្សនាទានស្តីពីសកម្មភាពរួមគ្នា។ ឧទាហរណ៍នៃសកម្មភាពរួមគ្នាមានដូចជាសកម្មភាពបង្កើតស្ថាប័ន ដូចជាក្រុមហ៊ុន ជាដើម។ ចំណុចរួមរវាងកិច្ចសន្យា និង សកម្មភាពរួមគ្នាគឺការបង្ហាញឆន្ទៈច្រើនដែលត្រូវគ្នា ក៏ប៉ុន្តែ ក្នុងកិច្ចសន្យាគឺភាគីមានជំហរផ្សេងៗគ្នា ហើយនៅក្នុងសកម្មភាពរួមគ្នាវិញ គឺភាគីជាច្រើននោះមានជំហរដូចគ្នា។ ឧទាហរណ៍នៅក្នុងកិច្ចសន្យាលក់ទិញ ចំពោះអ្នកលក់ ប្រសិនបើអាចលក់ក្នុងតម្លៃថ្លៃបានគឺជាការប្រសើរ ដោយឡែកចំពោះអ្នកទិញវិញ ប្រសិនបានក្នុងតម្លៃទាបគឺល្អ បែបនេះគឺជាជំហររបស់អ្នកលក់ និង អ្នកទិញគឺខុសគ្នា។ ផ្ទុយទៅវិញ នៅក្នុងការបង្កើតស្ថាប័ន គ្រប់ភាគីទាំងអស់គឺមានជំហរត្រូវគ្នា។ ដូច្នេះ នៅក្នុងកិច្ចសន្យាភាគីទាំងសងខាងបង្ហាញឆន្ទៈដោយឡែកៗទៅភាគីម្ខាងទៀត ដែលមានទិសដៅផ្ទុយគ្នា ប៉ុន្តែនៅក្នុងសកម្មភាពរួមគ្នាវិញ រាល់ការបង្ហាញឆន្ទៈទាំងឡាយគឺមានទិសដៅដូចគ្នាទាំងអស់ ។

ក្នុងលក្ខណៈជាទស្សនាទានដែលក្តោបទាំងសកម្មភាពឯកតោភាគី និង សកម្មភាពរួមគ្នា ក្នុងកិច្ចសន្យាបែបនេះ ពាក្យថា សកម្មភាពគតិយុត្តត្រូវបានគេយកមកប្រើប្រាស់ ។

### (២) សណ្តាប់ធ្នាប់សាធារណៈ ទំនៀមទម្លាប់ល្អ និង សមភាព

### ក) អត្ថន័យនៃសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ

មាត្រា ៩០ នៃក្រមរដ្ឋប្បវេណីចែងថា ខ្លឹមសារនៃសកម្មភាពគតិយុត្តដែលផ្ទុយទៅនឹងសណ្តាប់ធ្នាប់សាធារណៈ ឬ ទំនៀមទម្លាប់ល្អ គឺគ្មានសុពលភាព។ "សណ្តាប់ធ្នាប់សាធារណៈ" ត្រង់ចំណុចនេះគឺសំដៅលើសណ្តាប់ធ្នាប់ប្រទេស ឬ សង្គម រីឯ "ទំនៀមទម្លាប់ល្អ" គឺសំដៅទៅលើគោលគំនិតជាសីលធម៌ជាទូទៅនៅក្នុងសង្គម ។

ឧទាហរណ៍ថាមានករណីដែល A ស្នើឲ្យ B សម្លាប់ C ដោយសន្យាថាឲ្យប្រាក់រង្វាន់ កិច្ចសន្យាបែបនេះគឺផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អហើយ។ មោឃភាពនៃសកម្មភាពគតិយុត្តដែលផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ គឺមានន័យថា រដ្ឋមិនទទួលស្គាល់នូវការអនុវត្តនូវសកម្មភាពគតិយុត្តបែបដូច្នេះទេ។ នៅក្នុងឧទាហរណ៍ស្តីពីការស្នើសុំឲ្យធ្វើឃាតមនុស្សបែបនេះ គឺ A មិនអាចអនុវត្តសិទ្ធិទាមទារឲ្យ B សម្លាប់ C បានទេ ហើយ B ទៀតសោតក៏មិនអាចទាមទារឲ្យ A បង់ប្រាក់ឈ្នួលសម្លាប់ទៅតាមការសន្យា នៅក្រោយពេលខ្លួនបានសម្លាប់ C ហើយនោះដែរ។ ជាសរុបមក មាត្រា ៩០ នៃក្រមរដ្ឋប្បវេណី មោឃភាពសកម្មភាពដែលផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ គឺដើម្បីរក្សាសីលធម៌សង្គម និង សណ្តាប់ធ្នាប់ប្រទេស ។

ប្រសិនបើវត្ថុ ឬ ប្រាក់ត្រូវបានផ្តល់ជាតាវកាលិករួចហើយតាមរយៈកិច្ចសន្យាមោឃៈ ជាគោលការណ៍ តាវកាលិកនោះនឹងក្លាយទៅជាសេចក្តីចម្រើនដោយឥតហេតុរបស់ភាគីម្ខាងទៀត ហើយភាគីដែលបានអនុវត្តអាចធ្វើការអះអាងអំពីមោឃភាពនោះ ហើយអាចទាមទារឲ្យធ្វើបដិទាននូវស្ថានភាពដើម (មាត្រា ៧០៣ នៃក្រមរដ្ឋប្បវេណី)។ ក៏ប៉ុន្តែ ប្រសិនបើមោឃភាពនៃកិច្ចសន្យានោះដោយសារតែភាពផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ទោះបីជាវត្ថុ ឬ ប្រាក់ត្រូវបានផ្តល់ជាតាវកាលិកហើយក៏ដោយ ក៏មិនអាចទាមទារឲ្យសងមកវិញបានដែរ ដោយសារតែតាវកាលិកនោះជាតាវកាលិកដោយមូលហេតុខុសច្បាប់ (មាត្រា ៧០៨ នៃក្រមរដ្ឋប្បវេណី។ ចំពោះសេចក្តីចម្រើនដោយឥតហេតុ និង ការផ្តល់តាវកាលិកដោយមូលហេតុខុសច្បាប់វិញ នឹងមានពិភាក្សាលម្អិតក្នុងជំពូកទី ១០) ។

## ខ) ឧទាហរណ៍ជាក់ស្តែងអំពីភាពផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ

ពាក្យថា សណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ គឺមានន័យជាទូទៅ និង មានលក្ខណៈអរូបិយ ហើយខ្លឹមសារជាក់ស្តែងគឺមិនមានភាពច្បាស់លាស់ឡើយ។ ដោយហេតុនេះហើយ ទ្រឹស្តីសិក្សាបានធ្វើការកំណត់ប្រភេទករណីភាពផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អដោយយោងលើអ្វីដែលកើតមានកន្លងមកនៅក្នុងយុត្តិសាស្ត្រតុលាការ។ ជាក់ស្តែងដូចជា សកម្មភាពដែលផ្ទុយនឹងសីលធម៌គ្រួសារ (ឧទាហរណ៍ ដូចជាអ្វីដែលគេហៅថា កិច្ចសន្យាធ្វើជាប្រពន្ធចុង) កិច្ចសន្យាដើម្បីកម្រិតនូវសេរីភាព ឬ ការគោរពសេចក្តីថ្លៃថ្នូររបស់បុគ្គល (ឧទាហរណ៍ ដូចជាអ្វីដែលគេហៅថាជាកិច្ចសន្យាបញ្ចាំកូនឲ្យធ្វើជាស្ត្រីបម្រើសេវាកម្មកំសាន្ត ដោយកូនស្រីត្រូវទៅធ្វើជាអ្នកបម្រើគេដើម្បីដោះបំណុលរបស់ឪពុកម្តាយ) សកម្មភាពដែលផ្ទុយនឹងសីលធម៌សង្គម និង ទស្សនៈនៃភាពសុចរិត (ឧទាហរណ៍ដូចជាបទប្បញ្ញត្តិស្តីពីការងារដែលកំណត់អាយុចូលនិវត្តរបស់មនុស្សស្រីឲ្យទាបជាងមនុស្សប្រុស) សកម្មភាពភ្នាល់ (ដូចជាការភ្នាល់ល្បែងស៊ីសង) និង សកម្មភាពដែលកេងយកចំណេញហួសហេតុ ជាដើម ។

## គ) សមភាពនៃល័ក្ខខ័ណ្ឌដែលមានចែងនៅក្នុងកិច្ចសន្យា

ច្បាប់ស្តីពីកិច្ចសន្យាអ្នកប្រើប្រាស់ដែលត្រូវបានអនុម័តក្នុងឆ្នាំ ២០០០ បានកំណត់ថា បញ្ញត្តិដែលកំណត់ឲ្យពាណិជ្ជកររួចផុតពីការទទួលខុសត្រូវចំពោះសំណងការខូចខាត នៅក្រោមល័ក្ខខ័ណ្ឌជាក់លាក់មួយ (មាត្រា ៨ នៃច្បាប់នេះ) បញ្ញត្តិដែលកំណត់ចំនួននៃការបង់សំណងការខូចខាតដោយអ្នកប្រើប្រាស់ (មាត្រា ៩ នៃច្បាប់នេះ) និង បញ្ញត្តិផ្សេងទៀតដែលចែងអំពីការការបំពានផលប្រយោជន៍របស់អ្នកប្រើប្រាស់ (មាត្រា ១០ នៃច្បាប់នេះ) ត្រូវចាត់ទុកជាមោឃៈ។ បញ្ញត្តិទាំងនេះគឺដើម្បីធ្វើបដិទានផលប្រយោជន៍របស់អ្នកប្រើប្រាស់ដែលមានលទ្ធភាពខ្សោយជាងក្នុងការប្រមូលព័ត៌មាន និង លទ្ធភាពចរចា

ជាដើម ដោយធ្វើការបដិសេធនូវបញ្ញត្តិមិនត្រឹមត្រូវ ក្នុងករណីដែលផលប្រយោជន៍ត្រឹមត្រូវរបស់អ្នកប្រើប្រាស់ត្រូវបានបំពានដោយខកិច្ចសន្យាដែលមិនត្រឹមត្រូវ។ គោលគំនិតនេះខុសគ្នាជាមួយនឹងមាត្រា ៩០ នៃក្រមរដ្ឋប្បវេណី ក៏ប៉ុន្តែ វាមានចំណុចរួមគ្នាត្រង់ថា អានុភាពនៃខ្លឹមសារដែលបានព្រមព្រៀងរវាងភាគីគឺមិនត្រូវកើតឡើងឡើយ ។

## (៣) ការបង្ហាញឆន្ទៈដែលមានវិការៈ

ការបង្ហាញឆន្ទៈ គឺជាការសំដែងចេញទៅខាងក្រៅនូវឆន្ទៈខាងក្នុង ។ ជាធម្មតា វាមិនមានភាពខុសគ្នារវាងការបង្ហាញឆន្ទៈ និង ឆន្ទៈខាងក្នុងនោះទេ ក៏ប៉ុន្តែ ក៏មានករណីដែលមិនដូចគ្នាដែរ។ ឧទាហរណ៍ថា មានឆន្ទៈចង់ទិញរបស់មួយក្នុងតម្លៃ ១០ ម៉ឺនយ៉េន ក៏ប៉ុន្តែស្រាប់តែច្រឡំសំដែងចេញទៅខាងក្រៅថានឹងទិញក្នុងតម្លៃ ១ លានយ៉េន ទៅវិញ។ ក្រមរដ្ឋប្បវេណីមានបញ្ញត្តខ្លឹមសារបីប្រភេទចំពោះករណីដែលឆន្ទៈខាងក្នុង និង ការសំដែងចេញមកខាងក្រៅមិនត្រូវគ្នាយ៉ាងដូច្នេះ ពោលគឺបបនីយផ្លូវចិត្ត ការបង្ហាញឆន្ទៈមិនពិត និង ការភាន់ច្រឡំ ។

### ក) បបនីយផ្លូវចិត្ត

បបនីយផ្លូវចិត្តគឺឧទាហរណ៍ដូចជាករណីដែល A និយាយលេងជាមួយ B ថា "ចាំឲ្យប្រាក់ ១ លានយ៉េន" ដែលការពិតទៅបុគ្គល A ដែលជាអ្នកបង្ហាញនោះមិនមានឆន្ទៈពិតដូចដែលបានបង្ហាញចេញមកទេ ក៏ប៉ុន្តែបានបង្ហាញចេញមកយ៉ាងដូច្នេះ ។ ក៏ប៉ុន្តែ នៅក្នុងករណីបែបនេះគឺអ្នកដែលបាននិយាយបង្ហាញចេញមកនោះ A បានដឹងប្រាកដខ្លួនឯងថា ខ្លួនគ្មានឆន្ទៈដូចដែលបានបង្ហាញចេញមកនោះទេ។ ករណីដែលមានការបង្ហាញឆន្ទៈយ៉ាងដូច្នេះ ជាគោលការណ៍គឺមានអានុភាព ក៏ប៉ុន្តែ ប្រសិនបើភាគីម្ខាងទៀត B បានដឹងដែរថា វាជាបបនីយផ្លូវចិត្ត នោះច្បាប់បញ្ញត្តថា ការបង្ហាញឆន្ទៈនោះត្រូវទុកជាមោឃៈ (មាត្រា ៩៣ នៃក្រមរដ្ឋប្បវេណី) ។

### ខ) ការបង្ហាញឆន្ទៈមិនពិត

ការបង្ហាញឆន្ទៈមិនពិត គឺឧទាហរណ៍ដូចជាករណីដែល A មានគំនិតលាក់បាំងនូវទ្រព្យសម្បត្តិរបស់ខ្លួន ហើយបានពិភាក្សាជាមួយ B ដែលជាភរិយា ដោយឃុបឃិតគ្នាធ្វើជាធ្វើប្រទានកម្មនូវទ្រព្យសម្បត្តិរបស់គាត់ទៅ B ដែលតាមការពិតទៅគាត់គ្មានឆន្ទៈធ្វើប្រទានកម្មបែបនោះឡើយ ពោលគឺជាករណីដែលបានបង្ហាញចេញមក ថ្វីបើគ្មានឆន្ទៈដូចដែលបានបង្ហាញចេញមកក៏ដោយ។ ករណីបែបនេះ គឺមិនមែនតែអ្នកបង្ហាញឆន្ទៈតែម្នាក់ឯងទេ គឺភាគីម្ខាងទៀតក៏បានដឹងដែរថា អ្នកបង្ហាញឆន្ទៈមិនមានឆន្ទៈពិតដូចដែលបានបង្ហាញចេញមកនោះទេ។ ការបង្ហាញឆន្ទៈបែបនេះ គឺជាការបង្ហាញឆន្ទៈមិន

ពិតរវាងគូភាគី ហើយដែលច្បាប់បញ្ញត្តថាត្រូវទុកជាមោឃៈ (កថាខណ្ឌទី ១ មាត្រា ៩៤ នៃក្រមរដ្ឋប្បវេណី) ។

មោឃភាពមានន័យថា មិនមានកើតនូវអានុភាពតាមផ្លូវច្បាប់ ហើយក្នុងឧទាហរណ៍ខាងលើនេះ អានុភាពនៃប្រទានកម្មមិនកើតមានឡើងទេ។ ដោយសារតែមិនមានឆន្ទៈប្រទានកម្មរវាងគូភាគីមោឃភាពបែបនេះគឺជារឿងធម្មតា។ ក៏ប៉ុន្តែ យើងមិនអាចគិតបែបដូច្នេះបានទេ នៅក្នុងទំនាក់ទំនងជាមួយតតិយជនក្រៅពីគូភាគីនៃការបង្ហាញឆន្ទៈមិនពិត។ ហេតុដូច្នេះ នៅក្នុងករណីតតិយជនមិនដឹងអំពីអង្គហេតុស្តីពីការបង្ហាញឆន្ទៈមិនពិតនោះ (មានន័យថា សុចរិត) គឺច្បាប់បញ្ញត្តថា ត្រូវចាត់ចែងចំពោះការបង្ហាញឆន្ទៈមិនពិតនោះដូចគ្នាទៅនឹងការបង្ហាញឆន្ទៈដែលមានសុពលភាពដែរ (មានន័យថាមិនអាចតតាំងដោយផ្អែកលើមោឃភាពបានទេ) (កថាខណ្ឌទី ២ មាត្រា ៩៤ នៃក្រមរដ្ឋប្បវេណី) ។

## គ) ការភាន់ច្រឡំ

ការភាន់ច្រឡំ គឺមានដូចជាករណីដែល A មានបំណងចង់លក់ដី (ក) ក៏ប៉ុន្តែ បែរជាច្រឡំបង្ហាញឆន្ទៈថា "លក់ដី (ខ)" ទៅវិញ ដូច្នេះគឺជាករណីដែលអ្នកបង្ហាញឆន្ទៈបានធ្វើការបង្ហាញហួសទៅហើយ បើទោះជាឆន្ទៈមិនស្របទៅនឹងការបង្ហាញនោះក៏ដោយ។ ក៏ប៉ុន្តែ វាខុសពីបបនីយផ្លូវចិត្តនៅត្រង់ថា អ្នកបង្ហាញឆន្ទៈមិនបានដឹងថា ការបង្ហាញរបស់ខ្លួនខុសអំពីឆន្ទៈរបស់ខ្លួនទេ។ ការបង្ហាញឆន្ទៈរបៀបនេះ នៅពេលដែលមានកើតចេញនូវធាតុផ្សំនៃសកម្មភាពគតិយុត្តគឺជាការភាន់ច្រឡំ ដែលច្បាប់បញ្ញត្តថាត្រូវទុកជាមោឃៈ (មាត្រា ៩៥ នៃក្រមរដ្ឋប្បវេណី)។ ធាតុផ្សំនៃសកម្មភាពគតិយុត្តត្រង់ចំណុចនេះត្រូវបានគិតថាមានន័យថាជាផ្នែកសំខាន់ៗនៃសកម្មភាពគតិយុត្ត។ បញ្ញត្តិនេះមានគោលបំណងការពារអ្នកបង្ហាញឆន្ទៈដែលបានធ្វើការបង្ហាញឆន្ទៈដែលខុសពីឆន្ទៈខាងក្នុងរបស់ខ្លួនដោយភាន់ច្រឡំ ប៉ុន្តែក៏មិនកំណត់ថា ភាគីម្ខាងទៀតបានដឹងថា អ្នកបង្ហាញឆន្ទៈស្ថិតក្នុងសភាពភាន់ច្រឡំនោះទេ។ ហេតុដូច្នេះ ប្រសិនបើអ្នកបង្ហាញឆន្ទៈមានការភាន់ច្រឡំដោយសារកំហុសធ្ងន់ធ្ងរ ច្បាប់បញ្ញត្តថា អ្នកបង្ហាញឆន្ទៈមិនអាចអះអាងអំពីមោឃភាពដោយផ្អែកលើការភាន់ច្រឡំបានទេ (វាក្យខណ្ឌទី ២ មាត្រា ៩៥ នៃក្រមរដ្ឋប្បវេណី) ។

ក៏ប៉ុន្តែ ចំពោះការជួញដូរតាមប្រព័ន្ធអេឡិចត្រូនិកដោយប្រើប្រាស់ម៉ាស៊ីនកុំព្យូទ័រ ក្នុងករណីដែលអ្នកប្រើប្រាស់គឺជាភាគីម្ខាង បើតាមច្បាប់ពិសេស វាក្យខណ្ឌទី ២ មាត្រា ៩៥ នៃក្រមរដ្ឋប្បវេណីមិនត្រូវយកអនុវត្តចំពោះការបង្ហាញឆន្ទៈនៃសំណើ ឬ ស្ទីការរបស់អ្នកប្រើប្រាស់ទេ (ចំពោះកិច្ចសន្យារបស់អ្នកប្រើប្រាស់តាមប្រព័ន្ធអេឡិចត្រូនិក និង ការជូនដំណឹងពីស្ទីការតាមប្រព័ន្ធអេឡិចត្រូនិក សូមមើលមាត្រា ៣ នៃច្បាប់ស្តីពីបទប្បញ្ញត្តិពិសេសលើក្រមរដ្ឋប្បវេណីទាក់ទងនឹងកិច្ចសន្យារបស់អ្នកប្រើប្រាស់តាមប្រព័ន្ធអេឡិចត្រូនិក និង ការជូនដំណឹងពីស្ទីការតាមប្រព័ន្ធអេឡិចត្រូនិក។ ក៏ប៉ុន្តែ គេត្រូវ

ត្រឡប់មកអនុវត្តគោលការណ៍ដើមរបស់ក្រមរដ្ឋប្បវេណីវិញ នៅពេលដែលមានវិធានការត្រឹមត្រូវទាមទារឲ្យបញ្ជាក់អំពីសុពលភាព ឬ មោឃភាពនៃការបង្ហាញឆន្ទៈរបស់អ្នកប្រើប្រាស់ ដោយការចុចលើផ្ទាំងរូបភាពតាមរយៈប្រព័ន្ធអេឡិចត្រូនិក (ឧទាហរណ៍ ដូចជាការបង្ហាញតាមផ្ទាំងកញ្ចក់នូវប៊ូតុងឲ្យបញ្ជាក់ពីការយល់ព្រម ឬ មិនយល់ព្រម ជាដើម) ។

### ឃ) ការឆបោក ឬ ការគម្រាមកំហែង

ការឆបោកគឺដូចជាករណីដែល A ត្រូវបាន B បោកឲ្យលក់អចលនវត្ថុដែលជាកម្មសិទ្ធិរបស់ខ្លួនទៅ B ក្នុងតម្លៃយ៉ាងថោក នោះការបង្ហាញឆន្ទៈនោះគឺស្របទៅនឹងឆន្ទៈខាងក្នុងរបស់អ្នកបង្ហាញឆន្ទៈរបស់ A ហើយ ក៏ប៉ុន្តែ វាជាករណីនៃការបង្កើតឡើងនូវការបង្ហាញឆន្ទៈខាងក្នុងដោយលទ្ធផលនៃការដែលត្រូវបានឆបោក។ ដោយឡែក ការគម្រាមកំហែងគឺដូចជាករណីដែល A ត្រូវបាន B គម្រាមឲ្យលក់អចលនវត្ថុដែលជាកម្មសិទ្ធិរបស់ខ្លួនទៅ B ក្នុងតម្លៃយ៉ាងថោក ពោលគឺការបង្ហាញឆន្ទៈនោះស្របទៅនឹងឆន្ទៈខាងក្នុងរបស់ A ហើយ ក៏ប៉ុន្តែ វាជាករណីនៃការបង្កើតឡើងនូវការបង្ហាញឆន្ទៈខាងក្នុងដោយលទ្ធផលនៃការដែលត្រូវបានគម្រាមកំហែង។ ការបង្ហាញឆន្ទៈទាំងនេះមិនមែនជាភាពមិនត្រូវគ្នានៃការបង្ហាញឆន្ទៈ និង ឆន្ទៈពិតនោះទេ ក៏ប៉ុន្តែ ប្រសិនបើមិនមានការឆបោក ឬ ការគម្រាមកំហែងទេ បើទោះបីជាមានឆន្ទៈខាងក្នុងក៏ដោយ ក៏មិនមានការបង្ហាញចេញមកខាងក្រៅដែរ។ ដោយហេតុនេះហើយបានជាក្រមរដ្ឋប្បវេណីបញ្ញត្តថា អ្នកបង្ហាញឆន្ទៈអាចលុបចោលនូវការបង្ហាញនោះបាន ដោយសំអាងថាជាការបង្ហាញឆន្ទៈនោះមានវិការៈ (កថាខណ្ឌទី ១ មាត្រា ៩៦ នៃក្រមរដ្ឋប្បវេណី)។

ក៏ប៉ុន្តែ បើ A ដែលត្រូវបានឆបោកដោយតតិយជន C បានលក់អចលនវត្ថុដែលជាកម្មវត្ថុរបស់ខ្លួនទៅឲ្យ B ក្នុងតម្លៃថោក ហើយភាគី B មិនបានដឹងថា ការលក់នោះធ្វើឡើងដោយសារអំពើឆបោករបស់តតិយជន C ទេ នោះការបង្ហាញឆន្ទៈនេះមិនអាចត្រូវបានលុបចោលដោយសារការឆបោកទេ (កថាខណ្ឌទី ២ មាត្រា ៩៦ នៃក្រមរដ្ឋប្បវេណី) ។ ម្យ៉ាងវិញទៀត ប្រសិនបើនៅក្រោយពេលដែល A បានលក់អចលនវត្ថុរបស់ខ្លួនក្នុងតម្លៃថោកទៅឲ្យ B ដោយការឆបោករបស់ B ហើយ B បានលក់បន្តនូវអចលនវត្ថុនោះទៅឲ្យ C ដែលជាការបង្កើតឲ្យមាននូវទំនាក់ទំនងនៃសិទ្ធិតាមរយៈការលក់ទិញដោយសន្មតថា B ជាអ្នកមានសិទ្ធិកម្មសិទ្ធិយ៉ាងដូច្នេះ ក្រមរដ្ឋប្បវេណីបញ្ញត្តថា អ្នកបង្ហាញឆន្ទៈ A មិនអាចធ្វើការអះអាងអំពីការលុបចោលនូវការបង្ហាញឆន្ទៈរបស់ខ្លួនចំពោះ B ជាមួយតតិយជន C ដែលមិនបានដឹងអំពីហេតុ (នៃការឆបោក) នោះបានទេ (កថាខណ្ឌទី ៣ មាត្រា ៩៦ នៃក្រមរដ្ឋប្បវេណី) ។

ក្នុងករណីដូចខាងលើនេះ មានការកម្រិតចំពោះការអះអាងអំពីការឆបោកចំពោះតតិយជនដែលមិនបានដឹងអំពីអង្គហេតុស្ដីពីបង្ហាញឆន្ទៈដែលមានវិការៈ ក៏ប៉ុន្តែ មិនមានបញ្ញត្តិដើម្បីការពារតតិយជន

បែបនោះ នៅក្នុងករណីការបង្ហាញឆន្ទៈដោយសារការគម្រាមកំហែងនោះទេ។ ក៏ប៉ុន្តែ ប្រសិនបើ A បានលក់អចលនវត្ថុក្នុងតម្លៃថោកទៅឲ្យ B ដោយសារតែត្រូវបានគម្រាមកំហែងដោយតតិយជន C គឺ A អាចលុបចោលនូវការបង្ហាញឆន្ទៈរបស់ខ្លួនបាន ដោយមិនអាស្រ័យទៅលើថាតើ B បានដឹង ឬ មិនដឹងអំពីអង្គហេតុអំពីការគម្រាមនោះទេ។ ម្យ៉ាងទៀត នៅក្រោយពេលដែល A បានលក់អចលនវត្ថុដែលជាកម្មសិទ្ធិរបស់ខ្លួនក្នុងតម្លៃថោកទៅ B ដោយសារខ្លួនត្រូវបាន B គម្រាមកំហែង ហើយប្រសិនបើមានករណីដែល B បានលក់បន្តទៅឲ្យ C កើតឡើងដែរ ទោះបីជា B បានដឹង ឬ មិនបានដឹងអំពីអង្គហេតុអំពីការគម្រាមកំហែងនោះក៏ដោយ ក៏ A អាចអះអាងចំពោះ C អំពីការលុបចោលនូវការបង្ហាញឆន្ទៈរបស់ខ្លួនដែលបានធ្វើជាមួយ B និង អាចទាមទារយកអចលនវត្ថុនោះមកវិញបានដែរ។

### ង) អំពើអូសទាញដោយមិនសមហេតុផលដើម្បីកេងយកចំណេញហួសហេតុ

ច្បាប់ស្តីពីកិច្ចសន្យាអ្នកប្រើប្រាស់ទទួលស្គាល់ការលុបចោលការបង្ហាញឆន្ទៈ ក្នុងករណីដែលការធ្វើកិច្ចសន្យាដោយសារឥទ្ធិពលនៃអំពើអូសទាញដោយមិនសមហេតុផលដើម្បីកេងយកចំណេញហួសហេតុ (មាត្រា ៤ នៃច្បាប់នេះ) ។

បើទោះជាវាមិនមែនជាករណីដែលបង្កើតឲ្យមានការឆបោក ឬ ការគម្រាមកំហែងដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីក៏ដោយ ក៏ប៉ុន្តែ វាជាការទទួលស្គាល់ដោយមើលពីទិដ្ឋភាពនៃភាពយុត្តិធម៌រវាងគូភាគី។ ក្នុងន័យទូលាយ យើងអាចនិយាយបានថា នេះគឺជាករណីនៃការបង្ហាញឆន្ទៈដែលមានវិការៈ។ បើនិយាយឲ្យជាក់លាក់ទៅ គឺមានដូចជាករណីអង្គហេតុដែលពាក់ព័ន្ធនឹងចំណុចសំខាន់ៗខុសពីព័ត៌មានដែលបានផ្តល់ ឬ ករណីដែលមិនបានផ្តល់ព័ត៌មានដែលពាក់ព័ន្ធទៅនឹងចំណុចសំខាន់ដែលមានខ្លឹមសារជាការខូចខាតដល់ប្រយោជន៍ដល់របស់អ្នកប្រើប្រាស់ ។

## (4) មោឃភាព និង ការលុបចោល

### ក) ភាពខុសគ្នារវាងមោឃភាព និង ការលុបចោល

ក្រមរដ្ឋប្បវេណីបញ្ញត្តពីមោភាព និង ការលុបចោល ដើម្បីបដិសេធចោលសុពលភាពនៃសកម្មភាពគតិយុត្ត។ មោឃភាពសំដៅទៅលើការដែលសកម្មភាពគតិយុត្តមួយត្រូវបានចាត់ទុកថាមិនមានអត្ថិភាពតាំងពីដំបូង ហើយអ្នកណាក៏អាចអះអាងចំពោះគ្រប់បុគ្គលបានដែរ។ ម្យ៉ាងទៀត មិនមានការកំណត់ពីអំឡុងពេលដែលអាចអះអាងអំពីមោឃភាពទេ។ ដោយឡែកចំពោះការលុបចោលវិញ គឺសកម្មភាពគតិយុត្តមួយមានសុពលភាពតាំងពីដំបូង ក៏ប៉ុន្តែ នៅពេលដែលត្រូវបានលុបចោល គឺត្រូវបានចាត់ចែងដោយចាត់ទុកថាមិនមានសុពលភាពតាំងពីដំបូង។ នៅពេលដែលត្រូវបានលុបចោល គឺវានឹងក្លាយទៅជាដូចគ្នាជាមួយនឹងមោឃភាពដែរ ក៏ប៉ុន្តែ អ្វីដែលខុសគ្នាខ្លាំងជាមួយនឹងមោឃភាពគឺថាសកម្មភាព

នោះមានសុពលភាពតាំងពីមុនរហូតមកត្រឹមពេលដែលត្រូវបានលុបចោល។ លើសពីនេះទៀត គឺមានការកំណត់វិសាលភាពនៃអ្នកដែលអាចលុបចោលបាន និង ការកំណត់ថា ប្រសិនបើមិនបានលុបចោលក្នុងអំឡុងពេល ៥ ឆ្នាំ គិតចាប់ពីពេលដែលអាចផ្តល់សច្ចានុមតិ គឺមិនអាចលុបចោលបានឡើយ (ការផ្តល់សច្ចានុមតិត្រង់នេះ គឺមានន័យថាជាការសម្រេចយល់ព្រមឲ្យសកម្មភាពដែលអាចលុបចោលមួយ មានសុពលភាព ដោយការលះបង់ចោលសិទ្ធិលុបចោល)។ សរុបមក ចំពោះមោឃភាព និង ការលុបចោល អាចនិយាយបានថា មោឃភាពគឺផ្តល់នូវឥទ្ធិពលដែលមានអានុភាពខ្លាំងក្លាជាង។

ក្រមរដ្ឋប្បវេណីដែលចែងអំពីមោឃភាពនៃអានុភាពចំពោះបបនីយផ្លូវចិត្ត ការបង្ហាញឆន្ទៈមិនពិត និង ការភាន់ច្រឡំ គឺដោយផ្អែកទៅលើទស្សនៈថា វាជាករណីដែលឆន្ទៈខាងក្នុង និង ការបង្ហាញឆន្ទៈមិនត្រូវគ្នា រីឯការលុបចោលនូវអានុភាពនៃការបង្ហាញឆន្ទៈ ក្នុងករណីការឆបោក និង ការគម្រាមកំហែង គឺដោយផ្អែកលើទស្សនៈថា វាគ្រាន់តែជាករណីវិការៈចំពោះឆន្ទៈខាងក្នុងធម្មតាប៉ុណ្ណោះ។ ក៏ប៉ុន្តែ នាពេលបច្ចុប្បន្ន មានការលើកឡើងថា ការដែលត្រូវទទួលស្គាល់ថាជាការលុបចោល ឬ មោឃភាពនោះគឺជាបញ្ហានៃគោលនយោបាយនីតិកម្ម ហើយចំពោះមោឃភាពត្រូវមានការកម្រិតចំពោះការអះអាង (កថាខណ្ឌទី ២ មាត្រា ៩៤ និង វាក្យខណ្ឌទី ២ មាត្រា ៩៥ នៃក្រមរដ្ឋប្បវេណី) ដែលមានប្រភេទផ្សេងៗ។

## ២ សមត្ថភាពទទួលសិទ្ធិ សមត្ថភាពខាងឆន្ទៈ និងសមត្ថភាពក្នុងការធ្វើសកម្មភាពគតិយុត្ត

### (១) សមត្ថភាពទទួលសិទ្ធិ

#### ក) អត្ថន័យនៃសមត្ថភាពទទួលសិទ្ធិ

ស្ថានភាព (លក្ខណសម្បត្តិ) ដែលអាចទទួលបាននូវសិទ្ធិ និង មានកាតព្វកិច្ច ហៅថា សមត្ថភាពទទួលសិទ្ធិ។ ជាគោលការណ៍ បុគ្គលគ្រប់រូបមានសមត្ថភាពទទួលសិទ្ធិស្មើៗគ្នា (គោលការណ៍នៃភាពស្មើគ្នាចំពោះសមត្ថភាពទទួលសិទ្ធិ) ក៏ប៉ុន្តែ មានការកម្រិតតិច ឬ ច្រើនចំពោះជនបរទេស (កថាខណ្ឌទី ២ មាត្រា ៣ នៃក្រមរដ្ឋប្បវេណី)។ ក្រមរដ្ឋប្បវេណីចែងអំពីចំណុចចាប់ផ្តើមនេះ ដោយផ្អែកលើការទទួលស្គាល់នូវសមភាពនៃសមត្ថភាពទទួលសិទ្ធិរបស់បុគ្គលនីមួយៗជាមូលដ្ឋាន។ មានន័យដូចបញ្ញត្តក្នុងកថាខណ្ឌទី ១ មាត្រា ៣ នៃក្រមរដ្ឋប្បវេណីថា រូបវន្តបុគ្គលគ្រប់រូបមានសមត្ថភាពទទួលសិទ្ធិនៅពេលចាប់កំណើត។ ក៏ប៉ុន្តែ បើទោះជាមានការមិនទទួលស្គាល់នូវសមត្ថភាពទទួលសិទ្ធិនៅមុនពេលចាប់កំណើតរបស់ទារកនៅក្នុងគភ៌ក៏ដោយ ជាករណីលើកលែង សមត្ថភាពទទួលសិទ្ធិរបស់ទារកក្នុងគភ៌ក៏ត្រូវបានទទួលស្គាល់ផងដែរនៅក្នុងករណីសន្តតិកម្ម និង ការទាមទារសំណងការខូចខាតដែលកើតឡើងដោយអំពើអនីត្យានុកូល (មាត្រា ៧២១ និង មាត្រា ៨៨៦ នៃក្រមរដ្ឋប្បវេណី) ។

## ខ) សមត្ថភាពទទួលសិទ្ធិរបស់នីតិបុគ្គល

លើសពីនេះទៅទៀត ក្រមរដ្ឋប្បវេណីទទួលស្គាល់ភាពជាប្រធាននៃសិទ្ធិរបស់សាជីវកម្មដែលជាការប្រមូលផ្តុំនៃមនុស្ស និង មូលនិធិដែលជាការប្រមូលផ្តុំនៃទ្រព្យសម្បត្តិ។ ការទទួលស្គាល់នេះគេហៅថា របបនីតិបុគ្គល។ ឧទាហរណ៍ដូចជាការដែលក្រុមហ៊ុនមួយអាចទទួលបានសិទ្ធិ និង មានកាតព្វកិច្ចក្នុងនាមក្រុមហ៊ុន។ តាមរយៈអត្ថន័យនៃការបែងចែកជាមួយនីតិបុគ្គល មនុស្សត្រូវបានហៅថា រូបវន្តបុគ្គល (ជំពូកទី ១៥ នឹងមានពិភាក្សាលម្អិតអំពីនីតិបុគ្គល) ។

## (២) សមត្ថភាពខាងឆន្ទៈ និង សមត្ថភាពក្នុងការធ្វើសកម្មភាពគតិយុត្ត

## ក) សមត្ថភាពខាងឆន្ទៈ

មនុស្សគ្រប់រូបអាចទទួលបានសិទ្ធិ និង រ៉ាប់រងកាតព្វកិច្ច ក៏ប៉ុន្តែ បើនិយាយឲ្យជាក់លាក់ទៅ ការទទួលសិទ្ធិ និង រ៉ាប់រងកាតព្វកិច្ច គឺជាអានុភាពនៃសកម្មភាពគតិយុត្ត ដូចជា កិច្ចសន្យា ជាដើម។ ជាពិសេស ការរ៉ាប់រងកាតព្វកិច្ច គឺជាអានុភាពដែលសេរីភាពរបស់មនុស្សត្រូវបានចង។ ជាឧទាហរណ៍ តាមរយៈកិច្ចសន្យា អ្នកទិញមានកាតព្វកិច្ចបង់ថ្លៃលក់ទិញ។ ឧបមាថា ទោះបីជាអ្នកទិញមិនបង់ថ្លៃលក់ទិញក៏ដោយ ក៏អ្នកលក់អាចខ្ចីអំណាចតុលាការ ដើម្បីប្រមូលយកថ្លៃលក់ទិញនោះពីអ្នកទិញបានដែរ។ ក៏ប៉ុន្តែ ក្នុងការធ្វើសកម្មភាពគតិយុត្ត វាមានភាពចាំបាច់ដែលភាគីត្រូវយល់អំពីអានុភាពគតិយុត្តដែលកើតឡើងពីសកម្មភាពគតិយុត្តនោះ។ ឧទាហរណ៍ថា កុមារអាយុ ៥ ឆ្នាំម្នាក់ និយាយនៅហាងលក់ទំនិញថា "ខ្ញុំចង់ទិញរបស់ក្មេងលេង" ដូច្នេះ វាជារឿងធម្មតាទេដែលទស្សនៈជាទូទៅមួយយល់ឃើញថា មិនអាចនិយាយថាមានកិច្ចសន្យាលក់ទិញមួយបានកើតឡើងនោះឡើយ។ ហេតុដូច្នេះ ដើម្បីធ្វើសកម្មភាពគតិយុត្តមួយ ចាំបាច់ត្រូវមានសមត្ថភាពវិនិច្ឆ័យជាក់លាក់ទៅលើការយល់ដឹងអំពីអានុភាពនៃសកម្មភាពដែលខ្លួនកំពុងធ្វើនោះ។ សមត្ថភាពនេះហៅថា សមត្ថភាពខាងឆន្ទៈ។

## ខ) សមត្ថភាពក្នុងការធ្វើសកម្មភាពគតិយុត្ត និង ការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពគតិយុត្ត

ភាពមាន ឬ គ្មានសមត្ថភាពខាងឆន្ទៈ ចាំបាច់ត្រូវវិនិច្ឆ័យដាច់ដោយឡែកពីគ្នា ក៏ប៉ុន្តែ សម្រាប់យើងគ្រប់គ្នា នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ដោយសារតែយើងត្រូវធ្វើការជួញដូរជាប់ជារៀងរាល់ថ្ងៃ យ៉ាងដូច្នេះ ការដែលត្រូវតែធ្វើការវិនិច្ឆ័យថាតើភាគីមាន ឬ គ្មានសមត្ថភាពខាងឆន្ទៈគ្រប់គ្រាន់នៅក្នុងគ្រប់ករណីជួញដូរនីមួយៗបែបនោះ គឺពិតជាមានភាពស្មុគស្មាញ។ ក្នុងស្ថានភាពជាក់ស្តែង គឺយើងពិបាកសង្ឃឹមថានឹងមាននីតិវិធីយ៉ាងដូច្នេះណាស់។ ដោយហេតុនេះហើយបានជាក្រមរដ្ឋប្បវេណី

កំណត់ក្នុងលក្ខណៈជាប្រព័ន្ធថា បុគ្គលជាក់លាក់មួយចំនួនមានសមត្ថភាពខាងឆន្ទៈជាធម្មតា។ មានន័យថា គេមានលក្ខណសម្បត្តិធ្វើសកម្មភាពគតិយុត្តដោយឯករាជ្យដោយមិនចាំបាច់មានជំនួយពីអ្នកដទៃ ដែលហៅថា សមត្ថភាពក្នុងការធ្វើសកម្មភាពគតិយុត្ត ហើយដោយផ្អែកលើមូលដ្ឋានថាជាគោលការណ៍ មនុស្សគ្រប់រូបមានសមត្ថភាពក្នុងការធ្វើសកម្មភាពគតិយុត្ត និង ដើម្បីរក្សាគោលការណ៍នេះ ទើបមានការកម្រិតនូវសមត្ថភាពក្នុងការធ្វើសកម្មភាពរបស់បុគ្គលដែលមិនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការវិនិច្ឆ័យមួយចំនួនជាករណីលើកលែង ដោយចាំបាច់ត្រូវមានជំនួយពីអ្នកដទៃដើម្បីអាចធ្វើសកម្មភាពគតិយុត្តបាន ។

### គ) ជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព

ចាប់តាំងពីឆ្នាំ ១៩៩៩ រហូតមកដល់ត្រឹមពេលធ្វើវិសោធនកម្ម ក្រមរដ្ឋប្បវេណីបានផ្តល់ការការពារដល់ជនដែលមិនមានសមត្ថភាពក្នុងការធ្វើសកម្មភាព (និងជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព) ក្នុងលក្ខណៈជាជនដែលគ្មានសមត្ថភាពក្នុងការធ្វើសកម្មភាព។ បើនិយាយឲ្យជាក់លាក់ទៅ គឺមានអនីតិជន ជនដែលត្រូវបានកម្រិតសមត្ថភាព និង ឧបជនដែលត្រូវបានកម្រិតសមត្ថភាព។ អនីតិជនគឺសំដៅទៅលើជនដែលមិនទាន់ដល់នីតិភាព។ ជនដែលត្រូវបានកម្រិតសមត្ថភាពគឺជាជនដែលខ្វះនូវសមត្ថភាពខាងស្មារតីពុំគ្រប់គ្រាន់សម្រាប់ធ្វើសកម្មភាពគតិយុត្ត (ក្រមរដ្ឋប្បវេណីបានពន្យល់ថា "ជនដែលស្ថិតក្នុងស្ថានភាពបាត់បង់ស្មារតីជានិរន្តរ៍") ហើយជាជនដែលត្រូវបានតុលាការដែលមានសមត្ថកិច្ចលើរឿងក្តីគ្រួសារប្រកាសថាជាជនដែលត្រូវបានកម្រិតសមត្ថភាពទៅតាមពាក្យសុំរបស់បុគ្គលជាក់លាក់មួយចំនួន។ រីឯឧបជនដែលត្រូវបានកម្រិតសមត្ថភាពវិញ គឺមិនធ្ងន់ធ្ងរដូចជនដែលត្រូវបានកម្រិតសមត្ថភាពទេ ក៏ប៉ុន្តែ ជាជនដែលមានសមត្ថភាពខាងស្មារតីអន់ខ្សោយ (ក្រមរដ្ឋប្បវេណីបានពន្យល់ថា "ជនដែលមានស្មារតីអន់ខ្សោយ") និង ខ្ជះខ្ជាយ ហើយជាជនដែលត្រូវបានតុលាការគ្រួសារប្រកាសថាជាឧបជនដែលត្រូវបានកម្រិតសមត្ថភាព ទៅតាមពាក្យសុំរបស់បុគ្គលជាក់លាក់មួយចំនួន ។

ក៏ប៉ុន្តែ នៅក្នុងឆ្នាំ ១៩៩៩ របបជនដែលត្រូវបានកម្រិតសមត្ថភាព និង ឧបជនដែលត្រូវបានកម្រិតសមត្ថភាពត្រូវបានធ្វើវិសោធនកម្មមួយផ្នែកធំ។ បានសេចក្តីថា ការកើនឡើងនូវភាពចាំបាច់ក្នុងការការពារមនុស្សចាស់ដែលបាត់បង់សមត្ថភាពក្នុងការវិនិច្ឆ័យ ដោយសារតែការវិវត្តទៅរកសង្គមដែលសម្បូរណ៍ទៅដោយមនុស្សចាស់ និង ការកើនឡើងនូវភាពចាំបាច់ក្នុងការលើកកម្ពស់សុខុមាលភាពរបស់ជនដែលការលូតលាស់ខាងបញ្ញាស្មារតីមានភាពយឺតយ៉ាវ ជាដើម ជាមូលហេតុនៃវិសោធនកម្មនេះ។

ជាលទ្ធផលនៃវិសោធនកម្មនេះ ក្រមរដ្ឋប្បវេណីបានលុបចោលនូវប្រភេទជនដែលគ្មានសមត្ថភាព

ក្នុងការធ្វើសកម្មភាព ដោយកំណត់យកនូវប្រភេទថ្មីវិញ គឺជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព។ អាចនិយាយបានថា ក្រៅពីអនីតិជន ក្រមរដ្ឋប្បវេណីបានទទួលស្គាល់ជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពបីប្រភេទគឺ ជនដែលគ្មានសមត្ថភាពយល់ដឹង និងវិនិច្ឆ័យឲ្យបានត្រឹមត្រូវ ដោយសារស្ថិតក្នុងស្ថានភាពវិបត្តិផ្នែកបញ្ញាស្មារតីជានិរន្តរ៍ (មាត្រា ៧ នៃក្រមរដ្ឋប្បវេណី) ជនដែលមានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹង និង វិនិច្ឆ័យឲ្យបានត្រឹមត្រូវដោយសារតែវិបត្តិផ្នែកបញ្ញាស្មារតី (មាត្រា ១១ នៃក្រមរដ្ឋប្បវេណី) និង ជនដែលមានសមត្ថភាពយល់ដឹងមិនគ្រប់គ្រាន់ដើម្បីយល់ដឹង និង វិនិច្ឆ័យឲ្យបានត្រឹមត្រូវដោយសារតែវិបត្តិផ្នែកបញ្ញាស្មារតី (មាត្រា ១៥ នៃក្រមរដ្ឋប្បវេណី)។ ចំពោះជនក្រៅពីអនីតិជន ចំណុចស្តីពីការប្រកាសរបស់តុលាការគ្រួសារទៅតាមពាក្យសុំរបស់បុគ្គលជាក់លាក់មួយចំនួនមិនមានភាពខុសគ្នាជាមួយរបបពីមុនទេ ក៏ប៉ុន្តែចំណុចខុសគ្នាចម្បងនៃវិសោធនកម្ម គឺការប្តូរពី ២ ប្រភេទ ពោលគឺជនដែលត្រូវបានកម្រិតសមត្ថភាព និងឧបជនដែលត្រូវបានកម្រិតសមត្ថភាព ទៅជា ៣ ប្រភេទវិញ។ សមត្ថភាពយល់ដឹង និង វិនិច្ឆ័យឲ្យបានត្រឹមត្រូវមានន័យថា សមត្ថភាពវិនិច្ឆ័យអំពីហេតុការណ៍ ក៏ប៉ុន្តែ ចំពោះកម្រិតតិច ឬ ច្រើននៃសមត្ថភាពដែលខ្វះគឺមានការបែងចែកជា ៣ ប្រភេទ។ ក្នុងចំណោមប្រភេទជនទាំងនេះ បើទោះបីជាជននោះជាជនដែលគ្មានសមត្ថភាពយល់ដឹង និងវិនិច្ឆ័យឲ្យបានត្រឹមត្រូវ ដោយសារស្ថិតក្នុងស្ថានភាពជានិរន្តរ៍នៃវិបត្តិផ្នែកបញ្ញាស្មារតី ដែលជាប្រភេទមួយដែលសមត្ថភាពខាងស្មារតីអន់ខ្សោយបំផុតក៏ដោយ ក៏មានការទទួលស្គាល់នូវការធ្វើសកម្មភាពដោយឯករាជ្យដែលជាករណីលើកលែងចំពោះសកម្មភាពដែលទាក់ទងទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃដែរ ពោលគឺមិនមែនដូចជនដែលត្រូវបានកម្រិតសមត្ថភាពដែលជាជនមិនមានសមត្ថភាពទាំងស្រុងនោះទេ។ ដោយហេតុនេះហើយបានជា ប្តូរពីពាក្យថា ជនដែលខ្វះសមត្ថភាពធ្វើសកម្មភាព ទៅជាប្រើពាក្យថា ជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពជំនួសវិញ ។

## ឃ) អនីតិជន

ជនដែលត្រូវបានកម្រិតសមត្ថភាពទី ១ គឺអនីតិជន។ អនីតិជនគឺសំដៅលើជនដែលមិនទាន់ដល់នីតិភាព ពោលគឺមិនទាន់គ្រប់អាយុ ២០ ឆ្នាំ (សូមមើលមាត្រា ៤ នៃក្រមរដ្ឋប្បវេណី)។ ជាគោលការណ៍អនីតិជនមិនអាចធ្វើសកម្មភាពគតិយុត្តដោយឯករាជ្យបានទេ សកម្មភាពដែលបានធ្វើឡើងដោយឯករាជ្យអាចត្រូវបានលុបចោលបាន (មាត្រា ៥ នៃក្រមរដ្ឋប្បវេណី)។ ដើម្បីឲ្យអនីតិជនអាចធ្វើសកម្មភាពគតិយុត្តបាន ចាំបាច់ត្រូវធ្វើសកម្មភាពតាមរយៈអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ អនីតិជនខ្លួនឯងអាចធ្វើសកម្មភាពគតិយុត្តបាន ក្រោយពីទទួលបានការយល់ព្រមពីអ្នកតំណាងដែលច្បាប់បានកំណត់។ ក៏ប៉ុន្តែ ជាករណីលើកលែង អនីតិជនត្រូវបានទទួលស្គាល់ឲ្យធ្វើសកម្មភាពដោយឯករាជ្យបានចំពោះសកម្មភាពទាំងឡាយណាដែលមិនសំខាន់ (វាក្យខណ្ឌទី ២

កថាខណ្ឌទី ១ និង កថាខណ្ឌទី ៣ មាត្រា ៥ និង មាត្រា ៦ នៃក្រមរដ្ឋប្បវេណី)។

### ឯ) នីតិជននៅក្រោមអាណាព្យាបាល

ជនដែលត្រូវបានកម្រិតសមត្ថភាពទី ២ គឺ ជនដែលគ្មានសមត្ថភាពយល់ដឹង និង វិនិច្ឆ័យឲ្យបានត្រឹមត្រូវ ដោយសារស្ថិតក្នុងស្ថានភាពជានិរន្តរ៍នៃវិបត្តិផ្នែកបញ្ញាស្មារតី ហើយដែលតុលាការគ្រួសារបានសម្រេចប្រកាសការចាប់ផ្ដើមអាណាព្យាបាល ទៅតាមពាក្យសុំរបស់បុគ្គលជាកំណត់ ដូចជាសហព័ទ្ធ ឬ ញាតិនៅក្នុង ៤ ថ្នាក់ ជាដើម (មាត្រា ៧ នៃក្រមរដ្ឋប្បវេណី។ ការពិភាក្សាអំពីអត្ថន័យនៃញាតិមាននៅក្នុងជំពូកទី ១២)។ ជនប្រភេទនេះគឺស្រដៀងគ្នាទៅនឹងអសមត្ថជននៅក្នុងរបបមុន ក៏ប៉ុន្តែ ដោយសារតែត្រូវបានដាក់ឲ្យមានអ្នកអាណាព្យាបាលសម្រាប់នីតិជន ទើបជននេះត្រូវបានហៅថា នីតិជននៅក្រោមអាណាព្យាបាល (មាត្រា ៨ នៃក្រមរដ្ឋប្បវេណី)។ ជាគោលការណ៍ នីតិជននៅក្រោមអាណាព្យាបាលមិនអាចធ្វើសកម្មភាពគតិយុត្តបានទេ គឺត្រូវផ្ទេរឲ្យអ្នកអាណាព្យាបាលសម្រាប់នីតិជន។ ប្រសិនបើអនុវត្តផ្ទុយពីគោលការណ៍នេះ សកម្មភាពដែលបានអនុវត្តដោយនីតិជននៅក្រោមអាណាព្យាបាលអាចត្រូវបានលុបចោល (មាត្រា ៩ នៃក្រមរដ្ឋប្បវេណី)។ ក៏ប៉ុន្តែ ចំពោះការទិញទំនិញប្រើប្រាស់ប្រចាំថ្ងៃ និង សកម្មភាពដែលពាក់ព័ន្ធនឹងជីវភាពប្រចាំថ្ងៃដទៃទៀត គឺនីតិជននៅក្រោមអាណាព្យាបាលអាចធ្វើសកម្មភាពដោយឯករាជ្យបាន។

### ច) ជននៅក្រោមហិតូបត្ថម្ភ

ជនដែលត្រូវបានកម្រិតសមត្ថភាពទី ៣ គឺជនដែលមានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹង និង វិនិច្ឆ័យឲ្យបានត្រឹមត្រូវ ហើយដែលតុលាការគ្រួសារបានសម្រេចប្រកាសការចាប់ផ្ដើមហិតូបត្ថម្ភចំពោះជននោះ តាមពាក្យសុំរបស់បុគ្គលជាកំណត់ (មាត្រា ១១ នៃក្រមរដ្ឋប្បវេណី)។ ជនប្រភេទនេះគឺស្រដៀងគ្នាទៅនឹងឧបជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពនៅក្នុងរបបមុន ក៏ប៉ុន្តែដោយសារតែត្រូវបានដាក់ឲ្យមានហិតូបត្ថម្ភកៈ ទើបត្រូវបានហៅថា ជននៅក្រោមហិតូបត្ថម្ភ (មាត្រា ១២ នៃក្រមរដ្ឋប្បវេណី)។ ក៏ប៉ុន្តែ ចំពោះជនដែលខ្វះខ្ខាយនៅក្នុងរបបឧបជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពកាលពីមុន ដរាបណាមិនមានសមត្ថភាពខាងបញ្ញាស្មារតីអន់ខ្សោយទេ នោះគឺមិនត្រូវបានដាក់ឲ្យមានរបបហិតូបត្ថម្ភឡើយ។ ជាគោលការណ៍ ជននៅក្រោមរបបហិតូបត្ថម្ភអាចធ្វើសកម្មភាពគតិយុត្តដោយឯករាជ្យបាន ក៏ប៉ុន្តែ ជាករណីលើកលែងចំពោះសកម្មភាពសំខាន់ៗចាំបាច់ត្រូវមានការយល់ព្រមពីហិតូបត្ថម្ភកៈ (មាត្រា ១៣ នៃក្រមរដ្ឋប្បវេណី)។ ប្រសិនមានការអនុវត្តផ្ទុយពីនេះ សកម្មភាពដែលជននៅក្រោមរបបហិតូបត្ថម្ភបានធ្វើដោយមិនមានការយល់ព្រមពីហិតូបត្ថម្ភកៈទេ អាចត្រូវបានលុបចោលបាន ។

### ឆ) ជននៅក្រោមជំនួយ

ជាចុងក្រោយ ជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពគឺជាជនដែលមានសមត្ថភាពយល់ដឹងមិនគ្រប់គ្រាន់ដើម្បីយល់ដឹង និង វិនិច្ឆ័យឲ្យបានត្រឹមត្រូវ ហើយជាជនដែលតុលាការគ្រួសារបានសម្រេចប្រកាសការចាប់ផ្ដើមជំនួយទៅតាមពាក្យសុំរបស់បុគ្គលជាក់លាក់ (មាត្រា ១៥ នៃក្រមរដ្ឋប្បវេណី)។ របបនេះជាប្រភេទថ្មីមួយដែលជាលទ្ធផលនៃវិសោធនកម្ម ហើយដោយសារតែត្រូវបានដាក់ឲ្យមានអ្នកជំនួយ ទើបជននោះត្រូវបានហៅថា ជននៅក្រោមជំនួយ (មាត្រា ១៦ នៃក្រមរដ្ឋប្បវេណី)។ ដើម្បីឲ្យជននៅក្រោមជំនួយអាចធ្វើសកម្មភាពគតិយុត្តណាមួយដែលតុលាការគ្រួសារបានសម្រេចថាត្រូវមានការយល់ព្រមពីអ្នកជំនួយ ជននៅក្រោមជំនួយចាំបាច់ត្រូវទទួលការយល់ព្រមពីអ្នកជំនួយ ហើយក្នុងករណីដែលជននោះបានធ្វើសកម្មភាពដោយមិនបានទទួលការយល់ព្រមពីអ្នកជំនួយទេ សកម្មភាពនោះអាចត្រូវបានលុបចោលបាន។

### ជ) កិច្ចការជំនួញរបស់ជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព

ដូចបានឃើញខាងលើនេះស្រាប់ ការការពារជនដែលត្រូវបានកម្រិតសមត្ថភាពដែលជាជនដែលមានសមត្ថភាពវិនិច្ឆ័យខ្សោយជាងជនសាមញ្ញទូទៅពីការទទួលរងនូវការខូចខាតផលប្រយោជន៍ គឺធ្វើឡើងតាមរយៈអ្នកមានអំណាចមេបា អ្នកអាណាព្យាបាល ហិតូបត្ថម្ភកៈ និង អ្នកជំនួយ។ ក៏ប៉ុន្តែប្រសិនបើភាគីម្ខាងទៀតនៃការជួញដូរមិនបានដឹងថា ជននេះជាជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពទេ នោះក៏ត្រូវតែពិចារណាឲ្យមានការការពារចំពោះភាគីម្ខាងទៀតផងដែរ។ ក្រមរដ្ឋប្បវេណីបានកំណត់យករបបពីរជាយន្តការការពារក្នុងករណីនេះ។ ទី ១ គឺការផ្ដល់មធ្យោបាយលុបចោលនូវស្ថានភាពដែលមិនប្រាកដប្រជាចំពោះសកម្មភាពដែលអាចលុបចោលបាន (នៅមុនពេលមានការលុបចោល សកម្មភាពនោះមានអានុភាពជាធម្មតា ក៏ប៉ុន្តែនៅពេលត្រូវបានលុបចោលសកម្មភាពនោះនឹងក្លាយទៅជាមោឃភាពតាំងពីដំបូង) ដោយការផ្ដល់នូវសិទ្ធិដាស់តឿនរបស់ភាគីម្ខាងទៀតដែលបានធ្វើការជួញដូរជាមួយជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព (មាត្រា ២០ នៃក្រមរដ្ឋប្បវេណី)។ មានន័យថា ភាគីម្ខាងទៀតអាចដាស់តឿនទៅអ្នកតំណាងដែលច្បាប់បានកំណត់ (អ្នកមានអំណាចមេបា និង អ្នកអាណាព្យាបាល) ហិតូបត្ថម្ភកៈ និង អ្នកជំនួយឲ្យធ្វើសច្ចានុមតិចំពោះសកម្មភាពរបស់ជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពបាន។ ការឆ្លើយតបរបស់អ្នកទាំងនោះចំពោះការដាស់តឿន ប្រសិនបើជាការឆ្លើយតបថាលុបចោលនូវសកម្មភាព នោះសកម្មភាពនឹងក្លាយទៅជាគ្មាន ហើយប្រសិនបើជាការផ្ដល់សច្ចានុមតិ នោះសកម្មភាពនឹងមានសុពលភាព។ ម្យ៉ាងវិញទៀត ក្នុងករណីដែលមិនមានការឆ្លើយតបក៏ដោយ ក៏វាអាចក្លាយជាការលុបចោល ឬ ការផ្ដល់សច្ចានុមតិដែរ។ ទី ២ គឺជាករណីដែលជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពបោកដល់ភាគីម្ខាងទៀតឲ្យជឿជាក់ថាខ្លួនជាសមត្ថជនពេញលេញ។ ក្នុងករណីបែបនេះ

ការទទួលស្គាល់ឲ្យលុបចោលពុំមែនជាការត្រឹមត្រូវនោះទេ។ ដោយហេតុនោះ ប្រសិនបើមានករណីបែបនេះ គឺពុំអាចធ្វើការលុបចោលបានទេ (មាត្រា ២១ នៃក្រមរដ្ឋប្បវេណី) ។

✐ សកម្មភាពគតិយុត្តរបស់អនីតិជន--ការពិចារណាតាមរយៈករណីសិក្សា

ក្នុងករណីសិក្សាខាងលើ ដោយសារតែ A ជាអនីតិជន ដើម្បីលក់អចលនវត្ថុ ចាំបាច់ត្រូវតែធ្វើកិច្ចសន្យាជាមួយ C និង D ដែលជាអ្នកតំណាងដែលច្បាប់កំណត់របស់ A ឬក៏ A ត្រូវទទួលការយល់ព្រមពី C និង D ដើម្បីធ្វើកិច្ចសន្យា។ ហេតុដូច្នេះ ប្រសិនបើក្នុងករណីដែល A បានធ្វើកិច្ចសន្យាដោយឯករាជ្យជាមួយ B ដោយពុំមានការយល់ព្រមពី C និង D ទេ កិច្ចសន្យានោះអាចត្រូវបានលុបចោល (កថាខណ្ឌទី ២ មាត្រា ៥ និង មាត្រា ១២០ នៃក្រមរដ្ឋប្បវេណី)។ ក៏ប៉ុន្តែ ប្រសិនបើ A បានប្រើវិធីបោកប្រាស់ B ឲ្យជឿជាក់ថាខ្លួនជាសមត្ថជន ហើយករណីដែល B បានជឿជាក់ដោយភ័ន្តច្រឡំបែបនេះ C និង D មិនអាចលុបចោលកិច្ចសន្យាលក់ទិញរវាង A និង B បានឡើយ ។

### ✧ នីតិរដ្ឋប្បវេណី និង នីតិព្រហ្មទណ្ឌ

នៅក្នុងរឿងក្ដីមួយ អាចមានជាបញ្ហាព្រហ្មទណ្ឌ និង បញ្ហារដ្ឋប្បវេណីរដ្ឋប្បវេណី ។ ឧទាហរណ៍ករណីអ្នកបើកតាក់ស៊ី (ចារី) បានបើកបរក្នុងស្ថានភាពក្រោយពេលបានទទួលទានសុរាហើយ ដោយសារតែពុំបានមើលភ្លើងសញ្ញាចរាចរណ៍នៅត្រង់ផ្លូវបំបែក ក៏បានជ្រុលទៅបុកអ្នកថ្មើរជើងដែលកំពុងតែឆ្លងកាត់ផ្លូវ (ជនរងគ្រោះ) បណ្ដាលឲ្យមានរបួស។ តាមច្បាប់ព្រហ្មទណ្ឌ ចារីដែលជាអ្នកបើកបរបានបង្ករបួសយ៉ាងធ្ងន់ធ្ងរដោយសារកំហុសក្នុងពេលបំពេញកិច្ចការរបស់ខ្លួន ដែលអំពើនោះគឺជាកម្មវត្ថុនៃការផ្ដន្ទាទោសព្រហ្មទណ្ឌ (មាត្រា ២១១ នៃក្រមព្រហ្មទណ្ឌ)។ តាមច្បាប់រដ្ឋប្បវេណី ជនរងគ្រោះអាចទាមទារនូវសំណងការខូចខាតដែលខ្លួនបានទទួលរងពីចារីបាន (មាត្រា ៧០៩ នៃក្រមរដ្ឋប្បវេណី)។ បញ្ហាទាំងពីរនេះ គឺត្រូវចាត់ចែងដាច់ដោយឡែកពីគ្នានៅឯតុលាការ។ មានន័យថា ការជំនុំជម្រះផ្នែកព្រហ្មទណ្ឌ គឺត្រូវដំណើរការទៅតាមការដែលព្រះរាជអាជ្ញាធ្វើបណ្ដឹងអាជ្ញាប្រឆាំងនឹងចារី (ជនជាប់ចោទ)។ ដូច្នេះ នីតិវិធីនៃការវិនិច្ឆ័យផ្នែកព្រហ្មទណ្ឌត្រូវដំណើរការដោយអនុលោមទៅតាមក្រមនីតិវិធីព្រហ្មទណ្ឌ។ នាសម័យដើម ពុំមានការបែងចែកឲ្យដាច់ពីគ្នារវាងរឿងព្រហ្មទណ្ឌ និង រឿងរដ្ឋប្បវេណីទេ ក៏ប៉ុន្តែ នៅក្នុងច្បាប់ទំនើបនាពេលបច្ចុប្បន្ន ករណីទាំងពីរនេះត្រូវបានបែងចែកយ៉ាងច្បាស់លាស់ ។

ការវិនិច្ឆ័យពីករណីរដ្ឋប្បវេណី និង ករណីព្រហ្មទណ្ឌនេះត្រូវធ្វើឡើងដោយឯករាជ្យពីគ្នា។ បានសេចក្ដីថា ជាទ្រឹស្ដី ការវិនិច្ឆ័យអំពីអង្គហេតុក្នុងការជំនុំជម្រះទាំងពីរខាងលើនេះអាចខុសពីគ្នា។ ឧទាហរណ៍ នៅក្នុងការជំនុំជម្រះផ្នែកព្រហ្មទណ្ឌ ចារីអាចត្រូវបានវិនិច្ឆ័យថាគ្មានទោសដោយសារតែគ្មានកំហុសក៏ពិតមែន ក៏ប៉ុន្តែនៅក្នុងការជំនុំជម្រះផ្នែករដ្ឋប្បវេណីវិញ សាលក្រមទទួលស្គាល់ការទាមទារសំណងការខូចខាតរបស់ជនរងគ្រោះដោយសារកំហុសរបស់ចារី។ នៅក្នុងរឿងក្ដីបែបនេះ មានទស្សនៈថា ដោយសារតែកម្មវត្ថុនៃរឿងរដ្ឋប្បវេណីគឺជាការបង់ប្រាក់សំណង ដូច្នេះ បើទោះបីជាការទទួលស្គាល់កំហុសមានភាពធូរលុងជាងការទទួលស្គាល់នៅក្នុងរឿងព្រហ្មទណ្ឌក៏ដោយ ក៏មិនជាបញ្ហាអ្វីដែរ។ ផ្ទុយទៅវិញ ថ្វីបើគេក៏អាចគិតឃើញជាទ្រឹស្ដីផងដែរថា អាចមានករណីដែលនៅក្នុងរឿងព្រហ្មទណ្ឌ មានសាលក្រមកំណត់ថាមានទោស ដោយសារកំហុសរបស់ចារី ក៏ប៉ុន្តែនៅក្នុងរឿងរដ្ឋប្បវេណីវិញ សំណងការខូចខាតមិនត្រូវបានទទួលស្គាល់ដោយសារតែចារីមិនមានកំហុសក៏ដោយ ក៏ប៉ុន្តែ នៅក្នុងស្ថានភាពជាក់ស្ដែង ដូចជាពុំដែលឃើញមានករណីបែបនេះទេ (នៅក្នុងករណីបទល្មើសដែលបង្កដោយអនីតិជន ដូចជាមានករណីដែលការវិនិច្ឆ័យតាមនីតិវិធីព្រហ្មទណ្ឌរបស់តុលាការចំពោះអង្គហេតុ មានភាពខុសគ្នាពីការវិនិច្ឆ័យតាមច្បាប់រដ្ឋប្បវេណីចំពោះករណីនៃការទាមទារសំណងការខូចខាតដែរ)។

នៅបរទេស ក៏នៅតែមានប្រព័ន្ធដែលចាត់ចែងរឿងក្ដីទាំងពីរក្នុងករណីខាងលើនេះតែមួយព្រមគ្នាដែរ (ដែលគេហៅថា បណ្ដឹងរដ្ឋប្បវេណីបន្ទាប់បន្សំ)។ ឧទាហរណ៍ ដូចជានៅប្រទេសបារាំង គេមានគោលការណ៍

ស្តីពីអាទិភាពនៃរឿងព្រហ្មទណ្ឌ ដែលការវិនិច្ឆ័យនៅក្នុងការជំនុំជម្រះរឿងព្រហ្មទណ្ឌ មានឥទ្ធិពលទៅលើការជំនុំជម្រះក្នុងរឿងរដ្ឋប្បវេណី។ មានន័យថា ការវិនិច្ឆ័យអំពីភាពមាន ឬ គ្មានកំហុស ក្នុងការជំនុំជម្រះអំពីរឿងព្រហ្មទណ្ឌ នឹងចងដល់ការវិនិច្ឆ័យនៅក្នុងរឿងរដ្ឋប្បវេណី (បានសេចក្តីថា នៅមុនពេលដែលមានការវិនិច្ឆ័យអំពីរឿងព្រហ្មទណ្ឌ ការវិនិច្ឆ័យអំពីរឿងរដ្ឋប្បវេណីត្រូវផ្អាកសិន)។ ប្រព័ន្ធបែបនេះគឺមានប្រយោជន៍ដល់ការសង្គ្រោះចំពោះជនរងគ្រោះក៏ពិតមែនហើយ ក៏ប៉ុន្តែ វាក៏មានការលើកឡើងអំពីបញ្ហាដែលថា ដើម្បីជួយដល់ជនរងគ្រោះ គឺត្រូវតែចេញសាលក្រមផ្តន្ទាទោសចារី ដែលការពិតទៅពុំចាំបាច់ដាក់ទណ្ឌកម្មព្រហ្មទណ្ឌដល់ចារីនោះក៏បានដែរនោះ។ ឧទាហរណ៍ថា នៅក្នុងករណីនៃគ្រោះថ្នាក់ខាងវេជ្ជសាស្ត្រ មានការទទួលស្គាល់កំហុសរបស់គ្រូពេទ្យ ក៏ប៉ុន្តែ ប្រសិនបើមិនចេញសាលក្រមផ្តន្ទាទោសគ្រូពេទ្យទេ គឺមិនអាចទទួលស្គាល់ការទាមទារសំណងការខូចខាតរបស់ជនរងគ្រោះបានទេ ដូច្នេះ ករណីនៃការផ្តន្ទាទោសចំពោះគ្រូពេទ្យនឹងកើនច្រើនឡើង ហើយជាលទ្ធផលគឺថា គ្រូពេទ្យខ្លាចរអាលែងហ៊ានព្យាបាលអ្នកជំងឺទៀតហើយ ។

Khmer Law's Association

# ជំពូកទី ៥

# ការតំណាង

## ១ អត្ថន័យនៃរបបតំណាង

## ២ ការតំណាងដោយគ្មានសិទ្ធិ

## ៣ ការតំណាងដែលមានលក្ខណៈជារូបភាព

✎ ការតំណាងដែលមានលក្ខណៈជារូបភាពដែលហួសពីទំហំនៃសិទ្ធិតំណាង--ការពិចារណាតាមរយៈករណីសិក្សា

Khmer Law's Association

**ករណីសិក្សា៖** ដោយសារ A មានវ័យចំណាស់ហើយនោះ គាត់បានប្រគល់ភារៈគ្រប់គ្រងទ្រព្យសម្បត្តិទៅកូនរបស់គាត់ឈ្មោះ B ។ B បានធ្វើការបង់អាករលើអចលនវត្ថុ និង ទទួលប្រាក់ឈ្នួលពីអ្នកជួល ជាដើម ក្នុងនាម A ហើយបានប្រគល់ប្រាក់នោះទៅ A ជាធម្មតា។ ក្រោយមក ដោយសារអាជីវកម្មរបស់ B ខ្លួនឯងខាតឡុងចុង គាត់បានលក់អចលនវត្ថុ (ក) ដែលជាកម្មសិទ្ធិរបស់ A ដោយគ្មានការយល់ព្រមពី A ទៅឲ្យអ្នកជួលអចលនវត្ថុឈ្មោះ C ។ ដោយសារតែរៀងរហូតមក C តែងតែបង់ប្រាក់ឈ្នួលអចលនវត្ថុនោះទៅឲ្យ B ដូច្នេះ គាត់ជឿជាក់ថា B ទទួលបានសិទ្ធិតំណាងដើម្បីលក់អចលនវត្ថុនោះ។ ក្រោយពេលបានដឹងអំពីអង្គហេតុស្ដីពីការលក់ A បានប្ដឹងទាមទារឲ្យ C លុបការចុះបញ្ជីអំពីការផ្ទេរដែលបានធ្វើឡើងពី B ទៅ C ដោយអះអាងថា ខ្លួនមិនដែលបានប្រគល់សិទ្ធិតំណាងទៅឲ្យ B ដើម្បីលក់អចលនវត្ថុនោះឡើយ ។ តើតុលាការអាចទទួលស្គាល់ការទាមទាររបស់ A ដែរឬទេ?

## ១ អត្ថន័យនៃរបបតំណាង

### ក) ម្ចាស់សិទ្ធិ និង អ្នកតំណាង

សកម្មភាពគតិយុត្តមិនមែនមានន័យថាចាំបាច់ត្រូវតែធ្វើដោយខ្លួនឯងដោយផ្ទាល់នោះទេ។ ច្បាប់ទទួលស្គាល់ការដែលបុគ្គលម្នាក់ស្នើសុំឲ្យអ្នកដទៃណាម្នាក់ធ្វើសកម្មភាពគតិយុត្តជំនួសម្ចាស់សិទ្ធិបាន។ ឧទាហរណ៍ ករណីដែល A ស្នើសុំឲ្យ B ធ្វើសកម្មភាពលក់ដីដែលជាកម្មសិទ្ធិរបស់ខ្លួន ដោយ B ជាអ្នកជំនួស A ក្នុងការលក់អចលនវត្ថុនោះទៅ C (ជាធម្មតា គេឃើញថា B ត្រូវធ្វើនីតិវិធីលក់ជំនួសឲ្យ A )។ ដូច្នេះ កិច្ចសន្យាលក់ទិញត្រូវបានចុះរវាង B និង C ក៏ប៉ុន្តែវាកើតមានអានុភាពដូចគ្នាប្រៀបបានទៅនឹងការដែលម្ចាស់សិទ្ធិ A ចុះកិច្ចសន្យាជាមួយ C ដែរ (មាត្រា ៩៩ នៃក្រមរដ្ឋប្បវេណី)។ សកម្មភាពគតិយុត្តដែលធ្វើជំនួសសាមីខ្លួនបែបនេះ ហៅថា ការតំណាង រីឯជនដែលអនុវត្តសកម្មភាពតំណាងជំនួស (ករណីឧទាហរណ៍មុននេះគឺ B) ហៅថា អ្នកតំណាង។

### ខ) ការតំណាងដែលច្បាប់បានកំណត់

របបតំណាងបែបនេះត្រូវបានប្រើប្រាស់តាមរូបភាពច្រើនបែបច្រើនយ៉ាង។ ជាបឋម អនីតិជន និងនីតិជននៅក្រោមអាណាព្យាបាល (សូមមើលជំពូកទី ៤) ដោយសារតែជាជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព សកម្មភាពដែលពួកគេអាចធ្វើបានដោយឯករាជ្យគឺត្រូវបានកម្រិត។ ហើយចំពោះជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពទាំងនោះ ច្បាប់កំណត់ថា អ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាល អាចធ្វើសកម្មភាពជំនួសម្ចាស់សិទ្ធិទាំងនោះបាន។ ក្នុងករណីដែលអ្នកតំណាងត្រូវបានកំណត់តាមបញ្ញត្តិច្បាប់យ៉ាងដូច្នេះ អ្នកតំណាងនោះត្រូវបានហៅថា អ្នកតំណាងដែលច្បាប់បានកំណត់។ ដោយសារតែសមត្ថភាពទទួលសិទ្ធិរបស់ជនដែលត្រូវបានកម្រិត

សមត្ថភាពទាំងនោះត្រូវបានទទួលស្គាល់ស្មើគ្នាដូចជនដទៃទៀតដែរនោះ នៅពេលដែលជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពត្រូវទទួលសិទ្ធិ និង រ៉ាប់រងកាតព្វកិច្ចដូច្នេះ របបអ្នកតំណាងមានភាពចាំបាច់ណាស់ដើម្បីការពារជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព។ ក្នុងករណីនេះ ដោយសារតែអ្នកដែលត្រូវក្លាយជាអ្នកតំណាងដែលច្បាប់បានកំណត់ (អ្នកមានអំណាចមេបា និង អ្នកអាណាព្យាបាល) ឆន្ទៈរបស់សាមីខ្លួននឹងមិនក្លាយជាបញ្ហាឡើយ ។

## គ) ការតំណាងដោយអាណត្តិ

ម្យ៉ាងវិញទៀត ភាពចាំបាច់នៃរបបតំណាងមិនមែនត្រឹមតែសម្រាប់ការពារជនដែលត្រូវបានកម្រិតសមត្ថភាព ដោយផ្អែកលើរបបតំណាងដែលច្បាប់បានកំណត់ប៉ុណ្ណោះទេ។ ជាធម្មតា សកម្មភាពទាំងឡាយដែលមនុស្សនៅក្នុងសង្គមអាចធ្វើបានគឺមានកម្រិតព្រំដែនកំណត់ ឧទាហរណ៍ គេមិនអាចធ្វើជំនួញនៅអូសាកាផង និង នៅតូក្យូផងក្នុងពេលតែមួយបានទេ។ ហេតុដូច្នេះ ប្រសិនបើប្រើប្រាស់របបតំណាងទៅ គឺគេអាចពង្រីកទំហំនៃសកម្មភាពជំនួញបែបនេះបាន។ ម្យ៉ាងវិញទៀត របបតំណាងត្រូវបានប្រើប្រាស់ដើម្បីអាចឲ្យគេអាចប្រើប្រាស់សមត្ថភាព និង ចំណេះដឹងរបស់អ្នកជំនាញ ដូចជាក្នុងករណីការផ្ទុកផ្ដាក់ឲ្យមេធាវីជួយដោះស្រាយវិវាទ ឬ ករណីដែលគេស្នើសុំចុះបញ្ជីទៅមេធាវីដែលមានជំនាញខាងចុះបញ្ជី ជាដើម។ លើសពីនេះទៅទៀត របបអាណាព្យាបាលស្ម័គ្រចិត្តដែលប្រើប្រាស់របបតំណាង ត្រូវបានបង្កើតឲ្យមានតាមរយៈវិសោធនកម្មឆ្នាំ ១៩៩៩ ដើម្បីបំពេញបន្ថែមចំពោះរបបអាណាព្យាបាលដែលច្បាប់បានកំណត់។ មានន័យថា តាមរយៈកិច្ចសន្យា គេអាចប្រគល់ទៅឲ្យអ្នកអាណាព្យាបាលដោយស្ម័គ្រចិត្តនូវការគ្រប់គ្រងទ្រព្យសម្បត្តិ ការមើលថែទាំព្យាបាលជំងឺ និង ជួយដល់ជីវភាពរស់នៅរបស់ខ្លួន ដោយសារតែខ្លួនស្ថិតក្នុងស្ថានភាពដែលមានសមត្ថភាពមិនគ្រប់គ្រាន់ ដើម្បីយល់ដឹង និង វិនិច្ឆ័យឲ្យបានត្រឹមត្រូវដោយសារតែវិបត្តិផ្នែកបញ្ញាស្មារតី (ច្បាប់ស្ដីពីកិច្ចសន្យាអាណាព្យាបាលដោយស្ម័គ្រចិត្ត) ។

ក្នុងករណីបែបនេះ អ្នកតំណាងត្រូវបានកំណត់ទៅតាមឆន្ទៈរបស់ម្ចាស់សិទ្ធិដែលគិតថាចង់ប្រើប្រាស់របបតំណាង។ ដូច្នេះ ក្នុងន័យធៀបជាមួយការតំណាងដែលច្បាប់បានកំណត់ អ្នកតំណាងប្រភេទនេះហៅថា ការតំណាងដោយអាណត្តិ។ ដើម្បីឲ្យអ្នកដទៃធ្វើជាអ្នកតំណាងដោយអាណត្តិបានមធ្យោបាយសាមញ្ញដែលត្រូវបានប្រើប្រាស់គឺកិច្ចសន្យាអាណត្តិ (ត្រូវបានប្រើប្រាស់ក្នុងទម្រង់ជាលិខិតប្រគល់អាណត្តិ)។ មានន័យថាជាកិច្ចសន្យាដែលមានខ្លឹមសារថា ម្ចាស់សិទ្ធិប្រគល់អាណត្តិតំណាងដើម្បីធ្វើសកម្មភាពគតិយុត្តទៅអ្នកដែលត្រូវក្លាយជាអ្នកតំណាង ហើយបុគ្គលនោះទទួលយកអាណត្តិតំណាងនោះ។ អ្នកតាក់តែងសេចក្ដីព្រាងក្រមរដ្ឋប្បវេណីទំនងជាមានទស្សនៈថា សកម្មភាពដែលផ្ដល់ឲ្យនូវសិទ្ធិតំណាងគឺទាល់តែមានក្នុងកិច្ចសន្យាអាណត្តិ ក៏ប៉ុន្តែ នាពេលបច្ចុប្បន្ន សកម្មភាពដែលត្រូវបានផ្ដល់ឲ្យនូវសិទ្ធិតំណាងគឺមិនកម្រិតត្រឹមអ្វីដែលមានចែងនៅក្នុងកិច្ចសន្យាអាណត្តិប៉ុណ្ណោះទេ ក៏ប៉ុន្តែ

គេអាចគិតឃើញផងដែរនៅក្នុងករណីដែលសិទ្ធិតំណាងត្រូវបានផ្តល់ឲ្យដោយកិច្ចសន្យាការងារ ជាដើម។ ម្យ៉ាងទៀត បើទោះបីមិនមែនជាកិច្ចសន្យាក៏ដោយ ក៏វាអាចត្រូវបានបកស្រាយថាមានការផ្តល់ឲ្យអ្នកដទៃនូវសិទ្ធិតំណាងតាមរយៈសកម្មភាពឯកតោភាគីផងដែរ ។

ក៏ប៉ុន្តែ ចំពោះនីតិបុគ្គលវិញ ដោយសារតែនីតិបុគ្គលមិនអាចធ្វើសកម្មភាពដោយផ្ទាល់បាន ទើបវាចាំបាច់ដោយជៀសមិនរួចដែលត្រូវមានបុគ្គលដែលធ្វើសកម្មភាពជំនួសនីតិបុគ្គល។ នៅក្នុងក្រមរដ្ឋប្បវេណីចែងនូវបញ្ញត្តិដែលមានខ្លឹមសារថា អភិបាលត្រូវតំណាងឲ្យនីតិបុគ្គល (មាត្រា ៧៧ នៃច្បាប់ស្តីពីនីតិបុគ្គលសាជីវកម្មទូទៅ និង នីតិបុគ្គលមូលនិធិទូទៅ។ ជំពូកទី១៥ នឹងមានបង្ហាញលម្អិតអំពីនីតិបុគ្គល) ក៏ប៉ុន្តែអាចត្រូវបានបកស្រាយថាមានន័យដូចគ្នានឹងការតំណាងដែរ (ពាក្យថា ការតំណាង ក៏ត្រូវបានប្រើប្រាស់ចំពោះនីតិបុគ្គលដែរ)។

### ឃ) ចំណុចដែលជាបញ្ហានៃរបបតំណាង

យើងអាចនិយាយបានផងដែរថា របបតំណាងគឺជារបបដែលមានសារៈសំខាន់ខ្វះមិនបាន ដោយសារតែវិសាលភាពនៃសកម្មភាពរបស់មនុស្សនៅក្នុងសង្គមទំនើបបច្ចុប្បន្ននេះមានភាពធំទូលាយ។ ក៏ប៉ុន្តែ មិនមានន័យថា របបតំណាងមិនមានបញ្ហាអ្វីសោះនោះទេ។ មានន័យថា វាមានបញ្ហានៅក្នុងករណីក្រោយពេលដែលបានធ្វើកិច្ចការជំនួញជាមួយអ្នកតំណាង ហើយអ្នកតំណាងនោះគ្មានសិទ្ធិតំណាង។ បើមើលពីទស្សនៈមួយទៅ គឺថាចាំបាច់ត្រូវការពារភាគីម្ខាង (តតិយជន) ដែលបានជឿជាក់ដោយភ័ន្តច្រឡំថា អ្នកតំណាងមានសិទ្ធិតំណាង។ មានន័យថា ប្រសិនបើករណីនៃការជឿជាក់ដោយភ័ន្តច្រឡំបែបនោះ ត្រូវបានចាត់ចែងដូចគ្នានឹងករណីដែលអ្នកតំណាងមានសិទ្ធិតំណាងដែរ គឺលទ្ធផលនឹងទទួលបានដូចការរំពឹងទុករបស់ភាគីម្ខាងនោះ។ ក៏ប៉ុន្តែ ក្នុងករណីនៃការចាត់ចែងបែបនេះ ម្ចាស់សិទ្ធិនឹងអាចទទួលរងនូវការខាតបង់។ ហេតុដូច្នេះ ពីទស្សនៈមួយផ្សេងទៀត គឺថាចាំបាច់ត្រូវពិចារណាការពារទៅដល់ម្ចាស់សិទ្ធិខ្លួនផងដែរ។ របបដែលសម្របសម្រួលរវាងការការពារទៅដល់ភាគីម្ខាងទៀត (តតិយជន) ក្នុងករណីបែបនោះ និង ការការពារចំពោះម្ចាស់សិទ្ធិខ្លួន គឺជារបបតំណាងដែលមានលក្ខណៈជារូបភាព។

## ២ ការតំណាងដោយគ្មានសិទ្ធិ

### ក) ការតំណាងដោយគ្មានសិទ្ធិ

ប្រសិនបើបុគ្គលម្នាក់បានប្រគល់សិទ្ធិតំណាងទៅឲ្យបុគ្គលម្នាក់ផ្សេងទៀត ហើយអ្នកតំណាងបានធ្វើសកម្មភាពគតិយុត្តនៅក្នុងទំហំនៃសិទ្ធិតំណាង អានុភាពនៃសកម្មភាពនោះនឹងធ្លាក់ទៅលើម្ចាស់សិទ្ធិ (មានន័យថា សកម្មភាពនោះមានសុពលភាព)។ ករណីបែបនេះគឺជាករណីប្រក្រតីនៃសកម្មភាព

តំណាង ដែលជាទូទៅគេហៅថា ការតំណាងដោយមានសិទ្ធិ។ ក៏ប៉ុន្តែ ក្នុងលោកយើងនេះ មិនមែនសកម្មភាពតំណាងដែលប្រក្រតីបែបនេះសុទ្ធតែត្រូវបានធ្វើឡើងនោះទេ ពោលគឺមានអ្នកខ្លះគ្មានសិទ្ធិតំណាងតែបានក្លែងបន្លំធ្វើជាអ្នកតំណាង ហើយបានទៅធ្វើកិច្ចសន្យាជាមួយតតិយជន ជាដើម។ ឧទាហរណ៍ថា B បានបន្លំធ្វើជាអ្នកតំណាងរបស់ A ហើយបានចុះកិច្ចសន្យាជាមួយ C ក៏ប៉ុន្តែ B មិនមានសិទ្ធិតំណាងទេ។ ករណីដូចឧទាហរណ៍នេះ គេហៅថា ការតំណាងដោយគ្មានសិទ្ធិ។ ក្នុងករណីបែបនេះ អានុភាពនៃសកម្មភាពគតិយុត្តដែលបានធ្វើដោយជនដែលក្លែងធ្វើជាអ្នកតំណាង B ជាគោលការណ៍ មិនធ្លាក់ទៅលើម្ចាស់សិទ្ធិ A ទេ (មានន័យថា មោឃភាព) ។

### ខ) ការផ្តល់សច្ចានុមតិ

ក្នុងករណីដែលម្ចាស់សិទ្ធិចង់ឲ្យអានុភាពនៃសកម្មភាពនៃការតំណាងដោយគ្មានសិទ្ធិធ្លាក់មកលើខ្លួន ម្ចាស់សិទ្ធិអាចផ្តល់សច្ចានុមតិចំពោះសកម្មភាពនោះបាន (កថាខណ្ឌទី ១ មាត្រា ១១៣ នៃក្រមរដ្ឋប្បវេណី)។ សច្ចានុមតិត្រង់នេះមានន័យថា ការបង្ហាញឆន្ទៈរបស់ម្ចាស់សិទ្ធិដែលមានខ្លឹមសារទទួលស្គាល់ថាសកម្មភាពមួយជាសកម្មភាពដែលមានសិទ្ធិតំណាង នៅក្រោយពេលដែលសកម្មភាពតំណាងនោះត្រូវបានធ្វើឡើងដោយជនដែលគ្មានសិទ្ធិតំណាង។ ប្រសិនបើម្ចាស់សិទ្ធិផ្តល់សច្ចានុមតិ សកម្មភាពតំណាងដែលបានធ្វើដោយជនដែលគ្មានសិទ្ធិតំណាង សកម្មភាពនោះនឹងត្រូវចាត់ចែងដូចជាសកម្មភាពដែលមានសិទ្ធិតំណាងតាំងពីដំបូងយ៉ាងដូច្នេះដែរ ។

ម្ចាស់សិទ្ធិអាចសម្រេចបានដោយសេរីថា ផ្តល់ ឬ មិនផ្តល់សច្ចានុមតិចំពោះសកម្មភាពដែលគ្មានសិទ្ធិតំណាង។ ប្រសិនបើម្ចាស់សិទ្ធិគិតឃើញថា ការផ្តល់សច្ចានុមតិមានប្រយោជន៍សម្រាប់ខ្លួន ម្ចាស់សិទ្ធិអាចផ្តល់សច្ចានុមតិបាន ក៏ប៉ុន្តែ ប្រសិនបើគិតឃើញថា ការផ្តល់សច្ចានុមតិនោះមិនមានប្រយោជន៍សម្រាប់ខ្លួនទេ ម្ចាស់សិទ្ធិមិនផ្តល់សច្ចានុមតិក៏បានដែរ។ ក៏ប៉ុន្តែ បើមើលពីខាងភាគីម្ខាងទៀតវិញ ប្រសិនបើមិនធ្វើការបញ្ជាក់ឲ្យច្បាស់ថាមានសច្ចានុមតិ ឬ មិនមានទេ គឺនឹងបង្កើតឲ្យមានស្ថានភាពមិនប្រាកដប្រជាចំពោះភាគីម្ខាងទៀតនោះហើយ។ ដូច្នេះ វាលេចចេញនូវភាពចាំបាច់ដើម្បីការពារតាមកម្រិតចំពោះភាគីម្ខាងទៀតដែលបានជឿជាក់ទៅលើបុគ្គលដែលបានបន្លំធ្វើជាអ្នកតំណាង។

ទី ១ ភាគីម្ខាងទៀតនៃអំពើដែលគ្មានសិទ្ធិអាចដាស់តឿនឲ្យម្ចាស់សិទ្ធិឆ្លើយអំពីការផ្តល់ ឬ មិនផ្តល់សច្ចានុមតិ (មាត្រា ១១៤ នៃក្រមរដ្ឋប្បវេណី)។ អានុភាពនៃសកម្មភាពតំណាងដោយគ្មានសិទ្ធិធ្លាក់ ឬ មិនធ្លាក់ទៅលើម្ចាស់សិទ្ធិ អាចត្រូវបានកំណត់ដោយអាស្រ័យទៅលើការសម្រេចដោយម្ចាស់សិទ្ធិថាផ្តល់សច្ចាសនុមតិ ឬ បដិសេធការផ្តល់សច្ចានុមតិ។ ភាគីម្ខាងទៀតអាចដាស់តឿនឲ្យម្ចាស់សិទ្ធិឆ្លើយអំពីការផ្តល់ ឬ មិនផ្តល់សច្ចានុមតិដោយកំណត់អំឡុងពេលសមរម្យមួយដើម្បីឲ្យម្ចាស់សិទ្ធិឆ្លើយ ហើយប្រសិនបើមិនបានឆ្លើយក្នុងអំឡុងពេលដែលបានកំណត់នោះទេ គឺត្រូវចាត់ទុកថាម្ចាស់សិទ្ធិ

បដិសេធការផ្តល់សច្ចានុមតិ ។

### គ) ការលុបចោល

ទី ២ ភាគីម្ខាងទៀតអាចធ្វើការលុបចោលសកម្មភាពតំណាងដោយគ្មានសិទ្ធិបាន (មាត្រា ១១៥ នៃក្រមរដ្ឋប្បវេណី)។ មានន័យថា ក្នុងអំឡុងពេលដែលម្ចាស់សិទ្ធិមិនទាន់បានផ្តល់សច្ចានុមតិទេ ភាគីម្ខាងទៀតអាចធ្វើការលុបចោលសកម្មភាពតំណាងដោយគ្មានសិទ្ធិបាន។ ប្រសិនបើម្ចាស់សិទ្ធិបានផ្តល់សច្ចានុមតិហើយ ភាគីម្ខាងទៀតមិនអាចធ្វើការលុបចោលបានឡើយ។ ដោយសារតែតាំងពីដើមដំបូងឡើយ ភាគីម្ខាងទៀតតែងរំពឹងទុកថាអានុភាពបានធ្លាក់ទៅលើម្ចាស់សិទ្ធិហើយ ដូច្នេះនៅពេលដែលអានុភាពបានធ្លាក់ទៅលើម្ចាស់សិទ្ធិដោយសារសច្ចានុមតិរបស់ម្ចាស់សិទ្ធិហើយ ទោះបីជាសិទ្ធិលុបចោលរបស់ភាគីម្ខាងទៀតលែងមានទៀតក៏ដោយ ក៏វាពុំមែនជាការខូចប្រយោជន៍ចំពោះភាគីម្ខាងទៀតដែរ។ ម្យ៉ាងវិញទៀត ប្រសិនបើភាគីម្ខាងទៀតបានដឹងអំពីការដែលគ្មានសិទ្ធិតំណាងដែរ (ក៏ប៉ុន្តែមិនសូវមានស្ថានភាពដែលអាចសន្និដ្ឋានបានដូច្នេះទេ) គាត់មិនអាចលុបចោលបានទេ ។

### ឃ) ការទទួលខុសត្រូវរបស់អ្នកតំណាងដោយគ្មានសិទ្ធិ

ទី ៣ ភាគីម្ខាងទៀតអាចទាមទារឲ្យអ្នកតំណាងដោយគ្មានសិទ្ធិដែលបានធ្វើសកម្មភាពតំណាងដោយគ្មានសិទ្ធិតំណាងនោះ ទទួលខុសត្រូវចំពោះអំពើតំណាងបាន (មាត្រា ១១៧ នៃក្រមរដ្ឋប្បវេណី)។ បើនិយាយឲ្យជាក់លាក់ទៅ គឺថា ភាគីម្ខាងទៀតនោះអាចទាមទារ (អ្នកតំណាងដោយគ្មានសិទ្ធិ) ឲ្យអនុវត្តកាតព្វកិច្ចដូចម្ចាស់សិទ្ធិ ឬ អាចទាមទារសំណងការខូចខាតបាន។ ក៏ប៉ុន្តែ ដើម្បីឲ្យភាគីម្ខាងទៀតនោះអាចទាមទារឲ្យអ្នកតំណាងដោយគ្មានសិទ្ធិនោះទទួលខុសត្រូវបាន គឺទាល់តែវាជាករណីដែលភាគីម្ខាងទៀតនោះមិនបានដឹងអំពីការគ្មានសិទ្ធិតំណាងនោះ ហើយខ្លួនគ្មានកំហុសចំពោះការដែលមិនបានដឹងនោះ ។

## ៣ ការតំណាងដែលមានលក្ខណៈជារូបភាព

### ក) អត្ថន័យនៃការតំណាងដែលមានលក្ខណៈជារូបភាព

ចំពោះសកម្មភាពតំណាងដោយគ្មានសិទ្ធិ ប្រសិនបើមានមូលហេតុណាមួយពាក់ព័ន្ធទៅនឹងម្ចាស់សិទ្ធិដែលជាមូលហេតុខាងក្រៅដែលគ្រប់គ្រាន់សម្រាប់ធ្វើឲ្យភាគីម្ខាងទៀតបានជឿជាក់ថា អ្នកតំណាងដែលបានក្លែងបន្លំមានសិទ្ធិតំណាងយ៉ាងដូច្នេះ ការដាក់បន្ទុកទៅលើម្ចាស់សិទ្ធិឲ្យទទួលខុសត្រូវដូចគ្នាទៅនឹងករណីដែលម្ចាស់សិទ្ធិបានផ្តល់សិទ្ធិតំណាងនោះ គឺមានភាពសមរម្យ។ មានន័យថា បើទោះជាគ្មានសិទ្ធិតំណាងក៏ដោយ ក៏ត្រូវបានចាត់ទុកដូចករណីដែលមានសិទ្ធិតំណាងដែរ (អានុភាពនៃ

សកម្មភាពតំណាងត្រូវធ្លាក់ទៅលើម្ចាស់សិទ្ធិ) ដែលគេហៅថា ការតំណាងដែលមានលក្ខណៈជារូបភាព។ បើនិយាយឲ្យជាក់លាក់ទៅ មានករណី ៣ ដែលត្រូវបានទទួលស្គាល់ថាជាការតំណាងដែលមានលក្ខណៈជារូបភាព គឺករណីដែលតាមពិតទៅ ម្ចាស់សិទ្ធិមិនបានប្រគល់សិទ្ធិតំណាងទេ ក៏ប៉ុន្តែម្ចាស់សិទ្ធិបានបង្ហាញឲ្យឃើញថា ហាក់ដូចជាបានប្រគល់សិទ្ធិតំណាង (មាត្រា ១០៩ នៃក្រមរដ្ឋប្បវេណី) ករណីដែលបានធ្វើសកម្មភាពហួសពីទំហំនៃសិទ្ធិតំណាងដែលបានប្រគល់ឲ្យអ្នកតំណាង(មាត្រា ១១០ នៃក្រមរដ្ឋប្បវេណី) និង ករណីដែលបានធ្វើសកម្មភាពតំណាងក្នុងនាមជាអ្នកតំណាង បើទោះបីជាសិទ្ធិតំណាងបានរលត់ទៅហើយក៏ដោយ (មាត្រា ១១២ នៃក្រមរដ្ឋប្បវេណី) ។

## ខ) ប្រភេទទាំងបីនៃការតំណាងដែលមានលក្ខណៈជារូបភាព

ប្រភេទទី ១ គឺជាក្នុងករណីដែលតាមពិតទៅម្ចាស់សិទ្ធិមិនបានប្រគល់សិទ្ធិតំណាងទៅឲ្យជនដទៃទេ ក៏ប៉ុន្តែម្ចាស់សិទ្ធិបានបង្ហាញឲ្យភាគីម្ខាងទៀត ឬ តតិយជនបានឃើញហាក់ដូចជាគាត់បានប្រគល់សិទ្ធិតំណាងទៅឲ្យជនដទៃអញ្ចឹង។ តាមមើលទៅ អ្នកតាក់តែងសេចក្តីព្រាងក្រមរដ្ឋប្បវេណីគិតឃើញថា បញ្ញត្តិនេះគឺជាវិធីមួយក្នុងការផ្តល់ឲ្យនូវសិទ្ធិតំណាង (ជាការបង្ហាញនូវខ្លឹមសារនៃការផ្តល់ឲ្យនូវសិទ្ធិតំណាងទៅភាគីម្ខាងទៀតដោយផ្ទាល់ គឺមិនមែនផ្តល់ឲ្យទៅអ្នកតំណាងទេ) ក៏ប៉ុន្តែ នៅពេលក្រោយមក វាត្រូវបានគេយល់ថាជាប្រភេទមួយនៃការតំណាងដែលមានលក្ខណៈជារូបភាពទៅវិញ (ផ្អែកទៅលើវិសោធនកម្មឆ្នាំ ២០០៤ ចំណងជើងមាត្រាត្រូវបានដាក់ថា "ការតំណាងដែលមានលក្ខណៈជារូបភាពអាស្រ័យដោយការបង្ហាញឲ្យឃើញពីការផ្តល់ឲ្យនូវសិទ្ធិតំណាង")។ នៅក្នុងស្ថានភាពជាក់ស្តែង ដូចជាពុំសូវឃើញមានករណីដែលបាននិយាយថា ប្រគល់សិទ្ធិតំណាងឲ្យហើយ ប៉ុន្តែបែរជាមិនឲ្យវិញនោះទេ។ ប្រសិនបើយើងពិចារណាដោយយកមាត្រា ១០៩ នៃក្រមរដ្ឋប្បវេណីជាឧទាហរណ៍គឺមានដូចជាករណីដែលម្ចាស់សិទ្ធិបានអនុញ្ញាតឲ្យអ្នកដទៃប្រើប្រាស់ឈ្មោះគេក្នុងនាមជាអ្នកតំណាងរបស់ខ្លួន និង ករណីដែលមានលិខិតប្រគល់អាណត្តិដែលពុំមានសរសេរឈ្មោះអ្នកតំណាងត្រូវបានបន្តពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ ហើយក៏ត្រូវបានគេបំពេញឈ្មោះអ្នកតំណាងដែលខុសពីការរំពឹងទុក (ការចង់បាន) របស់ម្ចាស់សិទ្ធិ និង បានធ្វើសកម្មភាពតំណាង ជាដើម។ ដើម្បីឲ្យការតំណាងដែលមានលក្ខណៈជារូបភាពប្រភេទនេះត្រូវបានទទួលស្គាល់ ភាគីម្ខាងទៀតចាំបាច់ត្រូវតែសុចរិត និង គ្មានកំហុស (មានន័យថា ចាំបាច់គឺត្រូវតែមិនបានដឹងពីការដែលគ្មានសិទ្ធិតំណាង និងគ្មានកំហុសចំពោះការមិនបានដឹងនោះ) ។

ប្រភេទទី ២ គឺជាករណីដែលអ្នកតំណាងដែលត្រូវបានប្រគល់ឲ្យនូវសិទ្ធិតំណាងបានធ្វើសកម្មភាពតំណាងលើសពីសិទ្ធិតំណាង (វាត្រូវបានហៅថា ការតំណាងដែលមានលក្ខណៈជារូបភាពដោយសារលើសពីទំហំនៃសិទ្ធិតំណាង)។ ឧទាហរណ៍ដូចជាករណីដែលអ្នកតំណាងត្រូវបានស្នើឲ្យយកអចលនវត្ថុទៅដាក់ជាប្រាតិភោគដើម្បីខ្ចីប្រាក់គេ ក៏ប៉ុន្តែអ្នកតំណាងនោះបែរជាលក់អចលនវត្ថុនោះទៅវិញ។ ក្នុង

ករណីបែបនេះ ហេតុផលសមរម្យគឺចាំបាច់ដើម្បីកំណត់ថា ភាគីម្ខាងទៀតគួរជឿថា អ្នកតំណាងបានធ្វើសកម្មភាពក្នុងទំហំនៃសិទ្ធិតំណាង (វាត្រូវបានបកស្រាយដូចគ្នាទៅនឹងភាពសុចរិត និង គ្មានកំហុសចំពោះការមិនដឹងពីការដែលគ្មានសិទ្ធិតំណាង)។

ប្រភេទទី ៣ គឺជាករណីដែលបើទោះបីជាសិទ្ធិតំណាងដែលត្រូវបានប្រគល់ឲ្យម្តងបានរលត់ទៅហើយក៏ដោយ ក៏អ្នកតំណាងនៅតែធ្វើសកម្មភាពតំណាងក្នុងទំហំនៃសិទ្ធិតំណាងដែលខ្លួនធ្លាប់មានកាលពីមុនម្តងនោះ។ ក្នុងករណីនេះផងដែរ ច្បាប់កំណត់ថា វាមានភាពចាំបាច់ដែលភាគីម្ខាងទៀតត្រូវតែមិនបានដឹងពីការបានរលត់នូវសិទ្ធិតំណាង ហើយគ្មានកំហុសចំពោះការមិនបានដឹងនោះ ។

ម្យ៉ាងវិញទៀត គេអាចគិតឃើញប្រភេទផ្សេងទៀតដែលត្រូវបានអនុវត្តជាន់គ្នាជាមួយប្រភេទពីទី ១ ដល់ទី ៣ ខាងលើនេះ។ ឧទាហរណ៍ថា ក្នុងករណីអ្នកដែលធ្លាប់មានសិទ្ធិតំណាង នៅក្រោយពេលដែលសិទ្ធិតំណាងបានរលត់ហើយ បានធ្វើសកម្មភាពតំណាងលើសពីទំហំនៃសិទ្ធិតំណាងដែលធ្លាប់ត្រូវបានប្រគល់ឲ្យ ប្រសិនបើភាគីម្ខាងទៀតសុចរិត ហើយ គ្មានកំហុស ត្រូវបានបកស្រាយថាបានបង្កើតការតំណាងដែលមានលក្ខណៈជារូបភាព ហើយមាត្រា ១១០ និង ១១២ នៃក្រមរដ្ឋប្បវេណីនឹងត្រូវអនុវត្ត។

### គ) ទំនាក់ទំនងរវាងការតំណាងដែលមានលក្ខណៈជារូបភាព និង ការតំណាងដោយគ្មានសិទ្ធិ

ក៏ប៉ុន្តែ ក្នុងករណីនៃការតំណាងដែលមានលក្ខណៈជារូបភាពទាំងនេះ ខ្លឹមសារដើមគឺគ្មានសិទ្ធិតំណាងជាសារវន្តទេ ពោលគឺជាប្រភេទមួយនៃការតំណាងដែលគ្មានសិទ្ធិដែរ ដូច្នេះ គេអាចបកស្រាយថា បញ្ញត្តិស្តីពីការតំណាងដែលគ្មានសិទ្ធិដូចបានលើកឡើងក្នុងចំណុចទី ២ ក៏ត្រូវបានយកមកអនុវត្តផងដែរ។ ឧទាហរណ៍ថា បើទោះជាក្នុងករណីដែលភាគីម្ខាងទៀតអាចអះអាងអំពីការតំណាងដែលមានលក្ខណៈជារូបភាពចំពោះម្ចាស់សិទ្ធិក៏ដោយ តែមិនបានអះអាងដូច្នេះទេ ក៏ភាគីម្ខាងទៀតអាចអះអាងអំពីការតំណាងដោយគ្មានសិទ្ធិចំពោះអ្នកតំណាងដោយគ្មានសិទ្ធិ ហើយទាមទារឲ្យបំពេញកាតព្វកិច្ចបានដែរ។ ក្នុងករណីបែបនេះ អ្នកតំណាងដែលគ្មានសិទ្ធិមិនអាចអះអាងពីការកើតឡើងនូវការតំណាងដែលមានលក្ខណៈជារូបភាព ដើម្បីឲ្យខ្លួនរួចផុតពីការទទួលខុសត្រូវបានទេ។

តាមរយៈការពន្យល់ខាងលើ ទំនាក់ទំនងរវាងការតំណាងដែលមានលក្ខណៈជារូបភាព និង ការតំណាងដោយគ្មានសិទ្ធិគឺមានដូចតារាងពន្យល់ខាងក្រោម៖

**តារាងពន្យល់ ៥-១ ការតំណាងដែលមានលក្ខណៈជារូបភាព និងការតំណាងដោយគ្មានសិទ្ធិ**




## ✎ ការតំណាងដែលមានលក្ខណៈជារូបភាពដែលហួសពីទំហំនៃសិទ្ធិតំណាង--ការពិចារណាតាមរយៈករណីសិក្សា

តាមរយៈករណីសិក្សាខាងលើការកើតឡើង ឬ មិនកើតឡើងនូវសិទ្ធិតំណាងដែលក្លាយទៅជាបញ្ហាគឺជាករណីសាមញ្ញជាទូទៅមួយ។ ដោយសារតែ B បានទទួលអាណត្តិពី A ដើម្បីគ្រប់គ្រងទ្រព្យសម្បត្តិរបស់ A សូមយើងគិតថា គាត់ជាអ្នកតំណាងរបស់ A ទៅចុះ។ ដូច្នេះ ទំហំនៃសិទ្ធិតំណាងអាចត្រូវបានគិតឃើញថាត្រូវបានកម្រិតត្រឹមការចាត់ចែងបង់ពន្ធ ការប្រមូលថ្លៃឈ្នួល ជាដើមដែលមានព្រមគ្នាជាមួយនឹងការសកម្មភាពគ្រប់គ្រងអចលនវត្ថុនោះ។ ក៏ប៉ុន្តែ សកម្មភាពដូចជាការលក់អចលនវត្ថុដែលជាកម្មសិទ្ធិរបស់ A គឺត្រូវបានគិតថាជាសកម្មភាពដែលលើសពីទំហំនៃសិទ្ធិតំណាង។ មានន័យថា សកម្មភាពដែល B លក់ទៅឲ្យ C នូវអចលនវត្ថុដែលជាកម្មសិទ្ធិរបស់ A គឺជាសកម្មភាពតំណាងដោយគ្មានសិទ្ធិ ។

ក៏ប៉ុន្តែ ប្រសិនបើ C មានហេតុផលសមរម្យដែលធ្វើឲ្យខ្លួនជឿជាក់ថា B មានសិទ្ធិតំណាងដើម្បីលក់អចលនវត្ថុ បើតាមមាត្រា ១១០ នៃក្រមរដ្ឋប្បវេណី អានុភាពនៃសកម្មភាពរបស់ B នឹងធ្លាក់ទៅលើ A (នឹងត្រូវបានចាត់ចែងដូចគ្នាទៅនឹងករណីមានសិទ្ធិតំណាងដែរ)។ ដោយហេតុនេះ ការដែល C តាំងពីដើមរៀងមកបានបង់ថ្លៃឈ្នួលអចលនវត្ថុដែលជាកម្មសិទ្ធិរបស់ A ទៅឲ្យ B អាចក្លាយទៅជាហេតុផលសមរម្យដែរ ឬ យ៉ាងណានោះ នឹងក្លាយទៅជាបញ្ហា។ ដើមដំបូងឡើយ ប្រសិនបើមាន

ស្ថានភាពដែលថា B គឺជាអ្នកតំណាងរបស់ A សម្រាប់ការលក់អចលនវត្ថុនោះអាចនឹងមានឱកាសដើម្បីទទួលស្គាល់ថាជាការតំណាងដោយមានលក្ខណៈជារូបភាព (សូមមើលសេចក្តីសម្រេចរបស់តុលាការកំពូលចុះថ្ងៃទី២២ ខែ ឧសភា ឆ្នាំ ១៩៥៦ ក្នុងកម្រងសាលក្រម ឬ សាលដីការឿងក្តីរដ្ឋប្បវេណីលេខ ១០.៥ ទំព័រទី ៥៤៥) ក៏ប៉ុន្តែប្រសិនបើគ្រាន់តែជាករណីដែលធ្វើសកម្មភាពទទួលយកប្រាក់ឈ្នួលប៉ុណ្ណឹង C គួរតែសួរបញ្ជាក់ទៅ A ពីភាពមាន ឬ គ្មានសិទ្ធិតំណាង ហើយប្រសិនបើមិនបានសួរបញ្ជាក់ទេ បើទោះជា C ជឿពីភាពមានសិទ្ធិតំណាងនោះក៏ដោយ ក៏មិនអាចនិយាយបានថាមានហេតុផលសមរម្យដែរ ។

ប្រសិនបើពិចារណាបែបដូច្នេះទៅ គឺក្នុងករណីសិក្សាខាងលើ មិនមានការកើតឡើងនូវការតំណាងដែលមានលក្ខណៈជារូបភាពទេ ដូច្នេះ ការទាមទាររបស់ A ចំពោះ C ឲ្យលុបការចុះបញ្ជីអំពីការផ្ទេរត្រូវទទួលស្គាល់ ។

# ជំពូកទី ៦

# អាជ្ញាយុកាល

## ១ របបអាជ្ញាយុកាល

(១) អត្ថន័យនៃរបបអាជ្ញាយុកាល (មូលហេតុនៃអត្ថិភាព)

(២) ការលើកឡើងនូវអាជ្ញាយុកាល និង អានុភាពនៃអាជ្ញាយុកាល

(៣) ការផ្អាកអាជ្ញាយុកាល និង ការបង្អង់អាជ្ញាយុកាល

## ២ អាជ្ញាយុកាលនៃលទ្ធកម្ម

## ៣ ល័ក្ខខ័ណ្ឌនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិ

✎ ការលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិ-- ការពិចារណាតាមរយៈករណីសិក្សា

ករណីសិក្សា៖ A បានខ្ចីប្រាក់ពី B ដែលជាមិត្តធ្លាប់សិក្សានៅមហាវិទ្យាល័យជាមួយគ្នាចំនួន ១០ ម៉ឺនយ៉េនដោយសន្យាថាសងវិញ ១ ឆ្នាំក្រោយពេលខ្ចី។ ក៏ប៉ុន្តែ បើទោះបីជាអំឡុងពេលកំណត់សងបានកន្លងហួសទៅហើយក៏ដោយ A នៅតែមិនអាចសងនូវប្រាក់ដែលខ្លួនបានខ្ចីទៅ B វិញដែរ។ ចំណែក B ដោយយល់ថា A គឺជាមិត្តចាស់ធ្លាប់រាប់អានគ្នាយូរមកហើយ ក៏មិនអើពើនឹកនាទាមទារឲ្យសងវិញដែរ។ ដោយឡែក A វិញ ដោយមិនត្រូវបានទាមទារឲ្យសងដូច្នេះ ក៏ភ្លេចពីការខ្ចីប្រាក់នោះបាត់ទៅ។ ក៏ប៉ុន្តែ ក្រោយរយៈពេល ១០ ឆ្នាំ ក្រោយកាលបរិច្ឆេទសងបានកន្លងផុតទៅ ក៏ស្រាប់តែ B នឹកឃើញទាមទារ A ឲ្យសង។ តើការទាមទាររបស់ B ត្រូវបានទទួលស្គាល់ដែរឬទេ? តើ A ត្រូវតែសងជាដាច់ខាត ឬ ធ្វើយ៉ាងដូចម្តេច ?

## ១. របបអាជ្ញាយុកាល

### (១) អត្ថន័យនៃរបបអាជ្ញាយុកាល (មូលហេតុនៃអត្ថិភាព)

អាជ្ញាយុកាលគឺជារបបដែលទទួលស្គាល់ទំនាក់ទំនងនៃអង្គហេតុ ក្នុងករណីដែលទំនាក់ទំនងនៃសិទ្ធិ និងកាតព្វកិច្ចពិតប្រាកដតាមផ្លូវច្បាប់ខុសគ្នាពីស្ថានភាពអង្គហេតុដែលបានឆ្លងកាត់អំឡុងពេលដ៏យូរវែងមួយ ហើយបានបន្តឥតដាច់។ ឧទាហរណ៍ដូចជាក្នុងករណីដែលបុគ្គលម្នាក់មិនមែនជាកម្មសិទ្ធិករនៃដីមួយកន្លែងទេ ក៏ប៉ុន្តែគាត់បានកាន់កាប់ដីធ្លីនោះហាក់ដូចជាកម្មសិទ្ធិករអញ្ចឹង ក្នុងអំឡុងពេលលើសពី ២០ ឆ្នាំ គឺអាចធ្វើលទ្ធកម្មកម្មសិទ្ធិលើដីនោះបាន។ ក្នុងករណីមួយផ្សេងទៀតបុគ្គលម្នាក់មានកាតព្វកិច្ចត្រូវសងប្រាក់បំណុល ១ លានយ៉េន ក៏ប៉ុន្តប្រសិនបើគាត់មិនដែលបានទទួលការទាមទារឲ្យសងពីម្ចាស់បំណុលក្នុងអំឡុងពេលលើសពី ១០ ឆ្នាំ (នៅក្រោយកាលបរិច្ឆេទត្រូវសង) បំណុលនោះត្រូវរលត់ (ករណីមុនគឺអាជ្ញាយុកាលនៃលទ្ធកម្ម រីឯករណីក្រោយគឺអាជ្ញាយុកាលនៃការរំលត់សិទ្ធិ)។ ករណីបែបនេះ ការគោរពចំពោះស្ថានភាពអង្គហេតុដែលបានបន្តឥតដាច់ក្នុងអំឡុងពេលជាកំណត់មួយ គឺជាអាជ្ញាយុកាល។

របបអាជ្ញាយុកាល ក៏ជារបបដែលត្រូវបានទទួលស្គាល់តាំងពីយូរណាស់មកហើយដែរនៅក្នុងច្បាប់រ៉ូម៉ាំង ក៏ប៉ុន្តែ មានការជជែកដេញដោលគ្នាពីបញ្ហាដែលថាតើហេតុអ្វីបានជាមានការទទួលស្គាល់នូវអាជ្ញាយុកាល។ មកដល់ពេលបច្ចុប្បន្ននេះ ដោយពិចារណាជារួមពីអាជ្ញាយុកាលនៃលទ្ធកម្ម និង អាជ្ញាយុកាលនៃរំលត់សិទ្ធិលើបំណុល ទ្រឹស្តីមួយចំនួនធំបានលើកឡើងពីមូលហេតុនៃអត្ថិភាព ៣ យ៉ាងដូចតទៅនេះ ។

#### ក) ភាពបន្តឥតដាច់នៃស្ថានភាពអង្គហេតុ

ទី ១ ក្នុងករណីដែលស្ថានភាពអង្គហេតុ ខុសពីទំនាក់ទំនងនៃសិទ្ធិ និង កាតព្វកិច្ចពិតប្រាកដក្នុងអំឡុងពេលជាក់លាក់មួយបានបន្តឥតដាច់ ហើយឈរលើសម្មតិកម្មបែបនេះ មានទំនាក់ទំនងគតិយុត្តកើតឡើងបន្ថែមទៀត ប្រសិនបើទំនាក់ទំនងគតិយុត្តថ្មីនេះត្រូវបានបដិសេធដោយផ្អែកលើទំនាក់ទំនងសិទ្ធិ និង កាតព្វកិច្ចពិតប្រាកដ នោះអាចបង្កផលប៉ះពាល់ដល់ស្ថិរភាពគតិយុត្ត ដូច្នេះទើបបានជារបបអាជ្ញាយុកាលមានភាពចាំបាច់ដើម្បីការពារតតិយជនដែលបានជឿជាក់ទៅលើស្ថានភាពអង្គហេតុ ។

សូមយើងពិចារណាលើឧទាហរណ៍ថា មានដីមួយកន្លែងត្រូវបានធ្វើអនុប្បទានជាបន្តបន្ទាប់ពី A ទៅ B ទៅ C ហើយ C បាន និង កំពុងកាន់កាប់ជាបន្តរហូតលើសអំឡុងពេល ២០ឆ្នាំ។ ប្រសិនបើកិច្ចសន្យាលក់ទិញពី A ទៅ B ត្រូវបានទុកជាមោឃៈតាំងពីដំបូងដោយសារមូលហេតុណាមួយគឺ B មិនបានក្លាយទៅជាអ្នកកាន់កាប់ពីដំបូងទេ ហើយបើទោះបីជា C បានជឿជាក់ដោយគ្មានកំហុសថា B គឺជាកម្មសិទ្ធិករក៏ដោយ ក៏មិនអាចធ្វើលទ្ធកម្មកម្មសិទ្ធិបានដែរ (គឺជាគោលការណ៍ដែលបុគ្គលណាក៏ដោយ ក៏មិនអាចធ្វើអនុប្បទានសិទ្ធិដែលខ្លួនពុំមានទៅអ្នកដទៃបានទេ)។ ហេតុដូច្នេះ A អាចអះអាងអំពីមោឃភាពនៃកិច្ចសន្យាលក់ទិញរវាង A និង B និងយកដីនោះពី C មកវិញបាន។ ក៏ប៉ុន្តែវាមានភាពចាំបាច់ដែលត្រូវការពារ C ដែលបានជឿជាក់ថា B មានកម្មសិទ្ធិ និង បានកាន់កាប់ដីក្នុងនាមជាកម្មសិទ្ធិករអស់រយៈពេលយ៉ាងយូរហើយនោះ។ ដោយហេតុនេះហើយ ក្រមរដ្ឋប្បវេណីបានទទួលស្គាល់ឲ្យ C ធ្វើលទ្ធកម្មកម្មសិទ្ធិលើដីនោះដោយផ្អែកលើអាជ្ញាយុកាល។ ដូច្នេះ C អាចតតាំងទៅនឹងការទាមទាររបស់ A បានដោយអះអាងពីការដែលខ្លួនមានកម្មសិទ្ធិ ។

ប្រសិនបើមិនទទួលស្គាល់អាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិទេ បុគ្គលដែលគិតថាចង់ទិញអចលនវត្ថុត្រូវតែធ្វើការស្រាវជ្រាវត្រឡប់ទៅក្រោយវិញរហូតគ្មានទីបញ្ចប់ចំពោះម្ចាស់កម្មសិទ្ធិមុនៗ ដោយចាំបាច់ត្រូវតែបញ្ជាក់ឲ្យបានច្បាស់លាស់ថាតើអ្នកមុនៗទាំងនោះបានកាន់កាប់ពិតប្រាកដមែនដែរ ឬយ៉ាងណា។ ក៏ប៉ុន្តែ ដោយសារតែមានរបបអាជ្ញាយុកាល ការស្រាវជ្រាវនោះធ្វើឡើងដោយគិតទៅដល់ត្រឹមតែអំឡុងពេលដែលបានកំណត់ជាអំឡុងពេលគ្រប់គ្រាន់សម្រាប់ទទួលស្គាល់អាជ្ញាយុកាលជាការគ្រប់គ្រាន់ហើយ ។

## ខ) ភាពលំបាកក្នុងការបញ្ជាក់

ទី ២ នៅពេលដែលអំឡុងពេលដ៏យូរមួយបានកន្លងផុតទៅ ដោយសារតែការបញ្ជាក់អំពីទំនាក់ទំនងគតិយុត្តពិតប្រាកដ ដោយផ្អែកលើភស្តុតាងច្បាស់លាស់ក្លាយទៅជាការលំបាក ដូច្នេះ គឺជាការសមរម្យដែលត្រូវចាត់ទុកស្ថានភាពអង្គហេតុ ដូចជាទំនាក់ទំនងរវាងសិទ្ធិ និង កាតព្វកិច្ចពិតប្រាកដ។ ឧទាហរណ៍ថា បើទោះជា D បានបង់បំណុល ១ លានយ៉េន ដែលខ្លួនបានជំពាក់ទៅ E ហើយក៏ដោយ ស្រាប់តែ ២០ ឆ្នាំ ក្រោយមក E ទាមទារឲ្យខ្លួនសងជាថ្មីម្តងទៀត ករណីបែបនេះ ការបញ្ជាក់ដោយ

ភស្តុតាងថាខ្លួនបានបង់ហើយកាលពី ២០ ឆ្នាំមុនគឺជាការលំបាកខ្លាំងណាស់ (ការរក្សាទុកបង្កាន់ដៃទទួលឲ្យបាន ២០ ឆ្នាំ មិនមែនជារឿងធម្មតាសោះឡើយ)។ ដូច្នេះហើយ ប្រសិនបើម្ចាស់បំណុលមិនបានអនុវត្តសិទ្ធិលើបំណុលរបស់ខ្លួនក្នុងអំឡុងពេល ១០ ឆ្នាំ នៅក្រោយកាលបរិច្ឆេទសងបានកន្លងហួសទេ បំណុលនោះត្រូវរំលត់ដោយអាជ្ញាយុកាល។ ប្រសិនបើមិនទទួលស្គាល់អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលទេ នៅក្រោយពេលសងបំណុលរួចហើយ កូនបំណុលត្រូវរក្សាទុកភស្តុតាងនៃការសងបំណុលនោះរហូតជាអចិន្ត្រៃយ៍។ ក៏ប៉ុន្តែ ដោយសារតែមានការទទួលស្គាល់អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល កូនបំណុលអាចរក្សាទុកភស្តុតាងនៃការសងបំណុលត្រឹមអំឡុងពេលដែលចាំបាច់សម្រាប់អាជ្ញាយុកាលទៅបានហើយ ។

## គ) ការធ្វេសប្រហែសរបស់អ្នកមានសិទ្ធិ

ទី ៣ គឺការដែលមិនចាំបាច់ក្នុងការការពារបុគ្គលដែលលង់លក់ក្នុងសិទ្ធិរបស់ខ្លួន។ មានន័យថា ប្រសិនបើម្ចាស់សិទ្ធិបានព្រងើយកន្តើយចំពោះសិទ្ធិរបស់ខ្លួន ក្នុងអំឡុងពេលដ៏យូរដោយមិនបានអនុវត្តសិទ្ធិនោះទៅហើយ វាគ្មានតម្លៃអ្វីដែលត្រូវការពារម្ចាស់សិទ្ធិនោះទៀតទេ ដូច្នេះ យើងអាចគិតបានថា វាជាការរលត់នូវសិទ្ធិ។ ឧទាហរណ៍ថា F មានសិទ្ធិលើបំណុលចំពោះ E ១ លានយ៉េន ក៏ប៉ុន្តែប្រសិនបើព្រងើយកន្តើយក្នុងអំឡុងពេលលើសពី ១០ ឆ្នាំ ដោយមិនទាមទារឲ្យសងទេ សិទ្ធិលើបំណុលនោះត្រូវរលត់ដោយអាជ្ញាយុកាល ។

ថ្មីៗនេះ ទ្រឹស្តីមួយចំនួនធំបានលើកឡើងថា គួរតែគិតពិចារណាដល់មូលហេតុនៃអត្ថិភាព និងមូលដ្ឋាននៃប្រភេទនៃអាជ្ញាយុកាល គឺមិនមែនគិតពិចារណាពីរបបអាជ្ញាយុកាលទូទៅទេ។ ម្យ៉ាងទៀត បទប្បញ្ញត្តិដែលពាក់ព័ន្ធជាមួយអាជ្ញាយុកាលដែលត្រូវបានដាក់បញ្ចូលក្នុងក្រមរដ្ឋប្បវេណីក៏ត្រូវបានលើកឡើងដូចគ្នាដែរថា ដោយសារតែវាមានដើមកំណើតជាប្រវត្តិសាស្ត្រជាច្រើនផ្សេងៗគ្នា ទើបការយល់ដឹងជារួម (អំពីប្រភពនៃអាជ្ញាយុកាលនោះ) មានការលំបាកខ្លាំង ។

## (២) ការលើកឡើងនូវអាជ្ញាយុកាល និង អានុភាពនៃអាជ្ញាយុកាល

## ក) អានុភាពនៃអាជ្ញាយុកាល

ស្ថានភាពអង្គហេតុដែលខុសពីទំនាក់ទំនងគតិយុត្តពិតប្រាកដ នៅពេលដែលល័ក្ខខ័ណ្ឌសំខាន់ដែលកំណត់អំពីខ្លឹមសារនៃភាពបន្តឥតដាច់នៃអំឡុងពេលជាកំណត់មួយត្រូវបានបំពេញហើយ អាជ្ញាយុកាលត្រូវបានសម្រេច ហើយអានុភាពនៃអាជ្ញាយុកាលចាប់កើតមានឡើង ។ ពាក់ព័ន្ធជាមួយនឹងអាជ្ញាយុកាល កថាខណ្ឌទី ១ និង កថាខណ្ឌទី ២ មាត្រា ១៦២ នៃក្រមរដ្ឋប្បវេណីចែងថា "......ត្រូវធ្វើលទ្ធកម្មកម្មសិទ្ធិ" កថាខណ្ឌទី ១ នៃមាត្រា ១៦៧ ចែងថា "សិទ្ធិលើបំណុល......ត្រូវរលត់"

រីឯកថាខណ្ឌទី ២ បញ្ញត្តថា "សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀតក្រៅពីសិទ្ធិលើបំណុល និង កម្មសិទ្ធិ...... ត្រូវរលត់"។ ប្រសិនបើយើងពិចារណាពីបញ្ញត្តិនីមួយៗទាំងនេះទៅ យើងឃើញថានៅពេលដែលល័ក្ខខ័ណ្ឌអាជ្ញាយុកាលត្រូវបានបំពេញ (នៅពេលសម្រេចអាជ្ញាយុកាល) អានុភាពនោះនឹងកើតឡើងជាធម្មតា។ ក៏ប៉ុន្តែ មាត្រា ១៤៥ នៃក្រមរដ្ឋប្បវេណីចែងថា ប្រសិនបើភាគីមិនបានលើកឡើងនូវអាជ្ញាយុកាលទេ តុលាការមិនអាចធ្វើការវិនិច្ឆ័យដោយផ្អែកលើអាជ្ញាយុកាលបានឡើយ។ ការលើកឡើងនូវអាជ្ញាយុកាលត្រង់នេះគឺមានន័យថា បុគ្គលដែលត្រូវទទួលផលប្រយោជន៍ពីអាជ្ញាយុកាល (ប្រសិនបើជាករណីអាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិ បុគ្គលនោះសំដៅលើបុគ្គលដែលត្រូវធ្វើលទ្ធកម្មដោយអាជ្ញាយុកាល ឬ ប្រសិនបើជាអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល គឺកូនបំណុល ជាដើម) ធ្វើសកម្មភាពទទួលផលប្រយោជន៍ពីអាជ្ញាយុកាល។ បានសេចក្ដីថា ប្រសិនបើភាគីមិនបានបង្ហាញឆន្ទៈដែលមានខ្លឹមសារទទួលនូវផលប្រយោជន៍ពីអាជ្ញាយុកាលទេ តុលាការមិនអាចធ្វើការវិនិច្ឆ័យដោយផ្អែកលើការកើតឡើងនូវអានុភាពនៃអាជ្ញាយុកាលជាមូលដ្ឋានទេ។

ឧទាហរណ៍ថា បើទោះជា B ដែលមានសិទ្ធិលើបំណុលលើ A បានព្រងើយកន្តើយពុំទារបំណុលអស់រយៈពេលលើសពី ១០ ឆ្នាំ នៅក្រោយកាលបរិច្ឆេទសងក៏ដោយ តែបានទារឲ្យ A សងនៅពេលក្រោយ ហើយ A មិនបានអះអាងពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលទេ តែបែរជាអះអាងថាបានសងបំណុលរួចហើយទៅវិញ តុលាការមិនអាចវិនិច្ឆ័យដោយផ្អែកលើអាជ្ញាយុកាលបានទេ។ ហេតុដូច្នេះ ប្រសិនបើ A មិនអាចបញ្ជាក់ពីអង្គហេតុស្ដីពីការសងបានទេ តុលាការនឹងចេញសាលក្រមបង្គាប់ឲ្យ A សងប្រាក់ហើយ។ យើងអាចមើលឃើញថាមានភាពផ្ទុយគ្នារវាងបញ្ញត្តិដែលពាក់ព័ន្ធជាមួយនឹងអាជ្ញាយុកាលនៃការរំលត់សិទ្ធិ ឬ អាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិ និង បញ្ញត្តិស្ដីពីការលើកឡើងអាជ្ញាយុកាល។

### ខ) ការពន្យល់តាមន័យច្បាប់សារធាតុ និង តាមន័យច្បាប់នីតិវិធី

ដើម្បីស្វែងយល់ជារួមពីបញ្ញត្តិទាំងឡាយនោះ ទស្សនៈនៃយុត្តិសាស្ត្រតុលាការ និង ទ្រឹស្ដីសិក្សាត្រូវបានបែងចែកពាក់ព័ន្ធទៅនឹងបញ្ហាថាតើត្រូវបកស្រាយអានុភាពនៃអាជ្ញាយុកាលយ៉ាងដូចម្ដេច។ ប្រសិនបើបែងចែកឲ្យទូលាយទៅ មានទស្សនៈពីរដែលផ្ទុយគ្នា។ ទស្សនៈទី ១ គឺថា តាមរយៈការសម្រេចអាជ្ញាយុកាល អានុភាពតាមច្បាប់សារធាតុនឹងកើតឡើង ដោយការទទួលសិទ្ធិ ឬ ការរំលត់សិទ្ធិ (ការពន្យល់តាមន័យច្បាប់សារធាតុ)។ ហើយចំពោះការលើកឡើងនូវអាជ្ញាយុកាលដោយភាគីមានទស្សនៈ ២ គឺទស្សនៈដែលយកការលើកឡើងនោះធ្វើជាមធ្យោបាយតទល់ និង ការពារខ្លួនក្នុងបណ្ដឹង និង ទស្សនៈដែលគិតថា អានុភាពតាមច្បាប់សារធាតុមិនជាស្ថាពរទេ ដូច្នេះ អានុភាពនៃអាជ្ញាយុកាលនឹងត្រូវបានកំណត់ត្រង់ភាពមាន ឬ គ្មានការលើកឡើងនូវអាជ្ញាយុកាល។ ទស្សនៈ ទី ២ ពន្យល់ថាអាជ្ញាយុកាលគឺជារបបតាមច្បាប់នីតិវិធី ហើយការលើកឡើងនូវអាជ្ញាយុកាលគឺជាការដាក់

នូវភស្តុតាងដែលកំណត់ដោយច្បាប់ (ការពន្យល់តាមន័យច្បាប់នីតិវិធី)។ នៅក្នុងស្ថានភាពជាក់ស្តែង ការបកស្រាយបញ្ញត្តិនីមួយៗនោះពុំសូវមានផលប៉ះពាល់អ្វីទៅលើភាពខុសគ្នានៃរចនាសម្ព័ន្ធច្បាប់នោះទេ ។

ដូច្នេះ ភាពផ្ទុយគ្នានៃទស្សនៈចំពោះអានុភាពនៃអាជ្ញាយុកាលមានដូចខាងលើនេះក៏ពិតមែន ប៉ុន្តែ ប្រសិនបើភាគីមិនបានលើកឡើងទេ អានុភាពនៃអាជ្ញាយុកាលក៏មិនត្រូវបានទទួលស្គាល់ដែរ។ មានន័យថា បើទោះបីជាអាជ្ញាយុកាលបានសម្រេចហើយក៏ដោយ ប្រសិនបើបុគ្គលដែលគិតថា មិនចង់ឲ្យរួចពីបំណុលដោយសារលើកឡើងនូវអាជ្ញាយុកាលទេ គឺច្បាប់ទទួលស្គាល់នូវសេរីភាពក្នុងការមិនលើកឡើងពីអាជ្ញាយុកាលនោះ។ ឧទាហរណ៍ថា បំណុលត្រូវរលត់ដោយអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលក៏ពិតមែន តែកូនបំណុលគិតថាចង់សងបំណុល គឺគាត់អាចសងបំណុលបាន ដោយមានសុពលភាព។ មានន័យថា មិនមែនជាការសងបំណុលដែលគ្មាននោះទេ ប៉ុន្តែ ត្រូវបានវាយតម្លៃថាបានធ្វើការសងបំណុលដែលមានអត្ថិភាព ។

## គ) វិសាលភាពនៃអ្នកដែលមានសិទ្ធិលើកឡើងនូវអាជ្ញាយុកាល

មាត្រា ១៤៥ នៃក្រមរដ្ឋប្បវេណីបានចែងកំណត់ឲ្យត្រឹមតែ "ភាគី" ប៉ុណ្ណោះដែលជាអ្នកអាចលើកឡើង (អ្នកមានសិទ្ធិលើកឡើង) ពីអាជ្ញាយុកាល។ ដូច្នេះ វិសាលភាពនៃអ្នកដែលមានសិទ្ធិលើកឡើងពីអាជ្ញាយុកាលក្លាយជាបញ្ហា ក៏ប៉ុន្តែ យុត្តិសាស្ត្ររបស់តុលាការបានបកស្រាយថា អ្នកដែលមានសិទ្ធិលើកឡើង គឺជាអ្នកដែលទទួលផលប្រយោជន៍ដោយផ្ទាល់ពីអាជ្ញាយុកាល។ ជាឧទាហរណ៍ បើក្នុងករណីអាជ្ញាយុកាលនៃលទ្ធកម្ម គឺបុគ្គលដែលធ្វើលទ្ធកម្មសិទ្ធិដោយផ្អែកលើអាជ្ញាយុកាល ហើយចំពោះករណីអាជ្ញាយុកាលនៃការរំលត់សិទ្ធិវិញ គឺបុគ្គលដែលទទួលផលប្រយោជន៍ដោយផ្ទាល់ គឺកូនបំណុលដែលត្រូវរួចផុតពីបំណុលដោយសារអាជ្ញាយុកាល។ យុត្តិសាស្ត្រតុលាការមានទំនោរទៅរកការពង្រីកវិសាលភាពនៃបុគ្គលដែលមានសិទ្ធិលើកឡើងនូវអាជ្ញាយុកាលដែលរាប់បញ្ចូលទាំងអ្នកធានារបស់កូនបំណុល (បុគ្គលដែលបានធ្វើការសន្យាថានឹងសងបំណុលជំនួសកូនបំណុល ប្រសិនបើកូនបំណុលមិនសងទេ) អ្នកធានាដោយវត្ថុ (បុគ្គលដែលបានយកទ្រព្យសម្បត្តិរបស់ខ្លួនទៅដាក់ដើម្បីធានាបំណុលរបស់អ្នកដទៃ។ ក្នុងករណីដែលបំណុលមិនត្រូវបានសងទេ ម្ចាស់បំណុលអាចទទួលការសងពីទ្រព្យនោះ) តតិយជនដែលធ្វើលទ្ធកម្មនូវអចលនវត្ថុហ៊ីប៉ូតែក (ជនដែលបានធ្វើលទ្ធកម្មលើអចលនវត្ថុដែលត្រូវបានដាក់ជាហ៊ីប៉ូតែកដើម្បីធានាបំណុលរបស់កូនបំណុល) ថាជាជនដែលមានសិទ្ធិលើកឡើងនូវអាជ្ញាយុកាល ។

## ឃ) ការបោះបង់ចោលនូវផលប្រយោជន៍នៃអាជ្ញាយុកាល

ផ្ទុយពីការលើកឡើងអាជ្ញាយុកាលដែលជាសកម្មភាពដើម្បីទទួលផលប្រយោជន៍ពីអាជ្ញាយុកាល ការបង្ហាញឆន្ទៈមិនទទួលយកនូវផលប្រយោជន៍ពីអាជ្ញាយុកាល ហៅថាការបោះបង់ចោលផលប្រយោជន៍នៃអាជ្ញាយុកាល។ ច្បាប់បញ្ញត្តថា ការបោះបង់ចោលផលប្រយោជន៍នៃអាជ្ញាយុកាលមិនអាចបោះបង់ចោលនៅមុនពេលដែលអាជ្ញាយុកាលបានសម្រេចទេ (មាត្រា ១៥៦ នៃក្រមរដ្ឋប្បវេណី)។ ប្រសិនបើទទួលស្គាល់ការបោះបង់ចោលនៅមុនពេលដែលអាជ្ញាយុកាលបានសម្រេចតាមរយៈការព្រមព្រៀងរបស់ភាគី វានឹងក្លាយជាការបង្កើតឲ្យមានទំនាក់ទំនងនៃសិទ្ធិលើបំណុល និង បំណុលដែលមិនដែលមានអាជ្ញាយុកាលជារៀងរហូត។ ឧទាហរណ៍ យើងអាចគិតឃើញករណីនៅពេលឲ្យប្រាក់ខ្ចីទៅបុគ្គលដែលកំពុងជួបការលំបាក ដោយមានភ្ជាប់ការប្រាក់ខ្ពស់ ហើយកូនបំណុលអាចត្រូវបានគេធ្វើឲ្យព្រមបោះបង់ចោលផលប្រយោជន៍នៃអាជ្ញាយុកាលជាមុន។ បែបនេះ ប្រសិនបើទទួលស្គាល់នូវការបោះបង់ចោលជាមុនទៅ វានឹងធ្វើឲ្យកូនបំណុលខាតប្រយោជន៍យ៉ាងខ្លាំង ហើយដូចដែលបានលើកពីខាងដើម ដោយហេតុថា វាផ្ទុយពីខ្លឹមសារនៃរបបអាជ្ញាយុកាល ដូច្នេះ ការបោះបង់ចោលជាមុនត្រូវបានបដិសេធ ។

### (៣) ការផ្អាកអាជ្ញាយុកាល និង ការបង្អង់អាជ្ញាយុកាល

### ក) ការផ្អាកអាជ្ញាយុកាល

ដើម្បីឲ្យអាជ្ញាយុកាលបានសម្រេច ស្ថានភាពអង្គហេតុក្នុងអំឡុងពេលជាកំណត់មួយចាំបាច់ត្រូវតែបន្តឥតដាច់ ក៏ប៉ុន្តែ នៅក្នុងចន្លោះនៃអំឡុងពេលដែលត្រូវបានកំណត់ដោយច្បាប់ ប្រសិនបើកើតមានហេតុណាមួយ (ហេតុនៃការផ្អាក) នៃការអនុវត្តសិទ្ធិដោយអ្នកមានសិទ្ធិ អំឡុងពេលនៃអាជ្ញាយុកាលត្រូវផ្អាក ហើយគិតមកត្រឹមពេលផ្អាកនេះ អំឡុងពេលនោះនឹងក្លាយជាគ្មានន័យតាមផ្លូវច្បាប់។ បែបនេះហៅថា ការផ្អាកអាជ្ញាយុកាល។ ដូច្នេះ នៅពេលដែលហេតុនៃការផ្អាកនេះបានរលត់ទៅ អំឡុងពេលនៃអាជ្ញាយុកាលនឹងចាប់ដំណើរការសាជាថ្មី (មាត្រា ១៥៧ នៃក្រមរដ្ឋប្បវេណី)។ ឧទាហរណ៍ថា ក្នុងករណីដែល A មានសិទ្ធិលើបំណុលចំពោះ B ១ លានយ៉េន ហើយ A បានព្រងើយកន្តើយមិនទាមទារឲ្យ B សងអស់រយៈពេល ៦ ឆ្នាំ ក្រោយពីពេលត្រូវសងបានមកដល់ តែក្រោយមក បានដាស់តឿនឲ្យ B សង ហើយ B បានទទួលស្គាល់ថាខ្លួនបានជំពាក់បំណុលយ៉ាងដូច្នេះ អាជ្ញាយុកាលនៃការរំលត់សិទ្ធិបំណុលត្រូវផ្អាក។ ដូច្នេះ ចាប់ពីពេលដែល B បានទទួលស្គាល់បំណុល អាជ្ញាយុកាលថ្មីចាប់ដំណើរការ ហើយប្រសិនបើមិនទាន់ហួស ១០ ឆ្នាំ ក្រោយពីពេលនោះទេ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលមិនអាចសម្រេចបានឡើយ ។

### ខ) មូលហេតុនៃការផ្អាក

ហេតុនៃការផ្អាកអាជ្ញាយុកាលមានលើកឡើងក្នុងមាត្រា ១៤៧ នៃក្រមរដ្ឋប្បវេណី។ ហេតុទាំងនោះមានដូចជាទី ១ គឺការទាមទារ ទី ២ គឺការរឹបអូស ការរឹបអូសជាបណ្ដោះអាសន្ន ឬ ការចាត់ចែងជាបណ្ដោះអាសន្ន និងទី ៣ ការទទួលស្គាល់កាតព្វកិច្ច។ បញ្ញត្តិលម្អិតចំពោះហេតុនីមួយៗគឺមាននៅក្នុងមាត្រាចាប់ពីមាត្រា ១៤៩ នៃក្រមរដ្ឋប្បវេណី។

ហេតុនៃការផ្អាកទី ១ និងទី ២ គឺជាហេតុនៃការផ្អាកដោយសារការអនុវត្តសិទ្ធិរបស់អ្នកមានសិទ្ធិ។ ការអនុវត្តសិទ្ធិមួយណាក៏ដោយ គឺសំដៅទៅលើការអនុវត្តសិទ្ធិរបស់អ្នកមានសិទ្ធិតាមរយៈតុលាការ (មាត្រា ១៤៩ ដល់មាត្រា ១៥៥ នៃក្រមរដ្ឋប្បវេណី)។ នៅពេលដែលល័ក្ខខ័ណ្ឌនៃការអនុវត្តសិទ្ធិបានរលត់ ដោយសារការលើកចោលបណ្ដឹង ការដកបណ្ដឹង និង ការលុបចោលការរឹបអូស ជាដើម អានុភាពនៃការផ្អាកអាជ្ញាយុកាលមិនកើតមានឡើងទេ (មាត្រា ១៤៩ និង មាត្រា ១៥៤ ជាដើម នៃក្រមរដ្ឋប្បវេណី) ។

ក៏ប៉ុន្តែ ប្រសិនបើអ្នកមានសិទ្ធិ (ជាពិសេស ម្ចាស់បំណុល) បានធ្វើការទាមទារក្រៅផ្លូវតុលាការទៅភាគីម្ខាងទៀត គឺតាមវិធីការ ដាស់តឿន ហើយដរាបណាមិនចាត់វិធានការទាមទារច្បាស់លាស់តាមផ្លូវតុលាការក្នុងអំឡុងពេល ៦ ខែទេ អានុភាពនៃការផ្អាកអាជ្ញាយុកាលមិនកើតមានឡើងទេ (មាត្រា ១៥៣ នៃក្រមរដ្ឋប្បវេណី)។ ក៏ប៉ុន្តែ មិនមែនមានន័យថា ការដាស់តឿនក្រៅផ្លូវតុលាការនោះមិនមានន័យអ្វីនោះទេ ក៏ប៉ុន្តែ វាមានន័យថា នៅដំណាក់កាលដែលមើលទៅអំឡុងពេលនៃអាជ្ញាយុកាលជិតផុតហើយ ជាបឋម តាមរយៈការដាស់តឿន ម្ចាស់សិទ្ធិអាចទទួលបានពេល ៦ ខែ ជារយៈពេលដើម្បីរៀបចំធ្វើការទាមទារតាមផ្លូវតុលាការ ។

ហេតុនៃការផ្អាកទី ៣ គឺជាការទទួលស្គាល់ជាវិជ្ជមានពីខាងកូនបំណុលនូវអត្ថិភាពនៃសិទ្ធិលើបំណុល។ ដោយសារតែអ្នកត្រូវទទួលផលប្រយោជន៍ពីការសម្រេចអាជ្ញាយុកាលទទួលស្គាល់ហើយដូច្នេះ វាពុំទាមទារជាពិសេសនូវទម្រង់បែបបទអ្វីនោះទេ។ បានសេចក្ដីថា ការទទួលស្គាល់កាតព្វកិច្ចអាចធ្វើបានមិនត្រឹមតែក្នុងទម្រង់ជាលាយលក្ខណ៍អក្សរប៉ុណ្ណោះទេ តែក៏អាចទទួលស្គាល់ដោយផ្ទាល់មាត់ដែរ។ ដោយឡែក ក្រៅពីហេតុនៃការផ្អាកខាងលើនេះ ហេតុនៃការផ្អាក ជាពិសេសចំពោះអាជ្ញាយុកាលនៃលទ្ធកម្មត្រូវបានចែង ដែលជាការផ្អាកការកាន់កាប់របស់អ្នកដែលគិតថាចង់ធ្វើលទ្ធកម្មដោយអាជ្ញាយុកាល (មាត្រា ១៦៤ នៃក្រមរដ្ឋប្បវេណី)។ បើប្រៀបធៀបជាមួយការផ្អាកនៃមាត្រា ១៤៧ នៃក្រមរដ្ឋប្បវេណីដែលហៅថាការផ្អាកដែលកំណត់ដោយច្បាប់ ការផ្អាកនេះហៅថាការផ្អាកដោយស្វ័យប្រវត្តិ។ អានុភាពនៃការផ្អាកដែលកំណត់ដោយច្បាប់ កើតមានដោយមិនដាច់ខាតតែរវាងភាគី និង អ្នកទទួលបន្តតែប៉ុណ្ណោះ (មាត្រា ១៤៨ នៃក្រមរដ្ឋប្បវេណី) ដោយឡែកអានុភាពនៃការផ្អាកដោយស្វ័យប្រវត្តិគឺកើតមានជាដាច់ខាត (មានន័យថាកើតមានចំពោះបុគ្គលគ្រប់រូប)។ ក៏ប៉ុន្តែ

ដោយសារតែការផ្អាកការកាន់កាប់គឺជាការខ្វះនូវល័ក្ខខ័ណ្ឌកាន់កាប់ ដូច្នេះ ការផ្អាកអាជ្ញាយុកាលនោះអាចគិតបានថាជារឿងធម្មតា ។

### គ) មូលហេតុនៃការបង្អង់

ផ្ទុយពីការផ្អាកអាជ្ញាយុកាលដូចបានរៀបរាប់ខាងលើ នៅក្នុងករណីដែលមានស្ថានភាពលំបាកសម្រាប់ម្ចាស់សិទ្ធិក្នុងការអនុវត្តសិទ្ធិនៅពេលអាជ្ញាយុកាលត្រូវសម្រេច ការពន្យារពេលវេលាសម្រេចអាជ្ញាយុកាល គឺជាការបង្អង់អាជ្ញាយុកាល។ ឧទាហរណ៍ថា នៅមុនពេលបន្តិចនៃអាជ្ញាយុកាលត្រូវសម្រេចដោយសារតែអ្នកមានសិទ្ធិជាអនីតិជនដែលមិនអាចអនុវត្តសិទ្ធិដោយឯកពាជ្យបាន ក៏ប៉ុន្តែគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ (ដោយសារតែអ្នកមានអំណាចមេបាបានទទួលមរណភាព ឬ អ្នកអាណាព្យាបាលមិនទាន់ជ្រើសតាំងបាន ជាដើម) ដូច្នេះ អាជ្ញាយុកាលមិនត្រូវបានសម្រេចក្នុងអំឡុងពេល ៦ ខែ គិតចាប់ពីពេលដែលអ្នកនោះបានក្លាយទៅជាសមត្ថជន ឬ ពីពេលដែលអ្នកអាណាព្យាបាលត្រូវបានជ្រើសតាំងឡើយ (កថាខណ្ឌទី ១ មាត្រា ១៥៨ នៃក្រមរដ្ឋប្បវេណី)។ម្យ៉ាងវិញទៀត ក្នុងករណីដែលមិនអាចផ្អាកអាជ្ញាយុកាលបាន ដោយសារតែមានគ្រោះធម្មជាតិនៅពេលសម្រេចអាជ្ញាយុកាល អាជ្ញាយុកាលមិនត្រូវបានសម្រេចឡើយក្នុងអំឡុង ២ សប្តាហ៍ ក្រោយពីឧបសគ្គដែលបង្កឡើងដោយគ្រោះធម្មជាតិនោះបានរលត់ (មាត្រា ១៦១ នៃក្រមរដ្ឋប្បវេណី)។ ក្នុងន័យនេះ ការបង្អង់អាជ្ញាយុកាល គឺខុសពីការផ្អាកអាជ្ញាយុកាល ដោយគ្រាន់តែជាការបង្អង់អំឡុងពេលដែលអាជ្ញាយុកាលត្រូវសម្រេចបន្តិចបន្តួចប៉ុណ្ណោះ។ ចំពោះហេតុនៃការបង្អង់គឺមានចែងលម្អិតក្នុងក្រមរដ្ឋប្បវេណីចាប់ពីមាត្រា ១៥៨ ។

## ២ អាជ្ញាយុកាលនៃលទ្ធកម្ម

### ក) ល័ក្ខខ័ណ្ឌនៃអាជ្ញាយុកាលនៃលទ្ធកម្ម

អាជ្ញាយុកាលនៃលទ្ធកម្មមានចែងក្នុងក្រមរដ្ឋប្បវេណី ចាប់ពីមាត្រា ១៦២។ កម្មវត្ថុទាំងអស់នៃអាជ្ញាយុកាលនៃលទ្ធកម្មគឺជាសិទ្ធិលើទ្រព្យសម្បត្តិ ក៏ប៉ុន្តែមាត្រា ១៦២ ចែងពាក់ព័ន្ធជាមួយកម្មសិទ្ធិរីឯសិទ្ធិលើទ្រព្យសម្បត្តិក្រៅពីនោះគឺមានចែងនៅក្នុងមាត្រា ១៦៣ នៃក្រមរដ្ឋប្បវេណី។ ថ្វីត្បិតតែបទប្បញ្ញត្តិខុសគ្នាក៏ដោយ ក៏ប៉ុន្តែទស្សនៈជាមូលដ្ឋានគឺដូចគ្នាទាំងអស់ ។

បុគ្គលដែលមិនមែនជាកម្មសិទ្ធិករ ប្រសិនបើបានកាន់កាប់វត្ថុរបស់អ្នកដទៃក្នុងអំឡុងពេល ២០ ឆ្នាំដោយមានឆន្ទៈយកជាកម្មសិទ្ធិដោយសន្តិវិធី និង មានការដឹងឮជាសាធារណៈ បុគ្គលនោះអាចធ្វើលទ្ធកម្មកម្មសិទ្ធិដោយអាជ្ញាយុកាលលើវត្ថុនោះបាន (កថាខណ្ឌទី ១ មាត្រា ១៦២ នៃក្រមរដ្ឋប្បវេណី)។ ដោយឡែក បន្ថែមលើល័ក្ខខ័ណ្ឌមួយចំនួនទៀតនៃការកាន់កាប់ដូចខាងលើ ចាប់ពីពេលចាប់ផ្តើមកាន់កាប់

ប្រសិនបើអ្នកកាន់កាប់បានកាន់កាប់ដោយសុចរិត និង គ្មានកំហុស (ការដែលបានជឿជាក់ថា ខ្លួនជាម្ចាស់កម្មសិទ្ធិដោយគ្មានកំហុស) អំឡុងពេលចាំបាច់សម្រាប់អាជ្ញាយុកាលនឹងត្រូវបង្រួមមកត្រឹម ១០ ឆ្នាំវិញ (កថាខណ្ឌទី ២ នៃមាត្រាដដែល) ។

បុគ្គលដែលបានអះអាងពីអាជ្ញាយុកាល ពុំចាំបាច់ធ្វើការបញ្ជាក់ពីល័ក្ខខ័ណ្ឌទាំងនេះទេ។ ដើម្បីបញ្ជាក់ពីភាពបន្តឥតដាច់នៃការកាន់កាប់ ប្រសិនបើអាចបញ្ជាក់ពីការបានកាន់កាប់នៅមុនអំឡុងពេល និង ក្រោយអំឡុងពេល ច្បាប់ចាត់ទុកថា ការកាន់កាប់បានបន្តឥតដាច់ក្នុងអំឡុងពេលនោះ (កថាខណ្ឌទី ២ មាត្រា ១៨៦ នៃក្រមរដ្ឋប្បវេណី)។ ម្យ៉ាងវិញទៀត ប្រសិនបើអាចបញ្ជាក់បានពីការកាន់កាប់ហើយនោះ គេសន្មតថាបានកាន់កាប់ដោយមានឆន្ទៈយកជាកម្មសិទ្ធិ ដោយសុចរិត សន្តិវិធី និង ទទួលការដឹងឮជាសាធារណៈ (កថាខណ្ឌទី ១ នៃមាត្រាដដែល)។ ចំពោះភាពគ្មានកំហុស ដោយសារតែគ្មានមាត្រាដែលចែងកំណត់ដូច្នោះ បុគ្គលដែលអះអាងអំពីអាជ្ញាយុកាលនៃអំឡុងពេល ១០ ឆ្នាំ ត្រូវតែធ្វើការបញ្ជាក់ ។

## ខ) ការបញ្ជាក់ពីអាជ្ញាយុកាលនៃលទ្ធកម្ម

លទ្ធកម្មកម្មសិទ្ធិដែលបុគ្គលដែលធ្វើលទ្ធកម្មដោយអាជ្ញាយុកាល គឺធ្វើលទ្ធកម្មកម្មសិទ្ធិដោយសារការបានកាន់កាប់ក្នុងអំឡុងពេលជាក់លាក់មួយ ហើយត្រូវបានចាត់ទុកថាជាលទ្ធកម្មតាំងពីដើមដំបូង។ មានន័យថា ដោយសារតែមិនមែនជាលទ្ធកម្មបន្តដោយផ្អែកលើកម្មសិទ្ធិពីម្ចាស់កម្មសិទ្ធិដើម បុគ្គលដែលបានធ្វើលទ្ធកម្មកម្មសិទ្ធិត្រូវធ្វើលទ្ធកម្មកម្មសិទ្ធិទាំងស្រុងដោយមិនទទួលឥទ្ធិពលពីបន្ទុក (ឧទាហរណ៍មានដូចជាសិទ្ធិហ៊ីប៉ូតែក ជាដើម) ដែលមានភ្ជាប់ជាមួយកម្មសិទ្ធិដើមនោះទេ ។

# ៣ ល័ក្ខខ័ណ្ឌនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិ

## ក) ល័ក្ខខ័ណ្ឌនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិ

ចំពោះអាជ្ញាយុកាលនៃការរំលត់សិទ្ធិ មានចែងក្នុងក្រមរដ្ឋប្បវេណី ចាប់ពីមាត្រា ១៦៦។ សិទ្ធិលើបំណុល ប្រសិនបើមិនបានអនុវត្តក្នុងអំឡុងពេល ១០ ឆ្នាំទេ នឹងត្រូវរលត់ដោយអាជ្ញាយុកាល (កថាខណ្ឌទី ១ មាត្រា ១៦៧ នៃក្រមរដ្ឋប្បវេណី)។ ម្យ៉ាងវិញទៀត សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀតក្រៅពីសិទ្ធិលើបំណុល ឬ កម្មសិទ្ធិ ប្រសិនបើមិនបានអនុវត្តក្នុងអំឡុងពេល ២០ ឆ្នាំទេ នឹងត្រូវរលត់ដោយអាជ្ញាយុកាល (កថាខណ្ឌទី ២ នៃមាត្រាដដែល) ។ ក៏ប៉ុន្តែ ចំពោះកម្មសិទ្ធិវិញគឺពុំមានភ្ជាប់អាជ្ញាយុកាលនៃការរំលត់សិទ្ធិទេ។ ជាការពិត ប្រសិនបើមានករណីលទ្ធកម្មកម្មសិទ្ធិដោយអាជ្ញាយុកាល ម្ចាស់កម្មសិទ្ធិពិតប្រាកដត្រូវបាត់បង់កម្មសិទ្ធិ ហើយអ្នកផ្សេងបានធ្វើលទ្ធកម្មកម្មសិទ្ធិ ដោយផ្អែកលើអាជ្ញាយុកាលនៃលទ្ធកម្មដែលនោះជាអានុភាពដែលឆ្លុះបញ្ចាំងឲ្យឃើញនូវការបាត់បង់កម្មសិទ្ធិ (ការ

បង្កើតកម្មសិទ្ធិបានតែមួយទៅលើវត្ថុមួយ។ មានលើកមកពន្យល់លម្អិតក្នុងជំពូកទី ៨) ។ បានសេចក្តីថា បើទោះជាម្ចាស់កម្មសិទ្ធិមិនបានអនុវត្តសិទ្ធិអស់រយៈពេលកន្លងមកប៉ុន្មានឆ្នាំហើយក៏ដោយ ប្រសិនបើមិនលេចមុខអ្នកធ្វើលទ្ធកម្មដោយអាជ្ញាយុកាលទេ កម្មសិទ្ធិមិនត្រូវបាត់បង់ដោយសារអាជ្ញាយុកាលនៃការរំលត់សិទ្ធិឡើយ ។ទស្សនៈនៃកម្មសិទ្ធិគឺមានប្រភពចេញមកពីទស្សនៈនៃភាពដាច់ខាត និង ជាអចិន្ត្រៃយ៍ ។

## ខ) អាជ្ញាយុកាលនៃការរំលត់សិទ្ធិរយៈពេលខ្លី

លើសពីនេះទៅទៀត អំឡុងពេលនៃអាជ្ញាយុកាលនឹងរួញខ្លី អាស្រ័យទៅតាមប្រភេទនៃសិទ្ធិលើបំណុល។ ឧទាហរណ៍ថា ថ្លៃឈ្នួលព្យាបាលរបស់គ្រូពេទ្យ និង ថ្លៃឈ្នួលសាងសង់របស់អ្នកម៉ៅការ អំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិគឺ ៣ ឆ្នាំ (មាត្រា ១៧០ នៃក្រមរដ្ឋប្បវេណី) ហើយអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលចំពោះថ្លៃលក់ទំនិញដោយឡជំពាក់ គឺ ២ ឆ្នាំ (មាត្រា ១៧៣ នៃក្រមរដ្ឋប្បវេណី) រីឯថ្លៃអាហារនៅភោជនីយដ្ឋាន ឬ ថ្លៃឈ្នួលបន្ទប់សណ្ឋាគារវិញ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលមានរយៈពេល ១ ឆ្នាំ (មាត្រា ១៧៤ នៃក្រមរដ្ឋប្បវេណី)។ ក៏ប៉ុន្តែ ក្រមពាណិជ្ជកម្មវិញចែងថា អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលគឺ ៥ ឆ្នាំ (មាត្រា ៥២២ នៃក្រមពាណិជ្ជកម្ម) ក្រៅពីនោះ ច្បាប់ពិសេសដទៃទៀតដែលចែងពីអំឡុងពេលអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលតិចជាង ១០ ឆ្នាំ គឺមានច្រើនណាស់។ ក៏ប៉ុន្តែ បើទោះជាមានសិទ្ធិលើបំណុលដែលមានអាជ្ញាយុកាលរយៈពេលខ្លីទាំងនេះក៏ដោយ នៅពេលដែលមានការទទួលស្គាល់ដោយសាលក្រមស្ថាពរ ជាអាទិ៍ ដែលបានចេញដោយតុលាការហើយ អំឡុងពេលនៃអាជ្ញាយុកាលនឹងក្លាយទៅជា ១០ ឆ្នាំ (មាត្រា ១៧៤-២ នៃក្រមរដ្ឋប្បវេណី) ។

**តារាងពន្យល់ ៦–១ អំឡុងពេលនៃអាជ្ញាយុកាល**

| | | អាជ្ញាយុកាលនៃលទ្ធកម្ម | អាជ្ញាយុកាលនៃការរំលត់សិទ្ធិ |
|---|---|---|---|
| កម្មសិទ្ធិ | | ○ (មាត្រា១៦២)<br>២០ឆ្នាំ ១០ឆ្នាំ | ×<br>(មិនមានជាប់អាជ្ញាយុកាលនៃការរំលត់សិទ្ធិ) |
| សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត | កម្មសិទ្ធិ សិទ្ធិលើទ្រព្យសម្បត្តិក្រៅពីកម្មសិទ្ធិ | ○ (មាត្រា១៦៣)<br>២០ឆ្នាំ ១០ឆ្នាំ | ○ (កថាខណ្ឌទី២ មាត្រា១៦៧)<br>២០ឆ្នាំ |
| | សិទ្ធិលើបំណុល | | ○ (កថាខណ្ឌទី១ មាត្រា១៦៧ ពីមាត្រា១៦៨ ដល់ មាត្រា១៧៤)<br>១០ឆ្នាំ ឬ ៥ឆ្នាំ – ១ឆ្នាំ |

✎ ការលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិ-- ការពិចារណាតាមរយៈករណីសិក្សា

តាមករណីសិក្សាខាងលើ ដោយសារតែ B មិនបានអនុវត្តសិទ្ធិលើបំណុលរបស់ខ្លួនក្នុងអំឡុងពេល ១០ ឆ្នាំ A អាចលើកឡើងពីអាជ្ញាយុកាល និង អាចអះអាងពីការដែលបំណុលត្រូវបានរំលត់។ ក៏ប៉ុន្តែ A ក៏អាចមិនធ្វើការលើកឡើងនូវអាជ្ញាយុកាលបានដែរ។ មានន័យថា បើទោះបីជាអំឡុងពេល ១០ ឆ្នាំបានកន្លងផុតទៅហើយក៏ដោយ ប្រសិនបើ A គិតថាចង់សងបំណុល គឺអាចសងបានដោយមិនលើកពីអាជ្ញាយុកាលទេ។ មានន័យថា ទោះជាការសងបំណុលដែលបានសម្រេចអាជ្ញាយុកាលរំលត់បំណុលហើយក៏ដោយ ក៏ជាការសងដែលមានសុពលភាពដែរ ។

Khmer Law's Association

## ✧ក្រមណាប៉ូឡេអុង និង ក្រមរដ្ឋប្បវេណីបារាំង

ធ្វើងកាត់បដិវត្តន៍បារាំងនាឆ្នាំ ១៧៨៩ ក្រមរដ្ឋប្បវេណីបារាំងត្រូវបានអនុម័តក្នុងឆ្នាំ ១៨០៤ ។ ក្រមរដ្ឋប្បវេណីនោះគឺជាក្រមរដ្ឋប្បវេណីទំនើបដំបូងគេ និង បានក្លាយទៅជាគំរូនៃក្រមរដ្ឋប្បវេណីទំនើបនៅក្នុងបណ្តាប្រទេសដែលស្ថិតនៅក្រោមអាណានិគមបារាំងដោយសារសង្គ្រាមពង្រីកទឹកដី។ នៅក្នុងការអនុម័តនោះ ណាប៉ូឡេអុងបានចូលរួមជាញឹកញាប់ក្នុងកិច្ចប្រជុំពិភាក្សាដេញដោលនៅក្រុមប្រឹក្សារដ្ឋ (Conseil d'Etat) ក្នុងឋានៈគាត់ជាប្រធានកិច្ចប្រជុំពិភាក្សា និង បានបញ្ចេញយោបល់យ៉ាងសកម្ម ។ ណាប៉ូឡេអុងគឺជាទាហាន មិនមែនជាអ្នកច្បាប់ ក៏ប៉ុន្តែបានបន្សល់ទុកនូវឥទ្ធិពលដ៏ច្រើនលើសលប់ទៅក្នុងខ្លឹមសារនៃក្រម។ ឈ្មោះជាផ្លូវការគឺ"ក្រមរដ្ឋប្បវេណីបារាំង" ក៏ប៉ុន្តែ ដោយសារតែណាប៉ូឡេអុងបានដើរតួនាទីយ៉ាងសំខាន់ដូចបានរៀបរាប់ដូច្នេះ ទើបក្រមនេះត្រូវបានហៅថា "ក្រមណាប៉ូឡេអុង" (ក្រោយពីពេលនោះមក នៅក្នុងសម័យរាជាណាចក្រទី ១ និង រាជាណាចក្រទី ២ វាបានក្លាយជាឈ្មោះជាផ្លូវការមួយរយៈ) ។ ជាឧទាហរណ៍ របបលែងលះ និង របបសុំកូនត្រូវបានអនុម័តទៅតាមការលើកឡើងរបស់ណាប៉ូឡេអុង ។ អាចនិយាយបានថា របបនោះបានកើតឡើងដោយសារនាពេលនោះណាប៉ូឡេអុងគិតចង់លែងលះជាមួយយ៉ូសេហ្វីន (Joséphine de Beauharnais) ហើយក្នុងករណីដែលមិនមានកូន គាត់គិតយកកូនសុំដើម្បីបន្តរជ្ជកាលបូណាប៉ាត (Bonaparte) ឲ្យនៅស្ថិតស្ថេរ ។ តែតាមការពិតទៅ នៅក្រោយពេលដែលណាប៉ូឡេអុងបានលែងលះជាមួយយ៉ូសេហ្វីន គាត់បានរៀបការសាជាថ្មីជាមួយ ម៉ារី ល្វីស (Marie-Louise) (ក្នុងចំណងអាពាហ៍ពិពាហ៍ជាមួយ ម៉ារី ល្វីស ណាប៉ូឡេអុងទី ២ ក៏បានប្រសូតមក ដែលពេលនោះសុំកូនបានក្លាយទៅជាលែងចាំបាច់ទៀតហើយ) ។

នាពេលក្រោយមក នៅលើកោះ សែនហេឡេណា (Saint Helena) ណាប៉ូឡេអុងបានធ្វើការរំលឹកឡើងវិញថា "កិត្តិស័ព្ទដ៏ពិតប្រាកដរបស់យើង គឺមិនមែនជាជ័យជំនះក្នុងសង្គ្រាមចំនួន ៤០ ដងនោះទេ ។ បរាជ័យក្នុងសង្គ្រាមនៅវ៉ាទើលូ (Waterloo) បានលុបចោលនូវការចងចាំពីជ័យជំនះដ៏ច្រើនលើសលប់របស់យើងហើយ។ ក៏ប៉ុន្តែ អ្វីដែលនឹងមិនអាចលុបចោលបាន និង នៅស្ថិតស្ថេរជាដរាបនោះ គឺក្រមរដ្ឋប្បវេណីរបស់យើង" (សូមមើលសេចក្តីពិស្តារក្នុងទំព័រទី ៧៩ នៃសៀវភៅដែលមានចំណងជើងថា "ច្បាប់បារាំង" បោះពុម្ពផ្សាយជាលើកទី ២ របស់អ្នកនិពន្ធ តាគិហ្សាវ៉ា តាដាស៊ី) ។

# ជំពូកទី ៧

# កិច្ចសន្យា

១ ការបង្កើតកិច្ចសន្យា

២ អានុភាពនៃកិច្ចសន្យា

៣ ទំនាក់ទំនងរវាងកាតព្វកិច្ចពីរនៅក្នុងកិច្ចសន្យាអញ្ញមញ្ញ

៤ ការអនុវត្តកិច្ចសន្យា (ការអនុវត្តកាតព្វកិច្ច)

៥ ការមិនអនុវត្តកិច្ចសន្យា (ការមិនអនុវត្តកាតព្វកិច្ច)

✐ការបង្កើតកិច្ចសន្យារវាងភាគីដែលនៅឆ្ងាយពីគ្នា--ការពិចារណាតាមរយៈករណីសិក្សា

Khmer Law's Association

ករណីសិក្សាៈ A គិតថាចង់លក់ដី (ក) ដែលជាកម្មសិទ្ធិរបស់ខ្លួន ក៏បានជូនដំណឹងទៅមិត្តភក្តិឈ្មោះ B តាមរយៈប្រៃសណីយ៍ដោយមានខ្លឹមសារថា ចង់លក់ដី (ក) ក្នុងតម្លៃ ១០០ លានយ៉េន។ B បានធ្វើការឆ្លើយតបទៅវិញតាមរយៈប្រៃសណីយ៍ដែលមានខ្លឹមសារថាទទួលទិញដី (ក) តាមល័ក្ខខ័ណ្ឌដែលបានស្នើដោយ A ។ ក៏ប៉ុន្តែ នៅមុនពេលដែល A បានទទួលការឆ្លើយតបនោះ C បានស្នើសុំទិញដី (ក) តម្លៃ ១៥០ លានយ៉េន ដូច្នេះ A ក៏បានលក់ដីនោះទៅឲ្យ C បាត់ទៅ។ តើកិច្ចសន្យារវាង A និង B បានកើតឡើងដែរឬទេ?

## ១ ការបង្កើតកិច្ចសន្យា

### ក) សំណើ និង ស្ទីការ

ដូចដែលបានរៀបរាប់រួចមកហើយ កិច្ចសន្យាកើតឡើងដោយសារការត្រូវគ្នានៃឆន្ទៈរវាងភាគីពីរ។ ក្នុងសម័យបុរាណ ទម្រង់បែបបទដ៏តឹងរ៉ឹងក្នុងការធ្វើកិច្ចសន្យាត្រូវបានកំណត់ឡើង ក៏ប៉ុន្តែនៅក្នុងសម័យទំនើប ជាគោលការណ៍ ដើម្បីបង្កើតកិច្ចសន្យា ចាំបាច់គ្រាន់តែមានឆន្ទៈត្រូវគ្នាប៉ុណ្ណោះ គឺគ្រប់គ្រាន់ហើយ (ដូចដែលនឹងលើកមកពិភាក្សានាពេលក្រោយ ចំពោះកិច្ចសន្យាដែលចាំបាច់ត្រូវប្រគល់វត្ថុគឺជាករណីលើកលែង ដោយហេតុថា កិច្ចសន្យាមិនអាចកើតឡើងទេ បើមានតែការព្រមព្រៀង គឺត្រូវមានការប្រគល់វត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យា ទើបកិច្ចសន្យាកើតមានឡើង)។ មានន័យថា មិនចាំបាច់មានការធ្វើជាលាយលក្ខណ៍អក្សរ ឬ ត្រូវមានទម្រង់ជាពិសេសអ្វីទេ។ ទស្សនៈជាមូលដ្ឋានចំពោះការធ្វើកិច្ចសន្យាបែបដូច្នោះ ហៅថាគោលការណ៍នៃការបង្កើតតាមការព្រមព្រៀង។ ក៏ប៉ុន្តែ នាពេលថ្មីនេះ ដើម្បីការពារទៅដល់ភាគីម្ខាងដែលស្ថិតក្នុងស្ថានភាពសង្គមទន់ខ្សោយ ដូចជាអ្នកប្រើប្រាស់ ជាដើម ភាគីម្ខាងទៀត (ដែលភាគច្រើនគឺជាអ្នកជំនួញ) មានកាតព្វកិច្ចប្រគល់ទៅឲ្យភាគីម្ខាងទៀត (អ្នកប្រើប្រាស់ ជាដើម) នូវឯកសារជាលាយលក្ខណ៍អក្សរដែលមានសរសេរចូលនូវចំណុចសំខាន់ៗនៃកិច្ចសន្យា (ច្បាប់ស្តីពីការធ្វើអាជីវកម្មលើដី ផ្ទះសម្បែង និង អគារ និង ច្បាប់ស្តីពីការលក់ដោយការបង់រំលោះ ជាអាទិ៍) ។

ដំបូង ការបង្ហាញឆន្ទៈស្នើសុំបង្កើតកិច្ចសន្យាហៅថា សំណើ ហើយការឆ្លើយតបទៅនឹងសំណើនេះ ដោយបង្ហាញឆន្ទៈថានឹងចុះកិច្ចសន្យានេះ ហៅថា ស្ទីការ ។ ជាឧទាហរណ៍ ប្រសិនបើនិយាយទៅដល់កិច្ចសន្យាលក់ទិញរវាង A និង B នៅក្នុងករណីសិក្សា គឺយើងឃើញថាមានទាំងការបង្ហាញឆន្ទៈដែលជាសំណើរបស់ A និងការបង្ហាញឆន្ទៈដែលជាស្ទីការរបស់ B ។

ក្នុងករណីដែលភាគីទាំងសងខាងជួបគ្នានៅកន្លែងតែមួយ ហើយបានចុះកិច្ចសន្យា ប្រសិនបើឆន្ទៈត្រូវគ្នា កិច្ចសន្យានឹងត្រូវកើតឡើង ហើយពុំមានប្រយោជន៍ដែលត្រូវបែងចែករវាងសំណើ និង ស្ទីការ

ទេ។ ក៏ប៉ុន្តែ ក្នុងករណីដែលភាគីនៅឆ្ងាយពីគ្នា ហើយការផ្លាស់ប្តូរការបង្ហាញឆន្ទៈត្រូវធ្វើតាមរយៈប្រៃសណីយ៍ដូច្នេះ (គេហៅថាកិច្ចសន្យារវាងគូភាគីដែលនៅឆ្ងាយ) ការបែងចែកសំណើ និង ស្វីការគឺមានសារៈសំខាន់។

## ខ) ពេលនៃការបង្កើតកិច្ចសន្យា

យោងទៅតាមគោលការណ៍ជាទូទៅនៃការបង្ហាញឆន្ទៈ សំណើកើតមានអានុភាពនៅពេលដែលសំណើនោះបានទៅដល់ភាគីម្ខាងទៀត (មាត្រា ៩៧ នៃក្រមរដ្ឋប្បវេណី)។ ប្រសិនបើនៅពេលដែលភាគីម្ខាងទៀតបានទទួលសំណើនោះ ហើយចង់បង្កើតកិច្ចសន្យាតាមខ្លឹមសារនៃសំណើ ត្រូវបញ្ជូនការជូនដំណឹងអំពីស្វីការ។ ស្វីការ គឺដូចជាសំណើដែរ គឺត្រូវបានបកស្រាយថានឹងមានអានុភាពចាប់ពីពេលដែលការជូនដំណឹងពីស្វីការបានទៅដល់ភាគីអ្នកធ្វើសំណើ ក៏ប៉ុន្តែ ក្នុងទ្រឹស្តី មានការខ្វែងគំនិតគ្នាថាតើគួរបកស្រាយយ៉ាងដូចម្តេចចំពោះទំនាក់ទំនងជាមួយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៥២៦ ដែលបានបញ្ញត្តថា កិច្ចសន្យាត្រូវកើតឡើងនៅពេលដែលបានបញ្ជូនដំណឹងពីស្វីការ។ ផ្អែកលើបញ្ញត្តិនេះ គេអាចអាន និង យល់បានថា ដរាបណាបានធ្វើស្វីការ ទោះបីជាស្វីការនោះមិនបានទៅដល់ភាគីម្ខាងទៀតដោយប្រការណាមួយក៏ដោយ ក៏កិច្ចសន្យាកើតឡើងដែរ។ ប៉ុន្តែជាក់ស្តែងក្នុងករណីដែលមិនបានកំណត់អំឡុងពេលសម្រាប់ស្វីការទេ ស្វីការដែលបានធ្វើឡើងហើយ បើទោះបីជាមិនទាន់ទៅដល់ភាគីម្ខាងទៀតក៏ដោយ ក៏អាចបកស្រាយបានថា កិច្ចសន្យាបានកើតឡើងដែរ។ នៅពេលដែលមានការកំណត់អំឡុងពេលសម្រាប់ធ្វើស្វីការ ប្រសិនបើស្វីការមិនបានទៅដល់អ្នកស្នើក្នុងអំឡុងពេលដែលបានកំណត់ទេ សំណើត្រូវបាត់បង់អានុភាព ហើយកិច្ចសន្យាមិនកើតឡើងទេ (កថាខណ្ឌទី ២ មាត្រា ៥២១ នៃក្រមរដ្ឋប្បវេណី)។ ម្យ៉ាងទៀត ទ្រឹស្តីភាគីច្រើនបកស្រាយថា កិច្ចសន្យាកើតឡើងនៅពេលដែលមានស្វីការ ក៏ប៉ុន្តែអានុភាពនៃកិច្ចសន្យានោះមិនជាស្ថាពរទេ គឺអានុភាពនឹងចូលជាស្ថាពរនៅពេលដែលមានការមកដល់នៃស្វីការ ។

សំណើដែលបានធ្វើរួចហើយមានអនុភាពនៅក្នុងអំឡុងពេលជាក់លាក់មួយ ហើយអ្នកស្នើមិនអាចដកសំណើនោះវិញបានទេ (ក្រមរដ្ឋប្បវេណីបានប្រើពាក្យថាលុបចោលសំណើ ក៏ប៉ុន្តែពាក្យថាលុបចោលត្រង់នេះគឺខុសពីការលុបចោលដោយសារអសមត្ថភាព ឬ ការលុបចោលដោយសារការឆបោក និង ដោយសារតែក្នុងករណីការបង្ហាញឆន្ទៈធ្វើសំណើដែលមានសុពលភាពទាំងស្រុងបានកើតមាន ហើយឆន្ទៈនោះបានរលត់ទៅវិញយ៉ាងដូច្នេះ ទើបទ្រឹស្តីបានប្រើប្រាស់ពាក្យថា ដកសំណើដើម្បីចែកឲ្យដាច់គ្នាជាមួយការលុបចោលធម្មតា។ ក្រោយមក តាមរយៈវិសោធនកម្មឆ្នាំ ២០០៥ មាត្រាច្បាប់ក៏បានកែទៅប្រើពាក្យថា ដកវិញដែរ)។ អំឡុងពេលដែលមិនអាចដកសំណើវិញបានចំពោះសំណើដែលមានកំណត់អំឡុងពេលសម្រាប់ស្វីការ គឺអំឡុងពេលដែលបានកំណត់សម្រាប់ស្វីការក្នុងសំណើនោះ (កថាខណ្ឌទី ១ មាត្រា ៥២១ នៃក្រមរដ្ឋប្បវេណី) រីឯចំពោះសំណើដែល

គ្មានកំណត់អំឡុងពេលសម្រាប់ស្ទីការវិញ គឺអំឡុងពេលសមរម្យសម្រាប់ស្ទីការ (មាត្រា ៥២៤ នៃក្រមរដ្ឋប្បវេណី)។ អំឡុងពេលសមរម្យសម្រាប់ស្ទីការត្រង់កន្លែងនេះ មានន័យថាជាអំឡុងពេលដែលចាំបាច់សម្រាប់ពិចារណាថាត្រូវធ្វើ ឬ មិនធ្វើស្ទីការ និង អំឡុងពេលសម្រាប់ការជូនដំណឹងអំពីស្ទីការ ។

ចំពោះសំណើដែលមានកំណត់អំឡុងពេលសម្រាប់ស្ទីការ ប្រសិនបើអ្នកស្នើមិនបានទទួលការជូនដំណឹងអំពីស្ទីការក្នុងអំឡុងពេលដែលបានកំណត់ទេ សំណើត្រូវបាត់បង់អានុភាពដោយឯកឯង។ ម្យ៉ាងវិញទៀត ចំពោះសំណើដែលគ្មានកំណត់អំឡុងពេលសម្រាប់ស្ទីការវិញ នៅក្រោយពេលដែលអំឡុងពេលសមរម្យបានកន្លងផុតទៅហើយ អ្នកស្នើអាចដកសំណើបាន (ការបកស្រាយបញ្ច្រាស់នៃមាត្រា ៥២៤) ។

## គ) ប្រតិបត្តិការដោយការប្រើប្រាស់កុំព្យូទ័រ

នាសម័យបច្ចុប្បន្ន ឧទាហរណ៍ដូចជានៅផ្សារទំនើប ជាដើម ក្នុងករណីនៃការទិញទំនិញពីអ្នកផ្គត់ផ្គង់មក ចំពោះកិច្ចសន្យាលក់ទិញដែលបន្តជាប់រហូតរវាងពាណិជ្ជករ ការទទួលការបញ្ជាទិញទំនិញតាមរយៈប្រព័ន្ធកុំព្យូទ័រ ត្រូវបានប្រតិបត្តិយ៉ាងទូលំទូលាយ។ ដោយឡែកកិច្ចសន្យាដែលអ្នកប្រើប្រាស់គឺជាភាគីម្ខាងទៀតវិញ ការធ្វើកិច្ចសន្យាដោយប្រើប្រាស់ប្រព័ន្ធម៉ាស៊ីនកុំព្យូទ័រវិញ ក៏បានក្លាយទៅជាទូលំទូលាយដូចកិច្ចសន្យារវាងពាណិជ្ជករដែរ។ ចំពោះប្រតិបត្តិការជំនួញបែបនេះ ប្រសិនបើគិតទៅដល់ការកើតឡើងនូវកិច្ចសន្យាដោយផ្អែកលើសំណើ និង ស្ទីការដូចដែលបានរៀបរាប់ពីខាងដើមវិញ ថាតើត្រូវបកស្រាយដូចម្ដេចនោះ គឺជាបញ្ហាដែលត្រូវជជែកដេញដោល។ ជាមូលដ្ឋាន យើងអាចនិយាយបានថា ការយកទស្សនៈនៃក្រមរដ្ឋប្បវេណីមកអនុវត្តគឺជាការត្រឹមត្រូវ។ មានន័យថា កិច្ចសន្យាកើតឡើងនៅពេលដែលសំណើ និង ស្ទីការត្រូវគ្នា ហើយចំណុចពេលនៃការបង្កើតកិច្ចសន្យានៅក្នុងក្របខ័ណ្ឌនៃពេលដែលបញ្ជូនដំណឹងអំពីស្ទីការ គឺគេអាចវិនិច្ឆ័យបានតាមរយៈការបញ្ជាក់យ៉ាងច្បាស់តាមលក្ខណៈគតិយុត្តថា ចំណុចណាជាសំណើ ចំណុចណាជាស្ទីការ ហើយការបញ្ជូនដំណឹងអំពីស្ទីការនៅពេលណា ជាដើម តាមទិន្នន័យដែលបានឆ្លើយឆ្លងតាមប្រព័ន្ធអេឡិចត្រូនិក (ផ្ទុយទៅវិញបញ្ហាគតិយុត្តដែលអាចកើតមានចំពោះកិច្ចសន្យារបៀបនេះគឺបញ្ហាផ្សេងទេ ដូចជាកិច្ចការជំនួញដែលប្រតិបត្តិដោយបុគ្គលដែលគ្មានសិទ្ធិ ជាដើម)។

ក៏ប៉ុន្តែ ចំពោះកិច្ចសន្យាតាមប្រព័ន្ធអេឡិចត្រូនិកដែលធ្វើឡើងរវាងពាណិជ្ជករ និង អ្នកប្រើប្រាស់ ក្នុងករណីដែលភាគីម្ខាងបានធ្វើការជូនដំណឹងពីស្ទីការអេឡិកត្រូនិក កថាខណ្ឌទី ១ នៃមាត្រា ៥២៦ មិនត្រូវបានយកមកអនុវត្តទេ (មាត្រា ៤ នៃច្បាប់ស្ដីពីបទប្បញ្ញត្តិពិសេសលើក្រមរដ្ឋប្បវេណីទាក់ទងនឹងកិច្ចសន្យារបស់អ្នកប្រើប្រាស់តាមប្រព័ន្ធអេឡិចត្រូនិក និង ការជូនដំណឹងពីស្ទីការតាមអេឡិចត្រូនិក)។

ឧទាហរណ៍ថា ក្នុងករណីដែលអ្នកប្រើប្រាស់ធ្វើការជូនដំណឹងអំពីស្ទីការ គឺកិច្ចសន្យានឹងកើតមានឡើងនៅពេលដែលការបង្ហាញឆន្ទៈបានទៅដល់ពាណិជ្ជករ ។

## ២ អានុភាពនៃកិច្ចសន្យា

### ក) ការកើតឡើងនូវសិទ្ធិ និង កាតព្វកិច្ច

នៅពេលដែលកើតមានកិច្ចសន្យា សិទ្ធិ និង កាតព្វកិច្ចរវាងភាគីកើតមានឡើង។ ឧទាហរណ៍ នៅក្នុងកិច្ចសន្យាលក់ទិញ អ្នកលក់មានកាតព្វកិច្ចផ្ទេរវត្ថុដែលជាកម្មវត្ថុនៃការលក់ទិញទៅអ្នកទិញ (មានន័យថា អ្នកទិញមានសិទ្ធិទាមទារឲ្យអ្នកលក់ប្រគល់នូវវត្ថុដែលជាកម្មវត្ថុនៃការលក់ទិញ) រីឯអ្នកទិញមានកាតព្វកិច្ចបង់ថ្លៃលក់ទិញទៅអ្នកលក់ (មានន័យថា អ្នកលក់មានសិទ្ធិទាមទារឲ្យអ្នកទិញបង់ថ្លៃលក់ទិញ)។ ម្យ៉ាងវិញទៀត នៅក្នុងកិច្ចសន្យាជួលអគារវិញ ភតិបតីមានកាតព្វកិច្ចប្រគល់អគារទៅឲ្យភតិកៈប្រើប្រាស់ (ភតិកៈមានសិទ្ធិប្រើប្រាស់អគារ) រីឯភតិកៈវិញមានកាតព្វកិច្ចបង់ថ្លៃឈ្នួលទៅភតិបតី (មានន័យថា ភតិបតីមានសិទ្ធិទាមទារថ្លៃឈ្នួលពីភតិកៈ) ។

កាតព្វកិច្ចរបស់ភាគីខុសៗគ្នាអាស្រ័យទៅតាមកិច្ចសន្យា ក៏ប៉ុន្តែ កិច្ចសន្យាដែលភាគីមានកាតព្វកិច្ចចំពោះគ្នាទៅវិញទៅមកដូច្នេះ ហៅថា កិច្ចសន្យាអញ្ញមញ្ញ។ កិច្ចសន្យាលក់ទិញ កិច្ចសន្យាជួល គឺជាឧទាហរណ៍នៃកិច្ចសន្យាអញ្ញមញ្ញនោះ។ កិច្ចសន្យាដែលភាគីតែម្ខាងមានកាតព្វកិច្ច រីឯភាគីម្ខាងទៀតមិនមានទេ គឺជាកិច្ចសន្យាឯកតោភាគី។ ឧទាហរណ៍ដូចជាកិច្ចសន្យាប្រទានកម្ម។ ទាយកមានកាតព្វកិច្ចផ្តល់ទៅឲ្យបដិគ្គាហកនូវវត្ថុដែលជាកម្មវត្ថុនៃប្រទានកម្ម ក៏ប៉ុន្តែ បដិគ្គាហកមិនមានកាតព្វកិច្ចអ្វីទាំងអស់ក្រៅតែពីការមានសិទ្ធិទាមទារឲ្យប្រគល់នូវវត្ថុដែលជាកម្មវត្ថុនៃប្រទានកម្ម ។

ម្យ៉ាងវិញទៀត កិច្ចសន្យាដែលភាគីម្ខាងផ្តល់ឲ្យទៅភាគីម្ខាងទៀតនៃកិច្ចសន្យានូវប្រាក់ ឬ វត្ថុខ្លះដើម្បីទទួលបានមកវិញនូវផលប្រយោជន៍ជាតម្លៃតបនៃកិច្ចសន្យា ហៅថាកិច្ចសន្យាដោយយកតម្លៃថ្នូរ។ ឧទាហរណ៍ដូចជា កិច្ចសន្យាលក់ទិញ និង កិច្ចសន្យាជួលអចិន្ត្រៃយ៍ ជាដើម។ អ្នកទិញធ្វើលទ្ធកម្មកម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុនៃការលក់ទិញជាតម្លៃតប ហើយត្រូវបង់ថ្លៃលក់ទិញទៅអ្នកលក់។ ផ្ទុយទៅវិញ អ្នកទិញធ្វើលទ្ធកម្មលើប្រាក់ជាតម្លៃតប និង ប្រគល់កម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុនៃការទិញលក់ទៅអ្នកទិញ។ ដូចក្នុងឧទាហរណ៍ទាំងនេះ កិច្ចសន្យាអញ្ញមញ្ញគឺជាកិច្ចសន្យាដោយយកតម្លៃថ្នូរ។ ផ្ទុយទៅវិញ កិច្ចសន្យាដែលភាគីម្ខាងនៃកិច្ចសន្យាទទួលផលប្រយោជន៍ តែមិនបានផ្តល់ឲ្យទៅភាគីម្ខាងទៀតនៃកិច្ចសន្យានូវប្រាក់ ឬ វត្ថុខ្លះជាតម្លៃតបទេ ហៅថាកិច្ចសន្យាដោយមិនយកតម្លៃថ្នូរ។ កិច្ចសន្យាប្រទានកម្ម គឺជាឧទាហរណ៍សាមញ្ញនៃកិច្ចសន្យាប្រភេទនេះ។ មានន័យថា បដិគ្គាហកត្រូវធ្វើលទ្ធកម្មកម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុនៃប្រទានកម្មដោយមិនអស់ថ្លៃ

ដោយមិនមានលះបង់អ្វីទៅវិញជាតម្លៃតបទេ។ កិច្ចសន្យាដោយមិនយកតម្លៃថ្នូរបែបនេះក៏ជាកិច្ចសន្យាឯកតោភាគីដែរ ។

## ខ) កិច្ចសន្យាដែលចាំបាច់ត្រូវប្រគល់វត្ថុ

នៅក្នុងកិច្ចសន្យាខ្ចីបរិភោគ (កិច្ចសន្យាខ្ចីវត្ថុដែលអាចជំនួសបានដូចជាប្រាក់ ហើយអ្នកខ្ចីក្រោយពេលប្រើប្រាស់វត្ថុដែលបានខ្ចី ត្រូវប្រគល់ទៅឲ្យអ្នកឲ្យខ្ចីវិញនូវវត្ថុដែលមានប្រភេទ គុណភាព និង ចំនួនស្មើគ្នា) កិច្ចសន្យាខ្ចីប្រើ (កិច្ចសន្យាដែលភាគីម្ខាងឲ្យភាគីម្ខាងទៀតប្រើប្រាស់ និង អាស្រ័យផលនូវវត្ថុដែលបានខ្ចីដោយមិនឲ្យបង់ថ្លៃ) និង កិច្ចសន្យាបញ្ញើ (អ្នកទទួលបញ្ញើរក្សាទុកនូវវត្ថុផ្ញើ ហើយត្រូវប្រគល់វិញនៅពេលក្រោយមក) កិច្ចសន្យាចាប់កើតមានឡើងនៅពេលដែលភាគីម្ខាងនៃកិច្ចសន្យា (អ្នកខ្ចីបរិភាគ អ្នកខ្ចីប្រើ និង អ្នកទទួលបញ្ញើ) ទទួលរបស់ដែលជាកម្មវត្ថុនៃកិច្ចសន្យា។ កិច្ចសន្យាមិនកើតឡើងដោយគ្រាន់តែមានការព្រមព្រៀងតែប៉ុណ្ណោះទេ ។

ជាឧទាហរណ៍ នៅក្នុងកិច្ចសន្យាខ្ចីប្រាក់បរិភោគ បើគ្រាន់តែឆន្ទៈឲ្យខ្ចីរបស់អ្នកឲ្យខ្ចីត្រូវគ្នាជាមួយឆន្ទៈខ្ចីរបស់អ្នកខ្ចីប៉ុណ្ណោះ កិច្ចសន្យាខ្ចីបរិភោគមិនកើតឡើងទេ ហើយអ្នកខ្ចីមិនអាចទាមទារអ្នកឲ្យខ្ចីឲ្យប្រគល់ប្រាក់មកខ្លួនបានទេ។ កិច្ចសន្យាខ្ចីបរិភោគចាប់ផ្តើមកើតមាននៅពេលដែលប្រាក់ត្រូវបានប្រគល់ពីអ្នកឲ្យខ្ចីទៅអ្នកខ្ចី ទៅតាមការព្រមព្រៀងរបស់អ្នកខ្ចី និង អ្នកឲ្យខ្ចី។ កិច្ចសន្យាបែបនេះជាកិច្ចសន្យាដែលមានខ្លឹមសារថា ការប្រគល់ និង ទទួលវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យាមានសារៈសំខាន់ ដែលហៅថាកិច្ចសន្យាដែលចាំបាច់ត្រូវប្រគល់វត្ថុ ។

## ៣ ទំនាក់ទំនងរវាងកាតព្វកិច្ចពីរនៅក្នុងកិច្ចសន្យាអញ្ញមញ្ញ

ដូចបានលើកឡើងខាងលើ កិច្ចសន្យាដែលបង្កើតឲ្យមានកាតព្វកិច្ចនីមួយៗចំពោះភាគីទាំងសងខាងក្នុងកិច្ចសន្យា ហៅថា កិច្ចសន្យាអញ្ញមញ្ញ។ ឧទាហរណ៍ដូចជានៅក្នុងកិច្ចសន្យាលក់ទិញ អ្នកលក់មានកាតព្វកិច្ចប្រគល់វត្ថុដែលជាកម្មវត្ថុនៃការលក់ទិញទៅអ្នកទិញ រីឯអ្នកទិញមានកាតព្វកិច្ចបង់ថ្លៃលក់ទិញទៅឲ្យអ្នកលក់។ កាតព្វកិច្ចទាំងពីរនេះមានទំនាក់ទំនងយ៉ាងជិតស្និទ្ធនឹងគ្នា។ មានន័យថា ដោយសារតែភាគីម្ខាងមានកាតព្វកិច្ច ភាគីម្ខាងទៀតក៏ត្រូវមានទំនាក់ទំនងជាប់រងកាតព្វកិច្ចផងដែរ។ ប្រសិនបើពិចារណាពីកិច្ចសន្យាលក់ទិញ ដោយសារតែអ្នកទិញត្រូវបង់ថ្លៃលក់ទិញមកខ្លួន អ្នកលក់ត្រូវទទួលកាតព្វកិច្ចប្រគល់វត្ថុដែលជាកម្មវត្ថុនៃការលក់ទិញ ហើយដោយសារតែអ្នកលក់ត្រូវប្រគល់វត្ថុដែលជាកម្មវត្ថុនៃការលក់ទិញមកខ្លួន អ្នកទិញត្រូវមានកាតព្វកិច្ចបង់ថ្លៃលក់ទិញ។ ក្នុងករណីបែបនេះ កាតព្វកិច្ចទាំងពីរមានទំនាក់ទំនងជាតម្លៃតបចំពោះគ្នាទៅវិញទៅមក (ត្រូវបានគេប្រើពាក្យថា ទំនាក់ទំនងទៅវិញទៅមក)។ ហេតុដូច្នេះ ប្រសិនបើយើងមើលពីទស្សនៈនៃយុត្តិធម៌ កាលបើមាន

ហេតុណាមួយកើតឡើងចំពោះកាតព្វកិច្ចមួយ ទោះបីក្នុងទម្រង់ណាមួយក៏ដោយ នឹងផ្តល់ឥទ្ធិពលទៅដល់កាតព្វកិច្ចមួយទៀត។ ទំនាក់ទំនងយ៉ាងជិតស្និទ្ធនេះត្រូវបានស្តែងឡើងជាក់លាក់តាមរូបភាព ៣ យ៉ាង គឺការកើតឡើងនៃកិច្ចសន្យា ការអនុវត្តកិច្ចសន្យា និង ភាពបន្តឥតដាច់នៃកិច្ចសន្យា។ ទី ១ ក្នុងការកើតឡើងនៃកិច្ចសន្យា ទំនាក់ទំនងទៅវិញទៅមកគឺចង់មានន័យថា នៅពេលដែលកាតព្វកិច្ចណាមួយក្នុងចំណោមកាតព្វកិច្ចទាំង ២ អលទ្ធភាពក្នុងការអនុវត្តតាំងពីដំបូង (ហៅថាអលទ្ធភាពតាំងពីដំបូង) កាតព្វកិច្ចមួយទៀតក៏មិនត្រូវកើតឡើងដែរ (មានន័យថា កិច្ចសន្យាមិនបានកើតឡើង) (ថ្វីត្បិតតែមិនមានចែងនៅក្នុងក្រមរដ្ឋប្បវេណីក៏ដោយ ក៏ប៉ុន្តែត្រូវបានគេយល់ថាជារឿងធម្មតា)។ ទី ២ នៅក្នុងការអនុវត្តកិច្ចសន្យា ទំនាក់ទំនងទៅវិញទៅមកគឺសំដៅលើការដែលច្បាប់មានចែងអំពីសិទ្ធិតវ៉ាឲ្យអនុវត្តព្រមគ្នា (មាត្រា ៥៣៣ នៃក្រមរដ្ឋប្បវេណី)។ ទី ៣ នៅក្នុងភាពបន្តឥតដាច់ ទំនាក់ទំនងទៅវិញទៅមកគឺសំដៅលើការដែលច្បាប់ចែងពីបន្ទុកនៃហានិភ័យ (ចាប់ពីមាត្រា ៥៣៥ នៃក្រមរដ្ឋប្បវេណី)។ សូមលើកមកពិភាក្សាឲ្យលម្អិតបន្តិចទាក់ទងនឹងសិទ្ធិតវ៉ាឲ្យអនុវត្តព្រមគ្នា និង បន្ទុកនៃហានិភ័យត្រង់កន្លែងនេះ ។

## ក) សិទ្ធិតវ៉ាឲ្យអនុវត្តព្រមគ្នា

ទំនាក់ទំនងជិតស្និទ្ធនៃកាតព្វកិច្ចទាំងពីរដែលជាទំនាក់ទំនងនៃតម្លៃតប កាតព្វកិច្ចនីមួយៗនឹងក្លាយទៅជាមូលហេតុនៃការកើតឡើងនូវកាតព្វកិច្ចមួយផ្សេងទៀត (មានន័យថា ដោយសារតែកាតព្វកិច្ចមួយត្រូវអនុវត្ត កាតព្វកិច្ចមួយទៀតក៏ត្រូវអនុវត្តដែរ)។ ដូច្នេះ អាចគិតបានថា ជាគោលការណ៍ កាតព្វកិច្ចទាំងពីរដែលត្រូវអនុវត្តព្រមគ្នា។ មានន័យថា ភាគីម្ខាងអាចបដិសេធមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន រហូតទាល់តែភាគីម្ខាងទៀតអនុវត្តកាតព្វកិច្ចរបស់គេដែរ (មាត្រា ៥៣៣ នៃក្រមរដ្ឋប្បវេណី)។ ឧទាហរណ៍ ដូចជានៅក្នុងកិច្ចសន្យាលក់ទិញ អ្នកទិញអាចអះអាងមិនបង់ថ្លៃលក់ទិញរហូតទាល់តែអ្នកលក់ប្រគល់វត្ថុដែលជាកម្មវត្ថុនៃការលក់ទិញ រីឯអ្នកលក់អាចអះអាងមិនប្រគល់វត្ថុដែលជាកម្មវត្ថុនៃការលក់ទិញ រហូតទាល់តែអ្នកទិញបង់ថ្លៃលក់ទិញ។ ដូច្នេះ ដើម្បីឲ្យអ្នកលក់អាចទាមទារឲ្យអ្នកទិញបង់ប្រាក់បាន ចាំបាច់ទាល់តែខ្លួនអនុវត្តកាតព្វកិច្ចរបស់ខ្លួនព្រមគ្នា (បើនិយាយឲ្យជាក់លាក់ទៅ វាជាការទាមទារ "ឲ្យបង់ថ្លៃលក់ទិញជាថ្នូរនឹងការប្រគល់វត្ថុដែលជាកម្មវត្ថុនៃការលក់ទិញ")។ ការតវ៉ាបែបនេះ គេហៅថាការតវ៉ាឲ្យអនុវត្តព្រមគ្នា។ តាមរយៈការអនុវត្តបែបនេះ គឺអាចជៀសវាងបាននូវស្ថានភាពដែលខ្លួនបានអនុវត្តកាតព្វកិច្ចហើយ តែភាគីម្ខាងទៀតមិនទាន់បានអនុវត្តកាតព្វកិច្ចចំពោះខ្លួនឡើយ ។

ក៏ប៉ុន្តែ ចំពោះគូភាគីនៃកិច្ចសន្យា ប្រសិនបើបានព្រមព្រៀងថាត្រូវឲ្យកាតព្វកិច្ចមួយអនុវត្តជាមុនសិន (ឧទាហរណ៍ថាមានករណីព្រមព្រៀងគ្នាថា អ្នកលក់ត្រូវប្រគល់វត្ថុដែលជាកម្មវត្ថុនៃការលក់ទិញជាមុនសិន ទើបអ្នកទិញបង់ប្រាក់ជាក្រោយ) សិទ្ធិតវ៉ាឲ្យអនុវត្តព្រមគ្នាគឺគ្មានអត្ថិភាពទេ ។

## ខ) ការទទួលបន្ទុកហានិភ័យ

ក្នុងករណីដែលកាតព្វកិច្ចមួយដែលកើតចេញពីកិច្ចសន្យាមិនត្រូវបានអនុវត្តទេ វានឹងក្លាយទៅជាបញ្ហានៃការលុបចោលកិច្ចសន្យា ឬ សំណងការខូចខាតដោយសារការមិនអនុវត្តកាតព្វកិច្ច ក៏ប៉ុន្តែ បើមើលពីទស្សនៈនៃទំនាក់ទំនងដ៏ជិតស្និទ្ធរវាងកាតព្វកិច្ច ២ ដែលកើតចេញពីកិច្ចសន្យាអញ្ញមញ្ញ ក្នុងករណីមានហេតុដែលមិនមែនជាការទទួលខុសត្រូវរបស់កូនបំណុលម្ខាងដែលបណ្តាលឲ្យមានអលទ្ធភាពនៃការអនុវត្តកាតព្វកិច្ច នោះនឹងមានបញ្ហាថាតើកាតព្វកិច្ចម្ខាងទៀតនឹងទៅជាយ៉ាងណា (ការទទួលបន្ទុកហានិភ័យគឺសំដៅលើការដែលភាគីម្ខាងដែលជាកូនបំណុល ឬ ម្ចាស់បំណុល ត្រូវទទួលបន្ទុកហានិភ័យនៃអលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ច)។ ឧទាហរណ៍ដូចជានៅក្នុងករណីនៃការផ្ទេរកម្មសិទ្ធិលើវត្ថុជាក់លាក់មួយដោយផ្អែកលើកិច្ចសន្យាលក់ទិញ នៅមុនពេលប្រគល់វត្ថុស្រាប់តែវត្ថុនោះត្រូវបាត់បង់ ឬ ខូចខាតដោយសារមូលហេតុណាមួយដែលមិនមែនជាកំហុសរបស់កូនបំណុល (អ្នកលក់) ដូច្នេះ ច្បាប់បញ្ញត្តថា ម្ចាស់បំណុល (អ្នកទិញ) ត្រូវទទួលបន្ទុកចំពោះការខាតបង់ (មាត្រា ៥៣៤ នៃក្រមរដ្ឋប្បវេណី។ បែបនេះគេហៅថា គោលការណ៍ទទួលបន្ទុកហានិភ័យរបស់ម្ចាស់បំណុល ហើយផ្ទុយពីគោលការណ៍នេះ គឺជាគោលការណ៍ទទួលបន្ទុកហានិភ័យរបស់កូនបំណុល)។ ការដែលម្ចាស់បំណុល (អ្នកទិញ) ទទួលបន្ទុកចំពោះការខាតបង់ មានន័យថា បើទោះបីជាវត្ថុមិនអាចត្រូវបានប្រគល់ឲ្យបានទាំងស្រុងក៏ដោយ ក៏ម្ចាស់សិទ្ធិលើបំណុល (អ្នកទិញ) ត្រូវតែបង់ប្រាក់ដែរ។ ដូចគ្នានេះដែរ គោលការណ៍ទទួលបន្ទុកហានិភ័យរបស់ម្ចាស់បំណុល ត្រូវបានអនុម័តយកចំពោះការទទួលបន្ទុកហានិភ័យក្នុងកិច្ចសន្យាអញ្ញមញ្ញដែលមានកម្មវត្ថុផ្ទេរ ឬ បង្កើតសិទ្ធិប្រត្យក្សលើវត្ថុជាក់លាក់ណាមួយ។ ក៏ប៉ុន្តែ ដោយសារតែទ្រឹស្តីមួយចំនួនធំមានទស្សនៈថា វាជាការមិនសមរម្យទេដែលម្ចាស់បំណុល (អ្នកទិញ) ត្រូវទទួលបន្ទុកហានិភ័យនៃការបាត់បង់ ឬ ខូចខាត បើទោះបីជាវត្ថុស្ថិតនៅទីកន្លែងរបស់កូនបំណុល (អ្នកលក់) ក៏ដោយ ទើបការអនុវត្តមាត្រា ៥៣៤ នៃក្រមរដ្ឋប្បវេណីមានលក្ខណៈមិនសូវទូលំទូលាយ ។

ដោយឡែកការទទួលបន្ទុកហានិភ័យក្នុងកិច្ចសន្យាអញ្ញមញ្ញដទៃផ្សេងទៀតក្រៅពីនេះ គេអនុម័តយកគោលការណ៍ទទួលបន្ទុកហានិភ័យរបស់កូនបំណុល (កថាខណ្ឌទី ១ នៃមាត្រា ៥៣៦)។ មានន័យថា ក្នុងករណីដែលកាតព្វកិច្ចមួយនៃកិច្ចសន្យាអញ្ញមញ្ញក្លាយទៅជាអលទ្ធភាពក្នុងការអនុវត្តដោយមូលហេតុដែលមិនមែនជាកំហុសរបស់កូនបំណុល កាតព្វកិច្ចមួយផ្សេងទៀតត្រូវរលត់ (មានន័យថា កូនបំណុលត្រូវទទួលបន្ទុកចំពោះការខាតបង់ដោយសារការរលត់កាតព្វកិច្ចម្ខាង)។ ឧទាហរណ៍ក្នុងករណីដែលនិយោជិតមិនអាចទៅកន្លែងបំពេញការងារបាន ដោយសារតែកូដកម្មរបស់ស្ថាប័នគមនាគមន៍ ការផ្តល់នូវកម្លាំងពលកម្មនឹងក្លាយទៅជាអលទ្ធភាព ដោយមូលហេតុដែលមិនមែនជា

កំហុសរបស់កូនបំណុល (និយោជិត) ក៏ប៉ុន្តែ គាត់មិនអាចទទួលនូវតាវកាលិកតប (ថ្លៃឈ្នួលពលកម្ម) បានទេ ។

## ៤ ការអនុវត្តកិច្ចសន្យា (ការអនុវត្តកាតព្វកិច្ច)

នៅពេលដែលកិច្ចសន្យាកើតឡើង ទំនាក់ទំនងនៃសិទ្ធិលើបំណុល និង កាតព្វកិច្ចកើតមានរវាងគូភាគី ហើយភាគីដែលមានកាតព្វកិច្ចត្រូវតែអនុវត្តកាតព្វកិច្ចនោះ។ និយាយបែបម្យ៉ាងទៀតគឺថា ភាគីត្រូវបានចងដោយកិច្ចសន្យា។ ប្រការបែបនេះ គឺដូចសុភាសិតច្បាប់ជាភាសាឡាតាំងដែលហៅថា "Pacta sunt servanda" (ត្រូវតែគោរពកិច្ចសន្យាជាដាច់ខាត) ។

### ក) ការអនុវត្តដោយស្ម័គ្រចិត្ត

ប្រសិនបើភាគីនៃកិច្ចសន្យាយល់ព្រមអនុវត្តកាតព្វកិច្ចដោយស្ម័គ្រចិត្ត បញ្ហាមិនកើតមានឡើងទេ។ យើងអាចនិយាយបានថា នៅក្នុងកិច្ចសន្យាស្ទើរតែទាំងអស់ ភាគីអនុវត្តកាតព្វកិច្ចដោយស្ម័គ្រចិត្ត។ ក៏ប៉ុន្តែ ដោយសារស្ថានភាពណាមួយនោះ វាកើតនូវករណីដែលភាគីមិនអនុវត្តកាតព្វកិច្ចដែរ។ នៅក្នុងករណីដែលភាគីមិនអនុវត្តកាតព្វកិច្ចដូច្នេះ ម្ចាស់បំណុលអាចខ្ចីអំណាចរបស់រដ្ឋ ដើម្បីសម្រេចឲ្យបាននូវការអនុវត្តដោយបង្ខំនូវខ្លឹមសារនៃសិទ្ធិលើបំណុល។ គេហៅថា "ការបង្ខំឲ្យអនុវត្ត" ឬ "ការអនុវត្តដោយបង្ខំ" ហើយដែលវិធីទាំងនោះមានចែងនៅក្នុងមាត្រា ៤១៤ នៃក្រមរដ្ឋប្បវេណី និង ច្បាប់ស្ដីពីការអនុវត្តដោយបង្ខំក្នុងរឿងរដ្ឋប្បវេណី។ វិធីដែលត្រូវបានទទួលស្គាល់ត្រង់នេះ គឺរក្សាការគោរពសិទ្ធិបុគ្គលរបស់កូនបំណុលផង (សេរីភាពដែលមិនអាចត្រូវបានបង្ខំពីបុគ្គលដទៃ) និង ការខិតខំសម្រេចឲ្យបានសិទ្ធិលើបំណុលដែលម្ចាស់បំណុលផង (ការការពារម្ចាស់បំណុល)។ ដោយឡែកដូចនឹងមានលើកយកមកពិភាក្សានៅពេលក្រោយគឺថា មានករណីដែលមិនទទួលស្គាល់នូវការសម្រេចឲ្យបាននូវសិទ្ធិដោយបង្ខំ នៅពេលដែលមានការគិតគូរខ្លាំងទៅដល់កូនបំណុល ។

### ខ) ការអនុវត្តដោយផ្ទាល់

វិធីនៃការសម្រេចសិទ្ធិដោយបង្ខំ ខុសគ្នាអាស្រ័យទៅតាមខ្លឹមសារនៃកាតព្វកិច្ច។ ចំពោះកិច្ចសន្យាដែលមានខ្លឹមសារផ្ដល់វត្ថុជាតាវកាលិក "កាតព្វកិច្ចផ្ដល់តាវកាលិក" គឺត្រូវសម្រេចតាមការអនុវត្តដោយផ្ទាល់ (កថាខណ្ឌទី ១ មាត្រា ៤១៤ នៃក្រមរដ្ឋប្បវេណី និង ចាប់ពីមាត្រា ៤៣ និង ចាប់ពីមាត្រា ១៦៨ នៃច្បាប់ស្ដីពីការអនុវត្តដោយបង្ខំក្នុងរឿងរដ្ឋប្បវេណី) ។ មានន័យថាជាវិធីដែលតុលាការ (ឬអាជ្ញាសាលា) រឹបអូសយកវត្ថុដែលជាកម្មវត្ថុពីកូនបំណុល ហើយប្រគល់ទៅឲ្យម្ចាស់បំណុល។ ជាឧទាហរណ៍ ចំពោះការលក់ទិញរូបគំនូរ ក្នុងករណីដែលអ្នកលក់មិនព្រមប្រគល់វត្ថុដែលជាកម្មវត្ថុនៃការលក់ទិញទេ អាជ្ញាសាលានឹងរឹបអូសយករូបគំនូរដែលជាកម្មវត្ថុនៃការលក់ទិញនោះពីអ្នកលក់ ហើយធ្វើការប្រគល់

ទៅឲ្យអ្នកទិញ។ ក៏ប៉ុន្តែ ចំពោះកិច្ចសន្យាដែលមានខ្លឹមសារថា កូនបំណុលត្រូវធ្វើសកម្មភាព "កាតព្វកិច្ចធ្វើសកម្មភាព" អ្វីមួយ (ឬ "កាតព្វកិច្ចមិនធ្វើសកម្មភាព") វិធីអនុវត្តដោយបង្ខំដោយផ្ទាល់របៀបនេះមិនអាចធ្វើទៅបានទេ។ ដូច្នេះហើយ ច្បាប់មានកំណត់ពីវិធីអនុវត្តផ្សេងៗ ដោយធ្វើការបែងចែកអាស្រ័យទៅតាមភាពអាចជំនួសបាន ឬ ភាពមិនអាចជំនួសបាននៃសកម្មភាពនោះ ។

## គ) ការអនុវត្តជំនួស

ជាបឋម ក្នុងករណីដែលអាចជំនួសបាន ការអនុវត្តកាតព្វកិច្ចត្រូវបានធ្វើឡើងតាមការអនុវត្តជំនួស (កថាខណ្ឌទី ២ និង កថាខណ្ឌទី ៣ មាត្រា ៥១៤ នៃក្រមរដ្ឋប្បវេណី និង មាត្រា ១៧១ នៃច្បាប់ស្តីពីការអនុវត្តដោយបង្ខំក្នុងរឿងរដ្ឋប្បវេណី)។ មានន័យថាជាមធ្យោបាយប្រមូលយកសោហ៊ុយពីកូនបំណុល ដោយឲ្យតតិយជនធ្វើសកម្មភាពជំនួស (ឬ ឲ្យលុបចោលនូវសកម្មភាពដែលផ្ទុយនឹងខ្លឹមសារ "មិនឲ្យធ្វើសកម្មភាព")។ ជាឧទាហរណ៍ គឺក្នុងករណីដែលក្រុមហ៊ុនសំណង់ដែលបានម៉ៅការសាងសង់ប្រឡាយទឹក មិនបានអនុវត្តកាតព្វកិច្ចសាងសង់ ម្ចាស់ការអាចឲ្យអ្នកសាងសង់ផ្សេងសាងសង់ប្រឡាយនោះ រួចហើយទើបទារប្រាក់ថ្លៃសាងសង់ពីក្រុមហ៊ុនសំណង់វិញ។ ឧទាហរណ៍ផ្សេងទៀត ដូចជាមានការព្រមព្រៀងជាមួយអ្នកជិតខាងថា ក្រៅពីរៀបចំដាំដើមរុក្ខជាតិតាមច្រាំងប្រឡាយ គឺមិនធ្វើប្រឡាយទេ ក៏ប៉ុន្តែ អ្នកជិតខាងបានសង់ប្រឡាយបិទ ហើយពុំព្រមលុបចេញទៅតាមការទាមទារទេ ដូច្នេះ អាចឲ្យតតិយជនលុបចោល ហើយអាចទារថ្លៃចំណាយនោះពីអ្នកជិតខាងតាមក្រោយ ។

## ឃ) ការអនុវត្តដោយប្រយោល

ក៏ប៉ុន្តែ ក្នុងករណីដែលមិនមានភាពអាចជំនួសបានទេ គឺមិនអាចធ្វើការអនុវត្តដោយជំនួសបែបនេះបានទេ។ ឧទាហរណ៍ថា មានការស្នើសុំឲ្យវិចិត្រករដែលល្បីម្នាក់គូររូបគំនូរមួយផ្ទាំង អត្ថន័យសំខាន់គឺការដែលវិចិត្រករជាអ្នកគូររូបគំនូរនោះ ពោលគឺមិនអាចឲ្យអ្នកដទៃគូរជំនួសបានទេ។ ដូច្នេះចំពោះសិទ្ធិលើបំណុលដែលមានខ្លឹមសារជាសកម្មភាពដែលមិនអាចជំនួសបានបែបនេះ គឺត្រូវអនុលោមតាមវិធីអនុវត្តដោយប្រយោល។ នៅក្នុងក្រមរដ្ឋប្បវេណី មិនមានបញ្ញត្តិស្តីពីវិធីអនុវត្តដោយប្រយោលនេះទេ ក៏ប៉ុន្តែវាមានចែងនៅក្នុងច្បាប់ស្តីពីការអនុវត្តដោយបង្ខំក្នុងរឿងរដ្ឋប្បវេណី (មាត្រា ១៧២ នៃច្បាប់ស្តីពីការអនុវត្តដោយបង្ខំក្នុងរឿងរដ្ឋប្បវេណី) ។

មានន័យថា ជាវិធីដែលបង្ខំឲ្យអនុវត្តកាតព្វកិច្ចដោយប្រយោលនៅពេលដែលមិនអនុវត្តកាតព្វកិច្ចហួសដល់អំឡុងពេលជាកំណត់មួយ ដោយអនុលោមទៅតាមការបង្គាប់ឲ្យសងនូវចំនួននៃសំណងការខូចខាតដែលបានកំណត់ (ឧទាហរណ៍ថា បង្គាប់ឲ្យបង់ប្រាក់.....យ៉េន ក្នុង ១ ថ្ងៃចាប់ពីថ្ងៃមិនអនុវត្ត

កាតព្វកិច្ចរហូតដល់ថ្ងៃដែលត្រូវអនុវត្ត)។ ដោយឡែកកាតព្វកិច្ចដែលមានកម្មវត្ថុជាការធ្វើសកម្មភាពគតិយុត្តណាមួយ (ឧទាហរណ៍ថា កាតព្វកិច្ចធ្វើស្ទីការ ជាដើម) ការសម្រេចរបស់តុលាការបង្គាប់ឲ្យធ្វើសកម្មភាពគតិយុត្តអាចជំនួសការបង្ហាញឆន្ទៈរបស់កូនបំណុលបាន (វាក្យខណ្ឌទី ២ កថាខណ្ឌទី ២ មាត្រា ៥១៩ នៃក្រមរដ្ឋប្បវេណី និង មាត្រា ១៧៩ នៃច្បាប់ស្តីពីការអនុវត្តដោយបង្ខំក្នុងរឿងរដ្ឋប្បវេណី)។ នេះគឺការទទួលស្គាល់ភាពមិនចាំបាច់ក្នុងការបង្ខំឲ្យកូនបំណុលធ្វើការបង្ហាញឆន្ទៈ នៅពេលដែលសាលក្រម ឬ សាលដីកា ត្រូវបានសម្រេចរួចរាល់ទៅហើយ ដែលនេះគេហៅថា ការជំនួសដោយសាលក្រម ឬ សាលដីកា។

នាពេលកន្លងមកនេះ ក្នុងករណីដែលអាចអនុវត្តបានតាមការអនុវត្តដោយបង្ខំដោយផ្ទាល់ គឺមិនអាចអនុវត្តតាមការអនុវត្តជំនួស ឬ តាមការអនុវត្តដោយបង្ខំដោយប្រយោលទេ ឬ ក្នុងករណីដែលអាចអនុវត្តដោយជំនួសបាន គឺមិនអាចអនុវត្តតាមការអនុវត្តដោយបង្ខំដោយប្រយោលទេ។ មានការទិតៀនចំពោះការបំពេញបន្ថែមចំពោះការអនុវត្តដោយប្រយោល ទើបក្នុងឆ្នាំ ២០០៣ មានវិសោធនកម្មចំពោះរបបការអនុវត្ត និង ការដាក់ប្រាតិភោគ ហើយទើបបានជាពេលក្រោយមក ទោះបីជាក្នុងករណីដែលអាចអនុវត្តដោយជំនួស ឬ ដោយផ្ទាល់បានក៏ដោយ ក៏អាចប្រើប្រាស់ការអនុវត្តដោយប្រយោលបានដែរ (កថាខណ្ឌទី ១ នៃច្បាប់ស្តីពីការអនុវត្តដោយបង្ខំក្នុងរឿងរដ្ឋប្បវេណី)។ ត្រង់ចំណុចនេះ ប្រសិនបើពិនិត្យមើលតារាងពន្យល់ទៅ នឹងឃើញអំពីទំនាក់ទំនងរវាងវិធីសម្រេចឲ្យបាននូវសិទ្ធិដោយបង្ខំ និងប្រភេទនៃកាតព្វកិច្ចដោយមើលពីតាវកាលិក ។

**តារាងពន្យល់ ៧- ១ ការសម្រេចកាតព្វកិច្ចដោយបង្ខំ**



### ង) ករណីដែលមិនអាចសម្រេចបានតាមរយៈការអនុវត្តដោយបង្ខំ

ក៏ប៉ុន្តែ ការសម្រេចសិទ្ធិតាមរយៈការអនុវត្តដោយបង្ខំ មិនមែនសុទ្ធតែអាចធ្វើទៅបានចំពោះគ្រប់បំណុលទាំងអស់នោះទេ ជាករណីលើកលែង វាក៏មានដែរ គឺកាតព្វកិច្ចដែលទោះបីប្រើវិធីអនុវត្តដោយបង្ខំណាមួយក៏មិនអាចទទួលស្គាល់បានដែរ។ ជាឧទាហរណ៍ ករណីយកិច្ចរួមរស់នឹងគ្នារបស់ប្តីប្រពន្ធ (មាត្រា ៧៥២ នៃក្រមរដ្ឋប្បវេណី) ឬ ករណីនៃការត្រូវប្រគល់កូនដែលជាអនីតិជនទៅឲ្យសហព័ទ្ធដែលលែងលះណាម្ខាង ជាដើម ត្រូវបានបកស្រាយថា មិនអាចប្រើប្រាស់វិធីដោយបង្ខំណាមួយបានទេ ពីព្រោះឆន្ទៈសេរីរបស់មនុស្សត្រូវតែទទួលបាននូវការគោរពជាដាច់ខាត។ មានន័យថា ក្នុងករណីណាមួយក្នុងចំណោមករណីទាំងនេះ បើទោះបីជាការអនុវត្តដោយបង្ខំដោយផ្ទាល់ ឬ ដោយប្រយោលក៏ដោយ ក៏មិនអាចសម្រេចឲ្យបានដោយបង្ខំនូវកាតព្វកិច្ចនោះបានដែរ ។

## ៥ ការមិនអនុវត្តកិច្ចសន្យា (ការមិនអនុវត្តកាតព្វកិច្ច)

ដូចបានរៀបរាប់ពីខាងដើម ក្នុងករណីដែលភាគីដែលមានកាតព្វកិច្ចដោយសារកិច្ចសន្យាមិនអនុវត្តកាតព្វកិច្ចទេ ភាគីម្ខាងទៀតដែលជាម្ចាស់បំណុលអាចបង្ខំឲ្យអនុវត្តនូវកាតព្វកិច្ចនោះបាន ប៉ុន្តែករណីដែលមិនអាចសម្រេចឲ្យបាននូវសិទ្ធិលើបំណុលដោយបង្ខំ ក៏មានមិនតិចដែរ។ ជាឧទាហរណ៍ នៅក្នុងការលក់ទិញរូបគំនូរ នៅមុនពេលដែលអ្នកលក់ប្រគល់រូបគំនូរទៅអ្នកទិញ អាចមានករណីដែលរូបគំនូរត្រូវបានភ្លើងឆេះបំផ្លាញ ដោយសារអគ្គិភ័យ ដែលកើតឡើងដោយសារកំហុសរបស់អ្នកលក់។ ក្នុងករណីនេះ វត្ថុដែលត្រូវប្រគល់លែងមានរូបរាងទៀតហើយ បើទោះបីជាអ្នកលក់មានឆន្ទៈអនុវត្តកាតព្វកិច្ចក៏ដោយ ជាសត្យានុម័ត ក៏ការអនុវត្តមិនអាចធ្វើទៅបានជារូបភាពជាក់ស្តែងដែរ។ ម៉្យាងវិញទៀត ដោយសារតែកូនបំណុលមិនអនុវត្តកាតព្វកិច្ចដោយស្ម័គ្រចិត្ត បើទោះជាម្ចាស់បំណុលបានទាមទារនូវការអនុវត្តដោយបង្ខំក៏ដោយ ដោយសារតែការអនុវត្តកាតព្វកិច្ចមានការយឺតយ៉ាវ ការខូចខាតដែលម្ចាស់បំណុលទទួលរង មិនអាចត្រូវបានធ្វើបដិទានឡើងវិញទេ។ ដូច្នេះ ក្រមរដ្ឋប្បវេណីបញ្ញត្តថា កូនបំណុលត្រូវតែសងសំណងការខូចខាតទៅម្ចាស់បំណុលដែលទទួលរងនូវការខូចខាតដោយសារតែការមិនអនុវត្តកាតព្វកិច្ច (មាត្រា ៤១៥ នៃក្រមរដ្ឋប្បវេណី)។

### ក) អលទ្ធភាពក្នុងការអនុវត្ត

ការមិនអនុវត្តកាតព្វកិច្ចត្រូវបានទទួលស្គាល់ថាមាន ៣ ប្រភេទ។ ទី ១ គឺករណីដែលលែងមាននូវលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ចតទៅទៀតហើយ (ហៅថា អលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ច)។ ឧទាហរណ៍ដែលបានលើកឡើងខាងលើអំពីរូបគំនូរដែលជាកម្មវត្ថុនៃការលក់ទិញ ត្រូវបានភ្លើងឆេះអស់ហើយ គឺជាឧទាហរណ៍អំពីអលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ចនេះ។ អលទ្ធភាពក្នុងន័យនេះ

គឺប្រសិនបើអាចវិនិច្ឆ័យបានពីទស្សនៈនៃសង្គមជាទូទៅថាមិនមានលទ្ធភាពគឺគ្រប់គ្រាន់ហើយ មិនមែនមានន័យថាមិនមានលទ្ធភាពជារូបវន្តទេ។ ជាឧទាហរណ៍ នៅក្នុងករណីនៃការលក់ទិញរូបគំនូរ នៅមុនពេលដែលអ្នកលក់ប្រគល់រូបគំនូរ អាចមានករណីដែលតតិយជនទិញយករូបគំនូរនោះទៅបាត់ ឬ ករណីដែលត្រូវបានគេលួចយកទៅបាត់។ ក្នុងករណីបែបនេះ ដោយសារវត្ថុដែលជាកម្មវត្ថុនៅតែមាននៅឡើយ ជាលក្ខណៈទ្រឹស្តី អ្នកលក់អាចអនុវត្តកាតព្វកិច្ចបានដោយធ្វើលទ្ធកម្មជាថ្មីម្តងទៀត ឬ ក៏យករូបគំនូរពីអ្នកលួចវិញ ក៏ប៉ុន្តែ លទ្ធភាពនៃការដែលអាចសម្រេចគឺទាបណាស់។ នៅក្នុងករណីបែបនេះ គឺអាចត្រូវបានវិនិច្ឆ័យថាវាបានក្លាយទៅជាអលទ្ធភាពក្នុងការអនុវត្តហើយ ។

## ខ) ការយឺតយ៉ាវក្នុងការអនុវត្ត

ទី ២ គឺករណីហួសពេលត្រូវអនុវត្ត បើទោះបីជាមានលទ្ធភាពក្នុងការអនុវត្តក៏ដោយ (ហៅថាការយឺតយ៉ាវក្នុងការអនុវត្ត)។ ឧទាហរណ៍ដូចជាក្នុងករណីដែលកូនបំណុលបានខ្ចីប្រាក់ ហើយបានសន្យាថាខ្លួននឹងសងវិញ ៣ ខែក្រោយ ក៏ប៉ុន្តែ ទោះបីជាអំឡុងពេល ៣ ខែ បានកន្លងផុតទៅហើយក្តី ក៏គាត់មិនទាន់បានសងដែរ ។

ការកំណត់ថាតើកូនបំណុលបានយឺតយ៉ាវក្នុងការសងបំណុលពីពេលណានោះ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងការកំណត់អំពីពេលដែលត្រូវអនុវត្តកាតព្វកិច្ច។ ជាបឋម ក្នុងករណីដែលមានការកំណត់ច្បាស់លាស់អំពីពេលវេលាត្រូវអនុវត្តកាតព្វកិច្ច ពោលគឺការសន្យាថា "ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៩" ឬក៏ "៣ ខែក្រោយ" ជាដើម ដូច្នេះ នៅពេលដែលពេលវេលាដែលត្រូវសងបានកំណត់ច្បាស់ដោយប្រតិទិនហើយ ចាប់ពីចំណុចពេលវេលាដែលថ្ងៃនោះបានមកដល់ កូនបំណុលត្រូវធ្លាក់ទៅក្នុងស្ថានភាពនៃការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចហើយ (កថាខណ្ឌទី១ មាត្រា ៥១២ នៃក្រមរដ្ឋប្បវេណី)។ ជាបន្តគឺក្នុងករណីដែលមានការកំណត់អំពីពេលវេលាមិនច្បាស់លាស់ មានន័យថាបានសន្យាថា "ក្រោយពេលបានទទួលលុយផ្ញើពីផ្ទះមក" ដូច្នេះ ការមកដល់នៃពេលត្រូវអនុវត្ត (ពេលទទួលលុយផ្ញើមក) គឺច្បាស់លាស់ហើយ ក៏ប៉ុន្តែមិនអាចកំណត់អំពីពេលវេលានោះតាមប្រតិទិនបានទេ ដូច្នេះ ភាពយឺតយ៉ាវនឹងកើតមានចាប់ពីចំណុចពេលដែលកូនបំណុលបានដឹងថា អំឡុងពេលសងដែលមិនច្បាស់លាស់នោះ បានមកដល់ហើយ (កថាខណ្ឌទី ២ នៃមាត្រាដដែល)។ ចុងក្រោយ គឺក្នុងករណីដែលមិនបានកំណត់ពេលសម្រាប់អនុវត្តកាតព្វកិច្ចទេ ឧទាហរណ៍ថា មិត្តភក្តិខ្ចីប្រាក់បន្តិចបន្តួច ហើយមិនបានបញ្ជាក់ថាសងពេលណា ដូច្នេះ ការយឺតយ៉ាវនឹងកើតមានក្រោយពេលដែលកូនបំណុលទទួលបានការទាមទារឲ្យសង (កថាខណ្ឌទី ៣ នៃមាត្រាដដែល) ។

## គ) ការអនុវត្តមិនពេញលេញ

មាត្រា ៩១៥ នៃក្រមរដ្ឋប្បវេណីមានចែងអំពីអលទ្ធភាពក្នុងការអនុវត្ត និង ការយឺតយ៉ាវក្នុងការអនុវត្ត ក៏ប៉ុន្តែ ដោយសារតែទទួលឥទ្ធិពលពីទ្រឹស្តីច្បាប់រដ្ឋប្បវេណីអាល្លឺម៉ង់ ទ្រឹស្តី និង យុត្តិសាស្ត្រតុលាការ ក៏បានទទួលស្គាល់ការមិនអនុវត្តកាតព្វកិច្ចក្នុងប្រភេទទី ៣ នេះ។ មានន័យថា ការពិតទៅបានអនុវត្តកាតព្វកិច្ចហើយ ក៏ប៉ុន្តែអនុវត្តមិនអស់សព្វគ្រប់ (ហៅថា ការអនុវត្តមិនពេញលេញ)។ ឧទាហរណ៍នៅក្នុងការលក់ទិញសៀវភៅ អ្នកទិញបានទទួលពីអ្នកលក់នូវសៀវភៅដែលខ្វះទំព័រ ឬ ក៏ទំព័រមិនតាមលំដាប់ ដែលជាករណីដែលរបស់នោះមិនពេញលេញគ្រប់លក្ខណៈ។ ឬក៏មានករណីដូចជាការលក់ទិញកូនមាន់ ដោយសារតែអ្នកលក់បានប្រគល់ទៅឲ្យអ្នកទិញនូវកូនមាន់ដែលឈឺ ជំងឺនោះបានឆ្លងទៅមាន់ធំៗដែលអ្នកទិញបានចិញ្ចឹមតាំងពីមុនមក ហើយមាន់ទាំងនោះបានងាប់អស់ទៅ ។ ក្នុងករណីទាំងអស់នេះ កាតព្វកិច្ចត្រូវអនុវត្តហើយ ក៏ប៉ុន្តែ មិនអាចវាយតម្លៃបានថាជាការអនុវត្តដែលពេញលេញទេ ហើយដោយសារម្ចាស់បំណុលបានទទួលរងនូវការខូចខាត យើងអាចគិតបានថា កូនបំណុលត្រូវបានឲ្យទទួលកាតព្វកិច្ចចំពោះសំណងការខូចខាត ដូចជាក្នុងករណីអលទ្ធភាពក្នុងការអនុវត្ត ឬ ករណីយឺតយ៉ាវក្នុងការអនុវត្តដែរ ។

### ឃ) មូលហេតុនៃការដាក់ការទទួលខុសត្រូវ និង ភាពផ្ទុយនឹងច្បាប់

ក្នុងករណីដែលមានអង្គហេតុស្តីពីការមិនអនុវត្តកាតព្វកិច្ច កូនបំណុលមិនមែនសុទ្ធតែត្រូវទទួលកាតព្វកិច្ចចំពោះសំណងការខូចខាតទេ។ កូនបំណុលត្រូវដាក់ឲ្យទទួលខុសត្រូវចំពោះសំណងការខូចខាត លុះត្រាតែលក្ខខណ្ឌនៃការមិនអនុវត្តកាតព្វកិច្ចដោយសារហេតុដែលជាកំហុសរបស់កូនបំណុល (ហៅថា មូលហេតុនៃការដាក់ការទទួលខុសត្រូវ) ឬ លក្ខខណ្ឌដែលថាការមិនអនុវត្តកាតព្វកិច្ចគឺផ្ទុយនឹងច្បាប់ ត្រូវបានបំពេញ។ ហេតុដែលត្រូវដាក់ការទទួលខុសត្រូវចំពោះកូនបំណុលត្រង់នេះ មិនមែនសំដៅទាំងស្រុងថាជាការដែលកូនបំណុលមានចេតនា ឬ កំហុស ចំពោះការមិនអនុវត្តកាតព្វកិច្ចនោះទេ តែត្រូវបានបកស្រាយដោយទូលាយថា ជាការរាប់បញ្ចូលទាំងហេតុដែលចាត់ទុកថាដូចគ្នានឹងចេតនា ឬ កំហុស ក៏ដូចជាគោលការណ៍សុចរិត និង សច្ចភាព។ ជាឧទាហរណ៍ ចេតនា ឬ កំហុសរបស់អ្នកដែលត្រូវបានកូនបំណុលប្រើដើម្បីអនុវត្តកាតព្វកិច្ច ជាដើម (អ្នកជំនួយក្នុងការអនុវត្ត) ។

ចេតនាត្រង់កន្លែងនេះមានន័យថា ការដែលមានចេតនាមិនអនុវត្តកាតព្វកិច្ច ឬ ក៏ការដែលដឹងដែរថាជាការមិនអនុវត្តកាតព្វកិច្ច ប៉ុន្តែ នៅតែបណ្តែតបណ្តោយឲ្យស្ថានភាពនៅដដែល។ ដោយឡែកកំហុសវិញ មានន័យថា ការក្លាយទៅជាការមិនអនុវត្តកាតព្វកិច្ច ដោយសារតែខ្វះការប្រុងប្រយ័ត្នឲ្យដិតដល់។ ក៏ប៉ុន្តែនៅក្នុងបណ្តឹង ដោយសារតែចាំបាច់ត្រូវធ្វើការអះអាង និង បញ្ជាក់ថា កូនបំណុលគ្មានមូលហេតុនៃការទទួលខុសត្រូវ ថាតើត្រូវមានអង្គហេតុបែបណាដើម្បីកំណត់ថាគ្មានមូលហេតុនៃការទទួលខុសត្រូវនោះ បានក្លាយទៅជាបញ្ហា ហើយទស្សនៈស្តីពីចេតនា ឬ កំហុសចំពោះការមិនអនុវត្តកាតព្វកិច្ចគឺមានភាពស្រពេចស្រពិល ។

ដើម្បីទទួលស្គាល់សំណងការខូចខាតដោយសារការមិនអនុវត្តកាតព្វកិច្ច ក្រៅពីមានមូលហេតុនៃការទទួលខុសត្រូវ ការមិនអនុវត្តកាតព្វកិច្ចចាំបាច់ត្រូវតែជាភាពផ្ទុយនឹងច្បាប់។ ករណីមួយចំនួនធំនៃការមិនអនុវត្តកាតព្វកិច្ចគឺជាការផ្ទុយនឹងច្បាប់ ហើយករណីលើកលែងដែលការមិនអនុវត្តកាតព្វកិច្ចមិនមែនជាការផ្ទុយនឹងច្បាប់នោះដូចជាមិនសូវមានទេ។ ជាឧទាហរណ៍ ចំពោះកាតព្វកិច្ចពីរដែលកើតចេញពីកិច្ចសន្យាអញ្ញមញ្ញ ផ្តើមចេញពីទំនាក់ទំនងតម្លៃតបនៃកាតព្វកិច្ចទាំងពីរដែលជាទំនាក់ទំនងជិតស្និទ្ធនឹងគ្នា ដូចបានរៀបរាប់ខាងលើ គឺសិទ្ធិតវ៉ាឲ្យអនុវត្តព្រមគ្នា ត្រូវបានទទួលស្គាល់ (មាត្រា ៥៣៣ នៃក្រមរដ្ឋប្បវេណី)។ ហេតុដូច្នេះ បើទោះបីជាមានអង្គហេតុស្តីពីការមិនអនុវត្តកាតព្វកិច្ចក៏ដោយ នៅពេលដែលកូនបំណុលអាចលើកឡើងពីការតវ៉ាឲ្យអនុវត្តព្រមគ្នា នោះការមិនអនុវត្តកាតព្វកិច្ចនឹងក្លាយទៅជាខ្វះភាពផ្ទុយនឹងច្បាប់ហើយ ។

## ង) សំណងការខូចខាត

ក្នុងករណីដែលកូនបំណុលត្រូវទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ច ជាគោលការណ៍ត្រូវសងសំណងការខូចខាតជាប្រាក់ (មាត្រា ៤១៧ នៃក្រមរដ្ឋប្បវេណី) ក៏ប៉ុន្តែ ទំហំនៃការខូចខាតដែលត្រូវសងមានចែងនៅក្នុងមាត្រា ៤១៦ នៃក្រមរដ្ឋប្បវេណី។ ពោលគឺសំដៅលើការខូចខាតដែលកើតឡើងជាធម្មតាពីការមិនអនុវត្តកាតព្វកិច្ច និង ការខូចខាតដោយសារកាលៈទេសៈពិសេស ដែលអាចព្យាករទុកជាមុនបាន (កថាខណ្ឌទី ២ នៃមាត្រាដដែល) ។

ជាឧទាហរណ៍ នៅក្នុងការលក់ទិញរូបគំនូរ ក្នុងករណីដែលអលទ្ធភាពក្នុងការអនុវត្តដោយសារតែរូបគំនូរត្រូវបានភ្លើងឆេះអស់ហើយ រូបគំនូរនោះគឺជាការខូចខាតធម្មតា (ត្រូវសងសំណងទឹកប្រាក់តាមចំនួនដែលបានវាយតម្លៃជាទឹកប្រាក់)។ ម្យ៉ាងវិញទៀត ក្នុងការលក់ទិញអគារ ក្នុងករណីដែលអ្នកទិញត្រូវស្នាក់នៅសណ្ឋាគារ ដោយសារតែការប្រគល់អគារមានការយឺតយ៉ាវ ដូច្នេះ សោហ៊ុយស្នាក់នៅនោះត្រូវបានគិតថាជាការខូចខាតធម្មតា។ ដោយឡែកចំពោះការលក់ទិញរូបគំនូរ ក្នុងករណីដែលអ្នកទិញមានគម្រោងលក់រូបគំនូរនោះបន្តក្នុងតម្លៃដែលថ្លៃជាងតម្លៃដើម ជាទូទៅ ផលប្រយោជន៍ដែលរំពឹងថានឹងបានពីការលក់បន្តនោះ ត្រូវបានគិតថាជាការខូចខាតដោយសារកាលៈទេសៈពិសេស ហើយថាតើភាគីបានដឹងអំពីការលក់បន្តនោះដែរ ឬទេ ប្រសិនបើភាគីបានដឹង សំណងនោះនឹងត្រូវបានទទួលស្គាល់ ។

ក៏ប៉ុន្តែ រហូតមកដល់ពេលថ្មីៗនេះ នៅក្រោមឥទ្ធិពលនៃទ្រឹស្តីច្បាប់អាល្លឺម៉ង់ ការខូចខាតដែលគួរសង គឺជាអ្វីដែលមានទំនាក់ទំនងនៃហេតុផលដែលត្រឹមត្រូវសមរម្យជាមួយនឹងការមិនអនុវត្តកាតព្វកិច្ច ហើយមាត្រា ៤១៦ នៃក្រមរដ្ឋប្បវេណីត្រូវបានបកស្រាយថាជាបញ្ញត្តិដែលចែងអំពីវិសាលភាពនោះ។ ដោយសារតែទំនាក់ទំនងនៃហេតុផល ជាធម្មតា រីកដុះដោយគ្មានដែនកំណត់ មានទស្សនៈដែលលើក

ឡើងថា មិនមែនត្រូវសងនូវរាល់ការខូចខាតដែលបានកើតឡើងជាក់ស្តែងទាំងអស់នោះទេ ក៏ប៉ុន្តែសងតែសំណងការខូចខាតក្នុងទំហំដែលសមរម្យបានហើយ ដោយមានការពន្យល់ចំពោះការខូចខាតក្នុងទំហំដែលសមរម្យ ដោយពាក្យទំនាក់ទំនងនៃហេតុផលដែលត្រឹមត្រូវសមរម្យ។ នាពេលបច្ចុប្បន្ន មាត្រាដដែលនេះត្រូវបានគិតថាមានប្រភពមកពីយុត្តិសាស្ត្ររបស់អង់គ្លេសដែលទទួលឥទ្ធិពលពីច្បាប់បារាំង ហើយមានខ្លឹមសារខុសគ្នាពីបញ្ញត្តិបែបនេះនៅក្នុងក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ (នៅអាល្លឺម៉ង់ គេអនុម័តយកគោលការណ៍សំណងទាំងស្រុងដែលកំណត់ថា រាល់ការខូចខាតដែលបានកើតឡើង ត្រូវតែសងសំណង ហើយចំពោះការគិតពីទំហំការខូចខាតដែលត្រូវសងសំណង ត្រូវយកទំនាក់ទំនងនៃហេតុផលដែលត្រឹមត្រូវសមរម្យរវាងការខូចខាត និង ការមិនអនុវត្តកាតព្វកិច្ច ធ្វើជាបទដ្ឋាននៃការពិចារណា) ។

ទោះជាយ៉ាងនេះក្តី ដោយហេតុថា ក្នុងក្រមរដ្ឋប្បវេណី មាត្រា ៤១៦ មានចែងពីទំហំការខូចខាតដែលត្រូវទទួលសំណង ដូច្នេះ ទោះបីជាក្នុងទ្រឹស្តីសិក្សាមានភាពផ្ទុយគ្នាក្តី ចំពោះការបកស្រាយជាក់ស្តែង ភាពខុសគ្នានោះមិនមានលក្ខណៈច្បាស់លាស់នោះទេ ។

ក្នុងករណីដែលមានការព្រមព្រៀងជាមុនរវាងគូភាគីអំពីចំនួននៃសំណងការខូចខាត ចំនួនដែលបានព្រមព្រៀងនោះនឹងក្លាយទៅជាចំនួនសំណងការខូចខាត (មាត្រា ៤២០ នៃក្រមរដ្ឋប្បវេណី)។ តុលាការមិនអាចបន្ថែម ឬ បន្ថយចំនួននោះបានទេ (ផ្អែកតាមមាត្រា ៩០ នៃក្រមរដ្ឋប្បវេណី គឺនៅមានឱកាសធ្វើជាមោឃៈបាន)។ ក៏ប៉ុន្តែ ចំពោះកិច្ចសន្យាអ្នកប្រើប្រាស់ ក្នុងករណីដែលចំនួនសំណងការខូចខាតដែលត្រូវបង់របស់អ្នកប្រើប្រាស់ លើសពីចំនួនការខូចខាតជាមធ្យមដែលគួរកើតមានចំពោះពាណិជ្ជករ ជាដើម ខ្លឹមសារដែលកំណត់អំពីចំនួនសំណងការខូចខាតនោះត្រូវទុកជាមោឃៈចំពោះផ្នែកដែលលើសនោះ (មាត្រា ៩ នៃច្បាប់ស្តីពីកិច្ចសន្យាអ្នកប្រើប្រាស់) ។

## ៤) ការរំលាយកិច្ចសន្យា

ជាឧទាហរណ៍ដូចជាកាតព្វកិច្ចបង់ថ្លៃលក់ទិញរបស់អ្នកទិញ ជាដើម ក្នុងករណីដែលមិនអនុវត្តកាតព្វកិច្ចដែលកើតចេញពីកិច្ចសន្យានោះទេ អ្នកលក់ដែលជាម្ចាស់បំណុលមិនត្រឹមតែអាចទាមទារឲ្យអនុវត្តដោយបង្ខំ ឬ ទាមទារសំណងការខូចខាតប៉ុណ្ណោះទេ តែអាចរំលាយកិច្ចសន្យាលក់ទិញបានដែរ។ នៅពេលដែលអ្នកលក់រំលាយកិច្ចសន្យាលក់ទិញ កិច្ចសន្យានឹងរលត់ដោយមានអានុភាពប្រតិសកម្ម (នឹងត្រូវបានចាត់ចែងដូចករណីដែលគ្មានកិច្ចសន្យាតាំងពីដំបូង) ហើយអ្វីដែលភាគីទាំងសងខាងបានធ្វើលទ្ធកម្មដោយកិច្ចសន្យា ត្រូវតែប្រគល់ទៅឲ្យភាគីម្ខាងទៀតវិញជាដាច់ខាត (កថាខណ្ឌទី ១ មាត្រា ៥៤៥ នៃក្រមរដ្ឋប្បវេណី។ គេហៅថា ករណីយកិច្ចបដិទាននូវស្ថានភាពដើម )។

ដូច្នេះហើយ ការរំលាយកិច្ចសន្យាមានន័យថា ដោយសារមូលហេតុនៃការមិនអនុវត្តកាតព្វកិច្ចរបស់ភាគីម្ខាងទៀតនៃកិច្ចសន្យា អានុភាពនៃកិច្ចសន្យាត្រូវបានចាត់ទុកថាមិនបានកើតឡើងចំពោះភាគីម្ខាងតាំងពីដំបូង។ ក៏ប៉ុន្តែ ចំពោះកិច្ចសន្យាដែលមានភាពបន្តឥតដាច់ដូចជាកិច្ចសន្យាជួលអចិន្ត្រៃយ៍ ជាដើម អានុភាពនៃការលុបចោលគឺមានត្រឹមតែទៅអនាគតតែប៉ុណ្ណោះ ដោយមិនចាត់ទុកថាមានអានុភាពប្រតិសកម្មទេ (មាត្រា ៦០២ នៃក្រមរដ្ឋប្បវេណី ជាដើម)។ ក្នុងករណីដែលសិទ្ធិរំលាយត្រូវបានកំណត់ដោយច្បាប់ ជាដើម កិច្ចសន្យាដែលអាចត្រូវបានរំលាយដោយមូលហេតុផ្សេងក្រៅពីការមិនអនុវត្តកាតព្វកិច្ច ក៏មានដែរដែលវាជាករណីលើកលែង)។ ក្នុងករណីដែលភាគីទាំងសងខាងមានកាតព្វកិច្ចរៀងខ្លួនដោយសារកិច្ចសន្យាណាមួយ (កិច្ចសន្យាអញ្ញមញ្ញ) ភាគីម្ខាងអាចរួចផុតពីការអនុវត្តកាតព្វកិច្ចរបស់ខ្លួនដោយការរំលាយកិច្ចសន្យាដោយមូលហេតុការមិនអនុវត្តកាតព្វកិច្ចរបស់ភាគីម្ខាងទៀត។ ក្នុងករណីដែលទាមទារសំណងការខូចខាតដោយមូលហេតុការមិនអនុវត្តកាតព្វកិច្ច កិច្ចសន្យានៅបន្តមាន ហើយខ្លួនឯងក៏ត្រូវអនុវត្តកាតព្វកិច្ចជាដាច់ខាតដែរ ដូច្នេះ ដើម្បីរួចផុតពីការអនុវត្តកាតព្វកិច្ច មានតែមធ្យោបាយរំលាយកិច្ចសន្យាទេដែលល្អ។ ក៏ប៉ុន្តែ ក្នុងករណីដែលត្រូវធ្វើបដិទាននូវស្ថានភាពដើមដោយសារការរំលាយកិច្ចសន្យា ប្រសិនបើមានការខូចខាតណាដែលមិនអាចធ្វើបដិទានតាមរយៈការធ្វើបដិទានស្ថានភាពដើមទេ ភាគីក៏អាចទាមទារសំណងបានដែរ (កថាខណ្ឌទី ៣ មាត្រា ៥៤៥ នៃក្រមរដ្ឋប្បវេណី)។

ដូចគ្នាទៅនឹងករណីនៃការទាមទារសំណងការខូចខាតដែរ ដើម្បីរំលាយកិច្ចសន្យា មិនមែនត្រូវមានតែអង្គហេតុស្ដីពីការមិនអនុវត្តកាតព្វកិច្ច (ការយឺតយ៉ាវក្នុងការអនុវត្ត អលទ្ធភាពក្នុងការអនុវត្ត ឬការអនុវត្តមិនពេញលេញ) តែប៉ុណ្ណោះទេ ក៏ប៉ុន្តែ ចាំបាច់ត្រូវមានមូលហេតុដាក់បន្ទុកទទួលខុសត្រូវចំពោះកូនបំណុលផងដែរ។ ក្រមរដ្ឋប្បវេណីចែងអំពីនីតិវិធីខុសគ្នារវាងករណីនៃការយឺតយ៉ាវក្នុងការអនុវត្ត និង ករណីនៃអលទ្ធភាពក្នុងការអនុវត្ត។ ក្នុងករណីដែលភាគីម្ខាងនៃកិច្ចសន្យាមានការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច ភាគីម្ខាងទៀតត្រូវធ្វើការដាស់តឿនដោយកំណត់អំឡុងពេលសមរម្យមួយ ហើយប្រសិនបើកាតព្វកិច្ចមិនត្រូវបានអនុវត្តក្នុងអំឡុងពេលនោះទេ គឺអាចរំលាយកិច្ចសន្យាបាន (មាត្រា ៥៤១ នៃក្រមរដ្ឋប្បវេណី)។ មានន័យថា ជាការផ្តល់ឲ្យភាគីដែលមិនអនុវត្តកាតព្វកិច្ចនូវឱកាសម្តងទៀតក្នុងការអនុវត្តកាតព្វកិច្ច។ ផ្ទុយទៅវិញ ក្នុងករណីដែលភាគីម្ខាងធ្លាក់ទៅក្នុងស្ថានភាពអលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ច ភាគីម្ខាងទៀតអាចរំលាយកិច្ចសន្យាបានភ្លាម (មាត្រា ៥៤៣ នៃក្រមរដ្ឋប្បវេណី)។ វាជារឿងធម្មតាទេដែលមិនចាំបាច់មានការដាស់តឿន ដោយសារតែលទ្ធភាពក្នុងការអនុវត្តលែងមានតទៅទៀតហើយនោះ។

### ឆ) ការមិនអនុវត្តកាតព្វកិច្ចដោយគ្មានមូលហេតុនៃការដាក់ការទទួលខុសត្រូវ

ការរំលាយកិច្ចសន្យា ឬ ការទាមទារសំណងការខូចខាតដោយមូលហេតុការមិនអនុវត្តកាតព្វកិច្ច គឺដូចដែលបានរៀបរាប់ពីខាងដើមមកយ៉ាងដូច្នេះ គឺជាវិធានការការពារដែលបានផ្តល់ទៅឲ្យម្ចាស់បំណុល ក្នុងករណីមានហេតុនៃការដាក់បន្ទុកទទួលខុសត្រូវចំពោះកូនបំណុលក្នុងការមិនអនុវត្តកាតព្វកិច្ច។ ក៏ប៉ុន្តែក្នុងករណីដែលគ្មានហេតុនៃការដាក់បន្ទុកទទួលខុសត្រូវចំពោះកូនបំណុលចំពោះការមិនអនុវត្តកាតព្វកិច្ចទេ ម្ចាស់បំណុលមិនអាចទាមទារសំណងការខូចខាតបានទេ ហើយលើសពីនេះទៀត គឺមិនអាចរំលាយកិច្ចសន្យាបានទេ ហើយកាតព្វកិច្ចតាមកិច្ចសន្យានៅតែមានដដែល។ ជាលទ្ធផល ម្ចាស់បំណុលនឹងត្រូវរ៉ាប់រងនូវការខូចខាតដោយសារការមិនអនុវត្តកាតព្វកិច្ច ។

ក៏ប៉ុន្តែ ចំពោះកាតព្វកិច្ចពីរដែលកើតពីកិច្ចសន្យាអញ្ញមញ្ញពីទំនាក់ទំនងដ៏ជិតស្និទ្ធនោះ ក្នុងករណីដែលកាតព្វកិច្ចមួយបានក្លាយទៅជាអលទ្ធភាពក្នុងការអនុវត្ត ដោយគ្មានហេតុនៃការទទួលខុសត្រូវរបស់កូនបំណុលទេ ច្បាប់មានកំណត់អំពីរបបនៃការទទួលបន្ទុកហានិភ័យ ចំពោះកាតព្វកិច្ចម្ខាងទៀតដែលនៅបន្តអត្ថិភាពនៅឡើយ។ ត្រង់ចំណុចនេះ ក្នុងករណីដែលការអនុវត្តកាតព្វកិច្ច បានក្លាយជាអលទ្ធភាពដោយសារគ្មានហេតុនៃការដាក់បន្ទុកទទួលខុសត្រូវរបស់កូនបំណុល ម្ចាស់បំណុលមិនអាចទាមទារសំណងការខូចខាតបានទេ ក៏ប៉ុន្តែ នៅពេលដែលកាតព្វកិច្ចនោះបានកើតពីកិច្ចសន្យាអញ្ញមញ្ញ កាតព្វកិច្ចម្ខាងទៀតត្រូវរលត់ (ករណីនៃការអនុវត្តគោលការណ៍ទទួលបន្ទុកហានិភ័យរបស់កូនបំណុល)។ ក៏ប៉ុន្តែ នៅក្នុងកិច្ចសន្យាលក់ទិញ ប្រសិនបើកាតព្វកិច្ចប្រគល់វត្ថុដែលជាកម្មវត្ថុនៃការលក់ទិញក្លាយទៅជាអលទ្ធភាពក្នុងការអនុវត្ត អ្នកទិញដែលជាម្ចាស់បំណុលមិនអាចរួចផុតពីកាតព្វកិច្ចបង់ថ្លៃលក់ទិញបានទេ (ដោយសារតែច្បាប់អនុម័តយកគោលការណ៍ទទួលបន្ទុកហានិភ័យរបស់ម្ចាស់បំណុល) ។

**តារាងពន្យល់ ៧-២ អានុភាពនៃការមិនអនុវត្តកាតព្វកិច្ច**

**ការមិនអនុវត្តកាតព្វកិច្ច**
(ការយឺតយ៉ាវក្នុងការអនុវត្ត អលទ្ធភាពក្នុងការអនុវត្ត ឬ ការអនុវត្តមិនពេញលេញ)

- ➡ ការសម្រេចដោយបង្ខំ (ករណីដែលអាចអនុវត្តបាន)
- ➡ សំណងការខូចខាត
- ➡ ការរំលាយកិច្ចសន្យា (ការមិនអនុវត្តកាតព្វកិច្ចទៅតាមកិច្ចសន្យា)
- ➡ បន្ទុកហានិភ័យ (អលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ចរបស់ភាគីម្ខាងនៃកិច្ចសន្យាអញ្ញមញ្ញ)

✐ ការបង្កើតកិច្ចសន្យារវាងភាគីដែលនៅឆ្ងាយពីគ្នា--ការពិចារណាតាមរយៈករណីសិក្សា

A បានធ្វើសំណើដែលជាការបង្ហាញឆន្ទៈទៅ B ថាចង់លក់ដី (ក) តាមរយៈការជូនដំណឹងតាមប្រៃសណីយ៍ ហើយ B ក៏បានធ្វើស្វីការតបទៅនឹងសំណើនោះវិញថាព្រមទិញដីនោះ។ ដូច្នេះ កិច្ចសន្យាលក់ទិញរវាង A និង B បានកើតឡើងហើយ។ នៅមុនពេលដែលស្វីការពី B បានទៅដល់ A លោក A បានលក់ដី (ក) នោះទៅឲ្យ C បាត់ ក៏ប៉ុន្តែ បើយោងទៅលើស្វីការរបស់ B គឺកិច្ចសន្យាលក់ទិញរវាង A និង B បានកើតឡើងហើយ ដូច្នេះ កិច្ចសន្យារវាង A និង C មិនរារាំងកិច្ចសន្យាលក់ទិញរវាង A និង B ទេ ។

ក៏ប៉ុន្តែ ប្រសិនបើកិច្ចសន្យារវាង A និង C បានអនុវត្តហើយ ហើយការចុះបញ្ជីផ្ទេរដី (ក) ទៅឈ្មោះ C បានធ្វើរួចហើយដែរនោះ កាតព្វកិច្ចរបស់ A ដែលកើតឡើងតាមកិច្ចសន្យារវាង A និង B ត្រូវបានវិនិច្ឆ័យថាបានក្លាយទៅជាអលទ្ធភាពក្នុងការអនុវត្តដែល A ត្រូវទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ច (ក៏ប៉ុន្តែ ចំពោះបញ្ហាក្នុងករណីដែលទ្រព្យតែមួយត្រូវបានធ្វើអនុប្បទានជាន់គ្នា សូមពិនិត្យមើលជាលម្អិតក្នុងជំពូកទី ១៨) ។

## ✧ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ (BGB)

នៅពេលដែលក្រមរដ្ឋប្បវេណីបារាំងត្រូវបានបញ្ញត្តនាដើមសតវត្សទី ១៩ នៅអាល្លឺម៉ង់ នៅមិនទាន់មានការចងក្រងជាក្រមនៅឡើយទេ ក៏ប៉ុន្តែ ច្បាប់រ៉ូម៉ាំងត្រូវបានអនុវត្តជានីតិរួមដែលមានព្រំដែននៃការអនុវត្តផ្សេងៗគ្នា (នេះត្រូវបានគេហៅថា ការទទួលបន្តនូវច្បាប់រ៉ូម៉ាំង)។ ប្រព័ន្ធច្បាប់ឯកជនដែលគេហៅថាទ្រឹស្តីច្បាប់ផានដេកតេង ដែលផ្តោតជាសំខាន់ទៅលើការស្រាវជ្រាវកម្រងទ្រឹស្តីច្បាប់រ៉ូម៉ាំង ជាពិសេស ក្រមរដ្ឋប្បវេណីយ៉ាស្ទីនៀនស៍ (របស់អធិរាជ Justinianus ទី១) (គេហៅថា ផានដេកតេង (Pandectae) ឬ ឌីហ្គេសតា (Digesta) ) ត្រូវបានបង្កើតឡើង ។

ដោយទទួលឥទ្ធិពលពីបារាំង មានការជជែកដេញដោលគ្នាបានកើតឡើងរវាងទស្សនៈដែលគិតថា ដល់ពេលដែលអាល្លឺម៉ង់គិតគូរពីការបញ្ញត្តក្រមរដ្ឋប្បវេណី ដើម្បីធ្វើឲ្យមានឯកភាពច្បាប់ហើយ ជាមួយនឹងទស្សនៈដែលគិតថា ការដែលបញ្ញត្តក្រមរដ្ឋប្បវេណីក្នុងដំណាក់កាលដែលប្រទេសជាតិមិនទាន់រួបរួមគ្នានៅឡើយ គឺបីដូចជាលឿនពេកហើយ ។

ក្រោយពីនោះ ក្រមរដ្ឋប្បវេណីដែលត្រូវបានបញ្ញត្តនាឆ្នាំ ១៨៩៦ គឺយកតាមប្រព័ន្ធផានដេកតេង។ លំនាំដូចគ្នានោះគឺបទប្បញ្ញត្តិទូទៅ ច្បាប់ស្តីពីកាតព្វកិច្ច ច្បាប់ស្តីពីសិទ្ធិប្រត្យក្ស ច្បាប់ស្តីពីគ្រួសារ និង ច្បាប់ស្តីពីសន្តតិកម្ម ដែលបង្កើតទៅជា ៥ គន្ថី។ ក្រមរដ្ឋប្បវេណីបារាំងយកលំនាំតាមការបែងចែកជាគន្ថី ដែលមាននៅក្នុងក្រមយ៉ាស្ទីនៀនស៍ ក៏ប៉ុន្តែ ក្រមរដ្ឋប្បវេណីបារាំងត្រូវបានរិះគន់ថា មានបញ្ហាលើរចនាសម្ព័ន្ធ ទាក់ទងនឹងចំណុចដូចជាការដែលដាក់បញ្ញត្តិស្តីពីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ជាប្រភេទមួយនៃកិច្ចសន្យា ដូចបញ្ញត្តិស្តីពីកិច្ចសន្យាលក់ទិញ និង ការដែលកំណត់ថា សន្តតិកម្មគឺជាវិធីធ្វើលទ្ធកម្មកម្មសិទ្ធិដូចគ្នានឹងកិច្ចសន្យា ជាអាទិ៍។ ផ្ទុយទៅវិញ របៀបបែងចែកជាគន្ថីរបស់ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ ត្រូវបានវាយតម្លៃថាមានភាពល្អប្រសើរជាង (គន្ថីស្តីពីបទប្បញ្ញត្តិទូទៅគឺជាលក្ខណៈពិសេសរបស់ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ ដោយវាបានស្តែងឲ្យឃើញនូវលទ្ធភាពបំព្រួញរបស់ទ្រឹស្តីច្បាប់អាល្លឺម៉ង់)។ ដោយហេតុនេះហើយ នៅក្នុងសតវត្សទី ២០ ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់បានជះឥទ្ធិពលយ៉ាងខ្លាំងទៅដល់ប្រទេសជាច្រើន។ ក្នុងចំណោមនោះ ក៏មានប្រទេសដែលធ្លាប់មានក្រមរដ្ឋប្បវេណីយកលំនាំតាមក្រមរដ្ឋប្បវេណីបារាំង បានធ្វើវិសោធនកម្មទាំងស្រុង ហើយងាកមកអនុម័តក្រមរដ្ឋប្បវេណីថ្មីដែលយកលំនាំតាមអាល្លឺម៉ង់វិញផងដែរ ។

ដោយឡែកប្រទេសជប៉ុនវិញ ការបែងចែកជាគន្ថីនៅក្នុងក្រមរដ្ឋប្បវេណីចាស់គឺផ្អែកលើមូលដ្ឋាននៃក្រមរដ្ឋប្បវេណីបារាំង ក៏ប៉ុន្តែ ចំពោះក្រមរដ្ឋប្បវេណីថ្មីគឺជាក្រមដែលយកលំនាំតាមក្រមអាល្លឺម៉ង់ ។

# ជំពូកទី ៨

# កម្មសិទ្ធិ

១ ប្រភេទនៃសិទ្ធិប្រត្យក្ស

២ កម្មសិទ្ធិៈ ចលនវត្ថុ និង អចលនវត្ថុ

៣ លទ្ធកម្មនៃកម្មសិទ្ធិ

៤ សិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្ស

✎ សិទ្ធិទាមទារឲ្យបង្ការការរារាំង និង ការទទួលបន្ទុកចំពោះសោហ៊ុយ --ការពិចារណាតាមរយៈករណីសិក្សា

Khmer Law's Association

ករណីសិក្សា ៖ ដីរបស់ A មានទីតាំងនៅក្រោមជម្រាលដីរបស់ B ហើយដីរបស់ B បានបាក់ជាបន្តបន្ទាប់ ដែលអាចធ្វើឲ្យដីបាក់នោះគ្របលុបលើផ្ទះរបស់ A ។ ក្នុងករណីបែបនេះ តើ A អាចទាមទារទៅ B យ៉ាងដូចម្ដេចដែរ ?

## ១ ប្រភេទនៃសិទ្ធិប្រត្យក្ស

សិទ្ធិប្រត្យក្ស គឺមានន័យថាជាសិទ្ធិគ្រប់គ្រងលើវត្ថុដោយចំពោះ ដែលផ្ទុយពីសិទ្ធិលើបំណុលដែលជាសិទ្ធិដែលអាចអះអាងសកម្មភាពចំពោះបុគ្គល។ ដូច្នេះ ប្រសិនបើប្រៀបធៀបជាមួយសិទ្ធិលើបំណុល គឺសិទ្ធិប្រត្យក្សមានភាពដាច់ខាតដែលអាចអះអាងចំពោះគ្រប់បុគ្គលដទៃបាន និង ជាសិទ្ធិដែលមានអានុភាពខ្លាំងជាងសិទ្ធិលើបំណុល (សូមមើលជំពូកទី ៣) ។

### ក) កម្មសិទ្ធិ និង សិទ្ធិប្រត្យក្សផ្សេងទៀត

ដោយសារសិទ្ធិប្រត្យក្សមានភាពដាច់ខាតបែបនេះ ទើបវាជះឥទ្ធិពលខ្លាំងទៅបុគ្គលដទៃ ដូច្នេះហើយទើបគូភាគីមិនអាចបង្កើតសិទ្ធិប្រត្យក្សបានតាមការព្រមព្រៀងតាមទំនើងចិត្តនោះទេ ក៏ប៉ុន្តែសិទ្ធិប្រត្យក្សអាចត្រូវបានបង្កើតតាមក្រមរដ្ឋប្បវេណី និង តាមច្បាប់ផ្សេងទៀត។ សិទ្ធិប្រត្យក្សដែលចែងនៅក្នុងក្រមរដ្ឋប្បវេណីគឺដូចគូសបង្ហាញជូនក្នុងតារាងពន្យល់ (សិទ្ធិប្រត្យក្សដែលត្រូវបានកំណត់ដោយច្បាប់ផ្សេង ជាមូលដ្ឋាន គឺរួមបញ្ចូលទៅក្នុងប្រភេទនៃសិទ្ធិប្រត្យក្សដែលមានក្នុងក្រមរដ្ឋប្បវេណីដែរ )។

កម្មសិទ្ធិដែលជាប្រភេទមួយក្នុងសិទ្ធិប្រត្យក្សដែរនោះ ក៏ត្រូវបានគិតថាជាសិទ្ធិពេញលេញផ្ដាច់មុខ។ ដោយហេតុនោះ ភាពពេញលេញផ្ដាច់មុខនៃសិទ្ធិប្រត្យក្សផ្សេងទៀតក្រៅពីកម្មសិទ្ធិ លើកលែងតែសិទ្ធិកាន់កាប់ចេញ គឺត្រូវបានកម្រិត (សិទ្ធិប្រត្យក្សដែលត្រូវបានកម្រិត)។ មានន័យថា ខ្លឹមសារនៃកម្មសិទ្ធិគឺសំដៅលើការប្រើប្រាស់ អាស្រ័យផល និង ចាត់ចែងដោយសេរីនូវវត្ថុដែលជាកម្មវត្ថុ (មាត្រា ២០៦ នៃក្រមរដ្ឋប្បវេណី)។ ដោយឡែកខ្លឹមសារនៃសិទ្ធិប្រត្យក្សដទៃផ្សេងទៀតក្រៅពីកម្មសិទ្ធិ និង សិទ្ធិកាន់កាប់ មានត្រឹមតែផ្នែកមួយនៃសិទ្ធិដែលជាខ្លឹមសារនៃកម្មសិទ្ធិ និង សិទ្ធិកាន់កាប់តែប៉ុណ្ណោះ។ ជាឧទាហរណ៍ សិទ្ធិលើផ្ទៃដី ឬ សិទ្ធិបង្កបង្កើនផលជាអចិន្ត្រៃយ៍ មានខ្លឹមសារជាសិទ្ធិប្រើប្រាស់ និង អាស្រ័យផលពីដីនោះ ក៏ប៉ុន្តែ ម្ចាស់នៃសិទ្ធិទាំងនោះមិនមានសិទ្ធិអំណាចចាត់ចែងបានទេ។ សិទ្ធិចាត់ចែងគឺបម្រុងទុកសម្រាប់តែកម្មសិទ្ធិតែប៉ុណ្ណោះ។ ក៏ប៉ុន្តែ ការដែលម្ចាស់សិទ្ធិលើផ្ទៃដី ឬ ម្ចាស់សិទ្ធិបង្កបង្កើនផលអចិន្ត្រៃយ៍មានសិទ្ធិប្រើប្រាស់ និង អាស្រ័យផលបាន គឺមានន័យថា សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យផលរបស់ម្ចាស់កម្មសិទ្ធិនឹងត្រូវបានកម្រិត ។

## ខ) ការកាន់កាប់

ការកាន់កាប់គឺសំដៅលើស្ថានភាពនៃការគ្រប់គ្រងវត្ថុដោយជាក់ស្តែង (ជាធម្មតាគឺជាស្ថានភាពនៃការរក្សាទុកវត្ថុ ក៏ប៉ុន្តែ ការកាន់កាប់មានន័យទូលាយជាងនេះ) ក៏ប៉ុន្តែ ក្រមរដ្ឋប្បវេណីផ្តល់ការការពារជាកំណត់មួយចំពោះការកាន់កាប់ក្នុងឋានៈជាសិទ្ធិកាន់កាប់។ បានសេចក្តីថា ជាធម្មតា ម្ចាស់កម្មសិទ្ធិធ្វើការកាន់កាប់វត្ថុដែលជាកម្មវត្ថុ ក៏ប៉ុន្តែ ម្ចាស់សិទ្ធិប្រត្យក្សដទៃផ្សេងទៀតក្រៅពីម្ចាស់កម្មសិទ្ធិ (ឧទាហរណ៍ដូចជាម្ចាស់សិទ្ធិលើផ្ទៃដី ម្ចាស់សិទ្ធិបង្កបង្កើនផលជាអចិន្ត្រៃយ៍ ម្ចាស់សិទ្ធិឃាត់ទុក ម្ចាស់សិទ្ធិលើការបញ្ចាំ) ក៏កាន់កាប់វត្ថុដែលជាកម្មវត្ថុដែរ ។

**តារាងពន្យល់ ៨-១ ប្រភេទនៃសិទ្ធិប្រត្យក្ស**



ក្នុងករណីមួយចំនួនធំ សាមីខ្លួនដែលជាអ្នកកាន់កាប់ ធ្វើការរក្សាទុកដោយការក្តាប់ទុកវត្ថុដោយផ្ទាល់ ក៏ប៉ុន្តែ វាក៏មាននូវករណីដែលសាមីខ្លួនធ្វើការកាន់កាប់តាមរយៈការដែលអ្នកក្រោមបង្គាប់ (ឧទាហរណ៍ដូចជា និយោជិត) ធ្វើការក្តាប់ទុកវត្ថុដោយផ្ទាល់ដែរ (បុគ្គលដែលមានទំនាក់ទំនងក្រោមបង្គាប់ត្រូវបានហៅថា អ្នកជំនួយក្នុងការកាន់កាប់) ។

ម្យ៉ាងវិញទៀត បើទោះបីអ្នកកាន់កាប់ខ្លួនគាត់ផ្ទាល់មិនបានធ្វើការរក្សាទុកនូវវត្ថុក៏ដោយ ការកាន់កាប់ក៏កើតមានឡើងតាមរយៈការឲ្យអ្នកដទៃរក្សាទុកនូវវត្ថុបានដែរ (មាត្រា ១៨១ នៃក្រមរដ្ឋប្បវេណី)។ ជាឧទាហរណ៍ អ្នកជូលវត្ថុទៅឲ្យអ្នកដទៃ (ភតិបតី ពោលគឺកម្មសិទ្ធិករ) ធ្វើការកាន់កាប់វត្ថុតាមរយៈការដែលភតិកៈ ធ្វើការរក្សាទុកនូវវត្ថុនោះ។ តាមក្រមរដ្ឋប្បវេណី ករណីបែបនេះហៅថា ការកាន់កាប់ដោយការតំណាង ។

## គ) សិទ្ធិប្រត្យក្សប្រើប្រាស់ និង អាស្រ័យផល និង សិទ្ធិប្រាតិភោគប្រត្យក្ស

សិទ្ធិប្រត្យក្សដែលត្រូវបានកម្រិតផ្សេងទៀតត្រូវបានបែងចែកជាពីរប្រភេទធំៗ គឺសិទ្ធិប្រត្យក្សប្រើប្រាស់ និង អាស្រ័យផល និង សិទ្ធិប្រាតិភោគប្រត្យក្ស។ សិទ្ធិប្រត្យក្សប្រើប្រាស់ និង អាស្រ័យផល គឺសំដៅទៅលើការប្រើប្រាស់ និង ទទួលយកផលពីវត្ថុរបស់អ្នកដទៃ។ ឲ្យកាន់តែជាក់លាក់ គឺមានសិទ្ធិ ៥ នៅក្នុងនោះដូចជា សិទ្ធិលើផ្ទៃដីដែលសំដៅទៅលើការមានកម្មសិទ្ធិទៅលើដើមឫស្សី ឬ ដើមឈើ ឬ ការផ្សេងៗដែលដុះ ឬ សង់លើដីអ្នកដទៃ សិទ្ធិបង្កបង្កើនផលជាអចិន្ត្រៃយ៍ដែលជាសិទ្ធិប្រើប្រាស់ដីអ្នកដទៃសម្រាប់ការដាំដុះ និង ចិញ្ចឹមសត្វ សិទ្ធិសេវភាពដែលជាសិទ្ធិប្រើប្រាស់ដីអ្នកដទៃដើម្បីផលប្រយោជន៍ដីរបស់ខ្លួនឯង និង សិទ្ធិជាសមាជិកដែលអនុញ្ញាតឲ្យមានការប្រើប្រាស់ដីដែលជាកម្មសិទ្ធិរួម ឬ ដីរបស់អ្នកដទៃ ។

សិទ្ធិប្រាតិភោគប្រត្យក្សសំដៅទៅលើសិទ្ធិក្តោបទុកនូវតម្លៃនៃវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុល ឬ របស់តតិយជនដែលបានដាក់ជាប្រាតិភោគដើម្បីធានាបំណុល។ ឬនិយាយម្យ៉ាងទៀតថា ក្នុងករណីដែលកាតព្វកិច្ចមិនត្រូវបានអនុវត្តទេ (ឧទាហរណ៍គំរូ គឺដូចជាក្នុងករណីដែលអ្នកខ្ចីប្រាក់មិនសងប្រាក់ដែលបានខ្ចី ជាដើម) គេអាចលក់វត្ថុដែលត្រូវបានដាក់ជាប្រាតិភោគនោះ ហើយម្ចាស់សិទ្ធិប្រាតិភោគអាចទទួលបានមុនគេនូវការសងបំណុលពីប្រាក់ដែលបានលក់វត្ថុដែលជាប្រាតិភោគនោះ ដោយផ្អែកទៅតាមនីតិវិធីដែលបានកំណត់ដោយច្បាប់។ បើនិយាយឲ្យជាក់លាក់ទៅ សិទ្ធិប្រាតិភោគប្រត្យក្សគឺក្តោបរួមនូវសិទ្ធិ៥ដែលក្នុងនោះ មានដូចជា សិទ្ធិឃាត់ទុកដែលសំដៅទៅលើសិទ្ធិដែលអាចឃាត់ទុកនូវវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុលរហូតទាល់តែកូនបំណុលសងបំណុលរួចសិន ឯកសិទ្ធិដែលមានន័យថាម្ចាស់បំណុលនៃបំណុលជាកំណត់ណាមួយ អាចទទួលបាននូវការសងបំណុលពី

ទ្រព្យទូទៅ (មានន័យថាទ្រព្យសរុប) ឬ វត្ថុជាកំណត់ណាមួយរបស់កូនបំណុល ដោយមានអាទិភាពជាងម្ចាស់បំណុលដទៃទៀត ម្យ៉ាងវិញទៀតគឺហ៊ីប៉ូតែកដែលសំដៅទៅលើការដែលម្ចាស់បំណុលអាចទទួលបាការសងបំណុលដោយមានអាទិភាពពីអចលនវត្ថុដែលកូនបំណុល ឬ តតិយជនបានប្រគល់ដើម្បីធានាបំណុល និង សិទ្ធិលើការបញ្ចាំដែលម្ចាស់បំណុលអាចឃាត់ទុកនូវវត្ថុដែលត្រូវបានដាក់បញ្ចាំដោយកូនបំណុល ឬ ដោយតតិយជនដើម្បីធានាបំណុល រហូតដល់ពេលទទួលបានការសងបំណុល និង ទទួលបាននូវការសងបំណុលពីវត្ថុនោះដោយមានអាទិភាព (សិទ្ធិប្រាតិភោគប្រត្យក្សមានពិភាក្សាលម្អិតក្នុងជំពូកទី ១១) ។

## ២ កម្មសិទ្ធិ: ចលនវត្ថុ និង អចលនវត្ថុ

ដូចបានលើកឡើងពីខាងដើម ក្នុងចំណោមសិទ្ធិប្រត្យក្សទាំងអស់ កម្មសិទ្ធិត្រូវបានយល់ឃើញថាមានភាពពេញលេញ។ ហើយជាប្រវត្តិសាស្ត្រ នៅក្នុងចំណោមកម្មសិទ្ធិត្រូវបានគិតថា កម្មសិទ្ធិលើអចលនវត្ថុមានភាពសំខាន់ខ្លាំងជាងកម្មសិទ្ធិលើចលនវត្ថុ។ ដូចសុភាសិតច្បាប់បស្ចិមប្រទេសចែងថា "res mobilis res vilis" (ចលនវត្ថុគឺជាវត្ថុអាក្រក់) នេះគឺបានរំលេចចេញនូវទស្សនៈនៃតម្លៃបែបនេះ ។ ក្នុងក្រមរដ្ឋប្បវេណី ក៏មានបញ្ញត្តិមិនតិចដែរដែលចាត់ចែងដោយធ្វើការបែងចែកផ្សេងគ្នារវាងចលនវត្ថុ និង អចលនវត្ថុ។

### ក) វត្ថុ

នៅក្នុងក្រមរដ្ឋប្បវេណី ជាបឋម វត្ថុគឺសំដៅទៅវត្ថុដែលមានរូបរាង (មាត្រា ៨៥ នៃក្រមរដ្ឋប្បវេណី)។ អត្ថន័យនៃវត្ថុដែលមានរូបរាងគឺមានដូចជាសារធាតុរឹង ឧស្ម័ន និង សារធាតុរាវ។ ដូច្នេះយើងអាចនិយាយបានថា នៅក្នុងជីវភាពប្រចាំថ្ងៃរបស់យើង វត្ថុដែលមានតម្លៃជាទ្រព្យត្រូវបានរាប់បញ្ចូលទៅក្នុងអត្ថន័យនេះស្ទើរតែទាំងអស់។ ក៏ប៉ុន្តែ ចំពោះថាមពលចរន្តអគ្គិសនី និង ថាមពលកំដៅវិញ វាមានតម្លៃសេដ្ឋកិច្ចក៏ពិតមែន ក៏ប៉ុន្តែ មិនរាប់បញ្ចូលទៅក្នុងអត្ថន័យនេះទេ។ នៅក្នុងទ្រឹស្តីសិក្សាវិញ យើងឃើញមានចលនាចង់រាប់បញ្ចូលថាមពលបែបនេះទៅក្នុងអត្ថន័យនៃវត្ថុ ។

នៅក្នុងច្បាប់ព្រហ្មទណ្ឌដែលកំណត់យកគោលការណ៍នៃការកំណត់ជាមុនដោយច្បាប់នូវបទល្មើសព្រហ្មទណ្ឌ ចាំបាច់ត្រូវកំណត់ជាមុននូវបទល្មើស និង ទោសទណ្ឌចំពោះបទល្មើសនោះ ដូច្នេះវាមានភាពចាំបាច់ដែលឲ្យនិយមន័យតឹងរ៉ឹងចំពោះវត្ថុ ក្នុងករណីបទល្មើសដូចជាការលួច ជាដើម (បើតាមមាត្រា ២៨៥ នៃក្រមព្រហ្មទណ្ឌ គេចាត់ទុកអគ្គិសនីជាទ្រព្យសម្បត្តិ) ក៏ប៉ុន្តែ ចំពោះក្រមរដ្ឋប្បវេណីវិញ មិនចាំបាច់បកស្រាយតឹងរ៉ឹងដូច្នេះទេ។ ក្នុងករណីកើតមាននូវបញ្ហាដែលពាក់ព័ន្ធ

ទៅនឹងអត្តិសនី ឬ កំដៅបែបដូច្នោះ គេគ្រាន់តែពិចារណាថាតើត្រូវចាត់ទុកចែងរបស់ទាំងនោះដូចគ្នាទៅនឹងវត្ថុដែរ ឬ យ៉ាងណា គឺជាការគ្រប់គ្រាន់ ។

### ខ) ចលនវត្ថុ និង អចលនវត្ថុ

ជាបន្ត វត្ថុត្រូវបានបែងចែកជាចលនវត្ថុ និង អចលនវត្ថុ (មាត្រា ៨៦ នៃក្រមរដ្ឋប្បវេណី)។ អចលនវត្ថុ សំដៅទៅលើដី និង វត្ថុនៅជាប់នឹងដី រីឯចលនវត្ថុវិញគឺសំដៅលើវត្ថុក្រៅពីអចលនវត្ថុ។ វត្ថុដែលជាប់នឹងដីត្រូវបានបកស្រាយក្នុងទស្សនៈទូលាយថាជាវត្ថុដែលភ្ជាប់ទៅនឹងដីតាមទម្រង់ធម្មជាតិ។ ឲ្យកាន់តែជាក់លាក់គឺមានអគារ ឬ ការ ឬ ដើមឈើដែលស្ថិតនៅលើដី ត្រូវបានរាប់បញ្ចូលទៅក្នុងអត្ថន័យនៃវត្ថុដែលជាប់នឹងដី។ ក្នុងក្រមរដ្ឋប្បវេណីបារាំងដែលបានជះឥទ្ធិពលទៅលើក្រមរដ្ឋប្បវេណីជប៉ុន ឧបករណ៍សម្រាប់ធ្វើការដាំដុះ (នង្គ័ល ឬ ចបកាប់ ជាដើម) និង សត្វចិញ្ចឹម (គោ ជ្រូក ចៀម មាន់ ជាដើម) ដែលជាចលនវត្ថុពីកំណើត ត្រូវបានកំណត់ថាជាអចលនវត្ថុ ដូច្នេះ បើយកទស្សនាទានពីអចលនវត្ថុនៃក្រមរដ្ឋប្បវេណីជប៉ុនទៅប្រៀបធៀបនឹងទស្សនាទានបែបនេះ ទស្សនាទានពីអចលនវត្ថុរបស់ក្រមជប៉ុនគឺមានភាពសាមញ្ញខ្លាំងណាស់ ។

ដោយឡែក នៅក្នុងក្រមរដ្ឋប្បវេណីជប៉ុនចាត់ទុកដី និង អគារជាអចលនវត្ថុដាច់ដោយឡែកពីគ្នា ហើយត្រូវក្លាយជាកម្មវត្ថុនៃសិទ្ធិឯករាជ្យដាច់ពីគ្នា។ ឧទាហរណ៍ ការដែលកម្មសិទ្ធិករនៃដី និង កម្មសិទ្ធិករនៃអគារជាមនុស្សផ្សេងគ្នា គឺមានមិនតិចទេ (នៅក្នុងជីវភាពជាក់ស្តែង អ្នកដែលជួលដីពីគេ ហើយសង់អគារដើម្បីរស់នៅលើដីនោះ គឺមានច្រើន)។ ច្បាប់នៃបណ្តាប្រទេសជាច្រើនធ្វើការចាត់ចែងដី និង អគារដូចគ្នា ហើយករណីដែលកម្មសិទ្ធិករនៃដីធ្លីជាបុគ្គលផ្សេងគ្នាពីកម្មសិទ្ធិករនៃអគារ (ឧទាហរណ៍ ដូចជារបបជួលដីធ្លី) គឺមិនសូវមានទេ។ ការចាត់ចែងចំពោះដី និង អគារដូចករណីប្រទេសជប៉ុននេះ គឺជាការអនុវត្តដោយផ្អែកលើទំនៀមទម្លាប់របស់ជប៉ុន ក៏ប៉ុន្តែ ដោយសារតែកម្មសិទ្ធិករនៃអគារខុសពីកម្មសិទ្ធិករនៃដី បញ្ហាស្មុគស្មាញដែលបណ្តាប្រទេសជាច្រើនមិនធ្លាប់ឃើញ ក៏កើតមានឡើងមិនតិចដែរទេ។

## ៣ លទ្ធកម្មនៃកម្មសិទ្ធិ

### ក) លទ្ធកម្មដោយកិច្ចសន្យា និង លទ្ធកម្មដោយសន្តតិកម្ម

មានករណីច្រើនដែលបុគ្គលម្នាក់អាចធ្វើលទ្ធកម្មកម្មសិទ្ធិលើវត្ថុមួយបាន។ ប៉ុន្តែ វិធីដែលសាមញ្ញ និងកើតមានជាញឹកញាប់បំផុតនោះគឺលទ្ធកម្មកម្មសិទ្ធិដោយកិច្ចសន្យាលក់ទិញ ឬ កិច្ចសន្យាប្រទានកម្ម ជាដើម។ ឧទាហរណ៍ ដូចជាការធ្វើលទ្ធកម្មកម្មសិទ្ធិលើវត្ថុតាមរយៈកិច្ចសន្យា នៅពេលយើងទិញវត្ថុពីហាងទំនិញនៅទីផ្សារនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់យើង។ ម្យ៉ាងទៀត ការដែល

យើងទទួលអំណោយផ្សេងៗពីក្រុមគ្រួសារ ឬ មិត្តភក្តិ នៅថ្ងៃខួបកំណើត គឺជាការដែលយើងធ្វើលទ្ធកម្មកម្មសិទ្ធិលើវត្ថុទាំងនោះតាមរយៈកិច្ចសន្យាប្រទានកម្ម ។

ជាបន្ត យើងអាចគិតឃើញពីការធ្វើលទ្ធកម្មកម្មសិទ្ធិដោយសន្តតិកម្ម។ ឧទាហរណ៍ ការដែលឪពុកទទួលមរណភាព ហើយកូនត្រូវធ្វើសន្តតិកម្ម គឺជាការដែលកូននោះធ្វើលទ្ធកម្មកម្មសិទ្ធិលើទ្រព្យសម្បត្តិរបស់ឪពុក តាមរយៈសន្តតិកម្ម ។

### ខ) លទ្ធកម្មដោយវិធីផ្សេងទៀត

លទ្ធកម្មកម្មសិទ្ធិតាមវិធីដែលបានរៀបរាប់ទាំងនេះ គឺជាលទ្ធកម្មដែលអាចឃើញមានជាញឹកញាប់បំផុតនៅក្នុងជីវភាពប្រចាំថ្ងៃរបស់យើង ក៏ប៉ុន្តែ លទ្ធកម្មកម្មសិទ្ធិមិនមែនកម្រិតត្រឹមតែកិច្ចសន្យា និងសន្តតិកម្មប៉ុណ្ណោះទេ។ ក្រៅពីវិធីទាំងនេះ ក្រមរដ្ឋប្បវេណីបានបញ្ញត្តពីមូលហេតុមួយចំនួនដែលជាវិធីផ្សេងទៀតនៃលទ្ធកម្មកម្មសិទ្ធិ។ ជាឧទាហរណ៍ មានដូចជាអាជ្ញាយុកាលនៃលទ្ធកម្ម។ អាជ្ញាយុកាលនៃលទ្ធកម្មមានន័យថា នៅពេលដែលបុគ្គលដែលមិនមែនជាម្ចាស់កម្មសិទ្ធិ បានកាន់កាប់វត្ថុមួយក្នុងអំឡុងពេលជាកំណត់មួយដូចជាកម្មសិទ្ធិករ បុគ្គលនោះអាចធ្វើលទ្ធកម្មកម្មសិទ្ធិលើវត្ថុនោះបាន (មាត្រា ១៦២ នៃក្រមរដ្ឋប្បវេណី។ សូមមើលជំពូកទី ៦)។ ម្យ៉ាងវិញទៀត ចំពោះចលនវត្ថុដែលគ្មានម្ចាស់ (ឧទាហរណ៍សត្វព្រៃ) បុគ្គលដែលបានកាន់កាប់ចលនវត្ថុនោះ ដំបូងគេត្រូវធ្វើលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុនោះ (មាត្រា ២៣៩ នៃក្រមរដ្ឋប្បវេណី)។ ម្យ៉ាងវិញទៀត ដោយការអនុវត្តតាមនីតិវិធីជាកំណត់មួយ (នីតិវិធីនោះមានចែងនៅក្នុងច្បាប់ស្តីពីវត្ថុបាត់) អ្នករើសបានវត្ថុបាត់អាចធ្វើលទ្ធកម្មកម្មសិទ្ធិលើវត្ថុនោះបាន (មាត្រា ២៤០ នៃក្រមរដ្ឋប្បវេណី) ។

### គ) ល័ក្ខខ័ណ្ឌតតាំង

បុគ្គលដែលបានធ្វើលទ្ធកម្មកម្មសិទ្ធិលើវត្ថុមួយដោយសន្តតិកម្ម ឬ ដោយអាជ្ញាយុកាល (ជាទូទៅគឺជាបុគ្គលដែលធ្វើលទ្ធកម្មសិទ្ធិប្រត្យក្ស) អាចអះអាងពីកម្មសិទ្ធិនោះចំពោះគ្រប់បុគ្គលដទៃបាន (ភាពដាច់ខាតនៃសិទ្ធិប្រត្យក្ស) ក៏ប៉ុន្តែ ចាំបាច់ត្រូវបំពេញល័ក្ខខ័ណ្ឌជាកំណត់ណាមួយ ។

ការផ្ទេរកម្មសិទ្ធិតាមរយៈកិច្ចសន្យាលក់ទិញ ជាដើម (ជាទូទៅ គឺករណីនៃការបង្កើត ការផ្ទេរ និងការកែប្រែសិទ្ធិប្រត្យក្ស) អាស្រ័យដោយការបង្ហាញឆន្ទៈរវាងគូភាគីដែលមានខ្លឹមសារផ្ទេរកម្មសិទ្ធិ អានុភាពនៃការផ្ទេរកើតមានឡើង (មាត្រា ១៧៦ នៃក្រមរដ្ឋប្បវេណី)។ ឧទាហរណ៍ថា តាមរយៈកិច្ចសន្យាលក់ទិញ ការបង្ហាញឆន្ទៈដែលមានខ្លឹមសារផ្ទេរកម្មសិទ្ធិនោះត្រូវបានគិតថាបានដាក់បញ្ចូលទៅក្នុងកិច្ចសន្យាលក់ទិញធម្មតានោះហើយ ដូច្នេះ វាត្រូវបានបកស្រាយថាទន្ទឹមនឹងពេលដែលកិច្ចសន្យាកើតឡើង កម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុត្រូវផ្ទេរពីអ្នកលក់ទៅអ្នកទិញ។ ក៏ប៉ុន្តែ ដើម្បីឲ្យបុគ្គល

ដែលបានធ្វើលទ្ធកម្មកម្មសិទ្ធិអាចអះអាងកម្មសិទ្ធិនោះចំពោះតតិយជនបាន ការបង្ហាញឆន្ទៈត្រឹមតែរវាងគូភាគីគឺមិនគ្រប់គ្រាន់ទេ ដោយចាំបាច់ត្រូវធ្វើការចុះបញ្ជីចំពោះករណីដែលវត្ថុនោះជាអចលនវត្ថុ ឬ ប្រសិនបើជាចលនវត្ថុវិញ ចាំបាច់ត្រូវធ្វើការប្រគល់ (មាត្រា ១៧៧ និង មាត្រា ១៧៨ នៃក្រមរដ្ឋប្បវេណី)។ ដោយសារតែសិទ្ធិប្រត្យក្សមានភាពដាច់ខាត និង មានឥទ្ធិពលយ៉ាងខ្លាំងទៅលើតតិយជន វាទាមទារឲ្យមានការមើលឃើញពីខាងក្រៅដើម្បីវិនិច្ឆ័យពីការបានបង្កើត ការផ្ទេរ និង ការបានកែប្រែសិទ្ធិប្រត្យក្ស ដោយមិនគ្រាន់តែមានការបង្ហាញឆន្ទៈតែរវាងគូភាគីប៉ុណ្ណោះទេ (ហៅថា វិធីបង្ហាញជាសាធារណៈ)។ អាចនិយាយបានម្យ៉ាងទៀតថា ដើម្បីអះអាង (តតាំង) ពីការបានធ្វើលទ្ធកម្មកម្មសិទ្ធិចំពោះតតិយជន ចាំបាច់ត្រូវតែមានការចុះបញ្ជី ឬ ការប្រគល់ (ហៅថា ល័ក្ខខ័ណ្ឌតតាំង)។ ហេតុដូច្នេះ បើទោះបីជាមានការផ្ទេរកម្មសិទ្ធិរវាងគូភាគីហើយក៏ដោយ នៅមុនពេលដែលបំពេញល័ក្ខខ័ណ្ឌតតាំង គឺមិនអាចតតាំងថា ខ្លួនជាម្ចាស់កម្មសិទ្ធិចំពោះតតិយជនបានទេ (ក៏ប៉ុន្តែតតិយជនវិញអាចធ្វើការទទួលស្គាល់នូវភាពជាម្ចាស់កម្មសិទ្ធិបាន) ។

ក៏ប៉ុន្តែ ការបង្កើតរបៀបផ្ទេរកម្មសិទ្ធិ និង ល័ក្ខខ័ណ្ឌតតាំងបែបនេះ គឺមានប្រភពដើមចេញមកពីច្បាប់បារាំង។ ច្បាប់អាល្លឺម៉ង់ ឬ ច្បាប់ស្វីសមិនទទួលយកនូវទស្សនៈបែបដូច្នោះទេ។ មានន័យថា កម្មសិទ្ធិត្រូវចាត់ទុកថាបានផ្ទេរនៅពេលដែលមានការបង្ហាញឆន្ទៈ និង ការចុះបញ្ជី ឬ ការប្រគល់វត្ថុ។ ក្នុង ករណីអនុវត្តបែបនេះគឺមិនមានគម្លាតខុសគ្នារវាងគូភាគី និង តតិយជនដូចបានរៀបរាប់ពីខាងដើមទេ ។

ក៏ប៉ុន្តែ ចំពោះអនុប្បទានចលនវត្ថុវិញ ក្នុងករណីដែលអនុប្បទាយីជានីតិបុគ្គលវិញ នៅពេលដែលអនុប្បទានត្រូវបានចុះបញ្ជីនៅក្នុងបញ្ជីអនុប្បទានចលនវត្ថុហើយនោះ នឹងត្រូវបានចាត់ទុកថាបានធ្វើការប្រគល់តាមមាត្រា ១៧៨ នៃក្រមរដ្ឋប្បវេណីហើយ (កថាខណ្ឌទី ១ មាត្រា ៣ នៃច្បាប់ស្តីពីបទប្បញ្ញត្តិពិសេស ជាអាទិ៍ លើក្រមរដ្ឋប្បវេណីចំពោះល័ក្ខខ័ណ្ឌតតាំងនៃការផ្ទេចលនវត្ថុ និង អនុប្បទានសិទ្ធិលើបំណុល)។ មានន័យថា ចំពោះចលនវត្ថុក៏ដោយ នៅក្នុងករណីជាកំណត់ណាមួយ ការចុះបញ្ជីក៏ត្រូវបានទទួលស្គាល់ថាជាល័ក្ខខ័ណ្ឌតតាំងដែរ ។

## ៤ សិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្ស

### ក) អត្ថន័យនៃសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្ស

ដូចដែលបានលើកឡើងពីដំបូង សិទ្ធិប្រត្យក្សមានភាពដាច់ខាត ហើយនៅពេលដែលមានករណីដែលការប្រើប្រាស់សិទ្ធិនោះត្រូវបានរារាំង (ឧទាហរណ៍ដូចជា ប្រសិនបើមានសិទ្ធិកម្មសិទ្ធិ គឺអាចអនុវត្តសិទ្ធិប្រើប្រាស់ និង អាស្រ័យផលបាន) ម្ចាស់សិទ្ធិប្រត្យក្សអាចទាមទារបញ្ឈប់ការរារាំងនោះ

បាន។ សិទ្ធិប្រភេទនោះត្រូវបានហៅថាសិទ្ធិទាមទារឲ្យបញ្ឈប់ការរារាំង។ សិទ្ធិនេះគឺជាសិទ្ធិដែលមានភ្ជាប់ជាមួយសិទ្ធិប្រត្យក្ស ហើយអ្នកដែលមានសិទ្ធិប្រត្យក្ស ជាធម្មតា អាចអនុវត្តនូវសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្សនោះបាន។ ចំពោះការកាន់កាប់ ក្រមរដ្ឋប្បវេណីមានចែងអំពីសិទ្ធិធ្វើបណ្តឹងដោយផ្អែកលើសិទ្ធិកាន់កាប់ ៣ ប្រភេទ (មាត្រា ១៩៨ ដល់មាត្រា ២០០ នៃក្រមរដ្ឋប្បវេណី) ក៏ប៉ុន្តែ មិនមាននូវបញ្ញត្តិស្តីពីសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្សដែលអនុវត្តដូចគ្នាចំពោះគ្រប់សិទ្ធិប្រត្យក្សទាំងអស់នោះទេ។ ក៏ប៉ុន្តែ ការដែលសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្សត្រូវបានទទួលស្គាល់ គឺត្រូវបានចាត់ទុកថាជាករណីធម្មតា។ ក្នុងករណីដែលមានស្ថានភាពជាក់ស្តែងថាការអនុវត្តសិទ្ធិប្រត្យក្សត្រូវបានរារាំង ម្ចាស់សិទ្ធិប្រត្យក្សអាចអនុវត្តនូវសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្ស ដោយមិនចាំបាច់គិតដល់បញ្ហាថា ជនដែលបង្កការរារាំងនោះមានចេតនា ឬកំហុសទេ។ម្យ៉ាងវិញទៀត អ្នកដែលក្លាយទៅជាភាគីម្ខាងទៀតនៃការអនុវត្ត ត្រូវបានគេយល់ថាជាអ្នកដែលរារាំងការអនុវត្តសិទ្ធិប្រត្យក្សជាក់ស្តែង ហើយមិនចាំបាច់គិតពិចារណាទៅដល់ស្ថានភាពដែលបុគ្គលនោះបង្កើតឡើងដើម្បីធ្វើការរារាំងនោះទេ។ និយាយឲ្យកាន់តែជាក់លាក់ទៅ សិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្សមាន ៣ គឺសិទ្ធិទាមទារឲ្យប្រគល់វិញ សិទ្ធិទាមទារឲ្យបញ្ឈប់ និង បង្ការការរារាំង ។

### ខ) សិទ្ធិទាមទារឲ្យប្រគល់វិញ សិទ្ធិទាមទារឲ្យបញ្ឈប់ និង បង្ការការរារាំង

សិទ្ធិទាមទារឲ្យប្រគល់វិញមានន័យថា សិទ្ធិដែលអាចទាមទារទៅបុគ្គលដែលបានដណ្តើមយកឲ្យប្រគល់មកវិញនូវសិទ្ធិប្រត្យក្សក្នុងករណីដែលសិទ្ធិប្រត្យក្សត្រូវបានដណ្តើមយកទៅដោយបុគ្គលដទៃ។ ជាឧទាហរណ៍ ម្ចាស់កម្មសិទ្ធិលើវត្ថុដែលត្រូវបានលួចយកទៅបាត់ អាចទាមទារទៅបុគ្គលដែលកាន់កាប់វត្ថុនោះ (មិនថាតែបុគ្គលដែលជាអ្នកលួច ឬ បុគ្គលណាទេ) ឲ្យប្រគល់វត្ថុត្រឡប់មកវិញបាន ។

សិទ្ធិទាមទារឲ្យបញ្ឈប់ការរារាំងមានន័យថា សិទ្ធិដែលអាចទាមទារទៅបុគ្គលដែលកំពុងបង្កការរារាំងឲ្យលុបចោលនូវការរារាំងក្នុងករណីដែលការអនុវត្តសិទ្ធិប្រត្យក្សត្រូវបានរារាំងដោយបុគ្គលដទៃ។ ឧទាហរណ៍ ក្នុងករណីដែលដើមឈើរបស់ដីជិតខាងដុះលយចូលក្នុងដីដែលជាកម្មសិទ្ធិរបស់ខ្លួន និងរារាំងដល់ការប្រើប្រាស់ដីដែលជាកម្មសិទ្ធិរបស់ខ្លួន កម្មសិទ្ធិករអាចទាមទារទៅកម្មសិទ្ធិករនៃដីជិតខាងនោះឲ្យកាប់ចោលដើមឈើនោះបាន ។

សិទ្ធិទាមទារឲ្យបង្ការការរារាំង មានន័យថា សិទ្ធិទាមទារឲ្យបង្ការកុំឲ្យការរារាំងកើតឡើង ក្នុងករណីដែលបច្ចុប្បន្នការអនុវត្តសិទ្ធិប្រត្យក្សមិនទាន់ត្រូវបានរារាំងទេ ក៏ប៉ុន្តែអាចនឹងមានហានិភ័យបង្កការរារាំង។ ឧទាហរណ៍ដូចជាក្នុងករណីសិក្សាដែលបានលើកឡើង ជាដើម។ ក្នុងករណីបែបនោះ A អាចទាមទារទៅ B ឲ្យចាត់នូវវិធានការការពារជាមុនកុំឲ្យដីនោះបាក់ធ្លាក់បាន ។

✎ សិទ្ធិទាមទារឲ្យបង្អាក្សការរារាំង និង ការទទួលបន្ទុកសោហ៊ុយ--ការពិចារណាតាមរយៈករណីសិក្សា

ករណីសិក្សាខាងលើ គឺជាឧទាហរណ៍គំរូចំពោះសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្ស។ ក្នុងករណីនេះ ការអនុវត្តសិទ្ធិកម្មសិទ្ធិលើដីរបស់ A (ការប្រើប្រាស់ដីដែលនៅក្រោមផ្ទះគាត់ ជាដើម) អាចត្រូវបានរារាំងដោយសារហានិភ័យដែលកើតឡើងពីការបាក់ដីរបស់ B ។ មានន័យថា នាពេលបច្ចុប្បន្នការអនុវត្តសិទ្ធិកម្មសិទ្ធិមិនត្រូវបានរារាំងទេ ក៏ប៉ុន្តែ នាពេលអនាគត ហានិភ័យពីការដែលត្រូវបានរារាំងនោះអាចនឹងកើតឡើង។ ដូច្នេះ A អាចអនុវត្តសិទ្ធិទាមទារឲ្យបង្អាក្សការរារាំង ដោយផ្អែកលើកម្មសិទ្ធិ ហើយអាចទាមទារទៅ B ដែលជាកម្មសិទ្ធិករនៃដីដែលអាចបង្កហានិភ័យនោះ ឲ្យសាងសង់កាព្យដើម្បីការពារកុំឲ្យដីរបស់ B បាក់ធ្លាក់។ ក្នុងករណីនេះ ចំពោះហានិភ័យនៃការបាក់ដីដែលកើតឡើង មិនចាំបាច់ត្រូវពាក់ព័ន្ធជាមួយនឹងចេតនា ឬ កំហុសរបស់ B ទេ (ពាក្យថា ចេតនា ឬ កំហុស ត្រូវបានប្រើប្រាស់នៅគ្រប់ទីកន្លែង ដោយមិនប្រាកដថាមានន័យជាក់លាក់ដូចគ្នាទាំងអស់នោះទេ ក៏ប៉ុន្តែពាក្យចេតនា ឬ កំហុសនៅត្រង់នេះ អាចគិតបានថាមានន័យដូចគ្នាជាមួយនឹងចេតនា ឬ កំហុសនៅក្នុងអំពើអនីត្យានុកូល ក៏បានដែរ។ ខ្លឹមសារលម្អិត សូមអានជំពូកទី ៩)។ នៅពេលដែលមានមូលហេតុនៃការរារាំងកើតឡើង ត្រូវមានការទទួលខុសត្រូវជាសត្យានុម័ត ដោយសារតែការដែលមានកម្មសិទ្ធិលើដីនោះ ។

ដោយឡែកអ្វីដែលជាបញ្ហានោះគឺថាតើអ្នកណាត្រូវទទួលបន្ទុកចំពោះសោហ៊ុយសាងសង់កាព្យទប់ល្បាក់ដីនោះ។ ជាប្រពៃណី ភាគីម្ខាងទៀតនៃសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្ស ត្រូវបានគិតថាជាអ្នកត្រូវទទួលបន្ទុកលើសោហ៊ុយសម្រាប់សាងសង់កាព្យនោះ។ ចំពោះករណីសិក្សា B ត្រូវទទួលបន្ទុកចំពោះសោហ៊ុយសាងសង់កាព្យសម្រាប់ការពារល្បាក់ដី។ ក៏ប៉ុន្តែ ដោយសារតែចេតនា ឬ កំហុសនៃការរារាំងការអនុវត្តសិទ្ធិប្រត្យក្សមិនមែនជាកត្តាចាំបាច់ បញ្ហាថាតើការដាក់បន្ទុកឲ្យបុគ្គលដែលគ្មានកំហុសត្រូវទទួលបន្ទុកសោហ៊ុយនោះមានយុត្តិធម៌ដែរ ឬទេ ត្រូវបានលើកឡើង ហើយទំនាក់ទំនងស្តីពីការអនុវត្តសិទ្ធិប្រត្យក្ស និង បន្ទុកនៃសោហ៊ុយបានក្លាយទៅជាកម្មវត្ថុនៃការពិភាក្សាដេញដោលគ្នា។ ឧទាហរណ៍ មានទស្សនៈថា បុគ្គលដែលអនុវត្តនូវសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្សត្រូវទទួលបន្ទុកសោហ៊ុយ (ទស្សនៈបែបនេះហៅថា ទ្រឹស្តីសិទ្ធិទាមទារឲ្យទទួលស្គាល់ដែលខុសពីទស្សនៈជាប្រពៃណីដែលហៅថា ទ្រឹស្តីសិទ្ធិទាមទារឲ្យធ្វើសកម្មភាព) និង ទស្សនៈដែលថា គួរធ្វើការបែងចែករវាងការអនុវត្តសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្ស ជាមួយបន្ទុកនៃសោហ៊ុយ (ឧទាហរណ៍ត្រូវធ្វើការកំណត់ ជាដើម ថាតើភាគីម្ខាងទៀតនៃការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូល និង ការទទួលខុសត្រូវក្នុងកិច្ចសន្យាត្រូវទទួលបន្ទុកសោហ៊ុយដែរ ឬទេ) ជាដើម ដូច្នេះ ក្នុងទ្រឹស្តីសិក្សាក៏មិនកំណត់ថាមានការឯកភាពគ្នាដែរ ។

ក៏ប៉ុន្តែ ក្នុងករណីដែលកម្រិតខ្ពស់ទាបនៃទំនាក់ទំនងរវាងដីរបស់ A និង ដី របស់ B ត្រូវបានធ្វើឲ្យ

កើតមានឡើងដោយសារតែការចាក់បន្ថែមតាមរបៀបសិប្បនិម្មិតរបស់កម្មសិទ្ធិករនៃដីរបស់ A (រាប់បញ្ចូលទាំងអ្នកដែលជាម្ចាស់កម្មសិទ្ធិមុន A ផង) យុត្តិសាស្ត្រ គឺផ្ទុយពីអ្វីដែលបានលើកឡើងក្នុងករណីសិក្សា ដោយសោហ៊ុយនោះត្រូវបានបកស្រាយថាគួរតែជាបន្ទុករបស់ A (សាលដីការបស់តុលាការកំពូលជប៉ុនចាស់ ចុះថ្ងៃទី៩ ខែ វិច្ឆិកា ឆ្នាំ១៩៣២ ក្នុងកម្រងសាលក្រម ឬ សាលដីការឿងក្តីរដ្ឋប្បវេណីលេខ ១១ ទំព័រទី ២២៧៧)។ ដោយការជីកដីរបស់ A ដើម្បីធ្វើជ្រលង អាចបង្កហានិភ័យដោយធ្វើឲ្យដីរបស់ B បាក់លើដីរបស់ A ពោលគឺដោយសារថា ការអនុវត្តសិទ្ធិកម្មសិទ្ធិលើដីរបស់ B ត្រូវបានរាំងដោយសារហានិភ័យដែលបានកើតឡើង ដូច្នេះ B អាចប្រើប្រាស់សិទ្ធិទាមទារទៅ A ឲ្យបង្ការការរាំងបាន ។

# ជំពូកទី ៩

# អំពើអនីត្យានុកូល

## ១ អំពើអនីត្យានុកូល

(១) អត្ថន័យនៃអំពើអនីត្យានុកូល

(២) មុខងាររបស់ច្បាប់ស្តីពីអំពើអនីត្យានុកូល

(៣) អំពើអនីត្យានុកូល និង ការធានារ៉ាប់រង

(៤) ល័ក្ខខ័ណ្ឌនៃអំពើអនីត្យានុកូល

(៥) ប្រភេទនៃអំពើអនីត្យានុកូល(អំពើអនីត្យានុកូលដែលមានលក្ខណៈទូទៅ និង អំពើអនីត្យានុកូលដែលមានលក្ខណៈពិសេស)

## ២ សំណងការខូចខាត

✎ ការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលក្នុងករណីគ្រោះថ្នាក់រថយន្ត-- ការពិចារណាតាមរយៈករណីសិក្សា

ករណីសិក្សា៖ B ដែលជាអ្នកបើកបររថយន្តឲ្យក្រុមហ៊ុនរថយន្តតាក់ស៊ី A នៅពេលកំពុងបើកបរ បានជ្រុលចង្កូតទៅកៀរ C ដែល កំពុងដើរឆ្លងផ្លូវ ធ្វើឲ្យ C មានរបួស។ តើ C អាចទាមទារថ្លៃព្យាបាល ពីក្រុមហ៊ុន A និង បុគ្គល B បានដែរឬទេ ?

## ១ អំពើអនីត្យានុកូល

### (១) អត្ថន័យនៃអំពើអនីត្យានុកូល

#### ក) ទំនាក់ទំនងរវាងសិទ្ធិលើបំណុល និង កាតព្វកិច្ចដោយផ្អែកលើមូលហេតុក្រៅកិច្ចសន្យា

ដូចដែលបានលើកឡើងខាងដើម កិច្ចសន្យាគឺជាការព្រមព្រៀងដែលបង្កើតឲ្យមានអានុភាពគតិយុត្ត។ ប្រសិនបើយើងមើលពីជ្រុងម្ខាងទៀតនៃទស្សនៈនេះ នៅពេលដែលកិច្ចសន្យាកើតឡើង គឺទំនាក់ទំនងរវាងសិទ្ធិ និង កាតព្វកិច្ច រវាងគូភាគីបានកើតឡើង។ ជាឧទាហរណ៍ នៅក្នុងកិច្ចសន្យាលក់ទិញ អ្នកលក់ធ្វើលទ្ធកម្មសិទ្ធិលើបំណុលដែលជាសិទ្ធិទាមទារឲ្យអ្នកទិញបង់ថ្លៃលក់ទិញ ក៏ប៉ុន្តែ មានកាតព្វកិច្ចប្រគល់វត្ថុដែលជាកម្មវត្ថុនៃការលក់ទិញទៅអ្នកទិញ។ ផ្ទុយទៅវិញ អ្នកទិញត្រូវធ្វើលទ្ធកម្មលើសិទ្ធិលើបំណុលដែលជាសិទ្ធិទាមទារឲ្យប្រគល់វត្ថុដែលជាកម្មវត្ថុនៃការលក់ទិញ ក៏ប៉ុន្តែ មានកាតព្វកិច្ចបង់ថ្លៃលក់ទិញ ។

ដូចគ្នានេះដែរ កិច្ចសន្យាធ្វើឲ្យមានការកើតឡើងទំនាក់ទំនងរវាងសិទ្ធិលើបំណុល និង កាតព្វកិច្ច ក៏ប៉ុន្តែ មូលហេតុនៃការកើតឡើងនូវទំនាក់ទំនងរវាងសិទ្ធិលើបំណុល និង កាតព្វកិច្ច មិនកម្រិតត្រឹមតែកិច្ចសន្យាតែប៉ុណ្ណោះទេ។ ក្រមរដ្ឋប្បវេណីផ្តល់ប្រភពនៃសិទ្ធលើបំណុល មានតាំងពីកិច្ចសន្យា ការគ្រប់គ្រងដោយឈឺឆ្អាល សេចក្តីចម្រើនដោយឥតហេតុ រហូតដល់អំពើអនីត្យានុកូល។ មានន័យថា ទំនាក់ទំនងរវាងសិទ្ធិលើបំណុល និង កាតព្វកិច្ចអាចកើតឡើង ដោយសារមូលហេតុទាំងនេះដែរ ក្រៅពីមូលហេតុនៃកិច្ចសន្យា ។

#### ខ) អត្ថន័យនៃអំពើអនីត្យានុកូល

អំពើអនីត្យានុកូលមានន័យថា បុគ្គលម្នាក់ (ចារី) បានបង្កឲ្យមានការខូចខាតដោយខុសច្បាប់ទៅដល់បុគ្គលផ្សេងទៀត (ជនរងគ្រោះ) ដោយចេតនា ឬ ដោយកំហុស។ នៅពេលដែលអំពើអនីត្យានុកូលកើតឡើង ជនរងគ្រោះអាចទាមទារសំណងការខូចខាតដែលខ្លួនបានទទួលរងពីចារីបាន (មាត្រា ៧០៩ នៃក្រមរដ្ឋប្បវេណី)។ មានន័យថា ជនរងគ្រោះដោយអំពើអនីត្យាកូលធ្វើលទ្ធកម្មនូវសិទ្ធិលើបំណុលនៃសំណងការខូចខាតចំពោះចារី។ បើមើលពីទស្សនៈម្ខាងទៀត ចារីត្រូវសងសំណងការខូចខាតដែលកើតមានឡើងនោះទៅជនរងគ្រោះ។ មានន័យថា ចារីមានកាតព្វកិច្ចសងការខូចខាត

ចំពោះជនរងគ្រោះ។ ករណីបែបនេះ គឺជាការកើតឡើងនូវទំនាក់ទំនងនៃសិទ្ធិលើបំណុល និង កាតព្វកិច្ចដោយសារអំពើអនីត្យានុកូល ។

## ២) មុខងាររបស់ច្បាប់ស្តីពីអំពើអនីត្យានុកូល

តើរបបសំណងការខូចខាតដោយសារអំពើអនីត្យានុកូល ដើរតួនាទីក្នុងសង្គមត្រឹមកម្រិតណា? ជាទូទៅ វាមានមុខងារ ៣ យ៉ាង ។

### ក) ការធ្វើបដិទានចំពោះការខូចខាត

ទី ១ តាមរយៈរបបអំពើអនីត្យានុកូល ការខូចខាតដែលជនរងគ្រោះបានទទួលរងអាចត្រូវបានធ្វើបដិទាន។ រវាងជនរងគ្រោះ ដែលទទួលរងនូវការខូចខាត និង ចារីដែលបង្កឲ្យមានការខូចខាត អំពើអនីត្យានុកូលជារបបដាក់បន្ទុកទទួលខុសត្រូវលើចារី ចំពោះការខូចខាតដែលបានកើតឡើង។ ជាធម្មតា ដោយសារតែសកម្មភាពរបស់ចារីគឺជាមូលហេតុនៃការកើតឡើងនូវការខូចខាត យើងអាចនិយាយបានថា ការដាក់ឲ្យចារីឲ្យទទួលកាតព្វកិច្ចសងការខូចខាត គឺមានភាពយុត្តិធម៌ហើយសម្រាប់គូភាគី ។

### ខ) ទណ្ឌកម្មចំពោះចារីនៃអំពើអនីត្យានុកូល

ទី ២ របបអំពើអនីត្យានុកូល មានន័យថាជាទណ្ឌកម្មចំពោះចារីនៃអំពើអនីត្យានុកូល។ នាសម័យដើម មិនមានការបែងចែកច្បាស់លាស់រវាងច្បាប់រដ្ឋប្បវេណី និង ច្បាប់ព្រហ្មទណ្ឌទេ។ នៅក្នុងក្រមហាមុរ៉ាប៊ី (Hammurabi) របស់អរិយធម៌មេសូប៉ូតាមៀ (Mesopotamia) និង ច្បាប់មូលដ្ឋានទាំង ១២ របស់រ៉ូម៉ាំង ជាដើម មានបទដ្ឋានដែលចែងថា "ភ្នែកសងភ្នែក ធ្មេញសងធ្មេញ" ។ បទដ្ឋានបែបនោះ (ភាសាឡាតាំងហៅថា Talio) គឺមានន័យថាយុត្តិធម៌ត្រូវបានផ្តល់ឲ្យ នៅពេលដែលមានការផ្តល់ការខូចខាតដល់ចារីវិញ ដូចគ្នាទៅនឹងការខូចខាតដែលជនរងគ្រោះបានទទួលរង (ដោយអនុលោមតាមរបបអំពើអនីត្យានុកូលនេះ កម្រិតនៃការសងសឹកនឹងត្រូវបានរឹតបន្តឹង)។ របបអំពើអនីត្យានុកូលដែលមានន័យជាទណ្ឌកម្មនេះ មានន័យដូចគ្នាទៅនឹងការដាក់ទណ្ឌកម្ម (ការដាក់ទោសទណ្ឌ) ចំពោះជនដែលបានប្រព្រឹត្តអំពើអាក្រក់ និង ធ្វើឲ្យជនរងគ្រោះបានស្កប់ចិត្ត (បដិទាននូវការខូចខាត)។ នៅពេលដែលសម័យកាលបានផ្លាស់ប្តូរ ហើយបើទោះច្បាប់រដ្ឋប្បវេណី និង ច្បាប់ព្រហ្មទណ្ឌបានត្រូវបែងចែកដាច់ពីគ្នាក៏ដោយ ក៏សំណងការខូចខាតនៅតែមានអត្ថន័យជាទណ្ឌកម្មប្រឆាំងនឹងចារីដែលបង្កការខូចខាតដែរ។ នៅក្នុងប្រទេសអាមេរិក មានការដាក់ឲ្យចារីទទួលនូវកាតព្វកិច្ចសងការខូចខាតដែលលើសពីទំហំការខូចខាតដែលជនរងគ្រោះបានទទួលរងជាក់ស្តែង (នេះគេហៅថា

សំណងការខូចខាតដែលមានលក្ខណៈជាការពិន័យ) ហើយដែលត្រង់នេះ វាស្តែងឲ្យឃើញជាពិសេសនូវមុខងារជាទណ្ឌកម្មនៃអំពើអនីត្យានុកូល ។

### គ) ការទប់ស្កាត់ការខូចខាត

ទី ៣ របបអំពើអនីត្យានុកូលត្រូវបានចាត់ទុកថាមានតួនាទីទប់ស្កាត់ចំពោះការខូចខាត។ មានន័យថា ជនដែលបានបង្កឲ្យមានការខូចខាតកើតឡើងចំពោះជនដទៃ ដោយសារចេតនា ឬ កំហុសរបស់ខ្លួនត្រូវរ៉ាប់រងកាតព្វកិច្ចសងការខូចខាតចំពោះជនរងគ្រោះដែលទទួលរងនូវការខូចខាត ដូច្នេះ ដើម្បីជៀសវាងការទទួលកាតព្វកិច្ចសងការខូចខាត ជាទូទៅ ត្រូវមានការប្រុងប្រយ័ត្នខ្ពស់ចំពោះរាល់សកម្មភាពរបស់ខ្លួន ដើម្បីកុំមានការខូចខាតកើតឡើង (ដូចដែលនឹងមានលើកមកជម្រាបជូនពេលក្រោយ បើតាមទ្រឹស្តីនៃការទទួលខុសត្រូវដោយកំហុសនៃក្រមរដ្ឋប្បវេណី ក្នុងករណីដែលចារីគ្មានចេតនា ឬ កំហុស គឺមិនទទួលកាតព្វកិច្ចសងការខូចខាតទេ )។ ជាលទ្ធផល ការខូចខាតនឹងត្រូវបានទប់ស្កាត់ ។

## ៣) អំពើអនីត្យានុកូល និង ការធានារ៉ាប់រង

### ក) សំណងដោយផ្អែកលើរបបធានារ៉ាប់រង

ពាក់ព័ន្ធទៅនឹងតួនាទីសំខាន់នៃរបបអំពើអនីត្យានុកូល ដើម្បីសង្គ្រោះជនដែលរងគ្រោះដោយអំពើអនីត្យានុកូលដែលមានន័យជាការធ្វើបដិទាននោះ គឺដូចបានរៀបរាប់ខាងលើរួចហើយ។ ក៏ប៉ុន្តែ បើទោះជាដាក់បន្ទុកឲ្យចារីទទួលកាតព្វកិច្ចសងការខូចខាតក៏ដោយ ក្នុងការអនុវត្តជាក់ស្តែង ប្រសិនបើចារីមិនសងការខូចខាតទៅជនរងគ្រោះទេ គឺជនរងគ្រោះមិនត្រូវបានសង្គ្រោះដដែល។ម្យ៉ាងវិញទៀត បើទោះជាចារីមានឆន្ទៈសងការខូចខាតក៏ដោយ ប្រសិនបើចារីគ្មានធនធានទេ ក៏នៅតែមិនអាចសងបានដដែល។ ដូច្នេះ វាមានភាពចាំបាច់ដែលត្រូវធ្វើយ៉ាងណាឲ្យជនរងគ្រោះអាចទទួលបាននូវសំណងការខូចខាតដោយប្រាកដប្រជា។ ប្រព័ន្ធធានារ៉ាប់រងមានតួនាទីយ៉ាងសំខាន់ ដើម្បីសម្រេចឲ្យបាននូវគោលគំនិតនេះ។

ដូចជាក្នុងករណីគ្រោះថ្នាក់ចរាចរណ៍ដែលបង្កដោយរថយន្ត ជនដែលអាចជាជនបង្កគ្រោះថ្នាក់បង់ថ្លៃធានារ៉ាប់រងទៅក្រុមហ៊ុនធានារ៉ាប់រង ហើយនៅពេលដែលគ្រោះថ្នាក់បានកើតឡើង និង បានបង្កការខូចខាតទៅដល់អ្នកដទៃ ក្រុមហ៊ុនធានារ៉ាប់រងជាអ្នកបង់សំណងការខូចខាតដែលត្រូវបង់ដោយជនបង្កគ្រោះថ្នាក់ទៅជនរងគ្រោះជំនួសជនបង្កគ្រោះថ្នាក់។ ដោយសារហេតុផលថា មិនមែនសុទ្ធតែម្ចាស់រថយន្ត ឬ អ្នកបើកបរជាអ្នកបង្កគ្រោះថ្នាក់ ដូច្នេះ ប្រាក់ដែលត្រូវបង់ជាមុនជាថ្លៃធានារ៉ាប់រង

បើប្រៀបធៀបជាមួយ នឹងបុព្វលាភធានារ៉ាប់រងដែលត្រូវបង់ដោយក្រុមហ៊ុនធានារ៉ាប់រង គឺជាទឹកប្រាក់ដែលមានចំនួនតិចតួចណាស់ ។

## ខ) បញ្ហាចំពោះរបបធានារ៉ាប់រង និង វិធានការ

ដូចបានរៀបរាប់ខាងលើ ប្រព័ន្ធធានារ៉ាប់រងគឺជាប្រព័ន្ធប្រសើរមួយសម្រាប់ជួយសង្គ្រោះដល់ជនរងគ្រោះ ក៏ប៉ុន្តែ មិនមែនមានន័យថា មិនមានបញ្ហាអ្វីសោះនោះទេ។ មានន័យថា ដោយសារតែមានរបបនៃការបង់សំណងការខូចខាតជំនួសដោយការធានារ៉ាប់រងបែបនេះ មុខងារការពារគ្រោះថ្នាក់របស់សំណងការខូចខាតចំពោះអំពើអនីត្យានុកូលអាចនឹងក្លាយទៅជាចុះខ្សោយ។ មានន័យថា ដោយសារតែមានទំនុកចិត្តថា បើទោះបីជាមានគ្រោះថ្នាក់កើតឡើងក៏ដោយ គង់តែមានក្រុមហ៊ុនធានារ៉ាប់រងបង់សងជំនួស វាអាចនឹងលើកទឹកចិត្តឲ្យមានការធ្វេសប្រហែសចំពោះករណីយកិច្ចប្រុងប្រយ័ត្នដើម្បីបញ្ចៀសគ្រោះថ្នាក់ ។

ចំពោះបញ្ហាខាងលើនេះ ដើម្បីលុបបំបាត់នូវចំណុចខ្សោយនៃប្រព័ន្ធធានារ៉ាប់រង គេអាចមានវិធានការដូចជា ការបន្ថយថ្លៃធានារ៉ាប់រង ប្រសិនបើមិនមានគ្រោះថ្នាក់អ្វីទេ ឬក៏ផ្ទុយទៅវិញ ប្រសិនបើបានបង្កឲ្យមានគ្រោះថ្នាក់ ថ្លៃធានារ៉ាប់រងដែលត្រូវបង់នៅពេលក្រោយនឹងខ្ពស់ជាងមុន ជាដើម។

ការធានារ៉ាប់រងដែលមានគោលបំណងផ្តល់ឲ្យអ្នកបង្កគ្រោះថ្នាក់នូវធនធានសម្រាប់សំណងការខូចខាតបែបនេះ គឺបុគ្គលដែលអាចនឹងក្លាយទៅជាអ្នកបង្កគ្រោះថ្នាក់ជាអ្នកធ្វើកិច្ចសន្យាធានារ៉ាប់រង (ការធានារ៉ាប់រងចំពោះកាតព្វកិច្ចសំណង) ក៏ប៉ុន្តែ ក្រៅពីនេះ ក៏មានការធានារ៉ាប់រងដល់បុគ្គលដែលគិតថាខ្លួនអាចនឹងក្លាយទៅជាជនរងគ្រោះដែរ។ មានន័យថា ក្នុងករណីដែលមានការទទួលរងនូវការខូចខាតណាមួយ ជនរងគ្រោះនោះអាចទទួលបាននូវការបង់បុព្វលាភធានារ៉ាប់រងពីក្រុមហ៊ុនដែលខ្លួនបានទិញធានារ៉ាប់រង ។

នៅក្នុងរបបនៃអំពើអនីត្យានុកូល ទម្រង់នៃការធានារ៉ាប់រងទី ១ គឺមានសារៈសំខាន់ជាងក៏ពិតមែនហើយ ក៏ប៉ុន្តែ ដោយសារតែខ្វះល័ក្ខខ័ណ្ឌដូចដែលនឹងលើកមកពិភាក្សាបន្ទាប់ទៅនេះ ចារីនឹងក្លាយទៅជាគ្មានកាតព្វកិច្ចសងការខូចខាត ដោយហេតុនេះហើយបានជាការធានារ៉ាប់រងទម្រង់ទី ២ ដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ឲ្យជនរងគ្រោះនូវការសង្គ្រោះ ។

## ៤) ល័ក្ខខ័ណ្ឌនៃអំពើអនីត្យានុកូល

យោងតាមអំពើអនីត្យានុកូល ដើម្បីឲ្យអ្នករងគ្រោះទាមទារសំណងការខូចខាតពីអ្នកប្រព្រឹត្តអំពើបំពាន ចាំបាច់ត្រូវបំពេញនូវល័ក្ខខ័ណ្ឌដូចតទៅ (មាត្រា ៧០៩ នៃក្រមរដ្ឋប្បវេណី)។ ទី ១ អ្នក

ប្រព្រឹត្តអំពើបំពានត្រូវមានចេតនា ឬ កំហុស។ ទី ២ ចេតនា ឬ កំហុសរបស់អ្នកប្រព្រឹត្ត (អំពើបំពាន) ត្រូវមានទំនាក់ទំនងនៃហេតុផល ជាមួយនឹងការខូចខាតរបស់អ្នករងគ្រោះ។ ទី ៣ អ្នកប្រព្រឹត្តអំពើបំពានត្រូវមានសមត្ថភាពទទួលខុសត្រូវ ។ ទី ៤ ទង្វើរបស់អ្នកប្រព្រឹត្តអំពើបំពានគឺខុសនឹងច្បាប់។ នៅពេលដែលល័ក្ខខ័ណ្ឌទាំង ៤ ត្រូវបានបំពេញ អំពើអនីត្យានុកូលនឹងបង្កើតឡើង ហើយអ្នកប្រព្រឹត្តអំពើបំពានត្រូវទទួលរ៉ាប់រងកាតព្វកិច្ចសំណងការខូចខាតចំពោះអ្នករងគ្រោះ ។

### ក) ចេតនា ឬ កំហុស

ចេតនាក្នុងន័យនេះ សំដៅទៅលើការដែលខ្លួនបានដឹងថា អំពើរបស់ខ្លួនអាចនឹងបង្កការខូចខាតទៅដល់អ្នកដទៃ ក៏ប៉ុន្តែ នៅតែធ្វើអំពើនោះទៀត។ ដោយឡែកចំពោះកំហុសវិញ គឺជាការដែលមិនធ្វេសប្រហែសចំពោះករណីយកិច្ចប្រុងប្រយ័ត្នដែលត្រូវបានទាមទារតាមច្បាប់។ ឬមានន័យថា ថ្វីត្បិតតែចារីអាចព្យាករបានថាអាចមានការខូចខាតដល់អ្នកដទៃក៏ដោយ ក៏មិនបានព្យាករទុកជាមុនបានដែរ។

ប្រសិនបើចារីគ្មានចេតនា ឬ កំហុស បើទោះបីជាមានការខូចខាតកើតឡើងចំពោះជនរងគ្រោះដោយសារអំពើរបស់ចារីក៏ដោយ ក៏ចារីមិនមានកាតព្វកិច្ចសងការខូចខាតដែរ។ ដូច្នេះ ជនរងគ្រោះត្រូវទទួលបន្ទុកដោយខ្លួនឯងចំពោះការខូចខាតដែលខ្លួនបានទទួលរង ។

ការដែលតម្រូវឲ្យមានចេតនា ឬ កំហុស ធ្វើជាល័ក្ខខ័ណ្ឌស្នូលនៃអំពើអនីត្យានុកូលបែបនេះ ហៅថា គោលការណ៍ទទួលខុសត្រូវដោយផ្អែកលើកំហុស ក៏ប៉ុន្តែ នៅក្នុងអត្ថន័យនៃការគោរពឆន្ទៈសេរីរបស់បុគ្គល គោលការណ៍ទទួលខុសត្រូវដោយផ្អែកលើកំហុសអនុលោមទៅតាមគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជនដែលជាគោលការណ៍ជាមូលដ្ឋានមួយនៃក្រមរដ្ឋប្បវេណីដែលបានលើកយកមកពិភាក្សារួចមកហើយ (សូមមើលជំពូកទី ២) ។ ចំពោះសង្គមប្រទេសបារាំង នៅពេលដែលក្រមរដ្ឋប្បវេណីត្រូវបានបញ្ញត្តនៅក្នុងសតវត្សទី ១៩ ទស្សនៈស្តីពីគោលការណ៍ទទួលខុសត្រូវដោយផ្អែកលើកំហុសបែបនេះ គឺជាទស្សនៈដែលមានភាពសមហេតុផលគ្រប់គ្រាន់។ មានន័យថា ក្នុងករណីដែលមនុស្សធ្វើសកម្មភាពនៅក្នុងសង្គម ប្រសិនបើគេបានប្រុងប្រយ័ត្នដើម្បីជៀសវាងការបង្កការខូចខាតដល់អ្នកដទៃហើយ ក៏ប៉ុន្តែ នៅតែមានលទ្ធផលដែលផ្តល់ការខូចខាតទៅដល់បុគ្គលដទៃទៀតក៏ដោយ ត្រូវចាត់ទុកថាគ្មានកំហុស ហើយដោយសារតែមិនទទួលកាតព្វកិច្ចសងការខូចខាត គេអាចពង្រីកនូវវិសាលភាពនៃសកម្មភាពរបស់គេដោយសុវត្ថិភាព និង ស្ងប់ចិត្តបាន ។

ក៏ប៉ុន្តែ ផ្អែកទៅតាមការរីកចម្រើននៃវិទ្យាសាស្ត្រ និង បច្ចេកវិទ្យា ក៏ដូចជាឧស្សាហកម្ម វត្ថុដែលមានលក្ខណៈគ្រោះថ្នាក់ ដូចជារថយន្ត ជាដើម ដែលផ្តល់ការខូចខាតធ្ងន់ធ្ងរដល់អ្នកដទៃ ត្រូវបាន

ផលិតយ៉ាងច្រើនសន្ធឹកសន្ធាប់ ហើយម្យ៉ាងវិញទៀត វាកើតមាននូវស្ថានភាពដែលរោងចក្រធំៗអាចបង្កឲ្យមានការខូចខាតដែលមានវិសាលភាពធំធេង។ ដោយសារតែមាននូវករណីជាច្រើនដែលជនរងគ្រោះមិនត្រូវបានសង្គ្រោះតាមគោលការណ៍ទទួលខុសត្រូវដោយផ្អែកលើកំហុស ទើបមានចំណោទបញ្ហាជាច្រើនកើតឡើងចំពោះគោលការណ៍នេះ។ ដោយហេតុនេះហើយ ទើបលេចចេញនូវទស្សនៈដែលថា បើទោះបីមិនមែនជាបញ្ហាអំពីចេតនា ឬ កំហុសក៏ដោយ ក៏ត្រូវឲ្យចារីទទួលកាតព្វកិច្ចលើការខូចខាតដែរ ដោយសារតែផ្អែកលើមូលដ្ឋានថា ចារីបានបង្កឲ្យមានហានិភ័យដ៏ធំធេងទៅដល់សង្គម ឬ ដោយសារតែចារីបានទទួលផលប្រយោជន៍យ៉ាងច្រើនសន្ធឹកសន្ធាប់ពីអំពើដែលបង្កឲ្យមានគ្រោះថ្នាក់នោះ។ ចំពោះករណីបង្កហានិភ័យនេះគេហៅថា ការទទួលខុសត្រូវចំពោះហានិភ័យ រីឯករណីដែលទទួលផលប្រយោជន៍ពីហានិភ័យនោះ គេហៅថា ការទទួលខុសត្រូវសងការខូចខាត ។

បើតាមច្បាប់ស្តីពីការទប់ស្កាត់ការបំពុលបរិយាកាស និង ច្បាប់ស្តីពីការទប់ស្កាត់ការបំពុលបរិស្ថានទឹក ជាដើម ជនដែលបង្កការបំពុលត្រូវបានដាក់ឲ្យទទួលខុសត្រូវចំពោះសំណងការខូចខាតដោយគ្មានកំហុស ហើយនេះគឺជាការដាក់ឲ្យទទួលខុសត្រូវដោយអនុលោមតាមទស្សនៈខាងលើនេះ។

## ខ) ទំនាក់ទំនងនៃហេតុផល

ទំនាក់ទំនងនៃហេតុផលមានន័យថាជាទំនាក់ទំនងនៃហេតុលទ្ធផលនៃការកើតឡើងនូវការខូចខាតចំពោះជនរងគ្រោះ និង ចេតនា ឬ កំហុសរបស់ចារី។ វាជារឿងធម្មតាទេដែលចាំបាច់ត្រូវមានអត្ថិភាពនៃទំនាក់ទំនងនៃហេតុផល ដើម្បីកំណត់ថា ចារីបានបង្កឲ្យមានការខូចខាតដល់ជនរងគ្រោះ។ ឧទាហរណ៍ថា អ្នកបើកបររថយន្តមិនបានមើលភ្លើងសញ្ញាចរាចរណ៍ ក៏បានជ្រុលទៅបុកអ្នកថ្មើរជើងដែលកំពុងដើរឆ្លងកាត់គំនូសផ្លូវថ្នល់ និង បានបង្កឲ្យមានរបួស ករណីបែបនេះ ទំនាក់ទំនងនៃហេតុផលរវាងរបួសរបស់អ្នកថ្មើរជើង និង ការធ្វេសប្រហែសរបស់អ្នកបើកបរ គឺមានភាពច្បាស់លាស់ដោយមិនមានចម្ងល់អ្វីឡើយ។ ក៏ប៉ុន្តែ វាក៏មានករណីដែលទំនាក់ទំនងនៃហេតុផល មិនមានភាពច្បាស់លាស់ដែរ។ ឧទាហរណ៍ដូចជាក្នុងករណីដែលបរិយាកាសត្រូវបានបំពុលដោយសារឧស្ម័នដែលចេញពីរោងចក្រ បញ្ហាដែលពិបាកនោះគឺត្រង់ថាតើវាមាននូវទំនាក់ទំនងនៃហេតុផលរវាងជំងឺហឺតរបស់អ្នកភូមិដែលរស់នៅក្បែររោងចក្រនោះ ជាមួយនឹងការបញ្ចេញឧស្ម័នដោយរោងចក្រនោះដែរ ឬ ទេ។ នេះក៏ដោយសារថា បើទោះបីជាបរិស្ថានខ្យល់មិនមានការបំពុលក៏ដោយ ក៏អាចមានអ្នកជំងឺហឺតដែរ។ បើតាមយុត្តិសាស្ត្រចំពោះការបំពុលបរិស្ថាន បញ្ហាស្តីពីអត្ថិភាព ឬ នត្ថិភាពនៃទំនាក់ទំនងនៃហេតុផលគឺមានមិនតិចឡើយ ប៉ុន្តែ គេក៏ឃើញមានជាញឹកញាប់នូវសាលក្រមដែលមានទំនោរទទួលស្គាល់ដោយងាយនូវទំនាក់ទំនងនៃហេតុផលដែរ ។

## គ) សមត្ថភាពទទួលខុសត្រូវ

សមត្ថភាពទទួលខុសត្រូវសំដៅទៅលើភាពមានសមត្ថភាពគ្រប់គ្រាន់របស់ចារីដើម្បីវិនិច្ឆ័យអំពីអំពើរបស់ខ្លួន។ មាត្រា ៧០៩ នៃក្រមរដ្ឋប្បវេណីមិនបានចែងឲ្យច្បាស់លាស់ពីអត្ថន័យនេះទេ។ ក៏ប៉ុន្តែយើងអាចនិយាយបានថា ការដែលកំណត់ថា ចេតនា ឬ កំហុស ជាលក្ខខ័ណ្ឌនៃការកើតមាននូវអំពើអនីត្យានុកូល គឺផ្អែកលើសម្មតិកម្មថា ជាធម្មតា ចារីមានសមត្ថភាពវិនិច្ឆ័យពីអំពើរបស់ខ្លួន ។ ម្យ៉ាងវិញទៀត មាត្រា ៧១២ និង មាត្រា ៧១៣ នៃក្រមរដ្ឋប្បវេណីបញ្ញត្តថា បុគ្គលដែលខ្វះសមត្ថភាពយល់ដឹង និង វិនិច្ឆ័យបានអំពីការទទួលខុសត្រូវ ដោយសារវិបត្តិផ្នែកបញ្ញាស្មារតី មិនត្រូវទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលឡើយ។ ប្រសិនបើយើងបកស្រាយមាត្រាទាំងនេះបញ្រ្ចាស់ទៅវិញ ដើម្បីឲ្យចារីទទួលកាតព្វកិច្ចសងការខូចខាត ចារីចាំបាច់ត្រូវមានសមត្ថភាពទទួលខុសត្រូវ ។

## ឃ) ភាពផ្ទុយច្បាប់

មាត្រា ៧០៩ នៃក្រមរដ្ឋប្បវេណីកំណត់ថា ករណីដែលសិទ្ធិត្រូវបានបំពាន គឺជាអំពើអនីត្យានុកូល។ នៅត្រង់នេះ គឺគេប្រមើលមើលនូវករណីដែល "សិទ្ធិ..." ដូចជាសិទ្ធិជួលអចិន្ត្រៃយ៍ សិទ្ធិលើដី ឬ សិទ្ធិកម្មសិទ្ធិត្រូវបានបំពាន។ នៅពេលដែលក្រមរដ្ឋប្បវេណីត្រូវបានអនុម័តដំបូង ក្នុងករណីដែល "សិទ្ធិ..." ត្រូវបានបំពាន ជនរងគ្រោះអាចទាមទារសំណងការខូចខាតពីចារីដោយផ្អែកលើអំពើអនីត្យានុកូលបាន ក៏ប៉ុន្តែ ក្នុងករណីដែលការខូចខាតដែលជនរងគ្រោះទទួលរងនោះមិនមែនជា "សិទ្ធិ..."ទេ តែគ្រាន់តែជាករណីនៃការបំពានផលប្រយោជន៍ជាធម្មតា គេបានបកស្រាយថា ជនរងគ្រោះមិនអាចទាមទារសំណងការខូចខាតពីចារីបានទេ។ ឧទាហរណ៍ថា ក្នុងករណីដែលបទភ្លេងប្រពៃណីបុរាណជប៉ុនត្រូវបានគេថតសាជាថ្មីឡើងវិញដោយខុសច្បាប់ បើទោះបីជាបទភ្លេងនោះត្រូវបានគេលេងឡើងវិញជារបៀបកែច្នៃក៏ដោយ ដោយសារតែវាមិនមែនជាកម្មវត្ថុនៃកម្មសិទ្ធិបញ្ញា ដូច្នេះ ទោះបីជាត្រូវបានគេថតសាឡើងវិញជាថ្មីក៏ដោយ ក៏មិនអាចទាមទារសំណងការខូចខាតបានដែរ។ ប៉ុន្តែ នៅពេលក្រោយមក ក៏មានការផ្លាស់ប្តូរថា បើទោះបីវាពុំមែនជាសិទ្ធិច្បាស់លាស់ក៏ដោយ នៅក្នុងករណីដែលផលប្រយោជន៍ដែលត្រូវការពារតាមផ្លូវច្បាប់ត្រូវបានបំពាន ជនរងគ្រោះអាចទាមទារសំណងការខូចខាតពីចារីបាន (សាលដីកាតុលាការកំពូលជប៉ុនចាស់ កម្រងសាលក្រម ឬ សាលដីកាព្រហ្មទណ្ឌលេខ ២០ ទំព័រទី ១៣៦០ ចុះថ្ងៃទី ៨ ខែកក្កដា ឆ្នាំ១៩១៤)។ ការវិវដ្តនៃយុត្តិសាស្ត្របែបនេះត្រូវបានបរិយាយថាជាការប្តូរ "ពីការបំពានសិទ្ធិទៅជាភាពផ្ទុយច្បាប់" ក៏ប៉ុន្តែ តាមរយៈវិសោធនកម្មនាឆ្នាំ ២០០៤ ច្បាប់បានចែងយ៉ាងច្បាស់ថា ក្នុងករណីដែលផលប្រយោជន៍ដែលត្រូវការពារតាមច្បាប់ត្រូវបានបំពាន ក៏នឹងក្លាយទៅជាអំពើអនីត្យានុកូលដែរ ។

## ៥) ប្រភេទនៃអំពើអនីត្យានុកូល (អំពើអនីត្យានុកូលដែលមានលក្ខណៈទូទៅ និង អំពើអនីត្យានុកូលដែលមានលក្ខណៈពិសេស)

### ក) អំពើអនីត្យានុកូលដែលមានលក្ខណៈទូទៅ និង អំពើអនីត្យានុកូលដែលមានលក្ខណៈពិសេស

ក្រមរដ្ឋប្បវេណីមានចែងចាប់ពី មាត្រា ៧០៩ នូវបញ្ញត្តិដែលពាក់ព័ន្ធនឹងអំពើអនីត្យានុកូល។ ពិសេសមាត្រា ៧០៩ កំណត់អំពីល័ក្ខខ័ណ្ឌនៃការកើតឡើងនូវអំពើអនីត្យានុកូលដែលមានលក្ខណៈទូទៅ។ ផ្ទុយទៅវិញ បញ្ញត្តិនៃមាត្រា ៧១២ ដល់ មាត្រា ៧១៩ មានចែងពីប្រភេទជាក់លាក់នីមួយៗនៅក្នុងអំពើអនីត្យានុកូលដែលធ្វើការកែសម្រួលនូវល័ក្ខខ័ណ្ឌលើចំណុចផ្សេងៗនៃមាត្រា ៧០៩។ ម្យ៉ាងវិញទៀត នៅក្នុងច្បាប់ពិសេសក្រៅពីក្រមរដ្ឋប្បវេណី ក៏មានបញ្ញត្តិស្តីពីការទទួលខុសត្រូវក្នុងការសងការខូចខាតទៅជនរងគ្រោះរបស់ចារីដែរ។ ត្រង់ចំណុចនេះ អំពើអនីត្យានុកូលទូទៅដែលមានកំណត់នៅក្នុងមាត្រា ៧០៩ នៃក្រមរដ្ឋប្បវេណី ហៅថាអំពើអនីត្យានុកូលដែលមានលក្ខណៈទូទៅ រីឯបញ្ញត្តិដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីក្រៅពីមាត្រានេះ និងដែលមានចែងនៅក្នុងច្បាប់ពិសេសផ្សេងទៀតហៅថា អំពើអនីត្យានុកូលដែលមានលក្ខណៈពិសេស។ ខាងក្រោមនេះ គឺជាប្រភេទខ្លះនៃអំពីអនីត្យានុកូលដែលមានលក្ខណៈពិសេសតាមក្រមរដ្ឋប្បវេណី ។

### ខ) ប្រភេទផ្សេងទៀតនៃអំពើអនីត្យានុកូលដែលមានលក្ខណៈពិសេស

#### (១) អនីតិជន និង បុគ្គលដែលមានវិបត្តិផ្នែកបញ្ញាស្មារតី

ទី ១ អនីតិជនដែលគ្មានសមត្ថភាពវិនិច្ឆ័យ និង បុគ្គលដែលមានវិបត្តិផ្នែកបញ្ញាស្មារតីត្រូវបានចាត់ទុកថាជាបុគ្គលដែលគ្មានសមត្ថភាពទទួលខុសត្រូវ ដូច្នេះ បើទោះជាពួកគេបានបង្កការខូចខាតទៅដល់អ្នកដទៃក៏ដោយ ក៏ពួកគេមិនទទួលខុសត្រូវចំពោះសំណងការខូចខាតដែរ (មាត្រា ៧១២ និង មាត្រា ៧១៣ នៃក្រមរដ្ឋប្បវេណី)។ ហេតុដូច្នេះ អ្នកមានករណីយកិច្ចគ្រប់គ្រងត្រូវទទួលកាតព្វកិច្ចសងការខូចខាតជំនួសអ្នកទាំងអស់នោះ (មាត្រា ៧១៤ នៃក្រមរដ្ឋប្បវេណី)។ អ្នកមានករណីយកិច្ចត្រួតពិនិត្យត្រង់នេះ មានដូចជាឪពុកម្តាយរបស់អនីតិជន ឬ អ្នកអាណាព្យាបាលសម្រាប់នីតិជន ក៏ប៉ុន្តែអ្នកដែលគ្រប់គ្រងជំនួសអ្នកមានករណីយកិច្ចគ្រប់គ្រង (ឧទាហរណ៍ដូចជា បុគ្គលិកសិក្សារបស់សាលារៀន ជាដើម) ក៏ទទួលករណីយកិច្ចទទួលខុសត្រូវដូចគ្នាដែរ ។

#### (២) និយោជិត (ការទទួលខុសត្រូវរបស់និយោជក)

ទី ២ ចំពោះការអនុវត្តកិច្ចការរបស់និយោជិតដែលត្រូវបានជួលដោយអ្នកដទៃ ក្នុងករណីដែលបានបង្កឲ្យមានការខូចខាតទៅដល់តតិយជន និយោជកដែលបានជួលនិយោជិតឲ្យធ្វើកិច្ចការនោះត្រូវទទួលខុសត្រូវចំពោះសំណងការខូចខាត (មាត្រា ៧១៥ នៃក្រមរដ្ឋប្បវេណី ។ នេះគេហៅថា ការ

ទទួលខុសត្រូវរបស់និយោជក)។ ក្នុងករណីនេះ ក៏មានលក្ខខ័ណ្ឌដែលនិយោជិតខ្លួនឯងជាចារីដោយផ្ទាល់ត្រូវទទួលកាតព្វកិច្ចសងការខូចខាតដោយអនុលោមតាមមាត្រា ៧០៩ ដែរ។ ដូច្នេះ ជនរងគ្រោះអាចទាមទារសំណងការខូចខាតទាំងពីនិយោជិត និង និយោជកបាន។ ប្រសិនបើនិយោជកបានសងសំណងការខូចខាតជំនួសនិយោជិត និយោជកអាចទាមទារសំណងពីនិយោជិតវិញបាន ។

### (៣) កម្មសិទ្ធិករ និង អ្នកកាន់កាប់សំណង់ដែលជាប់នឹងដី

ទី ៣ ក្នុងករណីដែលការសាងសង់ ឬ ការកាន់កាប់សំណង់ដែលជាប់នឹងដីមានវិការៈ ហើយបានបង្កឲ្យមានការខូចខាតដល់អ្នកដទៃអ្នកកាន់កាប់ត្រូវទទួលខុសត្រូវចំពោះសំណងការខូចខាតចំពោះជនរងគ្រោះ (មាត្រា ៧១៧ នៃក្រមរដ្ឋប្បវេណី)។ ឧទាហរណ៍ ដោយសារខ្វះការប្រុងប្រយ័ត្ន ថ្មស្អាមក្បឿងរបស់ផ្ទះបានធ្លាក់ត្រូវអ្នកថ្មើរជើងក្បែរនោះបណ្តាលឲ្យមានរបួស ក្នុងករណីនេះ អ្នកកាន់កាប់ស្អាមក្បឿងនោះ (ជាទូទៅ គឺអ្នកដែលរស់នៅក្នុងផ្ទះនោះ) ត្រូវសងការខូចខាត។ ក៏ប៉ុន្តែ ក្នុងករណីការខូចខាតនៅតែកើតមានទៀត បើទោះជាអ្នកកាន់កាប់បានធ្វើការប្រុងប្រយ័ត្នយ៉ាងខ្លាំងហើយក៏ដោយ កម្មសិទ្ធិករត្រូវទទួលខុសត្រូវចំពោះសំណងការខូចខាតជំនួសអ្នកកាន់កាប់ (ជាឧទាហរណ៍ ដូចក្នុងឧទាហរណ៍ ដដែលនេះអញ្ចឹង ប្រសិនបើផ្ទះជាផ្ទះជួល ជាបឋម អ្នកកាន់កាប់ ពោលគឺភតិកៈត្រូវទទួលខុសត្រូវ ក៏ប៉ុន្តែ ប្រសិនបើភតិកៈគ្មានកំហុសទេ គឺកម្មសិទ្ធិករ ពោលគឺភតិបតី ត្រូវទទួលខុសត្រូវ ) ។

### (៤) អ្នកកាន់កាប់សត្វ

ទី ៤ បុគ្គលដែលកាន់កាប់សត្វត្រូវទទួលខុសត្រូវសងការខូចខាតដែលបានកើតឡើងដល់អ្នកដទៃ ដោយសារសត្វដែលខ្លួនបានកាន់កាប់នោះ (មាត្រា ៧១៨ នៃក្រមរដ្ឋប្បវេណី)។ ឧទាហរណ៍ថាម្ចាស់ឆ្កែបានបណ្តើរឆ្កែដែលខ្លួនចិញ្ចឹមដើរលេង ដោយឥតមានដាក់ប្រឡៅក ហើយឆ្កែបានទៅខាំក្មួនក្មេងដែលកំពុងដើរ ករណីបែបនេះ ម្ចាស់ឆ្កែត្រូវទទួលកាតព្វកិច្ចសងការខូចខាតដែលបានកើតឡើងនោះ ។

### (៥) ចារីនៃអំពើអនីត្យានុកូលរួម

ទី ៥ ក្នុងករណីដែលបុគ្គលច្រើនបានប្រព្រឹត្តអំពើអនីត្យានុកូលរួមគ្នា ហើយបានបង្កការខូចខាតដល់អ្នកដទៃ បុគ្គលដែលបានប្រព្រឹត្តអំពើបំពានរួមគ្នាទាំងអស់ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតចំពោះជនរងគ្រោះដោយសាមគ្គីភាព ដោយមិនមែនតែបុគ្គលដែលបង្កការខូចខាតដោយផ្ទាល់តែឯងនោះទេ (មាត្រា ៧១៩ នៃក្រមរដ្ឋប្បវេណី)។

## ២ សំណងការខូចខាត

បុគ្គលដែលត្រូវទទួលខុសត្រូវចំពោះអំពើអនីត្យានុកូល គឺត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតទៅជនរងគ្រោះ។ ការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូល និង ការទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ច គឺជារបបដើម្បីធ្វើបដិទាននូវការខូចខាតដែលជនរងគ្រោះបានទទួលរងដែលមានភាពស្រដៀងគ្នា។ ត្រង់ចំណុចនេះ ទាក់ទងនឹងសំណងការខូចខាត របបទទួលខុសត្រូវទាំងពីរនេះ គឺមានចំណុចរួមគ្នាច្រើន ។

## ក) ខ្លឹមសារនៃសំណងការខូចខាត

ជាបឋម ខ្លឹមសារនៃការទទួលខុសត្រូវចំពោះសំណងការខូចខាត ជាគោលការណ៍គឺជាសំណងជាប្រាក់ (កថាខណ្ឌទី ១ មាត្រា ៧២២ នៃក្រមរដ្ឋប្បវេណីចែងថា មាត្រា ៤១៧ ស្តីពីគោលការណ៍នៃសំណងជាប្រាក់ ត្រូវយកមកអនុវត្តដូចគ្នាចំពោះរបៀបសងការខូចខាតដោយសារការមិនអនុវត្តកាតព្វកិច្ច)។ មានន័យថា ត្រូវវាយតម្លៃជាទឹកប្រាក់នូវការខូចខាតដែលទទួលរង រួចហើយត្រូវសងដោយផ្អែកលើទឹកប្រាក់ តាមចំនួនដែលត្រូវបានគណនានោះ។ ក៏ប៉ុន្តែ ក្នុងករណីដូចជាការបរិហារកេរ្តិ៍ ជាករណីលើកលែង វិធីស្តារកិត្តិយសឡើងវិញតាមមធ្យោបាយផ្សព្វផ្សាយជាសាធារណៈនូវសេចក្តីសុំអភ័យទោស ត្រូវបានទទួលស្គាល់ (មាត្រា ៧២៣ នៃក្រមរដ្ឋប្បវេណី)។ ឧទាហរណ៍ ចាវីត្រូវចុះផ្សាយក្នុងសារព័ត៌មាននូវអត្ថបទដែលមានខ្លឹមសារជាការសុំអភ័យទោសទៅជនរងគ្រោះ ជាដើម ។

## ខ) វិសាលភាពនៃសំណងការខូចខាត

ចំពោះវិសាលភាពនៃសំណងការខូចខាត មិនមានបញ្ញត្តិដូចមាត្រា ៤១៦ នៃក្រមរដ្ឋប្បវេណីដែលចែងអំពីទំហំសំណងការខូចខាតក្នុងករណីមិនអនុវត្តកាតព្វកិច្ចទេ ក៏ប៉ុន្តែ ទ្រឹស្តីមួយចំនួនធំគិតថាអាចអនុវត្តបានដូចគ្នាជាមួយនឹងសំណងការខូចខាតក្នុងករណីនៃការមិនអនុវត្តកាតព្វកិច្ចដែរ។ មានន័យថា គេអាចបកស្រាយបានថា បុគ្គលដែលត្រូវទទួលខុសត្រូវចំពោះអំពើអនីត្យានុកូល ត្រូវមានកាតព្វកិច្ចចំពោះសំណងការខូចខាត ដោយសារតែអំពើអនីត្យានុកូលដែលបានកើតឡើងចំពោះជនរងគ្រោះ និង ដោយសារទំនាក់ទំនងនៃហេតុផលដែលមានភាពសមស្រប (ក៏ប៉ុន្តែ ការទិតៀននានាទាំងឡាយចំពោះទ្រឹស្តីទំនាក់ទំនងនៃហេតុផលដែលមានភាពសមស្រប មានលើកមកពិភាក្សារួចហើយក្នុងជំពូកទី ៧) ។

ម្យ៉ាងវិញទៀត ក្នុងករណីនៃការទូទាត់កំហុសដែលជនរងគ្រោះមានចំណែកក្នុងកំហុសដែរ គឺត្រូវអនុវត្តដូចគ្នាទៅនឹងការមិនអនុវត្តកាតព្វកិច្ច (កថាខណ្ឌទី ២ មាត្រា ៧២២ នៃក្រមរដ្ឋប្បវេណី)។ ពាក្យថា "កំហុស" នៅត្រង់នេះ ត្រូវបានបកស្រាយថា ខុសពី "កំហុស" នៅក្នុងមាត្រា ៧០៩ នៃក្រមរដ្ឋប្បវេណី។ មានន័យថា បើទោះបីជាអនីតិជនក៏ដោយ ប្រសិនបើមានសមត្ថភាពយល់ដឹង និង

វិនិច្ឆ័យអំពីហេតុផល (មានន័យថាមានលទ្ធភាពវិនិច្ឆ័យអំពីហេតុផ្សេងៗដោយសមហេតុផល ដែលជាសមត្ថភាពទាបជាងសមត្ថភាពវិនិច្ឆ័យអំពីការទទួលខុសត្រូវ) នោះអាចនឹងត្រូវយកមកពិចារណាអំពីកំហុសដែរ។ អាចនិយាយម្យ៉ាងទៀតបានថា កំហុសដោយសារការរួមចំណែកខុស អាចត្រូវបានទទួលស្គាល់ដោយងាយស្រួល។ ម្យ៉ាងវិញទៀត ក្នុងករណីជនរងគ្រោះជាកូនក្មេង បើទោះបីជាមិនមានកំហុសក៏ដោយ កំហុសរបស់ឪពុកម្តាយអាចត្រូវបានទទួលស្គាល់ជាកំហុសសម្រាប់ទូទាត់របស់ជនរងគ្រោះ ។

### គ) អាជ្ញាយុកាលនៃសិទ្ធិទាមទារសំណងការខូចខាត

ដោយឡែកសិទ្ធិទាមទារសំណងការខូចខាតដោយផ្អែកលើការទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ច ត្រូវបានយល់ឃើញថាត្រូវរលត់អាជ្ញាយុកាលនៃសិទ្ធិលើបំណុល ក្រោយអំឡុងពេល ១០ឆ្នាំ គិតចាប់ពីពេលអាចធ្វើការទាមទារដោយផ្អែកលើសិទ្ធិលើបំណុល (កថាខណ្ឌទី ១ មាត្រា ១៦៧ នៃក្រមរដ្ឋប្បវេណី) ក៏ប៉ុន្តែ ចំពោះសិទ្ធិទាមទារសំណងការខូចខាត ដោយយោងលើអំពើអនីត្យានុកូលវិញ គឺមានបញ្ញត្តិពិសេស ដោយអាជ្ញាយុកាលនៃសិទ្ធិទាមទារត្រូវរលត់ក្នុងអំឡុងពេលខ្លី។ មានន័យថាក្នុងអំឡុងពេល ៣ ឆ្នាំគិតចាប់ពីចំណុចពេលដែលដឹងពីការខូចខាត និង បានស្គាល់ចារី បើជនរងគ្រោះមិនអនុវត្តសិទ្ធិទាមទារទេ នោះសិទ្ធិទាមទារនឹងត្រូវរលត់ដោយអាជ្ញាយុកាល (មាត្រា ៧២៨ នៃក្រមរដ្ឋប្បវេណី) ។

✎ ការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលក្នុងករណីគ្រោះថ្នាក់រថយន្ត -- ការពិចារណាតាមរយៈករណីសិក្សា

ជាបឋម អ្នកបើកបរ B ត្រូវទទួលកាតព្វកិច្ចសងការខូចខាតទៅ C ដោយអនុលោមតាមមាត្រា ៧០៩ នៃក្រមរដ្ឋប្បវេណី។ ដើម្បីឲ្យ C អាចទាមទារនូវថ្លៃព្យាបាលជាការខូចខាតដែលខ្លួនបានបង់រួចហើយពី B បាន ចាំបាច់ត្រូវបំពេញល័ក្ខខ័ណ្ឌនៃការកើតឡើងនូវអំពើអនីត្យានុកូលដូចបានលើកឡើងពីខាងលើរួចមកហើយនោះ។ ហើយជាបន្ត A ដែលជានិយោជករបស់ B ត្រូវទទួលកាតព្វកិច្ចសងការខូចខាតចំពោះ C ដោយអនុលោមតាមមាត្រា ៧១៥ នៃក្រមរដ្ឋប្បវេណី។ ក្នុងករណីនេះ ក្រៅពីល័ក្ខខ័ណ្ឌនៃមាត្រា ៧១៥ ត្រូវបានបំពេញហើយ ល័ក្ខខ័ណ្ឌនៃមាត្រា ៧០៩ ដែលពាក់ព័ន្ធជាមួយនឹង B ក៏ត្រូវបានបំពេញជាចាំបាច់ដែរ។ ហេតុដូច្នេះ ការទទួលខុសត្រូវរបស់ B និង ការទទួលខុសត្រូវរបស់ A ត្រូវបានហៅថា កាតព្វកិច្ចដោយសាមគ្គីភាពដែលមិនពិតប្រាកដ ដោយ C អាចទាមទារសំណងការខូចខាតទាំងអស់ពី A និង B ឬ ពីម្នាក់ណាមួយក្នុងចំណោមអ្នកទាំងពីរនេះក៏បាន ហើយប្រសិនបើអ្នកណាម្នាក់ក្នុងចំណោម A និង B បានអនុវត្តកាតព្វកិច្ចសងការខូចខាតនោះហើយ ម្នាក់ទៀតក៏ត្រូវរួច

ផុតពីការទទួលខុសត្រូវដែរ (ក្នុងករណីដែល A បានសង ទំនាក់ទំនងដែល A អាចទាមទារសំណងពី B នៅតែមាននៅឡើយ) ។

ក៏ប៉ុន្តែ ចំពោះការខូចខាតដល់រាងកាយដោយសារគ្រោះថ្នាក់រថយន្ត (ដូចជាការខូចខាតដែលជារបួស ឬ មរណភាព ជាដើម) ជនរងគ្រោះអាចទាមទារសំណងការខូចខាតបានដោយងាយដោយផ្អែកលើច្បាប់ស្តីពីការធានាសំណងការខូចខាតបង្កដោយរថយន្តបាន។ មានន័យថា បើតាមមាត្រា ៣ នៃច្បាប់ដដែលនេះ អ្នកមានចំណែកក្នុងរថយន្ត (ជាទស្សនៈដែលពិបាកយល់ ក៏ប៉ុន្តែជាទូទៅ វាមានន័យថាជាម្ចាស់រថយន្ត ឬ អ្នកបើកបររថយន្ត ហើយក្នុងករណីសិក្សានេះ អ្នកមានចំណែកក្នុងរថយន្តគឺ A និង B) ជាគោលការណ៍ ត្រូវទទួលខុសត្រូវសងការខូចខាត ហើយដរាបណាមិនមានការបញ្ជាក់អំពីការដែលអ្នកមានចំណែកក្នុងរថយន្ត ឬ អ្នកបើកបរគ្មានកំហុស ឬ ការដែលជនរងគ្រោះ ឬ តតិយជនមានកំហុស ឬ ការដែលរចនាសម្ព័ន្ធរបស់រថយន្តមានវិការៈទេ គឺមិនរួចផុតពីការទទួលខុសត្រូវបានទេ។ ច្បាប់នេះជាមូលដ្ឋានគឺអនុលោមទៅតាមគោលការណ៍ទទួលខុសត្រូវដោយកំហុស ហើយតាមរយៈការដាក់បន្ទុកឲ្យចារីធ្វើការបញ្ជាក់ពីភាពគ្មានល័ក្ខខ័ណ្ឌក្នុងការទទួលខុសត្រូវ (បើតាមមាត្រា ៧០៩ នៃក្រមរដ្ឋប្បវេណី ជនរងគ្រោះត្រូវធ្វើការបញ្ជាក់ថា ចារីមានការទទួលខុសត្រូវ) គឺគេអាចធ្វើការសង្គ្រោះជនរងគ្រោះបានងាយស្រួលជាង ។

# ជំពូកទី ១០

## ការគ្រប់គ្រងដោយឈឺឆ្អាល និង សេចក្តីចម្រើនដោយឥតហេតុ

### ១ ការគ្រប់គ្រងដោយឈឺឆ្អាល

(១) អត្ថន័យនៃការគ្រប់គ្រងដោយឈឺឆ្អាល

(២) ការគ្រប់គ្រងដោយឈឺឆ្អាលដែលមិនពេញលេញ

### ២ សេចក្តីចម្រើនដោយឥតហេតុ

(១) អត្ថន័យនៃសេចក្តីចម្រើនដោយឥតហេតុ

(២) សេចក្តីចម្រើនដោយឥតហេតុដែលមានបុគ្គលបីនាក់ចូលរួម

(៣) ការផ្តល់តាវកាលិកដោយមូលហេតុខុសច្បាប់

✏ ការបើកប្រាក់បញ្ញើលើស និង សេចក្តីចម្រើនដោយឥតហេតុ--ការពិចារណាតាមរយៈករណីសិក្សា

**ករណីសិក្សា៖** A បានដាក់បញ្ចូលប្រាក់ទៅក្នុងគណនីបញ្ញើធម្មតា។ ថ្ងៃមួយ A បានទៅជួបបេឡាធនាគារ និង ស្នើសុំបើកប្រាក់ ២០ ម៉ឺនយ៉េន ហើយពេលត្រឡប់មកផ្ទះវិញក៏បានរាប់ប្រាក់ ហើយស្រាប់តែឃើញមានដល់ទៅ ៣០ ម៉ឺនយ៉េន។ នៅក្នុងសៀវភៅធនាគារឃើញមានតួលេខដែលបើកឲ្យត្រឹមតែ ២០ ម៉ឺនយ៉េនទេ។ តើធនាគារអាចទាមទារឲ្យ A សងមកវិញនូវប្រាក់ដែលបានបើកឲ្យលើស ១០ ម៉ឺនយ៉េនដែរ ឬទេ ?

## ១ ការគ្រប់គ្រងដោយឈឺឆ្អាល

### ១) អត្ថន័យនៃការគ្រប់គ្រងដោយឈឺឆ្អាល

ដូចដែលបានរៀបរាប់ខាងដើម នៅក្នុងក្រមរដ្ឋប្បវេណី ទន្ទឹមនឹងកិច្ចសន្យា និង អំពើអនីត្យានុកូល នៅមានការគ្រប់គ្រងដោយឈឺឆ្អាល និង សេចក្តីចម្រើនដោយឥតហេតុ ដែលជាមូលហេតុនៃការកើតឡើងនូវទំនាក់ទំនងនៃសិទ្ធិលើបំណុល និង កាតព្វកិច្ច។ កិច្ចសន្យា និង អំពើអនីត្យានុកូលត្រូវបានយល់ដឹងដោយយើងគ្រប់គ្នា ដោយសារតែវាផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃរបស់យើង ក៏ប៉ុន្តែចំពោះការគ្រប់គ្រងដោយឈឺឆ្អាល និង សេចក្តីចម្រើនដោយឥតហេតុវិញ មានលក្ខណៈជាទស្សនាទានគតិយុត្តខ្លាំងដែលសូម្បីតែពាក្យពេចន៍ ក៏កម្រត្រូវបានប្រើប្រាស់នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់យើងដែរ។ក្នុងចំណោមមូលហេតុនៃការកើតឡើងនូវទំនាក់ទំនងនៃសិទ្ធិលើបំណុល និង កាតព្វកិច្ចទាំង ៤ កិច្ចសន្យាគឺជាការបង្កើតឲ្យមាននូវទំនាក់ទំនងនៃសិទ្ធិលើបំណុល និង កាតព្វកិច្ច ដោយសារការត្រូវគ្នានៃឆន្ទៈច្រើន។ ផ្ទុយទៅវិញ អំពើអនីត្យានុកូល ការគ្រប់គ្រងដោយឈឺឆ្អាល និង សេចក្តីចម្រើនដោយឥតហេតុ គឺជាអ្វីដែលបង្កើតឲ្យមានទំនាក់ទំនងនៃសិទ្ធិលើបំណុល និង កាតព្វកិច្ច ដោយមានអង្គហេតុកំណត់ណាមួយ ។

### ក) អត្ថន័យនៃការគ្រប់គ្រងដោយឈឺឆ្អាល

ការគ្រប់គ្រងដោយឈឺឆ្អាលគឺសំដៅលើការអនុវត្តកិច្ចការដើម្បីអ្នកដទៃ បើទោះជាខ្លួនគ្មានករណីយកិច្ចតាមច្បាប់ដូចជាករណីយកិច្ចដោយសារកិច្ចសន្យា ឬ ករណីយកិច្ចដោយយោងតាមបញ្ញត្តិច្បាប់ក៏ដោយ (មាត្រា ៦៩៧ នៃក្រមរដ្ឋប្បវេណី)។ ឧទាហរណ៍ដូចជា ក្នុងអំឡុងពេលដែលអ្នកជិតខាងធ្វើដំណើរកំសាន្ត ទាំងគ្រួសារទៅបរទេស មានខ្យល់ព្យុះដ៏ខ្លាំងធ្វើឲ្យដំបូលផ្ទះមួយផ្នែករបស់អ្នកជិតខាងនោះបាក់ខូច ឃើញដូច្នេះ ខ្លួនបានទៅជួលជាងសំណង់ឲ្យជួសជុលដំបូលផ្ទះឲ្យអ្នកជិតខាងនោះ បើទោះបីជាអ្នកជិតខាងមិនបានពឹងក៏ដោយ។ ក្នុងករណីបែបនេះ បុគ្គលដែលបានអនុវត្តកិច្ចការដើម្បីអ្នកដទៃ ហៅថា អ្នកគ្រប់គ្រងដោយឈឺឆ្អាល រីឯបុគ្គលដទៃដែលទទួលផលប្រយោជន៍ (ក្នុងករណីឧទាហរណ៍ខាងលើនេះ គឺអ្នកជិតខាង) ហៅថាសាមីខ្លួន ។

ក្នុងឧទាហរណ៍ដែលបានលើកឡើងប្រសិនបើខ្លួនបានទទួលនូវការស្នើសុំពីអ្នកជិតខាងឲ្យជួយគ្រប់គ្រងផ្ទះក្នុងអំឡុងពេលអវត្តមានរបស់អ្នកជិតខាង កិច្ចសន្យាអាណត្តិរវាងភាគីបានកើតឡើង (ដោយសារការគ្រប់គ្រងផ្ទះពុំមែនជាសកម្មភាពគតិយុត្ត បើនិយាយឲ្យជាក់លាក់ នេះគឺជាអាណត្តិមិនពេញលេញ។ សូមមើលមាត្រា ៦៥៦ នៃក្រមរដ្ឋប្បវេណី) ដូច្នេះ ការជួលឲ្យជាងសំណង់ជួសជុលដំបូលផ្ទះ គឺអនុលោមទៅតាមកាតព្វកិច្ចដោយផ្អែកលើកិច្ចសន្យា។ ក៏ប៉ុន្តែ ក្នុងករណីដែលមិនត្រូវបានស្នើសុំដោយអ្នកជិតខាងទេគឺគ្មានករណីយកិច្ចទៅជួលជាងមកជួសជុលដំបូលផ្ទះនោះទេ។ សកម្មភាពជួលជាងមកជួសជុលដំបូលផ្ទះឲ្យអ្នកជិតខាង បើទោះជាមិនមានការពឹងពាក់ពីអ្នកជិតខាងបែបនេះក៏ដោយ គឺជាការគ្រប់គ្រងដោយឈឺឆ្អាល ។

ម្យ៉ាងវិញទៀត ការជួយមនុស្សដែលកំពុងលង់ទឹក ក៏ជាឧទាហរណ៍មួយនៃការគ្រប់គ្រងដោយឈឺឆ្អាលដែរ។ ក៏ប៉ុន្តែ ក្នុងករណីដែលមានករណីយកិច្ចត្រូវជួយសង្គ្រោះតាមច្បាប់ (ឧទាហរណ៍ ដូចជានគរបាល ឬ ភ្នាក់ងារពន្លត់អគ្គិភ័យ) ការជួយសង្គ្រោះគឺជាការអនុលោមតាមករណីយកិច្ចរបស់ខ្លួនពុំមែនជាការគ្រប់គ្រងដោយឈឺឆ្អាលទេ ។

### ខ) គោលបំណងនៃរបបគ្រប់គ្រងដោយឈឺឆ្អាល

ពលរដ្ឋសាមញ្ញមានសេរីភាព និង ត្រូវជៀសវាងការជ្រៀតជ្រែកគ្នាទៅវិញទៅមក ក៏ប៉ុន្តែ ដោយសារតែជីវភាពសង្គមជាការជួយគ្នាទៅវិញទៅមក បើទោះបីជាគ្មានករណីយកិច្ចតាមច្បាប់ក៏ដោយក៏មានការទទួលស្គាល់នូវការអនុវត្តកិច្ចការដើម្បីអ្នកដទៃ ដែលនោះគឺជារបបគ្រប់គ្រងដោយឈឺឆ្អាល។ ក៏ប៉ុន្តែ ក្រមរដ្ឋប្បវេណីមិនមែនសុទ្ធតែទទួលស្គាល់ជាវិជ្ជមាននូវការគ្រប់គ្រងដោយឈឺឆ្អាលនោះទេ គឺកំណត់ត្រឹមតែការអនុវត្តកិច្ចការដើម្បីអ្នកដទៃ បើទោះជាគ្មានការស្នើសុំនោះ ដោយសកម្មភាពដែលស្របច្បាប់ ពោលគឺមិនត្រូវប្រព្រឹត្តអំពើអនីត្យានុកូលឡើយ ។

បើនិយាយឲ្យជាក់លាក់ អ្នកគ្រប់គ្រងដោយឈឺឆ្អាលមិនអាចអនុវត្តផ្ទុយពីឆន្ទៈរបស់សាមីខ្លួនបានទេ ហើយអ្នកគ្រប់គ្រងដែលបានចាប់ផ្តើមការគ្រប់គ្រងដោយឈឺឆ្អាលហើយ ត្រូវតែបន្តការគ្រប់គ្រងតទៅទៀត (មាត្រា ៧០០ នៃក្រមរដ្ឋប្បវេណី)។ ម្យ៉ាងវិញទៀត អ្នកគ្រប់គ្រងអាចទាមទារមកវិញបាននូវសោហ៊ុយដែលបានចំណាយសម្រាប់ការគ្រប់គ្រង (មាត្រា ៧០២ នៃក្រមរដ្ឋប្បវេណី) ក៏ប៉ុន្តែ មិនអាចទាមទារនូវកម្រៃសម្រាប់គ្រប់គ្រងនោះបានទេ ។

### គ) ការគ្រប់គ្រងដោយឈឺឆ្អាលដោយផ្អែកលើច្បាប់ពិសេស

នៅក្នុងច្បាប់ពិសេស ទទួលស្គាល់ជាវិជ្ជមាននូវការគ្រប់គ្រងដោយឈឺឆ្អាល ហើយក៏មានករណីលើកកម្ពស់ការគ្រប់គ្រងដោយឈឺឆ្អាលផងដែរ។ ក៏ប៉ុន្តែ អ្វីដែលគួរឲ្យកត់សម្គាល់នោះគឺករណីផ្តល់ឲ្យ

នូវសិទ្ធិទាមទារកម្រៃដល់អ្នកគ្រប់គ្រងដោយឈឺឆ្អាល។ ជាឧទាហរណ៍ ច្បាប់ស្តីពីវត្ថុបាត់ លើកទឹកចិត្តឲ្យមានការប្រគល់វត្ថុបាត់ទៅដល់ដៃម្ចាស់វត្ថុបាត់វិញ តាមរយៈការផ្តល់ឲ្យអ្នកដែលបានរើសវត្ថុបាត់នូវសិទ្ធិទាមទារកម្រៃ (ហៅថា ប្រាក់កម្រៃពលកម្ម) (មាត្រា ២៨ នៃច្បាប់ស្តីពីវត្ថុបាត់) ។

### ឃ) ល័ក្ខខ័ណ្ឌនៃការគ្រប់គ្រងដោយឈឺឆ្អាល

ដើម្បីឲ្យការគ្រប់គ្រងដោយឈឺឆ្អាលកើតឡើង ចាំបាច់ត្រូវមានល័ក្ខខ័ណ្ឌ ៤ ដែលល័ក្ខខ័ណ្ឌទាំងនោះ មានការគ្រប់គ្រងកិច្ចការរបស់អ្នកដទៃ មានឆន្ទៈគ្រប់គ្រងកិច្ចការដើម្បីអ្នកដទៃ គ្មានករណីយកិច្ចតាមច្បាប់ ភាពស្របទៅតាមឆន្ទៈ និង ផលប្រយោជន៍របស់សាមីខ្លួន (មាត្រា ៦៩៧ និងមាត្រា ៧០០ នៃក្រមរដ្ឋប្បវេណី)។ ហេតុដូច្នេះ ក្នុងករណីដែលបានបំពេញល័ក្ខខ័ណ្ឌទាំង ៤ នេះហើយ ការគ្រប់គ្រងដោយឈឺឆ្អាលនឹងពុំអាចក្លាយទៅជាអំពើអនីត្យានុកូលចំពោះសាមីខ្លួនទេ។ ម្យ៉ាងវិញទៀត ទំនាក់ទំនងរវាងសិទ្ធិលើបំណុល និង កាតព្វកិច្ចរវាងសាមីខ្លួន និង អ្នកគ្រប់គ្រងដោយឈឺឆ្អាល ត្រូវកើតឡើង។ មានន័យថា អ្នកគ្រប់គ្រងដោយឈឺឆ្អាលមានករណីយកិច្ចមួយចំនួនដូចជា ករណីយកិច្ចជូនដំណឹងទៅសាមីខ្លួនអំពីការចាប់ផ្តើមការគ្រប់គ្រងរបស់ខ្លួន (មាត្រា ៦៩៩ នៃក្រមរដ្ឋប្បវេណី) ករណីយកិច្ចបន្តការគ្រប់គ្រង (មាត្រា ៧០០ នៃក្រមរដ្ឋប្បវេណី) ជាដើម ។ ដោយឡែកចំពោះអាណត្តិរវាងអ្នកគ្រប់គ្រងដោយឈឺឆ្អាល និង សាមីខ្លួន ដោយសារតែវាមានភាពស្រដៀងគ្នាទៅនឹងទំនាក់ទំនងរវាងអាណត្តិគាហក និង អាណត្តិទាយក បញ្ញត្តិស្តីពីអាណត្តិត្រូវយកមកអនុវត្តដូចគ្នាផងដែរ (មាត្រា ៧០១ នៃក្រមរដ្ឋប្បវេណី) ។ បើនិយាយឲ្យជាក់លាក់ គឺអ្នកគ្រប់គ្រងត្រូវទទួលនូវករណីយកិច្ចរាយការណ៍ (មាត្រា ៦៤៥ នៃក្រមរដ្ឋប្បវេណី) ករណីយកិច្ចប្រគល់នូវវត្ថុដែលទទួលបាន (មាត្រា ៦៤៦នៃក្រមរដ្ឋប្បវេណី) និងករណីយកិច្ចសងសំណងនៃការខូចខាតចំពោះការប្រើប្រាស់ប្រាក់ (មាត្រា ៦៤៧នៃក្រមរដ្ឋប្បវេណី)។ ដោយឡែក បញ្ញត្តិនៃមាត្រា ៦៤៤ នៃក្រមរដ្ឋប្បវេណីដែលមានខ្លឹមសារថា អាណត្តិគាហកមានករណីយកិច្ចប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងសុចរិត (ករណីយកិច្ចប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងសុចរិត។ ក្នុងករណីគ្រប់គ្រងវត្ថុ ឬកិច្ចការ គឺទាមទារឲ្យមានការប្រុងប្រយ័ត្នក្នុងកម្រិតដែលជាធម្មតាតម្រូវឲ្យមានចំពោះបុគ្គលដែលស្ថិតក្នុងឋានៈ ឬ បុគ្គលដែលកាន់មុខការនោះ ) មិនត្រូវយកមកអនុវត្តដូចគ្នាទេ ក៏ប៉ុន្តែ នៅក្នុងការគ្រប់គ្រងដោយឈឺឆ្អាល គេអាចគិតបានដែរថា អ្នកគ្រប់គ្រងគឺមានករណីយកិច្ចដូចគ្នាទៅនឹងករណីយកិច្ចរបស់អាណត្តិគាហក។ ផ្ទុយទៅវិញ អ្នកគ្រប់គ្រងមានសិទ្ធិទាមទារឲ្យសាមីខ្លួនសងមកវិញនូវប្រាក់ដែលបានចំណាយបាន (មាត្រា ៧០២ នៃក្រមរដ្ឋប្បវេណី) ។

## (២) ការគ្រប់គ្រងដោយឈឺឆ្អាលមិនពេញលេញ

### ក) ករណីខ្វះល័ក្ខខ័ណ្ឌបង្កើតការគ្រប់គ្រងដោយឈឺឆ្អាល

ដើម្បីឲ្យការគ្រប់គ្រងដោយឈឺឆ្អាលកើតឡើងបាន ចាំបាច់ត្រូវមានល័ក្ខខ័ណ្ឌដូចដែលបានលើកឡើងខាងលើ ក៏ប៉ុន្តែ ក្នុងករណីដែលគ្រប់គ្រងកិច្ចការមិនមែនដើម្បីអ្នកដទៃទេ ក៏ប៉ុន្តែដើម្បីខ្លួនឯង ការគ្រប់គ្រងដោយឈឺឆ្អាលមិនកើតឡើងទេ។ ឧទាហរណ៍ថា X បានក្លែងធ្វើជាមានកម្មសិទ្ធិលើវត្ថុមួយដែលតាមពិតជាកម្មសិទ្ធិរបស់ Y សោះ ហើយបានលក់វត្ថុនោះទៅឲ្យ Z ក្នុងតម្លៃដែលថ្លៃជាងតម្លៃទីផ្សារធម្មតា ហើយបានគែបន្លំយកប្រាក់ថ្លៃលក់ទិញនោះទៅ។ សកម្មភាពលក់នេះពុំមែនជាការគ្រប់គ្រងដោយឈឺឆ្អាលដែល X បានធ្វើដើម្បី Y ទេ ដោយសារថា X គ្មានឆន្ទៈធ្វើសកម្មភាពនោះដើម្បី Y ទេ ។ សកម្មភាពរបស់ X គឺគ្រាន់តែជាការមិនអនុវត្តកាតព្វកិច្ច ឬ អំពើអនីត្យានុកូលតែប៉ុណ្ណោះ។ ឧទាហរណ៍ថា X បានខ្ចីវត្ថុនោះពី Y ហើយបានរក្សាទុកវត្ថុនោះ ដូច្នេះ X មានករណីយកិច្ចត្រូវប្រគល់វត្ថុនោះទៅវិញ ក៏ប៉ុន្តែ ដោយសារគាត់បានលក់វត្ថុនោះទៅ Z ដូច្នេះ ករណីនេះនឹងក្លាយទៅជាការទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ច ។ ម្យ៉ាងវិញទៀត ប្រសិនបើវាជាការដែល X បានលួចយករបស់នោះពី Y ទៅលក់ឲ្យ Z វានឹងក្លាយទៅជាការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូល ។

### ខ) ការគ្រប់គ្រងដោយឈឺឆ្អាលដែលមិនពេញលេញ

ក៏ប៉ុន្តែ ប្រសិនបើសកម្មភាពលក់របស់ X នោះជាការគ្រប់គ្រងដោយឈឺឆ្អាល Y អាចទាមទារឲ្យ X ប្រគល់មកខ្លួននូវប្រាក់ថ្លៃលក់ទិញទាំងអស់ដែលបានធ្វើលទ្ធកម្មពី Z បាន (ការយកមកអនុវត្តដូចគ្នានូវមាត្រា ៦៤៦ ដោយមាត្រា ៧០១ នៃក្រមរដ្ឋប្បវេណី)។ ក៏ប៉ុន្តែ ដោយសារតែអនុលោមទៅតាមសំណងការខូចខាតដោយផ្អែកលើអំពើអនីត្យានុកូល ឬ ការមិនអនុវត្តកាតព្វកិច្ច Y មិនអាចទាមទារពី X នូវតម្លៃសមរម្យតាមទីផ្សារនៃវត្ថុនោះបានទេ (មាត្រា ៩១៦ នៃក្រមរដ្ឋប្បវេណី) ប្រាក់ដែលបានពីការលក់ទៅ Z បើប្រៀបធៀបជាមួយតម្លៃទីផ្សារជាក់ស្តែង និង តម្លៃត្រូវសងទៅ Y គឺត្រូវនៅសល់នៅនឹង X។ នៅក្នុងក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ ក្នុងករណីបែបនេះត្រូវបានចាត់ទុកដូចគ្នាទៅនឹងការគ្រប់គ្រងដោយឈឺឆ្អាល ហើយ Y អាចទាមទារឲ្យប្រគល់មកខ្លួននូវប្រាក់ទាំងអស់ដែល X បានទទួល ដែលនេះគេហៅថា ការគ្រប់គ្រងដោយឈឺឆ្អាលដែលមិនពេញលេញ។ នៅប្រទេសជប៉ុន ក៏មានការគិតថាគួរតែគិតតាមរបៀបអាល្លឺម៉ង់ដូច្នេះដែរទៅ ។

## ២ សេចក្តីចម្រើនដោយឥតហេតុ

### (១) អត្ថន័យនៃសេចក្តីចម្រើនដោយឥតហេតុ

### ក) អត្ថន័យនៃសេចក្តីចម្រើនដោយឥតហេតុ

សេចក្តីចម្រើនដោយឥតហេតុ គឺសំដៅទៅលើការដែលបុគ្គលដែលបានទទួលផលប្រយោជន៍ពីទ្រព្យសម្បត្តិ ឬ ពីពលកម្មរបស់អ្នកដទៃ បើទោះជាគ្មានមូលហេតុលើផ្លូវច្បាប់ក៏ដោយ ការទទួលផលប្រយោជន៍នោះបានធ្វើឲ្យអ្នកដទៃបាត់បង់នូវផលប្រយោជន៍។ បុគ្គលដែលបានទទួលផលប្រយោជន៍នោះ ហៅថា អ្នកទទួលផលប្រយោជន៍ រីឯបុគ្គលដែលទទួលរងនូវការបាត់បង់ហៅថា អ្នកបាត់បង់ផលប្រយោជន៍។ ក្នុងករណីនេះ អ្នកទទួលផលប្រយោជន៍ត្រូវសងផលប្រយោជន៍នោះទៅអ្នកបាត់បង់ផលប្រយោជន៍វិញ (មាត្រា ៧០៣ នៃក្រមរដ្ឋប្បវេណី) ។ ឧទាហរណ៍ថា ក្នុងករណីដែលបុគ្គលដែលបានលួចត្រាសម្គាល់ខ្លួន និង សៀវភៅធនាគារ និង បានទទួលការបើកប្រាក់បញ្ញើពីធនាគារ ដោយធនាគារមិនបានដឹងពីអង្គហេតុនៃការលួច ហើយគិតថាបុគ្គលដែលទាមទារឲ្យបើកប្រាក់បញ្ញើនោះគឺជាសាមីខ្លួនដែលបានដាក់ប្រាក់សន្សំ ដូច្នេះ ក្នុងករណីនេះ គឺធនាគារគ្មានកំហុសទេ ហើយការបើកប្រាក់ឲ្យគឺមានសុពលភាព (មាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី) ក៏ប៉ុន្តែ បុគ្គលដែលជាអ្នកដាក់ប្រាក់សន្សំអាចទាមទារឲ្យបុគ្គលដែលទទួលការបើកប្រាក់ (បុគ្គលជាអ្នកលួចសៀវភៅ និងត្រាសម្គាល់ខ្លួន) សងប្រាក់ដែលបានទទួលនោះមកវិញ ដោយសារសេចក្តីចម្រើនដោយឥតហេតុ ។

### ខ) ល័ក្ខខ័ណ្ឌនៃសេចក្តីចម្រើនដោយឥតហេតុ

ដើម្បីឲ្យសេចក្តីចម្រើនដោយឥតហេតុកើតឡើងបាន ទាល់តែមានការទទួលផលប្រយោជន៍ដោយសារទ្រព្យសម្បត្តិរបស់អ្នកដទៃ ឬ ដោយសារពលកម្មអ្នកដទៃ ការបាត់បង់ផលប្រយោជន៍របស់អ្នកដទៃដោយសារការទទួលផលប្រយោជន៍នោះ ទំនាក់ទំនងនៃហេតុផលនៃការទទួលផលប្រយោជន៍ និង ការបាត់បង់ផលប្រយោជន៍ និង ភាពគ្មានមូលហេតុតាមផ្លូវច្បាប់ សរុបមាន ៤ ល័ក្ខខ័ណ្ឌចាំបាច់ (មាត្រា ៧០៣ នៃក្រមរដ្ឋប្បវេណី)។ ចំពោះរចនាសម្ព័ន្ធនៃល័ក្ខខ័ណ្ឌទាំងនេះ មានទ្រឹស្តីសិក្សាផ្សេងៗ ដូចជាទស្សនៈដែលពិចារណាដោយដាក់ល័ក្ខខ័ណ្ឌ ៣ ដំបូងបញ្ចូលគ្នា ជាដើម ក៏ប៉ុន្តែ ខ្លឹមសារនៃល័ក្ខខ័ណ្ឌគ្រឹះមិនមានអ្វីខុសគ្នាទេ ។

### គ) អានុភាពនៃការបង្កើតសេចក្តីចម្រើនដោយឥតហេតុ

បន្ទាប់មក នៅពេលដែលមានសេចក្តីចម្រើនដោយឥតហេតុកើតឡើង អ្នកដែលបានបាត់បង់ផលប្រយោជន៍ អាចទាមទារឲ្យអ្នកទទួលផលប្រយោជន៍សងមកវិញនូវផលប្រយោជន៍ដែលបានទទួល។ ក៏ប៉ុន្តែ ចំពោះទំហំផលប្រយោជន៍ដែលត្រូវសងនោះ វាខុសគ្នាដោយអាស្រ័យទៅលើថាតើអ្នកទទួលផលប្រយោជន៍នោះសុចរិត ឬ ទុច្ចរិត។ ប្រសិនបើអ្នកទទួលផលប្រយោជន៍សុចរិត (ករណីដែលអ្នកទទួលផលប្រយោជន៍មិនបានដឹងពីការដែលគ្មានមូលហេតុតាមផ្លូវច្បាប់ នៅពេលដែលទទួលផលប្រយោជន៍) គឺសងត្រឹមកម្រិតដែលផលប្រយោជន៍នៅមានសល់នាពេលបច្ចុប្បន្នទៅបានហើយ (មាត្រា ៧០៣ នៃក្រមរដ្ឋប្បវេណី)។ ផ្ទុយទៅវិញ ប្រសិនបើអ្នកទទួលផលប្រយោជន៍ទុច្ចរិត (ករណី

ដែលអ្នកទទួលផលប្រយោជន៍បានដឹងពីការដែលគ្មានមូលហេតុលើផ្លូវច្បាប់ នៅពេលដែលទទួលផលប្រយោជន៍) អ្នកទទួលផលប្រយោជន៍ត្រូវសងផលប្រយោជន៍ដែលបានទទួល និង ការប្រាក់ភ្ជាប់ទៅជាមួយផង (មាត្រា ៧០៤ នៃក្រមរដ្ឋប្បវេណី) ។

## (២) សេចក្តីចម្រើនដោយឥតហេតុដែលមានបុគ្គលបីនាក់ចូលរួម

### ក) សេចក្តីចម្រើនដោយឥតហេតុដែលមានតតិយជនចូលរួម

ក្នុងករណីដែលមិនមានតតិយជនចូលរួមនៅក្នុងទំនាក់ទំនងរវាងអ្នកទទួលបានផលប្រយោជន៍ និង អ្នកដែលបានបាត់បង់ផលប្រយោជន៍ទេ ភាពមាន ឬ គ្មានល័ក្ខខ័ណ្ឌដូចបានលើកឡើងខាងលើមិនមានបញ្ហាអ្វីជាធំដុំទេ។ ក៏ប៉ុន្តែ នៅក្នុងករណីដែលមានតតិយជនចូលរួមនៅក្នុងទំនាក់ទំនងនោះ បញ្ហាលំបាកស្តីពីភាពមាន ឬ គ្មានល័ក្ខខ័ណ្ឌ នឹងកើតមានឡើង។ ឧទាហរណ៍ថា នៅក្នុងករណីដែល P បានលួចប្រាក់ (ដោយឆបោក) ពី Q ហើយបានប្រគល់ប្រាក់នៅទៅឲ្យ R ជាការសងបំណុល បញ្ហានឹងកើតមានឡើងត្រង់ថាតើ Q អាចទាមទារទៅ R ឲ្យសងនូវផលប្រយោជន៍ដែលបានទទួលនោះបានដែរ ឬ ទេ។

**តារាងពន្យល់ ១០-១ ការសងដោយផ្អែកលើប្រាក់បន្លំពីគេ និងសេចក្តីចម្រើនដោយឥតហេតុ**



តាមពិត ដោយសារ Q អាចទាមទារសំណងការខូចខាត យោងតាមអំពើអនីត្យានុកូល ពី P ដែលបានលួច ដូច្នេះគឺអាចទទួលមកវិញនូវអ្វីដែលបានខូចខាត ដោយសារអំពើនោះបាន (ចំនួនទឹកប្រាក់ដែលត្រូវបានលួច)។ ប៉ុន្តែ ក្នុងករណីដែល P មិនមានលទ្ធភាពសងសំណងនោះទេ នោះនឹងមានបញ្ហាថាតើគេអាចទាមទារពី R ដែលបានទទួលផលប្រយោជន៍ជាក់ស្តែងដោយសារប្រាក់ដែល P បានលួច ឲ្យសងមកវិញនូវផលប្រយោជន៍នោះ ដោយសំអាងលើសេចក្តីចម្រើនដោយឥតហេតុដែរឬទេ។ ដោយសារ P ពុំមានទ្រព្យគ្រប់គ្រាន់ ហើយបានលួចប្រាក់ពី Q អាចចាត់ទុកថា R បានទទួលផលប្រយោជន៍ដែរ ព្រោះ R អាចទទួលការសង ដែលតាមពិត R មិនអាចទទួលបាន ។

ក៏ប៉ុន្តែ មានចម្ងល់មួយចំនួនចំពោះទស្សនៈដែលទទួលស្គាល់ការកើតឡើងនូវសេចក្តីចម្រើនដោយឥតហេតុ ។ R គ្រាន់តែទទួលការសងកាតព្វកិច្ចតែប៉ុណ្ណោះ ដូច្នេះ គេក៏អាចនិយាយថា សេចក្តីចម្រើនមិនបានកើតឡើងទេ (សិទ្ធិលើបំណុលរបស់ R នឹងត្រូវរលត់តាមការទទួលប្រាក់)។ម្យ៉ាងទៀតក៏មានចម្ងល់ថា R គ្រាន់តែបានទទួលប្រាក់ដែលជាការសងកាតព្វកិច្ច ដូច្នេះ គេមិនអាចនិយាយថាមានមូលហេតុតាមផ្លូវច្បាប់ថា R បានទទួលសេចក្តីចម្រើនឡើយ ។ បន្ថែមលើនេះ បើទោះជា R បានទទួលសេចក្តីចម្រើនក៏ពិតមែន ប៉ុន្តែ ក៏មានចម្ងល់ថាតើមានទំនាក់ទំនងនៃហេតុផលរវាងសេចក្តីចម្រើនរបស់ R និង ការខូចខាតរបស់ Q ដែរឬទេ។

ដូច្នេះគឺមានចម្ងល់ផ្សេងៗ ក៏ប៉ុន្តែ យុត្តិសាស្ត្រទទួលស្គាល់ការកើតឡើងនូវសេចក្តីចម្រើនដោយឥតហេតុចំពោះការសងដោយប្រាក់ដែលបានបន្លំដូចក្នុងករណីសិក្សាខាងលើ (សាលដីកាតុលាការកំពូល ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ១៩៧៤ កម្រងសាលក្រម ឬសាលដីការឿងក្តីរដ្ឋប្បវេណី ភាគទី ២៨ លេខ ៦ ទំព័រទី១២៤៣)។ យោងតាមទស្សនាទានទូទៅក្នុងសង្គម នេះគឺជាការផ្តោតសំខាន់ទៅលើទំនាក់ទំនងជិតស្និទ្ធរវាងការទទួលផលប្រយោជន៍របស់ R ដោយសារប្រាក់របស់ Q ។

## ខ) សិទ្ធិប្តឹងទាមទារវត្ថុដែលត្រូវបានផ្ទេរ

ដោយឡែក ជាឧទាហរណ៍នៃសេចក្តីចម្រើនដោយឥតហេតុដែលតតិយជនបានចូលរួម មានចំណុចមួយដែលគេហៅថា សិទ្ធិប្តឹងទាមទារវត្ថុដែលត្រូវបានផ្ទេរ។ ដូចជាក្នុងករណីដែល A បានជួលគ្រឿងចក្រសម្រាប់សាងសង់ដែលជាកម្មសិទ្ធិរបស់ Y ហើយបានជួល X ឲ្យជួសជុល ក្រោយពេលដែល X បានជួលជុលរួចហើយក៏បានប្រគល់ទៅឲ្យ A ក៏ប៉ុន្តែ A មិនបានបង់ថ្លៃជួសជុលទេ។ ក្នុងករណីដែល A បានក្ស័យធនជាក់ស្តែង ហើយមិនមានធនធានសម្រាប់សងថ្លៃឈ្នួលជួសជុលទេ នឹងមានបញ្ហាថាតើ X អាចទាមទារទៅ Y ឲ្យសងថ្លៃឈ្នួលជុសជុលក្នុងតម្លៃសមរម្យក្នុងលក្ខណៈជាការទាមទារឲ្យសងសេចក្តីចម្រើនដោយឥតហេតុបានដែរ ឬទេ ។

ក្នុងករណីនេះផងដែរ ការចាត់ទុកលក្ខខ័ណ្ឌនៃសេចក្តីចម្រើនដោយឥតហេតុត្រូវបានបំពេញដូចគ្នាទៅនឹងករណីនៃការសងប្រាក់ដែលបានដោយការឆបោកដែរ ឬ យ៉ាងណានោះ គឺជាបញ្ហា។ មានន័យថា តើមានការខូចខាតចំពោះ X ដែរឬទេ (X មានសិទ្ធិលើបំណុលលើ A ចំពោះថ្លៃជួសជុល) តើមានការកើតឡើងនូវផលប្រយោជន៍ចំពោះ Y ដែរឬទេ (ប្រសិនបើ A មានករណីយកិច្ចជួសជុលដោយសារទំនាក់ទំនងរវាង Y និង A ដូច្នេះ គេអាចគិតបានថា គ្មានផលប្រយោជន៍ណាមួយកើតឡើងចំពោះ Y ទេ) ហើយបើទោះបីជាផលប្រយោជន៍ចំពោះ Y ក៏ដោយ ក៏មិនអាចនិយាយបានថាមានហេតុនិងផលតាមច្បាប់បានដែរ (ដោយគេអាចគិតបានថា Y គ្រាន់តែទទួលបានវិញនូវការសងតាមស្ថានភាពដើមនូវគ្រឿងចក្រសម្រាប់សាងសង់ដែលបានជួលតែប៉ុណ្ណោះ) ដូច្នេះ ចំពោះការដែលថាទំនាក់ទំនងនៃហេតុផលនៃការខូចខាតរបស់ X និងផលប្រយោជន៍របស់ Y មានដែរ ឬទេ ជាដើមនោះ នឹងក្លាយទៅជាបញ្ហា។

ក្នុងករណីបែបនេះ យុត្តិសាស្ត្ររបស់តុលាការទទួលស្គាល់នូវទំនាក់ទំនងនៃហេតុផលដោយផ្ទាល់រវាងការខូចខាតរបស់ X និង ផលប្រយោជន៍របស់ Y ហើយទទួលស្គាល់នូវការទាមទារឲ្យសងសេចក្តីចម្រើនដោយឥតហេតុ (សាលដីកាតុលាការកំពូលចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ១៩៧០ ក្នុងកម្រងសាលក្រម ឬសាលដីការឿងក្តីរដ្ឋប្បវេណី ភាគ ២៤ លេខ ៧ ទំព័រទី ៩០៩)។ ក៏ប៉ុន្តែ ចំពោះទ្រឹស្តីសិក្សាវិញ មានទស្សនៈដែលយល់ស្រប និង ទស្សនៈដែលរិះគន់ចំពោះយុត្តិសាស្ត្រនេះ ។

**តារាងពន្យល់ ១០-២ សិទ្ធិប្តឹងទាមទារវត្ថុដែលត្រូវបានផ្ទេរ**



## (៣) ការផ្តល់តាវកាលិកដោយមូលហេតុខុសច្បាប់

### ក) ការផ្តល់តាវកាលិកដោយមូលហេតុខុសច្បាប់

ឧទាហរណ៍ នៅក្នុងការភ្នាល់ល្បែងស៊ីសង បើទោះជាអ្នកចាញ់យល់ព្រមបង់ប្រាក់ភ្នាល់ក៏ដោយ ក៏អ្នកឈ្នះការភ្នាល់នោះមិនអាចទាមទារឲ្យអ្នកចាញ់បង់ប្រាក់ដែលបានសន្យានោះបានដែរ។ ដោយសារតែសកម្មភាពភ្នាល់គឺជាសកម្មភាពដែលខុសច្បាប់ ហើយការព្រមព្រៀងបង់ប្រាក់ភ្នាល់ ត្រូវបានចាត់ទុកថាមានកម្មវត្ថុផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ និង ត្រូវចាត់ទុកជាមោឃៈ តាមមាត្រា ៩០ នៃក្រមរដ្ឋប្បវេណី (ចំពោះសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ សូមមើលជំពូកទី ៤)។

ក៏ប៉ុន្តែ ប្រសិនបើអ្នកចាញ់បានបង់ប្រាក់ភ្នាល់ទៅអ្នកឈ្នះរួចហើយ គាត់មិនអាចទាមទារយកប្រាក់ដែលបានបង់ហើយនោះមកវិញដោយផ្អែកលើមូលហេតុថា ការព្រមព្រៀងចំពោះសកម្មភាពភ្នាល់ត្រូវចាត់ទុកជាមោឃៈបានទេ។ មូលហេតុត្រង់នេះគឺត្រូវនឹងបញ្ញត្តិស្តីពីការផ្តល់តាវកាលិកដោយមូលហេតុខុសច្បាប់ដែលមានចែងក្នុងមាត្រា ៧០៨ នៃក្រមរដ្ឋប្បវេណី។ មានន័យថា មាត្រា ៧០៨ នៃក្រមរដ្ឋប្បវេណីបញ្ញត្តថា បុគ្គលដែលបានផ្តល់តាវកាលិកដោយមូលហេតុខុសច្បាប់ មិនអាចទាមទារឲ្យសងវិញនូវតាវកាលិកដែលបានផ្តល់ឲ្យហើយនោះទេ ដោយសារតែបញ្ញត្តិនេះត្រូវបានយកមកអនុវត្តចំពោះប្រាក់ភ្នាល់ដែលបានបង់ដោយសារការភ្នាល់នោះផងដែរ ។

ដូចបានលើកឡើងមុននេះ ជាគោលការណ៍ ក្នុងករណីដែលមានការប្រគល់នូវប្រាក់ ឬ ទ្រព្យ ដោយផ្អែកលើកិច្ចសន្យាដែលមោឃៈ អ្នកដែលបានទទួលនូវប្រាក់ ឬ ទ្រព្យនោះ ត្រូវសងវិញដោយសារជាសេចក្តីចម្រើនដោយឥតហេតុ (មាត្រា ៧០៣ នៃក្រមរដ្ឋប្បវេណី) ។ ក៏ប៉ុន្តែ ចំពោះករណីនៃការប្រគល់នូវប្រាក់ ឬ ទ្រព្យ ដោយអនុលោមទៅតាមការព្រមព្រៀងដែលមានកម្មវត្ថុផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ការទទួលស្គាល់នូវការទាមទារឲ្យសងនូវប្រាក់ ឬ ទ្រព្យទាំងនោះដោយសារជាសេចក្តីចម្រើនដោយឥតហេតុ គឺប្រៀបបីដូចជាច្បាប់ជួយដល់អ្នកដែលធ្វើសកម្មភាពដែលផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អអញ្ចឹង ដែលត្រូវបានគិតថាមិនមែនជាការសមរម្យទេ។ ដូច្នេះហើយបានជាមាត្រា ៧០៨ នៃក្រមរដ្ឋប្បវេណី ចាត់ទុកការផ្តល់នូវប្រាក់ ឬ ទ្រព្យបែបនោះជាការផ្តល់តាវកាលិកដែលមានមូលហេតុខុសច្បាប់ ហើយបដិសេធការទាមទារឲ្យសងនោះ ។

ជាសរុបមកគឺថា មាត្រា ៩០ និងមាត្រា ៧០៨ នៃក្រមរដ្ឋប្បវេណី បញ្ញត្តនូវខ្លឹមសារដែលមិនផ្តល់នូវ ការសង្គ្រោះតាមច្បាប់ចំពោះជនទាំងឡាយដែលបានធ្វើសកម្មភាពដែលប្រាស់ចាកពីសង្គម

ដោយបដិសេធនូវការទាមទារឲ្យអនុវត្តទៅតាមការព្រមព្រៀង និង បដិសេធនូវការទាមទារឲ្យធ្វើបដិទាននូវអ្វីដែលបានអនុវត្តហើយ ។

ក៏ប៉ុន្តែ ក្នុងករណីដែលមូលហេតុខុសច្បាប់ធ្លាក់ទៅលើអ្នកទទួលផលប្រយោជន៍ទាំងស្រុង ហើយភាពខុសច្បាប់មិនមែនជារបស់អ្នកផ្តល់តាវកាលិកទេ ជាករណីលើកលែង ច្បាប់ទទួលស្គាល់នូវការទាមទារឲ្យសងនូវសេចក្តីចម្រើនដោយឥតហេតុ (វាក្យខណ្ឌទី ២ មាត្រា ៧០៨ នៃក្រមរដ្ឋប្បវេណី) ។ មូលហេតុគឺដោយសារតែកម្រិតនៃការត្រូវបន្ទោសពីសង្គមចំពោះអ្នកផ្តល់តាវកាលិកមិនមានអ្វីជាធំដុំនោះទេ។ ដោយសារតែសកម្មភាពដែលកេងយកចំណេញហួសហេតុលើស្ថានភាពទន់ខ្សោយ និង ភាពខ្វះការពិចារណារបស់ភាគីម្ខាង (សកម្មភាពកេងចំណេញ) គឺជាសកម្មភាពដែលផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ និង ត្រូវចាត់ទុកជាមោឃៈ និង អាចគិតបានថាមូលហេតុដែលផ្ទុយច្បាប់ត្រូវធ្លាក់ទាំងស្រុងទៅលើអ្នកទទួលបានផលប្រយោជន៍ ទើបការទាមទារឲ្យសងតាវកាលិកដែលបានផ្តល់ហើយអាចទទួលស្គាល់បាន ដោយផ្អែកលើមូលហេតុទាំងអស់នេះ។ ក៏ប៉ុន្តែ យុត្តិសាស្ត្រធ្វើការប្រៀបធៀបនូវភាពផ្ទុយច្បាប់របស់អ្នកទទួលផលប្រយោជន៍ និង របស់អ្នកផ្តល់តាវកាលិក ហើយក្នុងករណីដែលភាពផ្ទុយច្បាប់របស់អ្នកទទួលផលប្រយោជន៍មានទំហំធំជាងភាពផ្ទុយច្បាប់របស់អ្នកផ្តល់តាវកាលិក គឺទទួលស្គាល់នូវការទាមទារឲ្យសងនូវសេចក្តីចម្រើនដោយឥតហេតុរបស់អ្នកផ្តល់តាវកាលិក ។

✎ ការបើកប្រាក់បញ្ញើលើស និង សេចក្តីចម្រើនដោយឥតហេតុ--ការពិចារណាតាមរយៈករណីសិក្សា

ក្នុងករណីសិក្សា ផលប្រយោជន៍ ១០ ម៉ឺនយ៉េន បានកើតឡើងចំពោះ A ហើយការខាតបង់ផលប្រយោជន៍ចំនួន ១០ ម៉ឺនយ៉េន បានកើតមានចំពោះធនាគារ B។ ដូច្នេះ ដោយសារតែមិនមែនជាការបើកប្រាក់ឲ្យ ២០ ម៉ឺន ដូចមានតួលេខនៅក្នុងសៀវភៅគណនីធនាគារ ផលប្រយោជន៍ដែល A ទទួលបាននោះគឺច្បាស់ណាស់ហើយថា គ្មានមូលហេតុតាមផ្លូវច្បាប់ទេ។ ម្យ៉ាងវិញទៀត ចំពោះអត្ថិភាពនៃទំនាក់ទំនងរវាងហេតុ និង ផលរវាងការខូចខាតរបស់ធនាគារ B និង ផលប្រយោជន៍ដែល A ទទួលបានក៏មានហើយដែរ។ បានសេចក្តីថា ធនាគារ B អាចទាមទារឲ្យ A សងសេចក្តីចម្រើនដោយឥតហេតុនោះបាន។ ចំពោះទំហំនៃផលប្រយោជន៍ដែលអាចទាមទារឲ្យសងវិញបាន ប្រសិនបើ A បានដឹងថាបានទទួលប្រាក់ លើសចំនួន ១០ ម៉ឺន គឺត្រូវសងចំនួន ១០ ម៉ឺននោះ បូកជាមួយនឹងការប្រាក់ (មាត្រា ៧០៤ នៃក្រមរដ្ឋប្បវេណី) ក៏ប៉ុន្តែ ប្រសិនបើ A មិនបានដឹងអំពីប្រាក់លើស ១០ ម៉ឺនទេ ហើយបានចាយវាយ (ក្នុងភាពជាក់ស្តែង ការដែលមិនបានដឹងថាលើសនោះ គឺមិនអាចមានទេ) គឺអាចទាមទារឲ្យសងបានត្រឹមប្រាក់ដែលនៅសល់ប៉ុណ្ណោះ (មាត្រា ៧០៣ នៃក្រមរដ្ឋប្បវេណី)។ ក៏ប៉ុន្តែ ចំពោះចំណុចពេលវិនិច្ឆ័យអំពីភាពសុចរិត ឬ ទុច្ចរិត គឺពេលទទួលប្រយោជន៍ (នៅក្នុងករណីសិក្សាគឺចំណុចពេលដែលទទួលបានការបើកឲ្យនូវប្រាក់បញ្ញើ) ក៏ប៉ុន្តែ បើទោះបីជានៅពេលទទួលប្រយោជន៍

នោះសុចរិតក៏ដោយ ប្រសិនបើនៅពេលក្រោយពីនោះមក បានក្លាយទៅជាទុច្ចរិត (នៅពេលដែលក្រោយមកបានដឹងថាប្រាក់នោះលើស) ត្រូវទទួលកាតព្វកិច្ចសងក្នុងនាមជាបុគ្គលទុច្ចរិត ចាប់ពីពេលដែលបានក្លាយជាទុច្ចរិត ។

Khmer Law's Association

# ជំពូកទី ១១

## ការសងបំណុល

**១ ការធានាបំណុល (ការធានាដោយវត្ថុ និង ការធានាដោយបុគ្គល)**

**២ ការសងបំណុល (ការអនុវត្តកាតព្វកិច្ច)**

**៣ រូបិយាណត្តិ និង មូលប្បទានប័ត្រ**

**៤ ការផ្ញើប្រាក់តាមធនាគារ**

**៥ ប័ណ្ណឥណទាន ជាដើម**

(១) អត្ថន័យនៃរូបិយាណត្តិ និង មូលប្បទានប័ត្រ

(២) ច្បាប់ស្តីពីរូបិយាណត្តិ និង ច្បាប់ស្តីពីមូលប្បទានប័ត្រ

✎ របៀបបង់ថ្លៃលក់ទិញ--ការពិចារណាតាមរយៈករណីសិក្សា

Khmer Law's Association

**ករណីសិក្សា៖** A បានអានព័ត៌មានក្នុងទស្សនាវដ្ដី ហើយបានធ្វើការបញ្ជាទិញគ្រឿងសង្ហារិមពីក្រុមហ៊ុន B។ ក្រុមហ៊ុន B បានប្រគល់ផលិតផលទៅតាមការបញ្ជាទិញរបស់ A រួចហើយបានទាមទារថ្លៃលក់ទិញនោះ។ តើ A អាចបង់ថ្លៃលក់ទិញដោយរបៀបណាបាន ?

## ១ ការធានាបំណុល (ការធានាដោយវត្ថុ និង ការធានាដោយបុគ្គល)

### ក) ការធានាបំណុល

ដូចដែលបានរៀបរាប់រួចមកហើយ សិទ្ធិប្រត្យក្សគឺជាសិទ្ធិគ្រប់គ្រងវត្ថុដោយចំពោះ ដោយឡែកចំពោះសិទ្ធិលើបំណុលវិញគឺជាសិទ្ធិដែលអាចទាមទារឲ្យបុគ្គលដទៃធ្វើសកម្មភាពអ្វីមួយ (សេចក្ដីលម្អិតសូមអានជំពូកទី ៣)។ ដោយហេតុនោះ នៅក្នុងករណីដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ចនោះទេ ម្ចាស់បំណុលអាចបង្ខំឲ្យធ្វើការអនុវត្តកាតព្វកិច្ចនោះ ព្រមទាំងអាចទាមទារសំណងការខូចខាតបាន (សេចក្ដីលម្អិត សូមអានជំពូកទី ៧)។ នៅក្នុងករណីនេះ ប្រសិនបើកូនបំណុលគ្មានទ្រព្យធនដើម្បីសងសំណងការខូចខាតទៅម្ចាស់បំណុលទេ គឺទីបំផុតម្ចាស់បំណុលមិនអាចទទួលបាននូវសំណងការខូចខាតទេ។ អាចនិយាយម្យ៉ាងទៀតបានថា ចំពោះម្ចាស់បំណុល ទ្រព្យសម្បត្តិរបស់កូនបំណុលគឺជាអ្នកកំណត់ជាចុងក្រោយថាអាចសងបំណុលបាន ឬ មិនបាន ។

ករណីដូចខាងលើនេះ ប្រសិនបើយើងធ្វើការប្រៀបធៀបសិទ្ធិលើបំណុលទៅនឹងសិទ្ធិប្រត្យក្សសិទ្ធិលើបំណុលគឺសិទ្ធិដែលខ្សោយ ក៏ប៉ុន្តែសម្រាប់ជាការប៉ះប៉ូវទៅដល់ភាពកម្សោយនោះ គឺមានរបបធានា។ មានន័យថា បើទោះជាក្នុងករណីដែលកូនបំណុលគ្មានទ្រព្យ ហើយមិនអាចសងបំណុលបានក៏ដោយ ម្ចាស់បំណុលអាចចាត់នូវវិធានការជាមុន ដើម្បីសម្រេចនូវផលប្រយោជន៍ដែលកំណត់ដោយសិទ្ធិលើបំណុលរបស់ខ្លួន។ របបបែបនេះគេហៅថា របបធានាសិទ្ធិលើបំណុល។ បើនិយាយឲ្យជាក់លាក់គឺមានករណីដែលកូនបំណុល ឬ តតិយជនក្រៅពីកូនបំណុលយកទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់ខ្លួនមកដាក់ជាប្រាតិភោគ និង ករណីដែលតតិយជនក្រៅពីកូនបំណុលយកសាធនភាពរបស់ខ្លួនដាក់ជាប្រាតិភោគ (បើទោះបីជាយើងថាសាធនភាពក៏ដោយ ក៏គង់តែទ្រព្យសម្បត្តិទាំងអស់របស់តតិយជននឹងក្លាយទៅជាប្រាតិភោគដដែល)។ ការធានាតាមរបៀបដំបូងអាចហៅថា ជាការធានាដោយវត្ថុ ដោយឡែកការធានាតាមរបៀបក្រោយនេះវិញហៅថា ការធានាដោយបុគ្គល។ របបធានារបៀបនេះត្រូវបានប្រើប្រាស់ច្រើនបំផុតនៅក្នុងករណីខ្ចីប្រាក់។ នៅពេលដែល X ខ្ចីប្រាក់ពី Y ដោយយកអចលនវត្ថុដែលជាកម្មសិទ្ធិរបស់ X ដាក់ជាហ៊ីប៉ូតែក គឺជាឧទាហរណ៍នៃករណីការធានាដោយវត្ថុ ហើយការដែល Z ក្លាយទៅជាអ្នកធានា គឺជាឧទាហរណ៍នៃករណីនៃការធានាដោយបុគ្គល (សេចក្ដីដែលនឹងលើកយកមកពិភាក្សាខាងក្រោម គឺជាករណីនៃសិទ្ធិលើបំណុលដែលមានគោលបំណងឲ្យសងជាប្រាក់បែបនេះ )។

## ខ) ការធានាដោយវត្ថុ (សិទ្ធិប្រាតិភោគប្រត្យក្ស)

ឧទាហរណ៍គំរូដែលត្រូវបានប្រើជាញឹកញាប់ក្នុងករណីនៃការធានាដោយវត្ថុ ដោយយកទ្រព្យសម្បត្តិរបស់កូនបំណុល ឬ ទ្រព្យសម្បត្តិរបស់តតិយជនក្រៅពីកូនបំណុលមកធ្វើជាប្រាតិភោគ គឺសិទ្ធិប្រាតិភោគប្រត្យក្ស។ មានន័យថា នៅក្នុងករណីដែលម្ចាស់បំណុលមានសិទ្ធិប្រាតិភោគប្រត្យក្សលើទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់កូនបំណុល ឬ ទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់តតិយជនក្រៅពីកូនបំណុល នៅពេលដែលកូនបំណុលមិនសងបំណុលទេ ម្ចាស់បំណុលអាចខ្ចីកម្លាំងរបស់តុលាការដើម្បីលក់ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគ និង អាចប្រមូលយកប្រាក់បំណុលពីថ្លៃលក់នោះបាន។ នេះគឺជាការគ្រប់គ្រងលើតម្លៃនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃប្រាតិភោគ ហើយដរាបណាតម្លៃនោះនៅរក្សាដដែល ម្ចាស់សិទ្ធិលើបំណុលអាចសម្រេចនូវសិទ្ធិលើបំណុលរបស់ខ្លួនដោយជាក់ច្បាស់បាន។

សិទ្ធិប្រាតិភោគប្រត្យក្សដែលមានចែងជាក់លាក់នៅក្នុងក្រមរដ្ឋប្បវេណី គឺសិទ្ធិឃាត់ទុក ឯកសិទ្ធិ សិទ្ធិលើការបញ្ចាំ និង ហ៊ីប៉ូតែក។ សិទ្ធិឃាត់ទុក គឺសំដៅទៅលើសិទ្ធិដែលអាចឃាត់ទុកវត្ថុបានរហូតដល់ពេលទទួលបានការសងបំណុល ក្នុងករណីបុគ្គលដែលកាន់កាប់វត្ថុរបស់អ្នកដទៃមានសិទ្ធិលើបំណុលដែលបានកើតឡើងចំពោះវត្ថុដែលខ្លួនបានកាន់កាប់នោះ (មាត្រា ២៩៥ នៃក្រមរដ្ឋប្បវេណី)។ ឧទាហរណ៍ ដូចជាក្នុងករណីដែលអ្នកប្រកបរបរជួសជុលរថយន្ត អាចបដិសេធការប្រគល់រថយន្តដែលបានជួសជុលរួច រហូតដល់ពេលដែលភ្ញៀវដែលបានយករថយន្តមកជួសជុលបានបង់ប្រាក់ថ្លៃជួសជុលរួចជាដើម។ ឯកសិទ្ធិ គឺសំដៅទៅលើសិទ្ធិដែលអ្នកមានសិទ្ធិលើបំណុលជាកំណត់មួយអាចទទួលបាននូវការសងបំណុលដោយមានអាទិភាពជាងម្ចាស់សិទ្ធិលើបំណុលដទៃទៀត (មាត្រា ៣០៣ នៃក្រមរដ្ឋប្បវេណី)។ ជាឧទាហរណ៍ ចំពោះសិទ្ធិលើបំណុលដែលជាប្រាក់ឈ្នួល នៅក្នុងករណីដែលប្រាក់ឈ្នួលនោះមិនត្រូវបានបង់ទេ ភតិបតីនៃអគារអាចទទួលបាននូវការសងដោយមានអាទិភាពពីចលនវត្ថុដែលភតិកៈបានបំពាក់ទៅនឹងអគារនោះ។ សិទ្ធិលើការបញ្ចាំ គឺសំដៅទៅលើសិទ្ធិដែលម្ចាស់បំណុលដែលកាន់កាប់វត្ថុដែលបានដាក់ជាប្រាតិភោគដោយកូនបំណុលអាចទទួលបានការសងពីវត្ថុនោះដោយមានអាទិភាព ក្នុងករណីដែលបំណុលមិនត្រូវបានសង (មាត្រា ៣៥២ នៃក្រមរដ្ឋប្បវេណី)។ ឧទាហរណ៍ ដូចជាក្នុងករណីដែលអ្នកខ្ចីប្រាក់បានយកចលនវត្ថុដែលជាកម្មសិទ្ធិរបស់ខ្លួនទៅដាក់បញ្ចាំជាមួយអ្នកឲ្យខ្ចីនៅពេលដែលខ្លួនខ្ចីប្រាក់។ ហ៊ីប៉ូតែក គឺសំដៅទៅលើសិទ្ធិដែលអាចទទួលការសងដោយមានអាទិភាពពីអចលនវត្ថុដែលត្រូវបានដាក់ជាប្រាតិភោគដោយមិនមានការផ្ទេរការកាន់កាប់ពីកូនបំណុល នៅក្នុងករណីដែលបំណុលមិនត្រូវបានសង (មាត្រា ៣៦៩ នៃក្រមរដ្ឋប្បវេណី)។ ឧទាហរណ៍ ដូចជាក្នុងករណីដែលអ្នកខ្ចីប្រាក់បានយកអចលនវត្ថុដែលជាកម្មសិទ្ធិរបស់ខ្លួនទៅដាក់ជាប្រាតិភោគចំពោះអ្នកឲ្យខ្ចី ។

សិទ្ធិឃាត់ទុក និង ឯកសិទ្ធិគឺជាសិទ្ធិប្រាតិភោគប្រត្យក្សដែលកើតឡើងទៅតាមការកំណត់របស់ច្បាប់ រីឯសិទ្ធិលើការបញ្ចាំ និង ហ៊ីប៉ូតែកវិញ គឺជាសិទ្ធិប្រាតិភោគប្រត្យក្សដែលកើតឡើងទៅតាមការព្រមព្រៀងរវាងម្ចាស់បំណុល និង អ្នកបង្កើតសិទ្ធិប្រាតិភោគ (ជាធម្មតាគឺកូនបំណុល ក៏ប៉ុន្តែវាក៏អាចមានករណីដែលអ្នកបង្កើតសិទ្ធិប្រាតិភោគនោះជាតតិយជនដែរ )នោះ ។

## គ) ការធានាដោយបុគ្គល (ការធានា)

ករណីដែលកើតមានជាញឹកញាប់បំផុតចំពោះការដែលសាធនភាព (ទ្រព្យសម្បត្តិទាំងអស់) របស់តតិយជនក្រៅពីកូនបំណុលក្លាយទៅជាប្រាតិភោគ គឺការធានា។ មានន័យថា ជាករណីដែលតតិយជនក្រៅពីកូនបំណុលធ្វើការធានាសងបំណុលជំនួសកូនបំណុល នៅក្នុងករណីដែលកូនបំណុលមិនសងបំណុលទេ (កថាខណ្ឌទី ១ មាត្រា ៩៤៦ នៃក្រមរដ្ឋប្បវេណី)។ បុគ្គលដែលធានា ត្រូវបានហៅថាអ្នកធានា។ ក៏ប៉ុន្តែ កិច្ចសន្យាធានានឹងមិនកើតអានុភាពទេ ប្រសិនបើមិនបានធ្វើជាលាយលក្ខណ៍អក្សរ (កថាខណ្ឌទី ២ នៃមាត្រាដដែល)។ ក៏ប៉ុន្តែ ចំពោះកិច្ចសន្យាដែលបានធ្វើឡើងដោយការចុះបញ្ជីអេឡិកត្រូនិក ត្រូវចាត់ទុកថាជាកិច្ចសន្យាដែលបានធ្វើឡើងជាលាយលក្ខណ៍អក្សរ (កថាខណ្ឌទី ៣ នៃមាត្រាដដែល) ។

បើទោះបីជាកូនបំណុលក្លាយជាអសោធានីយក៏ដោយ ក៏ម្ចាស់បំណុលអាចលៃលកសម្រេចឲ្យបានយ៉ាងជាក់លាក់នូវសិទ្ធិលើបំណុលរបស់ខ្លួនបានដែរ ប្រសិនបើអ្នកធានាមានសាធនភាពគ្រប់គ្រាន់សម្រាប់សងបំណុល។ ដោយសារតែអ្នកធានាជាបុគ្គលដែលត្រូវសងបំណុលជំនួសកូនបំណុល (លក្ខណៈបែបនោះត្រូវបាន ហៅថាភាពបំពេញបន្ថែម) បើទោះជាម្ចាស់បំណុលបានទាមទារឲ្យខ្លួនអនុវត្តកាតព្វកិច្ចក៏ដោយ ក៏អ្នកធានាអាចធ្វើការអះអាងជាការតវ៉ាបានដែរថា ម្ចាស់បំណុលត្រូវទាមទារពីកូនបំណុលជាមុនសិន និង ត្រូវទទួលការសងពីទ្រព្យសម្បត្តិរបស់កូនបំណុលជាមុនសិន (សិទ្ធិនីមួយៗនេះហៅថា សិទ្ធិតវ៉ាឲ្យធ្វើការដាស់តឿន និង សិទ្ធិតវ៉ាឲ្យធ្វើការស្រាវជ្រាវ ដែលមានបញ្ញត្តនៅក្នុងមាត្រា ៩៥២ និង មាត្រា៩៥៣ នៃក្រមរដ្ឋប្បវេណី)។ នៅក្នុងករណីដែលអ្នកធានាបានធ្វើការធានាដោយសាមគ្គីភាព (ហៅថា ការធានាដោយសាមគ្គីភាព) សិទ្ធិតវ៉ាបែបនោះគឺមិនមានឡើយ បើទោះជាមានករណីដែលម្ចាស់បំណុលបានទាមទារឲ្យអ្នកធានាអនុវត្តកាតព្វកិច្ច ដោយពុំបានទាមទារទៅកូនបំណុលក៏ដោយ ក៏អ្នកធានាត្រូវតែអនុវត្តកាតព្វកិច្ចធានាទៅតាមការទាមទារនោះដែរ (មាត្រា ៩៥៤ នៃក្រមរដ្ឋប្បវេណី) ។

ចំពោះករណីនៃការធានាដោយវត្ថុវិញ ម្ចាស់បំណុលអាចទទួលបានការសងពីវត្ថុដែលជាកម្មវត្ថុនៃការធានានោះដោយមានអាទិភាព។ ផ្ទុយទៅវិញ នៅក្នុងករណីនៃការធានាដោយបុគ្គល ម្ចាស់បំណុល

អាចទទួលបានការសងពីទ្រព្យសម្បត្តិរបស់តតិយជន (អ្នកធានា) ក៏ប៉ុន្តែ ពុំមែនមានន័យថាអាចទទួលបានការសងនោះដោយមានអាទិភាពជាងម្ចាស់បំណុលដទៃទៀតនោះទេ ។

### ឃ) ការធានាបំណុលអណ្តែត

ការធានាបំណុលដែលនឹងកើតនាពេលអនាគតដោយសារការធ្វើកិច្ចការជួញដូរជាបន្តបន្ទាប់ ហៅថាការធានាបំណុលអណ្តែត ក៏ប៉ុន្តែ នៅក្នុងភាពជាក់ស្តែង ការធានាបំណុលអណ្តែតសាកលដែលគ្មានកំណត់ចំនួននៃការធានា និង អំឡុងពេលនៃការធានា ត្រូវបានគេប្រើប្រាស់។ នៅក្នុងការធានាបំណុលអណ្តែតសាកលបែបនេះ ការទទួលខុសត្រូវរបស់អ្នកធានា គឺអាចនឹងធ្ងន់លើសពីការរំពឹងទុករបស់អ្នកធានា ហើយភាពរងគ្រោះបែបនេះត្រូវបានគេលើកឡើង។ ដោយហេតុនោះ យោងទៅលើវិសោធនកម្មក្រមរដ្ឋប្បវេណីឆ្នាំ ២០០៤ ចំពោះបំណុលលើប្រាក់កម្ចី ក្នុងករណីដែលអ្នកដែលនឹងក្លាយទៅជាអ្នកធានាគឺជាបុគ្គល ការធានានោះមិនមានសុពលភាពទេ ប្រសិនបើមិនបានកំណត់នូវចំនួនទឹកប្រាក់នៃការធានាទេ (កថាខណ្ឌទី ២ មាត្រា ៤៦៥-២ នៃក្រមរដ្ឋប្បវេណី)។ ម្យ៉ាងវិញទៀត ចំពោះអំឡុងពេលនៃការធានាវិញ អាចធ្វើការកំណត់បានដោយមិនឲ្យលើសពីអំឡុងពេល ៥ ឆ្នាំ ហើយប្រសិនបើមិនបានកំណត់អំឡុងពេលទេ គឺត្រូវចាត់ទុកថាប្រាក់ដើមត្រូវចូលជាស្ថាពរក្នុងអំឡុងពេល ៣ ឆ្នាំ (កថាខណ្ឌទី ១ និង កថាខណ្ឌទី ២ នៃមាត្រា ៤៦៥-៣ នៃក្រមរដ្ឋប្បវេណី)។ ប្រាក់ដើមត្រូវចូលជាស្ថាពរ មានន័យថា មានតែកាតព្វកិច្ចដែលមានអត្ថិភាពត្រឹមពេលដែលចូលជាស្ថាពរប៉ុណ្ណោះដែលក្លាយទៅជាកម្មវត្ថុនៃកាតព្វកិច្ចធានា។ ម្យ៉ាងវិញទៀត នៅពេលដែលកូនបំណុលនៃកាតព្វកិច្ចចម្បង ឬ អ្នកធានា ទទួលបានដីកាសម្រេចចាប់ផ្តើមនីតិវិធីធនក្ស័យ ឬ នៅពេលដែលបុគ្គលទាំងនេះទទួលមរណភាព ជាដើម ប្រាក់ដើមត្រូវចូលជាស្ថាពរ (មាត្រា ៤៦៥-៤ នៃក្រមរដ្ឋប្បវេណី) ។

## ២ ការសងបំណុល (ការអនុវត្តកាតព្វកិច្ច)

### ក) របៀបសងបំណុល

អាស្រ័យទៅតាមកិច្ចសន្យា ភាគីម្ខាង ឬ ភាគីទាំងសងខាងត្រូវទទួលបន្ទុកចំពោះកាតព្វកិច្ច ហើយដូចដែលបានលើកឡើងពីខាងលើ ភាគីដែលទទួលបន្ទុកចំពោះកាតព្វកិច្ច ត្រូវអនុវត្តកាតព្វកិច្ចនោះទៅតាមខ្លឹមសារនៃកិច្ចសន្យានោះ (សេចក្តីលម្អិត សូមអានជំពូកទី៧) ។ អាចនិយាយបានម្យ៉ាងទៀតថា ចំពោះបញ្ហាថាតើត្រូវអនុវត្តកាតព្វកិច្ចនោះយ៉ាងដូចម្តេចនោះ ជាទូទៅគឺត្រូវកំណត់ដោយគូភាគី។ ក៏ប៉ុន្តែ ចំពោះចំណុចជាមូលដ្ឋាន ឬ ចំពោះចំណុចសំខាន់ៗវិញ បើទោះបីជាមានការព្រមព្រៀងច្បាស់លាស់ក៏ដោយ ក៏មានករណីមិនតិចទេដែលចំណុចជាលម្អិតជាក់លាក់មួយចំនួនមិនដែលត្រូវបានធ្វើការព្រមព្រៀង។ ជាឧទាហរណ៍ ដូចជានៅពេលដែលខ្លឹមសារនៃកិច្ចសន្យានោះគឺជាការបង់

ប្រាក់ (កាតព្វកិច្ចបែបនេះ ហៅថា កាតព្វកិច្ចជាប្រាក់) បើទោះបីជាការព្រមព្រៀងអំពីចំនួនទឹកប្រាក់ និង អំឡុងពេលកំណត់ត្រូវសងក៏ដោយ ក៏អាចមានការដែលមិនបានធ្វើការព្រមព្រៀងគ្នាអំពីវិធីបង់ប្រាក់នោះដែរ។

ក៏ប៉ុន្តែវិធីជាទូទៅមួយ គឺមានវិធីបង់ជាសាច់ប្រាក់ដោយផ្ទាល់ ។ ក្នុងករណីដែលយើងទាំងអស់គ្នាទិញទំនិញនៅទីផ្សារ ឬ ទទួលទានអាហារនៅភោជនីយដ្ឋាន គឺមានករណីមួយចំនួនធំដែលបង់ជាសាច់ប្រាក់ ក៏ប៉ុន្តែ ការមិនអនុវត្តតាមការបង់ជាសាច់ប្រាក់ក៏មានករណីមិនតិចដែរ នៅក្នុងករណីដែលទឹកប្រាក់មានចំនួនច្រើន ឬ ករណីដែលភាគីម្ខាងទៀតនៅតំបន់ឆ្ងាយដាច់ស្រយាល ជាដើម។ ដោយហេតុនេះហើយបានជាវិធីបង់ផ្សេងៗជាច្រើនដូចជា វិធីបង់តាមរូបិយាណត្តិ និង តាមមូលប្បទានប័ត្រ វិធីបង់ដោយការផ្ទេរចំនួនទឹកប្រាក់ទៅក្នុងគណនីរបស់ភាគីម្ខាងទៀត ឬ វិធីបង់ដោយប្រើប្រាស់ប័ណ្ណឥណទានជាដើម ត្រូវបានជ្រើសរើសយក ។

## ៣ រូបិយាណត្តិ និង មូលប្បទានប័ត្រ

### (១) អត្ថន័យនៃរូបិយាណត្តិ និង មូលប្បទានប័ត្រ

#### ក) របបឧបករណ៍ដែលអាចជួញដូរបាន

រូបិយាណត្តិ និង មូលប្បទានប័ត្រ ជាវត្ថុដែលត្រូវបានប្រើប្រាស់ជាមធ្យោបាយបង់បំណុលជាប្រាក់ដែលជាប្រវត្តិសាស្ត្រ វាមានតាំងពីយូរយារណាស់មកហើយ។ រូបិយាណត្តិ និង មូលប្បទានប័ត្រ គឺជាឧបករណ៍ដែលអាចជួញដូរបានដូចជា ប័ណ្ណភាគហ៊ុន ប័ណ្ណប្តូរយកទំនិញ និង ប័ណ្ណដឹកជញ្ជូន ជាដើមដែរ។ ឧបករណ៍ដែលអាចជួញដូរបាន គឺប័ណ្ណដែលមានបង្ហាញពីសិទ្ធិទាមទារឲ្យបង់សងជាប្រាក់ ឬ សិទ្ធិទាមទារឲ្យប្រគល់ទំនិញ ជាដើម និង ជាប័ណ្ណដែលកំណត់នូវអត្តសញ្ញាណនៃសិទ្ធិទាំងនោះ។ មានន័យថា បុគ្គលដែលគ្រប់គ្រងប័ណ្ណទាំងនោះ អាចចាត់ចែងប័ណ្ណទាំងនោះក្នុងនាមជាអ្នកមានសិទ្ធិ ហើយសិទ្ធិនោះត្រូវផ្ទេរផងដែរ នៅពេលដែលប័ណ្ណត្រូវបានផ្ទេរការកាន់កាប់។ ចំពោះចំណុចនេះ ឧបករណ៍ដែលអាចជួញដូរបានគឺដូចគ្នាទៅនឹងវិញ្ញាបនបត្របញ្ជាក់ប្រាក់បញ្ញើដែលបង្ហាញអំពីសិទ្ធិ ក៏ប៉ុន្តែ ខុសគ្នាត្រង់ថា ឧបករណ៍ដែលអាចជួញដូរបានគឺមិនភ្ជាប់ជាមួយសិទ្ធិនោះទេ។ របបឧបករណ៍ដែលអាចជួញដូរបានបែបនេះ គឺជារបបដែលលើកកម្ពស់លំហូរនៃសិទ្ធិពីម្នាក់ទៅម្នាក់ តាមរយៈការដែលអ្នកដែលកាន់កាប់ប័ណ្ណ ត្រូវបានចាត់ចែងដូចជាអ្នកមានសិទ្ធិ ។

#### ខ) រូបិយាណត្តិ

រូបិយាណត្តិ និង មូលប្បទានប័ត្រ គឺជាប្រភេទគំរូនៃឧបករណ៍ដែលអាចជួញដូរបាន ហើយកំណត់ជាលាយលក្ខណ៍អក្សរនូវសិទ្ធិទាមទារឲ្យបង់ប្រាក់ក្នុងចំនួនជាកំណត់មួយ។ រូបិយាណត្តិ មានពីរប្រភេទគឺ ប័ណ្ណសងតាមបញ្ជា និង ប័ណ្ណប្តូរយកប្រាក់។ ប័ណ្ណសងតាមបញ្ជា គឺជាប័ណ្ណដែលតាមរយៈនោះ បុគ្គលម្នាក់បានធ្វើការសន្យាថានឹងបង់ទឹកប្រាក់ក្នុងចំនួនជាកំណត់មួយ នៅកាលបរិច្ឆេទជាក់លាក់មួយ។ បុគ្គលដែលបានធ្វើប័ណ្ណ ឬ អាចហៅម្យ៉ាងទៀតបានថា បុគ្គលដែលចេញប័ណ្ណដើម្បីធ្វើការទទួលបន្ទុកចំពោះកាតព្វកិច្ច ហៅថា អ្នកចេញផ្សាយ។ ដូច្នេះ អ្នកដែលទទួលនូវទឹកប្រាក់នោះហៅថា អត្ថគាហក។ អត្ថគាហក អាចធ្វើអនុប្បទានសិទ្ធិលើប័ណ្ណនោះទៅអ្នកដទៃបាន។ វិធីធ្វើអនុប្បទានសិទ្ធិត្រូវបានប្រតិបត្តិតាមរបៀបធ្វើការសរសេរចូលនូវភាគីនៃអនុប្បទាននៅផ្នែកខាងក្រោយសន្លឹកប័ណ្ណ ហើយប្រគល់ប័ណ្ណនោះទៅអនុប្បទានិក។ ការសរសេរចូលបែបនេះហៅថា បង្វិលេខ (អនុប្បទាយី ហៅថា រូបិយបដិភោគី ហើយអនុប្បទានិកវិញហៅថា អត្ថគាហកនៃបង្វិលេខ)។ លើសពីនេះទៅទៀត អនុប្បទានិកក៏អាចធ្វើអនុប្បទានសិទ្ធិលើប័ណ្ណនេះទៅអ្នកដទៃផ្សេងទៀតបានដោយការធ្វើបង្វិលេខដែរ។ ដោយការអនុវត្តរបៀបនេះ យើងអាចគិតឃើញបានថា ប័ណ្ណត្រូវបានធ្វើអនុប្បទានជាបន្តបន្ទាប់។ ដូច្នេះ នៅកាលបរិច្ឆេទសងដែលបានចុះនៅលើប័ណ្ណ បុគ្គលដែលមានសិទ្ធិលើប័ណ្ណ (អ្នកកាន់ប័ណ្ណ ឬ អត្ថគាហកនៃបង្វិលេខ) អាចទាមទារឲ្យ អ្នកចេញប័ណ្ណសងនូវចំនួនទឹកប្រាក់តាមតម្លៃដែលចុះលើប័ណ្ណនោះបាន។

ប័ណ្ណប្តូរយកប្រាក់ គឺពុំមែនជាប័ណ្ណដែលបុគ្គលអ្នកចេញប័ណ្ណសន្យាសងដោយខ្លួនឯងនោះទេ ក៏ប៉ុន្តែវាជាការផ្ទុកផ្តាក់ការបង់ជាប្រាក់ក្នុងចំនួនទឹកប្រាក់ជាកំណត់មួយទៅតតិយជន (អ្នកបង់)។ ប័ណ្ណប្តូរយកប្រាក់ត្រូវបានគេប្រើប្រាស់ជាមធ្យោបាយផ្ញើប្រាក់ ឬ ទទួលប្រាក់ដើម្បីធ្វើការទូទាត់ប្រាក់ក្នុងកិច្ចការជំនួញជាអន្តរជាតិ ។

### គ) មូលប្បទានប័ត្រ

មូលប្បទានប័ត្រ គឺដូចគ្នាទៅនឹងប័ណ្ណប្តូរយកប្រាក់ដែរ ដែលអ្នកចេញប័ណ្ណផ្ទុកផ្តាក់ឲ្យតតិយជនធ្វើការបង់ប្រាក់ ក៏ប៉ុន្តែ វាពុំមានទស្សនៈស្តីពីការដល់កាលបរិច្ឆេទសងទេ ដោយការបង់នឹងត្រូវធ្វើឡើងភ្លាមនៅពេលដែលឃើញប័ណ្ណ (ការបង់ប្រាក់ឲ្យត្រូវបានធ្វើឡើងភ្លាមៗ នៅពេលដែលមូលប្បទានប័ត្រត្រូវបានដកយកមកបង្ហាញ) ហើយខុសពីប័ណ្ណប្តូរយកប្រាក់ ដែលមានតែធនាគារទេដែលជាអ្នកបង់។ ដោយហេតុនេះហើយ មូលប្បទានប័ត្រដើរតួនាទីជាមធ្យោបាយបង់ជំនួសការបង់ជាសាច់ប្រាក់ ។

### (២) ច្បាប់ស្តីពីរូបិយាណត្តិ និង មូលប្បទានប័ត្រ

ក) ប្រព័ន្ធច្បាប់ដែលពាក់ព័ន្ធនឹងរូបិយាណត្តិ និង មូលប្បទានប័ត្រ

ច្បាប់ដែលពាក់ព័ន្ធជាមួយនឹងរូបិយាណត្តិ និង មូលប្បទានប័ត្រ ត្រូវបានតាក់តែងឡើងដោយអនុលោមទៅតាមសន្ធិសញ្ញាអន្តរជាតិ។ មានន័យថា ច្បាប់ស្តីពីរូបិយាណត្តិ និង មូលប្បទានប័ត្រត្រូវបានបញ្ញត្តដោយអនុលោមទៅតាមសន្ធិសញ្ញាក្រុងហ្សឺណែវស្តីពីការធ្វើឲ្យឯកភាពនៃច្បាប់ស្តីពីរូបិយាណត្តិ (១៩៣០) និង សន្ធិសញ្ញាក្រុងហ្សឺណែវស្តីពីការធ្វើឲ្យឯកភាពនៃច្បាប់ស្តីពីមូលប្បទានប័ត្រ (១៩៣១) (ពោលគឺប្រទេសមួយចំនួនដូចជាអាល្លឺម៉ង់ និង បារាំង ជាដើម បានផ្តល់សច្ចាប័នទៅលើសន្ធិសញ្ញាទាំងនេះ ហើយចំពោះប្រទេសដែលបញ្ញត្តច្បាប់ក្នុងប្រទេស ជាទូទៅគឺយកប្រព័ន្ធដូចច្បាប់ស្តីពីរូបិយាណត្តិ និង មូលប្បទានប័ត្រទាំងនេះ)។ ច្បាប់ទាំងឡាយនេះបានតាក់តែងនូវបញ្ញត្តិដើម្បីកំណត់ទម្រង់នៃរូបិយាណត្តិ និង មូលប្បទានប័ត្រ និងដើម្បីធានាដល់ការចែកចាយប័ណ្ណទាំងនោះ។ ដូច្នេះ ចំពោះសិទ្ធិលើបំណុលលើរូបិយាណត្តិ ត្រូវបានបង្កើតឲ្យមាននូវការចាត់ចែងដែលខុសគ្នាពីសិទ្ធិលើបំណុលតាមក្រមរដ្ឋប្បវេណី។ ជាពិសេស ចំពោះអនុប្បទានសិទ្ធិវិញ យើងអាចមើលឃើញថាមានភាពខុសគ្នាខ្លាំង ។

មានន័យថា បើតាមក្រមរដ្ឋប្បវេណី សិទ្ធិលើបំណុលអាចត្រូវបានធ្វើអនុប្បទានត្រឹមតែតាមរយៈការបង្ហាញឆន្ទៈធ្វើអនុប្បទានរវាងម្ចាស់សិទ្ធិ ពោលគឺអនុប្បទាយីជាមួយអនុប្បទានិកបាន ក៏ប៉ុន្តែដើម្បីឲ្យអនុប្បទានិកអាចតតាំងអនុប្បទាននោះជាមួយតតិយជនបាន ចាំបាច់ត្រូវបំពេញល័ក្ខខ័ណ្ឌតតាំង។ ដោយឡែកសិទ្ធិលើបំណុលដែលកំណត់ការបញ្ជា (ដូចគ្នាទៅនឹងរូបិយាណត្តិ និង មូលប្បទានប័ត្រដែរ វាជាសិទ្ធិលើបំណុលដែលបុគ្គលដែលត្រូវបានកំណត់នៅក្នុងមូលប័ត្រ ត្រូវធ្វើលទ្ធកម្មលើសិទ្ធិ) ដែលលិខិតបញ្ជាក់សិទ្ធិលើបំណុលត្រូវបានបង្កើតឡើង ល័ក្ខខ័ណ្ឌតតាំងនឹងកើតមាននៅពេលដែលមានការធ្វើបង្អិលេខលើលិខិតបញ្ជាក់នោះ ហើយមានការប្រគល់លិខិតនោះទៅអនុប្បទានិក (មាត្រា ៩៦៩ នៃក្រមរដ្ឋប្បវេណី)។ ផ្ទុយទៅវិញ នៅក្នុងក្រមពាណិជ្ជកម្ម មិនបានបង្កើតឲ្យមាននូវការបែងចែកល័ក្ខខ័ណ្ឌបង្កើតការផ្ទេរសិទ្ធិ និង ល័ក្ខខ័ណ្ឌតតាំងបែបនោះទេ។ មានន័យថា ចំពោះសិទ្ធិលើបំណុលដែលមានលើ ឧបករណ៍ដែលអាចជួញដូរបាន ដូចជារូបិយាណត្តិ ឬ មូលប្បទានប័ត្រជាដើម អានុភាពនៃអនុប្បទានសិទ្ធិនឹងមិនកើតឡើងដោយគ្រាន់តែការបង្ហាញឆន្ទៈធ្វើអនុប្បទានតែរវាងភាគីប៉ុណ្ណោះទេ ប៉ុន្តែ ត្រូវចុះបង្អិលេខលើមូលប័ត្រ និង ត្រូវប្រគល់មូលប័ត្រដែលបានចុះបង្អិលេខនោះ ទើបល័ក្ខខ័ណ្ឌនៃការបង្កើតការផ្ទេរត្រូវបានចាត់ទុកថាកើតមានឡើង (មាត្រា ១១ និង ចំណុចទី ១ កថាខណ្ឌទី ១ មាត្រា ៧៧ នៃច្បាប់ស្តីពីរូបិយាណត្តិ និង មាត្រា ១៤ នៃច្បាប់ស្តីពីមូលប្បទានប័ត្រ ) ។

តាមការអនុវត្តបែបនេះ ដោយសារតែបុគ្គលដែលបានទទួលការប្រគល់បង្អិលេខនៃមូលប័ត្រ ត្រូវធ្វើលទ្ធកម្មសិទ្ធិហើយ ដូច្នេះ ពុំចាំបាច់ត្រូវគិតដោយឡែកនូវល័ក្ខខ័ណ្ឌតតាំងអ្វីទៀតទេ ។

## ៤ ការផ្ញើប្រាក់តាមធនាគារ

### ក) ការផ្ញើប្រាក់ដោយការផ្ទេរប្រាក់តាមគណនីធនាគារ

ក្នុងករណីនៃការផ្ញើប្រាក់តាមធនាគារ ជាទូទៅ វិធីធ្វើការផ្ទេរតាមគណនីធនាគារត្រូវបានប្រើប្រាស់។ បុគ្គលដែលគិតថាចង់ផ្ញើប្រាក់ (អ្នកស្នើសុំឲ្យផ្ញើ) ផ្តល់ប្រាក់ទៅធនាគារ (ហៅថា ធនាគារផ្ញើ) ហើយស្នើសុំឲ្យធនាគារនោះធ្វើការផ្ទេរប្រាក់ ដោយចង្អុលបង្ហាញអំពីគណនីរបស់អត្ថគាហក។ ធនាគារផ្ញើបញ្ជាការផ្ទេរប្រាក់ទៅធនាគារ (ហៅថា ធនាគារទទួល) ដែលអត្ថគាហកមានគណនីនៅទីនោះ (វាក៏អាចមានករណីដែលធនាគារផ្ញើ និង ធនាគារទទួលជាធនាគារតែមួយដែរ)។ ធនាគារទទួល ធ្វើការបញ្ចូលប្រាក់ទៅក្នុងគណនីរបស់អត្ថគាហកទៅតាមការបញ្ជានោះ។ អត្ថគាហកធ្វើលទ្ធកម្មសិទ្ធិលើបំណុលលើប្រាក់សន្សំនូវចំនួនទឹកប្រាក់ដែលត្រូវបានបញ្ចូលនោះ ហើយទទួលបានផលប្រយោជន៍សេដ្ឋកិច្ចដូចគ្នាទៅនឹងការទទួលយកជាសាច់ប្រាក់ដែរ ។

### ខ) ទំនាក់ទំនងគតិយុត្តនៃការផ្ទេរប្រាក់

ការផ្ញើប្រាក់តាមធនាគារបែបនេះ អ្នកស្នើសុំឲ្យផ្ញើត្រូវបានចាត់ចែងដោយផ្អែកលើមូលដ្ឋានថាគាត់ទទួលរងនូវកាតព្វកិច្ចសងជាប្រាក់ចំពោះអត្ថគាហក ក៏ប៉ុន្តែ វាមានការជជែកដេញដោលជាច្រើនចំពោះបញ្ហាថាតើត្រូវគិតដូចម្តេចចំពោះទំនាក់ទំនងរវាងអ្នកស្នើសុំឲ្យផ្ញើ ជាមួយធនាគារផ្ញើ និង ទំនាក់ទំនងរវាងធនាគារផ្ញើ ជាមួយធនាគារទទួល ។

ឧទាហរណ៍ ទំនាក់ទំនងរវាងអ្នកស្នើសុំឲ្យផ្ញើ និង ធនាគារផ្ញើ ត្រូវបានគេបកស្រាយថាជាទំនាក់ទំនងអាណត្តិ ក៏ប៉ុន្តែ បញ្ហាថាករណីយកិច្ចអាណត្តិមានខ្លឹមសារដូចម្តេចនោះ ត្រូវបានជជែកដេញដោល។ បញ្ហានោះគឺថាតើយើងត្រូវគិតថា កាតព្វកិច្ចធនាគារផ្ញើចំពោះអ្នកស្នើសុំឲ្យផ្ញើមានកម្រិតត្រឹមតែបង្គាប់ឲ្យធនាគារទទួលធ្វើការបង់ប្រាក់ទៅអត្ថគាហក ដោយឲ្យធនាគារនោះធ្វើការចុះបញ្ជីបញ្ចូលប្រាក់ក្នុងចំនួនជាក់លាក់មួយទៅក្នុងគណនីរបស់អត្ថគាហក ឬ ក៏ត្រូវធ្វើរហូតទៅដល់ការចុះបញ្ជីបញ្ចូលទឹកប្រាក់ទៅក្នុងគណនីរបស់អត្ថគាហក។ តាមការអនុវត្តជាក់ស្តែងរបស់ធនាគារបានយកនូវទស្សនៈទី ១ ហើយបទប្បញ្ញត្តិ (ទាំងឡាយដែលពាក់ព័ន្ធនឹងការផ្ញើប្រាក់) ត្រូវបានតាក់តែងឡើងដោយផ្អែកលើទស្សនៈនេះ។

ម្យ៉ាងវិញទៀត ចំពោះទំនាក់ទំនងរវាងអត្ថគាហកជាមួយនឹងធនាគារទទួលក៏ដូចគ្នាផងដែរ នៅក្នុងស្ថានភាពជាក់ស្តែងនៅមុនពេលដែលការចុះបញ្ជីបញ្ចូលប្រាក់ទៅក្នុងគណនីធនាគាររបស់អត្ថគាហកត្រូវបានធ្វើឡើង ធនាគារទទួលបន្ទុកចំពោះកាតព្វកិច្ចលើប្រាក់សន្សំចំពោះអត្ថគាហកឡើយ។

បញ្ហាថាតើការដាក់ប្រាក់បញ្ញើកើតមាន ឬ គ្មានកើតឡើងរវាងបុគ្គលដែលបានធ្វើឲ្យក្លាយទៅជាអត្ថគាហក ជាមួយនឹងធនាគារទទួលនោះ នឹងក្លាយទៅជាបញ្ហានៅពេលដែលការផ្ទេរត្រូវបានធ្វើឡើងដោយភ័ន្តច្រឡំ។ យើងអាចគិតឃើញអំពីមូលហេតុផ្សេងៗ ថាហេតុអ្វីបានជាការផ្ញើដោយភ័ន្តច្រឡំបានកើតមានឡើង ក៏ប៉ុន្តែ នៅក្នុងករណីដែលការស្នើសុំឲ្យផ្ញើទៅចំពោះអត្ថគាហកដែលខុសត្រូវបានធ្វើឡើងដោយសារការភ័ន្តច្រឡំរបស់អ្នកស្នើសុំឲ្យផ្ញើ ដូច្នេះមានសាលដីការបស់តុលាការកំពូលដែលសម្រេចថា ការដាក់ប្រាក់បញ្ញើកើតមានរវាងអ្នកដែលបានក្លាយទៅជាអត្ថគាហកជាមួយនឹងធនាគារទទួល (សាលដីកាតុលាការកំពូលចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ១៩៩៦ ក្នុងកម្រងសាលដីការឿងក្តីរដ្ឋប្បវេណីភាគទី ៥០ លេខ ៥ ទំព័រទី ១២៦៧)។

## ៥ ប័ណ្ណឥណទាន ជាដើម

### ក) យន្តការប័ណ្ណឥណទាន

ប័ណ្ណឥណទាន (credit card) គឺជាប័ណ្ណដែលត្រូវបានគេប្រើដើម្បីជាមធ្យោបាយបង់ប្រាក់ នៅក្នុងករណីដែលត្រូវបង់ប្រាក់ចំពោះការទិញទំនិញ ឬ ចំពោះការទទួលបាននូវការផ្តល់សេវា ជាដើម ។ ក្រុមហ៊ុនដែលចេញប័ណ្ណនោះធ្វើការស្រាវជ្រាវទៅលើពាក្យសុំប្រើប្រាស់ប័ណ្ណរបស់អ្នកប្រើប្រាស់ មុននឹងចេញប័ណ្ណនោះឲ្យអ្នកដាក់ពាក្យសុំ។ ចំពោះផ្លូវច្បាប់ អ្នកប្រើប្រាស់ (ដែលត្រូវបានហៅថាអ្នកកាន់ប័ណ្ណ និង សមាជិកប័ណ្ណ) និង ក្រុមហ៊ុនដែលចេញប័ណ្ណធ្វើកិច្ចសន្យាជាមួយគ្នា ដែលហៅថាកិច្ចសន្យាចូលជាសមាជិក។ ដូច្នេះ ខ្លឹមសារជាក់លាក់នៃកិច្ចសន្យានោះ ដែលមានដូចជា របៀបប្រើប្រាស់ប័ណ្ណ និងរបៀបបង់ប្រាក់ប្រើប្រាស់ ជាដើម ត្រូវបានកំណត់នៅក្នុងលក្ខន្តិកៈសមាជិក ។

កិច្ចសន្យាហាងសមាជិក ត្រូវបានធ្វើឡើងរវាងហាងទំនិញដែលអាចប្រើប្រាស់ប័ណ្ណនោះជាដើម ជាមួយនឹងក្រុមហ៊ុនដែលចេញប័ណ្ណ ពាក់ព័ន្ធទៅនឹងការប្រើប្រាស់ប័ណ្ណរបស់អ្នកកាន់ប័ណ្ណ។ នៅក្នុងករណីដែលអ្នកកាន់ប័ណ្ណទិញទំនិញ ឬ ទទួលទានអាហារនៅហាងសមាជិក គាត់អាចប្រើប្រាស់ប័ណ្ណនោះបានដើម្បីធ្វើការបង់ថ្លៃលក់ទិញ និង ថ្លៃទទួលទានអាហារជំនួសឲ្យការបង់ជាសាច់ប្រាក់។ ក្រុមហ៊ុនដែល បានចេញប័ណ្ណត្រូវធ្វើការបង់ថ្លៃចាយវាយនោះទៅហាងសមាជិក ជំនួសឲ្យអ្នកកាន់ប័ណ្ណជាមុនសិន ហើយក្រោយមកទើបទាមទារឲ្យអ្នកកាន់ប័ណ្ណសងប្រាក់ដែលខ្លួនបានបង់ជួសនោះមកវិញ។ បើពិនិត្យមើលពីខាងអ្នកប្រើប្រាស់វិញ ឃើញថា វាមានគុណសម្បត្តិព្រោះថា ទោះបីគាត់មិនមានប្រាក់ជាប់នឹងខ្លួន ក៏គាត់អាចទិញទំនិញបានដែរ (ក៏ប៉ុន្តែ មានករណីច្រើនដែលអ្នកកាន់ប័ណ្ណត្រូវបង់ថ្លៃសមាជិកប្រចាំឆ្នាំ)។ ដោយឡែកចំពោះហាងសមាជិកវិញក៏ដូចគ្នាដែរ ប្រសិនបើប័ណ្ណមិនមែនជាប័ណ្ណក្លែងក្លាយ គុណសម្បត្តិគឺគាត់អាចទទួលបាននូវការបង់ប្រាក់ដែលគេបានចាយវាយគ្រប់

ចំនួនពីក្រុមហ៊ុនដែលចេញប័ណ្ណ (ក៏ប៉ុន្តែ ក៏ត្រូវបង់កម្រៃសេវាកម្មទៅតាមការកំណត់របស់ក្រុមហ៊ុនដែលចេញប័ណ្ណដែរ) ។

## ខ) បញ្ហាប័ណ្ណឥណទាន

ដូចដែលបានរៀបរាប់ខាងលើ ប័ណ្ណឥណទានបង្កភាពងាយស្រួលទៅដល់ជីវភាពប្រើប្រាស់នៃសម័យបច្ចុប្បន្ន ក៏ប៉ុន្តែ វាមិនមែនសុទ្ធតែមានចំណុចល្អទាំងអស់នោះទេ ដោយសារវាក៏មានបញ្ហាមួយចំនួនផងដែរ។ ជាបឋម គឺការទទួលបានប័ណ្ណយកមកប្រើប្រាស់ដោយការចូលជាសមាជិកនោះវាងាយស្រួលពេក (ក្រុមហ៊ុនប័ណ្ណធ្វើការស្រាវជ្រាវពាក់ព័ន្ធជាមួយនឹងភាពគួរឲ្យទុកចិត្តរបស់អតិថិជននៅពេលដែលដាក់ពាក្យសុំចូលជាសមាជិក ក៏ពិតមែន ក៏ប៉ុន្តែពុំមែនជាវិធានការម៉ឺងម៉ាត់នោះទេ) ហើយដោយសារតែអាចប្រើប្រាស់បានដោយងាយៗ បំណុលចំពោះការប្រើប្រាស់ប័ណ្ណនោះកាន់ តែគរច្រើនឡើង ហើយកូនបំណុលដែលធ្លាក់ទៅក្នុងស្ថានភាពមិនអាចសងបំណុលបានកាន់តែមានច្រើនឡើងៗ (កូនបំណុលដែលជំពាក់ប្រាក់ច្រើន) ហើយក៏ក្លាយទៅជាបញ្ហាសង្គមដ៏ធ្ងន់ធ្ងរ។ ម្យ៉ាងវិញទៀត ក្នុងករណីដែលប័ណ្ណត្រូវបានប្រើប្រាស់ដោយខុសច្បាប់ដោយសារតែការបាត់បង់ ឬ ដោយសារតែអំពើចោរកម្មជាដើម ការបង្ខំឲ្យអ្នកកាន់ប័ណ្ណទទួលខុសត្រូវចំពោះបំណុលក៏ក្លាយជាបញ្ហាដែរ។ ក៏ប៉ុន្តែ ចំពោះបញ្ហាទាំងអស់នេះ ក្រុមហ៊ុនប័ណ្ណស្ទើរតែទាំងអស់បានធ្វើការកែប្រែការតាក់តែងបញ្ញត្តិនៃកិច្ចសន្យារបស់ខ្លួន នាពេលបច្ចុប្បន្ននេះដោយបានប្តូរទៅជាកិច្ចសន្យាដែលមានខ្លឹមសារថា ប្រសិនបើអ្នកប្រើប្រាស់ធ្វើការជូនដំណឹងអំពីអង្គហេតុស្តីពីការបាត់បង់ ឬ អំពើចោរកម្មទាំងនោះ ជាដើម គឺគាត់មិនចាំបាច់ទទួលខុសត្រូវចំពោះការបាត់បង់ក៏បានដែរ ប្រសិនបើប័ណ្ណត្រូវបានយកទៅប្រើប្រាស់ដោយខុសច្បាប់នោះ។ ក៏ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ ផលប៉ះពាល់ដោយសារការប្រើប្រាស់ប្រព័ន្ធនេះ នៅក្នុងចេតនាទុច្ចរិត ក៏នៅតែជាបញ្ហា ចំពោះការដែលឲ្យតតិយជនប្រើប្រាស់ប័ណ្ណនោះ រួចហើយក្រោយមកបានធ្វើការជូនដំណឹងអំពីការបាត់បង់ប័ណ្ណ ហើយត្រូវបានលើកលែងឲ្យរួចពីកាតព្វកិច្ចបង់សងវិញ ។

## គ) ប័ណ្ណឥណពន្ធ

ប័ណ្ណឥណពន្ធ (debit card) បើចំណុចស្តីពីការប្រើប្រាស់ប័ណ្ណសម្រាប់ធ្វើការបង់ថ្លៃលក់ទិញវាក៏ជាយន្តការមួយដូចប័ណ្ណឥណទានដែរ ក៏ប៉ុន្តែវាជាយន្តការដែលទន្ទឹមពេលជាមួយគ្នានោះ ចំនួនទឹកប្រាក់ដែលបានចាយវាយត្រូវបានដកចេញពីគណនីប្រាក់បញ្ញើនៅធនាគារភ្លាមៗដែរ។ យន្តការនេះត្រូវបានរំពឹងថាមានប្រជាប្រិយភាពចំពោះការចាយវាយនូវចំនួនទឹកប្រាក់តិចតួច ជាដើម ជំនួសឲ្យការប្រើប្រាស់សាច់ប្រាក់ ។

## ឃ) រូបិយវត្ថុអេឡិកត្រូនិក

នាពេលថ្មីៗនេះ វិធីបង់ដែលក្លាយជាកម្មវត្ថុនៃការពិភាក្សាគឺ រូបិយវត្ថុអេឡិកត្រូនិក។ ចំពោះការផ្ទេរប្រាក់តាមធនាគារ និង ប័ណ្ណឥណទានក៏ដូចគ្នាដែរ គឺទិន្នន័យនៃចំនួនទឹកប្រាក់ អតិថិជន និង អគ្គគាហក ជាដើម ត្រូវធ្វើតាមប្រព័ន្ធអេឡិកត្រូនិក ដោយត្រូវបានប្រតិបត្តិយ៉ាងទូលំទូលាយតាមមធ្យោបាយផ្លាស់ប្តូរព័ត៌មានគ្នា ដោយការឆ្លើយឆ្លងតាមប្រព័ន្ធកុំព្យូទ័រ (កាលពីមុន ការចាត់ចែងចំពោះកិច្ចការប្តូរទិន្នន័យនានាទាំងឡាយត្រូវបានប្រតិបត្តិដោយផ្អែកលើទិន្នន័យដែលត្រូវបានសរសេរនៅលើក្រដាស) ក៏ប៉ុន្តែ រូបិយវត្ថុអេឡិកត្រូនិកគឺជាអ្វីដែលត្រូវបានអភិវឌ្ឍបន្ថែមលើការប្រើប្រាស់បច្ចេកទេសថ្មីទាំងនោះទៀត។ មានន័យថា ជំនួសឲ្យការប្រើប្រាស់ក្រដាសប្រាក់ និង កាក់ ដើម្បីធ្វើការបង់ដែលមានចំនួនទឹកប្រាក់តិច គឺគេអាចប្រើប័ណ្ណ IC (គឺប័ណ្ណផ្លាស្ទិកដែលមានបញ្ចុះឈីប IC ដែលដូចគ្នាទៅនឹងប័ណ្ណឥណទាន និង ប័ណ្ណបើកប្រាក់ដែរ)។ ម្យ៉ាងវិញទៀត ក៏មានរូបិយវត្ថុអេឡិកត្រូនិកដែលប្រើប្រាស់បានតាមប្រព័ន្ធអ៊ិនធើណែត ដោយមិនប្រើជាប័ណ្ណផងដែរ ។

និយាយឲ្យជាកលាក់ ចំពោះប្រព័ន្ធវិញ អាចគិតឃើញថាមានច្រើនបែបច្រើនយ៉ាង ក៏ប៉ុន្តែ បញ្ហាដែលចាំបាច់ត្រូវធ្វើការពិនិត្យពិច័យទៅលើបញ្ហាផ្លូវច្បាប់ (ចំណាត់ការចំពោះករណីនៃការប្រើប្រាស់ដោយខុសច្បាប់ដោយតតិយជន ករណីដែលមានការលួច និង ការបាត់បង់) គឺជាបញ្ហាដែលដូចគ្នាជាមួយនឹងបញ្ហាប័ណ្ណឥណទាន។ នៅក្នុងស្ថានភាពជាក់ស្តែង មុខងារនៃរូបិយវត្ថុអេឡិកត្រូនិកដែលបន្ថែមពីលើប័ណ្ណឥណទាន និង ប័ណ្ណបង់ប្រាក់ទុកជាមុន (prepaid card) កំពុងត្រូវបានប្រើប្រាស់ ។

### ✎ របៀបបង់ថ្លៃលក់ទិញ--ការពិចារណាតាមរយៈករណីសិក្សា

ជាធម្មតា ចំពោះកិច្ចសន្យាលក់ទិញរវាងគូភាគី វិធីបង់ថ្លៃលក់ទិញ និង ពេលវេលាត្រូវបង់ ជាដើម ត្រូវបានកំណត់ទៅតាមការព្រមព្រៀង ។ ប្រសិនបើមានការព្រមព្រៀងបែបនោះ ហើយ A ធ្វើការបង់ទៅក្រុមហ៊ុន B ទៅតាមការព្រមព្រៀងទៅមិនអីទេ។ ឧទាហរណ៍ ប្រសិនបើមានការព្រមព្រៀងដែលមានខ្លឹមសារថាបង់ជាប្រាក់សុទ្ធ គឺបង់ជាប្រាក់សុទ្ធទៅ ពុំមានអ្វីកើតឡើងទេ ហើយប្រសិនបើមានការសន្យាថាបង់តាមការផ្ទេរតាមធនាគារ គឺធ្វើការផ្ទេរថ្លៃលក់ទិញទៅតាមគណនីធនាគារដែលបានកំណត់ទៅជាការស្រេចហើយ។ ជាពិសេស បើមិនមានការព្រមព្រៀងទេ ជាគោលការណ៍ ត្រូវធ្វើការបង់ជាប្រាក់សុទ្ធ (ថ្លៃលក់ទិញដែលមានកំណត់ក្នុងមាត្រា ៥៥៥ នៃក្រមរដ្ឋប្បវេណី បើនិយាយឲ្យជាក់លាក់ គឺមានន័យថាជាសាច់ប្រាក់)។ ក៏ប៉ុន្តែ គេក៏អាចគិតបានផងដែរថា ប្រសិនបើក្រុមហ៊ុន B បានទទួលនូវការសងតាមវិធីសងណាមួយដូចជាតាមមូលប្បទានប័ត្រ ការផ្ទេរទឹកប្រាក់តាមធនាគារ និង វិធីផ្សេងទៀតជាដើម ក៏ការសងនោះមានសុពលភាពដែរ ។

## ✧ច្បាប់រ៉ូម៉ាំង និងក្រមយ៉ាស្ទីនៀន

ច្បាប់រ៉ូម៉ាំង ដែលមានដូចជាច្បាប់ហ្គែរម៉ាន (Germane) និងច្បាប់ព្រះវិហារសាសនាគ្រិស្ត បានក្លាយទៅជាប្រភពនៃច្បាប់របស់បណ្តាប្រទេសអឺរ៉ុបដីគោកមួយចំនួនដូចជាប្រទេសបារាំង និង អាល្លឺម៉ង់ ជាដើម ។ បើនិយាយពីច្បាប់រ៉ូម៉ាំងវិញក៏ដូចគ្នាផងដែរ ជាប្រវត្តិសាស្ត្រ វាបានឆ្លងកាត់នូវដំណាក់កាលដ៏ធំដែលបានរាប់បញ្ចូលនូវច្បាប់ផ្សេងៗជាច្រើន ក៏ប៉ុន្តែអ្វីដែលពិសេសជាងគេនោះគឺថា ក្រមយ៉ាស្ទីនៀនដែលត្រូវបានចងក្រងនៅក្នុងសតវត្សទី ៦ នៅពេលក្រោយមកត្រូវបានគេហៅថា កម្រងច្បាប់រ៉ូម៉ាំង (Corpus Iuris Civilis) ហើយដោយសារតែវាបានជះឥទ្ធិពលយ៉ាងខ្លាំងទៅដល់ប្រព័ន្ធច្បាប់របស់ប្រទេសនីមួយៗ បូករួមទាំងវិស័យសិក្សាអំពីច្បាប់ ហើយនាពេលបច្ចុប្បន្ននេះក៏ដូចគ្នាផងដែរ គឺវាបានក្លាយទៅជាកម្មវត្ថុនៃការសិក្សាស្រាវជ្រាវជាមូលដ្ឋាន។ ក្រមយ៉ាស្ទីនៀន នៅពេលនោះជាច្បាប់ព្រះមហាក្សត្រ និង ជាកម្រងនៃទ្រឹស្តី ដែលត្រូវបានបង្កើតឡើងចេញពីកម្រងទ្រឹស្តី (Pandectae Digesta) សេចក្តីសង្ខេបនៃនីតិ (Institutiones) កម្រងច្បាប់ព្រះមហាក្សត្រ (Codex) និង ច្បាប់ព្រះមហាក្សត្រថ្មី (Novellae) (នាសម័យកាលនោះ ទ្រឹស្តីសិក្សាពីច្បាប់ និង សេចក្តីសង្ខេបនីតិក៏ត្រូវបានគេគិតថាជាវិធានគតិយុត្តដែរៗ ក៏ប៉ុន្តែ ខ្លឹមសារមួយផ្នែកនៃទ្រឹស្តីទាំងនោះមិនបន្សល់ទុកនៅដល់ពេលបច្ចុប្បន្ននេះទេ) ។

នៅភាគខាងត្បូងនៃប្រទេសអ៊ីតាលី មានទីក្រុងមួយឈ្មោះថា អាម៉ាលហ្វិ។ ជាទីក្រុងដែលនៅចន្លោះខេត្តសាឡេណុដែលល្បីល្បាញខាងពាណិជ្ជកិច្ច និង សាកលវិទ្យាល័យ (វិទ្យាសាស្ត្រសុខាភិបាល) តាំងពីបុរាណ និងខេត្តសូរេនតូ ដែលជាកន្លែងចេញកប៉ាល់បែរមុខចំឈូងសមុទ្រណាប៉ូលី ហើយបច្ចុប្បន្នបានក្លាយទៅជាតំបន់ទេសចរណ៍ដែលភ្ជាប់ជាមួយនឹងឆ្នេរខ្សាច់ដ៏ស្រស់ត្រកាល ។ ជាប្រវត្តិសាស្ត្រ អ៊ីតាលីភាគខាងត្បូង និង ចក្រភពប៊ីហ្សិនទីន (ទីក្រុងរ៉ូមភាគខាងត្បូង) ជាតំបន់ដែលផ្លាស់ប្តូរសកម្មភាពជួញដូរទៅវិញទៅមក បានក្លាយជាតំបន់ដែលសម្បូរណ៍សប្បាយតាំងពីសតវត្សទី ៦ មកហើយ ត្រូវបានគេដំណាលថាធ្លាប់មានច្បាប់សមុទ្រដែលល្អបំផុតមួយ។

សំណៅដើមនៃកម្រងទ្រឹស្តីច្បាប់ ត្រូវបានគេដំណាលថាត្រូវបានរកឃើញនៅសតវត្សទី ១២ ដោយអ្នកភូមិ កីសា ដែលបានចូលទៅកាន់កាប់ទីក្រុងអាម៉ាលហ្វិ (ក៏ប៉ុន្តែ អ្នកទ្រឹស្តីច្បាប់រ៉ូម៉ាំងដែលជាជនជាតិបារាំងដ៏ល្បីល្បាញម្នាក់បានមានមន្ទិលចំពោះការពន្យល់នោះ ដោយបានធ្វើការសន្និដ្ឋានថា សំណៅនោះត្រូវបាននាំយកមកពីកន្លែងណាដែលជាកន្លែងប្រមូលផ្តុំនៃវប្បធម៌ប៊ីហ្សិនទីននៅអ៊ីតាលី) ។ នាពេលក្រោយពីនោះមក នៅដើម សតវត្សទី ១៥ សំណៅដើមនោះត្រូវបានរើយកទៅហ្វ្លរេនស៊ី ហើយក៏ត្រូវបានហៅថា ក្រមហ្វ្លរេនស៊ី ដោយអាចគិតបានថាវាជាសំណៅដើមនៃកម្រងទ្រឹស្តីដ៏ល្បីល្បាញមួយ ។

នៅតំបន់ប៉ូឡូនៀ ដែលស្ថិតនៅភាគខាងជើងនៃប្រទេសអ៊ីតាលី ការសិក្សាស្រាវជ្រាវកសំណៅដើមផ្សេងទៀតនៃកម្រងទ្រឹស្តីច្បាប់ត្រូវបានធ្វើឡើង ក៏ប៉ុន្តែ ការសិក្សាស្រាវជ្រាវនៅទីនោះ អាចនិយាយបានថាមានដើមកំណើតមកពីអង្គការអប់រំ និង ស្រាវជ្រាវ (ប្រហែលសតវត្សទី ១១ និងសតវត្សទី ១២) ដោយបានជះឥទ្ធិពលយ៉ាងខ្លាំងទៅដល់បណ្តាមហាវិទ្យាល័យផ្សេងៗទៀតនៅអឺរ៉ុប។ តាមរយៈប្រវត្តិនេះ ចំណេះដឹងអំពីច្បាប់ ហៅថាការសិក្សាអំពីច្បាប់ បានចាប់កំណើតពីការសិក្សាស្រាវជ្រាវទៅលើច្បាប់រ៉ូម៉ាំង (ជាពិសេស ក្រមយ៉ាស្ទីនៀន) នោះ។

ក្រមយ៉ាស្ទីនៀនត្រូវបានបកប្រែជាភាសាអង់គ្លេស ភាសាបារាំង និងភាសាអាល្លឺម៉ង់ (ដោយមានអមជាមួយភាសាឡាតាំង) ដូច្នេះបើទោះបីជាមិនចេះភាសាឡាតាំងក៏ដោយ ក៏អាចដឹងអំពីខ្លឹមសារនៃក្រមនោះបានដែរ ។

ក៏ប៉ុន្តែ បើទោះបីជាអាចនិយាយបានថា ច្បាប់រ៉ូម៉ាំងគឺជាមូលដ្ឋាននៃច្បាប់អឺរ៉ុបក៏ដោយ ក៏មិនមែនមានន័យថា ច្បាប់រ៉ូម៉ាំងដែលមានភាពប្រណិតមួយដូចក្រមយ៉ាស្ទីនៀនត្រូវបានរក្សាទុកដូចដើមដែរ នៅក្នុងមជ្ឈិមសម័យនៅអឺរ៉ុប។ ការបោះផ្សាយដែលមានលក្ខណៈសម្រាយដែលត្រូវបានគេហៅថា ការសរសេរដែលមានលក្ខណៈសាមញ្ញអាក៉ារីកស៍ ត្រូវបានចងក្រងនៅដើមសតវត្សទី ៦ ហើយត្រូវបានគេស្គាល់ថា បានក្លាយទៅជាប្រភពសំខាន់នៃច្បាប់រ៉ូម៉ាំងដែរ (ប្រភពនៃវិធានគតិយុត្ត) ។

Khmer Law's Association

# ជំពូកទី ១២

## គ្រួសារ

**១ ច្បាប់ស្ដីពីគ្រួសារ**

**២ ញាតិ**

**៣ សហព័ទ្ធ**

(១) អាពាហ៍ពិពាហ៍

(២) ការលែងលះ

✎ ការទាមទារលែងលះរបស់សហព័ទ្ធដែលមានករណីយកិច្ច--ការពិចារណាតាមរយៈករណីសិក្សា

Khmer Law's Association

ករណីសិក្សា៖ បុរស A មានភាពរកាំរកូសជាមួយនារី B ដែលជាប្រពន្ធ ហើយបានចេញពីផ្ទះទៅរស់នៅរបៀបជាប្ដីប្រពន្ធជាមួយនារី C។ ស្ថានភាពបែបនេះបានអូសបន្លាយអស់រយៈពេល ២០ ឆ្នាំ ។ A និង B ពុំមានកូនទេ ក៏ប៉ុន្តែ A និង C មានកូន។ ក្នុងស្ថានភាពបែបនេះ A អាចទាមទារលែងលះជាមួយ B បានដែរ ឬទេ ?

## ១ ច្បាប់ស្ដីពីគ្រួសារ

### ក) អត្ថន័យនៃច្បាប់ស្ដីពីគ្រួសារ

ដូចបានរៀបរាប់ខាងលើ ក្រមរដ្ឋប្បវេណីត្រូវបានបែងចែកជា ៥ គន្ថី ដោយឡែកគន្ថីទី ៤ "ញាតិ" មាន បញ្ញត្តិដែលពាក់ព័ន្ធជាមួយនឹងទំនាក់ទំនងគ្រួសារដែលរួមមាន ទំនាក់ទំនងរវាងសហព័ទ្ធ និង ទំនាក់ទំនង រវាងឪពុកម្ដាយ និងកូន ជាដើម។ ចំពោះគន្ថីទី ៥ "សន្តតិកម្ម" វិញ មានបញ្ញត្តិដែលពាក់ព័ន្ធជាមួយសន្តតិកម្ម និង មតកសាសន៍ ជាដើម។ គន្ថីទាំង ២ នេះ ជាទូទៅ ត្រូវបានគេហៅថា ច្បាប់ស្ដីពីគ្រួសារ (ឬ ច្បាប់ស្ដីពីឋានៈបុគ្គល) រីឯគន្ថីទី ១ ដល់គន្ថីទី ៣ ចែងពាក់ព័ន្ធជាមួយនឹងទ្រព្យសម្បត្តិ (គន្ថីទី ១ "បទប្បញ្ញត្តិទូទៅ" គឺជាបញ្ញត្តិទូទៅទាំងឡាយដែលពាក់ព័ន្ធជាមួយនឹងក្រមរដ្ឋប្បវេណីទាំងមូល ក៏ប៉ុន្តែ បញ្ញត្តិស្ដីពីទ្រព្យសម្បត្តិមានច្រើន)។ ក៏ប៉ុន្តែនៅប្រទេសដទៃផ្សេងទៀត នៅពេលនិយាយអំពីច្បាប់ស្ដីពីគ្រួសារ (family law (អង់គ្លេស) droit de famille (បារាំង) Familienrecht (អាល្លឺម៉ង់) ភាគច្រើនមិនរាប់បញ្ចូលច្បាប់ស្ដីពីសន្តតិកម្មទេ ក៏ប៉ុន្តែចំពោះប្រទេសជប៉ុនវិញ ភាសាច្បាប់ ជាធម្មតា នៅពេលដែលគេថា ច្បាប់ស្ដីពីគ្រួសារគឺរាប់បញ្ចូលទាំងច្បាប់ស្ដីពីសន្តតិកម្ម ។

ដោយសារតែក្រមរដ្ឋប្បវេណីត្រូវបានបែងចែកជាពីរផ្នែក ពោលគឺផ្នែកស្ដីពីទ្រព្យសម្បត្តិ និង ផ្នែកស្ដីពីគ្រួសារដូច្នេះហើយ បានជាភាពខុសគ្នានៃគោលការណ៍ជាមូលដ្ឋានចំពោះផ្នែកទាំងពីរត្រូវបានមើលឃើញ។ មានន័យថា នៅក្នុងច្បាប់ស្ដីពីទ្រព្យសម្បត្តិ គោលការណ៍នៃភាពដាច់ខាតនៃសិទ្ធិប្រត្យក្ស គោលការណ៍សេរីភាពក្នុងកិច្ចសន្យា និង គោលការណ៍នៃការទទួលខុសត្រូវដោយផ្អែកលើកំហុស ជាដើម ត្រូវបានលើកឡើងជាគោលការណ៍ជាមូលដ្ឋាន (សូមមើលជំពូកទី ២)។ ផ្ទុយទៅវិញ នៅក្នុងច្បាប់ស្ដីពីគ្រួសារ គោលការណ៍បុគ្គល និង គោលការណ៍នៃសមភាពរវាងបុរសនារីជាដើម ត្រូវបានចាត់ទុកថាជាគោលការណ៍ជាមូលដ្ឋាន។ ភាពខុសគ្នានៃគោលការណ៍ជាមូលដ្ឋានទាំងនោះគឺ ច្បាប់ស្ដីពីទ្រព្យសម្បត្តិ និង ច្បាប់ស្ដីពីគ្រួសារ ផ្អែកទៅលើដែនអធិបតេយ្យខុសគ្នា ក៏ប៉ុន្តែពុំមែនមានន័យថា ច្បាប់ទាំងពីរនោះផ្ទុយគ្នាទេ ។

### ខ) បុគ្គលនិយម

បុគ្គលនិយមត្រង់នេះមានន័យថាជាការគោរពនូវការសម្រេចដោយផ្អែកលើឆន្ទៈសេរីរបស់បុគ្គល។ បើនិយាយឲ្យជាក់លាក់ សកម្មភាពនៅក្នុងច្បាប់ស្តីពីគ្រួសារដូចជា អាពាហ៍ពិពាហ៍ សុំកូន និង មតកសាសន៍ ជាដើម ត្រូវអនុលោមទៅតាមឆន្ទៈសម្រេចដោយសេរីរបស់បុគ្គល និង មិនត្រូវមានការជ្រៀតជ្រែកពីសំណាក់រដ្ឋ ឬ ពីចាស់ទុំនៅក្នុងគ្រួសារ (ដូចជាឪពុកម្តាយ ជាដើម) ចំពោះឆន្ទៈសម្រេចនោះឡើយ ។

បើតាមក្រមរដ្ឋប្បវេណីសម័យមេជិ (ឆ្នាំ ១៨៧៩) មានរបបដែលគេស្គាល់ថាជារបបគ្រួសារជប៉ុន "អ៊ិអេ" ដែលទទួលស្គាល់នូវសិទ្ធិត្រួតត្រាគ្រួសារទាំងមូលរបស់មេគ្រួសារដែលជាអ្នកធំជាងគេនៅក្នុងគ្រួសារ ក៏ប៉ុន្តែ របប"អ៊ិអេ" បែបនោះត្រូវបានលុបចោលដោយវិសោធនកម្មនៅក្រោយសង្គ្រាមលោកលើកទី ២ ដោយសារតែផ្ទុយទៅនឹងគោលការណ៍បុគ្គលនិយមដែលមានចែងនៅក្នុងមាត្រា ២៤ នៃរដ្ឋធម្មនុញ្ញ ទើបច្បាប់ស្តីពីគ្រួសារ និង ច្បាប់ស្តីពីសន្តតិកម្មថ្មី ដែលឈរលើគោលការណ៍នៃការធានាសេចក្តីថ្លៃថ្នូររបស់បុគ្គលត្រូវបានអនុម័ត។ មានន័យថា បើតាមមាត្រា ២៤ នៃរដ្ឋធម្មនុញ្ញ អាពាហ៍ពិពាហ៍ត្រូវកើតឡើងអាស្រ័យដោយការព្រមព្រៀងរបស់បុរស និង នារីតែប៉ុណ្ណោះ (កថាខណ្ឌទី ១ នៃមាត្រាដដែល) ហើយច្បាប់ទាំងឡាយដែលពាក់ព័ន្ធទៅនឹងគ្រួសារត្រូវអនុម័តដោយផ្អែកលើការគោរពចំពោះសេចក្តីថ្លៃថ្នូររបស់បុគ្គល និង ភាពស្មើគ្នារបស់បុរស និង នារី (កថាខណ្ឌទី ២ នៃមាត្រាដដែល)។ លើសពីនេះទៅទៀត មាត្រា ២ នៃក្រមរដ្ឋប្បវេណីកំណត់ពីគោលការណ៍នៃការបកស្រាយដោយត្រូវផ្អែកលើការគោរពចំពោះសេចក្តីថ្លៃថ្នូររបស់បុគ្គល និង សមភាពរវាងបុរស និង នារី ។

### គ) សមភាពរវាងបុរស និង នារី

សមភាពរបស់បុរស និង នារី មានន័យថា មិនត្រូវធ្វើការរើសអើងចំពោះភេទឡើយ ក៏ប៉ុន្តែ ជាប្រវត្តិសាស្ត្រ មិនមែនតែប្រទេសជប៉ុនទេ ក៏ប៉ុន្តែបណ្តាប្រទេសមួយចំនួនធំបានទទួលស្គាល់អស់រយៈពេលយ៉ាងយូរនូវឧត្តមានុភាពនៃបុរសចំពោះនារី។ នៅក្នុងប្រទេសយើង នៅក្នុងក្រមរដ្ឋប្បវេណីមេជិបានចែងយ៉ាងច្បាស់ដោយទទួលស្គាល់នូវឧត្តមានុភាពនៃបុរស។ ជាឧទាហរណ៍ នៅក្នុងគ្រួសារ ប្តីមានអំណាចជាក់លាក់មួយចំនួនលើប្រពន្ធ (ហៅថា អំណាចស្វាមី) ឪពុកមានអំណាចជាក់លាក់មួយចំនួនលើកូន (ហៅថា អំណាចបិតា) ហើយប្រពន្ធ និង កូនត្រូវគោរពតាមប្តី ឬ ឪពុក ហើយត្រូវរស់នៅក្រោមការឃុំគ្រងនៃអំណាចនោះ ។ ក៏ប៉ុន្តែ ចំពោះចំណុចនេះ ក៏ត្រូវបានកែប្រែដោយជំនួសវិញដោយសមភាពរវាងបុរស និង នារី នៅក្នុងវិសោធនកម្មនៃក្រមរដ្ឋប្បវេណីនៅក្រោយសង្គ្រាមលោកលើកទី ២ ដែរ ។ មានន័យថា រវាងប្តី និង ប្រពន្ធ ត្រូវបានកំណត់ថាមានសមភាពទាំងស្រុង។ ជាឧទាហរណ៍ ក្រមរដ្ឋប្បវេណី ត្រង់មាត្រា ៧៥២ ចែងថា ប្តីប្រពន្ធមានករណីយកិច្ចរួមរស់នៅជាមួយគ្នា សហការគ្នា និងជួយសង្គ្រោះគ្នាទៅវិញទៅមក ដោយសហព័ទ្ធមានសមភាពទាំងស្រុង ដែលជាចំណុចមូលដ្ឋានធម្មតា (ជាការប្រៀបធៀបនៅប្រទេសបារាំង រហូតមកដល់ពេលថ្មីៗនេះ បានទទួល

ស្គាល់នូវសិទ្ធិជាធំរបស់ប្ដីក្នុងការសម្រេចអំពីទីកន្លែងរស់នៅ)។ ចំពោះទំនាក់ទំនងរវាងឪពុកម្ដាយ និងកូន ឪពុកនិងម្ដាយមានច្បាប់កំណត់ថា ឪពុកម្ដាយត្រូវអនុវត្តអំណាចមេបារួមគ្នាចំពោះកូន (មាត្រា ៨១៨ នៃក្រមរដ្ឋប្បវេណី) ដែលចំណុចនោះអាចនិយាយបានថា ឪពុក និង ម្ដាយមានសិទ្ធិគ្រប់គ្រងកូនស្មើគ្នា ។

ក៏ប៉ុន្តែ នៅក្នុងវិសោធនកម្មក្រមរដ្ឋប្បវេណីក្រោយសង្គ្រាមលោកលើកទី ២ នៅប្រទេសជប៉ុន សមភាពរវាងបុរស និង នារីអនុវត្តបានទាំងស្រុង ក៏ប៉ុន្តែ នៅក្រោយសង្គ្រាមលោកលើកទី ២ នៅអឺរ៉ុប វិសមភាពរវាងបុរស និងនារីនៅមានសល់ខ្លះៗនៅឡើយទេ ហើយបើប្រៀបធៀបទៅ វិសោធនកម្មដែលត្រូវបានធ្វើឡើងដើម្បីកំណត់ឲ្យមាននូវសមភាពទាំងស្រុងរវាងបុរស និងនារី ទើបតែមាននាពេលថ្មីៗនេះទេ។ ក៏ប៉ុន្តែ មិនមែនមានន័យថា នៅជប៉ុន សមភាពរវាងបុរ និងនារី សម្រេចបានទាំងស្រុងនោះទេ។ ឧទាហរណ៍ នៅក្នុងមាត្រា ៧៥០ នៃក្រមរដ្ឋប្បវេណីចែងថា នៅក្រោយពេលរៀបអាពាហ៍ពិពាហ៍ ប្រពន្ធអាចជ្រើសរើសប្រើនាមត្រកូលរបស់ប្ដី ឬ នាមត្រកូលរបស់ខ្លួនដែលមានមុនរៀបអាពាហ៍ពិពាហ៍ក៏បាន។ មិនមែនមានន័យថា ត្រូវតែយកនាមត្រកូលតាមប្ដីនោះទេ ក៏ប៉ុន្តែ នៅក្នុងការអនុវត្តជាក់ស្ដែង ការប្រើនាមត្រកូលរបស់ប្ដីនៅក្នុងចំណាងអាពាហ៍ពិពាហ៍គឺមានចំនួនលើសលុបដែលមិនអាចនិយាយបានថាសមភាពកើតមានជាជាក់ស្ដែងនោះទេ។ ចំពោះកិច្ចការវិសោធនកម្មនៃក្រមរដ្ឋប្បវេណីបច្ចុប្បន្ន ការដែលនាមត្រកូលដាច់ដោយឡែករបស់ប្ដីប្រពន្ធត្រូវទទួលបានការពិចារណា គឺជាការព្យាយាមដើម្បីធានានូវសមភាពរវាងប្ដីប្រពន្ធ ដោយឈរលើស្ថានភាពជាក់ស្ដែងបែបនេះ។

## ២ ញាតិ

### ក) ញាតិ

នៅក្នុងច្បាប់ស្ដីពីគ្រួសារ ច្បាប់បញ្ញត្តពីទំនាក់ទំនងគតិយុត្តរវាងបុគ្គល និង បុគ្គលដោយផ្អែកលើចេនាសម្ព័ន្ធនៃក្រុមមនុស្សដែលត្រូវបានបង្កើតដោយផ្ដើមចេញពីទំនាក់ទំនងរវាងប្ដីប្រពន្ធ និង កូនរបស់ប្ដីប្រពន្ធនោះ ដែលហៅថា គ្រួសារ។ ក៏ប៉ុន្តែ មិនមានបញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណីស្ដីពីអត្ថន័យនៃគ្រួសារទេ ដោយគ្រាន់តែកំណត់អំពីទំនាក់ទំនងញាតិ ដោយផ្ដោតជាសំខាន់លើទំនាក់ទំនងដែលកើតឡើងជាធម្មតាអាស្រ័យដោយខ្សែលោហិត ដូចជាឪពុកម្ដាយ និង កូន និងទំនាក់ទំនងញាតិដែលកើតឡើងតាមបែបជាសិប្បនិម្មិត ដោយសារអាពាហ៍ពិពាហ៍ ។

មាត្រា ៧២៥ នៃក្រមរដ្ឋប្បវេណីមានកំណត់អំពីទំហំញាតិ ។ ពោលគឺញាតិត្រូវបានកំណត់យកត្រឹមញាតិលោហិតក្នុង ៦ ថ្នាក់ សហព័ទ្ធ និង ញាតិពន្ធក្នុង ៣ ថ្នាក់ ។

### ខ) ញាតិលោហិត ញាតិខ្សែផ្ទាល់ សាខាញាតិ បុព្វញាតិ បច្ឆាញាតិ

ញាតិលោហិតគឺសំដៅលើឪពុកម្តាយ និងកូន ជីដូនជីតា និងចៅ បងប្អូនប្រុសស្រី និង ឪពុកមាម្តាយមីង ឬ អ៊ំប្រុសអ៊ំស្រី និងក្មួយប្រុសក្មួយស្រី ដែលជាជនដែលជាប់ខ្សែលោហិតពីកំណើត។ ចំពោះការបង្កើតសុំកូន ក៏ត្រូវបានចាត់ទុកថាជាការបង្កើតទំនាក់ទំនងញាតិដូចទំនាក់ទំនងញាតិលោហិតដែរ។ ក្នុងន័យនេះ ញាតិលោហិតដែលកើតឡើងអាស្រ័យដោយការបង្កើតសុំកូន ហៅថា ញាតិលោហិត ដែលច្បាប់បានកំណត់ រីឯញាតិលោហិតដែលមានជាប់ខ្សែលោហិតពិតប្រាកដ ហៅថា ញាតិលោហិតពីកំណើត។ នៅក្នុងតារាងពន្យល់ គំនូសខ្សែដិតគឺបង្ហាញពីញាតិលោហិត។ ដោយមិនចាំបាច់បរិយាយច្រើន គឺថាដោយសារតែទំនាក់ទំនងបែបនេះ គឺជាទំនាក់ទំនងដែលមានទិសដៅទៅវិញទៅមក ដូច្នេះប្រសិនបើមើលពីខាងឪពុកម្តាយទៅ គឺកូនជាញាតិលោហិត ហើយប្រសិនបើមើលពីខាងកូនមកវិញ គឺឪពុកម្តាយ ក៏នៅតែជាញាតិលោហិត ។

ទំនាក់ទំនងរវាងឪពុកម្តាយ និង កូន ឬ ទំនាក់ទំនងរវាងជីដូនជីតា និង ចៅបែបនេះ គឺជាទំនាក់ទំនង ខ្សែលោហិតដែលត្រូវបានស្តែងចេញជាខ្សែត្រង់តែមួយពីលើចុះក្រោម និង ពីក្រោមឡើងលើ ដែលហៅថា ញាតិលោហិតខ្សែផ្ទាល់។ ផ្ទុយពីញាតិលោហិតខ្សែផ្ទាល់នេះ ទំនាក់ទំនងរវាងបងប្អូនប្រុសស្រី និង ឪពុកមាម្តាយមីង ឬ អ៊ំប្រុសអ៊ំស្រី និងក្មួយប្រុសក្មួយស្រី ដែលមានបុព្វបុរស (ក្រមរដ្ឋប្បវេណី ហៅថា "បុព្វជន") រួមដូចគ្នាបែបនេះ ត្រូវបានហៅថា សាខាញាតិលោហិត។ ម្យ៉ាងវិញទៀត ប្រសិនបើមើលពីខ្លួនឯងទៅឪពុកម្តាយ ជីដូនជីតា ឪពុកមាម្តាយមីង ឬ អ៊ំប្រុសអ៊ំស្រី ដែលជាជនស្ថិតក្នុងលំដាប់លើខ្លួន ហៅថា បុព្វញាតិ រីឯកូនចៅ ឬ ក្មួយ ដែលជាជនដែលស្ថិតក្នុងលំដាប់ក្រោមខ្លួន ហៅថា បច្ឆាញាតិ។ ក៏ប៉ុន្តែ ចំពោះទំនាក់ទំនងពីលើចុះក្រោម ឬ ពីក្រោមឡើងលើនៃសាខាញាតិ អ្នកដែលនៅជិតជាងយើងពីបុព្វបុរសរួម គឺនៅលើយើង (បុព្វញាតិ) រីឯអ្នកដែលនៅឆ្ងាយជាងយើងពីបុព្វបុរសរួម គឺនៅក្រោមយើង (បច្ឆាញាតិ)។ បងប្អូនបង្កើត ឬ ជីដូនមួយ គឺមិនមានទំនាក់ទំនងពីលើចុះក្រោម ឬ ពីក្រោមឡើងលើបែប នេះទេ ដូច្នេះ គឺមិនមែនជាបុព្វញាតិ ហើយក៏មិនមែនជាបច្ឆាញាតិដែរ។ ម្យ៉ាងវិញទៀត ដោយសារតែបុព្វញាតិ និង បច្ឆាញាតិ គឺជាទំនាក់ទំនងដែលឆ្លុះគ្នាទៅវិញទៅមក ដូច្នេះ ប្រសិនបើមើលពីខាងឪពុកម្តាយទៅកូន គឺជាបច្ឆាញាតិ ហើយប្រសិនបើមើលពីខាងកូនទៅឪពុកម្តាយគឺជាបុព្វញាតិ។

តារាងពន្យល់ ១៦-១ តារាងញាតិ (ញាតិលោហិត)




សំគាល់៖ លេខក្នុងរង្វង់ប្រាប់ពីថ្នាក់ញាតិ។ សាខាញាតិមួយផ្នែកត្រូវបានលុបចោល។

## គ) សហព័ទ្ធ និង ញាតិពន្ធ

សហព័ទ្ធមានន័យថា ភាគីម្ខាងទៀតនៃអាពាហ៍ពិពាហ៍ ដែលមានន័យថា ប្រសិនបើមើលពីខាងប្ដី បុគ្គលនោះគឺជាប្រពន្ធ ប្រសិនបើមើលពីខាងប្រពន្ធ បុគ្គលនោះគឺជាប្ដី។ នៅក្នុងតារាងពន្យល់ សហព័ទ្ធត្រូវបានស្ដែងដោយខ្សែបន្ទាត់ដែលមានពីរ ។

ញាតិពន្ធគឺមានន័យថា ទំនាក់ទំនងញាតិដែលកើតឡើងចំពោះទំនាក់ទំនងរវាងញាតិលោហិតនៃសហព័ទ្ធដោយសារអាពាហ៍ពិពាហ៍។ មានន័យថា ប្រសិនបើមើលពីខ្លួនឯងទៅ ញាតិលោហិតរបស់សហព័ទ្ធគឺជាញាតិពន្ធរបស់ខ្លួន។ ទំនាក់ទំនងញាតិពន្ធក៏ដោយ ក៏ជាទំនាក់ទំនងដែលមានទិសដៅទៅវិញទៅមកដូចទំនាក់ទំនងញាតិលោហិតដែរ ដូច្នេះ ប្រសិនបើមើលពីខាងញាតិលោហិតរបស់សហព័ទ្ធគឺខ្លួនជាញាតិពន្ធ។ សរុបមក ទំនាក់ទំនងញាតិពន្ធមិនមែនមានត្រឹមតែញាតិលោហិតរបស់សហព័ទ្ធទេ ក៏ប៉ុន្តែ សហព័ទ្ធរបស់ញាតិលោហិតក៏ត្រឡប់ទៅជាញាតិពន្ធដែរ ។

**តារាងពន្យល់ ១២-២ ញាតិពន្ធ**




**សំគាល់៖ លេខក្នុងរង្វង់ប្រាប់ពីថ្នាក់ញាតិ។**

ក្រមរដ្ឋប្បវេណីបានប្រើប្រាស់ទស្សនៈស្តីពីថ្នាក់ញាតិ នៅពេលគណនាចំនួនតំណពូជរវាងញាតិ។ មានន័យថា ថ្នាក់ញាតិបានស្តែងឡើងដោយការគណនាតំណពូជនោះ។ ចំពោះរបៀបគណនាតំណពូជវិញ ជាប្រវត្តិសាស្ត្រ មានទ្រឹស្តី និង ទស្សនៈជាច្រើន (មិនមែនមានន័យថាសុទ្ធតែផ្អែកលើទំនាក់ទំនងខ្សែលោហិតទាំងអស់ទេ) ក៏ប៉ុន្តែ ទំនាក់ទំនងញាតិនៃក្រមរដ្ឋប្បវេណីជប៉ុន បានទទួលយកនូវទ្រឹស្តីនៃច្បាប់រ៉ូម៉ាំង ដោយមាត្រា ៧២៦ កំណត់អំពីរបៀបគណនាថ្នាក់ញាតិនោះ។ ប្រសិនបើផ្អែកលើមាត្រានោះ ថ្នាក់ញាតិត្រូវកំណត់ដោយការគណនាចំនួននៃតំណពូជ (ចំនួននៃទំនាក់ទំនងរវាងឪពុកម្តាយ និង កូន) រវាងញាតិ។ ឧទាហរណ៍ ឪពុកម្តាយ និង កូនជាញាតិថ្នាក់ទី ១។ ជីដូនជីតា និងចៅ ជាញាតិថ្នាក់ទី ២។ ក្នុងករណីនៃញាតិលោហិតខ្សែផ្ទាល់ គ្រាន់តែគណនាទំនាក់ទំនងឪពុកម្តាយ និងកូនគឺជាការគ្រប់គ្រាន់ ដូច្នេះមិនមានបញ្ហាអ្វីកើតឡើងជាពិសេសទេ។ ក្នុងករណីនៃសាខាញាតិលោហិត វាក្លាយជាបញ្ហាគឺនៅពេលគណនាចំនួនតំណពូជដោយរាប់ថយក្រោយទៅបុព្វញាតិរួមពីខាងអ្នកទាំងពីរ ហើយពីម្ខាងទៀតគឺត្រូវគណនាតំណពូជនោះដោយរាប់ចុះទៅក្រោម។ ករណីបងប្អូនជីដូនមួយ ត្រូវគណនាដោយរាប់ពីខ្លួនឯងថយក្រោយទៅរកជីដូនជីតាដែលជាបុព្វញាតិរួម (ញាតិថ្នាក់ទី ២) ហើយដោយសារតែត្រូវគណនាដោយរាប់ពីជីដូនជីតាចុះមកវិញ (ថ្នាក់ទី ២) ដូច្នេះទំនាក់ទំនងញាតិនឹងក្លាយទៅជាថ្នាក់ទី ៤។

ចំពោះញាតិពន្ធ គឺត្រូវគណនាដោយផ្អែកលើថ្នាក់ញាតិលោហិត។ មានន័យថា ចំពោះញាតិលោហិតនៃសហព័ទ្ធរបស់ខ្លួន (ប្រសិនបើមើលពីខាងខ្លួនទៅ ពួកគេជាញាតិពន្ធ) គឺអាចគណនាថ្នាក់ញាតិបាន ដោយយកសហព័ទ្ធជាមូលដ្ឋាននៃការគណនា។ ម្យ៉ាងវិញទៀត ចំពោះសហព័ទ្ធនៃញាតិលោហិតរបស់ ខ្លួនគឺអាចគណនាបានដោយយកញាតិលោហិតរបស់ខ្លួនជាមូលដ្ឋាន ។

## ៣ សហព័ទ្ធ

### (១) អាពាហ៍ពិពាហ៍

#### ក) អត្ថន័យនៃអាពាហ៍ពិពាហ៍

អាពាហ៍ពិពាហ៍មានន័យថាជាទំនាក់ទំនងនៃការចងសម្ព័ន្ធភាពភេទ រវាងបុរស និង នារីដែលត្រូវបានទទួលស្គាល់ថាជារបបសង្គមមួយ។ ជាប្រវត្តិសាស្ត្រ អាពាហ៍ពិពាហ៍កើតមានក្នុងសណ្ឋានច្រើនបែបច្រើនយ៉ាង ដែលខ្លះជាអាពាហ៍ពិពាហ៍ដែលមានលក្ខណៈជាពហុពន្ធភាព ក៏ប៉ុន្តែ នាសម័យបច្ចុប្បន្ន មានប្រទេសជាច្រើនដែលកំណត់យករបបអាពាហ៍ពិពាហ៍ឯកពន្ធភាព។ នៅប្រទេសណាក៏មានរបបអាពាហ៍ពិពាហ៍ដែរ ក៏ប៉ុន្តែ ចំពោះខ្លឹមសារលម្អិតគឺមានចំណុចខុសគ្នាតិច ឬ ច្រើនទៅតាមប្រទេសនីមួយៗ។ ជាពិសេស នៅក្នុងបណ្តាប្រទេសជាច្រើន មានអាពាហ៍ពិពាហ៍ដែលទទួលឥទ្ធិពល

យ៉ាងខ្លាំងក្លាពីជំនឿ ឬ សាសនា។ ឧទាហរណ៍ នៅលោកខាងលិច គេឃើញមានឥទ្ធិពលនៃសាសនាគ្រិស្ត រីឯនៅក្នុងបណ្ដាប្រទេសកាន់សាសនាអ៊ីស្លាមវិញ គេឃើញមានឥទ្ធិពលនៃសាសនាអ៊ីស្លាម។ ផ្ទុយទៅវិញ របបអាពាហ៍ពិពាហ៍នៅប្រទេសជប៉ុនវិញ មានលក្ខណៈពិសេសត្រង់ថា មិនសូវមានឥទ្ធិពលសាសនានោះទេ ។

## ខ) ការបង្កើតអាពាហ៍ពិពាហ៍

អាពាហ៍ពិពាហ៍កើតមានអានុភាពនៅពេលដែលប្រកាសជាសាធារណៈ ដោយអនុលោមតាមច្បាប់ស្ដីពីការចុះបញ្ជីគ្រួសារ (មាត្រា ៧៣៩ នៃក្រមរដ្ឋប្បវេណី)។ ដើម្បីឲ្យអាចទទួលបាននូវការប្រកាសជាសាធារណៈ ល័ក្ខខ័ណ្ឌគ្រឹះដែលមានកំណត់ចាប់ពីមាត្រា ៧៣១ ត្រូវតែបានបំពេញ។ ល័ក្ខខ័ណ្ឌទាំងនោះត្រូវបានហៅថាជាល័ក្ខខ័ណ្ឌគ្រឹះ ក៏ប៉ុន្តែ មូលហេតុទាំងនោះភាគច្រើនជាមូលហេតុដែលមិនអាចរៀបអាពាហ៍ពិពាហ៍បាន (ការហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍)។ មូលហេតុទាំងនោះគឺមានប្រភពចេញមកពីមូលដ្ឋាននៃសីលធម៌ និង មូលដ្ឋាននៃវិទ្យាសាស្ត្រដែលសិក្សាពីការវិវដ្តនៃសាព៌ាង្គកាយ និង បញ្ញារបស់មនុស្ស ។

ទី ១ បុរសដែលមិនទាន់គ្រប់អាយុ ១៨ ឆ្នាំ រីឯនារីមិនទាន់គ្រប់អាយុ ១៦ ឆ្នាំ ទេ គឺមិនអាចរៀបអាពាហ៍ពិពាហ៍បានឡើយ (មាត្រា ៧៣១ នៃក្រមរដ្ឋប្បវេណី)។ ក៏ប៉ុន្តែ បើទោះបីជាអនីតិជនក៏ដោយ ប្រសិនបើដល់វ័យដែលអាចរៀបអាពាហ៍ពិពាហ៍បានហើយ គឺអាចរៀបអាពាហ៍ពិពាហ៍បាន ក៏ប៉ុន្តែ ដើម្បីរៀបអាពាហ៍ពិពាហ៍ អនីតិជនចាំបាច់ត្រូវទទួលបានការយល់ព្រមពីឪពុកម្ដាយ (មាត្រា ៧៣៧ នៃក្រមរដ្ឋប្បវេណី)។ ទី ២ បុគ្គលដែលមានសហព័ទ្ធរួច មិនអាចរៀបអាពាហ៍ពិពាហ៍មួយផ្សេងទៀតបានទេ (មាត្រា ៧៣២ នៃក្រមរដ្ឋប្បវេណី)។ ក៏ប៉ុន្តែ ប្រសិនបើធ្លាប់បានរៀបអាពាហ៍ពិពាហ៍ម្ដងហើយក៏ដោយ ប្រសិនបើអាពាហ៍ពិពាហ៍នោះបានរលាយ ដោយសារសហព័ទ្ធម្ខាងទៀតបានទទួលមរណភាព ឬ ដោយសារការលែងលះ គឺអាចរៀបអាពាហ៍ពិពាហ៍ជាថ្មីម្ដងទៀតបាន។ ក៏ប៉ុន្តែចំពោះនារីវិញ គឺមិនអាចរៀបអាពាហ៍ពិពាហ៍សាជាថ្មីម្ដងទៀតបានទេ ប្រសិនបើអំឡុងពេល ៦ ខែគិតចាប់ពីពេលលែងលះមិនទាន់បានរំលងផុត (មាត្រា ៧៣៣ នៃក្រមរដ្ឋប្បវេណី)។ ការទុកអំឡុងពេលហាមឃាត់បែបនេះគឺដើម្បីអាចដឹងបានថា នរណាជាឪពុករបស់កូនដែលត្រូវកើត។ ទី ៣ អាពាហ៍ពិពាហ៍រវាងបុគ្គលនៅក្នុងទំនាក់ទំនងញាតិជាកំណត់មួយត្រូវហាមឃាត់ (មាត្រា ៧៣៤ ដល់ មាត្រា ៧៣៦ នៃក្រមរដ្ឋប្បវេណី)។ មានន័យថា អាពាហ៍ពិពាហ៍រវាងញាតិលោហិតខ្សែផ្ទាល់ (ឧទាហរណ៍ រវាងជីដូនជីតា និង ចៅ) ឬ អាពាហ៍ពិពាហ៍រវាងសាខាញាតិលោហិតក្នុងបីថ្នាក់ (ឧទាហរណ៍ដូចជា រវាងពូ ឬ អ៊ំប្រុសជាមួយក្មួយស្រី ឬ រវាងម្ដាយមីង ឬ អ៊ំស្រី ជាមួយក្មួយប្រុស) ឬ អាពាហ៍ពិពាហ៍ រវាងញាតិពន្ធខ្សែផ្ទាល់ (ឧទាហរណ៍ដូចជា រវាងកូនរបស់សហព័ទ្ធ ជាមួយឪពុកចុង) ជាដើម ត្រូវបានហាមឃាត់ ។

### គ) អានុភាពនៃអាពាហ៍ពិពាហ៍

នៅពេលដែលអាពាហ៍ពិពាហ៍កើតឡើង អានុភាពតាមផ្លូវច្បាប់ជាក់លាក់មួយចំនួនដែលពាក់ព័ន្ធទៅនឹងឋានៈបុគ្គល និង ទ្រព្យសម្បត្តិ នឹងកើតឡើងចំពោះសហព័ទ្ធ។ អានុភាពនៃឋានៈបុគ្គល គឺនឹងមានដូចពន្យល់ជាបន្តទៅនេះ។ ទី ១ នាមត្រកូលរួមរបស់សហព័ទ្ធ (មាត្រា ៧៥០ នៃក្រមរដ្ឋប្បវេណី)។ មានន័យថា សហព័ទ្ធមាននាមត្រកូលមួយរបស់ខ្លួន ក៏ប៉ុន្តែនៅពេលរៀបអាពាហ៍ពិពាហ៍ ចាំបាច់ត្រូវតែជ្រើសរើសប្រើនាមត្រកូលរបស់ប្ដី ឬ ប្រពន្ធដោយខានមិនបាន។ ទី ២ ករណីយកិច្ចរួមរស់ជាមួយគ្នា សហការគ្នា និង សង្គ្រោះគ្នាទៅវិញទៅមក (មាត្រា ៧៥២ នៃក្រមរដ្ឋប្បវេណី)។ មានន័យថា សហព័ទ្ធត្រូវប្រើប្រាស់ជីវិតអាពាហ៍ពិពាហ៍ដោយការរួមរស់នៅជាមួយគ្នា សហការគ្នា និង មានករណីយកិច្ចសង្គ្រោះគ្នាទៅវិញទៅមក។ ទី ៣ ករណីយកិច្ចស្មោះត្រង់។ ក្រមរដ្ឋប្បវេណីពុំមានចែងដោយផ្ទាល់នូវបញ្ញត្តិស្ដីពីករណីយកិច្ចស្មោះត្រង់របស់សហព័ទ្ធនោះទេ ក៏ប៉ុន្តែ ចំណុចទី ១ កថាខណ្ឌទី ១ នៃមាត្រា ៧៧០ ទទួលស្គាល់ថា អំពើផិតក្បត់របស់សហព័ទ្ធជាមូលហេតុនៃការលែងលះ ដែលមានន័យថាជាការទទួលស្គាល់ករណីយកិច្ចស្មោះត្រង់របស់សហព័ទ្ធ។ ទី៤ ការចាត់ទុកជានីតិជនដោយសារអាពាហ៍ពិពាហ៍ (មាត្រា ៧៥៣ នៃក្រមរដ្ឋប្បវេណី)។ មានន័យថា ប្រសិនបើអនីតិជនបានរៀបអាពាហ៍ពិពាហ៍ គាត់នឹងត្រូវបានចាត់ទុកថាជាបុគ្គលដែលមានសមត្ថភាពធ្វើសកម្មភាពដែរ។ សហព័ទ្ធដែលបានរៀបអាពាហ៍ពិពាហ៍មិនចាំបាច់បារម្ភពីការចូលជ្រៀតជ្រែកពីអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលក្នុងឋានៈជាអ្នកតំណាងដែលកំណត់ដោយច្បាប់ទេ។ ទី ៥ សិទ្ធិលុបចោលកិច្ចសន្យារវាងសហព័ទ្ធ (មាត្រា ៧៥៤ នៃក្រមរដ្ឋប្បវេណី)។ មានន័យថា ភាគីម្ខាងអាចលុបចោលកិច្ចសន្យាដែលបានធ្វើឡើងរវាងគូភាគីនៅពេលណាក៏បាន។ ឧទាហរណ៍ថា ប្រសិនបើប្រពន្ធត្រូវបានប្ដីបង្ខំឲ្យចុះកិច្ចសន្យាដែលខាតប្រយោជន៍ណាមួយ គាត់អាចលុបចោលកិច្ចសន្យានោះនៅពេលក្រោយបាន នេះគឺដើម្បីជាការការពារដល់សហព័ទ្ធជាប្រពន្ធ។

### ឃ) ប្រព័ន្ធទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធ

អានុភាពចំពោះទ្រព្យសម្បត្តិនៃអាពាហ៍ពិពាហ៍គឺផ្ដោតជាសំខាន់ទៅលើប្រព័ន្ធទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធ។ ប្រព័ន្ធទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធ គឺជារបបដែលកំណត់អំពីទំនាក់ទំនងទ្រព្យសម្បត្តិរវាងប្ដីប្រពន្ធនៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ (ជាពិសេស ទ្រព្យសម្បត្តិដែលរកបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍)។

នៅអឺរ៉ុប នៅពេលរៀបអាពាហ៍ពិពាហ៍ គេមានទម្លាប់ព្រមព្រៀងគ្នាចំពោះទ្រព្យសម្បត្តិរបស់សហព័ទ្ធ ដោយផ្អែកលើទម្លាប់នេះ ក្រមរដ្ឋប្បវេណីបានចែងបញ្ញត្តិលម្អិតពាក់ព័ន្ធជាមួយប្រព័ន្ធទ្រព្យសម្បត្តិរបស់ប្ដីប្រពន្ធ។ ជាទូទៅ មានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីនូវប្រភេទប្រព័ន្ធទ្រព្យសម្បត្តិរួម

របស់ប្តីប្រពន្ធមួយចំនួន ហើយនៅពេលរៀបអាពាហ៍ពិពាហ៍ សហព័ទ្ធអាចជ្រើសរើសប្រភេទណាបានតាមរយៈកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ (ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា) ហើយប្រសិនបើក្នុងករណីដែលសហព័ទ្ធមិនបានធ្វើកិច្ចសន្យាទ្រព្យសម្បត្តិនៅពេលរៀបអាពាហ៍ពិពាហ៍ទេ ច្បាប់កំណត់ថា ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ត្រូវយកមកអនុវត្ត។ ហេតុដូច្នេះ ប្រព័ន្ធទ្រព្យសម្បត្តិដែលបានជ្រើសរើសនៅពេលរៀបអាពាហ៍ពិពាហ៍ ជាគោលការណ៍ មិនអាចកែប្រែបានទេ (ថ្មីៗនេះដូចជានៅប្រទេសបារាំង យុត្តិសាស្ត្របានទទួលស្គាល់ការកែប្រែប្រព័ន្ធទ្រព្យសម្បត្តិដែលបានជ្រើសរើសហើយនៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍)។

ដោយឡែកនៅប្រទេសជប៉ុនវិញ ទំនៀមទម្លាប់នៃប្រព័ន្ធទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធដែលកំពុងអនុវត្តមិនមានទេ ហើយក៏មិនមានការកំណត់នូវប្រភេទនៃប្រព័ន្ធទ្រព្យសម្បត្តិបែបនោះជាពិសេសអ្វីដែរ ដោយប្រព័ន្ធទ្រព្យសម្បត្តិត្រូវកំណត់ទៅតាមការព្រមព្រៀងគ្នាដោយសេរីរបស់ប្តីប្រពន្ធ (មាត្រា ៧៥៥ នៃក្រមរដ្ឋប្បវេណី) ហើយក្នុងករណីដែលគ្មានការព្រមព្រៀងគ្នាទេ ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ដែលមាននៅក្នុងតែ ៣ មាត្រា ត្រូវយកមកអនុវត្ត។ នៅក្នុងស្ថានភាពជាក់ស្តែងការព្រមព្រៀងគ្នាអំពីប្រព័ន្ធទ្រព្យសម្បត្តិនៅពេលរៀបអាពាហ៍ពិពាហ៍ស្ទើរតែគ្មានទេ ។

## ង) ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់

ខ្លឹមសារនៃប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់គឺមានដូចតទៅនេះ។ ទី ១ សហព័ទ្ធត្រូវទទួលបន្ទុកចំពោះសោហ៊ុយនៃអាពាហ៍ពិពាហ៍ (សោហ៊ុយសម្រាប់ជីវភាពរស់នៅរបស់ឪពុកម្តាយ និងកូន និងសោហ៊ុយសម្រាប់ជីវភាពរស់នៅរបស់សហព័ទ្ធ) (មាត្រា ៧៦០ នៃក្រមរដ្ឋប្បវេណី)។ បញ្ញត្តិនេះមិនមែន មានន័យថា សហព័ទ្ធត្រូវទទួលបន្ទុកស្មើគ្នាចំពោះចំនួននៃសោហ៊ុយចំណាយនោះទេ ក៏ប៉ុន្តែរបៀបបែងចែកបន្ទុកគឺត្រូវបានកំណត់ថាត្រូវគិតទៅដល់ស្ថានភាពនានាទាំងឡាយ ដូចជាធនធាន ឬ ចំណូលរបស់សហព័ទ្ធ ជាដើម។ ឧទាហរណ៍ បើទោះជាក្នុងករណីដែលជីវភាពប្រចាំថ្ងៃរបស់គ្រួសារត្រូវពឹងផ្អែកទាំងស្រុងលើប្រាក់ចំណូលដែលបានមកដោយសារប្តីធ្វើការនៅខាងក្រៅតែម្នាក់ឯងក៏ដោយ ការដែលភរិយារ៉ាប់រងការងារផ្ទះ និង ការបីបាច់ថែរក្សាកូន ក៏អាចនិយាយបានថារួមចំណែកចំពោះបន្ទុកសោហ៊ុយដែរ។ ទី ២ ប្រសិនបើសហព័ទ្ធណាម្ខាងបានធ្វើសកម្មភាពគតិយុត្តណាមួយដែលពាក់ព័ន្ធនឹងជីវភាពប្រចាំថ្ងៃ សហព័ទ្ធម្ខាងទៀតក៏ត្រូវទទួលខុសត្រូវដោយសាមគ្គីភាពចំពោះកាតព្វកិច្ចដែលកើតឡើងពីសកម្មភាពនោះដែរ (មាត្រា ៧៦១ នៃក្រមរដ្ឋប្បវេណី)។ ឧទាហរណ៍ថា ក្នុងករណីដែលប្រពន្ធបានទិញអង្ករ ភាគីក្នុងកិច្ចសន្យាលក់ទិញចំពោះថ្លៃលក់ទិញមិនមែនតែប្រពន្ធម្នាក់ឯងទេ ប្តីក៏ត្រូវទទួលករណីយកិច្ចបង់ថ្លៃលក់ទិញនោះដែរ។ ទី ៣ សហព័ទ្ធតែម្ខាងណាម្នាក់ដែលមានទ្រព្យសម្បត្តិនៅមុនអាពាហ៍ពិពាហ៍ ឬ ដែលទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ដោយក្នុងនាមរបស់ខ្លួនផ្ទាល់ អាចគ្រប់គ្រងដោយផ្ទាល់ និង ចាត់ចែងទ្រព្យនោះ

តាមឆន្ទៈរបស់ខ្លួនបានដោយឯករាជ្យ ក៏ប៉ុន្តែ ប្រសិនបើមិនច្បាស់ថាជារបស់សហព័ទ្ធណាមួយទេ ត្រូវចាត់ទុកថាជាទ្រព្យសម្បត្តិរួមរបស់សហព័ទ្ធទាំងពីរ (មាត្រា ៧៦២ នៃក្រមរដ្ឋប្បវេណី) ។

### ច) អនីតិសង្វាស

ក៏ប៉ុន្តែ ប្រសិនបើមិនបានធ្វើការប្រកាសជាសាធារណៈទេ អាពាហ៍ពិពាហ៍មិនកើតឡើងទេ (របបអាពាហ៍ពិពាហ៍ដែលតម្រូវឲ្យប្រកាសជាសាធារណៈបែបនោះ ហៅថា គោលការណ៍នៃអាពាហ៍ពិពាហ៍តាមច្បាប់) ក៏ប៉ុន្តែ ក៏មានករណីដែលបុរសនារីរួមរស់ជាមួយគ្នានៅក្នុងសង្គមដូចជាប្ដីប្រពន្ធត្រឹមត្រូវតាមផ្លូវច្បាប់ ដោយមិនប្រកាសជាសាធារណៈដែរ។ ឧទាហរណ៍ ដូចជាករណីដែលបានរៀបចំធ្វើពីធីមង្គលការ និង ជប់លៀង ជាដើម ក៏ប៉ុន្តែបានព្រងើយកន្តើយក្នុងការប្រកាសជាសាធារណៈតាមការកំណត់របស់ច្បាប់។ បុរសនារីដែលរស់នៅជាមួយគ្នាបែបនោះត្រូវបានហៅថា អនីតិសង្វាសជន ក៏ប៉ុន្តែ ពួកគេមិនត្រូវចាត់ទុកថាគ្រាន់តែជាជនដែលរស់នៅជាមួយគ្នាដូចជាប្ដីប្រពន្ធប៉ុណ្ណោះទេ ក៏ប៉ុន្តែគឺដូចជាបានរៀបអាពាហ៍ពិពាហ៍អញ្ចឹងដែរ ពោលគឺទទួលបាននូវការគាំពារជាកំណត់មួយ។ ជាពិសេស ដូចជានៅក្នុងច្បាប់ដែលទាក់ទងទៅនឹងសុខុមាលភាពសង្គម និង ប្រាក់សោធននិវត្តន៍ ជាដើម មានចំណុចជាច្រើនដែលប្រព្រឹត្តកម្មចំពោះប្ដីប្រពន្ធនៃអនីតិសង្វាស ដូចគ្នាទៅនឹងប្រព្រឹត្តកម្មចំពោះប្ដីប្រពន្ធដែលមានចំណងអាពាហ៍ពិពាហ៍តាមច្បាប់ដែរ ។

### (២) ការលែងលះ

### ក) អត្ថន័យនៃការលែងលះ

ការលែងលះមានន័យថាជាការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍ (ប៉ុន្តែ ក្នុងករណីដែលសហព័ទ្ធណាម្ខាងបានទទួលមរណភាព ក៏អាពាហ៍ពិពាហ៍ត្រូវរលាយដែរ)។ ការរំលាយអាពាហ៍ពិពាហ៍ក្នុងន័យនេះ គឺសំដៅលើការរំដោះខ្លួនឲ្យរួចពីចំណងនៃទំនាក់ទំនងអាពាហ៍ពិពាហ៍ដែលខ្លួនធ្លាប់ជាបុគ្គលដែលជាសហព័ទ្ធ។ ឧទាហរណ៍ ករណីយកិច្ចរួមរស់នៅជាមួយគ្នា សហការគ្នា និង មានករណីយកិច្ចសង្គ្រោះគ្នាទៅវិញទៅមកត្រូវរលត់ (បើទោះជាសហព័ទ្ធដែលបានលែងលះអះអាងថា ជីវភាពរស់នៅមានការលំបាកក៏ដោយ ក៏បុគ្គលម្ខាងទៀតដែលជាអតីតសហព័ទ្ធមិនមានករណីយកិច្ចសង្គ្រោះដែរ)។ ម្យ៉ាងវិញទៀត ករណីយកិច្ចស្មោះត្រង់ ក៏ត្រូវរលត់ទៅតាមនោះដោយឯកឯងដែរ ដោយគេអាចរៀបអាពាហ៍ពិពាហ៍ជាថ្មីម្តងទៀតបាន ។

អាពាហ៍ពិពាហ៍ក៏ដូចគ្នាដែរ ដោយសារតែវាកើតឡើងអាស្រ័យទៅលើការព្រមព្រៀងរបស់បុគ្គលដែលនឹងក្លាយទៅជាសហព័ទ្ធ អាចនិយាយបានថា វាជាប្រភេទនៃកិច្ចសន្យាមួយដែលមានអត្ថន័យទូលំទូលាយ។ ក៏ប៉ុន្តែ ប្រសិនបើធ្វើការប្រៀបធៀបជាមួយនឹងកិច្ចសន្យាតាមច្បាប់ស្ដីពីទ្រព្យសម្បត្តិ

ការបញ្ចប់ទំនាក់ទំនងកិច្ចសន្យាទ្រព្យសម្បត្តិ អាចត្រូវបានទទួលស្គាល់ដោយងាយ (ហៅថា ការរំលាយ)។ ជាពិសេស ការរំលាយទំនាក់ទំនងកិច្ចសន្យាទៅតាមការព្រមព្រៀងរបស់គូភាគីនៃកិច្ចសន្យាជាគោលការណ៍ អាចត្រូវបានទទួលស្គាល់ដោយសេរី ។ ក៏ប៉ុន្តែ ចំពោះករណីនៃអាពាហ៍ពិពាហ៍វិញ ការរំលាយ ពោលគឺការលែងលះ មិនមែនអាចធ្វើបានដោយសេរីនោះទេ។ ហេតុផលគឺថា ដោយសារតែវាមានករណីដែលសហព័ទ្ធម្ខាងទៀត (ជាទូទៅ គឺប្រពន្ធ) ទទួលរងផលប៉ះពាល់យ៉ាងខ្លាំងពីការលែងលះនោះ។

នៅប្រទេសជប៉ុន ការលែងលះធ្លាប់ត្រូវបានទទួលស្គាល់តាំងពីជំនាន់មេជិមកម្លេះ ក៏ប៉ុន្តែបើធ្វើការប្រៀបធៀបទៅប្រទេសលោកខាងលិច ទើបតែទទួលស្គាល់ឲ្យមានការលែងលះនាពេលថ្មីៗនេះទេ។ មានន័យថា ជាប្រវត្តិសាស្ត្រ មិនមែនរដ្ឋទេ តែជាសាសនាគ្រិស្តទេដែលគ្រប់គ្រងទំនាក់ទំនងឋានៈបុគ្គល ដូច្នេះ អាពាហ៍ពិពាហ៍គឺជាផ្នែកមួយនៃការតាំងសញ្ញា (ការសម្គាល់ពីភាពប្តូរផ្តាច់) (sacrament) ដោយត្រូវធ្វើឲ្យស្ថិតស្ថិរហូតដល់ជីវិតចុងក្រោយ (អាពាហ៍ពិពាហ៍ត្រូវបានយល់ឃើញថាជាការរួមដំណេក និង ទទួលទានអាហារជាមួយគ្នា) ដោយហេតុនោះមិនទទួលស្គាល់ឲ្យមានការលែងលះទេ។ ឧទាហរណ៍ ប្រទេសបារាំងឆ្លងកាត់បដិវត្តន៍បារាំងឆ្នាំ ១៧៨៩ បានចែងយ៉ាងច្បាស់ថាទំនាក់ទំនងអាពាហ៍ពិពាហ៍គឺជាសកម្មភាពស៊ីវិលដែលអនុលោមទៅតាមច្បាប់ (មានន័យថា អាពាហ៍ពិពាហ៍មិនមែនជាសកម្មភាពសាសនាទេ ក៏ប៉ុន្តែ ជាបញ្ហាដែលមិនមានលក្ខណៈជាសាសនា) និងបានចាប់ផ្តើមដកហូតយកអំណាចគ្រប់គ្រងពីសាសនាគ្រិស្តមកឲ្យរដ្ឋវិញ ហើយនៅពេលជាមួយគ្នានោះបានចាប់ផ្តើមទទួលស្គាល់ឲ្យមានរបបលែងលះ។ ក៏ប៉ុន្តែ ដោយឡែកចំពោះបណ្តាប្រទេសមួយចំនួននៅអឺរ៉ុបខាងត្បូងដែលទទួលឥទ្ធិពលសាសនាគ្រិស្ត(កាតូលិក) ខ្លាំង ដូចជា អ៊ីតាលី និង អេស្ប៉ាញ ជាដើម និង បណ្តាប្រទេសអតីតដែនដីអាណានិគមនៅអាមេរិកខាងត្បូងមួយចំនួន ទើបតែបានទទួលស្គាល់ឲ្យមានការលែងលះនៅក្នុងប្រហែលចុងទសវត្សរ៍ ១៩៦០ ប៉ុណ្ណោះ។ ឧទាហរណ៍ ដូចជាប្រទេសអ៊ីតាលី ច្បាប់ស្តីពីការលែងលះត្រូវបានអនុម័តក្នុងឆ្នាំ ១៩៦៩ ដោយចែងថា ការលែងលះគឺជាការបញ្ចប់នូវអានុភាពនៃអាពាហ៍ពិពាហ៍តាមសកម្មភាពស៊ីវិល ដែលចំណុចនេះបង្ហាញឲ្យឃើញនូវឥទ្ធិពលដ៏ខ្លាំងក្លានៃសាសនាគ្រិស្ត។

## ខ) មូលហេតុនៃការលែងលះ

បើទោះបីជារបបលែងលះត្រូវបានទទួលស្គាល់ពិតមែនក៏ដោយ ក៏មូលហេតុនៃការលែងលះត្រូវបាន កម្រិតយ៉ាងតឹងរ៉ឹងដែរ។ ពោលគឺបើទោះជាបានព្រមព្រៀងគ្នាដើម្បីរៀបអាពាហ៍ពិពាហ៍ក៏ដោយក៏ការលែងលះត្រូវបានគិតថា មិនគួរទទួលស្គាល់ដោយងាយៗដោយគ្រាន់តែមានឆន្ទៈលែងលះរបស់សហព័ទ្ធតែម្ខាងនោះទេ (ការលែងលះដែលត្រូវបានទទួលស្គាល់ដោយសេរីដោយផ្អែកលើឆន្ទៈតែម្ខាងហៅថា ការលែងលះដោយឆន្ទៈទោល ឬ ហៅថាការលែងលះដោយការបណ្តេញចេញ)។ ក្នុងន័យនេះ

គឺត្រូវថ្លឹងថ្លែងពីការការពារចំពោះភាគីម្ខាងទៀតដែលគ្មានបំណងលែងលះ ដោយការរឹតបន្តឹងចំពោះមូលហេតុដែលសមរម្យសម្រាប់ការលែងលះ ។

នៅពេលដែលរបបលែងលះត្រូវបានទទួលស្គាល់នាគ្រាដំបូង គោលការណ៍កំហុសត្រូវបានអនុម័តយក ដោយសហព័ទ្ធម្ខាងអាចទាមទារលែងលះបានដោយហេតុផលថា ភាគីម្ខាងទៀតបានធ្វើឲ្យទំនាក់ទំនងអាពាហ៍ពិពាហ៍បែកបាក់ ឧទាហរណ៍ ដូចជាក្នុងករណីដែលប្តីទៅមានទំនាក់ទំនងផ្លូវភេទ ជាមួយស្ត្រីផ្សេងក្រៅពីប្រពន្ធរបស់ខ្លួន ជាដើម ។ ក្រោយពីនោះមក មូលហេតុនៃការលែងលះត្រូវបានពង្រីកជាបន្តបន្ទាប់ ក៏ប៉ុន្តែ ទំនោរនោះត្រូវបានលេចឡើងនៅអឺរ៉ុប និង អាមេរិក មុន និង ក្រោយឆ្នាំ ១៩៧០។ ជាលទ្ធផលនៃទំនោរនោះ នៅក្នុងបណ្តាប្រទេសជាច្រើន គោលការណ៍នៃការបែកបាក់ត្រូវបានអនុម័តយក ដែលមានន័យថាជាការទទួលស្គាល់ការលែងលះ ដោយគ្រាន់តែផ្អែកលើអង្គហេតុជាក់ស្តែងស្តីពីការបែកបាក់ចំណងអាពាហ៍ពិពាហ៍ប៉ុណ្ណោះ។ ការបែកបាក់ចំណងអាពាហ៍ពិពាហ៍សំដៅទៅលើការបន្តរស់នៅបែកគ្នាជាក់ស្តែងនៅក្នុងអំឡុងពេលជាកំណត់មួយ (អំឡុងពេលនេះវែង ឬ ខ្លី គឺអាស្រ័យទៅតាមប្រទេសនីមួយៗ)។ ឧទាហរណ៍នៃការរស់នៅបែកគ្នានោះ គឺដូចជាក្នុងករណីសិក្សាដែលមានន័យថាអាចមានលទ្ធភាពដែលការទាមទារលែងលះរបស់ A ចំពោះ B អាចត្រូវបានទទួលស្គាល់ ។

ក៏ប៉ុន្តែ ទន្ទឹមនឹងទទួលស្គាល់នូវគោលការណ៍នៃការបែកបាក់ ក៏នៅតែបន្តទទួលស្គាល់គោលការណ៍នៃការមិនទទួលស្គាល់ការលែងលះដោយឆន្ទៈទោលដែរ ហើយបញ្ញត្តិជាច្រើនត្រូវបានតាក់តែងឡើងដើម្បីការពារសហព័ទ្ធម្ខាងទៀតដែលត្រូវបានបង្ខំឲ្យធ្វើការលែងលះ។ ទីមួយគឺថា បើទោះបីជាអាពាហ៍ពិពាហ៍បែកបាក់ក៏ពិតមែនក៏ដោយ ក៏ប៉ុន្តែ ប្រសិនបើការលែងលះធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងទៅដល់សហព័ទ្ធម្ខាងទៀត ការលែងលះគឺមិនអាចទទួលយកបានទេ (ហៅថា បញ្ញត្តិតឹងតែង)។ ម្យ៉ាងវិញទៀត គឺការមិនទទួលខុសត្រូវចំពោះភាគីម្ខាងទៀតដែលត្រូវបានធ្វើឲ្យទទួលរងនូវផលប៉ះពាល់ខាងទ្រព្យសម្បត្តិ ដោយសារការលែងលះ (បុគ្គលដែលទាមទារលែងលះត្រូវទទួលបន្ទុកនោះ)។ ឧទាហរណ៍ យើងឃើញមានការដាក់បន្ទុកឲ្យសហព័ទ្ធដែលបានទាមទារលែងលះមានអាហារកិច្ចចំពោះភាគីម្ខាងទៀតនៅក្រោយពេលលែងលះ ។

### គ) ការលែងលះដោយការព្រមព្រៀង

ក្រមរដ្ឋប្បវេណីជប៉ុនកំណត់អំពីការលែងលះដោយការព្រមព្រៀង ដែលត្រូវបានទទួលស្គាល់ដោយសេរីទៅតាមការព្រមព្រៀងរបស់សហព័ទ្ធ និង ការលែងលះតាមផ្លូវតុលាការដែលត្រូវបានទទួលស្គាល់ ដោយការវិនិច្ឆ័យរបស់តុលាការដោយសារមូលហេតុនៃការលែងលះជាកំណត់ណាមួយ។ នៅបស្ចឹមប្រទេស ក៏ដូចគ្នាដែរ ការទទួលស្គាល់ការលែងលះតាមការព្រមព្រៀងរបស់សហព័ទ្ធគឺមាន

មិនតិចទេ ក៏ប៉ុន្តែ ក៏ភាគច្រើនគឺមានការបញ្ញត្តថា តុលាការត្រូវធ្វើការបញ្ជាក់ឲ្យច្បាស់ថាតើភាគីមានឆន្ទៈលែងលះពិតប្រាកដ ឬ យ៉ាងណា។ ឧទាហរណ៍ ដូចជានៅប្រទេសបារាំង បើទោះជាប្តីប្រពន្ធបានព្រមព្រៀងលែងលះគ្នាក៏ដោយ ប្តីប្រពន្ធត្រូវដាក់ពាក្យសុំលែងលះរួមគ្នាទៅតុលាការ និង ត្រូវតែទទួលបានសាលក្រមលែងលះ ជាចាំបាច់។ ដោយឡែកនៅប្រទេសជប៉ុនវិញ មានការទទួលស្គាល់ការលែងលះដោយសេរីដោយគ្រាន់តែភាគីធ្វើការប្រកាសជាសាធារណៈអំពីការព្រមព្រៀងលែងលះប៉ុណ្ណោះ ដោយពុំមានប្រព័ន្ធសម្រាប់ធ្វើការបញ្ជាក់ឲ្យច្បាស់ថាតើឆន្ទៈលែងលះនោះមានពិតមែន ឬ យ៉ាងណា ។ ដោយហេតុនេះ សហព័ទ្ធដែលទន់ខ្សោយជាង (ភាគច្រើនគឺជាប្រពន្ធ) បើទោះបីជាមិនចង់លែងលះក៏ដោយ ក៏អាចនឹងត្រូវបានកៀបសង្កត់ឲ្យលែងលះដែរ។ ក៏ប៉ុន្តែ ដោយសារតែមានការទទួលស្គាល់វិធីលែងលះដែលមិនចំណាយប្រាក់កាសដោយភាពបំព្រួញនោះហើយ ទើបបានជាក្នុងចំនួនសរុបនៃការលែងលះមាន ៩០ ភាគរយជាការលែងលះដោយការព្រមព្រៀង ។

## ឃ) គោលការណ៍នៃការបែកបាក់

នៅក្នុងប្រទេសជប៉ុន បើប្រៀបធៀបទៅ មានការទទួលស្គាល់ទូលំទូលាយនូវហេតុនៃការលែងលះ (មូលហេតុនៃការលែងលះ) នៅក្នុងការលែងលះតាមផ្លូវតុលាការ ក៏ប៉ុន្តែ មិនទាន់ឈានដល់ការទទួលស្គាល់គោលការណ៍បែកបាក់ដែលពេញលេញទេ។ កថាខណ្ឌទី ១ មាត្រា ៧៧០ នៃក្រមរដ្ឋប្បវេណីជប៉ុនមានចែងអំពីមូលហេតុ ៥ យ៉ាងដែលជាមូលហេតុនៃការលែងលះ។ ទី ១ នៅពេលមានអំពើផិតក្បត់របស់សហព័ទ្ធ។ ទី ២ នៅពេលដែលមានការបោះបង់ចោលសហព័ទ្ធដោយគំនិតទុច្ចរិត។ ទី ៣ ករណីដែលមិនបានដឹងអស់រយៈពេលលើសពី ៣ ឆ្នាំ ថាសហព័ទ្ធនៅរស់ ឬ ក៏ស្លាប់។ ទី ៤ ករណីដែលសហព័ទ្ធមានជំងឺផ្លូវចិត្តធ្ងន់ធ្ងរ ហើយមិនអាចព្យាបាលជាសះស្បើយវិញបាន។ ទី ៥ មូលហេតុធ្ងន់ធ្ងរដទៃផ្សេងទៀតដែលធ្វើឲ្យអាពាហ៍ពិពាហ៍បែកបាក់ និង គ្មានសង្ឃឹមថាអាចធ្វើឲ្យប្រសើរឡើងវិញបាន។ ក៏ប៉ុន្តែ បើទោះជាមានមូលហេតុពីទី ១ ដល់ទី ៤ នេះក៏ដោយ ដោយពិចារណាទៅលើស្ថានភាពផ្សេងៗ និង យល់ឃើញថាមានហេតុសមរម្យដែលអាចធ្វើឲ្យអាពាហ៍ពិពាហ៍បន្តស្ថិតស្ថេរទៅទៀតបាន តុលាការអាចច្រានចោលការទាមទារលែងលះគ្នានោះបាន (កថាខណ្ឌទី ២ នៃមាត្រាដដែល) ។

## ង) អានុភាពនៃការលែងលះ

ដូចបានរៀបរាប់ពីខាងដើមមកហើយ អានុភាពនៃការលែងលះគឺការរំលាយអាពាហ៍ពិពាហ៍ (មានន័យថា ការប្រើនាមត្រកូលរួម ជាដើម ដែលជាអានុភាពនៃអាពាហ៍ពិពាហ៍ត្រូវរលាយ) ក៏ប៉ុន្តែ បន្ថែមពីលើនេះ វាកើតមាននូវអានុភាពសំខាន់ៗមួយចំនួនផ្សេងទៀត។ ជាបឋម សហព័ទ្ធម្ខាងអាចទាមទារការបែងចែកទ្រព្យសម្បត្តិជាមួយភាគីម្ខាងទៀតបាន (មាត្រា ៧៦៨ នៃក្រមរដ្ឋប្បវេណី)។

ចំពោះរបៀបនៃការបែងចែកទ្រព្យសម្បត្តិវិញ គឺសំដៅទៅលើការគណនាដោយគិតពិចារណាទៅដល់ប្រាក់ជំងឺចិត្តចំពោះការដែលអាពាហ៍ពិពាហ៍ត្រូវបានធ្វើឲ្យបែកបាក់ ប្រាក់អាហារកិច្ចក្រោយពេលលែងលះ និង ប្រព័ន្ធទ្រព្យសម្បត្តិរួមប្តីប្រពន្ធដែលមាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ជាដើម។ ម្យ៉ាងវិញទៀត ក្នុងករណីមានកូនជាអនីតិជន គឺត្រូវកំណត់ពីអ្នកមានសិទ្ធិគ្រប់គ្រងកូន (មាត្រា ៧៦៦ នៃក្រមរដ្ឋប្បវេណី) ។

✎ ការទាមទារលែងលះរបស់សហព័ទ្ធដែលមានករណីយកិច្ច--ការពិចារណាតាមរយៈករណីសិក្សា

នៅក្នុងករណីសិក្សា មានបញ្ហាដែលត្រូវបានហៅថា ការទាមទារលែងលះរបស់សហព័ទ្ធដែលជាអ្នកមានកំហុស។ ប្រសិនបើមើលជាលក្ខណៈប្រវត្តិសាស្ត្រវិញ មូលហេតុនៃការលែងលះគឺត្រូវបានផ្លាស់ប្តូរពីគោលការណ៍កំហុស ទៅជាគោលការណ៍បែកបាក់វិញ ក៏ប៉ុន្តែ តាមគោលការណ៍កំហុស នៅក្នុងការបែកបាក់អាពាហ៍ពិពាហ៍ អាចពិចារណាបានថា សហព័ទ្ធដែលគ្មានកំហុស ជាអ្នកទាមទារទៅសហព័ទ្ធដែលមានកំហុសដើម្បីលែងលះគ្នា។បើតាមមូលហេតុនៃការលែងលះដែលមានចែងនៅក្នុងកថាខណ្ឌទី ១ មាត្រា ៧៧០ នៃក្រមរដ្ឋប្បវេណីជប៉ុន មូលហេតុដែលជាគោលការណ៍បែកបាក់ក៏ត្រូវបានរាប់បញ្ចូលដែរ (ឧទាហរណ៍ដូចជាការដែលមិនដឹងច្បាស់ថា ស្លាប់ ឬ រស់ ឬ ជំងឺផ្លូវចិត្តរបស់សហព័ទ្ធ) ក៏ប៉ុន្តែ យុត្តិសាស្ត្រមិនទទួលស្គាល់ការទាមទារលែងលះរបស់សហព័ទ្ធដែលមានកំហុសពីសហព័ទ្ធដែលគ្មានកំហុស ដោយសារតែការបែកបាក់អាពាហ៍ពិពាហ៍នោះទេ។ ក៏ប៉ុន្តែ សាលដីកាជំនុំជម្រះរួមក្រុមរបស់តុលាការកំពូលនៅឆ្នាំ ១៩៨៧ បានផ្លាស់ប្តូរយុត្តិសាស្ត្រកន្លងមក ដោយកំណត់ថា ការទាមទារលែងលះពីសហព័ទ្ធដែលមានកំហុសអាចទទួលស្គាល់បាន ប្រសិនបើមានការរស់នៅបែកគ្នាជាក់ស្តែងក្នុងអំឡុងពេលយូរ ប្រសិនបើគ្មានកូនដែលមិនទាន់ពេញវ័យ (កូនដែលមិនអាចរស់នៅខ្លួនឯងដោយឯករាជ្យពីឪពុកម្តាយ) ប្រសិនបើការលែងលះនោះមិនបង្កឲ្យមានស្ថានភាពលំបាកខ្លាំងទៅដល់ភាគីម្ខាងទៀត (សាលដីកាតុលាការកំពូលចុះថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ១៩៨៧ ក្នុងកម្រងសាលក្រម ឬ សាលដីការឿងក្តីរដ្ឋប្បវេណីភាគទី ៤១ លេខ ៦ ទំព័រទី ១៤២៣)។ នៅក្នុងបណ្តាប្រទេសមួយចំនួន ការធ្វើវិសោធនកម្មប្រព័ន្ធច្បាប់ស្តីពីគោលការណ៍បែកបាក់ត្រូវបានធ្វើឡើង ហើយក្នុងករណីដែលបានរស់នៅបែកគ្នាជាក់ស្តែងជាបន្តបន្ទាប់អស់រយៈពេលយ៉ាងយូរ គឺអាចទទួលស្គាល់នូវការលែងលះបានដោយពុំមានបញ្ហាស្តីពីកំហុសរបស់សហព័ទ្ធទេ (ក៏ប៉ុន្តែ អំឡុងពេលដែលរស់នៅបែកគ្នាចាំបាច់ដើម្បីទទួលស្គាល់ការលែងលះគឺកាន់តែខ្លីទៅៗ) ហើយទស្សនៈបែបនោះត្រូវបានគិតថាបានជះឥទ្ធិពលដល់យុត្តិសាស្ត្ររបស់តុលាការជប៉ុនដែរ ។

បើយោងតាមករណីយុត្តិសាស្ត្រថ្មី ប្រសិនបើដូចករណីសិក្សាខាងលើនេះ គឺអាចនិយាយបានថា ការទាមទារលែងលះរបស់ A ក៏នឹងត្រូវបានទទួលស្គាល់ដែរ ។ ក៏ប៉ុន្តែ នៅប្រទេសជប៉ុន ដោយផ្អែកទៅលើយុត្តិសាស្ត្រ និង និន្នាការបែបនេះនៃប្រព័ន្ធច្បាប់របស់ប្រទេសជាច្រើន ក្រុមប្រឹក្សានីតិកម្ម

របស់ក្រសួងយុត្តិធម៌) បានធ្វើវិសោធនកម្មក្រមរដ្ឋប្បវេណី ដោយសម្រេចទទួលស្គាល់សារជាថ្មីនូវការលែងលះដោយការបែកបាក់ ក៏ប៉ុន្តែ មកទល់ពេលនេះ នៅមិនទាន់សម្រេចអនុវត្តនៅឡើយទេ ។

Khmer Law's Association

### ✧ក្រមហាមមូរ៉ាប៊ី (Hammurabi)

ប្រសិនបើយើងចូលទៅក្នុងសារមន្ទីរល្វូរ (Louvre) នៃទីក្រុងប៉ារីស ដែលមានដាក់តាំងបង្ហាញវត្ថុសិល្បៈរបស់អរិយធម៌មេសូប៉ូតាមៀ (Mesopotamia) យើងនឹងឃើញបូជនីយដ្ឋានថ្មដែលធ្វើពីថ្មពពុះ (basalt) ពណ៌ខ្មៅ ដ៏ធំ ដែលមានកំពស់ ២.៥ ម៉ែត្រមួយនៅចំពីមុខយើង ។ នោះគឺជាបូជនីយដ្ឋានដ្ឋានថ្មដ៏ល្បីល្បាញមួយដែលមានចារិកក្រមហាមមូរ៉ាប៊ី ។ ហាមមូរ៉ាប៊ី គឺជាស្តេចនៃចក្រភពបាប៊ីឡូនដែលសោយរាជ្យក្នុងសតវត្សទី ១៨ មុនគ្រិស្តសករាជ និង បានកសាងប្រទេសដោយគ្រប់គ្រងតាំងពីបាប៊ីឡូន ដល់អាស៊ីរៀ ហើយនៅចុងរជ្ជកាលនោះ បានបញ្ញត្តក្រមហាមមូរ៉ាប៊ី ។

បូជនីយដ្ឋានថ្មនោះ ត្រូវបានរកឃើញនៅដើមសតវត្សទី ២០ នៅឯតំបន់ស៊ូសា (Susa) នៃតំបន់ពែរក្ស (Persian)។ ដើមឡើយ វាត្រូវបានកសាងឡើងនៅទីកន្លែងសក្ការៈបូជាសាសនានៅស៊ីប៉ាល នៅចក្រភពបាប៊ីឡូនភាគខាងជើង ប៉ុន្តែ ត្រូវបានផ្ញើជាសួយសារអាករទៅស៊ូសា។ ផ្នែកខាងលើនៃបូយនីយដ្ឋានថ្មនេះមានឆ្លាក់រូបអាទិទេពព្រះអាទិត្យនៃយុត្តិធម៌យ៉ាម៉ាស៊ូប្រទានក្រមដល់ស្តេចហាមមូរ៉ាប៊ី។ ក្រមហាមមូរ៉ាប៊ីត្រូវបានឆ្លាក់ជាភាសាអាកាដៀន ដែលមាត្រាដំបូង តួសេចក្តីដែលមាន ២៨២ មាត្រា និង មាត្រាចុងក្រោយ (មួយផ្នែកបានបាក់ខូច ហើយបាត់)។ នៅក្រោយពេលដែលរកឃើញ វាត្រូវបានគេគិតថាជាច្បាប់សរសេរដែលមានអាយុកាលយូរលង់ក្នុងសាកលលោក ក៏ប៉ុន្តែ នៅក្រោយពីនោះ ក៏មានក្រមផ្សេងទៀតដែលត្រូវបានគេស្គាល់ថាជាក្រមដែលមានអាយុកាលយូរលង់ដែរ ។

ហាមមូរ៉ាប៊ី មានបញ្ចូលនូវមាត្រាដែលពាក់ព័ន្ធជាមួយនឹងបទល្មើស ទ្រព្យសម្បត្តិ ការធ្វើជំនួញ ពាណិជ្ជកម្ម និង កសិកម្ម ជាដើម ក៏ប៉ុន្តែមានមាត្រាជាច្រើនពាក់ព័ន្ធជាមួយគ្រួសារ។ ក្រមនោះមានបញ្ញត្តិជាច្រើនពាក់ព័ន្ធជាមួយនឹងអាពាហ៍ពិពាហ៍ ការលែងលះ និង សន្តតិកម្ម ជាដើម ។ ឧទាហរណ៍ដូចជា មានបញ្ញត្តិដែលចែងថា អាពាហ៍ពិពាហ៍ត្រូវធ្វើឡើងតាមរបៀបនៃកិច្ចសន្យាលក់ទិញ។ មានបញ្ញត្តិ ដូចជា កូនកំលោះត្រូវបង់ថ្លៃកូនក្រមុំទៅឲ្យឪពុកកូនក្រមុំ ។ មានបញ្ញត្តិផ្សេងទៀតដែលចែងថា អ្នកណាដែលខ្វះភ្នែកគេ នោះភ្នែកអ្នកនោះនឹងត្រូវគេខ្វះវិញ ត្រូវបំបាក់ដល់ធ្មេញអ្នកដែលបានបំបាក់ធ្មេញគេ ដែលជាបញ្ញត្តិស្តីពីទណ្ឌកម្មដូចគ្នាទៅនឹងការខូចខាត ក៏ប៉ុន្តែ នៅក្នុងព្រះគម្ពីប៊ីប ភាសាដែលព្រះមានបន្ទូលទៅកាន់លោក ម៉ូសេ នៅក្នុងគ្រាសញ្ញាចាស់ ក៏មានន័យដូចគ្នានោះដែរគឺថា "ភ្នែកសងភ្នែក ធ្មេញសងធ្មេញ" (ព្រះគម្ពីរចាស់ លេវីវិន័យ ជំពូកទី ២៤ ខ ២០) ។

# ជំពូកទី ១៣

# ឪពុកម្តាយ និង កូន និង អាហារកាតព្វកិច្ច

**១ ទំនាក់ទំនងបុគ្គលភាព**

(១) កូនបង្កើត

(២) សុំកូន

(៣) កូនដែលកើតតាមវិធីបង្កកំណើតសិប្បនិម្មិត

**២ អនីតិជន និង អំណាចមេបារបស់ឪពុកម្តាយ**

**៣ ញាតិ (អាហារកាតព្វកិច្ច)**

✎ ល័ក្ខខ័ណ្ឌនៃការបង្កើតសុំកូន--ការពិចារណាតាមរយៈករណីសិក្សា

**ករណីសិក្សា៖** A និង B បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាអស់រយៈពេល ១០ ឆ្នាំមកហើយ ក៏ប៉ុន្តែមិនមានកូនទេ។ ដោយហេតុនេះ ពួកគេក៏បានគិតថាចង់សុំ E (ក្មួយប្រុសរបស់ A) ដែលមានអាយុ ១០ ឆ្នាំដែលត្រូវជាកូនរបស់ C និង D ដែល C គឺជាបងប្រុសរបស់ A ។ តើត្រូវអនុវត្តនីតិវិធីសុំកូនយ៉ាងដូចម្តេច ?

## ១ ទំនាក់ទំនងបុត្តភាព

នៅក្នុងទំនាក់ទំនងគ្រួសារ ចាប់តាំងពីទំនាក់ទំនងប្តីប្រពន្ធរហូតដល់ទំនាក់ទំនងរវាងបុត្តភាព គឺជាបញ្ហាដែលសំខាន់ខ្លាំង។ ទី ១ បញ្ហានោះគឺថាតើទំនាក់ទំនងបុត្តភាពតាមច្បាប់កើតឡើងត្រឹមកម្រិតណា។ បុត្តភាពគឺមានទាំងករណីដែលឪពុកម្តាយ និងកូនមានទំនាក់ទំនងលោហិតនឹងគ្នា និង ករណីដែលឪពុកម្តាយ និងកូនមិនមានទំនាក់ទំនងលោហិតនឹងគ្នា។ ទី ២ គឺជាបញ្ហាដែលថា ក្នុងករណីដែលទំនាក់ទំនងបុត្តភាពតាមច្បាប់ត្រូវបានទទួលស្គាល់ហើយ តើខ្លឹមសារជាក់លាក់នៃទំនាក់ទំនងនោះជាខ្លឹមសារបែបណា។ ជាពិសេស ថាតើឪពុកម្តាយមានសិទ្ធិអំណាចប៉ុណ្ណាលើកូននោះ ក៏ជាបញ្ហាដែរ ។

### (១) កូនបង្កើត

#### ក) កូនមានខាន់ស្លា

កូនដែលកើតចេញពីប្តីប្រពន្ធដែលមានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ គឺជាកូនមានខាន់ស្លារបស់ប្តីប្រពន្ធនោះ។ បើតាមកថាខណ្ឌទី ២ មាត្រា ៧៧២ នៃក្រមរដ្ឋប្បវេណី កូនដែលបានកើតក្នុងអំឡុងពេល ២០០ ថ្ងៃក្រោយអាពាហ៍ពិពាហ៍ និង កូនដែលកើតក្នុងអំឡុងពេល ៣០០ ថ្ងៃគិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍បានរលាយ ត្រូវចាត់ទុកថាជាកូនមានខាន់ស្លារបស់ប្តីប្រពន្ធនោះ ដូច្នេះមិនចាំបាច់ធ្វើនីតិវិធីបញ្ជាក់ពីទំនាក់ទំនងបុត្តភាពអ្វីទេ។ កូនដែលកើតចេញពីប្តីប្រពន្ធ ជាធម្មតា ត្រូវបានចាត់ទុកជាកូនមានខាន់ស្លា។

ក៏ប៉ុន្តែ ដោយសារតែបញ្ញត្តិនោះមានខ្លឹមសារជាការសន្មត ដូច្នេះ ប្រសិនបើមិនមែនជាកូនរបស់ប្តី ប្តីអាចបដិសេធការសន្មតថាជាកូននោះបាន និង អាចធ្វើការបដិសេធបិតុភាពបាន (មាត្រា ៧៧៤ នៃក្រមរដ្ឋប្បវេណី)។ ក៏ប៉ុន្តែ ច្បាប់បានកំណត់នូវល័ក្ខខ័ណ្ឌតឹងរ៉ឹងចំពោះនីតិវិធីធ្វើការបដិសេធនោះ ។

ជាបឋម ត្រូវតែធ្វើបណ្តឹងបដិសេធកូននោះ (មាត្រា ៧៧៥ នៃក្រមរដ្ឋប្បវេណី)។ ហើយបន្ទាប់មកបណ្តឹងបដិសេធបិតុភាពនោះត្រូវដាក់ក្នុងអំឡុងពេល ១ ឆ្នាំគិតចាប់ពីពេលដែលខ្លួនបានដឹងអំពីកំណើតរបស់កូននោះ (មាត្រា ៧៧៧ នៃក្រមរដ្ឋប្បវេណី)។ ម្យ៉ាងវិញទៀត ប្រសិនបើប្តីនោះបាន

ទទួលស្គាល់កូនថាជាកូនរបស់ខ្លួននៅក្រោយពេលកំណើតរបស់កូននោះហើយ គឺមិនអាចបដិសេធបិតុភាពវិញបានទេ (មាត្រា ៧៧៦ នៃក្រមរដ្ឋប្បវេណី) ។

របបកូនមានខាន់ស្លាបែបនេះ គឺដើម្បីកំណត់ឲ្យបានឆាប់រហ័សនូវទំនាក់ទំនងឋានៈបុគ្គលរបស់កូនដោយការយកទំនាក់ទំនងបុគ្គភាពធម្មជាតិរវាងឪពុក និងកូន ជាមូលដ្ឋាន ។

### ខ) ទំនាក់ទំនងបុគ្គភាពតាមរយៈការទទួលស្គាល់

ផ្ទុយទៅវិញ នៅពេលដែលកូនដែលបានកើតចេញពីបុរសនារី ដែលមិនមានទំនាក់ទំនងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ជាមួយគ្នាទេ ទំនាក់ទំនងបុគ្គភាពតាមច្បាប់មិនអាចកើតមានឡើងបានទេ ប្រសិនបើមិនធ្វើការទទួលស្គាល់ (ចាប់ពីមាត្រា ៧៧៩ នៃក្រមរដ្ឋប្បវេណី)។ ក៏ប៉ុន្តែ ចំពោះទំនាក់ទំនងមាតុភាពវិញ ត្រូវបានបកស្រាយថា បើទោះជាមានបញ្ញត្តិនៃក្រមរដ្ឋប្បវេណីក៏ដោយ មិនចាំបាច់មានការទទួលស្គាល់ទេ គឺទំនាក់ទំនងនោះនឹងកើតឡើងដោយសារការសម្រាលកូនដែលជាអង្គហេតុជាក់ស្តែង។ បានសេចក្តីថា ការទទួលស្គាល់នឹងក្លាយជាបញ្ហាក្នុងទំនាក់ទំនងបិតុភាព ។

ការទទួលស្គាល់មានការទទួលស្គាល់ដោយស្ម័គ្រចិត្តដែលជាការទទួលស្គាល់កូនពីខាងឪពុក និងការទទួលស្គាល់ដោយបង្ខំដែលកូនទាមទារឲ្យទទួលស្គាល់។ ទោះពិត ឬ មិនពិតក៏ដោយ ប្រសិនបើឪពុកម្តាយមិនមានទំនាក់ទំនងអាពាហ៍ពិពាហ៍នឹងគ្នាទេ បើទោះបីជាមានទំនាក់ទំនងបុគ្គភាពដោយផ្អែកលើអង្គហេតុពិតក៏ដោយ ទំនាក់ទំនងបុគ្គភាពតាមច្បាប់មិនកើតឡើងទេ ប្រសិនបើមិនមានការទទួលស្គាល់។ បណ្តឹងទាមទារឲ្យទទួលស្គាល់ពីខាងកូនអាចធ្វើទៅបានក្នុងអំឡុងពេល ៣ ឆ្នាំក្រោយមរណភាពរបស់ឪពុក (មាត្រា ៧៨៧ នៃក្រមរដ្ឋប្បវេណី)។ ក៏ប៉ុន្តែផ្ទុយទៅវិញ មានការរឹតត្បិតចំពោះការទទួលស្គាល់ពីខាងឪពុក (មាត្រា ៧៨២ នៃក្រមរដ្ឋប្បវេណី) ។

### (២) សុំកូន

### ក) អត្ថន័យនៃរបបសុំកូន

ក្រៅពីទំនាក់ទំនងបុគ្គភាពតាមធម្មជាតិ ក្រមរដ្ឋប្បវេណីទទួលស្គាល់ការបង្កើតឲ្យមានទំនាក់ទំនងបុគ្គភាពតាមបែបសិប្បនិម្មិត (ក្រមរដ្ឋប្បវេណីចាប់ពីមាត្រា ៧៩២) ពោលគឺទំនាក់ទំនងបុគ្គភាពរវាងឪពុកម្តាយចិញ្ចឹម និង កូនសុំ ។ ទំនាក់ទំនងបុគ្គភាពរវាងឪពុកម្តាយចិញ្ចឹម និង កូនសុំ ជាទូទៅគឺជាទំនាក់ទំនងបុគ្គភាពដែលត្រូវបានបង្កើតឡើងដោយផ្អែកតាមការព្រមព្រៀងរវាងអនាគតឪពុកម្តាយចិញ្ចឹម និង អនាគតកូនសុំ។ ចំណុចដែលផ្អែកលើការព្រមព្រៀងរវាងគូភាគីជាមូលដ្ឋាននេះគឺដូចគ្នាទៅនឹងអាពាហ៍ពិពាហ៍ដែរ ។

មូលដ្ឋាននៃការទទួលស្គាល់នូវរបបសុំកូននេះ គឺមានការប្រែប្រួលទៅតាមប្រវត្តិសាស្ត្រ។ នៅអតីតកាល របបសុំកូនត្រូវបានគិតថាមានគោលបំណងដើម្បីជៀសវាងការបាត់បង់គ្រួសារ ឬ វង្សត្រកូលដោយសារតែគ្មានអ្នកបន្តពូជ ដូច្នេះ បុគ្គលដែលគ្មានអ្នកបន្តពូជពង្សវង្សត្រកូលនោះអាចទទួលបាននូវអ្នកបន្តពូជពង្សវង្សត្រកូល តាមរយៈសុំកូននោះ។ សុំកូនបែបនោះ ហៅថា "សុំកូនដើម្បីគ្រួសារ"។ ក្រោយពីនោះមក គោលបំណងនៃសុំកូនត្រូវបានគិតថា ដើម្បីផ្តល់កូនទៅបុគ្គល (ប្តីប្រពន្ធ) ដែលគ្មានកូន។ ដោយសារហេតុនេះ ទើបសុំកូនត្រូវបានហៅថា "សុំកូនដើម្បីឪពុកម្តាយ"។ ក៏ប៉ុន្តែ នាពេលថ្មីៗនេះ សុំកូនត្រូវបានយល់ឃើញថា មានគោលបំណងផ្តល់ឪពុកម្តាយទៅឲ្យកូនដែលកំព្រាឪពុកម្តាយ។ មានន័យថា "សុំកូនដើម្បីកុមារ" ។

ទស្សនៈទាំងឡាយចំពោះរបបសុំកូន ក៏ត្រូវបានស្តែងឡើងនៅក្នុងការបកស្រាយចំពោះបញ្ញត្តិច្បាប់ដែលទាក់ទងទៅនឹងសុំកូនដែរ។ នាពេលថ្មីៗនេះ នៅពេលដែលមានបញ្ហាអំពីផ្លូវច្បាប់ដែលពាក់ព័ន្ធជាមួយសុំកូន មានការលើកឡើងថា ត្រូវតែធ្វើការបកស្រាយដោយគិតទៅដល់ទស្សនៈស្តីពីសុខុមាលភាពរបស់កុមារ ពោលគឺមានន័យថា ត្រូវយកទស្សនៈស្តីពី "សុំកូនដើម្បីកុមារ" មកធ្វើជាមូលដ្ឋានក្នុងការបកស្រាយ ។

## ខ) សុំកូនពេញលេញ និង សុំកូនមិនពេញលេញ

តាមរយៈសុំកូន ទំនាក់ទំនងបុគ្គភាពតាមច្បាប់រវាងកូនសុំ និង ឪពុកម្តាយចិញ្ចឹមត្រូវកើតឡើង ក៏ប៉ុន្តែ ចំពោះទំនាក់ទំនងបុគ្គភាពតាមច្បាប់រវាងកូនសុំ និង ឪពុកម្តាយបង្កើតវិញ ត្រូវបានគិតថាអាចចាត់ចែងតាមរបៀប ២ យ៉ាង។ របៀបចាត់ចែងម្យ៉ាងគឺថាទំនាក់ទំនងបុគ្គភាពតាមច្បាប់ជាមួយឪពុកម្តាយបង្កើត នៅបន្តមានតទៅទៀត រីឯរបៀបចាត់ចែងម្យ៉ាងទៀតគឺថា ទំនាក់ទំនងបុគ្គភាពតាមច្បាប់ជាមួយឪពុកម្តាយបង្កើតត្រូវរលត់។ ជាទូទៅ របៀបចាត់ចែងទីពីរនេះត្រូវបានហៅថា សុំកូនពេញលេញ រីឯការចាត់ចែងតាមរបៀបទីមួយវិញហៅថា សុំកូនមិនពេញលេញ។ ក្រមរដ្ឋប្បវេណីនៃប្រទេសជប៉ុនបានទទួលស្គាល់របបសុំកូនមិនពេញលេញរហូតមកដល់ពេលបច្ចុប្បន្ន ក៏ប៉ុន្តែ នៅក្រោយវិសោធនកម្មឆ្នាំ ១៩៨៧ មក សុំកូនពេញលេញក៏ត្រូវបានទទួលស្គាល់តាមរយៈឈ្មោះថា សុំកូនពិសេស (ក្រមរដ្ឋប្បវេណីជប៉ុនមាត្រា ៨១៧-២ ។ ដូច្នេះហើយ របបសុំកូនពីដើមត្រូវបានហៅថា សុំកូនធម្មតា ) ។

## គ) សុំកូនធម្មតា

របបសុំកូនធម្មតា ជាមូលដ្ឋាន គឺផ្អែកទៅលើយន្តការដូចគ្នាទៅនឹងយន្តការនៃការបង្កើតអាពាហ៍ពិពាហ៍ដែរ។ មានន័យថា វាកើតឡើងដោយសារការព្រមព្រៀងរវាងបុគ្គលដែលនឹងក្លាយទៅ

ជាកូនសុំ និង បុគ្គលដែលនឹងក្លាយទៅជាឪពុកម្តាយចិញ្ចឹម (ហៅថា ការបង្កើតស្មុំកូន)។ បុគ្គលដែលនឹងក្លាយទៅជាឪពុកម្តាយចិញ្ចឹមត្រូវតែជានីតិជន (មាត្រា ៧៩២ នៃក្រមរដ្ឋប្បវេណី) ក៏ប៉ុន្តែ មិនមានការកំណត់អំពីអាយុនៃបុគ្គលដែលនឹងត្រូវក្លាយទៅជាកូនសុំទេ។ ក៏ប៉ុន្តែ បុគ្គលដែលនឹងក្លាយទៅជាកូនសុំ ត្រូវតែជាបុគ្គលដែលមិនមែនជាបុព្វញាតិនៃបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម ឬ បុគ្គលដែលមានអាយុច្រើនជាងឪពុកម្តាយចិញ្ចឹមឡើយ (មាត្រា ៧៩៣ នៃក្រមរដ្ឋប្បវេណី)។ ម្យ៉ាងវិញទៀត ប្រសិនបើបុគ្គលដែលនឹងក្លាយទៅជាកូនសុំមិនទាន់គ្រប់អាយុ ១៥ ឆ្នាំនៅឡើយទេ អ្នកតំណាងដែលច្បាប់បានកំណត់អាចផ្តល់ការយល់ព្រមជំនួសបុគ្គលនោះបាន (មាត្រា ៧៩៧ នៃក្រមរដ្ឋប្បវេណី)។ ដោយឡែកប្រសិនបើសុំបុគ្គលដែលជាអនីតិជនវិញ ចាំបាច់ត្រូវទទួលបានការអនុញ្ញាតពីតុលាការគ្រួសារ (មាត្រា ៧៩៨ នៃក្រមរដ្ឋប្បវេណី)។

នៅពេលដែលស្មុំកូនកើតឡើង ទំនាក់ទំនងបុគ្គភាពមានខាន់ស្លារវាងឪពុកម្តាយចិញ្ចឹម និង កូនសុំកើតឡើង (មាត្រា ៨០៩ នៃក្រមរដ្ឋប្បវេណី) ដូច្នេះ ទំនាក់ទំនងញាតិរវាងកូនសុំជាមួយនឹងញាតិរបស់ឪពុកម្តាយចិញ្ចឹមក៏កើតឡើងដែរ។ ដោយឡែកចំពោះការរំលាយស្មុំកូនវិញ គឺអាចធ្វើឡើងតាមការព្រមព្រៀងរវាងភាគីនៃស្មុំកូនដែលហៅថា ការកាត់កាល់តាមការពិភាក្សា (មាត្រា ៨១១ នៃក្រមរដ្ឋប្បវេណី) និង ម្យ៉ាងវិញទៀតគឺការកាត់កាល់តាមផ្លូវតុលាការ ក្នុងករណីដែលមានមូលហេតុណាមួយដូចច្បាប់បានកំណត់ (មាត្រា ៨១៤ នៃក្រមរដ្ឋប្បវេណី)។ មូលហេតុដែលច្បាប់កំណត់សម្រាប់ការកាត់កាល់តាមផ្លូវតុលាការគឺមាន ៣ ។ ទី ១ ប្រសិនបើភាគីណាមួយនៃស្មុំកូនត្រូវបានបោះបង់ចោលដោយគំនិតទុច្ចរិត។ ទី ២ ប្រសិនបើមិនច្បាស់ក្នុងអំឡុងពេលលើសពី ៣ ឆ្នាំ ថាតើភាគីណាមួយនៃស្មុំកូននោះរស់ ឬស្លាប់។ ទី ៣ ប្រសិនបើមានហេតុធ្ងន់ធ្ងរផ្សេងទៀត ដែលពិបាកក្នុងការបន្តទំនាក់ទំនងស្មុំកូន។

## ឃ) ស្មុំកូនពិសេស

តុលាការគ្រួសារអាចអនុញ្ញាតឲ្យបង្កើតស្មុំកូនពិសេសទៅតាមពាក្យសុំរបស់បុគ្គលដែលនឹងក្លាយទៅជាឪពុកម្តាយចិញ្ចឹមបាន ក្រោមល័ក្ខខ័ណ្ឌតឹងរ៉ឹងមួយចំនួន ដូចជាបុគ្គលដែលនឹងក្លាយទៅជាឪពុកម្តាយចិញ្ចឹមត្រូវតែជាបុគ្គលដែលមានសហព័ទ្ធ (មាត្រា ៨១៧-៣ នៃក្រមរដ្ឋប្បវេណី) បុគ្គលដែលនឹងក្លាយទៅជាឪពុកម្តាយចិញ្ចឹមត្រូវតែជាបុគ្គលដែលមានអាយុចាប់ពី ២៥ ឆ្នាំ ឡើងទៅ (មាត្រា ៨១៧-៤ នៃក្រមរដ្ឋប្បវេណី) ជាគោលការណ៍ កុមារដែលនឹងក្លាយទៅជាកូនសុំត្រូវមានអាយុក្រោម ៦ ឆ្នាំ (មាត្រា ៨១៧-៥ នៃក្រមរដ្ឋប្បវេណី) ត្រូវមានការយល់ព្រមពីឪពុកម្តាយបង្កើតរបស់កុមារនោះ (មាត្រា ៨១៧-៦ នៃក្មរមរដ្ឋប្បវេណី) និងត្រូវមានភាពចាំបាច់ក្នុងការការពារកុមារដែលនឹងក្លាយទៅជាកូនសុំនោះ (មាត្រា ៨១៧-៧ នៃក្រមរដ្ឋប្បវេណី) ជាដើម។ ក្នុងករណីដែលស្មុំកូនពិសេសត្រូវបានបង្កើតឡើង មិនមែនតែទំនាក់ទំនងញាតិភាពមានខាន់ស្លារវាងកូនសុំ និង ឪពុកម្តាយ

ចិញ្ចឹមទេដែលត្រូវកើតឡើង ក៏ប៉ុន្តែទំនាក់ទំនងញាតិរវាងកូនសុំជាមួយឪពុកម្តាយបង្កើត និង ជាមួយញាតិលោហិតនៃឪពុកម្តាយបង្កើតនោះក៏ត្រូវចប់ដែរ (មាត្រា ៨១៧-៩ នៃក្រមរដ្ឋប្បវេណី) ។

ចំពោះការកាត់កាល់សុំកូនពិសេសវិញ គឺទទួលស្គាល់តែការកាត់កាល់តាមផ្លូវតុលាការ ទៅតាមការទាមទាររបស់កូនសុំ ឪពុកម្តាយបង្កើត ឬ ព្រះរាជអាជ្ញាតែប៉ុណ្ណោះ ក្នុងករណីដែលមានមូលហេតុដែលកំណត់ដោយច្បាប់ណាមួយ រីឯការកាត់កាល់តាមការពិភាក្សា ឬ ការកាត់កាល់តាមផ្លូវតុលាការទៅតាមការទាមទារពីខាងឪពុកម្តាយចិញ្ចឹមវិញគឺមិនទទួលស្គាល់ទេ (មាត្រា ៨១៧-១០ នៃក្រមរដ្ឋប្បវេណី)។ ការកាត់កាល់អាចអនុញ្ញាតឲ្យធ្វើទៅបានតែក្នុងករណីដែលមានភាពចាំបាច់ពិសេស ដើម្បីការពារផលប្រយោជន៍របស់កូនសុំ ដូចជាក្នុងករណីមានការធ្វើបាបដោយឪពុកម្តាយចិញ្ចឹម ការបោះបង់ចោលដោយគំនិតទុច្ចរិត ឬ មានហេតុផ្សេងទៀតដែលបំពានដល់ផលប្រយោជន៍ របស់កូនយ៉ាងធ្ងន់ធ្ងរ ឬ ប្រសិនបើឪពុកម្តាយបង្កើតអាចគ្រប់គ្រងថែរក្សាកូនសមរម្យវិញបាន ។

## (៣) កូនដែលកើតតាមវិធីបង្កកំណើតសិប្បនិម្មិត

### ក) ទំនាក់ទំនងរវាងឪពុកម្តាយ និង កូនដែលកើតតាមវិធីបង្កកំណើតសិប្បនិម្មិត

យោងតាមការរីកចម្រើននៃវិទ្យាសាស្ត្រខាងបង្កកំណើតសិប្បនិម្មិត ថាតើត្រូវគិតយ៉ាងដូចម្តេចចំពោះទំនាក់ទំនងបុគ្គភាពតាមច្បាប់នៃកូនដែលកើតតាមវិធីបង្កកំណើតសិប្បនិម្មិត (ហៅថា សេវាវេជ្ជសាស្ត្រជួយដល់ការបន្តពូជដែលសំដៅផ្តល់ការព្យាបាលចំពោះភាពអារ) នឹងក្លាយជាបញ្ហា ។

នៅក្នុងបណ្តាប្រទេសផ្សេងៗ វិវាទនៅតុលាការជុំវិញបញ្ហាស្តីពីការបង្កកំណើតសិប្បនិម្មិតមានមិនតិចទេ ហើយក៏ឃើញមានការផ្តល់ដំណោះស្រាយតាមនីតិកម្មចំពោះទំនាក់ទំនងបុគ្គភាពនៃកូនដែលកើតមកនោះ ថាតើគួរទទួលស្គាល់ ឬ យ៉ាងណានោះ។ ឧទាហរណ៍ ប្រសិនបើដូចករណីដែលការបង្កាត់ពូជសិប្បនិម្មិតរវាងប្តីប្រពន្ធដោយសារមេជីវិតរបស់ប្តី (ហៅថា AIH) រវាងកូនដែលកើតតាមវិធីបង្កកំណើតសិប្បនិម្មិត និង ឪពុកម្តាយ (ជាពិសេស ឪពុក) ដែលផ្តល់កំណើតដល់កូននោះ គឺជាករណីដែលទំនាក់ទំនងបុគ្គភាពធម្មជាតិ និង មិនសូវជាមានបញ្ហាអ្វីទេ ។ ក៏ប៉ុន្តែ ដូចករណីដែលការបង្កាត់ពូជសិប្បនិម្មិតធ្វើឡើងដោយការប្រើប្រាស់មេជីវិតរបស់តតិយជន (ហៅថា AID) ឬ ដោយការខ្ចីផ្ទៃពោះរបស់ម្តាយទីទៃ ក្នុងករណីដែលទំនាក់ទំនងបុគ្គភាពរវាងកូនដែលកើតតាមវិធីបង្កកំណើតសិប្បនិម្មិត និង ឪពុកម្តាយ មិនមានទំនាក់ទំនងបុគ្គភាពធម្មជាតិទេ នោះនឹងមានបញ្ហាថាតើត្រូវគិតយ៉ាងដូចម្តេចចំពោះទំនាក់ទំនងបុគ្គភាពតាមច្បាប់។

### ខ) បញ្ហាផ្លូវច្បាប់រវាងម្តាយជំនួស និង AID

បញ្ហានោះគឺជាបញ្ហាដែលថាតើត្រូវពិចារណាដល់កម្រិតណាចំពោះស្ថានភាពអង្គហេតុដែលត្រូវបានមើលឃើញថាជាទំនាក់ទំនងបុគ្គភាព ដោយការមើលពីឆន្ទៈរបស់ភាគី (ឆន្ទៈរួមគ្នានៃប្ដី ឬប្រពន្ធចំពោះការបង្កកំណើតដោយវិធីសិប្បនិម្មិត) និង ពីសង្គមមក ដោយយកទំនាក់ទំនងបុគ្គភាពតាមផ្លូវច្បាប់ក្រៅពីទំនាក់ទំនងបុគ្គភាពធម្មជាតិ (ពោលគឺទំនាក់ទំនងខ្សែលោហិត) ជាមូលដ្ឋាន។ ម្យ៉ាងវិញទៀត ចំពោះម្ដាយជំនួសវិញ អាចមានករណីដែលបុគ្គលដែលបានសម្រាលកូន មិនមែនសុទ្ធតែជាអ្នកដែលផ្ដល់បព្វាណ្ឌ (អូវុល) ដែលធ្វើឲ្យបញ្ហាកាន់តែស្មុគស្មាញឡើង ។

នៅក្នុងប្រទេសជប៉ុន បើតាមការចង្អុលបង្ហាញពីក្រុមអ្នកវិទ្យាសាស្ត្រដែលសិក្សាពីស្ត្រីសម្រាលកូន មានតែវិធីបង្កាត់ពូជសិប្បនិម្មិតទេដែលត្រូវទទួលស្គាល់ រីឯម្ដាយជំនួសវិញគឺមិនទទួលស្គាល់ទេ (មានករណីដែលជនជាតិជប៉ុនទទួលបានកូនដោយសារការសម្រាលរបស់ម្ដាយជំនួសនៅអាមេរិក ជាដើម)។ ហេតុដូច្នេះ កូនដែលកើតពីការបង្កាត់ពូជសិប្បនិម្មិត (រាប់បញ្ចូលទាំងករណីនៃ AID ផងដែរ) ត្រូវប្រតិបត្តិដូចជាកូនមានខាន់ស្លានៃប្ដីប្រពន្ធតាមអង្គហេតុជាក់ស្ដែង ។

ជាសរុបមក បញ្ហានេះអាចនិយាយបានថាគឺជាបញ្ហាសម្រាប់ពេលអនាគត សម្រាប់ការសិក្សានីតិរដ្ឋប្បវេណី។

### គ) ភាពជាក់ស្ដែងនៃបញ្ហា និង ការដោះស្រាយដោយផ្អែកលើនីតិកម្ម

មកទល់ពេលនេះ ការពិចារណាផ្ដល់ដំណោះស្រាយតាមរយៈនីតិកម្មចំពោះទំនាក់ទំនងបុគ្គភាពនៃកូនដែលកើតតាមវិធីបង្កកំណើតសិប្បនិម្មិត នៅហាក់ដូចជាមិនទាន់មានភាពខ្លាំងក្លានៅឡើយទេ។ ដូច្នេះ តាមពិត ក៏មានករណីមួយចំនួនតូចផងដែរ នៅពេលមានជម្លោះរវាងឪពុកម្ដាយ និងកូន។ (ឧទាហរណ៍ បើនៅប្រទេសបារាំងវិញ ធ្លាប់មានករណីវិវាទតាមផ្លូវតុលាការរួចមកហើយនៅក្នុងទសវត្សឆ្នាំ ១៩៨០ ហើយវាត្រូវបានដោះស្រាយដោយផ្អែកលើនីតិកម្មនៅក្នុងឆ្នាំ ១៩៩៤)។ ក៏ប៉ុន្តែ នៅប្រទេសជប៉ុន ក៏មានករណីបណ្ដឹងទាមទារឲ្យទទួលស្គាល់ក្រោយមរណភាព (បញ្ញត្តិលើកលែងនៃមាត្រា ៧៨៧ នៃក្រមរដ្ឋប្បវេណី) បន្ទាប់ពីការមានផ្ទៃពោះ និង សម្រាលកូនដោយកូនដែលកើតពីប្រពន្ធដែលបានប្រើប្រាស់មេជីវិតដែលត្រូវបានរក្សាទុកដោយការបង្កកនៅក្រោយពេលដែលប្ដីទទួលមរណភាព និង ករណីបណ្ដឹងដែលប្ដីប្រពន្ធដែលទទួលបានកូនតាមរយៈម្ដាយជំនួសនៅអាមេរិក បានប្ដឹងចំពោះសាលាខណ្ឌដែលមិនព្រមចាត់ចែងការចុះបញ្ជីកំណើត នៅពេលដែលប្ដីប្រពន្ធនោះបានទៅធ្វើការចុះបញ្ជីកំណើតកូននៅសាលាខណ្ឌ ជាដើម ដែលករណីទាំងនេះបង្ហាញឲ្យឃើញពីការលំបាកក្នុងការដោះស្រាយដោយផ្អែកលើបទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណីដែលអនុវត្តបច្ចុប្បន្ន។ ចំពោះករណីការបង្កកំណើតក្រោយមរណភាពនោះ សាលាដំបូងបានច្រានចោលការទាមទារ ក៏ប៉ុន្តែនៅតុលាការនៃបណ្ដឹងឧទ្ធរណ៍ ការទាមទារនោះត្រូវបានទទួលស្គាល់ ហើយបណ្ដឹងទាមទារចុះ

បញ្ជីនោះក៏បានបន្តទៅតុលាការកំពូលទៀត។ តុលាការកំពូលបានវិនិច្ឆ័យថា "ការកើតឡើងនូវទំនាក់ទំនងបុគ្គភាពតាមផ្លូវច្បាប់រវាងកូនដែលចាប់ទុំផ្ទៃក្រោយមរណភាព និង ឪពុកដែលបានទទួលមរណភាព គឺមិនអាចទទួលស្គាល់បានទេ" ដូច្នេះ ការទាមទារឲ្យទទួលស្គាល់គឺច្បាស់ណាស់ហើយថា មិនត្រូវបានទទួលស្គាល់ទេ។ ដោយឡែកចំពោះករណីនៃម្ដាយជំនួសវិញ សាលាដំបូងបានលើកបណ្ដឹងចោល ក៏ប៉ុន្តែ តុលាការនៃបណ្ដឹងឧទ្ធរណ៍ទទួលស្គាល់ពាក្យសុំចុះបញ្ជីនោះ ហើយបណ្ដឹងសាទុក្ខចំពោះសេចក្ដីអនុញ្ញាតនោះត្រូវបានធ្វើឡើងទៅតុលាការកំពូល ដោយទុកឲ្យតុលាការកំពូលធ្វើការវិនិច្ឆ័យ ។

នៅក្រសួងសុខាភិបាល ការងារ និង សង្គមកិច្ច ការសិក្សាស្រាវជ្រាវពីរបបនីតិកម្មដែលពាក់ព័ន្ធជាមួយនឹងការគ្រប់គ្រងការបង្កកំណើតសិប្បនិម្មិត (សេវាវេជ្ជសាស្ត្រជួយដល់ការបន្តពូជ) ត្រូវបានធ្វើឡើង ហើយក្រសួងយុត្តិធម៌បានផ្អែកលើមូលដ្ឋាននៃការសិក្សាស្រាវជ្រាវនោះ បានធ្វើការសិក្សាស្រាវជ្រាវលើរបបគតិយុត្តដែលពាក់ព័ន្ធទៅនឹងច្បាប់បុគ្គភាពនៃកូនដែលកើតដោយសារសេវាវេជ្ជសាស្ត្រជួយដល់ការបន្តពូជ ក៏ប៉ុន្តែ កិច្ចពិភាក្សាពីការតាក់តែងច្បាប់នោះត្រូវបានផ្អាក ហើយនីតិកម្មក៏មិនត្រូវបានធ្វើរហូតមកដល់សព្វថ្ងៃនេះ ។

នៅក្នុងកិច្ចប្រជុំពិភាក្សារបស់ក្រសួងយុត្តិធម៌ មានទស្សនៈផ្ដួចផ្ដើមក្នុងការចែងជាបញ្ញត្តិដែលមានខ្លឹមសារថា ក្នុងករណីដែលប្រើមេជីវិតដែលតតិយជនផ្ដល់ឲ្យ (AID គឺជាឧទាហរណ៍គំរូមួយនៃវិធីនោះ) ប្ដីដែលបានយល់ព្រមចំពោះវិធីវេជ្ជសាស្ត្របែបនោះត្រូវចាត់ទុកថាជាឪពុក ហើយករណីដែលប្រើបប្អូណន្តដែលតតិយជនផ្ដល់ឲ្យស្ត្រីដែលបានពរពោះត្រូវចាត់ទុកថាជាម្ដាយ ។

## ២ អនីតិជន និង អំណាចមេបារបស់ឪពុកម្ដាយ

### ក) ខ្លឹមសារនៃអំណាចមេបា

ដូចបានលើកឡើងរួចមកហើយ សមត្ថភាពធ្វើសកម្មភាពរបស់អនីតិជនត្រូវបានកម្រិត ហើយដើម្បីជាជំនួយទៅដល់សមត្ថភាពធ្វើសកម្មភាពនោះ របបអ្នកមានអំណាចមេបា និង អ្នកអាណាព្យាបាលត្រូវបានបង្កើតឡើង (បើនិយាយឲ្យជាក់លាក់គឺថា នៅពេលអនីតិជនត្រូវធ្វើសកម្មភាព បុគ្គលទាំងនោះជាអ្នកផ្ដល់ឲ្យនូវការយល់ព្រមដើម្បីឲ្យអនីតិជនធ្វើសកម្មភាពដោយខ្លួនឯង ឬ ក៏ពួកគាត់ធ្វើសកម្មភាពជំនួសអនីតិជន) ។

ក៏ប៉ុន្តែ សិទ្ធិអំណាចរបស់អ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាល មិនមានត្រឹមតែចំពោះសកម្មភាពដែលពាក់ព័ន្ធនឹងទ្រព្យសម្បត្តិទេ គឺមានចំពោះជីវភាពទាំងស្រុងរបស់អនីតិជនតែម្ដង។ ឧទាហរណ៍ដូចជា មាត្រា ៨២០ នៃក្រមរដ្ឋប្បវេណីចែងថា "អ្នកដែលអនុវត្តអំណាចមេបាមានសិទ្ធិ និង

ករណីយកិច្ចគ្រប់គ្រង និង អប់រំកូននោះ" (អ្នកអាណាព្យាបាលសម្រាប់អនីតិជន ក៏មានសិទ្ធិ និង ករណីយកិច្ចដូចគ្នានេះដែរ ។ សូមមើលមាត្រា ៨៥៧ នៃក្រមរដ្ឋប្បវេណី) ។

ដូចដែលបានឃើញក្នុងបញ្ញត្តិនេះ អំណាចមេបាគឺមានន័យថា សិទ្ធិត្រូវបានបង្កើតឡើង ក៏ប៉ុន្តែ វាខុសគ្នាខ្លាំងជាមួយនឹងសិទ្ធិលើទ្រព្យសម្បត្តិ។ បានសេចក្តីថា បើនៅក្នុងន័យភាពមិនទទួលនូវការគ្រប់គ្រងពីអ្នកដទៃ ឪពុកម្តាយមានសិទ្ធិចំពោះកូន ក៏ប៉ុន្តែ បើនៅក្នុងន័យថាត្រូវតែអនុវត្តសិទ្ធិ ដើម្បីសុខុមាលភាពរបស់កូន សិទ្ធិនោះមានលក្ខណៈជាករណីយកិច្ចខ្លាំងជាង។ ដោយហេតុនេះ ខ្លឹមសារនៃអំណាចមេបា គឺជាសិទ្ធិគ្រប់គ្រងបីបាច់ថែរក្សាតាមឋានៈបុគ្គលជាទូទៅ និង សិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូននោះ។ បើនិយាយឲ្យជាក់លាក់ សិទ្ធិគ្រប់គ្រងបីបាច់ថែរក្សាតាមឋានៈបុគ្គល គឺសិទ្ធិគ្រប់គ្រង និងអប់រំ (មាត្រា ៨២០ នៃក្រមរដ្ឋប្បវេណី) សិទ្ធិកំណត់ពីទីសំណាក់ (មាត្រា ៨២១ នៃក្រមរដ្ឋប្បវេណី) សិទ្ធិដាក់ទណ្ឌកម្ម (មាត្រា ៨២២ នៃក្រមរដ្ឋប្បវេណី) និង សិទ្ធិអនុញ្ញាតឲ្យប្រកបអាជីវកម្ម (មាត្រា ៨២៣ នៃក្រមរដ្ឋប្បវេណី)។ ដោយឡែកចំពោះខ្លឹមសារនៃសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិវិញ មានបញ្ញត្តិចាប់ពីមាត្រា ៨២៤ តទៅ។

### ខ) គោលការណ៍នៃអំណាចមេបារួម

នាសម័យដើម មានតែឪពុកទេដែលមានសិទ្ធិអំណាចលើកូន (នៅក្នុងច្បាប់នៃបណ្តាប្រទេសមួយចំនួន សិទ្ធិអំណាចនោះត្រូវបានហៅថា សិទ្ធិបិតា) ក៏ប៉ុន្តែ នាសម័យទំនើប ដោយផ្អែកលើគោលការណ៍នៃសមភាពរបស់បុរសនារីជាមូលដ្ឋាន ច្បាប់បានកំណត់ឪពុកម្តាយអនុវត្តនូវអំណាចមេបាដោយសហការគ្នា។ មាត្រា ៨១៨ នៃក្រមរដ្ឋប្បវេណីចែងអំពីគោលការណ៍នេះ។ ក៏ប៉ុន្តែ នៅក្នុងករណីដែលឪពុកម្តាយលែងលះគ្នា ច្បាប់បញ្ញត្តថា ត្រូវកំណត់យកឪពុក ឬ ម្តាយជាអ្នកមានអំណាចមេបា (មាត្រា ៨១៩ នៃក្រមរដ្ឋប្បវេណី)។ ក៏ប៉ុន្តែ អាចអនុញ្ញាតឲ្យម្នាក់ជាអ្នកមានអំណាចមេបា រីឯម្នាក់ទៀតជាអ្នកមានសិទ្ធិគ្រប់គ្រងថែរក្សាបាន (សូមមើលមាត្រា ៧៦៦ នៃក្រមរដ្ឋប្បវេណី) ។

ក៏ប៉ុន្តែ ចំពោះកូនដែលឥតខាន់ស្លា ទំនាក់ទំនងមាតុភាពកើតឡើងអាស្រ័យទៅការសម្រាលកូនដែលជាអង្គហេតុ គឺម្តាយនឹងក្លាយជាអ្នកមានអំណាចមេបាដោយស្វ័យប្រវត្តិ។ បើទោះជាឪពុកនៃកូនឥតខាន់ស្លានោះធ្វើការទទួលស្គាល់កូននោះក៏ដោយ ក៏មិនមែនមានន័យថា គាត់នឹងក្លាយទៅជាអ្នកមានអំណាចមេបាដោយស្វ័យប្រវត្តិដែរ ក៏ប៉ុន្តែ គាត់អាចនឹងក្លាយទៅជាអ្នកមានអំណាចមេបាបានតាមការពិភាក្សារវាងឪពុកម្តាយនោះ ឬ តាមការសម្រេចរបស់តុលាការ ។

នៅពេលដែលឪពុក ឬ ម្តាយម្ខាងក្លាយទៅជាអ្នកមានអំណាចមេបាដោយឯករាជ្យ ដោយសារមូលហេតុលែងលះ ឬ មូលហេតុផ្សេងទៀត ប្រសិនបើការអនុវត្តអំណាចមេបានោះមិនសមស្របទៅនឹង

សុខុមាលភាពរបស់កូនទេ អាចមានការផ្លាស់ប្តូរអ្នកមានអំណាចមេបាបាន (កថាខណ្ឌទី ៦ មាត្រា ៨១៩ នៃក្រមរដ្ឋប្បវេណី) ។

### គ) របបអាណាព្យាបាល

នៅក្នុងករណីដែលគ្មានអ្នកអនុវត្តអំណាចមេបាទេ របបអាណាព្យាបាលត្រូវចាប់ផ្តើម (មាត្រា ៨៣៨ នៃក្រមរដ្ឋប្បវេណី)។ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អាចត្រូវបានកំណត់សម្រាប់អនីតិជនទៅតាមការកំណត់របស់អ្នកមានអំណាចមេបា ឬ ទៅតាមការជ្រើសតាំងរបស់តុលាការគ្រួសារ (មាត្រា ៨៣៩ ដល់មាត្រា ៨៤២ នៃក្រមរដ្ឋប្បវេណី) អ្នកអាណាព្យាបាលត្រូវបានចាត់ទុកថាមានសិទ្ធិ និង ករណីយកិច្ចដូចគ្នានឹងអ្នកមានអំណាចមេបាដែរ (មាត្រា ៨៥៧ នៃក្រមរដ្ឋប្បវេណី)។ មានន័យថា មានសិទ្ធិ និង ករណីយកិច្ចបីបាច់ថែរក្សា និង អប់រំ និង គ្រប់គ្រងទ្រព្យសម្បត្តិរបស់អនីតិជន ។

ក៏ប៉ុន្តែ របបអាណាព្យាបាលក៏ត្រូវបានអនុវត្តដោយសារអ្នកអាណាព្យាបាល (ការថែទាំព្យាបាលបីបាច់ថែរក្សា និង គ្រប់គ្រងទ្រព្យសម្បត្តិរបស់នីតិជនដែលស្ថិតនៅក្រោមរបបអាណាព្យាបាល) ចំពោះជនមួយប្រភេទទៀតដែលជាជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពជាមួយគ្នានឹងអនីតិជនដែរ ពោលគឺជាជនដែលស្ថិតក្នុងស្ថានភាពខ្វះសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យ (នីតិជននៅក្រោមរបបអាណាព្យាបាល) ដោយសារវិបត្តិផ្នែកបញ្ញាស្មារតី (មាត្រា ៨៥៨ និង មាត្រា ៨៥៩ នៃក្រមរដ្ឋប្បវេណី។ សូមមើលជំពូកទី ៤)។ អ្នកអាណាព្យាបាលប្រភេទនេះ ត្រូវបានហៅជាពិសេសថា អ្នកអាណាព្យាបាលសម្រាប់នីតិជន ។

ម្យ៉ាងវិញទៀត ចំពោះជនដែលមានសមត្ថភាពខាងបញ្ញាស្មារតីអន់ខ្សោយជាងមនុស្សធម្មតា តែមិនធ្ងន់ធ្ងរជាងជននៅក្រោមអាណាព្យាបាលទេ របបហិតូបត្ថម្ភ និង របបជំនួយ ដែលស្រដៀងគ្នាទៅនឹងរបបអាណាព្យាបាលដែរ ត្រូវបានបង្កើតឲ្យមាន (មាត្រាចាប់ពី ៨៧៦ នៃក្រមរដ្ឋប្បវេណី។ ក៏ប៉ុន្តែសេចក្តីលម្អិត សូមមើលជំពូកទី ៤ នៃសៀវភៅនេះ) ។

លើសពីនេះទៅទៀត ចំពោះជនដែលមានសមត្ថភាពយល់ដឹងមិនគ្រប់គ្រាន់វិញ របបអាណាព្យាបាលតាមការស្ម័គ្រចិត្តដែលមានការត្រួតពិនិត្យនៃស្ថាប័នសាធារណៈមួយ ត្រូវបានបង្កើតឡើងតាមច្បាប់ពិសេស (ច្បាប់ស្តីពីកិច្ចសន្យាអាណាព្យាបាលតាមការស្ម័គ្រចិត្ត។ សូមមើលជំពូកទី ៥) ។

## ៣ ញាតិ (អាហារកាតព្វកិច្ច)

ក្នុងករណីមានបុគ្គលដែលមិនអាចចិញ្ចឹមជីវិតដោយខ្លួនឯងបាន ពាក់ព័ន្ធជាមួយនឹងបញ្ហាថាតើត្រូវផ្តល់ជំនួយត្រឹមកម្រិតណាទៅដល់ជននោះ ក្រៅពីជំនួយសង្គ្រោះសាធារណៈដើម្បីទ្រទ្រង់

ជីវភាពជាដើម ក្រមរដ្ឋប្បវេណីមានបញ្ញត្តនូវករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ចរវាងញាតិ ក្នុងលក្ខណៈជាជំនួយសង្គ្រោះឯកជន ។

## ក) ខ្លឹមសារនៃករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច

ដោយឡែកចំពោះករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ចរវាងប្តីប្រពន្ធវិញ គឺមានចែងនៅក្នុងមាត្រា ៧៥២ និង មាត្រា ៧៦០ នៃក្រមរដ្ឋប្បវេណី។ ម្យ៉ាងវិញទៀត ចំពោះកូនដែលជាអនីតិជន ករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ចចំពោះកូននោះ គឺត្រូវបានដាក់បញ្ចូលទៅក្នុងខ្លឹមសារនៃសិទ្ធិ និង ករណីយកិច្ចគ្រប់គ្រង និង អប់រំរបស់ឪពុកម្តាយដែលមានអំណាចមេបា ដោយសោហ៊ុយនោះអាចត្រូវបានគិតថា ត្រូវបានចាត់ចែងជាបន្ទុកលើសោហ៊ុយដែលកើតចេញពីអាពាហ៍ពិពាហ៍។ ក៏ប៉ុន្តែ ជំនួយសង្គ្រោះជាឯកជននេះមិនមែនចប់ត្រឹមទំហំនៃគ្រួសារដែលសមាជិកមានតែឪពុកម្តាយ និង កូនប៉ុណ្ណោះទេ គឺវាត្រូវលាតសន្ធឹងរហូតទៅដល់ញាតិផងដែរ។ មានន័យថា ករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ចមានចំពោះគ្នាទៅវិញទៅមករវាងញាតិលោហិតខ្សែផ្ទាល់ និង បងប្អូនប្រុសស្រីផងដែរ លើសពីនេះទៅទៀត ប្រសិនបើមានស្ថានភាពពិសេស តុលាការគ្រួសារអាចដាក់បន្ទុកឲ្យញាតិនៅក្នុងថ្នាក់ទី ៣ ទទួលករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ចបាន (មាត្រា ៨៧៧ នៃក្រមរដ្ឋប្បវេណី) ។

ក៏ប៉ុន្តែ ជាគោលការណ៍ ខ្លឹមសារនៃការផ្គត់ផ្គង់អាហារកាតព្វកិច្ចនៅក្នុងគ្រួសារដែលសមាជិកមានតែឪពុកម្តាយ និង កូន ត្រូវបានបកស្រាយថាខុសគ្នាជាមួយការផ្គត់ផ្គង់អាហារកាតព្វកិច្ចរវាងញាតិ ពោលគឺការផ្គត់ផ្គង់អាហារកាតព្វកិច្ចនៅក្នុងគ្រួសារដែលសមាជិកមានតែឪពុកម្តាយ និង កូន គឺជាករណីយកិច្ចធ្វើឲ្យជីវភាពរបស់ជនដែលទទួលអាហារកាតព្វកិច្ចមានកម្រិតដូចជីវភាពរបស់ខ្លួន (ហៅថា ករណីយកិច្ចរក្សាកម្រិតជីវភាព) រីឯការផ្គត់ផ្គង់អាហារកាតព្វកិច្ចរវាងញាតិគឺជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចពុំមែនត្រូវលះបង់ដើម្បីឲ្យសមទៅនឹងជីវភាព ដែលជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ចគួរ ទទួលបាននោះទេ ក៏ប៉ុន្តែ គាត់មានត្រឹមតែករណីយកិច្ចជួយសង្គ្រោះជីវិតរបស់ជនដែលត្រូវការអាហារកាតព្វកិច្ចតែប៉ុណ្ណោះ (ហៅថា ករណីយកិច្ចសង្គ្រោះជីវិត) ។

### ✎ ល័ក្ខខ័ណ្ឌនៃការបង្កើតសុំកូន--ការពិចារណាតាមរយៈករណីសិក្សា

A និង B បានរៀបអាពាហ៍ពិពាហ៍ ហើយបានដល់នីតិភាពហើយ ដូច្នេះពួកគេអាចសុំកូនបាន (មាត្រា ៧៩២ នៃក្រមរដ្ឋប្បវេណី)។ ម្យ៉ាងវិញទៀត ដោយសារតែ E ជាក្មួយប្រុសរបស់ A និង B ការដែល A និង B សុំ E គឺមិនស្ថិតក្នុងល័ក្ខខ័ណ្ឌហាមឃាត់ដោយសារកូនសុំជាបុព្វញាតិ ឬ កូនសុំមានអាយុច្រើនជាងនោះឡើយ (មាត្រា ៧៩៣ នៃក្រមរដ្ឋប្បវេណី)។ ហេតុដូច្នេះ អាចមានលទ្ធភាពដែល A និង B អាចសុំ E បាន ។ ក៏ប៉ុន្តែ ដោយសារ A និង B ជាប្តីប្រពន្ធ ហើយ E ជាអនីតិជន

ចាំបាច់ត្រូវ A និង B សុំ E រួមជាមួយគ្នា (មាត្រា ៧៩៥ នៃក្រមរដ្ឋប្បវេណី) ។

សុំកូនអាចត្រូវបង្កើតឡើងតាមរយៈការព្រមព្រៀងរវាងបុគ្គលដែលនឹងក្លាយទៅជាឪពុកម្ដាយចិញ្ចឹម និង បុគ្គលដែលនឹងក្លាយទៅជាកូនសុំ ក៏ប៉ុន្តែ ប្រសិនបើបុគ្គលដែលនឹងក្លាយទៅជាកូនសុំមានអាយុក្រោម ១៥ ឆ្នាំ ចាំបាច់ត្រូវទទួលការយល់ព្រមចំពោះការសុំនោះពីអ្នកតំណាងដែលច្បាប់បានកំណត់ (មាត្រា ៧៩៧ នៃក្រមរដ្ឋប្បវេណី) ឬ ក៏ទទួលការអនុញ្ញាតពីតុលាការគ្រួសារ (មាត្រា ៧៩៨ នៃក្រមរដ្ឋប្បវេណី)។ ដូច្នេះ នៅក្នុងករណីសិក្សាខាងលើ សុំកូនអាចធ្វើទៅបានដោយ ចាំបាច់ត្រូវមានការយល់ព្រមរបស់ C និង D ដែលជាអ្នកតំណាងដែលច្បាប់បានកំណត់របស់ E ឬ ក៏អាចធ្វើទៅបានដោយចាំបាច់ត្រូវទទួលបានការអនុញ្ញាតពីតុលាការគ្រួសារ ។ A និង B អាចសុំ E បានដោយអនុលោមតាមនីតិវិធីបែបនេះ ហើយនៅពេលដែលសុំកូនកើតឡើង E ត្រូវទទួលនូវឋានៈជាកូនមានខាន់ស្លារបស់ប្តីប្រពន្ធ A និង B។ ក៏ប៉ុន្តែ ដោយសារតែសុំកូនប្រភេទនេះជាសុំកូនធម្មតា ទំនាក់ទំនងបុត្តភាពតាមច្បាប់រវាង E និងឪពុកម្តាយបង្កើត C និង D មិនរលត់ទេ។ ក៏ប៉ុន្តែ ដើម្បីឲ្យទំនាក់ទំនងបុត្តភាពជាមួយឪពុកម្តាយបង្កើតរលត់ គឺមានរបបសុំកូនពិសេស ក៏ប៉ុន្តែ ដោយសារតែក្នុងករណីសិក្សាខាងលើអាយុរបស់ E ដែលជាល័ក្ខខ័ណ្ឌមួយនៃសុំកូនពិសេសមិនអាច ត្រូវបានបំពេញទេ (មាត្រា ៨១៧-៥ និង មាត្រា ៨១៧-៧ នៃក្រមរដ្ឋប្បវេណី ជាដើម ) ។

# ជំពូកទី ១៤

## សន្តតិកម្ម

**១ សន្តតិកម្ម**

(១) អត្ថន័យនៃសន្តតិកម្ម

(២) មូលដ្ឋាននៃសន្តតិកម្ម

(៣) សន្តតិកម្មតាមច្បាប់ និង សន្តតិកម្មតាមមតកសាសន៍

**២ សន្តតិជន និង ចំណែកមត៌ក**

(១) សន្តតិជន

(២) ការយល់ព្រម និង ការបោះបង់ចោល

(៣) ចំណែកមត៌ក

(៤) ភាគបម្រុង

**៣ មតកសាសន៍**

✎ សន្តតិកម្មតាមច្បាប់--ការពិចារណាតាមរយៈករណីសិក្សា

Khmer Law's Association

**ករណីសិក្សា៖** A បានទទួលមរណភាព ដោយបន្សល់ទុកនូវទ្រព្យសម្បត្តិមួយចំនួន។ A មាន B ដែលជាសហព័ទ្ធ និង មាន C និង D ជាកូន។ តើទ្រព្យសម្បត្តិរបស់ A នឹងត្រូវបានធ្វើសន្តតិកម្មយ៉ាងដូចម្ដេច?

## ១ សន្តតិកម្ម

### (១) អត្ថន័យនៃសន្តតិកម្ម

សន្តតិកម្មគឺជាសិទ្ធិ និង ករណីយកិច្ច (ហៅថា សន្តតិកម្ម ឬ មតិក) របស់បុគ្គលម្នាក់ដែលបានទទួលមរណភាពទៅហើយ (ហៅថា មតកជន) ត្រូវបានទទួលបន្តដោយបុគ្គលនៅក្នុងថ្នាក់នៃទំនាក់ទំនងញាតិជាកំណត់មួយ (ហៅថា សន្តតិជន)។ ចាំបាច់ត្រូវមានការពិចារណាយ៉ាងហ្មត់ចត់ចំពោះសន្តតិកម្ម ពីព្រោះមិនមែនមានតែទ្រព្យសកម្មប៉ុណ្ណោះទេ ក៏ប៉ុន្តែ ទ្រព្យអកម្ម ដូចជាបំណុលចំពោះប្រាក់កម្ចីជាដើម ក៏ត្រូវទទួលបន្តព្រមជាមួយគ្នាដែរ ។

### ក) ការស្នងបុគ្គលភាពគតិយុត្ត

ក៏ប៉ុន្តែ ថ្វីបើជាការបន្តនូវសិទ្ធិ និង ករណីយកិច្ចពិតមែនក៏ដោយ សន្តតិកម្មខុសគ្នាជាមួយនឹងករណីដែលកម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុនៃការលក់ទិញដែលត្រូវផ្ទេរពីអ្នកលក់ទៅអ្នកទិញ ដោយវាត្រូវបានយល់ឃើញថា ឋានៈតាមផ្លូវច្បាប់របស់មតកជនត្រូវផ្ទេរទៅឲ្យសន្តតិជន (សូមមើលមាត្រា ៨៩៦ នៃក្រមរដ្ឋប្បវេណី)។ មានន័យថា នៅក្នុងទំនាក់ទំនងជាមួយតតិយជន ជាគោលការណ៍សន្តតិជនគឺមានឋានៈស្មើគ្នានឹងមតកជនដែរ ។

ឧទាហរណ៍ X បានលក់ដី (ក) ដែលជាកម្មសិទ្ធិរបស់ខ្លួនទៅ Y ក្នុងអំឡុងពេល ដែលការចុះបញ្ជីផ្ទេរ មិនទាន់បានធ្វើឡើងផង គាត់ក៏បានលក់ដីនេះជាថ្មីម្ដងទៀតទៅឲ្យ Z ហើយការចុះបញ្ជីផ្ទេរទៅឲ្យ Z ក៏បានធ្វើរួចរាល់ ក្នុងករណីបែបនេះ ជាគោលការណ៍ Z មានសិទ្ធិអាទិភាព។ Y មិនអាចតតាំងពីការដែលខ្លួនបានធ្វើលទ្ធកម្មកម្មសិទ្ធិលើដី (ក) ដោយមិនបានធ្វើតាមការចុះបញ្ជី ចំពោះ Z បានទេ (មាត្រា ១៧៧ នៃក្រមរដ្ឋប្បវេណី)។ ម្យ៉ាងវិញទៀត គេអាចគិតបានថា ការដែល Z បានទិញដី (ក) មិនមែនជាការដែលគាត់ទទួលស្គាល់នូវឋានៈជាអ្នកទិញដោយផ្អែកលើកិច្ចសន្យាលក់ទិញពី X ទៅ Y នោះទេ។ ទស្សនៈនេះត្រូវបានហៅថា ទ្រឹស្ដីនៃការធ្វើអនុប្បទានជាន់គ្នានូវអចលនវត្ថុ ។

ផ្ទុយទៅវិញ ក្នុងករណីដែលការផ្ទេរកម្មសិទ្ធិពី X ទៅ Z ដោយសារសន្តតិកម្មវិញ បើមើលមួយភ្លែតទៅ យើងឃើញហាក់ដូចជាការធ្វើអនុប្បទានជាន់គ្នាដូច្នេះដែរ ក៏ប៉ុន្តែ សេចក្ដីសន្និដ្ឋានគឺខុសគ្នា ។ ពោលគឺ នៅក្រោយពេលដែលកម្មសិទ្ធិករលើដី (ក) X បានលក់ដីនោះទៅឲ្យ Y ហើយ គឺ

គាត់បានទទួលមរណភាពនៅមុនពេលដែលបានចុះបញ្ជីផ្ទេរ ហើយ Z បានធ្វើសន្តតិកម្មលើដី (ក) ហើយក្នុងករណីដែលការចុះបញ្ជីផ្ទេរពី X ទៅ Z ដោយមូលហេតុសន្តតិកម្មបានធ្វើរួចរាល់ហើយក៏ដោយ ក៏ Y អាចទាមទារក្នុងឋានៈជាអ្នកទិញឲ្យ Z អនុវត្តកាតព្វកិច្ចបានដែរ ពោលគឺអាចទាមទារឲ្យធ្វើការចុះបញ្ជីផ្ទេរ។ ហេតុផលនោះគឺថា ដោយសារតែ Z ត្រូវបានចាត់ទុកថាបានទទួលស្គាល់នូវឋានៈជាអ្នកលក់របស់ខ្លួនដែលបានមកពី X និង ត្រូវបានធ្វើឲ្យមានឋានៈស្មើគ្នាជាមួយនឹង X ។ ត្រង់ចំណុចនេះ ការទទួលបន្តដូចក្នុងករណីលក់ទិញបែបនេះហៅថា ការទទួលបន្តដែលមានកំណត់ ហើយផ្ទុយទៅវិញ ការទទួលបន្តដូចក្នុងករណីសន្តតិកម្ម ហៅថា ការទទួលបន្តជាទូទៅ ឬ ការទទួលបន្តទាំងស្រុង ។

## ខ) ប្រវត្តិនៃរបបសន្តតិកម្ម

របបសន្តតិកម្មត្រូវបានគេគិតថា ត្រូវបានទទួលស្គាល់តាំងពីយូរលង់ណាស់មកហើយ ដោយផ្អែកលើមូលដ្ឋាននៃរបបទ្រព្យសម្បត្តិឯកជន។ ក៏ប៉ុន្តែ ខ្លឹមសារនៃរបបសន្តតិកម្មត្រូវបានផ្លាស់ប្តូរខុសគ្នាទៅតាមសម័យកាលនីមួយៗ។

នៅប្រទេសជប៉ុនក៏ដូចគ្នាផងដែរ នៅក្នុងអតីតសម័យមេជិ ទម្រង់នៃសន្តតិកម្មកើតមានច្រើនផ្សេងៗគ្នា។ ក្រមរដ្ឋប្បវេណីមេជិ (១៨៩៨) កំណត់ថា របបសន្តតិកម្មដោយកូនច្បង ត្រូវបានអនុវត្តចំពោះត្រកូលកងទ័ព (ប៊ូកា) ហើយនៅក្នុងរបបមេគ្រួសារជាធំ (របប "អ៊ិអេ") វិញ នៅពេលដែលមេគ្រួសារទទួលមរណភាព ជាគោលការណ៍ កូនប្រុសច្បងដែលមានខាន់ស្លា ត្រូវទទួលការគ្រប់គ្រងផ្ទះបន្ត (មាត្រា ៩៧០ចាស់នៃក្រមរដ្ឋប្បវេណី។ ចំពោះករណីមរណភាពរបស់សមាជិកគ្រួសារផ្សេងទៀត ក្រៅពីមេគ្រួសារ គេកំណត់យករបបសន្តតិកម្មដែលឲ្យបច្ឆាញាតិនៃញាតិលោហិតខ្សែផ្ទាល់ ជាអាទិ៍ ធ្វើសន្តតិកម្មរួមគ្នា)។ បើតាមរបបសន្តតិកម្មបែបនោះ កូនប្រុសច្បងនៃមេគ្រួសារត្រូវទទួលមតិកទាំងអស់ ហើយកូនផ្សេងទៀត (កូនប្រុសបន្តបន្ទាប់ និង កូនស្រីៗ) មិនមានសិទ្ធិធ្វើសន្តតិកម្មទេ។ ក៏ប៉ុន្តែ ដោយសារវិសោធនកម្មនាសម័យក្រោយសង្គ្រាម ក្រមរដ្ឋប្បវេណីដែលអនុវត្តនាពេលបច្ចុប្បន្នបានលុបចោលរបបមេគ្រួសារជាធំនោះ ហើយនៅក្នុងគ្រប់ករណីទាំងអស់ កូនៗ និងសហព័ទ្ធត្រូវធ្វើសន្តតិកម្មរួមគ្នា ។

## (២) មូលដ្ឋាននៃសន្តតិកម្ម

ចំពោះរបបទ្រព្យសម្បត្តិឯកជន ក្រៅពីការដែលមតិកអាចចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួនបានដោយសេរីហើយ ការដែលសន្តតិជនអាចទទួលបន្តនូវទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់មតកជនគឺមិនអាចបដិសេធបានទេ ក៏ប៉ុន្តែ សមភាពរវាងមនុស្សដែលគួរមាននៅពេលកើតមកក្នុងលោកនេះ

ក៏អាចកើតមានជាគម្លាតមានក្រដែលមិនអាចចៀសផុតបានដែរ។ ហេតុដូច្នេះ មានទស្សនៈដែលដេញដោលថា ហេតុអ្វីបានចាំបាច់ត្រូវទទួលស្គាល់នូវរបបសន្តតិកម្ម ។

## ក) ការសម្រួលចំណែកដែលមានសក្តានុពល

ទី ១ ជាបឋម ថ្វីបើអាចនិយាយបានថា ទ្រព្យសម្បត្តិគឺជាទ្រព្យដែលជាប់ឈ្មោះរបស់បុគ្គលដែលជាមតកជនពិតមែនក៏ដោយ ក៏ប៉ុន្តែ តាមការពិតទៅ មានទ្រព្យសម្បត្តិមិនតិចទេដែលត្រូវបានបង្កើតឡើង ដោយសារកិច្ចសហការពីក្រុមគ្រួសារទាំងមូល ដូច្នេះហើយសន្តតិកម្មមានន័យថា ជាការសម្រួលចំណែកដែលមានសក្តានុពលទុកសម្រាប់គ្រួសារ។ ក៏ប៉ុន្តែ ការទទួលស្គាល់រហូតដល់សន្តតិកម្មដោយបងបង្កើតដែលជាញាតិលោហិតក្នុងថ្នាក់ទី ៣ ជាពិសេស ការទទួលស្គាល់ដល់អ្នកទទួលសន្តតិកម្មជំនួសរបស់បងប្អូនបង្កើតទាំងនោះ (ចំពោះសន្តតិកម្មដោយអ្នកទទួលសន្តតិកម្ម ជំនួស នឹងមានលើកមកពិភាក្សាពេលក្រោយ) ថាតើមូលដ្ឋាននៃការធ្វើសន្តតិកម្មបែបនេះត្រូវបានពន្យល់គ្រប់គ្រាន់ដែរ ឬ យ៉ាងណា ក៏មាននៅសល់ចម្ងល់ខ្លះដែរ។ ម្យ៉ាងវិញទៀត ចំពោះការសម្រួលចំណែកដែលមានសក្តានុពលនៃគ្រួសារដែលបានរួមវិភាគទានក្នុងការកើតឡើងនៃទ្រព្យសម្បត្តិរបស់មតកជនវិញ របបបែងចែកភាគនៃវិភាគទានត្រូវបានប្រើដោយវិសោធនកម្មឆ្នាំ ១៩៨០ ហើយទទួលស្គាល់នូវការទារយកមកវិញនៃចំណែកដែលមានសក្តានុពល (មាត្រា ៩០៤-២ នៃ ក្រមរដ្ឋប្បវេណី)។

## ខ) ការធានាជីវភាពគ្រួសារ

ទី ២ របបសន្តតិកម្មត្រូវបានទទួលស្គាល់ដោយសារតែដើម្បីទ្រទ្រង់ជីវភាពគ្រួសារដែលធ្លាប់តែទទួលបាននូវការផ្គត់ផ្គង់អាហារកាតព្វកិច្ចដោយមតកជន។ ជាពិសេស ចំពោះសហព័ទ្ធដែលនៅរស់រានមានជីវិត របបសន្តតិកម្មគឺមានសារៈសំខាន់ខ្លាំងណាស់ ការធ្វើវិសោធនកម្មនាពេលថ្មីដែលធ្វើឲ្យចំណែកមតិករបស់សហព័ទ្ធកាន់តែច្រើន គឺជាការស្តែងឲ្យឃើញនូវការផ្តោតជាសំខាន់លើមូលដ្ឋានបែបនោះហើយ។ ជាពិសេស ចំពោះទ្រព្យអកម្មរបស់មតកជន (ឧទាហរណ៍ដូចជា បំណុលលើប្រាក់កម្ចីជាដើម) ដើម្បីការពារម្ចាស់បំណុល របបសន្តតិកម្មត្រូវបានទទួលស្គាល់ ។

ក៏ប៉ុន្តែ ដូចដែលនឹងមានលើកមកពិភាក្សានាពេលក្រោយនេះ ក្នុងករណីដែលកូន បុព្វញាតិខ្សែផ្ទាល់ និង សហព័ទ្ធ ជាសហសន្តតិជន មតិកមួយភាគជាកំណត់មួយនឹងត្រូវបានរក្សាទុកជាភាគបម្រុង។ របបភាគបម្រុងបែបនោះក៏អាចនិយាយបានផងដែរថា មានន័យជាការទ្រទ្រង់ជីវភាពរបស់សន្តតិជន (ក៏ប៉ុន្តែមិនកំណត់ថាគ្រប់គ្រាន់នោះទេ) ។

## (៣) សន្តតិកម្មតាមច្បាប់ និង សន្តតិកម្មតាមមតកសាសន៍

ចំពោះទម្រង់នៃសន្តតិកម្មវិញ មានសន្តតិកម្មតាមច្បាប់ដែលត្រូវអនុវត្តទៅតាមការកំណត់របស់បញ្ញត្តិនៃច្បាប់ពាក់ព័ន្ធទៅនឹងសន្តតិជន និង ភាគរយនៃចំណែកមត៌ក និង សន្តតិកម្មតាមមតកសាសន៍ ដែលត្រូវអនុវត្តទៅតាមឆន្ទៈរបស់មតកជនកាលដែលនៅរស់ ។

## ក) សន្តតិកម្មតាមច្បាប់

សន្តតិកម្មតាមច្បាប់ត្រូវបានតាក់តែងឡើង ដោយគិតទៅដល់យុត្តិធម៌រវាងញាតិដែលត្រូវបានកំណត់ ថាជាសន្តតិជន។ ជាឧទាហរណ៍ ចំពោះកូនរបស់មតកជន ត្រូវបានទទួលប្រព្រឹត្តកម្មស្មើៗគ្នា ដោយមិនគិតថាជាកូនប្រុស ឬ កូនស្រី និង ក្មេង ឬ ចាស់ នោះទេ (សូមមើលមាត្រា ៨៨៧ និង មាត្រា ៩០០ នៃក្រមរដ្ឋប្បវេណី)។ ម្យ៉ាងវិញទៀត ចំពោះចំណែកមត៌ករបស់សហព័ទ្ធវិញ ច្បាប់ធ្លាប់បានកំណត់ស្មើនឹង ១ ភាគ ៣ នៃសន្តតិកម្ម ក៏ប៉ុន្តែ ដោយសារវិសោធនកម្មឆ្នាំ ១៩៨០ ចំណែកនោះបានក្លាយមកជា ១ ភាគ ២ វិញ (ក្នុងករណីដែលកូន និង សហព័ទ្ធជាសហសន្តតិជន)។ ការជ្រើសរើសយករបបបែបនេះគឺដោយផ្អែកលើការវាយតម្លៃថា គួរតែផ្តល់ប្រព្រឹត្តកម្មឲ្យបានសមគួរទៅដល់សហព័ទ្ធ ដែលនៅរស់ (ដែលជាភាគច្រើនគឺជាប្រពន្ធ) (ចំណុចទី ១ មាត្រា ៩០០ នៃក្រមរដ្ឋប្បវេណី។ នេះក៏ជាការពិចារណាពីស្ថានភាពជាក់ស្តែង ដោយហេតុថា បច្ចុប្បន្នចំនួនកូនបានថយចុះ ដូច្នេះ ទោះបីជាចំណែកដែលកូនបានទទួលថយចុះក៏ដោយ ចំណែកសន្តតិកម្មសម្រាប់ម្នាក់ៗគឺមិនមានការថយចុះធ្ងន់ធ្ងរនោះទេ)។ លើសពីនេះទៅទៀត ទស្សនៈអ្នកច្បាប់បានយល់ឃើញថា គួរតែចាត់ចែងឲ្យបានស្មើភាពគ្នាចំពោះចំណែកមត៌កនៃកូនមានខាន់ស្លា និង កូនឥតខាន់ស្លា (នាពេលបច្ចុប្បន្ន បើតាមចំណុចទី ៤ មាត្រា ៩០០ នៃក្រមរដ្ឋប្បវេណីចំណែកមត៌កនៃកូនឥតខាន់ស្លា គឺស្មើនឹង ១ ភាគ ២ នៃចំណែកមត៌ករបស់កូនមានខាន់ស្លា) ដោយឈរលើទស្សនៈដែលឯកភាពគ្នាថា ប្រព្រឹត្តកម្មដោយស្មើភាពគ្នាចំពោះកូនមានខាន់ស្លា និង កូនឥតខាន់ស្លា គឺការផ្តល់នូវយុត្តិធម៌ចំពោះពួកគេ (ទស្សនៈបែបនេះគឺជាទំនោរនៃពួកបស្ចិមប្រទេសនៅក្រោយសង្គ្រាមលោកលើកទី ២ ) ។

## ខ) សន្តតិកម្មតាមមតកសាសន៍

ផ្ទុយពីសន្តតិកម្មតាមច្បាប់ សន្តតិកម្មតាមមតកសាសន៍ គឺជាការផ្តោតជាសំខាន់ទៅលើការដែលមតកជនជាបឋម អាចធ្វើការចាត់ចែងដោយសេរីនូវទ្រព្យសម្បត្តិរបស់ខ្លួន ហើយជាការគោរពតាមដែលអាចធ្វើទៅបាននូវឆន្ទៈរបស់មតកជននោះកាលដែលគាត់នៅមានជីវិត។ ត្រង់នេះ គឺមានន័យថាជាការទទួលស្គាល់ដោយសេរីនូវការដែលមតកជនធ្វើការចាត់ចែងទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់ខ្លួនតាមមតកសាសន៍។ ឧទាហរណ៍ ការផ្តល់ឲ្យសន្តតិជនមួយចំនួនណានោះនូវទ្រព្យសម្បត្តិច្រើនជាងសន្តតិជនដទៃផ្សេងទៀត ឬ ការផ្តល់ឲ្យបុគ្គលផ្សេងទៀតក្រៅពីសន្តតិជននូវទ្រព្យសម្បត្តិ

ជាដើម អាចធ្វើទៅបានតាមរយៈមតកសាសន៍ (សូមមើលមាត្រា ៩០២ និង មាត្រា ៩៦៤ នៃ ក្រមរដ្ឋប្បវេណី) ។

### (គ) គោលការណ៍នៃសន្តតិកម្ម

ចំពោះបញ្ហាថាតើត្រូវយកសន្តតិកម្មទម្រង់ណាមួយពីក្នុងចំណោមសន្តតិកម្មតាមច្បាប់ និង សន្តតិកម្មតាមមតកសាសន៍ ជាគោលការណ៍នោះ គឺអាស្រ័យទៅលើប្រទេសនីមួយៗ។ តួយ៉ាង ដូចជានៅក្នុងប្រទេសអង់គ្លេស សន្តតិកម្មតាមមតកសាសន៍គឺជាគោលការណ៍ ក៏ប៉ុន្តែ ក្នុងករណីដែលគ្មានមតកសាសន៍ ទេ គឺសន្តតិកម្មត្រូវប្រតិបត្តិទៅតាមការកំណត់របស់ច្បាប់ ។ ដោយឡែកនៅប្រទសជប៉ុនវិញ អាចគិតបានថា ទន្ទឹមនឹងការយកសន្តតិកម្មតាមច្បាប់ជាមូលដ្ឋានគ្រឹះ តុល្យភាពជាមួយនឹងរបបសន្តតិកម្មតាមមតកសាសន៍ក៏កំពុងត្រូវបានថ្លឹងថ្លែងដែរ ។

នៅក្នុងប្រទេសជប៉ុន ជាក់ស្តែងការដែលមតកសាសន៍ត្រូវបានធ្វើឡើងនោះដូចជាមិនសូវមានច្រើនប៉ុន្មានទេ ក៏ប៉ុន្តែ ការធ្វើមតកសាសន៍ក្នុងកាលដែលកំពុងនៅរស់រានមានជីវិតនោះគឺហាក់ដូចជាកំពុងកើនឡើងបន្តិចម្តងៗ។

## ២ សន្តតិជន និង ចំណែកមតិក

### (១) សន្តតិជន

#### ក) កូន បុព្វញាតិផ្ទាល់ និង បងប្អូនប្រុសស្រី

ក្រមរដ្ឋប្បវេណីកំណត់អំពីសន្តតិជន ២ ប្រភេទខុសគ្នា ។ ទី ១ គឺ (ក) កូន (ខ) បុព្វញាតិផ្ទាល់ (ឪពុកម្តាយ ឬ ជីដូនជីតា ជាដើម) និង (គ) បងប្អូនបង្កើត។ អ្នកទាំងនេះគឺជាបុគ្គលដែលស្ថិតក្នុងទំនាក់ទំនងញាតិលោហិតខ្សែផ្ទាល់ជាមួយមតកជន ក៏ប៉ុន្តែ ពួកគេនឹងក្លាយជាសន្តតិជនតាមលំដាប់ (ក) (ខ) (គ)។ មានន័យថា ដំបូង គឺកូននឹងក្លាយទៅជាសន្តតិជន (កថាខណ្ឌទី ១ មាត្រា ៨៨៧ នៃក្រមរដ្ឋប្បវេណី) ប្រសិនបើគ្មានកូនទេ បុព្វញាតិផ្ទាល់នឹងក្លាយទៅជាសន្តតិជន (ចំណុចទី ១ កថាខណ្ឌទី ១ នៃ មាត្រា ៨៨៩ នៃក្រមរដ្ឋប្បវេណី)។ នៅក្នុងចំណោមបុព្វញាតិទាំងនោះ បុព្វញាតិដែលស្ថិតក្នុងលំដាប់ថ្នាក់ញាតិជិតជាងគេ ត្រូវក្លាយជាសន្តតិជន។ ឧទាហរណ៍ថា មានករណីដែលឪពុកម្តាយ និង ជីដូនជីតារបស់មតកជន នៅរស់រានមានជីវិតទាំងអស់គ្នាដូច្នេះ គឺមានតែឪពុកម្តាយទេដែលនឹងក្លាយជាសន្តតិជន។ ក្នុងករណីដែលពុំមានបុព្វញាតិផ្ទាល់ទេ បងប្អូនបង្កើតរបស់មតកជននោះនឹងក្លាយទៅជាសន្តតិជន (ចំណុចទី ២ កថាខណ្ឌ ទី១ មាត្រា ៨៨៩ នៃក្រមរដ្ឋប្បវេណី)។ ប្រសិនបើករណីដែលកូន និង បងប្អូនបង្កើតត្រូវក្លាយជាសន្តតិជន ហើយបុគ្គលទាំងនោះ (អ្នកដែលត្រូវបានធ្វើសន្តតិកម្មជំនួស)

បានទទួលមរណភាព ជាដើម កូនរបស់បុគ្គល (អ្នកធ្វើសន្តតិកម្មជំនួស) ទាំងនោះ ត្រូវធ្វើសន្តតិកម្មជំនួស (កថាខណ្ឌទី ២ មាត្រា ៨៨៧ និង កថាខណ្ឌទី ២ មាត្រា ៨៨៩ នៃក្រមរដ្ឋប្បវេណី)។ សន្តតិជនទាំងអស់នេះ ហៅថា សន្តតិជនញាតិលោហិត ។

### ខ) សហព័ទ្ធ

ទី ២ គឺសហព័ទ្ធ។ ជាធម្មតា សហព័ទ្ធមិនជាប់ទំនាក់ទំនងញាតិលោហិតជាមួយ មតកជនក៏ពិតមែន ក៏ប៉ុន្តែ សហព័ទ្ធជានិច្ចកាលត្រូវក្លាយជាសន្តតិជនលំដាប់ស្មើគ្នាជាមួយនឹងសន្តតិជនញាតិលោហិតដែលបានរៀបរាប់ខាងលើដែរ (មាត្រា ៨៩០ នៃក្រមរដ្ឋប្បវេណី)។ ប្រសិនបើយើងគិតថាសន្តតិកម្មគឺជា ទ្រព្យសម្បត្តិដែលត្រូវបានទទួលបន្តដោយញាតិលោហិត គឺសហព័ទ្ធមិនអាចក្លាយជាសន្តតិជនបានទេ (ការការពារសហព័ទ្ធដែលនៅរស់រានមានជីវិត អាចពិចារណាបានថាអាចធ្វើទៅបានដោយការសម្រួលនូវទ្រព្យសម្បត្តិក្នុងរបបទ្រព្យសម្បត្តិរួមប្តីប្រពន្ធ)។ ចំណុចនេះ ដំបូងឡើយទស្សនៈដែលចាត់ទុកថាសហព័ទ្ធត្រូវក្លាយទៅជាសន្តតិជន ជាករណីលើកលែង ក្នុងករណីដែលមិនមានសន្តតិជនញាតិលោហិត ត្រូវបានទទួលយក ហើយជាបន្តបន្ទាប់មក សហព័ទ្ធត្រូវបានចាត់ចែងដោយចាត់ទុកជាសន្តតិជនតែម្តង។ ប្រសិនបើពិនិត្យមើលដោយផ្តើមចេញពីទស្សនៈនោះទៅយើងអាចនិយាយបានថា ការដែលសហព័ទ្ធក្លាយទៅជាសន្តតិជនជានិច្ចនេះ គឺជាការវិវត្តយ៉ាងខ្លាំងមួយនៃក្រមរដ្ឋប្បវេណីជប៉ុន ។

## (២) ការយល់ព្រម និង ការបោះបង់ចោល

### ក) ការយល់ព្រមទាំងស្រុង ការបោះបង់ចោល និង ការយល់ព្រមដោយមានកម្រិត

ក៏ប៉ុន្តែ សន្តតិជនត្រូវបានរក្សាទុកឲ្យនូវសេរីភាពក្នុងការសម្រេចថាតើត្រូវធ្វើសន្តតិកម្ម ឬ មិនធ្វើ។ មានន័យថា ក្នុងអំឡុងពេល ៣ ខែគិតចាប់ពីពេលដែលបានដឹងថាសន្តតិកម្មបានចាប់ផ្តើម គាត់ត្រូវធ្វើការជ្រើសរើសណាមួយពីក្នុងចំណោមជម្រើសទាំង ៣ ដែលជម្រើសនោះគឺជា (ក) ការយល់ព្រមទាំងស្រុង (ខ) ការបោះបង់ ពោលគឺមិនធ្វើសន្តតិកម្មសោះឡើយ និង (គ) ការយល់ព្រមដោយមានកម្រិត ដោយលើកលែងការសងកាតព្វកិច្ច និង យល់ព្រមទទួលយកត្រឹមកម្រិតនៃទ្រព្យសម្បត្តិដែលខ្លួនបានទទួលតាមរយៈសន្តតិកម្ម (មាត្រា៩១៥ នៃក្រមរដ្ឋប្បវេណី) ។

ក្នុងចំណោមជម្រើសខាងលើ ដោយសារតែការយល់ព្រមដោយមានកម្រិតអាចធ្វើទៅបានលុះត្រាតែសន្តតិជនទាំងអស់ធ្វើរួមគ្នាដូច្នេះ (មាត្រា ៩២៣ នៃក្រមរដ្ឋប្បវេណី) ភាគច្រើនគឺការយល់ព្រមទាំងស្រុង ឬ ការបោះបង់ចោល ត្រូវបានជ្រើសរើស។ ក្នុងអំឡុងពេល ៣ ខែ ដែលកំណត់ទុកសម្រាប់ការពិចារណា ប្រសិនបើមិនបានធ្វើការយល់ព្រម ឬ បោះបង់ចោលទេ សន្តតិជននឹងត្រូវបានចាត់

ទុកថាបានយល់ព្រមទាំងស្រុង (ចំណុចទី ២ មាត្រា ៩២១ នៃក្រមរដ្ឋប្បវេណី) ជាពិសេស ការចាត់ទុកថាបានយល់ព្រមទាំងស្រុងគឺមានភាគច្រើនក្នុងចំណោមជម្រើសទាំង ៣ នេះ ។

## (៣) ចំណែកមត៌ក

### ក) ចំណែកមត៌កដែលកំណត់ដោយច្បាប់

ក្នុងករណីដែលសហសន្តតិជន (ចំនួននៃសន្តតិជនច្រើន) ចំណែកមត៌ករបស់សន្តតិជននីមួយៗត្រូវកំណត់ទៅតាមបញ្ញត្តិច្បាប់ (មាត្រា ៩០០ នៃក្រមរដ្ឋប្បវេណី)។ ជាបឋម ត្រូវកំណត់នូវចំណែកមត៌ករបស់សហព័ទ្ធ រួចហើយចំណែកដែលនៅសល់ត្រូវធ្វើសន្តតិកម្មដោយសន្តតិជនដែលជាញាតិលោហិតនោះ អាស្រ័យទៅលើថាតើសន្តតិជនជាញាតិលោហិតបែបណា (ប្រសិនបើមានចំនួនច្រើនត្រូវបែងចែកស្មើៗគ្នា)។ ក៏ប៉ុន្តែ ក្នុងករណីដែលគ្មានសហព័ទ្ធទេ សន្តតិជនដែលជាញាតិលោហិតត្រូវក្លាយជាសន្តតិជនតាមលំដាប់ដូចបានលើកឡើងខាងលើ ហើយសន្តតិជនក្នុងលំដាប់ដូចគ្នាត្រូវធ្វើសន្តតិកម្មស្មើគ្នា ។

### ខ) សមាមាត្រនៃចំណែកមត៌កដែលកំណត់ដោយច្បាប់

ជាបឋម ប្រសិនបើសហព័ទ្ធ និង កូនជាសន្តតិជន ចំណែកមត៌ករបស់សហព័ទ្ធ គឺស្មើនឹង ១ ភាគ ២ រីឯចំណែករបស់កូនវិញគឺ ១ ភាគ ២ ដែរ (ប្រសិនបើកូនមានចំនួនច្រើន ត្រូវបែងចែកចំណែក ១ ភាគ ២ នោះស្មើៗគ្នាជាបន្តទៀត)។ ជាបន្ត ប្រសិនបើសហព័ទ្ធ និង បុព្វញាតិផ្ទាល់ជាសន្តតិជន ចំណែកមត៌ករបស់សហព័ទ្ធ គឺស្មើនឹង ២ ភាគ ៣ រីឯចំណែកមត៌ករបស់បុព្វញាតិផ្ទាល់វិញ គឺស្មើនឹង ១ ភាគ ៣ (ប្រសិនបើបុព្វញាតិផ្ទាល់មានចំនួនច្រើន ត្រូវបែងចែក ១ ភាគ ៣ នោះស្មើៗគ្នាជាបន្តទៀត)។ ក្នុងករណីដែលសហព័ទ្ធ និង បងប្អូនបង្កើតរបស់មតកជនជាសន្តតិជន ចំណែកមត៌ករបស់សហព័ទ្ធស្មើនឹង ៣ ភាគ ៤ រីឯចំណែកមត៌ករបស់បងប្អូនបង្កើតរបស់មតកជនវិញស្មើនឹង ១ ភាគ ៤ (ប្រសិនបើបងប្អូនបង្កើតរបស់មតកជនមានចំនួនច្រើន ត្រូវបែងចែក ១ ភាគ ៤ នោះស្មើៗគ្នាជាបន្តទៀត)។ ក៏ប៉ុន្តែ ក្នុងករណីនៃការធ្វើសន្តតិកម្មជំនួសវិញ អ្នកធ្វើសន្តតិកម្មជំនួសត្រូវធ្វើសន្តតិកម្មនូវ ចំណែកមត៌កដែលត្រូវទទួលបានដោយអ្នកដែលត្រូវបានធ្វើសន្តតិកម្មជំនួស (ឪពុក ឬ ម្ដាយ របស់អ្នកធ្វើសន្តតិកម្មជំនួស) ។ ក្នុងករណីអ្នកដែលត្រូវបានធ្វើសន្តតិកម្មជំនួសមានតែម្នាក់ ហើយអ្នកធ្វើសន្តតិកម្មជំនួសមានចំនួនច្រើន ចំណែកមត៌កដែលត្រូវទទួលបានអ្នកដែលត្រូវបានធ្វើសន្តតិកម្មជំនួស ក្នុងនាមគាត់ជាសន្តតិជន ត្រូវយកមកបែងចែកស្មើគ្នាក្នុងចំណោមអ្នកធ្វើសន្តតិកម្មជំនួស (មាត្រា ៩០១ នៃក្រមរដ្ឋប្បវេណី) ។

### (៤) ភាគបម្រុង

#### ក) សមាមាត្រនៃចំណែកមត៌កតាមមតកសាសន៍

ដូចដែលបានលើកឡើងខាងលើ មតកជនអាចធ្វើការចង្អុលបង្ហាញពីសមាមាត្រនៃចំណែកមត៌ក ដែលខុសគ្នាពីចំណែកមត៌កដែលកំណត់ដោយច្បាប់ តាមមតកសាសន៍កាលដែលខ្លួននៅរស់រាន មានជីវិតបាន។ ឧទាហរណ៍ថា គាត់មានកូនច្រើននាក់ គាត់អាចធ្វើមតកសាសន៍ដែលមានខ្លឹមសារឲ្យ កូនណាម្នាក់នោះធ្វើសន្តតិកម្មលើទ្រព្យសម្បត្តិទាំងអស់បាន (មាត្រា ៩៦៤ នៃក្រមរដ្ឋប្បវេណី)។ ជាបឋម ដោយសារតែមតកជនអាចធ្វើការចាត់ចែងដោយសេរីនូវទ្រព្យសម្បត្តិ ដែលជាកម្មសិទ្ធិ របស់ខ្លួន មតកសាសន៍ដែលជាមធ្យោបាយបង្ហាញឆន្ទៈក្នុងកាលដែលខ្លួននៅរស់ ត្រូវតែទទួលបាន នូវការគោរពជាដាច់ខាត ក៏ប៉ុន្តែ ចាំបាច់ត្រូវធ្វើការពារត្រឹមកម្រិតណាមួយ ដើម្បីធានាដល់ការ រំពឹងទុកចំពោះសន្តតិកម្មរបស់សន្តតិជន។

#### ខ) របបភាគបម្រុង

ហេតុដូចខាងលើនេះ ទើបកើតមាននូវរបបភាគបម្រុងដែលជាការសម្រួលដល់ការទាមទារដែល ផ្ទុយពីឆន្ទៈរបស់មតកជនដូចរៀបរាប់ខាងលើ។ មានន័យថា ទ្រព្យសន្តតិកម្មមួយផ្នែកត្រូវបានរក្សាទុក ជាភាគបម្រុងសម្រាប់បុគ្គលដែលរំពឹងទុកថានឹងក្លាយជាសន្តតិជន ហើយប្រសិនបើមតកសាសន៍ នោះ បានប៉ះពាល់ទៅដល់ភាគបម្រុង សន្តតិជនអាចកាត់បន្ថយអច្ច័យទាន ជាដើមនោះ និង គ្រប់ គ្រងទុកភាគបម្រុងបាន។ ក៏ប៉ុន្តែ ភាគបម្រុងត្រូវបានទទួលស្គាល់តែចំពោះសន្តតិជនក្រៅពីសន្តតិជន ដែលជាបងប្អូនបង្កើតរបស់មតកជនប៉ុណ្ណោះ ពោលគឺត្រូវបានទទួលស្គាល់តែចំពោះកូន បុព្វញាតិ ផ្ទាល់ និង សហព័ទ្ធ តែប៉ុណ្ណោះ (មាត្រា ១០២៨ នៃក្រមរដ្ឋប្បវេណី)។ សមាមាត្រនៃចំណែក ភាគ បម្រុងខុសគ្នា អាស្រ័យលើថាតើអ្នកណាជាសន្តតិជន។ ឧទាហរណ៍ថា ប្រសិនបើមានតែបុព្វញាតិ ផ្ទាល់តែប៉ុណ្ណោះដែលជាសន្តតិជន ភាគបម្រុងគឺស្មើនឹង ១ ភាគ ៣ នៃទ្រព្យសម្បត្តិរបស់មតកជន ករណីក្រៅពីនេះ ភាគបម្រុងគឺ ១ ភាគ ២ នៃទ្រព្យសម្បត្តិរបស់មតកជន (មាត្រា ១០២៨ នៃ ក្រមរដ្ឋប្បវេណី)។ ដូច្នេះ សមាមាត្រនៃភាគបម្រុងរបស់សន្តតិជននីមួយៗ ត្រូវសម្រេចបែងចែក ដោយ អនុលោមទៅតាមសមាមាត្រនៃចំណែកមត៌ក ។

### ៣ មតកសាសន៍

#### ក) អត្ថន័យនៃមតកសាសន៍

មតកសាសន៍ គឺខុសពីកិច្ចសន្យាធម្មតា ដូចជា កិច្ចសន្យាលក់ទិញ ជាដើម ហើយអានុភាព និង ខ្លឹមសាររបស់មតកសាសន៍ ជាដើម ជាធម្មតានឹងក្លាយជាបញ្ហា នៅពេលដែលម្ចាស់បណ្តាំទទួលមរណភាព។ ដោយហេតុនេះ ល័ក្ខខ័ណ្ឌដ៏តឹងរ៉ឹងមួយចំនួនត្រូវបានកំណត់ឡើងដើម្បីអាចធ្វើការវិនិច្ឆ័យឲ្យបានច្បាស់លាស់អំពីឆន្ទៈរបស់ម្ចាស់បណ្តាំ។ អាចនិយាយម្យ៉ាងទៀតបានថា នៅក្នុងកិច្ចសន្យាលក់ទិញ មិនទាមទារឲ្យមានទម្រង់ជាចាំបាច់ជាកំណត់ណាមួយទេ ដោយសារគេយកគោលការណ៍នៃការបង្កើតកិច្ចសន្យាតាមការព្រមព្រៀង ដែលមានន័យថា កិច្ចសន្យាកើតមានអានុភាពដោយសារតែភាពត្រូវរ៉ូវគ្នានៃឆន្ទៈរបស់គូភាគីនៃកិច្ចសន្យាតែប៉ុណ្ណោះ។ ផ្ទុយទៅវិញ មតកសាសន៍ត្រូវធ្វើឡើងតាមទម្រង់ដែលច្បាប់បានកំណត់ ហើយឧបមាថា បើទោះបីជាឆន្ទៈរបស់ម្ចាស់បណ្តាំច្បាស់លាស់ហើយក៏ដោយ ក៏អានុភាពជាមតកសាសន៍មិនត្រូវបានទទួលស្គាល់ដែរ។

## ខ) មតកសាសន៍ដោយលិខិតឯកជន

ប្រភេទទី ១ នៃមតកសាសន៍គឺមតកសាសន៍ដោយលិខិតឯកជនដែលជាប្រភេទ មតកសាសន៍ដែលម្ចាស់បណ្តាំត្រូវសរសេរពាក្យទាំងអស់នៃបណ្តាំ ចុះដោយខ្លួនឯងនូវកាលបរិច្ឆេទ ឈ្មោះ និង ត្រូវបោះត្រាសម្គាល់អត្តសញ្ញាណលើនោះ (មាត្រា ៩៦៨ នៃក្រមរដ្ឋប្បវេណី)។ ប្រសិនបើខ្វះកាលបរិច្ឆេទ ឬ មិនបានបោះត្រាសម្គាល់អត្តសញ្ញាណទេ សុពលភាពនៃមតកសាសន៍នោះមិនត្រូវបានទទួលស្គាល់ឡើយ។ ក៏ប៉ុន្តែ នៅក្នុងយុត្តិសាស្ត្រ មានទំនោរទៅរកការដែលល័ក្ខខ័ណ្ឌមួយចំនួនត្រូវបានបន្ធូរបន្ថយ ឧទាហរណ៍ដូចជា សូម្បីតែមតកសាសន៍ដែលត្រូវបានសរសេរដោយផ្ទាល់ពីមតកជនដោយមានអ្នកផ្សេងជួយទ្រដៃសរសេរ ជាដើម ក៏ដោយ ក៏យើងអាចមើលឃើញថា សាលក្រមមួយចំនួនសម្រេចទទួលស្គាល់ថាមានសុពលភាពដែរ (សាលដីកាតុលាការកំពូលចុះថ្ងៃទី ៨ ខែ តុលា ឆ្នាំ ១៩៨៧ ក្នុងកម្រងសាលក្រម ឬ សាលដីការឿងក្តីរដ្ឋប្បវេណីភាគទី ៤១ លេខ ៧ ទំព័រទី ១៤៧១)។

មតកសាសន៍ដោយលិខិតឯកជន គឺជាវិធីដែលងាយស្រួលបំផុត ហើយមានគុណសម្បត្តិត្រង់ថាគ្មានអ្នកដទៃណាដឹងអំពីខ្លឹមសារនៃមតកសាសន៍នោះទេ។ ក៏ប៉ុន្តែ ប្រសិនបើខុសល័ក្ខខ័ណ្ឌតម្រូវគឺនឹងត្រូវចាត់ទុកជាមោឃៈ ហើយក៏អាចមានហានិភ័យចំពោះការដែលឆន្ទៈរបស់ម្ចាស់បណ្តាំកាលនៅរស់មិនអាចត្រូវបានសម្រេច ដោយសារតែមតកសាសន៍នោះមិនត្រូវបានគេរកឃើញ (ករណីខ្លះមានដូចជាការបំផ្លាញចោល ឬ លាក់ទុក) (ជាទូទៅ ម្ចាស់បណ្តាំធ្វើការចាត់ចែងចំពោះមតកសាសន៍ដោយការយកទៅផ្ញើទុកជាមួយអ្នកដែលខ្លួនទុកចិត្ត)។ ម្យ៉ាងវិញទៀត អ្នកដែលមិនអាចសរសេរអក្សរបាន គឺមិនអាចប្រើប្រាស់វិធីនេះបានទេ។

## គ) មតកសាសន៍ដោយលិខិតយថាភូត

ប្រភេទទី ២ នៃមតកសាសន៍ គឺមតកសាសន៍ដោយលិខិតយថាភូតដែលជាប្រភេទមតកសាសន៍ដែលត្រូវបានធ្វើឡើងដោយសារការីនៅចំពោះមុខសាក្សីចាប់ពី ២ នាក់ឡើងទៅ (មាត្រា ៩៦៩ នៃក្រមរដ្ឋប្បវេណី)។ ជាធម្មតា ម្ចាស់បណ្តាំត្រូវប្រាប់អំពីខ្លឹមសារនៃបណ្តាំទៅសារការីដោយផ្ទាល់មាត់ ប៉ុន្តែ ក្នុងករណីដែលម្ចាស់បណ្តាំជាបុគ្គលដែលមិនអាចនិយាយបានទេ អាចប្រើវិធីធ្វើមតកសាសន៍ដោយលិខិតយថាភូតនេះបានតាមរយៈអ្នកបកប្រែ (មាត្រា ៩៦៩-២ នៃក្រមរដ្ឋប្បវេណី)។ ភាពប្រថុយប្រថានចំពោះការដែលមតកសាសន៍នឹងត្រូវចាត់ទុកជាមោឃៈដោយសារតែភាពខុសនឹងទម្រង់ ឬអត្ថន័យមិនច្បាស់លាស់ គឺមានតិចតួចណាស់ (ម្យ៉ាងវិញទៀត អ្នកដែលមិនអាចសរសេរអក្សរបានក៏អាចប្រើវិធីនេះបានដែរ) ក៏ប៉ុន្តែ ភាពមិនសុខដុមរមនារវាងញាតិអាចកើតមានឡើង ដោយសារតែសន្តតិជនបានដឹងអំពីខ្លឹមសារនៃមតកសាសន៍នៅពេលដែលមតកជននៅរស់នៅឡើយ។ ក៏ប៉ុន្តែ នៅក្នុងយុត្តិសាស្ត្រ មានករណីមិនតិចទេដែលតុលាការចាត់ទុកជាមោឃៈចំពោះមតកសាសន៍ដោយលិខិតយថាភូត ដោយសារមានករណីដែលសន្តតិជនមួយផ្នែក បានធ្វើឲ្យមតកជនដែលលែងមានសមត្ថភាពខាងឆន្ទៈពេញលេញធ្វើមតកសាសន៍តាមលិខិតយថាភូតដែលផ្តល់ផលប្រយោជន៍ឲ្យពួកខ្លួន ។

### ឃ) មតកសាសន៍ដោយលិខិតសម្ងាត់

ប្រភេទទី ៣ នៃមតកសាសន៍ គឺ មតកសាសន៍ដោយលិខិតសម្ងាត់ដែលម្ចាស់បណ្តាំត្រូវចុះហត្ថលេខា និង បោះត្រាសម្គាល់អត្តសញ្ញាណលើលិខិត ហើយដាក់លិខិតក្នុងស្រោមសំបុត្រ និង ត្រូវបោះត្រាសម្គាល់អត្តសញ្ញាណលើស្រោមសំបុត្រនោះ។ ពុំមានភាពចាំបាច់ដែលម្ចាស់បណ្តាំត្រូវតែសរសេរខ្លឹមសារបណ្តាំដោយខ្លួនឯងទេ ក៏ប៉ុន្តែម្ចាស់បណ្តាំត្រូវដាក់លិខិតដែលបានបិទជិតនោះនៅចំពោះមុខសារការីម្នាក់ និង សាក្សីយ៉ាងតិច ២ នាក់ និងត្រូវធ្វើសេចក្តីថ្លែងការណ៍ថា លិខិតនោះជាលិខិតមតកសាសន៍របស់ខ្លួន ហើយសារការី និង សាក្សីទាំងនោះត្រូវចុះហត្ថលេខាលើលិខិតដែលបានបិទជិតនោះ (មាត្រា ៩៧០ នៃក្រមរដ្ឋប្បវេណី)។ មតកសាសន៍ដោយលិខិតសម្ងាត់នេះ គឺមានគុណសម្បត្តិជាងមតកសាសន៍ដោយលិខិតឯកជន និង មតកសាសន៍ដោយលិខិតយថាភូត ដោយសារតែវាមានភាពច្បាស់លាស់ថាមានមតកសាសន៍ដែលពិត ហើយវារក្សាបាននូវការសម្ងាត់អំពីខ្លឹមសារនៃបណ្តាំផង។

### ង) មតកសាសន៍ពិសេស

មតកសាសន៍ពិសេស គឺជាមតកសាសន៍ដែលត្រូវបានទទួលស្គាល់ជាពិសេស ដោយសារតែម្ចាស់បណ្តាំស្ថិតក្នុងស្ថានភាពមានជំងឺ ឬ ក្នុងហេតុការណ៍ផ្សេងទៀត ដែលមិនអាចធ្វើមតកសាសន៍ទៅតាមទម្រង់ធម្មតាណាមួយបាន ហើយមតកសាសន៍នោះនឹងត្រូវចាត់ទុកថាបាត់បង់សុពលភាព

បើម្ចាស់បណ្ដាំនៅរស់រានមានជីវិតក្នុងអំឡុងពេល ៦ ខែ គិតចាប់ពីពេលដែលម្ចាស់បណ្ដាំបែរជាអាចធ្វើមតកសាសន៍តាមទម្រង់ធម្មតាណាមួយដូចខាងលើបាន (ចាប់ពីមាត្រា ៩៧៦ នៃក្រមរដ្ឋប្បវេណី) ។

## សន្តតិកម្មតាមច្បាប់--ការពិចារណាតាមរយៈករណីសិក្សា

ដោយសារតែ A មិនបានធ្វើមតកសាសន៍កាលដែលគាត់នៅរស់ សន្តតិកម្មត្រូវអនុវត្តទៅតាមបញ្ញត្តិរបស់ច្បាប់។ មានន័យថា សន្តតិជនគឺមាន C និង D ដែលជាកូន និង B ដែលត្រូវជាសហព័ទ្ធ។ ដូច្នេះ សមាមាត្រនៃចំណែកមតិកគឺសហព័ទ្ធ B ត្រូវទទួល ១ ភាគ ២ នៃសន្តតិកម្ម។ ដោយឡែក ភាគដែលនៅសល់ ១ ភាគ ២ គឺកូនត្រូវធ្វើសន្តតិកម្ម ។ ដូច្នេះ C និង D ត្រូវទទួល ១ ភាគ ៤ នៃសន្តតិកម្មក្នុងម្នាក់ៗ។

ក៏ប៉ុន្តែ មិនមែនមានន័យថា B C និង D ត្រូវតែធ្វើសន្តតិកម្មលើទ្រព្យសម្បត្តិ (មិនមែនមានតែទ្រព្យសកម្មប៉ុណ្ណោះទេ គឺមានទ្រព្យអកម្មដែរ) របស់ A តែម្ដងនោះទេ ។ ចាប់ពីពេលដែលបានដឹងថាសន្តតិកម្មបានចាប់ផ្ដើមចំពោះខ្លួន (នៅក្នុងករណីសិក្សាខាងលើ អាចនិយាយបានថា B C និង D បានដឹងពីការចាប់ផ្ដើមសន្តតិកម្មចំពោះខ្លួននៅពេល A ទទួលមរណភាព) ក្នុងអំឡុងពេល ៣ ខែ សន្តតិជនអាចធ្វើការយល់ព្រមទាំងស្រុង ការយល់ព្រមដោយមានកម្រិត ឬ អាចធ្វើការបោះបង់បាន។ ប្រសិនបើសន្តតិកម្មរបស់ A មានទ្រព្យអកម្ម យើងអាចគិតបានថា ពួកគេនឹងធ្វើការបោះបង់ចោល ។

បើទោះបីជាសមាមាត្រនៃចំណែកមតិករបស់សន្តតិជននីមួយៗត្រូវបានកំណត់ហើយក៏ដោយ ដើម្បីធ្វើការបែងចែកទ្រព្យសម្បត្តិនោះឲ្យជាក់លាក់ទៅតាមសមាមាត្រនោះ ចាំបាច់ត្រូវអនុវត្តនីតិវិធីបែងចែកមតិក (ចាប់ពីមាត្រា ៩០៦ នៃក្រមរដ្ឋប្បវេណី)។ ជាគោលការណ៍ ការបែងចែកត្រូវធ្វើឡើងដោយអនុលោមទៅតាមការពិភាក្សារវាងសហសន្តតិជន ក៏ប៉ុន្តែ បើការពិភាក្សាពុំបានសម្រេច ឬ បើពុំអាចពិភាក្សាបានទេ ការបែងចែកអាចធ្វើឡើងដោយតុលាការទៅតាមការស្នើសុំរបស់សហសន្តតិជន (មាត្រា ៩០៧ នៃក្រមរដ្ឋប្បវេណី) ។

## ✧ សុភាសិតច្បាប់

សុភាសិតគឺជាប្រយោគសាមញ្ញធម្មតា ប៉ុន្តែ អាចពន្យល់បានយ៉ាងទូលំទូលាយនូវអត្ថន័យនៃការពិតដែលកើតឡើងក្នុងសង្គមមនុស្ស ហើយដែលត្រូវបានប្រើប្រាស់ក្នុងកិច្ចសន្ទនា និង ឃ្លាប្រយោគផ្សេងៗតាំងពីបុរាណកាលមក។ ក្នុងវិស័យសិក្សាច្បាប់ ក៏មានការលើកឡើងនូវសុភាសិតជាច្រើនផងដែរនៅក្នុងសៀវភៅនេះ (ដែលយើងហៅជាពិសេសថា សុភាសិតច្បាប់)។ សុភាសិតទាំងនោះ ភាគច្រើនមានប្រភពចេញមកពីច្បាប់រ៉ូម៉ាំង (ក្រមយ៉ាស្ទីនៀនស៍)ដែលភាគច្រើនត្រូវបានសរសេរជាភាសាឡាតាំងដែលជាភាសាយាននៅអឺរ៉ុបនាមជ្ឈិមសម័យ។

ឧទាហរណ៍ ដូចជាទាក់ទងនឹងអានុភាពចងនៃកិច្ចសន្យា គេច្រើនប្រើសុភាសិតច្បាប់ដែលថា "ត្រូវតែគោរពកិច្ចសន្យាជាដាច់ខាត" (Pacta sunt servanda)។ នេះគឺមានប្រភពចេញពីទ្រឹស្តីនីតិនៃវិហារគ្រិស្តដែលផ្តល់អានុភាពចងទៅលើកិច្ចសន្យានោះផ្ទាល់។ នេះគឺបង្ហាញអំពីមូលដ្ឋានសីលធម៌ក្នុងទំនាក់ទំនងគតិយុត្ត។

ដោយឡែក ក៏មានសុភាសិតច្បាប់មួយដែលថា "នរណាក៏មិនអាចយកកេរ្តិ៍អាស្រូវរបស់ខ្លួនមកធ្វើជាអំណះអំណាងបានឡើយ" (Nemo auditur propriam turpitudinem allegans)។ នេះក៏ជាសុភាសិតបង្កើតឡើងដោយនីតិវិទូវិហារគ្រិស្ត ដែលពាក់ព័ន្ធនឹងប្រជុំទ្រឹស្តីនៃនីតិរ៉ូម៉ាំង ពោលគឺសំដៅលើការដែលមិនអាចអះអាងយកទង្វើអសីលធម៌របស់ខ្លួនមកធ្វើជាមូលហេតុគតិយុត្តក្នុងបណ្តឹងបានទេ ។ នេះគឺត្រូវបានអនុវត្តក្នុងបណ្តាប្រទេសដែលប្រកាន់យកប្រព័ន្ធច្បាប់ទ្វីប ដូចជាប្រទេសបារាំង អាល្លឺម៉ង់ ជាដើម ។ មាត្រា ៧០៨ នៃក្រមរដ្ឋប្បវេណីជប៉ុនស្តីពីការផ្តល់តាវកាលិកដោយមូលហេតុខុសច្បាប់ ក៏មានប្រភពចេញពីគោលគំនិតបែបនេះដែរ (ក្នុងដំណាក់កាលបញ្ញត្តក្រមរដ្ឋប្បវេណី សុភាសិតច្បាប់នេះត្រូវបានគេលើកឡើង) ។

ដូច្នេះគឺមានសុភាសិតច្បាប់ច្រើន ហើយការដកស្រង់សុភាសិតទាំងនោះក្នុងសៀវភៅសិក្សារបស់ជប៉ុន ក៏មានមិនតិចដែរ។ ឧទាហរណ៍ ដូចជាសុភាសិតដែលកើតក្រោយច្បាប់រ៉ូម៉ាំង ដែលថា "ការលក់ទិញនឹងកាត់ផ្តាច់នូវការខ្ចីជួល" (Kauf bricht Miete) ត្រូវបានគេលើកឡើងក្នុងសៀវភៅសិក្សាជាច្រើន (មិនមែនជាភាសាឡាតាំងទេ គឺភាសាអាល្លឺម៉ង់)។ នេះគឺបានន័យថា ប្រសិនបើវត្ថុដែលកំពុងខ្ចីជួលត្រូវបានលក់ចេញ អ្នកខ្ចី ឬជួលមិនអាចអះអាងជាមួយអ្នកទិញដែលជាម្ចាស់កម្មសិទ្ធិថ្មីបានឡើយ (ប្រសិនបើអ្នកទិញទាមទារ ត្រូវតែសងមកវិញ)។ នេះគឺជាទ្រឹស្តីដែលកើតចេញពីភាពដាច់ខាតនៃសិទ្ធិប្រត្យក្ស និង ភាពមិនដាច់ខាតនៃសិទ្ធិលើបំណុល ប៉ុន្តែ ត្រូវបានធ្វើការកែប្រែយ៉ាងច្រើនក្នុងពេលបច្ចុប្បន្ននេះ ។

# ជំពូកទី ១៥

# ស្ថាប័ន

**១ ប្រធាននៃសិទ្ធិ ៖ រូបវន្តបុគ្គល ឬ នីតិបុគ្គល**

(១) របបនីតិបុគ្គល

(២) ច្បាប់ដែលពាក់ព័ន្ធនឹងនីតិបុគ្គល

**២ សកម្មភាពនីតិបុគ្គល**

**៣ សាជីវកម្ម ឬ មូលនិធិដែលគ្មានសមត្ថភាពទទួលសិទ្ធិ**

**៤ ក្រុមហ៊ុន**

✎ កាតព្វកិច្ចរបស់សាជីវកម្មដែលគ្មានសមត្ថភាពទទួលសិទ្ធិ--ការពិចារណាតាមរយៈករណីសិក្សា

Khmer Law's Association

ករណីសិក្សា៖ A B ...ជាដើមបានរួមគ្នាបង្កើតសមាគមមួយដែលមានឈ្មោះថា X ដែលមានគោលដៅការពារបរិស្ថាន ហើយបានធ្វើសកម្មភាពផ្សេងៗជាច្រើន។ A ដែលជាអ្នកតំណាងរបស់ X បានខ្ចីប្រាក់ពីធនាគារ Y ចំនួន ១ លានយ៉េន មកធ្វើជាប្រាក់ផ្គត់ផ្គង់ដល់សកម្មភាពទាំងនោះ។ ដោយសារតែកាលបរិច្ឆេទសងបានមកដល់ហើយ តែការសងនៅតែមិនទាន់បានធ្វើឡើង ធនាគារ Y បានទាមទារឲ្យ A សង ។ A បានឆ្លើយតបទៅវិញថាសូមឲ្យរង់ចាំបន្តិចទៀតព្រោះប្រាក់របស់សមាគម X មិនទាន់មានទេ ក៏ប៉ុន្តែ ធនាគារ Y បានទាមទារឲ្យ A សងក្នុងនាមជាបុគ្គល។ តើត្រូវគិតយ៉ាង ដូចម្តេច ចំពោះបញ្ហានេះ ?

១ ប្រធាននៃសិទ្ធិ ៖ រូបវន្តបុគ្គល ឬ នីតិបុគ្គល

## (១) របបនីតិបុគ្គល

### ក) អត្ថន័យនៃនីតិបុគ្គល

ដូចដែលបានបង្ហាញជូនពីខាងដើមរួចហើយ សមត្ថភាពទទួលសិទ្ធិត្រូវបានផ្តល់ដល់មនុស្សគ្រប់ៗគ្នា។ មានន័យថា ឋានៈ (លក្ខណសម្បត្តិ) ទទួលសិទ្ធិ និង រ៉ាប់រងកាតព្វកិច្ច ត្រូវបានទទួលស្គាល់។ ក៏ប៉ុន្តែ ឋានៈទទួលសិទ្ធិ និង រ៉ាប់រងកាតព្វកិច្ច មិនត្រូវបានកំណត់តែចំពោះរូបវន្តបុគ្គលតែប៉ុណ្ណោះទេ។ ក្រុមប្រមូលផ្តុំនៃមនុស្ស (ហៅថា សាជីវកម្ម) ឬ ក្រុមប្រមូលផ្តុំនៃទ្រព្យសម្បត្តិ (ហៅថា មូលនិធិ) ក៏ដូចគ្នាផងដែរ នៅក្រោមល័ក្ខខ័ណ្ឌជាកំណត់មួយ ឋានៈជាប្រធាននៃសិទ្ធិ និង កាតព្វកិច្ច នឹងត្រូវបានទទួលស្គាល់។ សាជីវកម្ម ឬ មូលនិធិបែបនេះ ហៅថា នីតិបុគ្គល (បើនិយាយប្រៀបធៀប ជាមួយនឹងនីតិបុគ្គល គេអាចហៅមនុស្សថា រូបវន្តបុគ្គល)។ សមត្ថភាពទទួលសិទ្ធិរបស់នីតិបុគ្គលបែបនោះ គេហៅថា បុគ្គលភាពគតិយុត្ត ឬ ភាពជានីតិបុគ្គល។

តើរបបនីតិបុគ្គលមានអត្ថន័យ និង ខ្លឹមសារយ៉ាងណា?

### ខ) មុខងារនៃនីតិបុគ្គលសាជីវកម្ម

ជាបឋម សូមពិចារណាពីនីតិបុគ្គលសាជីវកម្មដូចខាងក្រោម។ មានមនុស្សដែលមានគ្នាប៉ុន្មាននាក់ នាំគ្នាប្រមូលផ្តុំ ហើយបង្កើតជាសាជីវកម្ម (ពោលគឺជាស្ថាប័ន) ហើយក្នុងករណីដែលពួកគេធ្វើសកម្មភាពក្នុងនាមជាស្ថាប័ន យើងអាចគិតបានថា ចំពោះទំនាក់ទំនងទ្រព្យសម្បត្តិនៃនីតិបុគ្គលនោះគឺជាចំណែករបស់មនុស្សម្នាក់ៗដែលនាំគ្នាបង្កើតឲ្យមានជាស្ថាប័នឡើងនោះ។ ឧទាហរណ៍ថា

មនុស្ស ១០នាក់បង្កើតស្ថាប័នមួយក្នុងករណីដែលស្ថាប័នមានកម្មសិទ្ធិលើដីមួយកន្លែង គឺអាចប្រមើល មើលបានថា ដីនោះនឹងត្រូវកម្មសិទ្ធិរួមគ្នា (កម្មសិទ្ធិអវិភាគ) របស់អ្នកទាំង ១០ នាក់នោះ។

របបនីតិបុគ្គល ក្នុងករណីដូចសាជីវកម្មខាងលើនេះ គឺជារបបដែលទទួលស្គាល់សមត្ថភាពទទួលសិទ្ធិរបស់សាជីវកម្ម ដោយទទួលស្គាល់ភាពជាប្រធាននៃសិទ្ធិ និង កាតព្វកិច្ចរបស់សាជីវកម្ម ដែលដាច់ដោយឡែកពីភាពជាប្រធាននៃសិទ្ធិ និង កាតព្វកិច្ចរបស់សមាជិកនីមួយៗនៃសាជីវកម្មនោះ។ តាមរយៈការចាត់ចែងដាច់ដោយឡែកពីគ្នារវាងសាជីវកម្ម និង សមាជិកនៃសាជីវកម្ម យើងអាចធ្វើការបែងចែកដាច់ស្រឡះពីគ្នាបានរវាងទំនាក់ទំនងគតិយុត្តនៃសមាជិកនីមួយៗ និង ទំនាក់ទំនងគតិយុត្តនៃសាជីវកម្ម។ ឧទាហរណ៍ ម្ចាស់បំណុលដែលមានសិទ្ធិលើបំណុលលើសមាជិកម្នាក់នៃសាជីវកម្មណាមួយ មិនអាចទាមទារឲ្យសមាជិកនោះធ្វើការសងបំណុលដោយយកទ្រព្យសម្បត្តិរបស់សាជីវកម្មនោះបានទេ។ ការបែងចែកដាច់ពីគ្នារវាងសមាជិកនៃសាជីវកម្ម និង សាជីវកម្ម បែបយ៉ាងនេះគឺជាគុណសម្បត្តិដ៏ធំបំផុតមួយ នៃរបបនីតិបុគ្គលសាជីវកម្ម ។

### គ) មុខងារនៃនីតិបុគ្គលមូលនិធិ

ចំពោះមូលនិធិដែលជាក្រុមប្រមូលផ្តុំនៃទ្រព្យសម្បត្តិក៏ដូចគ្នាផងដែរ គឺមានភាពខុសគ្នាច្រើន ឬតិចទៅតាមរបៀបដែលស្តែងចេញជាជាក់លាក់ ក៏ប៉ុន្តែ ចំពោះការបែងចែករវាងបុគ្គលម្នាក់ៗជាមួយនឹងមូលនិធិគឺអាចគិតបានដូចគ្នាទៅនឹងការបែងចែករវាងបុគ្គលម្នាក់ជាមួយនឹងសាជីវកម្ម។ មានន័យថា មានករណីដែលបុគ្គលម្នាក់បានគិតឃើញថាចង់យកទ្រព្យដែលជាកម្មសិទ្ធិរបស់ខ្លួនទៅប្រើប្រាស់ដើម្បីជួយការពារបរិស្ថាន គឺគេអាចប្រតិបត្តិការងារផ្សេងៗដែលពាក់ព័ន្ធទៅដល់ការការពារបរិស្ថានដោយយកទ្រព្យសម្បត្តិនោះធ្វើជាមូលនិធិបាន។ គេក៏អាចធ្វើសកម្មភាពបែបនោះ ក្នុងនាមជា បុគ្គលបានដែរ ក៏ប៉ុន្តែ ដោយផ្អែកទៅលើការបែងចែកដាច់ស្រឡះពីគ្នារវាងសកម្មភាពបុគ្គល និង សកម្មភាពមូលនិធិ គឺអាចទប់ស្កាត់ឥទ្ធិពលនៃសកម្មភាពម្ខាងទៀតទៅវិញទៅមកបាន ។

ជាឧទាហរណ៍ ប្រសិនបើសកម្មភាពមួយជាសកម្មភាពជាបុគ្គល ប្រសិនបើបុគ្គលនោះទទួលមរណភាព សកម្មភាពនោះនឹងត្រូវបញ្ចប់ លើកលែងតែសន្តតិជនរបស់បុគ្គលនោះបន្តសកម្មភាពនោះ។ ផ្ទុយទៅវិញ ប្រសិនបើសកម្មភាពនោះជាសកម្មភាពរបស់មូលនិធិវិញ បើទោះជាបុគ្គលដែលបានបរិច្ចាកទ្រព្យសម្បត្តិបានទទួលមរណភាពហើយក៏ដោយ ក៏សកម្មភាពជាមូលនិធិនោះនៅតែបន្តមានដែរ។ ម្យ៉ាងវិញទៀត អត្ថន័យនៃរបបមូលនិធិក៏ជារបបគ្រប់គ្រងទ្រព្យសម្បត្តិដែលគ្មានម្ចាស់ដើម្បីគោលបំណងជាក់លាក់មួយដែរ ឧទាហរណ៍ដូចជាក្នុងករណីដែលបុគ្គលម្នាក់បានទទួលមរណភាព ដោយបន្សល់ទុកទ្រព្យសម្បត្តិដោយគ្មានសន្តតិជន (ទ្រព្យសម្បត្តិដែលគ្មានកម្មសិទ្ធិករ) ។

ក៏ប៉ុន្តែ ចំពោះច្បាប់នៅប្រទេសអាមេរិក និង អឺរ៉ុបវិញ មានរបបមួយហៅថា ការថែរក្សាទ្រព្យសម្បត្តិជំនួស (trust) ដែលជារបបផ្ញើទ្រព្យសម្បត្តិដើម្បីគោលបំណងជាក់លាក់ជាកំណត់មួយ។ ឧទាហរណ៍ថា ដូចជាក្នុងករណីដែលមានកិច្ចសន្យាដែលមានបុគ្គលម្នាក់ (អ្នកផ្ញើ) បានធ្វើអនុប្បទាននូវទ្រព្យរបស់ខ្លួនទៅក្រុមហ៊ុនទទួលផ្ញើ (អ្នកទទួលបញ្ញើ) ហើយក្រុមហ៊ុនទទួលផ្ញើបានយកទ្រព្យសម្បត្តិនោះទៅវិនិយោគដោយប្រគល់នូវផលប្រយោជន៍ដែលទទួលបានពីការវិនិយោគនោះទៅឲ្យតតិយជន (អ្នកទទួលផលប្រយោជន៍)។ នៅក្នុងប្រព័ន្ធច្បាប់ទ្វីប ពុំមានរបបបែបនេះទេ ដោយសារមានរបបមូលនិធិបំពេញមុខងារបែបដូចគ្នានោះហើយ។ ក៏ប៉ុន្តែនាពេលថ្មីៗនេះ បណ្តាប្រទេសនៃប្រព័ន្ធច្បាប់ទ្វីបមួយចំនួនបាននឹងកំពុងតែពិចារណាលើរបបថែរក្សាទ្រព្យសម្បត្តិជំនួសនេះ។ ប្រទេសជប៉ុនបានទទួលឥទ្ធិពលពីរបបថែរក្សាទ្រព្យសម្បត្តិជំនួសនេះ ហើយបានអនុម័តច្បាប់ស្តីពីការថែរក្សាទ្រព្យសម្បត្តិជំនួសនេះរួចហើយនៅឆ្នាំ ១៩២២ ក៏ប៉ុន្តែត្រូវបានធ្វើវិសោធនកម្មមួយភាគធំនៅក្នុងឆ្នាំ ២០០៦ ។

## (២) ច្បាប់ដែលពាក់ព័ន្ធនឹងនីតិបុគ្គល

របបគតិយុត្តដែលពាក់ព័ន្ធជាមួយនឹងនីតិបុគ្គលនេះ គឺមានភាពស្មុគស្មាញខ្លាំងណាស់។ នៅមុនពេលដែលមានវិសោធនកម្មនៅក្នុងឆ្នាំ ២០០៦ ក្រមរដ្ឋប្បវេណីបានចែងនូវបញ្ញត្តិដែលពាក់ព័ន្ធ ជាមួយនឹងការបង្កើតនីតិបុគ្គលបម្រើផលប្រយោជន៍សាធារណៈ រចនាសម្ព័ន្ធ និង ការគ្រប់គ្រង ជាដើម ។ ចំពោះការបង្កើតនីតិបុគ្គល គឺច្បាប់បានកំណត់យកគោលការណ៍ការទទួលការអនុញ្ញាត ដោយកំណត់ថា នីតិបុគ្គលអាចបង្កើតបានដោយទទួលបានការអនុញ្ញាតពីស្ថាប័នអាណាព្យាបាល ហើយស្ថាប័នអាណាព្យាបាលធ្វើការត្រួតពិនិត្យទៅលើនីតិបុគ្គលនោះ ។

ក៏ប៉ុន្តែ ដោយអនុលោមទៅតាមកំណែទម្រង់នីតិបុគ្គលដែលបម្រើផលប្រយោជន៍សាធារណៈនៅឆ្នាំ ២០០៦ ការបង្កើតសាជីវកម្ម ឬ មូលនិធិ និង ការទទួលស្គាល់ភាពមានផលប្រយោជន៍ជាសាធារណៈ ត្រូវបានដាក់ឲ្យមាននីតិវិធីដាច់ដោយឡែក។ ជាបឋម នៅក្នុងក្រមរដ្ឋប្បវេណី ការគ្រប់គ្រង ការប្រព្រឹត្តទៅ រចនាសម្ព័ន្ធ និង ការបង្កើតនីតិបុគ្គលដែលមានគោលបំណងបម្រើឲ្យការស្រាវជ្រាវ សិល្បៈ មនុស្សធម៌ សាសនា និង ផលប្រយោជន៍សាធារណៈដទៃផ្សេងទៀត និង នីតិបុគ្គលដែលមានគោលបំណងទាញយកចំណេញ ត្រូវអនុលោមទៅតាមការកំណត់របស់ក្រមរដ្ឋប្បវេណី និង ការកំណត់របស់ច្បាប់ផ្សេងទៀត (កថាខណ្ឌទី ២ មាត្រា ៣៣ នៃក្រមរដ្ឋប្បវេណី)។ ឧទាហរណ៍ ដូចជាចំពោះនីតិបុគ្គលដែលមានគោលបំណងបម្រើផលប្រយោជន៍សាធារណៈ មានច្បាប់ពិសេសដូចជា ច្បាប់ស្តីពីសាលាឯកជន និង ច្បាប់ស្តីពីនីតិបុគ្គលសាសនា ជាដើម ។ ម្យ៉ាងវិញទៀត ចំពោះនីតិបុគ្គលដែលមានគោលបំណងទាញយកចំណេញ គឺមានច្បាប់ក្រុមហ៊ុន។ ហេតុដូច្នេះហើយបានជាក្រមរដ្ឋប្បវេណីរក្សាទុកតែបញ្ញត្តិទូទៅមួយចំនួនដែលពាក់ព័ន្ធជាមួយសមត្ថភាពនៃនីតិបុគ្គល នីតិបុគ្គលបរទេស និង ការចុះបញ្ជីតែប៉ុណ្ណោះ ។

ច្បាប់ដែលត្រូវបានធ្វើវិសោធនកម្មថ្មី "ច្បាប់ស្តីពីនីតិបុគ្គលសាជីវកម្មទូទៅ និង នីតិបុគ្គលមូលនិធិទូទៅ (ច្បាប់លេខ ៤៨ ឆ្នាំ ២០០៦)" (តទៅហៅថា ច្បាប់នីតិបុគ្គលសាជីវកម្មទូទៅ និង មូលនិធិទូទៅ) បានកំណត់អំពីការបង្កើតនូវរបបដែលអាចទទួលឋានៈជានីតិបុគ្គលបានដោយងាយ ចំពោះសាជីវកម្ម ឬ មូលនិធិដែលគ្មានគោលបំណងធ្វើការបែងចែកប្រាក់ដែលនៅសេសសល់ ដោយពុំចាំបាច់គិតពិចារណាពីភាពមាន ឬ គ្មានផលប្រយោជន៍សាធារណៈនៃដំណើរការប្រព្រឹត្តទៅនៃសាជីវកម្ម ឬ មូលនិធិទាំងនោះទេ ហើយក៏បានកំណត់អំពីការបង្កើតបែបនេះ រចនាសម្ព័ន្ធស្ថាប័ន ជាដើម។ ម្យ៉ាងវិញទៀត "ច្បាប់ស្តីពីការទទួលស្គាល់នីតិបុគ្គលសាជីវកម្ម និង នីតិបុគ្គលមូលនិធិដែលបម្រើផលប្រយោជន៍សាធារណៈ (ច្បាប់លេខ ៤៩ ឆ្នាំ ២០០៦" ដែលត្រូវបានអនុម័តនៅពេលជាមួយគ្នា បានបង្កើតឲ្យមានជាមូលដ្ឋាននូវរបបដែលនាយករដ្ឋមន្ត្រី ឬ អភិបាលរាជធានី ខេត្ត អាចធ្វើការទទួលស្គាល់ភាពមានផលប្រយោជន៍ជាសាធារណៈនៃនីតិបុលគ្គលសាជីវកម្មទូទៅ ឬ នីតិបុគ្គលមូលនិធិទូទៅព្រមជាមួយគ្នានឹងការប្រតិបត្តិការត្រួតពិនិត្យចំពោះនីតិបុគ្គលដែលទទួលបានការទទួលស្គាល់តាមរយៈយោបល់របស់គណៈកម្មការដែលបង្កើតដោយបញ្ញាវន្តឯកជន ។

## ២ សកម្មភាពនីតិបុគ្គល

### ក) ការបង្កើតនីតិបុគ្គល

ចំពោះការបង្កើតនីតិបុគ្គល មានទម្រង់ច្រើនបែបច្រើនយ៉ាងអាស្រ័យទៅលើភាពខ្លាំង ឬ ខ្សោយនៃបទប្បញ្ញត្តិរបស់ប្រទេសចំពោះការបង្កើតនោះ។ គោលការណ៍ប័ណ្ណប៉ាតង់គឺមានការកម្រិតខ្លាំងបំផុត ដោយតម្រូវឲ្យនីតិបុគ្គលនីមួយៗ ផ្អែកលើច្បាប់ពិសេសក្នុងការបង្កើតនីតិបុគ្គល (ឧទាហរណ៍ដូចជាធនាគារជប៉ុន ជាដើម)។ ផ្ទុយទៅវិញ គោលការណ៍គោរពបទដ្ឋាន គឺការទទួលស្គាល់នូវការបង្កើតនីតិបុគ្គលនៅក្នុងករណីដែលបានបំពេញលក្ខណៈជាកំណត់ជាក់លាក់ដែលកំណត់ដោយច្បាប់រួចហើយ (ក្រៅពីនេះ នៅមានគោលការណ៍ដែលធូរលុងគឺគោលការណ៍បង្កើតដោយសេរីដែលមិនកំណត់ពីល័ក្ខខ័ណ្ឌជាទម្រង់អ្វីឡើយចំពោះការបង្កើត ប៉ុន្តែ ករណីនេះមិនមាននៅប្រទេសជប៉ុនទេ។ មានឧទាហរណ៍ ដូចជាក្រុមហ៊ុន និង សហជីពពលករដែលត្រូវបង្កើតឡើងតាមច្បាប់ក្រុមហ៊ុន ជាដើម ពោលគឺចំពោះនីតិបុគ្គលទាញយកចំណេញវិញ ច្បាប់ស្តីពីក្រុមហ៊ុនបានអនុម័តយកគោលការណ៍គោរពបទដ្ឋាន (មាត្រា ៤៩ និង មាត្រា ៥៧៩ នៃច្បាប់ស្តីពីក្រុមហ៊ុន)។ ម្យ៉ាងវិញទៀត ចំពោះនីតិបុគ្គលសាជីវកម្មទូទៅ ក៏ដូចជានីតិបុគ្គលមូលនិធិទូទៅដែរ គឺច្បាប់បានអនុម័តយកគោលការណ៍គោរពបទដ្ឋាន (មាត្រា ២២ និងមាត្រា ១៦៣ នៃច្បាប់ស្តីពីនីតិបុគ្គលសាជីវកម្ម និង មូលនិធិទូទៅ)។ គោលការណ៍ដែលមានលក្ខណៈជាកណ្តាលនោះគឺមានគោលការណ៍អនុញ្ញាត និង គោលការណ៍ទទួលស្គាល់។ គោលការណ៍ទាំងពីរនេះ គឺអាចបង្កើតនីតិបុគ្គលបានតាមរយៈការអនុញ្ញាត ឬ ការទទួលស្គាល់ដោយក្រសួងមន្ទីរសាមី ចំពោះករណីដែលបានបំពេញល័ក្ខខ័ណ្ឌដែលកំណត់ដោយច្បាប់ ។

នៅក្នុងករណីនៃគោលការណ៍អនុញ្ញាត គឺច្បាប់ផ្តល់នូវអំណាចឆន្ទានុសិទ្ធិទៅឲ្យស្ថាប័ន ក្រសួងមន្ទីរសាមី ក្នុងការសម្រេចថា អនុញ្ញាត ឬ មិនអនុញ្ញាត រីឯគោលការណ៍ទទួលស្គាល់វិញ ក្រសួងមន្ទីរសាមីពុំមានអំណាចឆន្ទានុសិទ្ធិអ្វីទេ ពោលគឺឲ្យតែល័ក្ខខ័ណ្ឌត្រូវបានបំពេញ គឺត្រូវតែផ្តល់ការអនុញ្ញាត។ នៅក្នុងក្រមរដ្ឋប្បវេណីមុនពេលធ្វើវិសោធនកម្មឆ្នាំ ២០០៦ បានអនុម័តយកគោលការណ៍ទទួលស្គាល់ចំពោះនីតិបុគ្គលដែលបម្រើផលប្រយោជន៍សាធារណៈ (មាត្រា ៣៤ ចាស់ នៃក្រមរដ្ឋប្បវេណី)។ នីតិបុគ្គលដែលច្បាប់បានអនុម័តយកគោលការណ៍ទទួលស្គាល់មកអនុវត្តមានដូចជា នីតិបុគ្គលសាលារៀន នីតិបុគ្គលសាសនា និង សហជីពផ្សេងៗ ជាដើម។ ក៏ប៉ុន្តែ នៅក្នុងករណីជាកំណត់មួយគឺនីតិបុគ្គលត្រូវតែបង្កើតឡើងជាកាតព្វកិច្ចដោយមិនអាចជៀសបាន (ឧទាហរណ៍ដូចជា គណៈមេធាវី ជាដើម។ នៅក្នុងករណីបែបនោះគេហៅថា គោលការណ៍ចាប់បង្ខំ ។

## ខ) នីតិវិធីបង្កើត និង អានុភាពនៃការបង្កើត

បុគ្គលដែលមានបំណងបង្កើតនីតិបុគ្គលសាជីវកម្មទូទៅ ឬ នីតិបុគ្គលមូលនិធិទូទៅ ត្រូវតែធ្វើការចុះបញ្ជីជាដាច់ខាតនូវចំណុចចាំបាច់ទៅតាមបញ្ញត្តិស្តីពីគោលបំណង នាមករណ៍ ទីស្នាក់ការ និង បញ្ញត្តិស្តីពីការតែងតាំង និង ការផ្លាស់ប្តូរអភិបាល ដែលជាបទប្បញ្ញត្តិទូទៅជាមូលដ្ឋាន កំណត់អំពីលក្ខន្តិកៈនៃការបង្កើតនីតិបុគ្គល (មាត្រា ១០ ដល់មាត្រា ១៤ និង មាត្រា ១៥២ ដល់មាត្រា ១៥៦ នៃច្បាប់ស្តីពីនីតិបុគ្គលសាជីវកម្ម និង មូលនិធិទូទៅ)។ ហេតុដូច្នេះ នៅពេលដែលបង្កើតនីតិបុគ្គលមួយចាំបាច់ត្រូវតែធ្វើការចុះបញ្ជី ហើយប្រសិនបើមិនបានចុះបញ្ជីទេ គឺមិនអាចតតាំងជាមួយតតិយជនបានទេ (មាត្រា ៣៦ នៃក្រមរដ្ឋប្បវេណី និង មាត្រាចាប់ពី ២៩៩ នៃ ច្បាប់ស្តីពីនីតិបុគ្គលសាជីវកម្ម និង មូលនិធិទូទៅ) ។

## គ) រចនាសម្ព័ន្ធរបស់នីតិបុគ្គល

ដោយសារតែនីតិបុគ្គលសាជីវកម្ម ជាការប្រមូលផ្តុំនូវមនុស្ស ដូច្នេះ ត្រូវតែមានសមាជិកដែលជាអ្នកបង្កើតឲ្យមាននីតិបុគ្គលនោះឡើង (ក៏ប៉ុន្តែ ចំពោះក្រុមហ៊ុនសាជីវកម្មវិញ ម្ចាស់ហ៊ុននីមួយៗគឺជាសមាជិក)។ ហេតុដូច្នេះ មហាសន្និបាតរបស់សមាជិកដើរតួនាទីជាវេទិកាដែលចាំបាច់បំផុតដើម្បីសម្រេចអំពីឆន្ទៈរបស់នីតិបុគ្គល (មាត្រា ៣៥ នៃច្បាប់ស្តីពីនីតិបុគ្គលសាជីវកម្ម និង មូលនិធិទូទៅ)។ ក៏ប៉ុន្តែ វាពុំមែនមានន័យថា ដើម្បីដំណើរការនីតិបុគ្គលដែលបានបង្កើត គឺចាំបាច់ត្រូវតែមានការចូលរួមសម្រេចចិត្តពីសមាជិកទាំងអស់គ្នាជាប់ជាប្រចាំរាល់ថ្ងៃនោះទេ។ ក្នុងន័យនេះ ចាំបាច់ត្រូវជ្រើសរើសបុគ្គលម្នាក់ ឬ អភិបាលច្រើននាក់ដើម្បីធ្វើការប្រតិបត្តិកិច្ចការរបស់នីតិបុគ្គល (កថាខណ្ឌទី ១ មាត្រា ៦០ នៃច្បាប់ស្តីពីនីតិបុគ្គលសាជីវកម្ម និង មូលនិធិទូទៅ) ។ ហេតុដូច្នេះ អភិបាលត្រូវតំណាងឲ្យនីតិបុគ្គលសាជីកម្ម និងត្រូវចាត់ចែងការងារ (ឧទាហរណ៍ដូចជាក្នុងករណីធ្វើ

ការជួញដូរជាមួយតតិយជន ជាដើម) របស់នីតិបុគ្គលសាជីវកម្មនោះ (មាត្រា ៧៦ នៃច្បាប់ស្តីពីនីតិបុគ្គលសាជីវកម្ម និង មូលនិធិទូទៅ)។ម្យ៉ាងវិញទៀត នីតិបុគ្គលសាជីវកម្មអាចបង្កើតឲ្យមានមហាសន្និបាតក្រុមប្រឹក្សាភិបាល អ្នកត្រួតពិនិត្យដែលមានភារកិច្ចត្រួតពិនិត្យមើលការអនុវត្តកិច្ចការរបស់អភិបាល និង ស្រាវជ្រាវពីស្ថានភាពទ្រព្យសម្បត្តិរបស់នីតិបុគ្គល និង អាចចាត់តាំងឲ្យមានសវនករត្រួតពិនិត្យមើលគណនេយ្យរបស់នីតិបុគ្គលទៀតផង (កថាខណ្ឌទី ២ មាត្រា ៦០ នៃច្បាប់ស្តីពីនីតិបុគ្គលសាជីវកម្ម និង មូលនិធិទូទៅ) ។

ចំពោះនីតិបុគ្គលមូលនិធិ ដោយសារវាជាការប្រមូលផ្តុំនូវទ្រព្យសម្បត្តិ គឺពុំមានសមាជិក និង មហាសន្និបាតសមាជិកដូចនីតិបុគ្គលសាជីវកម្មទេ។ ជំនួសឲ្យសមាជិក និង មហាសន្និបាតសមាជិក ចាំបាច់ត្រូវបង្កើតឲ្យមានសមាជិកក្រុមប្រឹក្សា សន្និបាតសមាជិកក្រុមប្រឹក្សា ក្រុមប្រឹក្សាភិបាល សន្និបាតក្រុមប្រឹក្សាភិបាល និង សវនករ (កថាខណ្ឌទី ១ នៃមាត្រា ១៧០ នៃច្បាប់ស្តីពីនីតិបុគ្គលសាជីវកម្ម និង មូលនិធិទូទៅ)។ ម្យ៉ាងវិញទៀត អាចចាត់តាំងឲ្យមានសវនករត្រួតពិនិត្យមើលគណនេយ្យរបស់នីតិបុគ្គលបានដែរ (កថាខណ្ឌទី ២ នៃមាត្រាដដែល)។ ដោយឡែកចំពោះនីតិបុគ្គលមូលនិធិទូទៅដែលធំវិញ ការបង្កើតឲ្យមានសវនករត្រួតពិនិត្យមើលគណនេយ្យរបស់នីតិបុគ្គលគឺជាកាតព្វកិច្ច (មាត្រា ១៧១ នៃច្បាប់ស្តីពីនីតិបុគ្គលសាជីវកម្មទូទៅ និង មូលនិធិទូទៅ) ។

## ៣ សាជីវកម្ម ឬ មូលនិធិដែលគ្មានសមត្ថភាពទទួលសិទ្ធិ

### ក) អត្ថន័យនៃសាជីវកម្ម ឬ មូលនិធិដែលគ្មានសមត្ថភាពទទួលសិទ្ធិ

ដូចដែលបានលើកឡើងខាងលើ នៅមុនពេលធ្វើវិសោធនកម្មនាឆ្នាំ ២០០៦ ក្រមរដ្ឋប្បវេណីទទួលស្គាល់តែនីតិបុគ្គល ២ ប្រភេទតែប៉ុណ្ណោះគឺនីតិបុគ្គលដែលបម្រើផលប្រយោជន៍សាធារណៈ (គឺសាជីវកម្ម ឬ មូលនិធិដែលបម្រើផលប្រយោជន៍សាធារណៈ ដែលគ្មានគោលបំណងយកចំណេញ) និងមួយទៀតគឺនីតិបុគ្គលទាញយកចំណេញ។ ដោយហេតុនេះបានជាល័ក្ខខ័ណ្ឌទាំងឡាយណាដែលមិនអនុលោមទៅតាមល័ក្ខខ័ណ្ឌនៃក្រមរដ្ឋប្បវេណីចាស់ទេ លើកលែងតែត្រូវបានទទួលស្គាល់ដោយច្បាប់ពិសេស គឺមិនអាចក្លាយទៅជានីបុគ្គលបានទេ។ ថ្វីបើក្នុងស្ថានភាពជាក់ស្តែង វាកើតមានឡើងនូវក្រុមប្រមូលផ្តុំជាសង្គម និងធ្វើសកម្មភាពជាស្ថាប័នក៏ពិតមែន ក៏ប៉ុន្តែពួកគេមិនមានឋានៈជានីតិបុគ្គលទេ។ ការដែលមិនមានឋានៈជានីតបុគ្គលគឺមានន័យថាពុំទទួលបាននូវលក្ខណសម្បត្តិជាប្រធាននៃសិទ្ធិ និង កាតព្វកិច្ចទេ។ លើសពីនេះទៅទៀត សកម្មភាពជាស្ថាប័ននោះមិនបង្កើតស្ថានភាពតាមផ្លូវច្បាប់អ្វីឲ្យលើសពីត្រឹមតែជាសកម្មភាពបុគ្គលនោះទេ។ ជាឧទាហរណ៍ថា មានស្ថាប័នដែលមានទ្រព្យសម្បត្តិជាកម្មសិទ្ធិរបស់ខ្លួនតាមផ្លូវច្បាប់ មានន័យថា សមាជិកដែលបង្កើតស្ថាប័នទាំង

អស់នោះគឺមានកម្មសិទ្ធិរួមទៅលើទ្រព្យសម្បត្តិនោះ។ ម្យ៉ាងវិញទៀត ការទទួលរងនូវកាតព្វកិច្ច គឺមានន័យតាមផ្លូវច្បាប់ថា សមាជិកដែលបង្កើតស្ថាប័នទាំងអស់គ្នានោះ ត្រូវទទួលរងនូវកាតព្វកិច្ច ។

ក៏ប៉ុន្តែ ការដែលសកម្មភាពរបស់ស្ថាប័នមានអានុភាពទៅលើបុគ្គលសមាជិកគ្រប់រូបនោះ គឺជាការប្រាសចាកការពិត ហើយមិនមែនសុទ្ធតែត្រឹមត្រូវនោះទេ។ ជាពិសេសគឺនៅពេលដែលមានការផ្លាស់ប្តូរសមាជិកភាព ជាដើម នឹងនាំឲ្យមានការលំបាក។ ដូច្នេះហើយ ទើបមានការប្រឹងប្រែងពិចារណាការបង្កើតរចនាសម្ព័ន្ធច្បាប់ដែលភ្ជាប់ទៅនឹងស្ថានភាពសង្គមជាក់ស្តែង ហើយនោះគឺទ្រឹស្តីបង្កើតសាជីវកម្ម (ឬមូលនិធិ) ដែលគ្មានសមត្ថភាពទទួលសិទ្ធិ។ មានន័យថា ចំពោះសមាគមដែលមានរចនាសម្ព័ន្ធ របៀបតំណាង និង ដំណើរការគ្រប់គ្រងនៃមហាសន្និបាត ជាដើម ដែលមានលក្ខណៈសារវន្តជានីតិបុគ្គលសាជីវកម្មត្រូវធ្វើប្រព្រឹត្តកម្មដូចជានីតិបុគ្គលសាជីវកម្មដែរ។ ចំពោះករណីបណ្តឹងវិញ ក្នុងករណីដែលមានការកំណត់របស់អ្នកតំណាង គឺត្រូវទទួលស្គាល់សមត្ថភាពជាភាគី (ពោលគឺឋានៈជាទូទៅដែលអាចក្លាយទៅជាភាគីនៃបណ្តឹង) (មាត្រា ២៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី) និង អាចធ្វើបណ្តឹងក្នុងនាមនៃស្ថាប័នបាន ។

ក៏ប៉ុន្តែ ចំពោះការចុះបញ្ជីអចលនវត្ថុវិញ គឺមិនអាចទទួលស្គាល់ឲ្យចុះបញ្ជីក្នុងដោយយកឈ្មោះជាសាជីវកម្មដែលគ្មានសមត្ថភាពទទួលសិទ្ធិទេ គឺមានតែវិធីដែលចុះដោយដាក់ឈ្មោះបុគ្គលរបស់អ្នកតំណាង ឬ ក៏ឈ្មោះរួមនៃសមាជិកដែលបង្កើតស្ថាប័ននោះប៉ុណ្ណោះ ។

តាមរយៈច្បាប់ស្តីពីនីតិបុគ្គលកម្រិតមធ្យមដែលត្រូវបានធ្វើវិសោធនកម្មក្នុងឆ្នាំ ២០០១ ក្រុមដែលពីមុនមិនអាចទទួលបាននូវលក្ខណសម្បត្តិជានីតិបុគ្គលនៅមុនវិសោធនកម្មនេះ ហើយអាចធ្វើតែសកម្មភាពបានក្នុងលក្ខណៈត្រឹមតែជាសាជីវកម្មដែលគ្មានសមត្ថភាពទទួលសិទ្ធិនោះ បានក្លាយទៅជាអាចទទួលបានលក្ខណសម្បត្តិជានីតិបុគ្គល។ លើសពីនេះទៅទៀត ផ្អែកលើវិសោធនកម្ម ឆ្នាំ ២០០៦ ចំពោះនីតិបុគ្គលសាជីវកម្មទូទៅ និង នីតិបុគ្គលមូលនិធិទូទៅ ការបង្កើតនីតិបុគ្គលមួយអាចធ្វើបានដោយងាយស្រួល ដោយសារតែគោលការណ៍គោរពបទដ្ឋាន (តាមរយៈវិសោធនកម្មនេះ ច្បាប់ស្តីពីនីតិបុគ្គលកម្រិតមធ្យមត្រូវបានធ្វើឲ្យនិរាករណ៍)។ ហេតុដូច្នេះ យើងអាចនិយាយបានថា ករណីនៃការអនុវត្តបញ្ញត្តិច្បាប់ពាក់ព័ន្ធនឹងសាជីវកម្ម និង មូលនិធិដែលគ្មានសមត្ថភាពទទួលសិទ្ធិ គឺកាន់តែតិចទៅហើយ (លើកលែងតែករណីដែលធ្វើសកម្មភាពដោយមិនបង្កើតជានីតិបុគ្គល ថ្វីត្បិតតែការពិតគឺអាចបង្កើតបាននីតិបុគ្គល) ។

## ៤ ក្រុមហ៊ុន

### ក) អត្ថន័យ និង ប្រភេទនៃក្រុមហ៊ុន

ដូចបានរៀបរាប់ខាងលើ កាលពីមុន យើងធ្លាប់ហៅសាជីវកម្មដែលត្រូវបានបង្កើតឡើងក្នុងគោលបំណងធ្វើកិច្ចការដែលជាការធ្វើសកម្មភាពពាណិជ្ជកម្ម (ចំពោះអត្ថន័យនៃសកម្មភាពពាណិជ្ជកម្មគឺមានចែងចាប់ពីមាត្រា ៥០១ នៃក្រមពាណិជ្ជកម្ម ក៏ប៉ុន្តែបើនិយាយឲ្យងាយទៅ សកម្មភាពពាណិជ្ជកម្ម គឺជាសកម្មភាពដែលទាញយកចំណេញ) ថាជា ក្រុមហ៊ុន ក៏ប៉ុន្តែ តាមរយៈវិសោធនកម្មច្បាប់ក្រុមហ៊ុនដែលធ្វើឡើងនៅក្នុងឆ្នាំ ២០០៥ ក្រុមហ៊ុនគឺមានន័យសំដៅទៅលើ ក្រុមហ៊ុនភាគហ៊ុន (Stock Company) ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ (General Partnership Company) ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត (Limited Partnership Company) ឬ ក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត (Limited Liability Company) (ចំណុចទី ១ មាត្រា ២ នៃច្បាប់ក្រុមហ៊ុន)។ ដូច្នេះ សកម្មភាពដែលក្រុមហ៊ុនធ្វើក្នុងនាមជាការអនុវត្តគម្រោង និង សកម្មភាពដែលធ្វើដើម្បីសម្រេចគម្រោងនោះ គឺត្រូវបានកំណត់ថាជាសកម្មភាពពាណិជ្ជកម្ម (មាត្រា ៥ នៃច្បាប់ក្រុមហ៊ុន) ។

ក្រុមហ៊ុនក៏មានច្រើនទម្រង់ដែរ ប្រសិនបើធ្វើការបែងចែកឲ្យទូលាយទៅ គឺអាចបែងចែកទៅជា ២ ប្រភេទធំៗគឺ ក្រុមហ៊ុនភាគហ៊ុន និង ក្រុមហ៊ុនសមាជិក (Membership Company)។ ចំពោះក្រុមហ៊ុនសមាជិកវិញ គឺអាចបែងចែកជាបីប្រភេទគឺ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត និង ក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត។ ដោយឡែកការធ្វើអនុប្បទានភាគហ៊ុនវិញ បើមិនមានកំណត់នៅក្នុងលក្ខន្តិកៈបង្កើតថាចាំបាច់ត្រូវតែមានការយល់ព្រមពីក្រុមហ៊ុនទេ គឺយើងអាចហៅក្រុមហ៊ុននោះថា ក្រុមហ៊ុនភាគហ៊ុនសាធារណៈ (ចំណុចទី ៥ មាត្រា ២ នៃច្បាប់ក្រុមហ៊ុន) ហើយប្រសិនបើដើមទុនប្រកាសនៅលើតារាងតុល្យការនៃឥណពន្ធ និងឥណទានមានលើសពី ៥០០ លានយ៉េន ឬ ប្រសិនបើបំណុលនៅលើតារាងតុល្យការនៃឥណពន្ធ និង ឥណទានមានលើសពី ២ ម៉ឺនលានយេន គេហៅក្រុមហ៊ុននោះថាជាក្រុមហ៊ុនធំ (ចំណុចទី ៦ នៃមាត្រាដដែល) ។

ក្រុមហ៊ុនភាគហ៊ុន គឺសំដៅទៅលើក្រុមហ៊ុនដែលត្រូវបានបង្កើតដោយសមាជិកក្រុមហ៊ុនដែលគេហៅថា ភាគទុនិក (ដូចដែលបានរៀបរាប់ពីខាងដើម សមាជិកក្រុមហ៊ុនគឺមានន័យថាជាសមាជិកដែលបង្កើតក្រុមហ៊ុនដែលជាសាជីវកម្ម)។ ភាគទុនិកនីមួយៗទទួលកាតព្វកិច្ចត្រឹមទំហំនៃភាគហ៊ុនដែលខ្លួនបានរួមវិភាគទានទៅក្រុមហ៊ុនតែប៉ុណ្ណោះ ដោយមិនទទួលខុសត្រូវចំពោះកាតព្វកិច្ចអ្វីផ្សេងទៀតចំពោះម្ចាស់បំណុលនៃក្រុមហ៊ុនលើសពីនោះទៀតឡើយ (មាត្រា ១០៤ នៃច្បាប់ក្រុមហ៊ុន។ ចំពោះអត្ថន័យនៃឃ្លាថាមិនទទួលខុសត្រូវចំពោះកាតព្វកិច្ចផ្សេងក្រៅពីភាគហ៊ុននៃក្រុមហ៊ុន មានន័យថា ការទទួលខុសត្រូវមានកម្រិត)។ ដូចដែលនឹងមានរៀបរាប់នាពេលក្រោយ អភិបាលដែលត្រូវបានជ្រើសតាំងដោយមហាសន្និបាតភាគទុនិកជាអ្នកប្រតិបត្តិកិច្ចការរបស់ក្រុមហ៊ុន ហើយប្រធានក្រុមប្រឹក្សាភិបាលដែលត្រូវបានជ្រើសតាំងដោយកិច្ចប្រជុំរបស់អភិបាលជាអ្នកតំណាងក្រុមហ៊ុន ។

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ គឺសំដៅលើក្រុមហ៊ុនដែលត្រូវបានបង្កើតឡើងតែពីសមាជិកដែល

មានករណីយកិច្ចទទួលខុសត្រូវដោយគ្មានកម្រិតចំពោះម្ចាស់បំណុលនៃក្រុមហ៊ុន។ នៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ សមាជិកនីមួយៗនៃក្រុមហ៊ុនធ្វើការគ្រប់គ្រង និង តំណាងក្រុមហ៊ុន ក៏ប៉ុន្តែអាចធ្វើការកំណត់ផ្សេង ជាពិសេសនៅក្នុងលក្ខន្តិកៈស្តីពីការបង្កើតក្រុមហ៊ុនបាន (កថាខណ្ឌទី ១ មាត្រា ៥៩០ នៃច្បាប់ក្រុមហ៊ុន)។

ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត គឺជាក្រុមហ៊ុនដែលត្រូវបានបង្កើតឡើងដោយសមាជិកដែលទទួលខុសត្រូវមានកម្រិត និង សមាជិកដែលទទួលខុសត្រូវគ្មានកម្រិត។ សមាជិកដែលទទួលខុសត្រូវគ្មានកម្រិត គឺត្រូវទទួលខុសត្រូវដោយគ្មានកម្រិតចំពោះម្ចាស់បំណុលនៃក្រុមហ៊ុន ដូចគ្នាទៅនឹងសមាជិកនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែរ។ ផ្ទុយទៅវិញ ចំពោះសមាជិកដែលទទួលខុសត្រូវមានកម្រិត គឺទទួលភាតព្វកិច្ចត្រឹមកម្រិតភាគទុនដែលមានកំណត់នៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុនតែប៉ុណ្ណោះ ដោយមិនទទួលខុសត្រូវចំពោះភាតព្វកិច្ចអ្វីផ្សេងទៀតចំពោះម្ចាស់បំណុលនៃក្រុមហ៊ុនឡើយ។ ដោយឡែកចំពោះការគ្រប់គ្រងកិច្ចការរបស់ក្រុមហ៊ុន និង ការតំណាងឲ្យក្រុមហ៊ុនវិញ គឺដូចគ្នាជាមួយនឹងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែរ ។

ក្រុមហ៊ុនទទួលខុសត្រូវមានកម្រិតជាទម្រង់នៃក្រុមហ៊ុនដែលត្រូវបានទទួលស្គាល់ថ្មីដោយវិសោធនកម្មច្បាប់ក្រុមហ៊ុនដែលធ្វើឡើងនៅឆ្នាំ ២០០៥។ ប្រសិនបើពិនិត្យមើលពីចំណុចដែលថាក្រុមហ៊ុនត្រូវបានបង្កើតឡើងដោយសមាជិកដែលទទួលខុសត្រូវមានកម្រិតដែលទទួលខុសត្រូវលើភាតព្វកិច្ចត្រឹមកម្រិតនៃភាគទុនទាំងអស់ប៉ុណ្ណោះ គឺវាដូចគ្នាទៅនឹងក្រុមហ៊ុនភាគហ៊ុនដែរ។ ដោយឡែកចំពោះការគ្រប់គ្រងកិច្ចការរបស់ក្រុមហ៊ុន និង ការតំណាងឲ្យក្រុមហ៊ុនវិញ គឺដូចគ្នាទៅនឹងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ និង ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតដែរ ។

នៅមុនការអនុម័តច្បាប់ក្រុមហ៊ុន ទម្រង់នៃក្រុមហ៊ុនមានកម្រិត (Limited Company) ត្រូវបានទទួលស្គាល់ដោយច្បាប់ចាស់ស្តីពីក្រុមហ៊ុនមានកម្រិត ក៏ប៉ុន្តែ នៅក្នុងច្បាប់ស្តីពីក្រុមហ៊ុនថ្មី ក្រុមហ៊ុនមានកម្រិត មិនត្រូវបានទទួលស្គាល់ទៀតទេ ហើយក្រោយពីការចូលជាធរមាននៃច្បាប់ថ្មី ក្រុមហ៊ុនដែលពីមុនជាក្រុមហ៊ុនមានកម្រិតត្រូវបន្តអត្ថិភាពរបស់ខ្លួនក្នុងឋានៈជាក្រុមហ៊ុនភាគហ៊ុន ។

### ខ) ការបង្កើតក្រុមហ៊ុន

ការបង្កើតក្រុមហ៊ុន ជាមូលដ្ឋានគឺដូចគ្នាទៅនឹងការបង្កើតសាជីវកម្មតាមក្រមរដ្ឋប្បវេណី (ដូចដែលបានលើកឡើងខាងលើថា គេយកគោលការណ៍គោរពបទដ្ឋាន)។ ក៏ប៉ុន្តែ ចំពោះការបង្កើតក្រុមហ៊ុនលក្ខណៈពិសេសធំបំផុតគឺការបង់ភាគទុន (ជាធម្មតាគឺជាប្រាក់) របស់បុគ្គលដែលនឹងក្លាយទៅជាសមាជិក ។ ត្រង់ចំណុចនេះ សូមពន្យល់ដោយលើកយកក្រុមហ៊ុនភាគហ៊ុនដែលត្រូវបានគេប្រើច្រើនជាងគេមក

និយាយ។ ចំពោះក្រុមហ៊ុនភាគហ៊ុន ស្ថាបនិកក្រុមហ៊ុនដែលគិតចង់បង្កើតក្រុមហ៊ុនត្រូវបង្កើតលក្ខន្តិកៈក្រុមហ៊ុន (មាត្រា ២៦ នៃច្បាប់ក្រុមហ៊ុន)។ បុគ្គលដែលនឹងក្លាយទៅជាមាជិកដោយដាក់ភាគទុន ដែលមានន័យថាដោយទទួលយកចំណែកភាគហ៊ុន ត្រូវបានហៅថា ភាគទុនិក។ អាចមានករណីដែលស្ថាបនិកក្រុមហ៊ុនធ្វើការទទួលយកភាគហ៊ុនទាំងអស់តែម្នាក់ឯង និង ករណីដែលស្ថាបនិកក្រុមហ៊ុនទទួលយកភាគហ៊ុនតែមួយផ្នែក ហើយអំពាវនាវរកអ្នកទទួលផ្នែកដែលនៅសល់ (កថាខណ្ឌទី ១ មាត្រា ២៥ នៃច្បាប់ក្រុមហ៊ុន)។ ទោះបីជាក្នុងករណីណាមួយ នៃករណី ទាំងពីរនេះក៏ដោយ ក៏បុគ្គលដែលទទួលយកចំណែកភាគហ៊ុនត្រូវបង់តម្លៃភាគទុនចូលទៅក្នុងក្រុមហ៊ុនជាដាច់ខាតដែរ ។

ដោយការអនុវត្តតាមនីតិវិធីបែបនេះ ក្រុមហ៊ុនត្រូវកើតឡើងដោយសារការចុះបញ្ជីចំពោះក្រុមហ៊ុនដែលត្រូវបានរៀបចំបង្កើតនោះ (មាត្រា ៤៩ នៃច្បាប់ក្រុមហ៊ុន) ។

## គ) រចនាសម្ព័ន្ធក្រុមហ៊ុន

នៅក្នុងក្រុមហ៊ុនភាគហ៊ុន សមាជិកត្រូវបានហៅថា ភាគទុនិក រីឯមហាសន្និបាតសមាជិកវិញត្រូវបានហៅថា មហាសន្និបាតភាគទុនិក។ ចំពោះចំណុចជាមូលដ្ឋាននៃក្រុមហ៊ុនត្រូវសម្រេចដោយមហាសន្និបាតភាគទុនិក (មាត្រា ២៩៥ នៃច្បាប់ក្រុមហ៊ុន)។ សេចក្តីសម្រេចរបស់មហាសន្និបាតភាគទុនិក ជាគោលការណ៍ ត្រូវធ្វើឡើងដោយវត្តមានភាគច្រើននៃភាគទុនិកដែលមានសិទ្ធិបោះឆ្នោត និង ដោយអនុលោមទៅតាមសំឡេងភាគច្រើននៃសំឡេងបោះនោះ (កថាខណ្ឌទី ១ មាត្រា ៣០៩ នៃច្បាប់ក្រុមហ៊ុន) ដោយជាគោលការណ៍ ភាគទុនមួយស្មើនឹងសិទ្ធិសម្រេចមួយ (មាត្រា ៣០៨ នៃច្បាប់ក្រុមហ៊ុន)។ មន្ត្រីប្រតិបត្តិ (មានដូចជា អភិបាល ទីប្រឹក្សាគណនេយ្យ និង សវនករក្រុមហ៊ុន) និង សវនករគណនេយ្យ នឹងត្រូវបានជ្រើសតាំងដោយមហាសន្និបាតភាគទុនិក (កថាខណ្ឌទី ១ មាត្រា ៣២៩ នៃច្បាប់ក្រុមហ៊ុន) ។

ក៏ប៉ុន្តែ ចាំបាច់ត្រូវតែបង្កើតឲ្យមានអភិបាល ១ រូប ឬ លើសពី ២ រូប រីឯទីប្រឹក្សាគណនេយ្យ ឬ ប្រធានសវនករ អាចបង្កើតឡើងបានទៅតាមភាពចាំបាច់ (មាត្រា ៣២៦ នៃច្បាប់ក្រុមហ៊ុន)។ ក៏ប៉ុន្តែក៏មានករណីដែលចាំបាច់ត្រូវតែបង្កើតឲ្យមានទីប្រឹក្សាគណនេយ្យ ឬ សនវករក្រុមហ៊ុនដែរ គឺអាស្រ័យទៅលើទម្រង់នៃក្រុមហ៊ុន (មាត្រា ៣២៨ នៃច្បាប់ស្តីពីក្រុមហ៊ុន)។ ម្យ៉ាងវិញទៀតវា ក៏មានករណីដែលការបង្កើតឲ្យមានក្រុមប្រឹក្សាភិបាល ក្រុមប្រឹក្សាសវនករក្រុមហ៊ុន ឬ សវនករគណនេយ្យ ជាករណីយកិច្ច និង ករណីដែលការបង្កើតទាំងនោះមិនមែនជាករណីយកិច្ចដែរ។ ម្យ៉ាងវិញទៀត ក៏អាចមានករណីដែលគណៈកម្មការសវនកម្មត្រូវបានបង្កើតឡើងជំនួសឲ្យសវនករក្រុមហ៊ុន និង ក្រុមប្រឹក្សាសនវករក្រុមហ៊ុនដែរ។

អភិបាលក្រុមហ៊ុន ក៏ដូចជាអភិបាលនៃនីតិបុគ្គលសាជីវកម្មដែរ គឺចាំបាច់ត្រូវមានលក្ខណសម្បត្តិមួយជាក់លាក់ (កថាខណ្ឌទី ១ មាត្រា ៣៣១ នៃច្បាប់ក្រុមហ៊ុន) ។

ចំពោះក្រុមហ៊ុនភាគហ៊ុនសាធារណៈដែលមិនមានកម្រិតអំពីការផ្ទេរអនុប្បទានភាគហ៊ុនដោយលក្ខន្តិកៈទេ ចាំបាច់ត្រូវបង្កើតឲ្យមានក្រុមប្រឹក្សាភិបាល។ អភិបាលនៅក្នុងករណីនោះ ជាគោលការណ៍ ត្រូវមានចាប់ពី ៣ រូប ឡើងទៅជាចាំបាច់ (កថាខណ្ឌទី ៤ នៃមាត្រាដដែល)។ ម្យ៉ាងវិញទៀត ការសម្រេចចិត្តចំពោះការប្រតិបត្តិកិច្ចការវិញត្រូវធ្វើឡើងដោយអនុលោមទៅតាមក្រុមប្រឹក្សាភិបាល រីឯការតំណាងឲ្យក្រុមហ៊ុននៅខាងក្រៅ និង ការប្រតិបត្តិកិច្ចការទាំងនោះ គឺធ្វើឡើងដោយអភិបាលតំណាង។ អភិបាលតំណាងត្រូវបានជ្រើសតាំងពីក្នុងចំណោមអភិបាល ដោយក្រុមប្រឹក្សាភិបាល (កថាខណ្ឌទី ២ មាត្រា ៣៦២ នៃច្បាប់ក្រុមហ៊ុន) ។

ដោយសារតែទំនាក់ទំនងរវាងបុគ្គលិកក្រុមហ៊ុន ជាមួយក្រុមហ៊ុនគឺជាទំនាក់ទំនងអាណត្តិ បុគ្គលិកទទួលករណីយកិច្ចប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត (មាត្រា ៦៥៥ នៃក្រមរដ្ឋប្បវេណី)។ ម្យ៉ាងវិញទៀត អភិបាលមានករណីយកិច្ចស្មោះត្រង់ចំពោះក្រុមហ៊ុន (មាត្រា ៣៥៥ នៃច្បាប់ក្រុមហ៊ុន)។ បុគ្គលិកត្រូវទទួលខុសត្រូវចំពោះសំណងការខូចខាតដែលពាក់ព័ន្ធជាមួយការមិនអើពើចំពោះករណីយកិច្ចការផ្តល់ផលប្រយោជន៍ (ទៅអ្នកដទៃ) និង ការបែងចែកភាគលើសដោយខុសច្បាប់ (មាត្រា ៤២៣ កថាខណ្ឌទី ៤ មាត្រា ១២០ និង មាត្រា ៤៦២ ជាដើម នៃច្បាប់ ក្រុមហ៊ុន) ។

ទីប្រឹក្សាគណនេយ្យ ត្រូវបានជ្រើសតាំងចេញពី Certified Public Accountant និង Certified Cax Accountant (មាត្រា ៣៣៣ នៃច្បាប់ក្រុមហ៊ុន) ក៏ប៉ុន្តែ ត្រូវធ្វើបញ្ជីទូទាត់ ជាដើម រួមគ្នាជាមួយអភិបាល (មាត្រា ៣៧៤ នៃច្បាប់ក្រុមហ៊ុន) ។

សវនករមានភារកិច្ចធ្វើរបាយការណ៍ពីលទ្ធផលនៃសនវកម្មគណនេយ្យ និង សនវកម្មលើការប្រតិបត្តិ កិច្ចការរបស់អភិបាល ជាដើម (មាត្រា ៤៣៦ និង មាត្រា ៣៨១ នៃច្បាប់ក្រុមហ៊ុន) ក៏ប៉ុន្តែ សវនករគណនេយ្យធ្វើសវនកម្មទៅលើឯកសារជម្រះបញ្ជីផ្សេងៗជាដើមរបស់ក្រុមហ៊ុន ហើយធ្វើរបាយការណ៍អំពីសវនកម្មគណនេយ្យនោះ (កថាខណ្ឌទី ១ មាត្រា ៣៩៦ នៃច្បាប់ស្តីពីក្រុមហ៊ុន)។ ចំពោះក្រុមហ៊ុនធំៗវិញ ចាំបាច់ត្រូវតែតែងតាំងឲ្យមានសវនករ និង សវនករគណនេយ្យ (កថាខណ្ឌទី ១ នៃមាត្រា ៣២៨ នៃច្បាប់ក្រុមហ៊ុន)។ ក្នុងករណីនេះ សវនករចាំបាច់ត្រូវតែមានចាប់ពី ៣ រូបឡើងទៅ (កថាខណ្ឌទី ៣ មាត្រា ៣៣៥)។ ម្យ៉ាងវិញទៀត ចំពោះក្រុមហ៊ុនធំៗដែលមិនមែនជាក្រុមហ៊ុនភាគហ៊ុនសាធារណៈវិញ ចាំបាច់ត្រូវតែបង្កើតឲ្យមានសវនករគណនេយ្យដោយខានមិនបាន (កថាខណ្ឌទី ២ នៃមាត្រា ៣២៨) ។

✐ កាតព្វកិច្ចនៃនីតិបុគ្គលសាជីវកម្មដែលគ្មានសមត្ថភាពទទួលសិទ្ធិ--ការពិចារណាតាមរយៈករណីសិក្សា

ប្រសិនបើស្ថាប័ន X ត្រូវបានវិនិច្ឆ័យថាជាសាជីវកម្មដែលគ្មានសមត្ថភាពទទួលសិទ្ធិជាសារវន្ត គឺ X ត្រូវទទួលរងកាតព្វកិច្ចចំពោះធនាគារ Y ចំពោះសកម្មភាពខ្ចីប្រាក់តាមរយៈ A ដើម្បី X។ ដូច្នេះ នៅក្នុងករណីដែលធនាគារ Y បានផ្ដល់ឥណទានទៅដល់ស្ថាប័ន X យ៉ាងដូច្នេះ មានន័យថា អ្នកតំណាង A បានធ្វើកិច្ចសន្យាធានាដែលមានខ្លឹមសារទទួលខុសត្រូវចំពោះកាតព្វកិច្ចធានាក្នុងនាមជាអ្នកធានា (ក្នុងករណីដែល X មិនអាចសងបំណុលបានទេ គឺ A ត្រូវសងជំនួស) ។

Khmer Law's Association

## ✧អក្សរសាស្ត្រ និង ច្បាប់

មានបញ្ហាផ្លូវច្បាប់ដែលមានលក្ខណៈជំនាញមិនតិចទេដែលត្រូវបានលើកឡើងគួរឲ្យកត់សម្គាល់នៅក្នុងខ្សែភាពយន្ត និង នៅក្នុងប្រលោមលោក ។ ហេតុដូច្នេះ យើងក៏អាចសិក្សាអំពីបញ្ហាច្បាប់តាមរយៈការប្រើប្រាស់ខ្សែភាពយន្ត ឬ ប្រលោមលោកបែបនោះបានដែរ ។ ជាឧទាហរណ៍ ដូចជារឿង ជេន អ៊ែ (Jane Eyre) របស់អ្នកនិពន្ធ ហ្សាឡុត ប្រុងតេ (ឆ្នាំ ១៨៤៧) ដែលបានសរសេរអំពីការតស៊ូអត្តក្មេងកំព្រា ជែន អ៊ែ ដែលតស៊ូមិនចុះញ៉មជាមួយភាពមិនយល់ដឹងនៃសង្គម ដែលនៅក្នុងសាច់រឿងមានឈុតនៅពេលដែលពិធីមង្គលការនៅព្រះវិហារ (Church) របស់ ជែន អ៊ែ និង អែដវូឌ រ៉ូចេស្ទ័រ កំពុងតែប្រព្រឹត្តទៅ ស្រាប់តែកើតមានការជំទាស់ទៅនឹងអាពាហ៍ពិពាហ៍នោះ ដោយការលេចមុខរបស់ភរិយារីកលចរិតរបស់ រ៉ូចេស្ទ័រ។ សម័យកាលនោះជាសម័យកាលដែលការរៀបចំពិធីអាពាហ៍ពិពាហ៍ស្ថិតនៅក្រោមសិទ្ធិអំណាចរបស់ព្រះវិហារ ជាសម័យកាលដែលការគ្រប់គ្រងឋានៈបុគ្គលត្រូវបានធ្វើឡើងដោយព្រះវិហារ និង ដោយសារតែជាសម័យកាលដែលការផ្លាស់ទីរបស់មនុស្សមានតិចនៅឡើយ ទើបអាចមានលទ្ធភាពនៃពហុពន្ធភាព។ ដូច្នេះ ដើម្បីបង្ការស្ថានភាពពហុពន្ធភាពបែបនេះ ទើបគេទទួលស្គាល់ឲ្យមានការប្រកាសផ្សាយជាសាធារណៈនូវអាពាហ៍ពិពាហ៍ជាមុន និង ទទួលស្គាល់ឲ្យមានការតវ៉ាពីអ្នកដទៃ ចំពោះអាពាហ៍ពិពាហ៍នោះ។ របបឋានៈបុគ្គលដែលត្រូវបានរក្សាទុកនាពេលបច្ចុប្បន្ននេះក៏ដូចគ្នាផងដែរ គឺរបបប្រកាសផ្សាយជាសាធារណៈបែបនោះនៅមាននៅឡើយ ដោយត្រូវធ្វើការប្រកាសផ្សាយជាសាធារណៈក្នុងអំឡុងពេលជាកំណត់មួយនៅសាលាពជធានី។ អ្នកនិពន្ធធ្លាប់បានមើលការប្រកាសអាពាហ៍ពិពាហ៍ជាសាធារណៈម្តងនៅទីក្រុងរ៉ូម ក៏ប៉ុន្តែហាក់ដូចជាពុំឃើញមានមនុស្សឈប់មើលច្រើននោះទេ គឺហាក់ដូចជាគ្រាន់តែជាការផ្សាយបង្គ្រប់កិច្ច។

មិនថាតែនៅក្នុងប្រលោមលោកបុរាណទេ ក៏ប៉ុន្តែ ប្រលោមលោកសម័យទំនើបបច្ចុប្បន្នក៏មានផ្តល់ចំណេះដឹងផ្នែកច្បាប់មិនតិចដែរ ។

# ជំពូកទី ១៦

# ការសម្រេចសិទ្ធិ

## ១ ការសម្រេចសិទ្ធិ

(១) របៀបសម្រេចសិទ្ធិ

(២) ការសម្រេចសិទ្ធិតាមរយៈបណ្ដឹង

## ២ ការដោះស្រាយវិវាទ និង ប្រព័ន្ធតុលាការ

✎ ការសម្រេចសិទ្ធិតាមរយៈបណ្ដឹង --ការពិចារណាតាមរយៈករណីសិក្សា

Khmer Law's Association

ករណីសិក្សា៖ A បានទិញរូបគំនូរប្រើប្រេង ១ ផ្ទាំង របស់វិចិត្រករដ៏ល្បីម្នាក់ពី B ហើយបានបង់ថ្លៃលក់ទិញ ១០ លានយ៉េន រួចហើយ។ ក៏ប៉ុន្តែ បើទោះបីថ្ងៃសន្យាប្រគល់បានមកដល់ហើយក៏ដោយ ក៏ B នៅតែមិនទាន់បានប្រគល់រូបគំនូរនោះទៅឲ្យ A ដែរ។ ដើម្បីឲ្យ A យកផ្ទាំងគំនូរនោះបាន តើគាត់អាចធ្វើដូចម្តេចបាន?

## ១ ការសម្រេចសិទ្ធិ

### (១) របៀបសម្រេចសិទ្ធិ

វិធានសម្រាប់គ្រប់គ្រងជីវភាពរស់នៅក្នុងសង្គមឲ្យមានរបៀបរៀបរយ ក្រៅពីវិធានគតិយុត្ត ក៏នៅមានវិធានដទៃផ្សេងទៀតដែរដូចជា វិធានសីលធម៌ វិធានសាសនា និង វិធានសេចក្តីថ្លៃថ្នូរ ជាដើម ក៏ប៉ុន្តែ វិធានដែលត្រូវបានអនុវត្ត ដោយផ្អែកលើវិធានការចាប់បង្ខំរបស់រដ្ឋគឺលក្ខណៈពិសេសសំខាន់បំផុតរបស់វិធានគតិយុត្ត ដូចដែលបានរៀបរាប់ពីមុនរួចមកហើយ។ មានន័យថា ក្នុងករណីដែលបុគ្គលម្នាក់មានសិទ្ធិ ហើយការសម្រេចសិទ្ធិនោះត្រូវបានរារាំង ម្ចាស់សិទ្ធិអាចខ្ចីអំណាចរបស់រដ្ឋដើម្បីសម្រេចសិទ្ធិនោះបាន។

#### ក) ការអនុវត្តដោយស្ម័គ្រចិត្ត

ក្នុងករណីដែលបុគ្គលម្នាក់មានសិទ្ធិអ្វីមួយ ហើយសិទ្ធិនោះត្រូវបានសម្រេចដោយពុំចាំបាច់ពឹងពាក់អំណាចរបស់រដ្ឋ នោះគឺពុំមានបញ្ហាអ្វីទេ។ ឧទាហរណ៍ X បានទិញដីមួយកន្លែងពី Y ក៏ប៉ុន្តែក្នុងករណី ដីនោះត្រូវបានកាន់កាប់ដោយខុសច្បាប់ដោយ Z គឺ Z ត្រូវប្រគល់ដីនោះទៅឲ្យ X វិញទៅតាមការទាមទារឲ្យប្រគល់របស់ X ដែលបានធ្វើឡើងចំពោះ Z។ ម្យ៉ាងវិញទៀត ឧទាហរណ៍ថា Q និង P បានចុះកិច្ចសន្យាលក់ទិញជាមួយគ្នា ដែលមានខ្លឹមសារថា P លក់វត្ថុចម្លាក់ចាស់ៗទៅឲ្យ Q ក្នុងតម្លៃ ២លានយេន ហើយ P បានប្រគល់វត្ថុដែលជាកម្មវត្ថុនៃការលក់ទិញនោះទៅឲ្យ Q ហើយ Q ក៏បានបង់ថ្លៃលក់ទិញចំនួន ២ លានយ៉េន ទៅឲ្យ P ហើយដែរ។ ក្នុងករណីទាំងឡាយបែបនេះ សិទ្ធិរបស់ម្ចាស់សិទ្ធិ (ករណីឧទាហរណ៍ទី ១ គឺសិទ្ធិកម្មសិទ្ធិរបស់ X រីឯករណីឧទាហរណ៍ទី ២ គឺសិទ្ធិលើបំណុលលើថ្លៃលក់ទិញរបស់ P និង សិទ្ធិទាមទារឲ្យប្រគល់របស់ Q ) ត្រូវបានសម្រេចដូច្នេះ ពុំចាំបាច់ត្រូវពឹងពាក់អំណាចរបស់រដ្ឋទេ ។

### (២) ការសម្រេចសិទ្ធិតាមរយៈបណ្តឹង

#### ក) ការហាមឃាត់ការចាត់វិធានការសង្គ្រោះដោយខ្លួនឯង

ក៏ប៉ុន្តែ ការសម្រេចសិទ្ធិ មិនមែនសុទ្ធតែអាចធ្វើទៅបានដោយរលូនទាំងអស់នោះទេ។ ជាឧទាហរណ៍ នៅឧទាហរណ៍ទី ១ អាចមានករណីដែល Z មិនព្រមធ្វើតាមការទាមទារឲ្យប្រគល់របស់ X។ ម្យ៉ាងវិញទៀត នៅក្នុងឧទាហរណ៍ទី ២ អាចមានករណីដែល P មិនប្រគល់វត្ថុដែលជាកម្មវត្ថុនៃការលក់ទិញ ឬ ករណីដែល Q មិនព្រមបង់ថ្លៃលក់ទិញ។ ប្រសិនបើមានករណីបែបដូច្នេះ បុគ្គលដែលមានសិទ្ធិទាំងនោះមិនត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់កម្លាំងបាយផ្ទាល់ខ្លួន (ការសង្គ្រោះដោយខ្លួនឯង) ដើម្បីសម្រេចសិទ្ធិឡើយ។ ពោលគឺក្នុងករណីឧទាហរណ៍ទី ១ X មិនអាចទៅយកដីពី Z ទាំងកំពោលបាននោះទេ។ ដោយឡែកករណីឧទាហរណ៍ទី ២ វិញ Q មិនអាចប្រើកម្លាំងទៅបង្ខំយកវត្ថុដែលជាកម្មវត្ថុនៃការលក់ទិញពី P បានទេ រីឯ P វិញ ក៏មិនអាចទៅប្រមូលយកថ្លៃលក់ទិញពី Q ទាំងកំពោលបានដែរ ។

មូលហេតុដែលការចាត់វិធានការសង្គ្រោះដោយខ្លួនឯងមិនត្រូវបានទទួលស្គាល់ គឺដោយសារតែប្រសិនបើទទួលស្គាល់នូវការចាត់វិធានការសង្គ្រោះដោយខ្លួនឯងដោយសេរីទៅ គឺមិនអាចរក្សាសណ្តាប់ធ្នាប់ និង របៀបរៀបរយក្នុងសង្គមបានទេ។ មានន័យថា ប្រសិនបើទទួលស្គាល់ការប្រើប្រាស់កម្លាំងរបស់បុគ្គលឯកជនដោយសេរីទៅ គឺមិនអាចកម្រិតការប្រើប្រាស់កម្លាំងនោះក្នុងទំហំដែលសមរម្យបានទេ ហើយវាប្រាកដជានឹងបង្កឲ្យមាននូវការខូចខាតចំពោះអ្នកដទៃជាក់ជាមិនខាន។ ជាបឋមការដែលបុគ្គលម្នាក់គិតថាខ្លួនមានសិទ្ធិនោះ មិនសុទ្ធតែត្រូវទាំងអស់នោះទេ។ ម្យ៉ាងវិញទៀត បើទោះជាមានសិទ្ធិក៏ដោយ វាក៏អាចមានករណីដែលភាគីម្ខាងទៀតមានមូលហេតុនឹងបដិសេធមិនទទួលយកការសម្រេចសិទ្ធិនោះដែរ។ ឧទាហរណ៍ដូចជា ក្នុងករណីឧទាហរណ៍ទី ១ អាចជាករណីដែលការទាមទារឲ្យប្រគល់របស់ X ជាការប្រើប្រាស់សិទ្ធិដោយបំពាន រីឯក្នុងករណីឧទាហរណ៍ទី ២ វិញ គឺអាចជាករណីដែលប្រសិនបើ P មិនប្រគល់វត្ថុដែលជាកម្មវត្ថុនៃការលក់ទិញទៅ Q ទេ ប្រាក់ថ្លៃលក់ទិញក៏មិនត្រូវបានប្រគល់ឲ្យដែរ ជាដើម ។

ការដែលការចាត់វិធានការសង្គ្រោះដោយខ្លួនឯងមិនត្រូវបានទទួលស្គាល់ មានន័យថា ប្រសិនបើករណីដែលម្ចាស់សិទ្ធិធ្វើការសម្រេចសិទ្ធិដោយវិធានការសង្គ្រោះដោយខ្លួនឯង ការសម្រេចសិទ្ធិដែលមិនសមរម្យនោះ គឺជាអំពើអនីត្យានុកូល ហើយត្រូវទទួលកាតព្វកិច្ចសងការខូចខាតដែលភាគីម្ខាងទៀតបានទទួលរងដោយសារអំពើអនីត្យានុកូលនោះ។

ដូច្នេះ ជាគោលការណ៍ ការចាត់វិធានការសង្គ្រោះដោយខ្លួនឯងមិនត្រូវបានទទួលស្គាល់ ក៏ប៉ុន្តែយើងអាចគិតបានថា ការចាត់វិធានការសង្គ្រោះដោយខ្លួនឯងអាចត្រូវបានទទួលស្គាល់ជាករណីលើកលែងដូចជាក្នុងករណីដែលមានស្ថានភាពបន្ទាន់បង្ខំដែលមិនអាចរំពឹងបានពីការសម្រេចសិទ្ធិ ប្រសិនបើរង់ចាំការសម្រេចសិទ្ធិដោយពឹងពាក់រដ្ឋ ឬ តុលាការ។ ឧទាហរណ៍ដូចជាករណីកញ្ឆក់ដណ្តើមយកមកវិញនូវកង់ដែលកំពុងត្រូវបានចោរដណ្តើមយកទៅ ជាដើម។ ក្នុងករណីបែបនេះ ការចាត់វិធានការ

សង្គ្រោះដោយខ្លួនឯងត្រូវបានទទួលស្គាល់ ដោយសារតែការសម្រេចសិទ្ធិនៅពេលក្រោយ នឹងក្លាយទៅជាស្ថានភាពលំបាកយ៉ាងខ្លាំង។ ក៏ប៉ុន្តែ វិធានការនៃការអនុវត្តសិទ្ធិមិនត្រូវឲ្យលើសពីព្រំដែននៃភាពចាំបាច់នោះទេ។

## ខ) ការសម្រេចសិទ្ធិតាមរយៈបណ្តឹង

ក្នុងករណីដែលការសម្រេចសិទ្ធិត្រូវបានរារាំង ម្ចាស់សិទ្ធិអាចទាមទារទៅរដ្ឋឲ្យជួយសម្រេចសិទ្ធិរបស់ខ្លួនបាន។ ពោលគឺអាចដាក់ពាក្យបណ្តឹងទៅតុលាការ (ដោយសារតែការសម្រេចសិទ្ធិត្រូវបានការពារដោយតុលាការ ការចាត់វិធានការសង្គ្រោះដោយខ្លួនឯងត្រូវបានហាមឃាត់)។ បណ្តឹងគឺជានីតិវិធី (ជូនកាលពាក្យថា "រឿងក្តី" ត្រូវបានគេប្រើ) ដែលតាមរយៈនោះ បុគ្គលដែលគិតថាចង់សម្រេចសិទ្ធិរបស់ខ្លួន (ហៅថា ដើមចោទ) ធ្វើការទាមទារទៅតុលាការឲ្យសម្រេចសិទ្ធិរបស់ខ្លួន ដោយយកបុគ្គលដែលរារាំងការសម្រេចសិទ្ធិ ធ្វើជាភាគីម្ខាងទៀត (ហៅថា ចុងចម្លើយ)។ បុគ្គលដែលត្រូវបានគេដាក់ពាក្យបណ្តឹង (ចុងចម្លើយ) មិនអាចបដិសេធការដោះស្រាយវិវាទតាមរយៈបណ្តឹងបានទេ។ ប្រសិនបើអវត្តមានក្នុងនីតិវិធីនៃបណ្តឹង ជាលទ្ធផល ការទាមទាររបស់ដើមចោទនឹងត្រូវបានទទួលស្គាល់ ។

នៅពេលដែលបណ្តឹងត្រូវបានធ្វើឡើង នីតិវិធីត្រូវបានអនុវត្តទៅតាមការកំណត់របស់ច្បាប់។ ចំពោះបណ្តឹងក្នុងរឿងរដ្ឋប្បវេណីជាទូទៅ ត្រូវផ្អែកលើនីតិវិធីដែលកំណត់ដោយក្រមនីតិវិធីរដ្ឋប្បវេណី។ តុលាការត្រូវធ្វើកំណត់ឲ្យច្បាស់នូវទំនាក់ទំនងរវាងអង្គហេតុ ដោយផ្អែកទៅលើការអះអាងរបស់ភាគី និង ភស្តុតាងដែលត្រូវបញ្ជាក់ ហើយត្រូវអនុវត្តវិធានគតិយុត្ត និង វិធានទូទៅផ្សេងៗ ចំពោះអង្គហេតុដែលតុលាការទទួលស្គាល់ និង ត្រូវចេញសាលក្រម។ ជាឧទាហរណ៍ នៅក្នុងករណីឧទាហរណ៍ទី ១ ខាងលើ ប្រសិនបើតុលាការវិនិច្ឆ័យថា ការទាមទារឲ្យប្រគល់របស់ X ចំពោះ Z មានមូលហេតុ តុលាការត្រូវចេញសាលក្រម ឬសាលដីកាបង្គាប់ឲ្យ Z ប្រគល់ដីនោះ។ ផ្ទុយទៅវិញ ប្រសិនបើតុលាការវិនិច្ឆ័យថា ការទាមទាររបស់ X គ្មានមូលហេតុទេ តុលាការត្រូវចេញសាលក្រម ឬសាលដីកាច្រានចោលការទាមទាររបស់ X ។ ប្រសិនបើភាគីធ្វើឧបាស្រ័យចំពោះសាលក្រម ឬសាលដីកាតុលាការ ភាគីអាចធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់បាន (ចំពោះប្រព័ន្ធតុលាការនឹងមានលើកមកជម្រាបជូនពេលក្រោយ)។

## គ) ការអនុវត្តដោយបង្ខំ

ក្នុងករណីដែលសាលក្រមបង្គាប់ឲ្យសម្រេចសិទ្ធិត្រូវបានបង្កើតឡើងដោយតុលាការហើយ

ប្រសិនបើបុគ្គលដែលត្រូវបង្គាប់ពីការសម្រេចសិទ្ធិ ព្រមអនុវត្តតាមខ្លឹមសារនៃសាលក្រម ឬ សាលដីកា គឺមិនមានបញ្ហាអ្វីទេ ក៏ប៉ុន្តែ យើងក៏អាចគិតឃើញនូវករណីដែលគេមិនអនុវត្តដោយស្ម័គ្រចិត្តដែរ។ ក្នុងករណីដែលគ្មានការអនុវត្តដោយស្ម័គ្រចិត្តបែបនោះ ម្ចាស់សិទ្ធិ (ដើមចោទ) អាចដាកមកខ្ចី អំណាចរដ្ឋ ហើយត្រូវសម្រេចឲ្យបានទៅតាមខ្លឹមសារនៃសាលក្រម ឬ សាលដីកា។ ដើម្បីអនុវត្ត បែបនោះ មាននីតិវិធីមួយហៅថា នីតិវិធីនៃការអនុវត្តដោយបង្ខំដែលត្រូវបានកំណត់នៅក្នុងច្បាប់ ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណី និង វិធានទូទៅស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណី។ ការអនុវត្តដោយបង្ខំ ត្រង់ចំណុចនេះត្រូវបានបញ្ញត្តដោយធ្វើការបែងចែករវាងការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល ដែលមានគោលបំណងឲ្យសងជាប្រាក់ និង ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលគ្មានគោល បំណងឲ្យសងជាប្រាក់ ។

ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឲ្យសងជាប្រាក់ គឺជានីតិវិធី ដែលធ្វើការរឹបអូសយកទ្រព្យសម្បត្តិរបស់កូនបំណុល រួចហើយប្តូរជាប្រាក់ដោយការលក់ឡាយឡុង និង ប្រគល់ប្រាក់ដែលបានពីការលក់នោះទៅម្ចាស់បំណុល ។ ជាឧទាហរណ៍ នៅក្នុងរណីឧទាហរណ៍ទី ២ ខាងលើ បើទោះបីជា P បានប្រគល់វត្ថុដែលជាកម្មវត្ថុនៃការលក់ទិញទៅ Q ហើយក៏ដោយ តែ Q នៅតែមិនទាន់បានបង់ថ្លៃលក់ទិញទៅ P ដែរដូច្នេះ P អាចដាក់ពាក្យបណ្តឹងទៅតុលាការដោយយក Q ជាចុងចម្លើយ ហើយនៅពេលបានទទួលសាលក្រម ឬ សាលដីកាដែលបង្គាប់ឲ្យ Q បង់ ២ លានយ៉េន ហើយ គឺអាចស្នើសុំឲ្យធ្វើការអនុវត្តដោយបង្ខំបាន។ ក្នុងករណីនេះ គឺត្រូវរឹបអូសទ្រព្យ សម្បត្តិរបស់ Q (អចលវត្ថុ ឬ ចលនវត្ថុ) ហើយប្រាក់ ២ លានយ៉េន ពីក្នុងចំណោមប្រាក់ដែលបាន មកពីការលក់ឡាយឡុងនឹងត្រូវបានសងទៅ P។

## ២ ការដោះស្រាយវិវាទ និង ប្រព័ន្ធតុលាការ

ប្រព័ន្ធតុលាការត្រូវបានបង្កើតឡើងដើម្បីជាមធ្យោបាយដោះស្រាយវិវាទរវាងបុគ្គលឯកជន ដោយ មានរចនាសម្ព័ន្ធជារាងពីរ៉ាមីតដែលទីប្រជុំអំណាចយុត្តាធិការស្ថិតនៅលើតុលាការកំពូល (មាត្រា ៧៦ នៃរដ្ឋធម្មនុញ្ញជប៉ុន និង មាត្រា ២ នៃច្បាប់ស្តីពីតុលាការជប៉ុន) ។

### ក) រឿងក្តីរដ្ឋប្បវេណីធម្មតា

ចំពោះរឿងក្តីរដ្ឋប្បវេណីធម្មតា ជាបឋម គឺតុលាការតំបន់ (ជាគោលការណ៍ តុលាការមួយ ត្រូវបង្កើតឡើងនៅក្នុងរាជធានី និង ខេត្តនានា) ដែលមានសមត្ថកិច្ចជាតុលាការនៃការជំនុំជម្រះ លើកទី ១។ តុលាការនៅតាមរាជធានី ឬខេត្តនានា នេះហៅថា តុលាការតំបន់ ដោយឡែកបញ្ហាថា តើត្រូវដាក់ពាក្យបណ្តឹងទៅតុលាការតំបន់មួយណានោះ គឺមិនមែនដើមចោទអាចដាក់ទៅតុលាការ

ណាមួយក៏បានដែរដោយសេរីនោះទេ។ ជាឧទាហរណ៍ ដូចជាមានការកំណត់នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីអំពីតុលាការតំបន់ដែលអាចដាក់ពាក្យបណ្តឹងបាន គឺតុលាការដែលមានសមត្ថកិច្ចលើតំបន់លំនៅឋានរបស់ចុងចម្លើយ ជាដើម។ ភាគីដែលធ្វើឧបាស្រ័យចំពោះសាលក្រមរបស់តុលាការតំបន់អាចធ្វើបណ្តឹងឧទ្ធរណ៍បានក្នុងអំឡុងពេល ២ សប្តាហ៍គិតចាប់ពីពេលបានទទួលការបញ្ជូនសាលក្រម (សាលាឧទ្ធរណ៍ត្រូវបានបង្កើតឡើងនៅសាប៉ូរ៉ូ សេនដៃ តូក្យូ ណាហ្គូយ៉ា អូសាកា តាកាម៉ាត់ស៊ឹ ហ៊ីរ៉ូស៊ីម៉ា និង ហ្វុគុអូកា) ។

ដូចនៅក្នុងតុលាការនៃការជំនុំជម្រះលើកទី ១ ដែរ តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវទទួលស្គាល់អង្គហេតុដោយផ្អែកលើការអះអាងរបស់ភាគី និង ភស្តុតាង ហើយត្រូវអនុវត្តវិធានគតិយុត្តចំពោះអង្គហេតុនោះ ហើយត្រូវចេញសាលដីកា។ ប្រសិនបើវិនិច្ឆ័យថា សាលក្រមរបស់តុលាការនៃការវិនិច្ឆ័យលើកទី ១ ត្រឹមត្រូវហើយ តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវចេញសាលដីកាដែលមានខ្លឹមសារច្រានចោលបណ្តឹងឧទ្ធរណ៍។ ម្យ៉ាងវិញទៀត ប្រសិនបើវិនិច្ឆ័យថា បណ្តឹងឧបាស្រ័យនោះមានមូលហេតុត្រឹមត្រូវ ត្រូវលុបចោល ឬ ផ្លាស់ប្តូរសាលក្រមនៃការជំនុំជម្រះលើកទី១។ ភាគីអាចធ្វើឧបាស្រ័យចំពោះសាលដីការបស់តុលាការនៃបណ្តឹងឧទ្ធរណ៍បាន ដោយត្រូវកម្រិតត្រឹមចំពោះមូលហេតុជាកំណត់មួយ ដោយធ្វើបណ្តឹងសាទុក្ខទៅតុលាការកំពូល។ ជាគោលការណ៍ តុលាការនៃបណ្តឹងសាទុក្ខត្រូវបានចងដោយអង្គហេតុដែលត្រូវបានទទួលស្គាល់ជាស្ថាពរដោយស្របច្បាប់ក្នុងសាលក្រម ឬ សាលដីកាដើម។ ដូច្នេះ ត្រូវវិនិច្ឆ័យចំពោះការអនុវត្តវិធានគតិយុត្ត ដោយផ្អែកលើអង្គហេតុនោះជាមូលដ្ឋាន។ ប្រសិនបើយល់ឃើញថាគ្មានមូលហេតុប្តឹងសាទុក្ខទេ តុលាការកំពូលត្រូវច្រានចោលបណ្តឹងសាទុក្ខនោះ។ ក៏ប៉ុន្តែ ប្រសិនបើយល់ឃើញថា មានមូលហេតុប្តឹងសាទុក្ខ ត្រូវបដិសេធចោលសាលក្រម ឬ សាលដីកាដើមនោះ ហើយជាគោលការណ៍ ត្រូវធ្វើការបញ្ជូនត្រឡប់ទៅតុលាការដើម (ដោយឲ្យធ្វើការជំនុំជម្រះសាជាថ្មី)។ ក៏ប៉ុន្តែ ក្នុងករណីដែលអាចធ្វើការវិនិច្ឆ័យរឿងក្តីជំនួសបាន គឺតុលាការកំពូលអាចចេញសាលដីកាចំពោះរឿងក្តីនោះ ដោយផ្អែកលើអង្គហេតុដែលបានកំណត់ជាស្ថាពរនៅក្នុងសាលក្រម ឬ សាលដីកាដើម (ការវិនិច្ឆ័យដោយខ្លួនឯង) ។

ក៏ប៉ុន្តែ ចំពោះរឿងក្តីដែលកម្មវត្ថុនៃបណ្តឹងមានតម្លៃមិនលើសពី ១៤០ ម៉ឺន យ៉េនទេ សាលាលហុនឹងក្លាយទៅជាតុលាការនៃការជំនុំជម្រះលើកទី ១ (មាត្រា ៣៣ នៃច្បាប់ស្តីពីតុលាការ)។ បណ្តឹងឧទ្ធរណ៍ចំពោះសាលក្រមនៃសាលាលហុ ត្រូវធ្វើឡើងទៅតុលាការតំបន់ ដោយតុលាការតំបន់នឹងក្លាយទៅជាតុលាការនៃបណ្តឹងឧទ្ធរណ៍ ហើយបណ្តឹងសាទុក្ខត្រូវធ្វើឡើងទៅសាលាឧទ្ធរណ៍ ។

ម្យ៉ាងវិញទៀត ចំពោះសាលាលហុ បណ្តឹងដែលមានកម្មវត្ថុជាការទាមទារឲ្យសងប្រាក់ដែលមិនលើសពី ៦០ ម៉ឺនយ៉េន ទេដើមចោទអាចស្នើសុំការជំនុំជម្រះ និង សេចក្តីសម្រេចតាមនីតិវិធីនៃ

បណ្តឹងរឿងក្តីទឹកប្រាក់តិចបាន។ បណ្តឹងរឿងក្តីទឹកប្រាក់តិចត្រូវបានកំណត់ដោយនីតិវិធីដែលមានលក្ខណៈសង្ខេបជាង (មាត្រា ៣៦៨ ដល់មាត្រា ៣៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។

ដូចបានឃើញក្នុងការពន្យល់នេះ នៅក្នុងរឿងក្តីមួយ អាចត្រូវបានទទួលនូវការវិនិច្ឆ័យ ៣ ដង (ហៅថា គោលការណ៍នៃការវិនិច្ឆ័យបីថ្នាក់) ។

ដោយឡែកបណ្តឹងដែលពាក់ព័ន្ធជាមួយនឹងសិទ្ធិលើប្រកាសនីយប័ត្រតក្កកម្មវិញ ជាគោលការណ៍ការជំនុំជម្រះលើកទី ១ គឺនៅតុលាការតំបន់តូក្យូ ឬ តុលាការតំបន់អូសាកា រីឯការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍វិញ គឺត្រូវវិនិច្ឆ័យដោយសាលាឧទ្ធរណ៍ដែលមានសមត្ថកិច្ចលើរឿងក្តីកម្មសិទ្ធិបញ្ញាដែលជាសាខាពិសេសមួយនៃសាលាឧទ្ធរណ៍តូក្យូ (មាត្រា ៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី និង មាត្រា ២ នៃច្បាប់ស្តីពីការបង្កើតសាលាឧទ្ធរណ៍ដែលមានសមត្ថកិច្ចលើរឿងក្តីកម្មសិទ្ធិបញ្ញា) ។

## ខ) រឿងក្តីគ្រួសារ

របបសន្ធានកម្មចំពោះរឿងក្តីគ្រួសារ និង ការវិនិច្ឆ័យរឿងក្តីគ្រួសារត្រូវបានបង្កើតឲ្យមានឡើងនៅក្នុងតុលាការគ្រួសារផ្សេងពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីធម្មតាសម្រាប់រឿងក្តីគ្រួសារដែលពាក់ព័ន្ធជាមួយទំនាក់ទំនងញាតិ ដូចជាប្រពន្ធ ឪពុកម្តាយ និងកូន ឬ សន្តតិកម្ម ជាដើម។ នៅក្នុងករណីមួយចំនួនធំគោលការណ៍នៃការដោះស្រាយវិវាទដោយសន្ធានកម្មត្រូវបានប្រើប្រាស់ ដោយមិនអាចដាក់ពាក្យបណ្តឹងបានទេ ប្រសិនបើមិនបានឆ្លងកាត់នីតិវិធីដោះស្រាយវិវាទដោយសន្ធានកម្មជាមុន (មាត្រា ១៨ នៃច្បាប់ស្តីពីការវិនិច្ឆ័យរឿងក្តីគ្រួសារ )។

ជាឧទាហរណ៍ នៅក្នុងករណីលែងលះគ្នា សហព័ទ្ធដែលចង់លែងលះត្រូវដាក់ពាក្យសុំធ្វើសន្ធានកម្ម ជាមុន។ សន្ធានកម្មត្រូវបានធ្វើឡើងនៅក្នុងកិច្ចប្រជុំគណៈកម្មការសន្ធានកម្ម នៅក្រោយពេលដែលគណៈកម្មការសន្ធានកម្មត្រូវបានបង្កើតឡើងដោយមានសមាសភាពចៅក្រមវិនិច្ឆ័យរឿងក្តីគ្រួសារ និង សមាជិកគណៈកម្មការសន្ធានកម្ម។ នៅក្នុងករណីដែលមានការព្រមព្រៀងចំពោះការលែងលះដោយគូភាគី ការលែងលះត្រូវកើតឡើងនៅពេលដែលបានសរសេរចុះនៅក្នុងកំណត់ហេតុសន្ធានកម្ម។ ក៏ប៉ុន្តែ នៅក្នុងករណីដែលសន្ធានកម្មមិនបានសម្រេចទេ ហើយប្រសិនបើតុលាការគ្រួសារទទួលស្គាល់ថាសមរម្យ គឺតុលាការអាចវិនិច្ឆ័យពីការលែងលះនោះបាន (មាត្រា ២៤ នៃច្បាប់ស្តីពីការវិនិច្ឆ័យរឿងក្តីគ្រួសារ)។ ប្រសិនបើមានការតវ៉ាចំពោះការវិនិច្ឆ័យនោះនៅក្នុងអំឡុងពេល ២ សប្តាហ៍ ការវិនិច្ឆ័យនោះត្រូវបាត់បង់អានុភាព (កថាខណ្ឌទី ២ មាត្រា ២៥ នៃច្បាប់ដដែល) ។ នៅពេលដែលការលែងលះដោយសន្ធានកម្មមិនកើតឡើង ហើយការលែងលះដោយការវិនិច្ឆ័យមិនកើតមានឡើង ឬ នៅពេលដែលការវិនិច្ឆ័យបានបាត់បង់អានុភាព ដោយសារមានបណ្តឹង

ឧបាស្រ័យ ប្រសិនបើប្តី ឬ ប្រពន្ធណាម្ខាងដាក់ពាក្យបណ្តឹង នីតិវិធីលែងលះត្រូវចាប់ផ្តើមដំណើរការតាមការសម្រេចរបស់តុលាការ (កថាខណ្ឌទី ២ មាត្រា ២៦ នៃច្បាប់ដដែល) ។

## គ) ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

យើងមិនអាចនិយាយបានទេថា គ្រប់ជម្លោះទាំងអស់សុទ្ធតែត្រូវបានដោះស្រាយដោយការសម្រេចសេចក្តីរបស់តុលាការទេ។ ការដោះស្រាយវិវាទដោយតុលាការ ជាទូទៅ គឺត្រូវចំណាយសោហ៊ុយ និង ពេលពេលវេលាច្រើន ហើយវាមិនសមជាមួយនឹងការដោះស្រាយវិវាទដែលមានចំនួនទឹកប្រាក់តិចទេ។ នៅក្នុងបណ្តាប្រទេសមួយចំនួនធំ ក្រៅពីនីតិវិធីសង្ខេប និងឆាប់រហ័សនៅក្នុងរបបវិនិច្ឆ័យរឿងក្តីទឹកប្រាក់តិច របបដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការត្រូវបានបង្កើតឲ្យមានឡើង។ វាត្រូវបានគេហៅថា ADR (Alternative Dispute Resolution) ដែលជំនួសឲ្យការសម្រេចសេចក្តីរបស់តុលាការ ។

នៅក្នុងប្រទេសជប៉ុន មានរបបដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅក្នុងវិស័យផ្សេងៗជាច្រើនក្រៅពីបណ្តឹងទឹកប្រាក់តិច ដូចជា វិវាទគ្រោះថ្នាក់ចរាចរណ៍ វិវាទអ្នកប្រើប្រាស់ផលិតផល និង វិវាទការទទួលខុសត្រូវចំពោះផលិតផល ជាដើម ។ របបដោះស្រាយវិវាទទាំងអស់នោះគឺជាការប្រគល់វិវាទទៅឲ្យតតិយជនដែលស្មោះត្រង់ ដើម្បីធ្វើការថ្លឹងថ្លែងដោះស្រាយវិវាទនោះ។ យើងអាចគិតបានថា ការដោះស្រាយវិវាទត្រូវបានថ្លឹងថ្លែងធ្វើឡើងទៅតាមស្ថានភាពនៃវិវាទ ដោយឆ្លុះបញ្ចាំងពីចំណេះដឹង និង បទពិសោធន៍របស់អ្នកជំនាញដែលជាតតិយជននោះ។ នេះគឺខុសពីការសម្រេចសេចក្តីរបស់តុលាការ ហើយនៅក្នុងករណីមួយចំនួនធំ ការដោះស្រាយវិវាទត្រូវបានធ្វើឡើងដោយស្របទៅតាមការព្រមព្រៀងរបស់គូភាគីជាមូលដ្ឋាន។ពោលគឺប្រព័ន្ធបែបនេះមានគោលបំណងផ្តល់នូវការថ្លឹងថ្លែងពីលទ្ធភាពដែលការដោះស្រាយវិវាទអាចធ្វើទៅបានដោយការសម្រេចសេចក្តីរបស់តុលាការ ជាមួយនឹងការដោះស្រាយវិវាទដោយផ្អែកទៅតាមការព្រមព្រៀងរបស់គូភាគី។ នៅក្នុងឆ្នាំ ២០០៤ ច្បាប់ពិសេសមួយត្រូវបានអនុម័ត ដើម្បីជាការលើកកម្ពស់ដល់នីតិវិធីដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការបែបនោះ (ច្បាប់ស្តីពីការលើកកម្ពស់ការប្រើប្រាស់នីតិវិធីដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (ច្បាប់លេខ ១៥១ ឆ្នាំ ២០០៤)) ហើយបន្ទាប់ពីនោះមក ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការបែបនោះកាន់តែដើរតួនាទីសំខាន់ឡើងៗ ។

### ✎ ការសម្រេចសិទ្ធិតាមរយៈបណ្តឹង--ការពិចារណាតាមរយៈករណីសិក្សា

A អាចទាមទារទៅ B ឲ្យប្រគល់រូបគំនូរមកខ្លួន ដោយអាចដាក់ពាក្យបណ្តឹងបាន។ នៅក្នុងបណ្តឹងដោយយកការទាមទារឲ្យប្រគល់រូបគំនូរជាមូលដ្ឋាន ចាំបាច់ត្រូវធ្វើការអះអាងអំពីការកើតឡើងនៃកិច្ច

សន្យាលក់ទិញ និង ត្រូវធ្វើការបញ្ជាក់អំពីអង្គហេតុនោះ។ ប្រសិនបើអង្គហេតុស្ដីពីការលក់ទិញត្រូវបានទទួលស្គាល់ គឺការទាមទាររបស់ A ពិតជានឹងត្រូវបានទទួលស្គាល់។ នៅក្នុងករណីនោះ ចំពោះសាលក្រម គឺសាលក្រមនឹងធ្វើការបង្គាប់ B ឲ្យប្រគល់រូបគំនូរទៅ A ។ ដោយអនុលោមទៅតាមសាលក្រមនោះ ប្រសិនបើ B ធ្វើការប្រគល់រូបគំនូរ មិនមានបញ្ហាអ្វីទេ ក៏ប៉ុន្តែប្រសិនបើ B ប្ដឹងឧទ្ធរណ៍ចំពោះសាលក្រមវិញ នីតិវិធីនៃបណ្ដឹងនឹងមានបន្តទៀត។ នៅទីបំផុត នៅពេលដែលសាលក្រមទទួលស្គាល់ការទាមទាររបស់ A ចូលជាស្ថាពរ A អាចធ្វើនីតិវិធីអនុវត្តដោយបង្ខំដោយផ្អែកលើសាលក្រមនោះបាន។ បើនិយាយឲ្យជាក់លាក់ គឺអាជ្ញាសាលានឹងធ្វើការរឹបអូសយករូបគំនូរពី B ហើយប្រគល់វាទៅឲ្យ A (មាត្រា ១៦៩ នៃច្បាប់ស្ដីពីការអនុវត្តផ្នែករដ្ឋប្បវេណី) ។

ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ
នៃប្រទេសជប៉ុន (JICA)

9 789996 326035

ហាមលក់